# កិច្ចការនៃពួកសាវ័ក

« ភាគទី១ »

ដោយ អ្នកស្រី **អែឡិន ជី វ៉ៃត៍**

បកប្រែនិងបោះពុម្ព
ចែកចាយដោយ

បេសកកម្មអាត់វេនទីស្ទកម្ពុជា
២០២០

# កិច្ចការនៃពួកសាវ័ក

នៅក្នុងការប្រកាសផ្សាយដំណឹងល្អ
របស់ព្រះយេស៊ូវគ្រិស្ត

ដោយ អ្នកស្រី **អែល្លិន ជី វ៉ៃត៍**

ជាអ្នកនិពន្ធសៀវភៅ «ការចាប់ផ្តើមនៃទីបញ្ចប់» «រឿងនៃ
ពួកហោរានិងស្តេច» «ព្រះនៃសេចក្តីស្រឡាញ់»
«មហាវិវាទ»

# បុព្វកថា

កណ្ឌគម្ពីរប្រាំនៃគម្ពីរសញ្ញាថ្មីត្រូវបានគេស្គាល់ថាជាកិច្ចការនៃពួកសាវ័ក ប៉ុន្តែ គេមិនអាចរកចំណងជើងនេះឃើញនៅក្នុងកណ្ឌគម្ពីរនេះដោយផ្ទាល់ទេ។ សំណេរមិនទាន់បោះពុម្ពដំបូង ដែលហៅថា កូដេក្សស៊ីណៃទីគូស (Codex Sinaiticus)បានដាក់ចំណងជើងជាពាក្យដ៏សាមញ្ញថា កិច្ចការដែលមិនមានពណ៌នាពីពាក្យថា នៃពួកសាវ័កទេ។ មានហេតុផលចំពោះរឿងនេះ។ គម្ពីរកិច្ចការត្រូវបានគេកំណត់ថាមិនគ្រាន់តែជាប្រវត្តិសាស្រ្តសង្ខេបនៃកិច្ចការដែលពួកសិស្សទាំងដប់ពីរនាក់បានប្រគល់ឲ្យមិនគ្រាន់តែជាព្រឹត្តិការណ៍សំខាន់ៗ នៅក្នុងការបំពេញកិច្ចការអស់មួយជីវិតរបស់តួអង្គសំខាន់ៗរួមមានលោកពេត្រុស យ៉ាកុប យ៉ូហាន និងលោកប៉ុលប៉ុណ្ណោះទេ។

កណ្ឌគម្ពីរកិច្ចការត្រូវបានសរសេរសម្រាប់ពួកជំនុំទាំងមូលទាំងសាសន៍យូដានិងសាសន៍ក្រិក ដោយលោកលូកា «ជាគ្រូពេទ្យសួនភ្ញា» ជាសាសន៍ដទៃដែលបានកែប្រែចិត្តទទួលជឿព្រះយេស៊ូវ។ ខណៈដែលកណ្ឌគម្ពីរនេះត្រូវការពេលវេលារហូតដល់ទៅជាងបីទសវត្សរ៍នោះ ធ្វើឲ្យកណ្ឌគម្ពីរនេះមានពេញទៅដោយមេរៀនសំខាន់ៗជាច្រើនសម្រាប់ពួកជំនុំគ្រប់សម័យកាល។ នៅក្នុងកណ្ឌគម្ពីរកិច្ចការ ព្រះបានបញ្ជាក់យ៉ាងច្បាស់ថាគ្រិស្តបរិស័ទនាពេលបច្ចុប្បន្ននេះនឹងជួបប្រទះនឹងព្រះវត្តមាននៃព្រះវិញ្ញាណបរិសុទ្ធ ដែលបានយាងមកដោយព្រះចេស្តានៅថ្ងៃប៉ង់តាកូស ហើយបានពាំនាំដំណឹងល្អដូចជាអណ្តាតភ្លើងយ៉ាងដូច្នោះដែរ។ កិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ តាមរយៈលោកពេត្រុស លោកប៉ុល លោកយ៉ូហាន លោកយ៉ាកុប និងសិស្សដទៃផ្សេងទៀតក៏អាចកើតឡើងជាថ្មីដោយសិស្សនៅសម័យទំនើបនេះដែរ។

ការប្រញាប់រួសរាន់បញ្ចប់កណ្ឌគម្ពីរកិច្ចការនេះ មិនមែនកើតឡើងដោយចៃដន្យទេកណ្ឌគម្ពីរនេះបានឲ្យយោបល់ដោយបានគិតទុកជាមុនថារឿងដ៏គួរឲ្យរំភើបនោះបានចប់សព្វគ្រប់ហើយ និងថាកិច្ចការរបស់ព្រះតាមរយៈព្រះវិញ្ញាណបរិសុទ្ធនៅតែមានដំណើរការរបស់ខ្លួនបន្ត នៅពាសពេញ

ទាំងការបែកបាក់នៃគ្រិស្តបរិស័ទជំនាន់ដ៏ជោគជ័យនីមួយៗបន្ថែមចំពូក មួយទៀតដែលពោរពេញទៅដោយសម្រស់និងអំណាចដល់ជំពូក ដែលមានពីមុន។ កិច្ចការដែលបានកត់ត្រានៅក្នុងកណ្ឌគម្ពីរដ៏ពិសេសនេះ នៅក្នុងទស្សនីយភាពដ៏ពិតប្រាកដបំផុតនៃព្រះវិញ្ញាណសម្រាប់សម័យពួកសាវ័ក គឺជាព្រះវិញ្ញាណបរិសុទ្ធដែលបានលេចឡើង ជាអ្នកណែនាំនិងជាអ្នកជំនួយរបស់ពួកអ្នកដឹកនាំជាគ្រិស្តបរិស័ទ។ នៅថ្ងៃប៉ង់តាកូស ពួកសាវ័កបានអធិប្បាយដំណឹងល្អដោយអំណាច។ បុរសប្រាំពីរនាក់ដែលគេបានជ្រើសតាំងឲ្យធ្វើជាអ្នកជំនួយការ «ពេញជាព្រះវិញ្ញាណបរិសុទ្ធ និងប្រាជ្ញា» (កិច្ចការ ៦:៣)។ គឺព្រះវិញ្ញាណបរិសុទ្ធដែលបានដឹកនាំក្នុងការបំពេញសិទ្ធិ (អ្នកខ្លះហៅថាពិធីបំបួស) ជូនលោកសុល (កិច្ចការ ៩:១៧) ក្នុងការទទួលយកពួកសាសន៍ដទៃចូលក្នុងពួកជំនុំ (កិច្ចការ ១០:៤៤-៤៧) ក្នុងការបំបែកលោកបាណាបាសនិងលោកប៉ុលសម្រាប់កិច្ចការជាបេសកជនផ្សាយដំណឹងល្អ (កិច្ចការ ១៣:២-៤) នៅក្នុងក្រុមប្រឹក្សា យេរូសាឡិម (កិច្ចការ ១៥:២៨) និងនៅក្នុងដំណើរបំពេញបេសកកម្មរបស់លោកប៉ុលនៅតាមកន្លែងផ្សេងៗ (កិច្ចការ ១៦:៦, ៧)។ ហើយនៅគ្រាមួយទៀត កាលពួក ជំនុំបានរងទុក្ខជាបន្ត ដោយសារដៃរបស់ពួកអ្នកបៀតបៀនសាសន៍រ៉ូម និង សាសន៍យូដា គឺព្រះវិញ្ញាណបរិសុទ្ធនេះឯងដែលបានទ្រទ្រង់ពួកអ្នកជឿនិងរក្សាពួកគេឲ្យរួចផុតពីកំហុសឆ្គង ។

សៀវភៅកិច្ចការនៃពួកសាវ័កគឺជាសៀវភៅចុងក្រោយបង្អស់ ក្នុងចំណោមសៀវភៅទាំងឡាយដែលអ្នកស្រីអែល្លីន ជី វ៉ៃត៍ បានសរសេរ សៀវភៅនេះបានបោះពុម្ពផ្សាយនៅពេលប៉ុន្មានឆ្នាំមុនមរណភាពរបស់អ្នកស្រី។ សៀវភៅនេះមិនមែនជាកម្រងសៀវភៅដ៏ភ្លឺថែងចាំងបំផុត ដែលប្រសូតចេញពីស្លាបប៉ាកកាដ៏ល្បីល្បាញរបស់អ្នកស្រីនោះទេ។ អ្នកអានអាចរកឃើញពន្លឺនៅក្នុងសៀវភៅនេះសម្រាប់ទីបន្ទាល់នៃគ្រិស្តបរិស័ទ។ សារនៃសៀវភៅនេះមានលក្ខណៈទាន់សម័យ ហើយទំនាក់ទំនងនៃសៀវភៅនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការខំប្រឹងប្រែងរបស់អ្នកនិពន្ធ ដើម្បីបង្ហាញថា នៅសតវត្សរ៍ទីម្ភៃនេះព្រះក៏បានប្រទានព្រះវិញ្ញាណបរិសុទ្ធចុះមកយ៉ាងហូរហៀរ ដូចនៅ

សម័យប៉ង់តាកូសដូច្នោះដែរ។ កិច្ចការនៃដំណឹងល្អនឹងមិនត្រូវបញ្ចប់ទៅ ដោយការបង្ហាញព្រះវិញ្ញាណបរិសុទ្ធតិចជាងពេលចាប់ផ្តើមនោះឡើយ។

ការដែលលោកអ្នកអាននឹងចូលរួមនៅក្នុងសកម្មភាពពីអតីតកាល តាមទស្សនីយភាពនៃសិរីល្អរបស់ពួកជំនុំដំបូងនេះឡើងវិញ ហើយនៅពេល ជាមួយគ្នានេះ ពួកគេត្រូវបានការពារឲ្យរួចផុតពីការក្លែងបន្លំដ៏ប៉ិនប្រសប់ របស់សត្រូវនៃមនុស្សលោក នោះហើយគឺជាសេចក្តីអធិដ្ឋាននិងបំណាង ប្រាថ្នាដ៏ស្មោះអស់ពីចិត្តរបស់ពួកគេ។

# មាតិការឿង


លេខរៀង ចំណងជើង លេខទំព័រ

១. ព្រះរាជគោលបំណងរបស់ព្រះសម្រាប់ពួកជំនុំរបស់ព្រះអង្គ.........១

២. ការបង្រៀនដល់ពួកសិស្សទាំងដប់ពីរនាក់ ....................................៣

៣. មហាបញ្ហា ........................................................................២០

៤. ថ្ងៃប៉ង់តាកូស..........................................................................៣២

៥. អំណោយទាននៃព្រះវិញ្ញាណ ...................................................៤៦

៦. នៅត្រង់មាត់ទ្វារព្រះវិហារ........................................................៥៨

៧. ការព្រមានប្រឆាំងទាស់នឹងភាពកំពុត........................................៧៥

៨. នៅចំពោះក្រុមប្រឹក្សាសាន់ហ៊ីឌ្រីន ...........................................៨៤

៩. អ្នកជំនួយការ(បុរស)ប្រាំពីរនាក់ ..............................................៩៦

១០. ទុក្ករបុគ្គល (អ្នកសុខចិត្តស្លាប់ដោយសារជំនឿ) គ្រិស្តបរិស័ទដំបូងបង្អស់ .................................................................................១០៨

១១. ដំណឹងល្អនៅស្រុកសាម៉ារី ...................................................១១៥

១២. ពីអ្នកបៀតបៀនមកជាសិស្ស ................................................១២៥

១៣. ថ្ងៃនៃការរៀបចំ ..................................................................១៤០

១៤. អ្នកស្វែងរកសេចក្ដីពិត .......................................................១៥០

១៥. ការរំដោះចេញពីគុក ...........................................................១៦៥

១៦. សារនៃដំណឹងល្អនៅទីក្រុងអាន់ទីយ៉ូក...................................១៨០

១៧. ការប្រកាសដំណឹងល្អ .........................................................១៩៤

១៨. ការអធិប្បាយនៅក្នុងចំណោមសាសន៍ដទៃ..............................២០៨

១៩. សាសន៍យូដានិងសាសន៍ដទៃ..............................................២២២

២០. ការលើកតម្កើងឈើឆ្កាង.....................................................២៣៩

២១. នៅភូមិភាគឯនាយ...........................................................២៥១

២២. ទីក្រុងថែស្សាឡូនីច ..........................................................២៦២

២៣.	ទីក្រុងបេរា និងទីក្រុងអាថែន ..................................................២៧៥
២៤.	ទីក្រុងកូរិនថូស ..................................................................២៩០

ជំពូកទី
១

# ព្រះរាជគោលបំណងរបស់ព្រះសម្រាប់ពួកជំនុំរបស់ព្រះអង្គ

<u>សៅរ៍-២០ មិថុនា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ១១

**ខព្រះគម្ពីរប្រចាំសប្តាហ៍:** *ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា ឯងរាល់គ្នាជាស្មរបន្ទាល់របស់អញ ហើយជាអ្នកបំរើដែលអញបានរើសតាំង ដើម្បីឲ្យបានស្គាល់ ហើយជឿដល់អញ ព្រមទាំងយល់ថា គឺអញនេះហើយ ឥតមានព្រះណាកើតមកមុនអញទេ ហើយក្រោយអញក៏ឥតមានដែរ គឺអញ អញនេះហើយជាយេហូវ៉ា ក្រៅពីអញ គ្មានអ្នកសង្គ្រោះណាទៀតឡើយ ។ អេសាយ ៤៣:១០-១១*

ពួកជំនុំគឺជាភ្នាក់ងារដែលព្រះបានតែងតាំង សម្រាប់សេចក្តីសង្គ្រោះរបស់មនុស្សលោក ព្រះបានរៀបចំពួកជំនុំនេះឡើងដើម្បីបម្រើ ហើយបេសកកម្មរបស់ពួកគេគឺពាំនាំដំណឹងល្អទៅកាន់ពិភពលោកទាំងមូល។ ព្រះមានផែនការដើម្បីឲ្យពិភពលោកនេះមើលឃើញភាពគ្រប់លក្ខណ៍និងភាពចាំបាច់របស់ទ្រង់ តាមរយៈពួកជំនុំរបស់ទ្រង់ ដែលមានតាំងពីដើមដំបូងមកម្ល៉េះ។ សមាជិកនៃពួកជំនុំ ជាអ្នកដែលទ្រង់បានត្រាស់ហៅចេញពីភាពងងឹតមកក្នុងពន្លឺដ៏អស្ចារ្យ ត្រូវតែបញ្ជាំងឲ្យមនុស្សលោកមើលឃើញសិរីល្អរបស់ទ្រង់។ ពួកជំនុំគឺជាឃ្លាំងផ្ទុកដោយព្រះគុណរបស់ព្រះគ្រិស្តពេញហូរហៀរ ហើយតាមរយៈពួកជំនុំនេះ «ពួកគ្រប់គ្រង និងពួកមានអំណាចនៅឋានដ៏ខ្ពស់បានស្គាល់ពីប្រាជ្ញានៃព្រះដ៏មានជាច្រើនយ៉ាងណាស់» (អេភេសូរ ៣:១០)។

មានសេចក្តីសន្យាអស្ចារ្យជាច្រើនដែលបានកត់ត្រានៅក្នុងព្រះគម្ពីរទាក់ទងនឹងពួកជំនុំនេះ។ «នោះអញនឹងនាំគេមកឯភ្នំបរិសុទ្ធរបស់អញ ហើយឲ្យគេបានអរសប្បាយ នៅក្នុងដំណាក់របស់អញដែលសម្រាប់ជា

ទីអធិដ្ឋាន អញនឹងទទួលអស់ទាំងតង្វាយដុត និងយញ្ញបូជារបស់គេ នៅលើអាសនា ដ្បិតដំណាក់អញនឹងបានហៅជាទីអធិដ្ឋានសម្រាប់គ្រប់ទាំងសាសន៍» (អេសាយ ៥៦:៧)។ «អញនឹងធ្វើឲ្យគេ ព្រមទាំងទីកន្លែងនៅជុំវិញភ្នំតូចរបស់អញ ជាទីឲ្យពរ អញនឹងបង្អុរឲ្យភ្លៀងធ្លាក់មកតាមរដូវកាល នោះនឹងមានព្រះពរធ្លាក់មកមួយមេៗ«អញនឹងធ្វើឲ្យមានដំណាំមួយកើតឡើងទុកជាល្បីដល់វា នោះវារាល់គ្នានឹងមិនត្រូវសាបសូន្យទៅដោយអំណត់អត់នៅក្នុងស្រុកឡើយ ក៏មិនត្រូវរងទ្រាំសេចក្តីខ្មាសនៃអស់ទាំងសាសន៍ទៀតដែរ នោះវារាល់គ្នានឹងដឹងថា អញដ៏ជាយេហូវ៉ា អញជាព្រះនៃវា ក៏នៅជាមួយផង ហើយថាវា ដែលជាពួកវង្សអ៊ីស្រាអែល វាជារាស្ត្ររបស់អញ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា ឯឯងរាល់គ្នាដែលជាហ្វូងចៀមរបស់អញ គឺជាហ្វូងចៀមនៅទីឃ្វាលរបស់អញ ឯងរាល់គ្នាជាមនុស្ស ហើយអញជាព្រះនៃឯង នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា» (អេសេគាល ៣៤:២៦, ២៩-៣១) ។

«ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា ឯងរាល់គ្នាជាស្មរបន្ទាល់របស់អញ ហើយជាអ្នកបម្រើដែលអញបានរើសតាំង ដើម្បីឲ្យបានស្គាល់ ហើយជឿដល់អញ ព្រមទាំងយល់ថា គឺអញនេះហើយ ឥតមានព្រះណាកើតមកមុនអញទេ ហើយក្រោយអញក៏ឥតមានដែរ គឺអញ អញនេះហើយជាយេហូវ៉ា ក្រៅពីអញ គ្មានអ្នកសង្គ្រោះណាទៀតឡើយ អញបានទាយប្រាប់ អញបានជួយសង្គ្រោះ អញបានសម្តែងឲ្យឃើញហើយ ឥតមានព្រះដទៃណានៅកណ្តាលឯងរាល់គ្នាឡើយ ហេតុដូច្នោះឯងរាល់គ្នាជាស្មរបន្ទាល់របស់អញ ហើយគឺអញនេះដែលជាព្រះ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា» ។ «អញនេះគឺជាយេហូវ៉ា អញបានហៅឯងមកដោយសេចក្តីសុចរិត អញនឹងកាន់ដៃឯង ហើយថែរក្សាឯង អញនឹងតាំងឯងឡើង ទុកជាសេចក្តីសញ្ញាដល់បណ្តាជន ហើយជាពន្លឺភ្លឺដល់អស់ទាំងសាសន៍ ដើម្បីនឹងធ្វើឲ្យភ្នែកមនុស្សខ្វាក់បានភ្លឺឡើង និងនាំពួកត្រូវចាប់ចងចេញពីគុកងងឹត ហើយឲ្យពួកអ្នកដែលអង្គុយ

នៅក្នុងទីងងឹត បានចេញរួចពីទីឃុំឃាំង» (អេសាយ ៤៣:១០-១២, ៤២:៦, ៧)។

«ដល់វេលាដែលគាប់ចិត្តអញ នោះអញបានឆ្លើយដល់ឯង ហើយនៅថ្ងៃសម្រាប់សង្គ្រោះ នោះអញបានជួយឯង អញនឹងទំនុកបម្រុងឯង ហើយតាំងឯងឡើងទុកជាសេចក្តីសញ្ញាដល់បណ្តាជន ប្រយោជន៍នឹងរៀបចំផែនដីឡើង ឲ្យគេបានគ្រងទីដែលចោលស្ងាត់ ទុកជាមរតក ព្រមទាំងប្រាប់ដល់ពួកអ្នកដែលជាប់ចំណងថា ចូរចេញទៅ ហើយដល់ពួកអ្នកដែលនៅក្នុងសេចក្តីងងឹតថា ចូរសម្តែងខ្លួនចេញមកចុះ គេនឹងមានអាហារស៊ីតាមផ្លូវ ហើយនៅលើកំពូលត្រងិលទាំងប៉ុន្មាន នឹងបានជាទីរកស៊ីដល់គេ គេមិនដែលស្រេកឃ្លានទៀត ឯចំហាយក្តៅឬព្រះអាទិត្យ នឹងមិនធ្វើទុក្ខគេ ដ្បិតព្រះដែលផ្តល់សេចក្តីមេត្តាដល់គេ ទ្រង់នឹងនាំគេទៅ អើទ្រង់នឹងដឹកដៃគេនាំទៅតាមទីមានក្បាលទឹក អញនឹងធ្វើអស់ទាំងភ្នំរបស់អញឲ្យជាផ្លូវ ឯអស់ទាំងថ្នល់របស់អញ នឹងបានលើកឡើង ...» ។

**<u>អាទិត្យ-២១ មិថុនា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ១២**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ទ្រង់ក៏មានព្រះបន្ទូលថា តើយើងនឹងធៀបនគរព្រះជាអ្វី ឬត្រូវយកពាក្យប្រៀបអ្វីមកប្រដូចនឹងនគរនោះ គឺដូចជាគ្រាប់ពូជ១ ដែលកាលណាគេព្រោះនៅដី ជាពូជយ៉ាងល្អិតជាងគ្រាប់ទាំងអស់នៅផែនដី។ ម៉ាកុស៤:៣០-៣១*

«ឱផ្ទៃមេឃអើយ ចូរច្រៀងឡើង ឱផែនដីអើយ ចូរឲ្យអរសប្បាយចុះ ឱភ្នំទាំងឡាយអើយ ចូរធ្លាយចេញជាបទចម្រៀង ពីព្រោះព្រះយេហូវ៉ាទ្រង់បានកម្សាន្តចិត្តរាស្ត្រទ្រង់ហើយ ទ្រង់នឹងមានព្រះហឫទ័យអាណិតអាសូរដល់ពួករបស់ទ្រង់ដែលត្រូវរងទុក្ខវេទនាផង ។ តែក្រុងស៊ីយ៉ូនបានថា ព្រះយេហូវ៉ាទ្រង់បានបោះបង់ចោលខ្ញុំទេ គឺព្រះអម្ចាស់ទ្រង់បានភ្លេចខ្ញុំហើយ ចុះតើស្ត្រីនឹងភ្លេចកូនដែលកំពុងបៅដោះ ឥតមានអាណិតដល់កូនដែលចេញពីផ្ទៃខ្លួនមកបានដែរឬ អើ គេនឹងភ្លេចបាន ប៉ុន្តែ អញមិនដែលភ្លេចឯង

ឡើយ មើល អញបានចារឹកឯងទុកនៅផ្ទៃបាតដៃរបស់អញហើយ អស់ទាំងកំផែងឯងនៅចំពោះភ្នែកអញជានិច្ច» (អេសាយ ៤៩:៨-១៦) ។

ពួកជំនុំគឺជាបន្ទាយរបស់ព្រះ ជាទីក្រុងពំនាក់របស់ទ្រង់ ដែលទ្រង់លាក់ពិភពលោកដែលបះបោរនេះ ។ អំពើក្បត់ណាមួយទៅលើពួកជំនុំ គឺជាអំពើក្បត់ជាមួយនឹងព្រះអង្គ ដែលបានលោះមនុស្សលោកដោយព្រះលោហិតនៃព្រះរាជបុត្រាស្ងួនភ្ញារតែមួយរបស់ទ្រង់ ។ មនុស្សដែលមានចិត្តស្មោះត្រង់បានបង្កើតជាពួកជំនុំនៅលើផែនដីនេះ តាំងពីដើមដំបូងមក ។ ព្រះជាម្ចាស់មានអ្នកឃ្លាំមើលរបស់ទ្រង់ ដែលបានធ្វើទីបន្ទាល់ដ៏ស្មោះត្រង់ដល់មនុស្សដែលរស់នៅលើផែនដីនេះ គ្រប់ជំនាន់ ។ អ្នកឃ្លាំមើលនេះបញ្ចេញសារនៃការព្រមាន ហើយនៅពេលដែលព្រះបានត្រាស់ហៅឲ្យពួកគេពាក់គ្រឿងសឹករបស់គេ អ្នកដទៃទៀតក៏បានចាប់ផ្ដើមបំពេញកិច្ចការ ។ ព្រះបាននាំទីបន្ទាល់ទាំងនេះ ជាសេចក្ដីសញ្ញាជាមួយនឹងព្រះអង្គផ្ទាល់ ដោយបង្រួបបង្រួមពួកជំនុំនៅលើផែនដី ជាមួយនឹងពួកជំនុំនៅឋានសួគ៌ ។ ព្រះអង្គបានចាត់បញ្ជូនពួកទេវតាឲ្យមកបម្រើពួកជំនុំរបស់ព្រះអង្គ ហើយទ្វារនៃឋាននរកមិនអាចយកជ័យជម្នះលើរាស្ត្ររបស់ទ្រង់បានឡើយ ។

ព្រះបានទ្រទ្រង់ពួកជំនុំរបស់ទ្រង់ ឆ្លងកាត់ការបៀតបៀន ទំនាស់និងភាពងងឹត អស់ជាច្រើនសតវត្សរ៍ ។ មិនមានពពកខ្មៅណាមួយមកបិទបាំងពួកជំនុំ ដែលព្រះអង្គបានរៀបចំការពារឡើយ មិនមានកម្លាំងប្រឆាំងណាមួយដែលបានកើតឡើង បានរំខានដល់កិច្ចការរបស់ព្រះអង្គ ដែលទ្រង់មិនបានជ្រាបជាមុននោះឡើយ ។ កិច្ចការទាំងអស់បានកើតឡើងតាមការទស្សទាយរបស់ទ្រង់ទាំងអស់។ ព្រះអង្គមិនបានបោះបង់ចោលពួកជំនុំរបស់ទ្រង់ទេ តែទ្រង់បានបង្ហាញនៅក្នុងសេចក្ដីប្រកាសនៃបទទំនាយពីអ្វីដែលនឹងកើតឡើង ហើយអ្វីៗដែលព្រះអង្គបានបណ្ដាលពួកហោរាឲ្យប្រកាសប្រាប់ឲ្យដឹងជាមុននោះបានកើតឡើងយ៉ាងពិតប្រាកដ  ព្រះរាជគោលបំណងរបស់ទ្រង់ទាំងអស់ត្រូវបានសម្រេច ។ ក្រឹត្យវិន័យរបស់ទ្រង់ត្រូវបានភ្ជាប់

ទំនាក់ទំនងជាមួយបល្ល័ង្ករបស់ទ្រង់ ហើយគ្មានអំណាចអាក្រក់ណាមួយអាចបំផ្លាញក្រឹត្យវិន័យនេះបានឡើយ ។ ព្រះជាម្ចាស់បានលើកទឹកចិត្តនិងការពារសេចក្ដីពិត ហើយសេចក្ដីពិតនេះនឹងមានជ័យជម្នះលើការប្រឆាំងទាំងឡាយ ។

នៅយុគសម័យខ្មៅងងឹតខាងព្រលឹងវិញ្ញាណ ពួកជំនុំរបស់ព្រះគឺជាទីក្រុងដែលបានតាំងនៅលើភ្នំ ។ ពីសម័យមួយទៅសម័យមួយ ជំនាន់មនុស្សដែលមានជោគជ័យ គោលលទ្ធិដ៏បរិសុទ្ធនៃឋានសួគ៌ ត្រូវបានបើកបង្ហាញនៅក្នុងព្រំដែនរបស់ខ្លួន ។ ភាពទន់ខ្សោយនិងភាពខ្វះខាតដែលបានកើតឡើង ព្រះបានប្រទានព្រះវិញ្ញាណជាពិសេសដល់ពួកជំនុំឲ្យដឹងពីការគោរពដ៏ខ្ពង់ខ្ពស់ដល់ទ្រង់ ។ ពួកជំនុំគឺជាគ្រូបង្រៀននៃព្រះគុណរបស់ទ្រង់ជាកន្លែងដែលព្រះអង្គសព្វព្រះហឫទ័យនឹងបង្ហាញព្រះចេស្ដានៃការបំផ្លាស់បំប្រែចិត្តរបស់មនុស្ស ។

ព្រះគ្រិស្ដមានបន្ទូលសួរថា «តើយើងនឹងធៀបនគរព្រះជាអ្វី ឬត្រូវយកពាក្យប្រៀបអ្វីមកប្រដូចនឹងនគរនោះ» (ម៉ាកុស ៤:៣០)។ ព្រះអង្គមិនអាចប្រៀបប្រដូចនគរនៅលើពិភពលោកនេះឲ្យស្មើទៅនឹងនគររបស់ទ្រង់បានឡើយ។ ព្រះអង្គមិនអាចរកអ្វីមកប្រៀបធៀបទៅនឹងនគរនោះ នៅក្នុងសង្គមនេះបានទេ ។ នគរនៅលើផែនដីគ្រប់គ្រងដោយអំណាចខាងរាងកាយ ប៉ុន្តែ នគររបស់ព្រះគ្រិស្ដ គ្រឿងសាស្ត្រាវុធរបស់មនុស្ស រាល់ឧបករណ៍នៃការបង្ខិតបង្ខំ ត្រូវបានលុបបំបាត់ ។ នគរនេះត្រូវបានលើកស្ទួយ និងលើកតម្កើងមនុស្សជាតិ ។ ពួកជំនុំរបស់ព្រះ គឺជាទីលាននៃជីវិតបរិសុទ្ធពោរពេញដោយអំណោយទានផ្សេងៗ និងដែលព្រះបានប្រទាន ព្រះវិញ្ញាណបរិសុទ្ធ។ សមាជិកនៃពួកជំនុំត្រូវតែរកឃើញសុភមង្គលរបស់ពួកគេនៅក្នុងពួកអ្នកដែលពួកគេជួយនិងចែកចាយព្រះពរ ។

កិច្ចការដែលព្រះជាម្ចាស់បានរៀបចំឲ្យបានសម្រេច តាមរយៈពួកជំនុំរបស់ទ្រង់ គឺជាកិច្ចការដ៏អស្ចារ្យ ដើម្បីឲ្យព្រះនាមរបស់ទ្រង់ត្រូវបាន

សរសើរតម្កើង។ ព្រះបានប្រទានរូបភាពនៃកិច្ចការនេះនៅក្នុងការបើកសម្តែងពីទន្លេនៃការព្យាបាលរបស់លោកអេសេគាលៈ «ទឹកនេះហូរចេញទៅទិសខាងកើត ធ្លាក់ចុះទៅដល់ស្រុកវាល រួចនឹងហូរធ្លាក់ទៅឯសមុទ្រ លុះហូរធ្លាក់ទៅក្នុងសមុទ្រហើយ នោះទឹកសមុទ្រនឹងទៅជាល្អវិញ ... នឹងបានរស់នៅ ... ឯតាមមាត់ច្រាំងទាំងសងខាងទន្លេនោះ នឹងមានដុះដើមឈើគ្រប់យ៉ាង សម្រាប់ជាអាហារ ជាដើមដែលស្លឹកមិនស្រពោនឡើយ ហើយមិនដែលខានមានផ្លែដែរ គឺនឹងកើតផ្លែថ្មីរាល់តែខែ ពីព្រោះទឹកនោះចេញពីទីបរិសុទ្ធមក ហើយផ្លែឈើទាំងនោះ នឹងបានសម្រាប់ជាអាហារ ឯស្លឹកក៏សម្រាប់នឹងកែរោគឲ្យជាដែរ» (អេសគាល ៤៧:៨-១២) ។

**<u>ច័ន្ទ-២២ មិថុនា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ១៣**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ព្រោះកាលគេបានស្គាល់ព្រះ នោះគេមិនបានដំកើងទ្រង់ ទុកជាព្រះទេ ក៏មិនដឹងគុណទ្រង់ដែរ គេកើតមានគំនិតឥតប្រយោជន៍វិញ ហើយចិត្តគេ ដែលឥតយោបល់ ក៏បានត្រឡប់ជាងងឹតទៅ។ រ៉ូម ១:២១*

ព្រះបានធ្វើការតាមរយៈរាស្ត្ររបស់ទ្រង់តាំងពីដំបូងមក ឲ្យនាំព្រះពរមកដល់ពិភពលោកនេះ ។ ព្រះបានធ្វើឲ្យលោកយ៉ូសែបក្លាយជារន្ធទឹកនៃជីវិតដល់ប្រទេសអេស៊ីព្ទ កាលពីបុរាណ។ ជីវិតនៃប្រជារាស្ត្ររបស់លោកទាំងអស់ត្រូវបានសង្គ្រោះដោយសារសេចក្តីសុចរិតរបស់លោកយ៉ូសែប។ ព្រះបានជួយសង្គ្រោះជីវិតរបស់ពួកអ្នកប្រាជ្ញនៅទីក្រុងបាប៊ីឡូនតាមរយៈលោកដានីយ៉ែល។ ហើយការរំដោះទាំងនេះគឺជាមេរៀនជាក់ស្តែងដែលត្រូវរៀនសូត្រជាមេរៀនដែលបង្ហាញពីព្រះពរខាងវិញ្ញាណដែលព្រះបានប្រទានដល់ពិភពលោកតាមរយៈការភ្ជាប់ទំនាក់ទំនងជាមួយនឹងព្រះដែលលោកយ៉ូសែប និងលោកដានីយ៉ែលបានថ្វាយបង្គំ។ អស់អ្នកណាដែលមានចិត្តជាប់នៅជាមួយនឹងព្រះគ្រិស្ត អស់អ្នកណាដែលនឹងបង្ហាញសេចក្តីស្រឡាញ់របស់ទ្រង់ដល់ពិភពលោក គឺជាអ្នកបម្រើការជាមួយនឹងព្រះក្នុងការនាំយក

ព្រះពរមកចែកជូនដល់មនុស្សលោក ។ នៅពេលដែលគេទទួលព្រះគុណពីព្រះអង្គសង្គ្រោះ ដើម្បីចែករំលែកដល់អ្នកដទៃ ជំនោរនៃជីវិតខាងវិញ្ញាណនឹងហូរចេញពីជីវិតរបស់អ្នកនោះទាំងស្រុង ។

ព្រះបានជ្រើសរើសរាស្ត្រអ៊ីស្រាអែលឲ្យបង្ហាញពីអត្តចរិតរបស់ទ្រង់ដល់មនុស្សទាំងឡាយ ។ ព្រះអង្គក៏ប្រាថ្នាចង់ឲ្យពួកគេក្លាយជាសេចក្ដីសង្គ្រោះដល់ពិភពលោកផងដែរ ។ ព្រះអង្គបានប្រទានបទទំនាយនៃឋានសួគ៌ដល់ពួកគេ គឺការបើកសម្ដែងអំពីព្រះរាជបំណងព្រះហឫទ័យរបស់ព្រះ ។ នៅសម័យដើមនៃនគរអ៊ីស្រាអែល នគរទាំងឡាយនៅលើពិភពលោកបានបាត់បង់ចំណេះដឹងអំពីព្រះ ដោយសារការអនុវត្តន៍មិនត្រឹមត្រូវរបស់ពួកគេ ។ ពួកគេធ្លាប់បានស្គាល់ទ្រង់ ប៉ុន្តែ ដោយសារ «គេមិនបានតម្កើងទ្រង់ទុកជាព្រះទេ ក៏មិនដឹងគុណទ្រង់ដែរ ... ហើយចិត្តគេ ដែលឥតយោបល់ក៏បានត្រឡប់ជាងងឹតទៅ» (រ៉ូម ១:២១) ។ ប៉ុន្តែ ដោយសេចក្ដីមេត្តាករុណារបស់ទ្រង់ ព្រះអង្គមិនបានលុបបំបាត់ពួកគេចេញពីផែនដីទេ ។ ព្រះអង្គសព្វព្រះហឫទ័យចង់ប្រទានឱកាសដល់ពួកគេម្ដងទៀត ដើម្បីរួបរួមជាមួយនឹងព្រះអង្គជាថ្មីឡើងវិញ តាមរយៈរាស្ត្រដ៏បរិសុទ្ធរបស់ទ្រង់។ តាមរយៈការបង្រៀនអំពីពិធីថ្វាយតង្វាយយញ្ញបូជា ព្រះគ្រិស្តត្រូវបានលើកតម្កើងនៅចំពោះនគរទាំងឡាយ ហើយអ្នកទាំងឡាយដែលសម្លឹងមើលទៅទ្រង់នឹងមានជីវិតរស់នៅ ។ ព្រះគ្រិស្តគឺជាគ្រឹះសេដ្ឋកិច្ចនៃនគរយូដា ។ ប្រព័ន្ធនៃការថ្វាយតង្វាយយញ្ញបូជានិងនិមិត្តរូបទាំងមូល គឺជាបទទំនាយដ៏សង្ខេបនៃដំណឹងល្អ ជាការបង្ហាញដែលចងភ្ជាប់ទៅនឹងសេចក្ដីសន្យានៃការប្រោសលោះ ។

ប៉ុន្តែ រាស្ត្រអ៊ីស្រាអែលមើលមិនឃើញកិត្តិយសដ៏ខ្ពង់ខ្ពស់របស់ពួកគេ ជាអ្នកតំណាងរបស់ព្រះនេះទេ ។ ពួកគេបានភ្លេចព្រះ ហើយខកខានមិនបានបំពេញបេសកកម្មតែមួយគត់របស់ពួកគេ ។ ព្រះពរដែលពួកគេបានទទួលមិនបាននាំមកនូវព្រះពរដល់ពិភពលោកឡើយ ។ ពួកគេបានយកអត្ថប្រយោជន៍ទាំងឡាយដែលគេបានទទួលមកធ្វើជាសិរីល្អរបស់ខ្លួនផ្ទាល់ទៅវិញ ។ ពួកគេបានដកខ្លួនចេញពីពិភពលោក ដើម្បីគេចវេះពីសេចក្ដីល្បួង ។

បញ្ញត្តិដែលព្រះបានប្រទានឲ្យគេ ទាក់ទងជាមួយនឹងពួកអ្នកថ្វាយបង្គំរូបព្រះ ដើម្បីជាមធ្យោបាយការពារពួកគេពីការប្រព្រឹត្តតាមការអនុវត្តន៍របស់ពួកសាសន៍ដទៃ ពួកគេបែរជាប្រើប្រាស់ដើម្បីធ្វើជាជញ្ជាំងបែងចែករវាងពួកគេនិងនគរដទៃទៅវិញ ។ ពួកគេបានលួចប្លន់ពីព្រះ ពីពិធីថ្វាយតង្វាយដែលព្រះតម្រូវឲ្យពួកគេធ្វើ ហើយពួកគេបានលួចប្លន់ពីមនុស្សដូចគ្នានូវការដឹកនាំខាងសាសនា និងគំរូដ៏បរិសុទ្ធ ។

ពួកសង្ឃនិងពួកមេដឹកនាំបានប្រកាន់ខ្ជាប់នូវគន្លងនៃពិធីនិយម ។ ពួកគេពេញចិត្តទៅនឹងសាសនាបែបនីតិនិយម (គោរពក្រឹត្យវិន័យដើម្បីបានសង្គ្រោះ) ហើយពួកគេមិនអាចផ្តល់នូវសេចក្តីពិតដ៏រស់នៃឋានសួគ៌ទៅឲ្យអ្នកដទៃឡើយ ។ ពួកគេបានគិតថាសេចក្តីសុចរិតរបស់ពួកគេល្មមគ្រប់គ្រាន់ហើយ ហើយមិនប្រាថ្នាចង់ឲ្យមានអ្វីមួយថ្មីត្រូវបាននាំចូលមកក្នុងសាសនារបស់ពួកគេឡើយ ។ ពួកគេមិនបានទទួលយកបំណងព្រះហឫទ័យដ៏ល្អរបស់ព្រះ ចំពោះមនុស្ស ទុកជាអ្វីដែលនៅខាងក្រៅពួកគេទេ  ប៉ុន្តែ បានភ្ជាប់ទៅនឹងសេចក្តីសុចរិតរបស់ពួកគេផ្ទាល់ ដោយសារតែអំពើល្អរបស់ពួកគេទៅវិញ។ សេចក្តីជំនឿដែលធ្វើការដោយសេចក្តីស្រឡាញ់និងចិត្តបរិសុទ្ធមិនអាចរកកន្លែងបង្រួបបង្រួមជាមួយនឹងសាសនានៃពួកផារិស៊ី និងពិធីបុណ្យផ្សេងៗ និងដំបូន្មានដែលមនុស្សបង្កើតនោះបានឡើយ ។

ព្រះបានមានបន្ទូលពីសាសន៍អ៊ីស្រាអែលយ៉ាងដូច្នេះ៖ «អញបានផ្សាំងឯងទុកជាទំពាំងបាយជូរសម្រាំង ជាពូជយ៉ាងល្អបំផុត ចុះធ្វើដូចម្តេចឲ្យឯងបានក្លាយទៅជាខ្នែងរបស់ដើមទំពាំងបាយជូរដទៃ ដល់អញដូច្នេះ?» (យេរេមា ២:២១) ។ «អ៊ីស្រាអែលជាដើមទំពាំងបាយជូរទ្រុបទ្រុល ដែលកើតមានផ្លែ គេមានផលកាន់តែច្រើនឡើងយ៉ាងណា នោះក៏ចម្រើនអាសនារបស់ខ្លួនជាច្រើនឡើងយ៉ាងនោះដែរ ហើយស្រុកគេបានព្ទយ៉ាងណា នោះគេបានធ្វើបង្គោលគោរពឲ្យល្អយ៉ាងនោះដែរ» (ហូសេ ១០:១) ។ « ឥឡូវនេះ ឱពួកក្រុងយេរូសាឡិម និងជនជាតិយូដាអើយ សូមវិនិច្ឆ័យរឿងអញដែលកើតក្តីនឹងចម្ការទំពាំងបាយជូររបស់អញនេះចុះ  តើគួរឲ្យអញធ្វើអ្វីដល់ចម្ការទំពាំងបាយជូររបស់អញ ដែលអញលះបង់មិនបានធ្វើនោះ ដូច្នេះ

កាលអញប្រាថ្នាឲ្យកើតមានផលល្អ ម្តេចក៏ក្លាយទៅជាមានផ្លែទំពាំងបាយជូរព្រៃវិញ?»

«ឥឡូវនេះ អញនឹងប្រាប់ឲ្យឯងរាល់គ្នាដឹងជាអញនឹងធ្វើអ្វីដល់ចម្ការទំពាំងបាយជូររបស់អញនោះ គឺអញនឹងរើរបងចេញ នោះសត្វនឹងចូលស៊ីបំផ្លាញ អញនឹងរំលំកំផែងចេញ នោះចម្ការនឹងត្រូវជាន់ឈ្លីទៅ អញនឹងបំផ្លាញអស់រលីង នឹងគ្មានអ្នកណាកាត់លួស ឬជ្រួយដីទៀតឡើយ គឺនឹងកើតមានអញ្ចាញ ហើយនិងបន្លាដុះឡើងវិញ ហើយអញនឹងបង្គាប់ដល់មេឃ ហាមមិនឲ្យធ្លាក់ភ្លៀងមកលើចម្ការនោះតទៅ ពីព្រោះចម្ការទំពាំងបាយជូររបស់ព្រះយេហូវ៉ានៃពួកពលបរិវារ នោះគឺជាពូជពង្សរបស់អ៊ីស្រាអែល និងពួកយូដា ជាដំណាំដែលគាប់ដល់ព្រះនេត្រទ្រង់ហើយទ្រង់ប្រាថ្នាចង់បានសេចក្តីយុត្តិធម៌ តែមើល បានតែការកម្ចាយឈាមវិញ ក៏ប្រាថ្នាចង់បានសេចក្តីសុចរិតដែរ តែមើលបានតែសម្រែកក្រលួចវិញ» (អេសាយ ៥:៣-៧)។ «ឯងរាល់គ្នាមិនបានចម្រើនកម្លាំងដល់សត្វណាដែលអន់កម្លាំង ហើយ (សត្វ) ណាដែលឈឺ នោះមិនបានមើលឲ្យជាទេ (សត្វ) ណាដែលបាក់ជើងឯងមិនបានរុំអប (សត្វ) ណាដែលត្រូវកម្ចាត់កម្ចាយ នោះឯងមិនបាននាំមកវិញ ហើយ (សត្វ) ណាដែលវង្វេងទៅ នោះក៏មិនបានស្វែងរកដែរគឺឯងរាល់គ្នាបានគ្រប់គ្រងលើវា ដោយកម្លាំង ហើយតឹងរ៉ឹងវិញ» (អេសេគាល ៣៤:៤)។ ពួកមេដឹកនាំសាសន៍យូដាបានគិតថា ពួកគេមានប្រាជ្ញា មិនត្រូវការការបង្រៀនទេ ពួកគេប្រកាន់សាសនាតឹងរ៉ឹង មិនត្រូវការសេចក្តីសង្គ្រោះទេ ពួកគេមានកិត្តិយសខ្ពង់ខ្ពស់ហើយ មិនចាំបាច់ត្រូវការកិត្តិយសរបស់ព្រះគ្រិស្តឡើយ ។ ព្រះអង្គសង្គ្រោះបានបែរចេញពីពួកគេដើម្បីប្រទានកិត្តិយសដែលពួកគេបានបំពាននិងកិច្ចការដែលពួកគេបានមើលងាយដល់សាសន៍ដទៃវិញ។ សិរីល្អរបស់ព្រះគ្រិស្តត្រូវតែលើកតម្កើង ព្រះបន្ទូលរបស់ទ្រង់បានតាំងឡើង  នគររបស់ព្រះគ្រិស្តត្រូវតែបានតាំងឡើងនៅលើផែនដី។ សេចក្តីសង្គ្រោះរបស់ព្រះត្រូវតែបានផ្សព្វផ្សាយនៅក្នុងទីក្រុងទាំងឡាយនៅក្នុងទីរហោស្ថាន ហើយព្រះអង្គបានត្រាស់ហៅពួកសាវ័ករបស់ទ្រង់ឲ្យបំពេញកិច្ចការដែលពួកអ្នកដឹកនាំសាសន៍យូដាខកខានមិនបានធ្វើ។

ជំពូកទី
២

# ការបង្រៀនដល់ពួកសិស្សទាំងដប់ពីរនាក់

<u>អង្គារ-២៣ មិថុនា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃៈ សាំយូអែលទី១ ជំពូក ១៤

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ទ្រង់ក៏យាងឡើងទៅលើភ្នំ រួចមានព្រះបន្ទូលហៅអស់អ្នក ដែលទ្រង់សព្វព្រះហឫទ័យចង់ហៅ ហើយអ្នកទាំងនោះក៏ចូលមកឯទ្រង់ រួចទ្រង់តម្រូវ១២នាក់ឲ្យបាននៅជាមួយនឹងទ្រង់ ដើម្បីទ្រង់បានចាត់គេ ឲ្យចេញទៅប្រកាសប្រដៅ។ ម៉ាកុស ៣:១៣-១៤*

ព្រះគ្រិស្តមិនបានជ្រើសរើសពួកសាន់ហ៊ីឌ្រីន ឬអ្នកមានអំណាចនៃទីក្រុងរ៉ូម ដែលមានចំណេះដឹងនិងមានត្រកូលខ្ពស់ឲ្យបំពេញកិច្ចការរបស់ទ្រង់ទេ។ ដោយយាងរំលងសាសន៍យូដាដែលអាងលើសេចក្តីសុចរិតរបស់ខ្លួនផ្ទាល់ ព្រះដែលជាម្ចាស់ចម្ការបានជ្រើសរើសបុរសដែលទន់ទាបគ្មានចំណេះវិជ្ជាឲ្យប្រកាសពីសេចក្តីពិតដែលធ្វើឲ្យពិភពលោកនេះក្រឡាប់ចាក់វិញ ព្រះអង្គមានគោលបំណងបង្រៀននិងអប់រំមនុស្សទាំងនេះឲ្យធ្វើជាមេដឹកនាំនៃពួកជំនុំរបស់ទ្រង់។ ភារកិច្ចរបស់ពួកគេគឺបង្រៀនដល់អ្នកដទៃ រួចបញ្ជូនពួកគេឲ្យចេញទៅជាមួយនឹងសារនៃដំណឹងល្អ។ ដើម្បីឲ្យពួកគេមានជោគជ័យក្នុងការបំពេញកិច្ចការរបស់ពួកគេ ព្រះត្រូវតែប្រទានព្រះវិញ្ញាណបរិសុទ្ធដល់ពួកគេ ។ ដំណឹងល្អត្រូវបានប្រកាសផ្សាយមិនមែនដោយអំណាច ឬដោយប្រាជ្ញារបស់មនុស្សនោះទេ គឺដោយសារព្រះចេស្តារបស់ព្រះជាម្ចាស់វិញ។

ពួកសាវ័កបានទទួលការបង្ហាត់បង្រៀនអស់ពេលបីឆ្នាំកន្លះពីគ្រូដ៏អស្ចារ្យបំផុត ដែលពិភពលោកមិនដែលមាន។ ព្រះគ្រិស្តបានបង្ហាត់បង្រៀនដល់ពួកគេសម្រាប់បំពេញកិច្ចការរបស់ទ្រង់ ដោយទំនាក់ទំនងនិងរស់នៅ

ជាមួយពួកគេដោយផ្ទាល់។ ពួកគេបានដើរនិងនិយាយជាមួយទ្រង់ពីមួយថ្ងៃទៅមួយថ្ងៃ ដោយស្តាប់ព្រះបន្ទូលលើកទឹកចិត្តរបស់ទ្រង់ ដល់អ្នកហេវហត់និងអ្នកមានបន្ទុកធ្ងន់ និងមើលការបង្ហាញព្រះចេស្តារបស់ទ្រង់ ជំនួសអ្នកជំងឺនិងអ្នកមានទុក្ខកង្វល់។ ជួនកាលព្រះអង្គបង្រៀនដល់ពួកគេដោយគង់ជាមួយពួកគេនៅលើភ្នំ ជួនកាលក្បែរមាត់សមុទ្រ ឬនៅពេលដើរតាមផ្លូវព្រះអង្គបានបង្ហាញពីអាថ៌កំបាំងនៃនគររបស់ព្រះ។ ព្រះបើកបង្ហាញអំពីសេចក្តីពិតនៃសេចក្តីសង្គ្រោះ នៅពេលដែលចិត្តពួកគេបើកចំហទទួលសាររបស់ព្រះ។ ព្រះអង្គមិនបានបង្គាប់ពួកសាវ័កឲ្យធ្វើការនេះឬការនោះឡើយ ប៉ុន្តែ ព្រះអង្គបានមានបន្ទូលថា «ចូរមកតាមខ្ញុំ»។ ព្រះអង្គបានយកពួកគេទៅជាមួយទ្រង់ នៅពេលដែលទ្រង់យាងកាត់ជនបទនិងទីក្រុងនានា ដើម្បីឲ្យពួកគេបានឃើញរបៀបដែលទ្រង់បានបង្រៀនដល់មនុស្ស។ ពួកគេបានធ្វើដំណើរជាមួយទ្រង់ពីកន្លែងមួយទៅកន្លែងមួយ។ ពួកគេបានចូលរួមដំណើរយ៉ាងអត្តខាត់ជាមួយទ្រង់ ហើយពេលខ្លះ ពួកគេបានជួបប្រទះនឹងការអត់ឃ្លាននិងការហេវហត់ដូចជាទ្រង់ដែរ។ ពួកគេបាននៅជាមួយនឹងទ្រង់ នៅលើផ្លូវដែលមានមនុស្សកុះករ ក្បែរមាត់បឹង ក្នុងទីរហោស្ថានដ៏ស្ងាត់ជ្រងំ។ ពួកគេបានឃើញទ្រង់នៅគ្រប់តំណាក់ការនៃជីវិត ។

គឺនៅពេលដែលញែកពួកសាវ័កទាំងដប់ពីរនោះឯង ដែលជាការបោះជំហានទីមួយក្នុងការរៀបចំពួកជំនុំមួយ ដែលបន្ទាប់ពីការចាកចេញរបស់ព្រះគ្រិស្តទៅកិច្ចការរបស់ព្រះអង្គត្រូវបានបន្តអនុវត្តនៅលើពិភពលោកនេះ។ ព្រះគម្ពីរបានចែងអំពីតម្រូវការនេះយ៉ាងដូច្នេះ៖ «ទ្រង់ក៏យាងឡើងទៅលើភ្នំ រួចមានព្រះបន្ទូលហៅអស់អ្នកដែលទ្រង់សព្វព្រះហឫទ័យចង់ហៅ ហើយអ្នកទាំងនោះក៏ចូលមកឯទ្រង់ រួចទ្រង់តម្រូវដប់ពីរនាក់ឲ្យបាននៅជាមួយនឹងទ្រង់ ដើម្បីទ្រង់បានចាត់គេ ឲ្យចេញទៅប្រកាសប្រដៅ» (ម៉ាកុស ៣:១៣, ១៤) ។

សូមក្រឡេកមើលទៅទស្សនីយភាពដ៏គួរឲ្យរំភើបនេះ។ មើលន៍ព្រះ

ដ៏មានអានុភាពនៃឋានសួគ៌ ព័ទ្ធជុំវិញដោយសាវ័កទាំងដប់ពីរនាក់ ជាអ្នកដែលទ្រង់បានជ្រើសរើស។ ព្រះអង្គរៀបនឹងញែកពួកគេដោយឡែកសម្រាប់បំពេញកិច្ចការរបស់ពួកគេនៅពេលបន្តិចទៀតនេះ។ ទ្រង់រៀបចំនឹងដាក់សេចក្ដីសង្គ្រោះដែលនៅជិតបង្ហើយ ដោយសារព្រះបន្ទូលនិងព្រះវិញ្ញាណរបស់ព្រះអង្គ ដោយសារពួកភ្នាក់ងារដ៏ទន់ខ្សោយទាំងនេះ។

ព្រះជាម្ចាស់និងពួកទេវតាបានទតមើលទស្សនីយភាពនេះ ដោយភាពរីករាយនិងក្ដីអំណរ។ ព្រះវរបិតាបានជ្រាបថា ពន្លឺនៃឋានសួគ៌និងបានភ្លឺចែងចាំងចេញពីបុរសទាំងនេះ ហើយពាក្យសម្ដីដែលពួកគេនិយាយ នៅពេលដែលពួកគេធ្វើទីបន្ទាល់អំពីព្រះរាជបុត្រា នឹងឮខ្ទរ ពីជំនាន់មួយ ទៅជំនាន់មួយរហូតដល់ទីអវសាន្ត។

ពួកសាវ័កត្រូវចេញទៅ ជាទីបន្ទាល់របស់ព្រះគ្រិស្ដ ដើម្បីប្រកាសប្រាប់ដល់ពិភពលោកពីអ្វីដែលពួកគេបានឃើញ និងបានឮអំពីទ្រង់។ តួនាទីរបស់ពួកគេមានសារៈសំខាន់បំផុត ដែលព្រះមិនធ្លាប់ដែលបានត្រាស់ហៅមនុស្សណាក្រៅពីពួកគេឡើយ ដែលគាំទ្រដោយព្រះគ្រិស្ដតែមួយគត់។ ពួកគេគឺជាអ្នកធ្វើការរួមជាមួយនឹងព្រះដើម្បីសេចក្ដីសង្គ្រោះរបស់មនុស្សលោក។ ពួកសាវ័កទាំងដប់ពីរនាក់ឈរជាតំណាងឲ្យពួកជំនុំនៃដំណឹងល្អ ដូចជាពួកចាស់ទុំទាំងដប់ពីរនាក់បានឈរ ជាតំណាងឲ្យសាសន៍អ៊ីស្រាអែល ក្នុងគម្ពីរសញ្ញាចាស់ដូច្នោះដែរ ។

**<u>ពុធ-២៤ មិថុនា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ១៥**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ទ្រង់បានបង្កើតមនុស្សគ្រប់សាសន៍ពីឈាមតែ១ ឲ្យបាននៅពេញលើផែនដី ព្រមទាំងសំរេចកំណត់ពេលវេលា ដែលបានតាំងជាមុន និងព្រំទីលំនៅរបស់គេគ្រប់គ្នា ដើម្បីឲ្យគេស្វែងរកព្រះ ក្រែងគេនឹងរកទ្រង់ឃើញ ដោយខំរាវរកមែននោះទេដឹង ទោះបើទ្រង់មិនគង់ឆ្ងាយពីយើងនិមួយៗក៏ដោយ។ កិច្ចការ ១៧:២៦-២៧*

នៅក្នុងព្រះរាជកិច្ចរបស់ព្រះអង្គនៅលើផែនដីព្រះគិស្ទ្របានចាប់ផ្តើមបំបែករនាំងបែងចែករវាងសាសន៍យូដានិងសាសន៍ដទៃហើយបានអធិប្បាយអំពីសេចក្តីសង្គ្រោះដល់មនុស្សលោកទាំងអស់។ ទោះបី ព្រះអង្គជាសាសន៍យូដាក៏ដោយ ក៏ព្រះទ្រង់បានរស់នៅលាយឡំជាមួយនឹងសាសន៍សាម៉ារីដោយសេរី ដោយមិនយកព្រះទ័យទុកដាក់ទៅនឹងទម្លាប់នៃពួកផារិស៊ីក្នុងសាសន៍យូដាដែលចាត់ទុកពួកនេះថាជាមនុស្សថោកទាបនោះឡើយ។ ព្រះអង្គបានយាងចូលទៅក្នុងផ្ទះរបស់ពួកគេសោយអាហារនៅនឹងតុរបស់ពួកគេ ហើយបង្រៀននៅតាមផ្លូវរបស់ពួកគេ ។

ព្រះអង្គសង្គ្រោះសព្វព្រះហឫទ័យចង់បង្រៀនដល់ពួកសាវ័កអំពីសេចក្តីពិត ទាក់ទងនឹងការបំបាក់បំបែក «ជញ្ជាំងដែលខ័ណ្ឌជាកណ្តាល» រវាងសាសន៍អ៊ីស្រាអែល និងសាសន៍ដទៃ ជាសេចក្តីពិតដែល «ពួកសាសន៍ដទៃ បានត្រឡប់ជាអ្នកគ្រងមរតក» ជាមួយនឹងសាសន៍យូដា និង «ជាអ្នកទទួលចំណែកនៃសេចក្តីសន្យារបស់ទ្រង់ ជាមួយគ្នាក្នុងព្រះគ្រិស្តដែរ ដោយសារដំណឹងល្អ» (អេភេសូរ ២:១៤, ៣:៦) ។

សេចក្តីពិតនេះត្រូវបានបង្ហាញមួយផ្នែកនៅពេលដែលព្រះអង្គបានប្រទានរង្វាន់ដល់សេចក្តីជំនឿរបស់មេទ័ពម្នាក់នៅភូមិកាពើណិម និងនៅពេលដែលព្រះអង្គបានអធិប្បាយអំពីសេចក្តីសង្គ្រោះអ្នកស្រុកស៊ូខារ។ រឿងនេះបានបង្ហាញកាន់តែច្បាស់ នៅពេលដែលព្រះអង្គបានយាងទៅសួរសុខទុក្ខស្ត្រីសាសន៍ភេនីស នៅពេលដែលទ្រង់បានព្យាបាលជំងឺកូនស្រីស្ត្រីស្រុកកាណាន។ បទពិសោធន៍នេះបានជួយដល់ពួកសាវ័កឲ្យយល់ថានៅក្នុងចំណោមមនុស្ស ដែលបានចាត់ទុកសេចក្តីសង្គ្រោះថាគ្មានតម្លៃសម្រាប់ខ្លួន មានមនុស្សជាច្រើនដែលស្រេកឃ្លានពន្លឺនៃសេចក្តីពិតនេះ ។

ដូច្នេះ ព្រះគ្រិស្តបានស្វះស្វែងបង្រៀនដល់ពួកសាវ័កអំពីសេចក្តីពិតថា នៅក្នុងនគររបស់ព្រះមិនមានខ្សែបន្ទាត់ព្រំដែនទេ មិនមានស្រទាប់វណ្ណៈទាបថោក មិនមានវណ្ណៈអភិជនទេ ទ្រង់បង្រៀនដល់គេថាពួកគេត្រូវតែចូល

ទៅកាន់គ្រប់ជាតិសាសន៍ទាំងអស់ ដោយចែកចាយសារនៃសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះជាមួយនឹងពួកគេ ។ ប៉ុន្តែ លុះចំណេរក្រោយមកទៀត ទើបពួកគេដឹងច្បាស់ពីការនេះថា «ទ្រង់បានបង្កើតមនុស្សគ្រប់សាសន៍ពីឈាមតែមួយ ឲ្យបាននៅពេញលើផែនដី ព្រមទាំងសម្រេចកំណត់ពេលវេលាដែលបានតាំងជាមុន និងព្រំទីលំនៅរបស់គេគ្រប់គ្នា ដើម្បីឲ្យគេស្វែងរកព្រះ ក្រែងគេនឹងរកទ្រង់ឃើញ ដោយខំរាវរកមែននោះទេដឹង ទោះបើទ្រង់មិនគង់ឆ្ងាយពីយើងនីមួយៗក៏ដោយ» ( កិច្ចការ ១៧:២៦, ២៧) ។

ព្រះបានបង្ហាញភាពខុសគ្នាដែលគួរឲ្យកត់សម្គាល់នេះដល់ពួកសាវ័កដំបូងៗ។ ពួកគេត្រូវតែធ្វើជាគ្រូបង្រៀនដល់ពិភពលោក ហើយពួកគេជាតំណាងពីអត្តចរិតខុសៗគ្នាយ៉ាងទូលំទូលាយ។ ដើម្បីបំពេញភារកិច្ចដែលព្រះបានត្រាស់ហៅនេះឲ្យមានជោគជ័យ ពួកមនុស្សដែលមានអត្តចរិតពីកំណើត និងទម្លាប់នៃជីវិតខុសៗគ្នាទាំងនេះត្រូវតែមានចិត្តគំនិតសកម្មភាពស្របគ្នា។ ការរួបរួមគ្នានេះគឺជាកម្មបទដែលព្រះគ្រិស្តត្រូវតែថែរក្សាឲ្យមានសុវត្ថិភាព។ ដើម្បីឲ្យដល់ទីបញ្ចប់នេះ ព្រះអង្គបានស្វះស្វែងនាំឲ្យពួកគេរួបរួមគ្នាជាមួយនឹងព្រះអង្គដោយផ្ទាល់។ បន្ទុកនៃកិច្ចការរបស់ទ្រង់ចំពោះពួកគេ ត្រូវបានបង្ហាញនៅក្នុងសេចក្តីអធិដ្ឋានទៅព្រះវរបិតារបស់ទ្រង់ «ដើម្បីឲ្យទាំងអស់បានរួមមកតែមួយ ឱព្រះវរបិតាអើយ ដូចជាទ្រង់គង់ក្នុងទូលបង្គំ ហើយទូលបង្គំនៅក្នុងទ្រង់ដែរ គឺឲ្យអ្នកទាំងនោះបានរួមគ្នាតែមួយ នៅក្នុងយើង ប្រយោជន៍ឲ្យលោកិយបានជឿថា ទ្រង់ចាត់ឲ្យទូលបង្គំមកពិត»។ «គឺទូលបង្គំនៅក្នុងគេ ហើយទ្រង់គង់ក្នុងទូលបង្គំ ដើម្បីឲ្យគេបានគ្រប់លក្ខណ៍ឡើង ដរាបដល់រួមគ្នាតែមួយជាស្រេច ប្រយោជន៍ឲ្យលោកិយបានដឹងថា គឺទ្រង់ដែលចាត់ឲ្យទូលបង្គំមកមែន ហើយថា ទ្រង់ស្រឡាញ់គេដូចជាស្រឡាញ់ទូលបង្គំដែរ» (យ៉ូហាន ១៧:២១, ២៣)។ សេចក្តីអធិដ្ឋានជាប្រចាំរបស់ព្រះអង្គ ចំពោះពួកគេគឺថាសូមឲ្យពួកគេបានញែកជាបរិសុទ្ធដោយសារសេចក្តីពិត ហើយទ្រង់បានអធិដ្ឋានដោយទំនុកចិត្ត ដោយជ្រាបថាបញ្ញត្តិ

នៃព្រះដ៏មានសព្វព្រះចេស្តា ត្រូវបានប្រទានដល់ពិភពលោកដែលទ្រង់បានបង្កើតនោះ។ ទ្រង់បានជ្រាបថាដំណឹងល្អនៃនគរនឹងត្រូវប្រកាសដល់គ្រប់ទាំងសាសន៍សម្រាប់ជាបន្ទាល់ ព្រះអង្គបានជ្រាបថាសេចក្តីពិតប្រដាប់អាវុធដោយព្រះវិញ្ញាណបរិសុទ្ធដែលមានអំណាចខ្លាំងក្រៃលែងដែលនឹងដណ្តើមយកជ័យជម្នះនៅក្នុងសមរភូមិជាមួយនឹងអារក្ស និងថាផ្ទាំងបដាដែលសរសេរដោយឈាមនឹងបក់ដោយជោគជ័យពីលើពួកអ្នកដើរតាមទ្រង់ នៅថ្ងៃណាមួយជាក់ជាមិនខាន ។

ខណៈដែលព្រះរាជកិច្ចរបស់ព្រះគ្រិស្តនៅលើផែនដីនេះឈានចូលជិតដល់ទីបញ្ចប់ ហើយព្រះអង្គបានជ្រាបថានៅពេលឆាប់ៗនេះទ្រង់នឹងទុកឲ្យពួកសាវ័កនៅបំពេញកិច្ចការដោយមិនមានការគ្រប់គ្រងពីព្រះអង្គតទៅទៀតនោះ ព្រះអង្គបានខំប្រឹងប្រែងលើកទឹកចិត្តនិងរៀបចំពួកគេសម្រាប់ពេលអនាគត។ ព្រះអង្គមិនបានបញ្ឆោតគេដោយសេចក្តីសង្ឃឹមក្លែងក្លាយនោះទេ។ ទ្រង់បានជ្រាបពីអ្វីដែលនឹងកើតឡើង ដូចជាសៀវភៅដែលបើកចំហ។ ព្រះអង្គបានជ្រាបថាទ្រង់នឹងត្រូវបំបែកចេញពីពួកគេនៅពេលឆាប់ៗនេះ ទុកឲ្យពួកគេនៅដូចជាចៀមក្នុងហ្វូងចចកដូច្នោះដែរ ។ ព្រះអង្គបានជ្រាបថាពួកគេនឹងរងទុក្ខដោយការបៀតបៀន ដែលពួកគេនឹងត្រូវបានបោះចេញទៅក្រៅសាលាប្រជុំ និងត្រូវបានគេចាប់ដាក់គុក ។ ព្រះអង្គបានជ្រាបថាអ្នកខ្លះក្នុងចំណោមពួកគេនឹងស្លាប់ដោយសារតែការធ្វើទីបន្ទាល់ថាទ្រង់គឺជាព្រះមែស្ស៊ី។ ហើយព្រះអង្គក៏បានមានបន្ទូលប្រាប់ដល់ពួកគេអំពីហេតុការណ៍នេះមួយចំនួន។ ក្នុងការមានបន្ទូលអំពីអនាគតរបស់ពួកគេ ព្រះអង្គបានបញ្ជាក់យ៉ាងច្បាស់ថា នៅក្នុងការពិបាកដែលនឹងមកដល់ ពួកគេនឹងនឹកឃើញពីព្រះបន្ទូលរបស់ទ្រង់ និងមានសេចក្តីក្លាហានក្នុងការជឿជាក់ដល់ទ្រង់ ថាជាព្រះដែលប្រោសលោះ ។

**<u>ព្រហស្បតិ៍-២៥ មិថុនា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ១៦**
**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ខ្ញុំប្រាប់សេចក្តីទាំងនេះ ដើម្បីឲ្យអ្នករាល់គ្នា បានសេចក្តីសុខសាន្ត ដោយសារខ្ញុំ នៅលោកីយ៍នេះ នោះអ្នករាល់គ្នាមានសេចក្តីវេទនាមែន ប៉ុន្តែ ត្រូវសង្ឃឹមឡើង ដ្បិតខ្ញុំបានឈ្នះលោកីយ៍ហើយ។*
*យ៉ូហាន ១៦:៣៣*

ព្រះអង្គក៏បានមានព្រះបន្ទូលពីសេចក្តីសង្ឃឹមនិងសេចក្តីក្លាហានផងដែរ។ «កុំឲ្យចិត្តអ្នករាល់គ្នាថប់បារម្ភឡើយ អ្នករាល់គ្នាជឿដល់ព្រះហើយ ចូរជឿដល់ខ្ញុំដែរ នៅក្នុងដំណាក់នៃព្រះវរបិតាខ្ញុំ មានទីលំនៅជាច្រើន ពុំនោះខ្ញុំបានប្រាប់អ្នករាល់គ្នាហើយ ខ្ញុំទៅរៀបកន្លែងឲ្យអ្នករាល់គ្នា បើខ្ញុំទៅរៀបកន្លែងឲ្យអ្នករាល់គ្នា នោះខ្ញុំនឹងត្រឡប់មកវិញ នឹងទទួលអ្នករាល់គ្នាទៅឯខ្ញុំ ប្រយោជន៍ឲ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅនោះដែរ ឯកន្លែងដែលខ្ញុំទៅ នោះអ្នករាល់គ្នាក៏ដឹង ហើយក៏ស្គាល់ផ្លូវទៅដែរ» (យ៉ូហាន ១៤:១-៤)។ ខ្ញុំបានយាងមកកាន់លោកិយនេះដើម្បីជាប្រយោជន៍ដល់អ្នករាល់គ្នា ។ ខ្ញុំកំពុងធ្វើការដើម្បីអ្នករាល់គ្នា ។ នៅពេលដែលខ្ញុំចាកចេញទៅឆ្ងាយ ខ្ញុំនៅតែធ្វើការជាមួយនឹងអ្នករាល់គ្នាដោយស្មោះស្ម័គ្រដដែល។ ខ្ញុំបានយាងមកកាន់លោកិយនេះដើម្បីបង្ហាញពីរូបខ្ញុំដល់អ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាបានជឿថា ខ្ញុំនឹងទៅឯព្រះវរបិតារបស់ខ្ញុំ ដើម្បីសហការជាមួយនឹងទ្រង់ជំនួសអ្នករាល់គ្នា ។

«ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលជឿដល់ខ្ញុំ នោះនឹងធ្វើការដែលខ្ញុំធ្វើដែរ ក៏នឹងធ្វើការធំជាងការទាំងនោះទៅទៀត ពីព្រោះខ្ញុំទៅឯព្រះវរបិតា» (យ៉ូហាន ១៤:១២)។ ដោយព្រះបន្ទូលនេះ ព្រះគ្រិស្តមិនបានចង់មានបន្ទូលថាពួកសាវ័កត្រូវតែលើកកម្ពស់ការខំប្រឹងប្រែងឲ្យខ្លាំងជាងការដែលទ្រង់បានធ្វើនោះទេ ប៉ុន្តែ ព្រះអង្គចង់មានបន្ទូលថាកិច្ចការរបស់ពួកគេនឹងមានទំហំកាន់តែធំធេងឡើង។ ព្រះអង្គមិនបានមានបន្ទូលត្រឹមតែការធ្វើការអស្ចារ្យប៉ុណ្ណោះទេ ប៉ុន្តែ ព្រះអង្គមានបន្ទូលអំពីកិច្ចការ

ទាំងអស់ដែលកើតឡើងនៅក្រោមអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។ ព្រះអង្គបានមានបន្ទូលថា «ប៉ុន្តែ កាលណាព្រះដ៏ជាជំនួយទ្រង់យាងមក ដែលខ្ញុំនឹងចាត់មកពីព្រះវរបិតា គឺជាព្រះវិញ្ញាណនៃសេចក្តីពិត ដែលចេញពីព្រះវរបិតាមក ព្រះអង្គនោះ ទ្រង់នឹងធ្វើបន្ទាល់ពីខ្ញុំ ហើយអ្នករាល់គ្នានឹងធ្វើបន្ទាល់ដែរ ពីព្រោះអ្នករាល់គ្នាបាននៅជាមួយនឹងខ្ញុំ តាំងតែពីដើមមក»
(យ៉ូហាន ១៥:២៦, ២៧) ។

ព្រះបន្ទូលនេះត្រូវបានសម្រេចយ៉ាងអស្ចារ្យ ។ បន្ទាប់ពីការយាងចុះនៃព្រះវិញ្ញាណបរិសុទ្ធមក ពួកសាវ័កពោរពេញទៅដោយសេចក្តីស្រឡាញ់ចំពោះទ្រង់ និងចំពោះអ្នកដែលព្រះអង្គបានសុគតជំនួស ចិត្តរបស់មនុស្សជាច្រើនត្រូវបានរលាយដោយសារតែពាក្យដែលពួកគេបាននិយាយ និងដោយសេចក្តីអធិដ្ឋានដែលពួកគេបានផ្តល់ ។ ពួកគេនិយាយដោយព្រះចេស្តានៃព្រះវិញ្ញាណ ហើយនៅក្រោមការសម្រេចនៃអំណាចនោះ មនុស្សរាប់ពាន់នាក់បានផ្លាស់ប្តូរជំនឿ ។

ជាព្រះរាជតំណាងរបស់ព្រះគ្រិស្ត ពួកសាវ័កត្រូវតែធ្វើជាគំរូដ៏ល្អនៅលើពិភពលោកនេះ  រឿងពិតដែលថាពួកគេជាមនុស្សទន់ទាប មិនបានលុបបំបាត់ឥទ្ធិពលរបស់ពួកគេឡើយ ប៉ុន្តែ បានបង្កើនឡើងទៅវិញទេ ដ្បិតគំនិតរបស់ពួកអ្នកដែលបានស្តាប់ពួកគេនឹងត្រូវបានដឹកនាំចេញពីពួកគេទៅកាន់ព្រះអង្គសង្គ្រោះ ជាព្រះដែលនៅតែធ្វើការនៅក្នុងជីវិតរបស់ពួកគេដែលមនុស្សមើលមិនឃើញ ។ ការបង្រៀនដ៏អស្ចារ្យរបស់ពួកសាវ័កពាក្យសម្តីនៃការលើកទឹកចិត្ត និងស្មោះត្រង់របស់ពួកគេ បញ្ជាក់ប្រាប់ថាពួកគេមិនបានធ្វើកិច្ចការដោយកម្លាំងរបស់ខ្លួនផ្ទាល់នោះទេ ប៉ុន្តែ គឺនៅក្នុងព្រះចេស្តារបស់ព្រះគ្រិស្តវិញ។ ពួកគេប្រកាសដោយការបន្ទាបខ្លួនថា ព្រះអង្គដែលសាសន៍យូដាបានឆ្កាង គឺជាព្រះអម្ចាស់នៃជីវិត ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់ និងថាពួកគេបានធ្វើកិច្ចការនៅក្នុងព្រះនាមរបស់ទ្រង់ ។

នៅក្នុងការសន្ទនាជាមួយនឹងពួកសាវ័ក នៅរាត្រីចុងក្រោយ មុន

ពេលដែលព្រះអង្គត្រូវគេឆ្កាង ព្រះអង្គសង្គ្រោះមិនបានយោងទៅលើការរងទុក្ខដែលព្រះអង្គនឹងរងទ្រាំ និងត្រូវតែរងទ្រាំនៅពេលខាងមុខនោះទេ។ ព្រះអង្គមិនបានមានបន្ទូលអំពីការអាម៉ាស់ដែលនៅពីមុខទ្រង់នោះទេ ប៉ុន្តែ ព្រះបានខំប្រឹងស្វះស្វែងនាំយកមកកាន់គំនិតរបស់ពួកគេនូវអ្វីដែលនឹងពង្រឹងដល់ជំនឿរបស់ពួកគេ ដោយដឹកនាំពួកគេឲ្យសម្លឹងមើលទៅក្តីអំណរនៅខាងមុខ ដែលកំពុងរង់ចាំអ្នកដែលមានជ័យជម្នះ។ ទ្រង់មានអំណរនៅក្នុងព្រះតម្រិះដែលព្រះអង្គអាចនិងធ្វើសម្រាប់ពួកសាវ័ករបស់ទ្រង់ បានច្រើនជាងការដែលទ្រង់បានសន្យា ដែលនឹងមានសេចក្តីស្រឡាញ់និងការអាណិតអាសូរនឹងហូរចេញមកពីព្រះអង្គ និងធ្វើឲ្យមនុស្សមានអត្តចរិតដូចទ្រង់ ដែលមនុស្សរបស់ទ្រង់បានប្រដាប់កាយដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ដែលនឹងចេញទៅមុខដោយជ័យជម្នះ និងដើម្បីគ្រប់គ្រង ។

ព្រះអង្គបានមានបន្ទូលថា «ខ្ញុំប្រាប់សេចក្តីទាំងនេះ ដើម្បីឲ្យអ្នករាល់គ្នាបានសេចក្តីសុខសាន្ត ដោយសារខ្ញុំ នៅលោកិយនេះ នោះអ្នករាល់គ្នាមានសេចក្តីវេទនាមែន ប៉ុន្តែ ត្រូវសង្ឃឹមឡើង ដ្បិតខ្ញុំបានឈ្នះលោកិយហើយ» (យ៉ូហាន ១៦:៣៣)។ ព្រះគ្រិស្តមិនបានបរាជ័យឡើយ ហើយក៏មិនដែលបាក់ទឹកចិត្តដែរ ហើយពួកសាវ័កក៏ត្រូវតែបង្ហាញពីនិស្ស័យនៃការអត់ធ្មត់នោះដែរ។ ពួកគេត្រូវតែធ្វើការដូចជាព្រះអង្គធ្លាប់បានធ្វើនោះដែរ ដោយទីពឹងទៅលើទ្រង់ដើម្បីឲ្យមានកម្លាំងឡើង។ ទោះបីជាផ្លូវរបស់ពួកគេត្រូវបានរារាំងដោយសភាពដែលហាក់ដូចជាមិនអាចសម្រេចបានក៏ដោយ ប៉ុន្តែ ដោយព្រះគុណរបស់ទ្រង់ ពួកគេបានបោះជំហានទៅមុខ ដោយគ្មានការព្រួយបារម្ភពីអ្វីឡើយ ហើយពួកគេមានសង្ឃឹមថានឹងបានអ្វីៗគ្រប់យ៉ាង។ ព្រះគ្រិស្តបានបង្ហើយកិច្ចការដែលព្រះវរបិតាបានប្រគល់ថ្វាយទ្រង់ធ្វើ។ ព្រះអង្គបានប្រមែប្រមូលអ្នកដែលនឹងត្រូវធ្វើការជាមួយទ្រង់ នៅក្នុងចំណោមមនុស្សទាំងឡាយ។ ហើយព្រះអង្គបានមានបន្ទូលថា «ទូលបង្គំបានថ្កើងឡើងក្នុងគេ អ្នកទាំងនេះនៅក្នុងលោកិយ តែទូលបង្គំមិននៅក្នុងលោកិយទៀតទេ ទូល

បង្គំនឹងទៅឯទ្រង់ ឱព្រះវរបិតាដ៏បរិសុទ្ធអើយ ឯពួកអ្នកដែលទ្រង់បានប្រទានមកទូលបង្គំ នោះសូមទ្រង់រក្សាគេដោយព្រះនាមទ្រង់ផង ដើម្បីឲ្យគេបានរួមគ្នាតែមួយ ដូចជាយើងដែរ។ «ទូលបង្គំមិនអធិដ្ឋានឲ្យអ្នកទាំងនេះតែប៉ុណ្ណោះ គឺឲ្យដល់ទាំងអ្នកណា ដែលនឹងជឿដល់ទូលបង្គំ ដោយសារពាក្យរបស់គេថែមទៀតដែរ ដើម្បីឲ្យទាំងអស់បានរួមមកតែមួយ ... គឺទូលបង្គំនៅក្នុងគេ ហើយទ្រង់គង់ក្នុងទូលបង្គំ ដើម្បីឲ្យគេបានគ្រប់លក្ខណ៍ឡើង ដរាបដល់រួមគ្នាតែមួយជាស្រេច ប្រយោជន៍ឲ្យលោកិយបានដឹងថា គឺទ្រង់ដែលចាត់ឲ្យទូលបង្គំមកមែន ហើយថា ទ្រង់ស្រឡាញ់គេ ដូចជាស្រឡាញ់ទូលបង្គំដែរ» (យ៉ូហាន ១៧:១០, ១១, ២០-២៣) ។

ជំពូកទី
៣

# មហាបញ្ញា

<u>សុក្រ-២៦ មិថុនា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ១៧

ខព្រះគម្ពីរប្រចាំថ្ងៃ: *នោះទ្រង់ក៏បើកបំភ្លឺសតិស្មារតីគេ ឲ្យបានយល់ក្នុងគម្ពីរ ទ្រង់មានព្រះបន្ទូលទៅគេថា គឺសេចក្តីនេះហើយ ដែលបានចែងទុកមក គឺថា ព្រះគ្រីស្ទត្រូវរងទុក្ខលំបាក ហើយនៅថ្ងៃទី៣ទ្រង់នឹងរស់ពីស្លាប់ឡើងវិញ ហើយត្រូវឲ្យការប្រែចិត្ត និងសេចក្តីប្រោសឲ្យរួច បានប្រកាសប្រាប់ដល់អស់ទាំងសាសន៍ ដោយនូវព្រះនាមទ្រង់ ចាប់តាំងពីក្រុងយេរូសាឡិមទៅ។ លូកា ២៤:៤៥-៤៧*

បន្ទាប់ពីការសុគតរបស់ព្រះគ្រិស្តមក ពួកសាវ័កសឹងតែបរាជ័យដោយការបាក់ទឹកចិត្តទៅហើយ។ លោកគ្រូរបស់ពួកគេត្រូវបានគេបដិសេធ គេកាត់ទោស ហើយត្រូវគេឆ្កាង។ ពួកសង្ឃនិងពួកមេដឹកនាំសាសនាបានប្រកាសដោយប្រមាថមើលងាយថា «វាជួយសង្គ្រោះមនុស្សឯទៀតបាន តែមិនអាចនឹងជួយសង្គ្រោះដល់ខ្លួនវាបានទេ បើសិនណាវាជាស្តេចសាសន៍អ៊ីស្រាអែលមែន ចូរឲ្យវាចុះពីឈើឆ្កាងមក នោះយើងនឹងជឿដល់វា» (ម៉ាថាយ ២៧:៤២)។ ព្រះអាទិត្យនៃសេចក្តីសង្ឃឹមរបស់ពួកសាវ័កបានអស្តង្គតទៅហើយ ហើយរាត្រីកាលបានចូលមកជំនួសនៅក្នុងចិត្តរបស់ពួកគេវិញ។ ពួកគេបានរំឭកជាញឹកញាប់នូវពាក្យថា «យើងខ្ញុំបានសង្ឃឹមថា គឺលោកនេះហើយ ជាព្រះដែលរៀបនឹងប្រោសលោះសាសន៍អ៊ីស្រាអែលទាំងប៉ុន្មាន» (លូកា ២៤:២១)។ ពួកគេបាននឹកឃើញព្រះបន្ទូលរបស់ព្រះអង្គ ទាំងចិត្តឈឺចុកចាប់ និងមានភាពឯកោ។ «ព្រោះបើគេធ្វើការទាំងនេះ ដល់ដើមឈើស្រស់ នោះតើនឹងកើតអ្វីដល់ដើមឈើស្ងួតវិញ?» (លូកា ២៣:៣១)។

ព្រះយេស៊ូវបានប៉ុនប៉ងបើកបង្ហាញពីអនាគតប្រាប់ដល់ពួកសាវ័ករបស់ទ្រង់ជាច្រើនដង ប៉ុន្តែ ពួកគេមិនបានយកចិត្តទុកដាក់ទៅនឹងអ្វីដែលទ្រង់បានមានបន្ទូលនោះទេ។ ដោយសារហេតុនេះហើយបានជាការសុគតរបស់ទ្រង់បានកើតឡើងដល់គេហាក់ដូចជាការដែលគួរឲ្យភ្ញាក់ផ្អើល ហើយបន្ទាប់ពីនោះមក ពួកគេមានការសោកស្តាយជាខ្លាំង នៅពេលដែលពួកគេរំឭកពីអតីតកាលនិងបានឃើញពីលទ្ធផលនៃការមិនជឿរបស់ពួកគេ។ នៅពេលដែលព្រះគ្រិស្តត្រូវគេឆ្កាង ពួកគេមិនបានជឿថាព្រះអង្គនឹងមានព្រះជន្មរស់ឡើងវិញនោះទេ។ ព្រះអង្គបានមានបន្ទូលយ៉ាងច្បាស់ថា ព្រះអង្គនឹងមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី ប៉ុន្តែ ពួកគេវិលវល់មិនយល់ពីអ្វីដែលទ្រង់ចង់មានបន្ទូលនោះទេ។ កង្វះការយល់ដឹងនេះបានបន្សល់ទុកនូវភាពអស់សង្ឃឹមជាខ្លាំងដល់ពួកគេ នៅពេលដែលព្រះអង្គបានសុគត។ ពួកគេបានខកចិត្តយ៉ាងជូរចត់។ ជំនឿរបស់ពួកគេមិនបានឆ្លងផុតពីស្រមោលដែលសាតាំងបានលាតសន្ធឹងរហូតដល់ជើងមេឃរបស់ពួកគេនោះឡើយ។ អ្វីៗទាំងអស់ហាក់ដូចជាមានភាពស្រពិចស្រពិល និងអាថ៌កំបាំងចំពោះពួកគេ។ ប្រសិនបើពួកគេបានជឿតាមព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះពួកគេនឹងមានការព្រួយបារម្ភយ៉ាងតិចបំផុត!

ដោយគ្របដណ្តប់ដោយការខូចចិត្ត ទុក្ខព្រួយ និងការអស់សង្ឃឹម ពួកសាវ័កបានជួបប្រជុំគ្នានៅបន្ទប់ខាងលើ ហើយបិទទ្វារចាក់សោ ដោយភ័យខ្លាចក្រែងវាសនាអាក្រក់នៃលោកគ្រូរបស់ពួកគេនឹងធ្លាក់មកលើពួកគេដែរ។ គឺនៅទីនោះហើយដែលព្រះអង្គសង្គ្រោះបានលេចមកឲ្យពួកគេឃើញបន្ទាប់ពីព្រះអង្គមានព្រះជន្មរស់ឡើងវិញ ។

ព្រះគ្រិស្តបានគង់នៅលើផែនដីអស់សែសិបថ្ងៃ រៀបចំពួកសាវ័កឲ្យបំពេញកិច្ចការដែលនៅចំពោះមុខពួកគេ និងពន្យល់ដល់ពួកគេថា ចាប់ពីពេលនេះតទៅពួកគេអាចនឹងយល់បាន។ ព្រះអង្គបានមានបន្ទូលអំពីបទទំនាយ ទាក់ទងនឹងការយាងមករបស់ទ្រង់ ការបដិសេធន៍ទ្រង់ពីសំណាក់

សាសន៍យូដា និងការសុគតរបស់ទ្រង់ ដោយពន្យល់ថាចំណុចជាក់លាក់ទាំងឡាយនៃបទទំនាយនេះបានសម្រេចហើយ។ ព្រះអង្គបានមានបន្ទូលប្រាប់ពួកគេថាពួកគេត្រូវចាត់ទុកការសម្រេចបទទំនាយទាំងនេះថា ជាការធានាអះអាងនៃព្រះចេស្ដាដែលនឹងនៅជាមួយពួកគេ នៅក្នុងកិច្ចរបស់ពួកគេនៅពេលអនាគត។ «នោះទ្រង់ក៏បើកបំភ្លឺសតិស្មារតីគេ ឲ្យបានយល់ក្នុងគម្ពីរ» ទ្រង់មានព្រះបន្ទូលទៅគេថា «គឺសេចក្ដីនេះហើយ ដែលបានចែងទុកមក គឺថាព្រះគ្រិស្ដត្រូវរងទុក្ខលំបាក ហើយនៅថ្ងៃទីបីទ្រង់នឹងរស់ពីសុគតឡើងវិញ ហើយត្រូវឲ្យការប្រែចិត្ត និងសេចក្ដីប្រោសឲ្យរួចបានប្រកាសប្រាប់ដល់អស់ទាំងសាសន៍ ដោយនូវព្រះនាមទ្រង់ចាប់តាំងពីក្រុងយេរូសាឡិមទៅ»។ «អ្នករាល់គ្នាជាស្មរបន្ទាល់ពីការទាំងនេះ» (លូកា ២៤:៤៥-៤៨) ។

<u>សៅរ៍-២៧ មិថុនា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ១៨

**ខព្រះគម្ពីរប្រចាំសប្ដាហ៍:** *គឺដោយហេតុនោះ បានជាខ្ញុំរងទុក្ខទាំងនេះ តែខ្ញុំមិនខ្មាសទេ ដ្បិតខ្ញុំស្គាល់ព្រះដែលខ្ញុំបានជឿតាម ហើយខ្ញុំជឿពិតថា ទ្រង់អាចនឹងថែរក្សាបញ្ញើ ដែលខ្ញុំបានផ្ញើទុកនឹងទ្រង់ ដរាបដល់ថ្ងៃនោះឯង។ ធីម៉ូថេទី២ ១:១២*

នៅក្នុងអំឡុងពេលដែលព្រះគ្រិស្ដបានគង់នៅជាមួយនឹងពួកសាវ័កនេះ ពួកគេបានទទួលនូវបទពិសោធន៍ថ្មីៗជាច្រើន។ ខណៈដែលពួកគេបានឮព្រះជាម្ចាស់ជាទីស្រឡាញ់របស់ពួកគេពន្យល់ព្រះគម្ពីរនៅក្នុងពន្លឺនៃរឿងរ៉ាវទាំងឡាយដែលបានកើតឡើង នោះសេចក្ដីជំនឿរបស់ពួកគេទៅលើទ្រង់ត្រូវបានបង្កើតឡើងយ៉ាងពេញលេញ។ ពួកគេបានឈានដល់កន្លែងមួយដែលពួកគេអាចនិយាយថា «ដ្បិតខ្ញុំស្គាល់ព្រះដែលខ្ញុំបានជឿតាម» (ធីម៉ូថេទី២ ១:១២) ។ ពួកគេបានចាប់ផ្ដើមដឹងពីនិស្ស័យនិងទំហំនៃកិច្ចការរបស់ពួកគេ ដោយយល់ថាពួកគេត្រូវតែប្រកាសព្រះបន្ទូលនៃសេចក្ដីពិត

ដែលព្រះបានប្រទានដល់ពួកគេ។ ព្រឹត្តិការណ៍នៃព្រះជន្ម ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រិស្ត បទទំនាយស្តីពីព្រឹត្តិការណ៍ទាំងអស់នោះ អាថ៌កំបាំងនៃសេចក្តីសង្គ្រោះ ព្រះចេស្តារបស់ព្រះយេស៊ូវសម្រាប់ការអត់ឱនទោសអំពើបាប ជាការដែលពួកគេត្រូវធ្វើទីបន្ទាល់ និងត្រូវប្រាប់ដល់ពិភពលោកឲ្យបានដឹង។ ពួកគេត្រូវតែប្រកាសដំណឹងនៃសេចក្តីសុខសាន្តនិងសេចក្តីសង្គ្រោះ តាមរយៈការកែប្រែចិត្ត និងព្រះចេស្តារបស់ព្រះអង្គសង្គ្រោះ ។

មុននឹងយាងឡើងទៅកាន់ឋានសួគ៌ ព្រះគ្រិស្តបានប្រទានការត្រាស់បង្គាប់ដល់ពួកសាវ័ករបស់ទ្រង់។ ព្រះអង្គបានប្រាប់ដល់ពួកគេថាពួកគេត្រូវធ្វើជាអ្នកប្រតិបត្តិតាមបំណងព្រះហឫទ័យដែលទ្រង់បានទុកជាកេរ្តិ៍មរតកដល់ពិភពលោក ជាទ្រព្យសម្បត្តិនៃជីវិតអស់កល្ប ។ ព្រះអង្គបានមានបន្ទូលថា អ្នករាល់គ្នាបានឃើញជីវិតនៃការលះបង់របស់ខ្ញុំដើម្បីលោកិយហើយ ។ អ្នកបានឃើញកិច្ចការដែលខ្ញុំបានធ្វើដើម្បីសាសន៍អ៊ីស្រាអែលហើយ។ ហើយទោះបីជារាស្ត្ររបស់ខ្ញុំមិនបានចូលមកឯខ្ញុំដើម្បីឲ្យបានជីវិតក៏ដោយ ហើយទោះបីជាពួកសង្ឃនិងពួកមេដឹកនាំសាសនាបានប្រព្រឹត្តមកលើខ្ញុំ តាមចិត្តគេក៏ដោយ ទោះបីពួកគេបានបដិសេធខ្ញុំក៏ដោយ ក៏ពួកគេនៅតែមានឱកាសនឹងទទួលយកព្រះរាជបុត្រាម្តងទៀតដែរ ។ អ្នកបានឃើញថាអ្នកដែលមកឯខ្ញុំដើម្បីលន់តួបាបរបស់ពួកគេ ខ្ញុំនឹងទទួលពួកគេដោយសេរី ។ អ្នកណាដែលចូលមកឯខ្ញុំ ខ្ញុំនឹងមិនបោះបង់គេចោលឡើយ។ ចំណែកអ្នកឱពួកសាវ័ករបស់ខ្ញុំអើយ ខ្ញុំប្រគល់សារនៃសេចក្តីមេត្តាករុណាដល់ពួកអ្នក។ ដំណឹងនេះត្រូវប្រគល់ដល់ទាំងសាសន៍យូដា និងសាសន៍ដទៃពោលគឺដល់សាសន៍អ៊ីស្រាអែលមុនគេ បន្ទាប់មកដល់គ្រប់ទាំងសាសន៍ គ្រប់ភាសា និងគ្រប់មនុស្សទាំងអស់។ អស់អ្នកដែលជឿនឹងប្រមូលគ្នាមកកាន់ពួកជំនុំតែមួយ ។

ការត្រាស់បង្គាប់នៃដំណឹងល្អគឺជាធម្មនុញ្ញដ៏ធំនៃបេសកជនសម្រាប់នគររបស់ព្រះគ្រិស្ត ។ ពួកសាវ័កត្រូវតែធ្វើការដោយស្មោះអស់ពីចិត្តដើម្បី

មនុស្សលោក ដោយផ្តល់សេចក្តីអញ្ជើញនៃសេចក្តីមេត្តាករុណាដល់មនុស្ស ទាំងអស់ ។ ពួកគេមិនត្រូវរង់ចាំឲ្យមនុស្សមករកពួកគេទេ គឺពួកគេត្រូវតែ ចេញទៅជួបនឹងមនុស្សជាមួយនឹងសារនោះ ។

ពួកសាវ័កត្រូវតែបំពេញកិច្ចការរបស់ពួកគេឆ្ពោះទៅមុខ ក្នុងព្រះនាម របស់ព្រះគ្រិស្ត ។ រាល់ពាក្យសម្តីនិងសកម្មភាពរបស់ពួកគេ ត្រូវតែពង្រឹង ដល់ចំណាប់អារម្មណ៍របស់មនុស្សទៅលើព្រះនាមរបស់ទ្រង់ ជាទ្រព្យសម្បត្តិ ដែលមានអំណាចអស្ចារ្យសម្រាប់ជួយសង្គ្រោះបាបជន ។ ជំនឿរបស់ពួកគេ ត្រូវតែមានមូលដ្ឋាននៅលើព្រះដែលជាប្រភពនៃអំណាច និងសេចក្តីមេត្តា ករុណា។ ពួកគេត្រូវតែបង្ហាញគំនិតរបស់ពួកគេ ដល់ព្រះវរបិតា តាមរយៈ ព្រះនាមរបស់ទ្រង់ ហើយពួកគេនឹងទទួលចម្លើយតបមកវិញ ។ ពួកគេត្រូវ ទទួលបុណ្យជ្រមុជទឹកដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ។ ព្រះនាមរបស់ព្រះគ្រិស្តគឺជាបន្ទូលឃ្លាំមើលរបស់ពួក គេ ជាត្រាសម្គាល់របស់ពួកគេ ជាចំណងមេត្រីភាព ជាអំណាចគ្រប់គ្រង នៃសកម្មភាព និងជាប្រភពនៃជោគជ័យរបស់ពួកគេ ។ គ្មានអ្វីនៅក្នុងនគរ របស់ទ្រង់ដែលគេស្គាល់ថាមិនមានព្រះនាម និងនិមិត្តរូប របស់ទ្រង់ឡើយ។

នៅពេលព្រះគ្រិស្តមានបន្ទូលទៅកាន់ពួកសាវ័កឲ្យបោះជំហានទៅ មុខនៅក្នុងព្រះនាមរបស់ខ្ញុំ ដើម្បីប្រមូលអ្នកដែលមានជំនឿឲ្យចូលមកក្នុង ពួកជំនុំ ព្រះអង្គបានបង្ហាញយ៉ាងច្បាស់នៅពីមុខពួកគេ អំពីភាពចាំបាច់នៃ ការរក្សាភាពសាមញ្ញ។ ពួកគេមិនត្រូវមានភាពក្អេងក្អាង និងភាពសម្ញឹង ឡើយ តែត្រូវមានឥទ្ធិពលនៃការល្អដ៏ធំធេងវិញ។ ពួកសាវ័កត្រូវតែនិយាយ សម្តីសុភាពរាបសា ដូចជាព្រះគ្រិស្តធ្លាប់បានមានបន្ទូលដូច្នោះដែរ។ ពួកគេ ត្រូវតែផ្ចិតនូវមេរៀនដែលព្រះអង្គបានបង្រៀនដល់ពួកគេ នៅក្នុងចិត្តមនុស្ស ទាំងឡាយ។

ព្រះគ្រិស្តមិនបានប្រាប់ដល់សាវ័ករបស់ព្រះអង្គថា កិច្ចការរបស់ពួក គេគឺជាកិច្ចការដែលងាយស្រួលនោះទេ។ ពួកគេនឹងត្រូវតយុទ្ធជាមួយ «នឹង ពួកគ្រប់គ្រង ពួកមានអំណាច និងពួកម្ចាស់នៃសេចក្តីងងឹតនៅលោកិយនេះ

វិញ ហើយទាស់នឹងអំណាចអាក្រក់ខាងវិញ្ញាណ នៅឋានដ៏ខ្ពស់ដែរ» (អេភេសូរ ៦:១២) ។ ប៉ុន្តែ ព្រះអង្គមិនបានទុកឲ្យពួកគេប្រយុទ្ធតែម្នាក់ឯង នោះឡើយ ។ ព្រះអង្គបានបញ្ជាក់ប្រាប់ពួកគេថា ទ្រង់នឹងគង់នៅជាមួយ ពួកគេ ហើយប្រសិនបើពួកគេបោះជំហានទៅមុខដោយសេចក្តីជំនឿ ពួកគេ នឹងធ្វើដំណើរនៅក្រោមខែលដ៏មានសព្វានុភាព។ ព្រះអង្គបានអង្វរករឲ្យពួក គេក្លាហាននិងមានកម្លាំងឡើង ព្រោះព្រះមួយអង្គដែលខ្លាំងជាងពួកទេវតា ជាមេទ័ពនៃនគរឋានសួគ៌ នឹងគង់នៅជាមួយពួកគេ។ ព្រះអង្គបានត្រៀមបម្រុងគ្រប់យ៉ាងសម្រាប់ទប់ទល់នឹងការបៀតបៀនទាស់នឹងកិច្ចការរបស់ពួកគេ ហើយនិងទទួលខុសត្រូវចំពោះជោគជ័យដោយព្រះអង្គផ្ទាល់។ ដរាបណា ពួកគេនៅតែស្តាប់តាមព្រះបន្ទូលរបស់ទ្រង់ ហើយធ្វើការដោយភ្ជាប់ទំនាក់ ទំនងជាមួយនឹងព្រះអង្គ ពួកគេនឹងមិនបរាជ័យឡើយ។ ព្រះអង្គបានត្រាស់ បង្គាប់ឲ្យពួកគេចេញទៅដល់មនុស្សគ្រប់ទាំងសាសន៍។ ចូរចេញទៅកន្លែង ឆ្ងាយបំផុតនៃផែនដី ហើយដឹងឲ្យច្បាស់ថាវត្តមានរបស់ខ្ញុំនឹងនៅទីនោះ ជាមួយអ្នកជានិច្ច។ ចូរធ្វើការដោយជំនឿនិងទំនុកចិត្តចុះ ព្រោះនឹងមិនមាន ពេលណាដែលខ្ញុំនឹងបោះបង់អ្នកចោលឡើយ។ ខ្ញុំនឹងនៅជាមួយអ្នកជានិច្ច ដោយជួយអ្នកក្នុងការបំពេញភារកិច្ចរបស់អ្នក ដោយដឹកនាំកម្សាន្តចិត្ត រាប់អ្នក សុចរិត ទ្រទ្រង់អ្នក និងផ្តល់ជោគជ័យដល់អ្នកឲ្យនិយាយពាក្យពេចន៍ដែល នឹងទាក់ទាញចិត្តមនុស្សដទៃឲ្យចាប់អារម្មណ៍ទៅនឹងឋានសួគ៌។

**<u>អាទិត្យ-២៨ មិថុនា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ១៩**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំង សាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ ហើយបង្រៀន ឲ្យគេកាន់តាមគ្រប់ ទាំងសេចក្តី ដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង ហើយមើល ខ្ញុំក៏នៅជាមួយ នឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរ ដរាបដល់បំផុតកល្ប។ ម៉ាថាយ ២៨:១៩-២០*

ការលះបង់របស់ព្រះគ្រិស្តជំនួសមនុស្សបានសម្រេចពេញលេញហើយ។ លក្ខខណ្ឌនៃការប្រោសលោះឲ្យផុតនឹងបាបរបស់មនុស្សបានសម្រេចហើយ។ កិច្ចការដែលទ្រង់បានយាងមកកាន់ផែនដីនេះត្រូវបានបំពេញរួចរាល់អស់ហើយ។ ទ្រង់មានជ័យជម្នះលើនគររបស់ទ្រង់ហើយ។ ទ្រង់បានដណ្ដើមនគរលោកិយនេះពីសាតាំងមកវិញ ហើយអ្វីៗទាំងអស់បានក្លាយជារបស់ពួកគេ ( ពួកសាវ័ក) វិញហើយ។ ព្រះកំពុងយាងទៅឯបល្ល័ង្ករបស់ព្រះ ដើម្បីទទួលការលើកតម្កើងពីពួកទេវតានៃឋានសួគ៌ ។ ប្រដាប់អង្គដោយអំណាចដ៏គ្មានព្រំដែន ព្រះអង្គបានត្រាស់បង្គាប់ដល់ពួកសាវ័ករបស់ទ្រង់ថា «ដូច្នេះចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាមព្រះវរបិតាព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ ហើយបង្រៀនឲ្យគេកាន់តាមគ្រប់ទាំងសេចក្ដី ដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង ហើយមើល ខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរដរាបដល់បំផុតកល្ប» (ម៉ាថាយ ២៨:១៩, ២០) ។

មុននឹងចាកចេញពីសាវ័ករបស់ព្រះអង្គ ព្រះគ្រិស្តបានប្រកាសយ៉ាងច្បាស់អំពីនគររបស់ទ្រង់ម្ដងទៀត។ ព្រះអង្គបានរំឭកដល់ពួកគេអំពីអ្វីដែលព្រះអង្គធ្លាប់បានមានបន្ទូលពីនគរនោះ។ ទ្រង់បានប្រកាសថាគោលបំណងរបស់ទ្រង់មិនមែនបង្កើតនគរបណ្ដោះអាសន្ននៅលើផែនដីនេះទេ។ ព្រះវរបិតាមិនបានតែងតាំងព្រះអង្គឲ្យយាងមកសោយរាជ្យនៅលើបល្ល័ង្ករបស់ស្ដេចដាវីឌទេ។ នៅពេលពួកសាវ័កបានសួរព្រះអង្គថា «ព្រះអម្ចាស់អើយតើនៅគ្រានេះឬអី ដែលទ្រង់នឹងតាំងនគរឲ្យសាសន៍អ៊ីស្រាអែលឡើងវិញនោះ» (កិច្ចការ ១:៦, ៧) ។ ពួកគេមិនចាំបាច់សម្លឹងមើលទៅអនាគតដ៏វែងឆ្ងាយ ក្រៅពីការបើកសម្ដែងដែលព្រះបានបង្ហាញឲ្យពួកគេមើលឃើញនោះឡើយ ។ កិច្ចការរបស់ពួកគេគឺប្រកាសផ្សាយដំណឹងល្អ ។

ព្រះវរបិតារៀបនឹងដកយកព្រះវត្តមានរបស់ព្រះគ្រិស្ត ដែលមនុស្សអាចមើលឃើញចេញពីពួកសាវ័ករបស់ទ្រង់ហើយ ប៉ុន្តែ ទយ្យទានជាអំណាច

ថ្មីមួយបានក្លាយជារបស់ពួកគេ ។ ព្រះវរបិតានឹងប្រទានព្រះវិញ្ញាណបរិសុទ្ធដល់ពួកគេក្នុងលក្ខណៈពេញលេញ បោះត្រាពួកគេឲ្យបំពេញកិច្ចការរបស់ខ្លួន។ ព្រះអង្គសង្គ្រោះបានមានបន្ទូលថា «ហើយមើល ខ្ញុំនឹងឲ្យសេចក្តីសន្យារបស់ព្រះវរបិតា មកសណ្ឋិតលើអ្នករាល់គ្នា ចូរអ្នករាល់គ្នានៅតែក្នុងក្រុងយេរូសាឡិម ដរាបដល់ព្រះចេស្តាពីឋានលើបានមកគ្របដណ្តប់លើអ្នករាល់គ្នា» (លូកា ២៤:៤៩)។ «ដ្បិតពិតជាលោកយ៉ូហានបានធ្វើបុណ្យជ្រមុជដោយទឹក ប៉ុន្តែ នៅបន្តិចទៀត អ្នករាល់គ្នានឹងទទួលបុណ្យជ្រមុជ ដោយព្រះវិញ្ញាណបរិសុទ្ធវិញ»។ «ប៉ុន្តែ កាលណាព្រះវិញ្ញាណបរិសុទ្ធបានមកសណ្ឋិតលើអ្នករាល់គ្នា នោះអ្នករាល់គ្នានឹងបានព្រះចេស្តា ហើយនិងធ្វើជាទីបន្ទាល់ពីខ្ញុំ នៅក្រុងយេរូសាឡិម ព្រមទាំងស្រុកយូដា និងស្រុកសាម៉ារីទាំងមូល ហើយរហូតដល់ចុងផែនដីបំផុតផង» (កិច្ចការ ១:៥, ៨)។

ព្រះអង្គបានជ្រាបថាគ្មានការតវ៉ាណា ទោះជាសមហេតុផលយ៉ាងណាក៏ដោយដែលអាចបំបែកចិត្តរឹង ឬអាចទម្លុះចូលទៅក្នុងស្រទាប់នៃភាពលោកិយ និងភាពអាត្មានិយមបានឡើយ  ព្រះអង្គបានជ្រាបថាពួកសាវ័ករបស់ទ្រង់ត្រូវតែទទួលអំណោយទានពីឋានសួគ៌ ទ្រង់ក៏បានជ្រាបផងដែរថា នៅពេលដែលពួកគេប្រកាសផ្សាយដោយចិត្តដែលត្រូវបានធ្វើឲ្យមានភាពកក់ក្តៅ និងដោយបបូរមាត់ដែលបានបង្កើតឲ្យមានវោហាសាស្ត្រ ដោយចំណេះដឹងដ៏រស់របស់ព្រះដែលជាផ្លូវ ជាជីវិត និងជាសេចក្តីពិត ប៉ុណ្ណោះនោះកិច្ចការរបស់ពួកគេនឹងមានប្រសិទ្ធិភាពជាក់ជាមិនខាន។ កិច្ចការដែលព្រះបានប្រទានដល់ពួកសាវ័ក តម្រូវឲ្យមានផលផ្លែដ៏ជាទីគាប់ចិត្ត ដ្បិតអីជំនោររបស់អារក្សបោកបក់ប្រឆាំងមកលើពួកគេយ៉ាងខ្លាំង។ មេដឹកនាំដែលមានការប្តេជ្ញាចិត្តយ៉ាងប្រុងប្រយ័ត្ននោះកំពុងបញ្ជាកងកម្លាំងនៃសេចក្តីងងឹត ហើយពួកសិស្សរបស់ព្រះគ្រិស្តអាចប្រយុទ្ធដណ្តើមជ័យជម្នះនៃភាពត្រឹមត្រូវបាន លុះត្រាណាតែដោយសារជំនួយដែលព្រះអង្គនឹងប្រទានដល់ពួកគេ តាមរយៈព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ ។

ព្រះគ្រិស្តបានប្រាប់ដល់ពួកសាវ័ករបស់ទ្រង់ថា ពួកគេត្រូវចាប់ផ្តើមកិច្ចការរបស់ពួកគេនៅទីក្រុងយេរូសាឡិម។ មនុស្សនៅក្នុងទីក្រុងនោះបានដឹងអំពីការជាប់ឆ្កាងជំនួសមនុស្សជាតិ ដ៏អស្ចារ្យរបស់ទ្រង់។ នៅទីនោះ ព្រះអង្គបានយាងនិងបានមានបន្ទូលជាមួយនឹងមនុស្សលោកនៅក្នុងសម្លៀកបំពាក់ជាមនុស្ស ហើយមនុស្សមួយចំនួនបានមើលឃើញការមកដល់នៃនគរឋានសួគ៌មកកាន់ផែនដី នៅជិតបង្កើយ។ នៅទីនោះ ព្រះអង្គត្រូវបានគេថ្កោលទោស និងបានយកទៅឆ្កាង។ នៅទីក្រុងយេរូសាឡិម មានមនុស្សជាច្រើនបានជឿជាសម្ងាត់ថា ព្រះយេស៊ូវពីស្រុកណាសារ៉ែត គឺជាព្រះមែស៊ីហើយមានមនុស្សជាច្រើនដែលត្រូវបានបោកបញ្ឆោតដោយពួកសង្ឃនិងពួកមេដឹកនាំសាសនា។ ដំណឹងល្អត្រូវតែប្រកាសប្រាប់ដល់ពួកមនុស្សទាំងអស់នេះ។ ត្រូវតែប្រកាសហៅឲ្យពួកគេកែប្រែចិត្ត។ សេចក្តីពិតដ៏អស្ចារ្យដែលមានតែតាមរយៈព្រះគ្រិស្តមួយប៉ុណ្ណោះ ដែលមនុស្សអាចទទួលការអត់ទោសបាប ត្រូវតែប្រកាសផ្សាយឲ្យបានច្បាស់។ ហើយខណៈដែលមនុស្សទាំងអស់នៅក្នុងទីក្រុងយេរូសាឡិមកំពុងពុះកញ្ជ្រោលដោយព្រឹត្តិការណ៍ដ៏គួរឲ្យរន្ធត់កាលពីពីរបីសប្តាហ៍មុន នោះពួកសាវ័កបានធ្វើឲ្យពួកគេមានការរំភើបយ៉ាងជ្រាលជ្រៅ ។

**<u>ច័ន្ទ-២៩ មិថុនា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ២០**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *បើខ្ញុំទៅរៀបកន្លែងឲ្យអ្នករាល់គ្នា នោះខ្ញុំនឹងត្រឡប់មកវិញ នឹងទទួលអ្នករាល់គ្នាទៅឯខ្ញុំ ប្រយោជន៍ឲ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅនោះដែរ។ យ៉ូហាន ១៤:៣*

នៅក្នុងអំឡុងពេលបំពេញព្រះរាជកិច្ចរបស់ព្រះអង្គ ព្រះយេស៊ូវតែងតែប្រាប់ដល់ពួកសិស្សរបស់ព្រះអង្គជាបន្តបន្ទាប់អំពីរឿងរ៉ាវដែលថាពួកគេត្រូវតែរួបរួមជាផ្តុងមួយ ជាមួយនឹងព្រះអង្គ នៅក្នុងកិច្ចការស្តារពិភពលោកចេញពីទាសករនៃអំពើបាប។ នៅពេលដែលព្រះបានចាត់ពួកសិស្សទាំង

ដប់ពីរនាក់ បន្ទាប់មកពួកចិតសិបនាក់ ឲ្យទៅប្រកាសផ្សាយអំពីនគររបស់ព្រះ ព្រះអង្គបានកំពុងបង្រៀនដល់ពួកគេអំពីភារកិច្ចរបស់ពួកគេ ដែលនឹងត្រូវចែករំលែកពីអ្វីដែលពួកគេបានរៀនពីព្រះអង្គ ជាមួយនឹងមនុស្សដទៃ ។ នៅក្នុងកិច្ចការទាំងអស់របស់ទ្រង់ ព្រះអង្គបានបង្ហាត់បង្រៀនដល់ពួកគេឲ្យចេះធ្វើការដោយខ្លួនឯងឲ្យបង្រៀនបន្តដល់អ្នកដទៃ នៅពេលដែលពួកគេមានចំនួនកើនកាន់តែច្រើនឡើង ហើយទីបំផុត ឈានទៅដល់ចុងបំផុតនៃផែនដី។ មេរៀនចុងក្រោយបង្អស់ដែលទ្រង់បានបង្រៀនដល់ពួកសិស្សរបស់ទ្រង់នោះគឺថា ពួកគេត្រូវបង្ហាញពីដំណឹងនៃសេចក្តីសង្គ្រោះដ៏រីករាយដល់ពិភពលោកទាំងមូល។

លុះដល់ពេលដែលព្រះគ្រិស្តត្រូវឡើងទៅឯព្រះវរបិតាទ្រង់វិញ ព្រះអង្គបានដឹកនាំពួកសិស្សចេញទៅរហូតដល់ភូមិបេថានី។ នៅទីនោះ ព្រះអង្គក៏បានឈប់សម្រាក ហើយពួកគេក៏បានឈរព័ទ្ធជុំវិញទ្រង់។ ព្រះអង្គបានយាងចាកចេញពីពួកគេ ដោយលើកព្រះហស្តប្រទានព្រះពរ ជាការធានាអះអាងពីការថែរក្សាការពាររបស់ទ្រង់។ «កំពុងដែលទ្រង់ប្រទានពរ នោះព្រះវរបិតាបានញែកទ្រង់ចេញពីគេ លើកឡើងទៅឋានសួគ៌ទៅ» (លូកា ២៤:៥១) ។

នៅពេលដែលពួកសាវ័កកំពុងសម្លឹងទៅលើ ដើម្បីមើលព្រះជាម្ចាស់ដែលកំពុងយាងឡើងទៅលើ ជាគ្រាចុងក្រោយបង្អស់នោះ ពួកទេវតានៃឋានសួគ៌បានទទួលទ្រង់ដោយអំណរ ខណៈដែលពួកទេវតាបានហែហមទ្រង់យាងចូលទៅក្នុងព្រះរាជវាំងនៅឋានលើ ពួកលោកបានច្រៀងដោយជោគជ័យថា «អស់ទាំងនគរនៅផែនដីអើយ ចូរច្រៀងថ្វាយព្រះ ឱចូរច្រៀងសរសើរដល់ព្រះអម្ចាស់ចុះ គឺដល់ព្រះដែលទ្រង់យាងលើផ្ទៃមេឃនៃអស់ទាំងជាន់ផ្ទៃមេឃ ដ៏នៅតាំងពីបុរាណមក ន៍ ទ្រង់បញ្ចេញព្រះសូរសៀងគឺជាសំនៀងដ៏ខ្លាំងក្រៃលែង ចូរសរសើរថា ព្រះទ្រង់មានព្រះចេស្តាឫទ្ធានុភាពនៃទ្រង់គ្របលើសាសន៍អ៊ីស្រាអែល ហើយព្រះចេស្តាទ្រង់ក៏នៅលើផ្ទៃមេឃ»

( ទំនុកតម្កើង ៦៨:៣២-៣៤) ។

ពួកសិស្សនៅតែសម្លឹងមិនដាក់ភ្នែក ឆ្ពោះទៅឋានសួគ៌ នៅពេលដែល «ឃើញមានពីរនាក់ ស្លៀកពាក់សឈរនៅជិត និយាយថា ពួកអ្នកស្រុកកាលីឡេអើយ ហេតុអ្វីបានជាឈរងើយមើលទៅលើមេឃដូច្នេះ ព្រះយេស៊ូវនេះឯង ដែលព្រះបានលើកពីអ្នករាល់គ្នាឡើងទៅលើឋានសួគ៌ ទ្រង់នឹងយាងមកវិញ តាមបែបដដែល ដូចជាអ្នករាល់គ្នាបានឃើញទ្រង់ទៅនោះដែរ» (កិច្ចការ ១:១០, ១១) ។

សេចក្តីសន្យានៃការយាងមកវិញជាលើកទីពីររបស់ព្រះគ្រិស្ត ដក់ជាប់នៅថ្មីៗជានិច្ច នៅក្នុងចិត្តនៃពួកសិស្សរបស់ព្រះអង្គ។ ព្រះយេស៊ូវដដែល ដែលអ្នករាល់គ្នាបានឃើញទ្រង់យាងឡើងទៅឋានសួគ៌នេះ ទ្រង់នឹងយាងមកវិញ ដើម្បីនឹងយកអស់អ្នកណាដែលនៅលើផែនដី ហើយបានប្រគល់ខ្លួនគេដើម្បីបំពេញព្រះរាជកិច្ចរបស់ព្រះអង្គ។ ជាសំឡេងដដែល ដែលធ្លាប់បាននិយាយជាមួយនឹងពួកគេថា «មើល ខ្ញុំនឹងនៅជាមួយនឹងអ្នករាល់គ្នាដរាបដល់បំផុតកល្ប» បានជំរុញដល់ពួកគេឲ្យស្វាគមន៍ព្រះវត្តមានរបស់ទ្រង់នៅនគរឋានសួគ៌។

ព្រះគ្រិស្តបានដោះព្រះពស្ត្ររាជ្យរបស់ទ្រង់ចេញ ហើយប្រដាប់អង្គជាមួយមនុស្សលោក រួចថ្វាយតង្វាយយញ្ញបូជា ដែលព្រះអង្គដើរតួជាសម្តេចសង្ឃផង និងជាតង្វាយយញ្ញបូជាផង ដូចជាពួកសង្ឃដែលជានិមិត្តរូប បានដោះសម្លៀកជាសង្ឃរបស់លោកចេញ ហើយពាក់អាវខ្លូតទេសពណ៌សរបស់លោកហើយប្រារព្ធពិធីថ្វាយតង្វាយដុតដែរ។ ព្រះអង្គគឺជាសម្តេចសង្ឃ ហើយព្រះអង្គគឺជាតង្វាយដុតដោយផ្ទាល់។ ដូចជាសម្តេចសង្ឃចេញមកជួបនឹងក្រុមជំនុំដែលរង់ចាំដោយសម្លៀកបំពាក់ជាសង្ឃដែរ ព្រះគ្រិស្តក៏នឹងយាងមកជាលើកទីពីរ ដោយសម្លៀកបំពាក់សភ្លឺត្រចះត្រចង់ «ដែលគ្មានមនុស្សណានៅលើផែនដីអាចធ្វើឲ្យសយ៉ាងនេះបានឡើយ» ដែរ ( ម៉ាកុស ៩:៣) (គម្ពីរភាសាខ្មែរបច្ចុប្បន្ន)។ ព្រះអង្គនឹងយាងដោយសិរីល្អរបស់ទ្រង់

និងក្នុងសិរីល្អរបស់ព្រះវរបិតា ហើយពពួកទេវតានឹងហែហមទ្រង់តាមផ្លូវរបស់ទ្រង់ ។

នេះគឺជាការសម្រេចតាមសេចក្តីសន្យារបស់ព្រះគ្រិស្ត ដែលព្រះអង្គបានសន្យាជាមួយនឹងពួកសាវ័ករបស់ទ្រង់ថា «បើខ្ញុំទៅរៀបកន្លែងឲ្យអ្នករាល់គ្នា នោះខ្ញុំនឹងត្រឡប់មកវិញ នឹងទទួលអ្នករាល់គ្នាទៅឯខ្ញុំ ប្រយោជន៍ឲ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅនោះដែរ» (យ៉ូហាន ១៤:៣)។ អស់អ្នកណាដែលបានស្រឡាញ់ទ្រង់ និងបានរង់ចាំទ្រង់ ព្រះអង្គនឹងបំពាក់មកុដជាមួយនឹងសិរីល្អនិងកិត្តិយស ព្រមទាំងភាពមិនចេះស្លាប់ផង។ ពួកអ្នកសុចរិតដែលបានស្លាប់ទៅ នឹងរស់ឡើងវិញ ចេញពីផ្នូរ ហើយអស់អ្នកដែលនៅរស់នឹងត្រូវលើកឡើងទៅជួបជាមួយនឹងព្រះជាម្ចាស់នៅនាអាកាសទាំងអស់គ្នា។ ពួកគេនឹងឮព្រះសូរសៀងរបស់ព្រះគ្រិស្ទ ដែលពីរោះជាងសំឡេងតូរ្យតន្ត្រីដែលត្រចៀករបស់មនុស្សមិនធ្លាប់បានឮ មានបន្ទូលមកកាន់ពួកគេ។ កិច្ចការរបស់អ្នកត្រូវបានបញ្ចប់ហើយ។ «ឱពួកអ្នកដែលព្រះវរបិតាយើងបានប្រទានពរអើយ ចូរមកទទួលមរតកចុះ គឺជានគរដែលបានរៀបចំទុកសម្រាប់អ្នករាល់គ្នា តាំងពីកំណើតលោកិយមក» ( ម៉ាថាយ ២៥:២៤) ។

មែនហើយ ពួកសាវ័កមានអំណរនៅក្នុងសេចក្តីសង្ឃឹមនៃការយាងត្រឡប់មកវិញរបស់ព្រះជាម្ចាស់។

ជំពូកទី
៤

# ថ្ងៃបុណ្យថ្ងៃប៉ង់តាកូស

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ២:១-៣៩។*

**<u>អង្គារ-៣០ មិថុនា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ២១**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *នៅថ្ងៃនោះ អ្នករាល់គ្នានឹងមិនសូមអ្វីពីខ្ញុំទៀត ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្វីៗ ដែលអ្នករាល់គ្នានឹងសូមដល់ព្រះវរបិតា ដោយនូវឈ្មោះខ្ញុំ នោះទ្រង់នឹងប្រទានឲ្យ។ យ៉ូហាន ១៦:២៣*

ខណៈដែលពួកសាវ័កបានវិលត្រឡប់ពីភ្នំដើមអូលីវ មកកាន់ទីក្រុងយេរូសាឡិមវិញ ពួកបណ្តាជនបានសម្លឹងមើលមុខពួកគេ ដោយសង្ឃឹមថានឹងបានឃើញទឹកមុខក្រៀមក្រំច្របូកច្របល់និងបរាជ័យរបស់ពួកគេ ប៉ុន្តែពួកគេបានឃើញភាពរីករាយ និងជោគជ័យទៅវិញ ពួកសិស្សមិនបានទួញសោកចំពោះសេចក្តីសង្ឃឹមដែលខកចិត្តនេះឡើយ។ ពួកគេបានឃើញព្រះអង្គសង្គ្រោះយាងឡើងទៅ និងបានឮព្រះបន្ទូលសន្យាចុងក្រោយនៃព្រះអង្គសង្គ្រោះ នៅជាប់នឹងត្រចៀករបស់ពួកគេជានិច្ច ។

ដោយស្តាប់បង្គាប់ដល់ការត្រាស់បង្គាប់របស់ព្រះគ្រិស្ត ពួកគេបានរង់ចាំនៅទីក្រុងយេរូសាឡិម តាមសេចក្តីសន្យារបស់ព្រះវរបិតាស្តីពីការចាក់ប្រទានព្រះវិញ្ញាណបរិសុទ្ធមក។ ពួកគេមិនបានរង់ចាំដោយភាពខ្ជិលច្រអូសទេ។ ព្រះគម្ពីរបានចែងថា «ក៏នៅក្នុងព្រះវិហារជានិច្ចទាំងសរសើរ ហើយលើកតម្កើងព្រះ» (លូកា ២៤:៥៣)។ ពួកគេបានប្រជុំគ្នាដើម្បីទូលថ្វាយសំណូមពររបស់ពួកគេទៅព្រះវរបិតា នៅក្នុងព្រះនាមព្រះយេស៊ូវ។ ពួកគេបានដឹងថាពួកគេមានព្រះដែលជាតំណាងរបស់ពួកគេនៅឋានសួគ៌ និងជាមេធាវីនៅចំពោះព្រះរាជបល្ល័ង្ករបស់ព្រះ។ ពួកគេបានឱនក្រាបដោយការ

ស៊ើចសរសើរជាខ្លាំង ដោយការអធិដ្ឋាន និងរំឮកពីការធានាអះអាងម្ដង ហើយម្ដងទៀតថា «អ្នករាល់គ្នានឹងមិនសូមអ្វីពីខ្ញុំទៀតប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្វីៗដែលអ្នករាល់គ្នានឹងសូមដល់ព្រះវរបិតា ដោយនូវឈ្មោះខ្ញុំ នោះទ្រង់នឹងប្រទានឲ្យ» (យ៉ូហាន ១៦:២៣, ២៤)។ ពួកគេបានពង្រីកដៃនៃសេចក្ដីជំនឿរបស់ពួកគេខ្ពស់ឡើងៗ ជាមួយនឹងពាក្យធានាអះអាងដ៏មានអំណាច «តើអ្នកណានឹងកាត់ទោសគេបាន ដ្បិតព្រះគ្រិស្ដទ្រង់បានសុគតជំនួសគេហើយ តែដែលថា ទ្រង់រស់ឡើងវិញ នោះមានទំនងជាងទ្រង់ក៏គង់នៅខាងស្តាំនៃព្រះ ហើយជាអ្នកអង្វរជំនួសយើងរាល់គ្នាដែរ» (រ៉ូម ៨:៣៤) ។

នៅពេលដែលពួកសិស្សបានរង់ចាំការសម្រេចតាមព្រះបន្ទូលសន្យានោះ ពួកគេបានបន្ទាបចិត្តដោយការកែប្រែយ៉ាងពិតប្រាកដ និងលន់តួកំហុសនៃការមិនជឿរបស់ពួកគេ ។ នៅពេលដែលពួកគេរំឮកពីព្រះបន្ទូលដែលព្រះគ្រិស្ដបានមានបន្ទូល មុនពេលព្រះអង្គសុគត ពួកគេបានយល់ពីអត្ថន័យនៃព្រះបន្ទូលនោះកាន់តែច្បាស់។ សេចក្ដីពិតដែលបានកន្លងផុតពីការចងចាំរបស់ពួកគេទៅនោះ ត្រូវបាននាំត្រឡប់មកកាន់គំនិតរបស់ពួកគេជាថ្មីឡើងវិញ ហើយពួកគេក៏បាននិយាយអំពីសេចក្ដីពិតនេះប្រាប់គ្នាទៅវិញទៅមក ម្ដងហើយម្ដងទៀត។ ពួកគេស្ដីបន្ទោសខ្លួនឯង ដោយសារការយល់ខុសរបស់ពួកគេទៅលើព្រះអង្គសង្គ្រោះ។ រូបភាពនៃព្រះជន្មដ៏អស្ចារ្យរបស់ទ្រង់បានរសាត់នៅមុខពួកគេម្ដងហើយម្ដងទៀត ដូចជាក្បួនដង្ហែ នៅពេលដែលពួកគេបានសញ្ជឹងគិតអំពីភាពបរិសុទ្ធរបស់ទ្រង់ ជាព្រះជន្មបរិសុទ្ធ ពួកគេបានដឹងថាគ្មានការវេទនាណាដែលពិបាកពេកឡើយ ក៏គ្មានការលះបង់ណាដែលធំពេកដែរ ប្រសិនបើពួកគេគ្រាន់តែធ្វើទីបន្ទាល់ពីភាពគួរឲ្យស្រឡាញ់នៃអត្តចរិតរបស់ព្រះគ្រិស្ដ នៅក្នុងជីវិតរបស់ពួកគេតែប៉ុណ្ណោះ ។ ពួកគេបានគិតថា អូប្រសិនបើពួកគេអាចរស់នៅក្នុងរយៈពេលបីឆ្នាំដដែលបានកន្លងផុតទៅនេះម្ដងទៀត មិនដឹងជាពួកគេប្រព្រឹត្តខុសពីមុនយ៉ាងណាទេ! ប្រសិនបើពួកគេអាចជួបនឹងព្រះជាម្ចាស់របស់ពួកគេម្ដងទៀត នោះពួក

គេនឹងខំប្រឹងប្រែងបង្ហាញដល់ទ្រង់ពីជម្រៅនៃសេចក្ដីស្រឡាញ់របស់ពួកគេចំពោះទ្រង់ និងពីការសោកស្ដាយអស់ពីចិត្ត ដោយបានធ្វើឲ្យព្រះអង្គព្រួយព្រះទ័យព្រោះតែពាក្យសម្ដី និងសកម្មភាពដែលមិនជឿរបស់ពួកគេ! ប៉ុន្ដែគំនិតដែលថាព្រះបានអត់ទោសឲ្យអំពើបាបរបស់ពួកគេ បានកម្សាន្ដ ចិត្តដល់ពួកគេហើយពួកគេបានប្ដេជ្ញាចិត្តថាពួកគេនឹងលុបលាងការមិនជឿរបស់ពួកគេនេះដោយលន់តួចំពោះទ្រង់ដោយក្លាហាននៅចំពោះពិភពលោកនេះ ឲ្យបានខ្លាំងក្លាជាទីបំផុត ។

ពួកសាវ័កបានអធិដ្ឋានដោយចេតនាស្មោះស្ម័គ្រ សុំឱកាសឲ្យបានជួបនឹងមនុស្ស និងឲ្យបាននិយាយពាក្យពេចន៍ដែលនាំមនុស្សមានបាបមកឯព្រះគ្រិស្ដ នៅក្នុងទំនាក់ទំនងប្រចាំថ្ងៃរបស់ពួកគេ។ ដោយដកយកចេញនូវរាល់ភាពខុសគ្នាទាំងអស់ សេចក្ដីប្រាថ្នាឲ្យបានខ្ពស់លើសគេទាំងអស់ពួកគេបានចូលមកជិតគ្នា ដោយការប្រកបគ្នាជាគ្រិស្ដបរិស័ទ។ ពួកគេបានខិតចូលទៅជិតព្រះកាន់តែកៀកឡើងៗហើយនៅពេលដែលពួកគេធ្វើដូច្នោះពួកគេបានដឹងពីកិត្តិយសដ៏ឧត្ដុង្គឧត្ដមរបស់ពួកគេ ដែលព្រះបានអនុញ្ញាតឲ្យពួកគេប្រស្រ័យទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងព្រះគ្រិស្ដ។ ភាពក្រៀមក្រំបានបំពេញចិត្តរបស់ពួកគេ ខណៈដែលពួកគេបានគិតអំពីពេលវេលាដែលពួកគេបានធ្វើឲ្យទ្រង់កើតទុក្ខជាច្រើនដង ដោយសារភាពយឺតយ៉ាវក្នុងការយល់ពីព្រះបន្ទូលរបស់ទ្រង់ ការបរាជ័យមិនបានយល់ពីមេរៀនទាំងឡាយ ដែលព្រះអង្គបានព្យាយាមបង្រៀនដល់ពួកគេសម្រាប់សេចក្ដីល្អ ។

ថ្ងៃនៃការរៀបចំណោះ គឺជាថ្ងៃនៃការស្វែងយល់ពីទឹកចិត្តយ៉ាងជ្រាលជ្រៅ។ ពួកសាវ័កបានដឹងអំពីសេចក្ដីត្រូវការខាងព្រលឹងវិញ្ញាណរបស់ពួកគេហើយបានស្រែកអំពាវនាវឲ្យព្រះដុសខាត់ពួកគេដើម្បីតម្រូវឲ្យស្របទៅនឹងកិច្ចការសង្គ្រោះមនុស្ស។ ពួកគេមិនបានសុំព្រះពរសម្រាប់តែខ្លួនឯងប៉ុណ្ណោះទេ។ ពួកគេទទួលបន្ទុកនៃសេចក្ដីសង្គ្រោះរបស់មនុស្ស។ ពួកគេបានដឹងថាដំណឹងល្អត្រូវតែផ្សព្វផ្សាយទៅកាន់ពិភពលោក ហើយពួកគេបានទាមទារអំណាចដែលព្រះគ្រិស្ដបានសន្យា ។

<u>ពុធ-១ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ២២

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ខ្ញុំប្រាប់តាមត្រង់ថា ដែលខ្ញុំទៅ នោះមានប្រយោជន៍ដល់អ្នករាល់គ្នាវិញ ដ្បិតបើខ្ញុំមិនទៅទេ នោះព្រះដ៏ជាជំនួយក៏មិនមកឯអ្នករាល់គ្នាដែរ តែបើខ្ញុំទៅ នោះខ្ញុំនឹងចាត់ទ្រង់ឲ្យមក។ យ៉ូហាន ១៦:៧*

នៅសម័យពួកអយ្យកោ ព្រះបានបង្ហាញព្រះវិញ្ញាណបរិសុទ្ធនៅក្នុងលក្ខណៈគួរឲ្យកត់សម្គាល់ ប៉ុន្តែ មិនបានពេញលេញទេ ។ ឥឡូវនេះ នៅក្នុងការស្តាប់បង្គាប់ព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះ ពួកសាវ័កបានថ្វាយការអង្វរករសុំអំណោយទាន ហើយនៅឋានសួគ៌ឯណោះវិញ ព្រះគ្រិស្តបានបន្ថែមការទូលអង្វររបស់ទ្រង់ជំនួសពួកគេ។ ព្រះអង្គបានទាមទារអំណោយទាននៃព្រះវិញ្ញាណដែលព្រះអង្គនឹងចាក់បង្ហូរមកលើពួករាស្ត្ររបស់ទ្រង់ ។

«កាលបុណ្យថ្ងៃទី៥០បានមកដល់ នោះគេមានចិត្តព្រមព្រៀងប្រជុំទាំងអស់គ្នា នៅកន្លែងតែមួយ ស្រាប់តែមានឮសូរពីលើមេឃ ដូចជាខ្យល់បក់គំហុកយ៉ាងខ្លាំង មកពេញក្នុងផ្ទះដែលគេអង្គុយនៅ»។

ព្រះវិញ្ញាណបានយាងចុះមកលើពួកសាវ័កដែលកំពុងរង់ចាំនិងកំពុងអធិដ្ឋានដោយភាពពេញលេញដែលបានចូលដល់ចិត្តរបស់មនុស្សគ្រប់គ្នា។ ព្រះដែលគ្មានព្រំដែនបានបង្ហាញអង្គទ្រង់ នៅក្នុងអំណាចនៃពួកជំនុំរបស់ទ្រង់។ ព្រះនៃឋានសួគ៌បានទប់ឥទ្ធិពលនេះមិនឲ្យធ្លាក់មកជាច្រើនជំនាន់មកហើយ  ហើយឥឡូវនេះ ព្រះអង្គមានអំណរជាខ្លាំងដោយអាចប្រទានព្រះគុណនៃព្រះវិញ្ញាណបរិសុទ្ធមកលើពួកជំនុំដ៏បរិបូរ ។ ហើយនៅក្រោមឥទ្ធិពលនៃព្រះវិញ្ញាណ ពាក្យពេចន៍នៃការទូលអង្វរនិងការលន់តួទោសបានលាយឡំជាមួយនឹងចម្រៀងនៃការសរសើរតម្កើង ចំពោះការអត់ទោសបាប។ គេបានឮសំឡេងនៃការថ្លែងអំណរគុណ និងសេចក្តីទំនាយ។ ទេវតាទាំងអស់នៃឋានសួគ៌បានឱនចុះយ៉ាងទាបមកមើលនិងសរសើរតម្កើងប្រាជ្ញានៃសេចក្តីស្រឡាញ់ដែលគ្មានគូប្រៀប និងមិនអាចថ្លែងបាន ។ ពួកសាវ័កបានឧទានដោយការអស្ចារ្យថា «នេះហើយជាសេចក្តីស្រឡាញ់» ។ ដាវនៃព្រះវិញ្ញាណបានសំលៀងជាថ្មី ជាមួយនឹងអំណាច និងមុជនៅក្នុងផ្លេកបន្ទោរ

នៃឋានសួគ៌ កាត់តាមផ្លូវ ឆ្លងកាត់អ្នកមិនជឿ។ មនុស្សរាប់ពាន់នាក់បាន កែប្រែចិត្តផ្លាស់ប្តូរជំនឿនៅថ្ងៃនោះ ។

ព្រះគ្រិស្តបានមានបន្ទូលទៅកាន់ពួកសាវ័ករបស់ទ្រង់ថា «ដែលខ្ញុំទៅ នោះមានប្រយោជន៍ដល់អ្នករាល់គ្នាវិញ ដ្បិតបើខ្ញុំមិនទៅទេ នោះព្រះដ៏ជាជំនួយក៏មិនមកឯអ្នករាល់គ្នាដែរ តែបើខ្ញុំទៅ នោះខ្ញុំនឹងចាត់ទ្រង់ឲ្យមក»។ «កាលណាព្រះអង្គនោះ គឺជាព្រះវិញ្ញាណនៃសេចក្តីពិតបានមកដល់ នោះទ្រង់នឹងនាំអ្នករាល់គ្នាចូលក្នុងគ្រប់ទាំងសេចក្តីពិត ដ្បិតទ្រង់នឹងមានព្រះបន្ទូល មិនមែនដោយអាងព្រះអង្គទ្រង់ទេ គឺនឹងមានព្រះបន្ទូល ចំពោះតែសេចក្តីណាដែលទ្រង់ឮ ហើយនិងសម្តែងឲ្យអ្នករាល់គ្នាដឹងការដែលត្រូវមក» (យ៉ូហាន ១៦:៧, ១៣) ។

ការយាងឡើងទៅកាន់ឋានសួគ៌របស់ព្រះគ្រិស្តគឺជាសញ្ញាប្រាប់ថា ពួកសិស្សរបស់ទ្រង់នឹងទទួលព្រះពរនៃសេក្តីសន្យា។ ពួកគេបានរង់ចាំព្រះពរនេះ មុននឹងពួកគេបំពេញកិច្ចការរបស់ពួកគេ។ នៅពេលព្រះគ្រិស្តបានឆ្លងកាត់ក្លោងទ្វារនៃឋានសួគ៌ ព្រះអង្គបានទទួលការថ្វាយរាជសម្បត្តិនៅកណ្តាលការសរសើរតម្កើងនៃពួកទេវតា។ នៅពេលដែលពិធីបុណ្យនេះបានបញ្ចប់ភ្លាម ព្រះវិញ្ញាណបរិសុទ្ធបានយាងចុះមកសណ្ឋិតលើពួកសាវ័ក ដោយចរន្តយ៉ាងបរិបូរ ហើយព្រះគ្រិស្តពិតជាត្រូវបានសរសើរតម្កើង រួមជាមួយនឹងសិរីល្អដែលព្រះអង្គមានជាមួយនឹងព្រះវរបិតាតាំងពីអស់កល្បរៀងមក។ ការចាក់ព្រះវិញ្ញាណបរិសុទ្ធនៅថ្ងៃប៉ង់តាកូសគឺជាទំនាក់ទំនងនៃឋានសួគ៌ ថាពិធីបុណ្យឆ្លងរបស់ព្រះដ៏ប្រោសលោះត្រូវបានបញ្ចប់ហើយ។ ព្រះយេស៊ូវបានចាក់ព្រះវិញ្ញាណបរិសុទ្ធមកលើពួកសាវ័ករបស់ទ្រង់តាមសេចក្តីសន្យា ជានិមិត្តរូបបញ្ជាក់ថាព្រះអង្គបានទទួលអំណាចទាំងអស់ ជាសម្តេចសង្ឃផងនិងជាស្តេចផង នៅលើឋានសួគ៌និងនៅផែនដី ហើយទ្រង់ក៏ជាតង្វាយធួននឹងបាបនៃរាស្ត្ររបស់ព្រះអង្គផងដែរ។

«ក៏មានអណ្តាត ដូចជាអណ្តាតភ្លើង ដែលបែកចេញពីគ្នា លេចមកឲ្យគេឃើញ ហើយមកសណ្ឋិតលើគេគ្រប់គ្នា រួចគេបានពេញជាព្រះវិញ្ញាណ

បរិសុទ្ធទាំងអស់ ក៏តាំងនិយាយភាសាផ្សេងៗ តាមដែលព្រះវិញ្ញាណប្រទានឲ្យ»។ ព្រះវិញ្ញាណបរិសុទ្ធមានសណ្ឋានដូចជាអណ្តាតភ្លើងមកសណ្ឋិតលើពួកអ្នកដែលបានជួបជុំគ្នានោះ។ នេះគឺជានិមិត្តរូបនៃអំណោយទានដែលព្រះបានប្រទានដល់ពួកសាវ័កនៅពេលនោះ ដែលបណ្តាលឲ្យពួកគេចេះនិយាយភាសាដទៃដែលគេមិនធ្លាប់ចេះពីមុនមក យ៉ាងស្ទាត់ជំនាញ ។ សណ្ឋានជាអណ្តាតភ្លើងមានន័យថាភាពពុះកញ្ជ្រោលយ៉ាងក្លៀវក្លាដែលពួកសាវ័កនឹងបំពេញកិច្ចការ និងជាអំណាចដែលនឹងនៅជាមួយនឹងកិច្ចការរបស់ពួកគេ។

<u>ព្រហស្បតិ៍-២ កក្កដា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ២៣**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *អ្នករាល់គ្នាបានសំឡាប់ព្រះអម្ចាស់ជីវិតនោះទៅ តែព្រះបានប្រោសឲ្យទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញ យើងខ្ញុំនេះជាទីបន្ទាល់ពីការនោះឯង។ កិច្ចការ ៣:១៥*

«រីឯនៅក្រុងយេរូសាឡិម មានពួកសាសន៍យូដា ជាអ្នកកោតខ្លាចដល់ព្រះ ដែលមកពីគ្រប់នគរនៅក្រោមមេឃ»។ នៅពេលបែកខ្ញែកគ្នា ពួកយូដាបានរស់នៅរាយប៉ាយសឹងតែគ្រប់ទីកន្លែងនៅលើពិភពលោក ហើយនៅពេលដែលពួកគេបាននិរទេសទៅនៅប្រទេសផ្សេងៗ ពួកគេបាននិយាយភាសាបរទេសនៃប្រទេសដែលពួកគេទៅស្នាក់អាស្រ័យនៅទីនោះ។ សាសន៍យូដាជាច្រើនបានមកកាន់ទីក្រុងយេរូសាឡិម ដើម្បីចូលរួមក្នុងពិធីបុណ្យខាងសាសនានៅពេលនោះ ជាពួកអ្នកដែលមានវឌ្ឍនភាព (ភាពជឿនលឿន)។ មនុស្សដែលបានមកប្រជុំគ្នានេះនិយាយភាសាផ្សេងៗគ្នាជាច្រើន។ ភាពទីទៃពីគ្នានៃភាសានេះគឺជាឧបសគ្គដ៏ធំមួយក្នុងការផ្សាយដំណឹងល្អ ហេតុដូច្នេះហើយបានជាព្រះបានប្រទានដំណោះស្រាយដល់ភាពកម្សោយរបស់ពួកសាវ័កនេះ ក្នុងលក្ខណៈដ៏អស្ចារ្យ។ ព្រះវិញ្ញាណបរិសុទ្ធបានធ្វើជំនួសពួកគេ នូវកិច្ចការដែលពួកគេមិនអាចសម្រេចដោយខ្លួនឯងនៅក្នុងជីវិតរបស់ពួកគេបាន។ ឥឡូវនេះ ពួកគេអាចប្រកាសពីសេចក្តីពិតនៃដំណឹងល្អទៅប្រទេសក្រៅបានយ៉ាងទូលំទូលាយ ដោយនិយាយភាសារបស់ពួកអ្នក

ដែលពួកគេធ្វើការជាមួយនោះយ៉ាងច្បាស់។ អំណោយនៃការអស្ចារ្យនេះគឺជាភស្តុតាងដ៏រឹងមាំមួយ បញ្ជាក់ប្រាប់ដល់ពិភពលោកថាបេសកកម្មដែលពួកគេបំពេញគឺជាត្រានៃឋានសួគ៌។

«កាលសូរស័ព្ទពីការនោះបានឮសុសសាយទៅ នោះបណ្តាមនុស្សក៏ប្រជុំគ្នា ហើយគេមានសេចក្តីស្រឡាំងកាំង ដោយគ្រប់គ្នាឮភាសាជាតិរបស់ខ្លួន ដែលពួកសាវ័កកំពុងតែអធិប្បាយ គេមានសេចក្តីអស្ចារ្យក្នុងចិត្ត ហើយនិយាយគ្នាទៅវិញទៅមក ដោយឆ្ងល់ថា អ្នកទាំងនេះដែលអធិប្បាយតើមិនមែនជាពួកអ្នកស្រុកកាលីឡេទាំងអស់គ្នាទេឬអី? ចុះដូចម្តេចបានជាយើងឮគេនិយាយតាមភាសាកំណើតរបស់យើងរៀងខ្លួនដូច្នេះ?»

ពួកសង្ឃនិងពួកមេដឹកនាំសាសនាគេក្តៅក្រហាយជាខ្លាំងទៅនឹងការសម្តែងដ៏អស្ចារ្យនេះ ប៉ុន្តែ ពួកគេមិនហ៊ានបំបែកការប្រជុំនេះទេ ព្រោះខ្លាចរងអំពើហិង្សាពីពួកបណ្តាជន។ ពួកគេបានធ្វើគតព្រះយេស៊ូវជាអ្នកស្រុកណាសារ៉ែត ប៉ុន្តែ នៅទីនេះអ្នកបម្រើរបស់ទ្រង់ ជាអ្នកស្រុកកាលីឡេដែលមិនមានចំណេះដឹង កំពុងនិយាយប្រាប់ពីរឿងរ៉ាវនៃព្រះជន្មនិងព្រះរាជបេសកកម្មរបស់ទ្រង់ ជាភាសាដែលមនុស្សនិយាយនៅសម័យនោះ។ ពួកសង្ឃបានប្រកាសថាពួកនេះស្រវឹងទេ ដោយពួកគេផឹកស្រាថ្មីដែលគេបានរៀបចំសម្រាប់ពិធីបុណ្យនេះច្រើនពេក ដោយបានតាំងចិត្តពន្យល់ពីអំណាចដ៏អស្ចារ្យរបស់ពួកសាវ័កនេះថាជារឿងធម្មតាទៅវិញ។ មនុស្សដែលល្ងិតល្ងង់បំផុតមួយចំនួនចាត់ទុករឿងរ៉ាវដែលពួកគេបានឃើញនេះថា ជារឿងពិត ប៉ុន្តែ ពួកអ្នកមានចំណេះដឹងខ្ពង់ខ្ពស់មួយចំនួនបានដឹងថានេះគឺជារឿងក្លែងក្លាយទៅវិញ ហើយអស់អ្នកដែលស្តាប់ភាសាផ្សេងៗនោះយល់បានបញ្ជាក់ពីភាពត្រឹមត្រូវនៃភាសាដែលពួកសាវ័កបាននិយាយ។

ជាការឆ្លើយតបទៅនឹងការចោទប្រកាន់របស់ពួកសង្ឃនោះ លោកពេត្រុសបានបង្ហាញថាការបកស្រាយនេះគឺជាការសម្រេចតាមបទទំនាយរបស់លោកយ៉ូអែលយ៉ាងត្រឹមត្រូវ ដែលនៅទីនោះលោកបានទស្សទាយជាមុនថាអំណាចនេះនឹងកើតឡើងដល់មនុស្ស ដើម្បីរៀបចំសម្រាប់បំពេញកិច្ច

ការដ៏ពិសេស។ លោកមានប្រសាសន៍ថា «ឱពួកសាសន៍យូដា និងពួកអ្នកនៅក្រុងយេរូសាឡិមទាំងអស់គ្នាអើយ សូមឲ្យអ្នករាល់គ្នាដឹងសេចក្តីនេះ ហើយប្រុងស្តាប់ពាក្យខ្ញុំចុះ ដ្បិតអ្នកទាំងនេះមិនមែនស្រវឹង ដូចជាអ្នករាល់គ្នាគិតស្មាននោះទេ ព្រោះទើបនឹងម៉ោង៩ព្រឹកនៅឡើយ នេះគឺជាសេចក្តីទំនាយរបស់ហោរាយ៉ូអែលវិញ ដែលលោកទាយទុកមកថា ព្រះទ្រង់មានព្រះបន្ទូលថា ដល់ថ្ងៃជាន់ក្រោយបង្អស់ អញនឹងចាក់ព្រះវិញ្ញាណអញ ទៅលើគ្រប់ទាំងមនុស្ស នោះកូនប្រុសកូនស្រីឯងរាល់គ្នានឹងទាយទំនាយ ពួកកំឡោះឯងរាល់គ្នា នឹងឃើញការជាក់ស្តែង ហើយពួកចាស់ៗ របស់ឯងរាល់គ្នានឹងយល់សប្តិ នៅគ្រានោះ អញនឹងចាក់ព្រះវិញ្ញាណអញ ទៅលើទាំងពួកអ្នកបម្រើប្រុសស្រីផង ហើយគេនឹងទាយទំនាយដែរ»។

លោកពេត្រុសបានធ្វើទីបន្ទាល់អំពីការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រិស្ត ដោយអំណាចនិងច្បាស់ៗស្រួលយល់ដូច្នេះថា «ឱពួកសាសន៍អ៊ីស្រាអែលអើយ សូមស្តាប់ពាក្យនេះចុះ ព្រះយេស៊ូវ ជាអ្នកស្រុកណាសារ៉ែត ដែលព្រះបានសម្តែងបង្ហាញមកអ្នករាល់គ្នាដោយការឫទ្ធិបារមី ការអស្ចារ្យ និងទីសម្គាល់ ដែលព្រះទ្រង់បានធ្វើ នៅកណ្តាលអ្នករាល់គ្នា ដោយសារទ្រង់ ដូចជាអ្នករាល់គ្នាដឹងស្រាប់ហើយ... ហើយអ្នករាល់គ្នាបានចាប់ទ្រង់ ដោយសារដៃមនុស្សទទឹងច្បាប់ព្រមទាំងឆ្កាងសម្លាប់ទ្រង់ផង ប៉ុន្តែ ព្រះបានប្រោសទ្រង់ ឲ្យមានព្រះជន្មរស់ឡើងវិញ ដោយបានស្រាយចំណងនៃសេចក្តីស្លាប់ចេញ ពីព្រោះសេចក្តីស្លាប់គ្មានអំណាចនឹងឃុំឃាំងទ្រង់ទុកបានឡើយ»។

**<u>សុក្រ-៣ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ២៤**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ពេត្រុសឆ្លើយតបថា ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយទទួលបុណ្យជ្រមុជទឹកទាំងអស់គ្នា ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទប្រយោជន៍ឲ្យបានរួចពីបាប នោះអ្នករាល់គ្នានឹងទទួលអំណោយទាន ជាព្រះវិញ្ញាណបរិសុទ្ធ ។ កិច្ចការ ២:៣៨*

លោកពេត្រុសមិនបាននិយាយសំដៅទៅលើការបង្រៀនរបស់ព្រះគ្រិស្តដើម្បីបញ្ជាក់ពីតួនាទីរបស់លោកទេ ពីព្រោះលោកបានដឹងថាពួកអ្នកដែលស្តាប់គាត់គេមានការប្រកាន់ពូជសាសន៍ខ្លាំងណាស់ ដែលធ្វើឲ្យសម្តីរបស់លោកទាក់ទងនឹងប្រធានបទនេះ មិនមានប្រសិទ្ធិភាពឡើយ។ ផ្ទុយទៅវិញ លោកបាននិយាយប្រាប់ពួកគេពីហ្លួងដាវីឌ ដែលពួកយូដាបានចាត់ទុកថាជាចាស់ទុំម្នាក់នៃសាសន៍របស់គេ។ លោកបានថ្លែងថា «ដ្បិតហ្លួងដាវីឌមានព្រះបន្ទូលពីទ្រង់ថា ទូលបង្គំបានឃើញព្រះអម្ចាស់ នៅមុខទូលបង្គំជានិច្ច ពីព្រោះទ្រង់សណ្ឋិតនៅខាងដៃស្តាំទូលបង្គំ ដើម្បីមិនឲ្យទូលបង្គំត្រូវរង្គើឡើយ ហេតុនោះបានជាចិត្តទូលបង្គំមានសេចក្តីអំណរ ហើយអណ្តាតទូលបង្គំក៏ថ្លែង ដោយសេចក្តីត្រេកអរមួយទៀត រូបសាច់ទូលបង្គំនឹងស្នាក់នៅដោយសេចក្តីសង្ឃឹមដែរ ដ្បិតទ្រង់នឹងមិនទុកព្រលឹងទូលបង្គំឲ្យជាប់នៅក្នុងឋានឃុំព្រលឹងមនុស្សស្លាប់ទេ ក៏មិនឲ្យអ្នកបរិសុទ្ធរបស់ទ្រង់ឃើញសេចក្តីពុករលួយដែរ ... ឱបងប្អូនរាល់គ្នាអើយ ខ្ញុំមានច្បាប់នឹងថ្លែងប្រាប់ដល់អ្នករាល់គ្នាយ៉ាងច្បាស់ ពីហ្លួងដាវីឌ ជាអយ្យកោថា លោកបានទាំងសុគតហើយគេបានបញ្ចុះសពលោកដែរ ផ្នូរលោកក៏នៅជាមួយនឹងយើងរាល់គ្នាដរាបដល់សព្វថ្ងៃនេះ» ... «លោកសម្តែងពីព្រះគ្រិស្តត្រូវរស់ឡើងវិញថា ព្រលឹងទ្រង់មិនត្រូវទុកចោល នៅក្នុងឋានឃុំព្រលឹងមនុស្សស្លាប់ទេ ហើយរូបសាច់ទ្រង់មិនត្រូវឃើញសេចក្តីពុករលួយឡើយ ឯព្រះយេស៊ូវនេះ ព្រះបានប្រោសឲ្យទ្រង់មានព្រះជន្មរស់ឡើងវិញ ហើយពួកយើងនេះជាទីបន្ទាល់ពីទ្រង់ទាំងអស់គ្នា» ។

សេចក្តីថ្លែងនេះធ្វើឲ្យពួកបណ្តាជនចាប់អារម្មណ៍យ៉ាងក្រៃលែង។ មើលន៍ មនុស្សម្នាបានមកពីគ្រប់ទិសទី ដើម្បីស្តាប់ទីបន្ទាល់ពីសេចក្តីពិតរបស់ពួកសាវ័ក ដូចជាពួកបណ្តាជនបានមកស្តាប់ព្រះយេស៊ូវដែរ។ នៅក្នុងចំណោមមនុស្សជាច្រើនកុះករនៅក្នុងព្រះវិហារ ពួកសង្ឃនិងពួកមេដឹកនាំសាសនាក៏នៅទីនោះដែរ ពួកគេប្រច្រៀតចូលទៅទាំងមុខក្រញូវ មានចិត្តពោរពេញដោយសម្អប់ទាស់នឹងព្រះគ្រិស្ត ដៃរបស់ពួកគេនៅប្រឡាក់ឈាម

ដែលបានខ្ចាយនៅពេលដែលពួកគេបានឆ្កាងព្រះដ៏ប្រោសលោះនោះនៅឡើយ។ ពួកគេបានគិតថានឹងបំភ័យដល់ពួកសាវ័កដោយការភ័យខ្លាច នៅក្រោមដៃនៃការកៀបសង្កត់និងការកាប់សម្លាប់ដ៏សាហាវ ពួកគេបានរកឃើញថាព្រះបានលើកពួកសាវ័កឲ្យផុតពីការភ័យខ្លាច និងពេញដោយព្រះវិញ្ញាណដោយប្រកាសពីភាពជាព្រះរបស់ព្រះយេស៊ូវពីស្រុកណាសារ៉ែតដោយអំណាចទៅវិញ ពួកគេបានឮពួកសាវ័កប្រកាសថាអ្នកដែលទើបនឹងត្រូវបានប្រមាថ ចំអកមើលងាយ និងវាយតប់ ហើយព្យួរនៅលើឈើឆ្កាង ដោយដៃដ៏ឃោរឃៅកាលពីពេលថ្មីៗនេះ គឺជាព្រះអម្ចាស់នៃជីវិត ឥឡូវនេះ ព្រះអង្គកំពុងតែគង់នៅខាងស្តាំនៃព្រះវរបិតា។

ពួកអ្នកដែលកំពុងស្តាប់ពួកសាវ័កនេះ មួយចំនួនធ្លាប់បានចូលរួមយ៉ាងសកម្មក្នុងការចោទប្រកាន់ និងការសុគតរបស់ព្រះគ្រិស្ត។ ពួកគេបានបន្លឺសំឡេងជាមួយនឹងក្រុមមនុស្សអាក្រក់ក្នុងការឆ្កាងទ្រង់។ នៅពេលដែលព្រះយេស៊ូវនិងបារ៉ាបាសបានឈរនៅចំពោះពួកគេ ក្នុងបន្ទប់ជំនុំជម្រះនោះលោកពីឡាត់បានសួរថា «តើអ្នករាល់គ្នាចង់ឲ្យខ្ញុំលែងឈ្មោះណា បារ៉ាបាស ឬយេស៊ូវ ដែលហៅថា ព្រះគ្រិស្ត»។ ពួកគេបានស្រែកឡើងថា «កុំលែងអ្នកនោះឡើយ សូមលែងបារ៉ាបាសវិញ» (ម៉ាថាយ ២៧:១៧ និង យ៉ូហាន ១៨:៤០)។ នៅពេលលោកពីឡាត់បានប្រគល់ព្រះយេស៊ូវទៅឲ្យពួកគេ ដោយនិយាយថា «ត្រូវឲ្យអ្នករាល់គ្នាយកគាត់ទៅឆ្កាងវិញ ដ្បិតខ្ញុំមិនឃើញជាមានទោសអ្វីទេ»។ «ខ្ញុំគ្មានទោសនឹងឈាមនៃអ្នកសុចរិតនេះទេ»។ ពួកបណ្តាជនក៏ស្រែកឡើងថា «ចូរឲ្យឈាមវាធ្លាក់មកលើយើងរាល់គ្នា និងកូនចៅរបស់យើងចុះ» (យ៉ូហាន ១៩:៦ និង ម៉ាថាយ ២៧:២៤, ២៥)។

ឥឡូវនេះ ពួកគេបានឮពួកសាវ័កប្រកាសថាអ្នកដែលពួកគេបានឆ្កាងនោះគឺជាព្រះរាជបុត្រានៃព្រះ។ ពួកសង្ឃនិងពួកមេសាសនាបានភ័យញ័រ។ ដោយដឹងកំហុសខ្លួន និងការទង្គឹះចិត្តពួកបណ្តាជន «គេមានសេចក្តីចាក់ចុចក្នុងចិត្ត ក៏សួរពេត្រុស និងពួកសាវ័កឯទៀតថា បងប្អូនអើយ តើយើងខ្ញុំត្រូវធ្វើដូចម្តេច?» នៅក្នុងចំណោមពួកអ្នកស្តាប់ពួកសាវ័កនោះ មានពួកយូដា

ដែលមានជំនឿមុតមាំ ដែលមានជំនឿស្មោះត្រង់ដែរ។ អំណាចដែលអមជាមួយនឹងសម្ដីរបស់ពួកសាវ័កបានបណ្ដាលឲ្យពួកគេជឿជាក់ថាព្រះយេស៊ូវគឺជាព្រះមែស៊ី។

«ពេត្រុសឆ្លើយតបថា ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយទទួលបុណ្យជ្រមុជទឹកទាំងអស់គ្នា ដោយនូវព្រះនាមព្រះយេស៊ូវគ្រិស្តប្រយោជន៍ឲ្យបានរួចពីបាប នោះអ្នករាល់គ្នានឹងទទួលអំណោយទាន ជាព្រះវិញ្ញាណបរិសុទ្ធ ដ្បិតសេចក្ដីសន្យានោះ គឺសន្យាដល់អ្នករាល់គ្នា និងកូនចៅអ្នករាល់គ្នា ព្រមទាំងអស់អ្នកដែលនៅឆ្ងាយដែរ គឺដល់អស់អ្នកណាដែលព្រះអម្ចាស់ជាព្រះនៃយើងរាល់គ្នាទ្រង់នឹងហៅ»។

<u>សៅរ៍-៤ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ២៥

**ខព្រះគម្ពីរប្រចាំសប្ដាហ៍:** *ឥឡូវនេះ ឱព្រះអម្ចាស់អើយ សូមទតមើលសេចក្ដីកំហែងរបស់គេ ហើយសូមប្រទានឲ្យពួកអ្នកបំរើទ្រង់ បានផ្សាយព្រះបន្ទូលដោយសេចក្ដីក្លាហានដ៏ពេញលេញ ដោយទ្រង់លូកព្រះហស្តមក សំរាប់នឹងប្រោសមនុស្សឲ្យបានជា ហើយនិងធ្វើទីសំគាល់ និងការអស្ចារ្យ ដោយសារព្រះនាមព្រះយេស៊ូវ ជាអ្នកបំរើបរិសុទ្ធរបស់ទ្រង់ ។ កិច្ចការ ៤:២៩-៣០*

លោកពេត្រុសបានជំរុញដល់គ្រួសារដែលបានភ្ញាក់រឭកអំពីរឿងពិតថា ពួកគេបដិសេធព្រះយេស៊ូវដោយសារពួកគេចាញ់បោកបញ្ឆោតពួកសង្ឃ និងពួកមេដឹកនាំសាសនា ហើយប្រសិនបើពួកគេបន្តសម្លឹងមើលទៅពួកអ្នកទាំងនោះដើម្បីទទួលដំបូន្មាន ហើយរង់ចាំឲ្យពួកគេទទួលស្គាល់ព្រះយេស៊ូវគ្រិស្តជាមុនសិន មុននឹងពួកគេហ៊ានទទួលព្រះយេស៊ូវដែរ នោះពួកគេមិនមានឱកាសទទួលទ្រង់ឡើយ។ ពួកមនុស្សដែលមានអំណាចទាំងនេះ បានគិតថាការប្រកាសអំពីសេចក្ដីល្អក៏ដោយ ក៏គ្រាន់តែជាមហិច្ឆតាចង់បានទ្រព្យសម្បត្តិ និងសិរីល្អនៃលោកិយនេះប៉ុណ្ណោះ។ ពួកគេមិនចង់មកឯព្រះយេស៊ូវដើម្បីទទួលពន្លឺទេ ។

នៅក្រោមឥទ្ធិពលនៃការបំភ្លឺពីឋានសួគ៌ បទគម្ពីរដែលព្រះគ្រិស្តបាន

ពន្យល់ដល់ពួកសាវ័ក បានឈរនៅចំពោះមុខពួកគេ ជាមួយនឹងពន្លឺនៃសេចក្ដីពិតដ៏គ្រប់លក្ខណ៍។ វាំងននដែលបានបាំងការពារពួកគេមិនឲ្យមើលឃើញទីចុងបំផុតដែលត្រូវបានបិទបាំងនោះ ឥឡូវនេះត្រូវបានដកយកចេញហើយ ហើយពួកគេបានយល់ពីបេសកកម្ម និងនគររបស់ព្រះយេស៊ូវយ៉ាងជាក់ច្បាស់។ ពួកគេអាចនិយាយដោយព្រះចេស្ដានៃព្រះអង្គសង្គ្រោះ ហើយនៅពេលដែលពួកគេបានបើកបង្ហាញអំពីផែនការនៃសេចក្ដីសង្គ្រោះដល់ពួកអ្នកស្ដាប់របស់គេ មនុស្សជាច្រើនបានជឿនិងបានកែប្រែចិត្ត។ ប្រពៃណីនិងជំនឿខុសឆ្គងដែលបានបណ្ដុះដោយពួកសង្ឃនិងពួកមេដឹកនាំសាសនាត្រូវបានលុបបំបាត់ចេញពីគំនិតរបស់ពួកគេ ហើយពួកគេក៏បានទទួលយកការបង្រៀនរបស់ព្រះអង្គសង្គ្រោះវិញ។

«នោះពួកអ្នកដែលទទួលពាក្យរបស់គាត់ដោយអំណរ ក៏បានទទួលបុណ្យជ្រមុជទឹក ហើយនៅថ្ងៃដដែលនោះ មានប្រហែលជាបីពាន់នាក់ថែមកើនឡើងទៀត» ។

ពួកមេដឹកនាំសាសន៍យូដាបានរំពឹងថាកិច្ចការរបស់ព្រះគ្រិស្ដនឹងត្រូវបញ្ចប់ នៅពេលដែលព្រះអង្គសុគត ប៉ុន្ដែ ផ្ទុយទៅវិញ ពួកគេបានឃើញទិដ្ឋភាពដ៏អស្ចារ្យនៅថ្ងៃប៉ង់តាកូស។ ពួកគេបានឮពួកសាវ័កអធិប្បាយអំពីព្រះគ្រិស្ដ ជាមួយនឹងអំណាចនិងថាមពល ជាអំណោយទានដែលគេមិនធ្លាប់ឃើញពីមុនមក ពាក្យសម្ដីរបស់ពួកសាវ័កបានបញ្ជាក់អះអាងដោយសញ្ញាសម្គាល់និងការអស្ចារ្យ។ នៅទីក្រុងយេរូសាឡិម ជាទីក្រុងដែលមានមនុស្សគាំទ្រសាសនាយូដាច្រើន មនុស្សរាប់ពាន់នាក់បានប្រកាសជំនឿរបស់ពួកគេលើព្រះយេស៊ូវពីស្រុកណាសារ៉ែតថា ជាព្រះមែស៊ី ។

ពួកសិស្សមានការភ្ញាក់ផ្អើលនិងមានក្ដីអំណរយ៉ាងក្រៃលែងទៅនឹងចម្រូតមនុស្សដ៏ធំនេះ។ ពួកគេមិនបានចាត់ទុកលទ្ធផលនៃការប្រមូលផលដ៏ធំនេះថាជាការខំប្រឹងប្រែងរបស់ពួកគេទេ ពួកគេបានដឹងថា ពួកគេកំពុងតែចូលទៅក្នុងកិច្ចការរបស់មនុស្សផ្សេងទៀត។ ចាប់តាំងពីការធ្លាក់ចុះរបស់លោកអ័ដាមមក ព្រះបានប្រស្រ័យទាក់ទងជាមួយនឹងអ្នកបម្រើដែលបាន

ជ្រើសតាំង នូវពូជនៃព្រះបន្ទូលរបស់ទ្រង់ ឲ្យត្រូវបានសាបព្រោះនៅក្នុងចិត្ត របស់មនុស្ស។ កាលព្រះអង្គមានព្រះជន្មរស់នៅលើផែនដី ព្រះអង្គបាន សាបព្រោះគ្រាប់ពូជនៃសេចក្តីពិត ហើយស្រោចដោយព្រះលោហិតរបស់ ព្រះអង្គ។ ការកែប្រែចិត្តដែលបានកើតឡើងនៅថ្ងៃប៉ង់តាកូស គឺជាលទ្ធផល នៃការសាបព្រោះនោះ គឺជាចម្រូតនៃកិច្ចការរបស់ព្រះគ្រិស្ត ដែលបង្ហាញ អំពីការបង្រៀនរបស់ទ្រង់ ។

ការអះអាងរបស់ពួកសាវ័កតែមួយមុខ មិនអាចដកយកចេញនូវការ ប្រកាន់ពូជសាសន៍ដែលបានប្រឆាំងជាខ្លាំងនោះបានទេ ទោះបីជាច្បាស់ លាស់ មានការថ្កោលទោសយ៉ាងណាក៏ដោយ។ ប៉ុន្តែ ព្រះវិញ្ញាណបរិសុទ្ធ បានបញ្ជូនការអះអាងទៅក្នុងចិត្តរបស់មនុស្សដោយអំណាចរបស់ព្រះ។ ពាក្យពេចន៍របស់ពួកសាវ័កគឺជាព្រួញនៃសព្វចេស្តាយ៉ាងមុតស្រួចរបស់ព្រះ ធ្វើឲ្យមនុស្សបានដឹងពីកំហុសរបស់ខ្លួន ក្នុងការបដិសេធន៍និងការឆ្កាងព្រះ អម្ចាស់នៃសិរីល្អ ។

នៅក្រោមការបង្ហាត់បង្រៀនរបស់ព្រះគ្រិស្ត ពួកសាវ័កត្រូវបានដឹក នាំឲ្យបំពេញសេចក្តីត្រូវការខាងវិញ្ញាណរបស់ពួកគេ។ នៅក្រោមការបង្រៀន របស់ព្រះវិញ្ញាណ ពួកគេបានទទួលគុណសម្បត្តិចុងក្រោយ ហើយបោះ ជំហានចូលទៅក្នុងជីវិតនៃកិច្ចការរបស់ពួកគេ។ ពួកគេលែងនៅល្ងិតល្ងង់ និងគ្មានវប្បធម៌ទៀតហើយ។ ពួកគេលែងប្រមូលធាតុដែលមានការបែក បាក់និងមានទំនាស់តទៅទៀតហើយ។ សេចក្តីសង្ឃឹមរបស់ពួកគេ លែង បិតនៅលើមុខមាត់នៅលោកិយនេះទៀតហើយ។ ពួកគេ «មានចិត្តព្រម ព្រៀងគ្នា» «គេក៏មានចិត្តមានគំនិតតែមួយ» (កិច្ចការ ២:៤៦ និង ៤:៣២)។ ព្រះគ្រិស្តបានបំពេញគំនិតរបស់ពួកគេ ការជឿនលឿនទៅមុខនៃនគររបស់ ទ្រង់គឺជាគោលបំណងរបស់ពួកគេ។ ពួកគេបានត្រាប់ដូចជាព្រះជាម្ចាស់ របស់ពួកគេ ទាំងខាងគំនិតនិងទាំងអត្តចរិត និងជាមនុស្សដែល «ធ្លាប់នៅ ជាមួយនឹងព្រះយេស៊ូវ» (កិច្ចការ ៤:១៣)។

ថ្ងៃប៉ង់តាកូសបាននាំមកដល់ពួកគេនូវការបំភ្លឺពីឋានសួគ៌។ សេចក្តី

ពិតដែលពួកគេមិនបានយល់ កាលព្រះគ្រិស្តបានគង់នៅជាមួយនឹងពួកគេនៅឡើយ ឥឡូវនេះ ត្រូវបានបើកបង្ហាញវិញ ជាមួយនឹងជំនឿនិងការធានាអះអាងដែលពួកគេមិនធ្លាប់ដឹងពីមុនមក ពួកគេបានទទួលយកថាជាការបង្រៀននៃព្រះបន្ទូលដ៏ពិសិដ្ឋ។ ជំនឿថាព្រះគ្រិស្តគឺជាព្រះរាជបុត្រារបស់ព្រះលែងជាកង្វល់សម្រាប់ពួកគេតទៅទៀតហើយ។ ពួកគេបានដឹងថាព្រះអង្គពិតជាព្រះមែស៊ី ទោះបីព្រះអង្គយកភាពជាមនុស្សក៏ដោយ ហើយពួកគេបានប្រាប់ពីបទពិសោធន៍របស់ពួកគេ ដល់ពិភពលោក ដោយទំនុកចិត្តដែលដឹងច្បាស់ថាព្រះគង់នៅជាមួយនឹងពួកគេ ។

ពួកគេអាចនិយាយពីព្រះនាមរបស់ព្រះយេស៊ូវដោយភាពប្រាកដនិយម ដ្បិតតើព្រះអង្គមិនមែនជាមិត្តសម្លាញ់ ឬមិនមែនជាបងប្រុសរបស់ពួកគេទេឬអី? ដោយបាននាំចូលទៅក្នុងទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនិងព្រះគ្រិស្ត ពួកគេបានអង្គុយជាមួយព្រះអង្គនៅក្នុងកន្លែងនៃឋានសួគ៌។ ពួកគេបានស្រោបគំនិតរបស់ពួកគេដោយពាក្យសម្ដីដ៏ឆេះឆួលយ៉ាងអស្ចារ្យខណៈដែលពួកគេបានធ្វើទីបន្ទាល់ពីព្រះអង្គ! ចិត្តរបស់ពួកគេបានផ្ទុកទៅដោយចិត្តមេត្តាដ៏ពោរពេញ សែនជ្រាលជ្រៅ សែនឆ្ងាយ ដែលជំរុញពួកគេឲ្យចេញទៅបញ្ជាក់ប្រាប់ពីព្រះចេស្ដារបស់ព្រះគ្រិស្ត រហូតដល់ចុងបំផុតនៃផែនដី។ ពួកគេត្រូវបានបំពេញទៅដោយចេតនា ចង់ជំរុញកិច្ចការដែលពួកគេបានចាប់ផ្ដើមឲ្យលឿនទៅមុខ។ ពួកគេបានដឹងពីបំណុលដ៏ធំរបស់ពួកគេចំពោះឋានសួគ៌ និងការទទួលខុសត្រូវនៃកិច្ចការរបស់ពួកគេ។ ដោយមានការពង្រឹងពីព្រះវិញ្ញាណបរិសុទ្ធ ពួកគេបានបោះជំហានទៅមុខដោយចិត្តពុះកញ្ជ្រោល ដើម្បីពង្រីកជោគជ័យនៃឈើឆ្កាង។ ព្រះវិញ្ញាណបានលើកទឹកចិត្តនិងមានបន្ទូលជំនួសពួកគេ។ សេចក្ដីសុខសាន្តរបស់ព្រះគ្រិស្តបានចែងចាំងចេញពីមុខរបស់ពួកគេ។ ពួកគេបានថ្វាយជីវិតរបស់ពួកគេដើម្បីបំពេញកិច្ចការរបស់ទ្រង់ ហើយលក្ខណៈរបស់ពួកគេបង្ហាញភ័ស្តុតាងពីការចុះចូលដែលពួកគេបានធ្វើ។

# ជំពូកទី ៥

# អំណោយទាននៃព្រះវិញ្ញាណ

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ២:១-៣៩ ។*

<u>អាទិត្យ-៥ កក្កដា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ២៦**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ពួកសាវ័កក៏ធ្វើបន្ទាល់ ដោយព្រះចេស្តាដ៏ធំ ពីដំណើរដែលព្រះអម្ចាស់យេស៊ូវមានព្រះជន្មរស់ឡើងវិញ ហើយមានព្រះគុណជាធំសណ្ឋិតលើគេទាំងអស់គ្នាដែរ។ កិច្ចការ ៤:៣៣*

នៅពេលដែលព្រះគ្រិស្តបានប្រទានសេចក្តីសន្យាពីព្រះវិញ្ញាណដល់ពួកសិស្សរបស់ទ្រង់ គឺព្រះអង្គចង់មានបន្ទូលអំពីទីបញ្ចប់នៃព្រះរាជកិច្ចរបស់ទ្រង់នៅលើផែនដី។ ព្រះអង្គបានឈរនៅក្រោមស្រមោលនៃឈើឆ្កាងដោយបានជ្រាបច្បាស់អំពីបន្ទុកនៃកំហុសដែលនឹងធ្លាក់មកលើទ្រង់ដែលជាអ្នករងអំពើបាប។ មុននឹងលះបង់អង្គទ្រង់ជាតង្វាយយញ្ញបូជា ព្រះអង្គបានបង្រៀនដល់ពួកសិស្សរបស់ទ្រង់ទាក់ទងនឹងអំណោយទានដ៏សំខាន់ និងពេញលេញបំផុត ដែលព្រះអង្គនឹងប្រទានដល់ពួកអ្នកដែលជឿដល់ទ្រង់ ជាអំណោយទានដែលនឹងនាំមកនូវប្រភពនៃព្រះគុណរបស់ទ្រង់ ដល់ពួកគេគ្មានដែនកំណត់។ «នោះខ្ញុំនឹងទូលសូមដល់ព្រះវរបិតា ហើយទ្រង់នឹងប្រទានព្រះដ៏ជាជំនួយមួយអង្គទៀត មកអ្នករាល់គ្នាឲ្យបានគង់នៅជាមួយ នៅអស់កល្បរៀងទៅ គឺជាព្រះវិញ្ញាណនៃសេចក្តីពិត ដែលលោកិយទទួលពុំបាន ព្រោះមិនឃើញ ហើយមិនស្គាល់ទ្រង់សោះ តែអ្នករាល់គ្នាស្គាល់ទ្រង់ ដ្បិតទ្រង់គង់ជាមួយក៏នឹងសណ្ឋិតនៅក្នុងអ្នករាល់គ្នាដែរ» (យ៉ូហាន ១៤:១៦, ១៧)។ ព្រះគ្រិស្តកំពុងចង្អុលទៅពេលខាងមុខ ដល់គ្រាដែលព្រះវិញ្ញាណបរិសុទ្ធនឹងយាងមកធ្វើការដ៏ធំជាតំណាងរបស់ទ្រង់ ។

អារក្សដែលបានកើតឡើងជាច្រើនសតវត្សរ៍មកហើយនោះ ត្រូវបានប្រឆាំងទប់ទល់ដោយព្រះចេស្ដាដ៏ខ្លាំងពូកែគឺព្រះវិញ្ញាណបរិសុទ្ធ ។

តើការចាក់បង្ហូរព្រះវិញ្ញាណបរិសុទ្ធនៅថ្ងៃប៉ង់តាកូសនោះមានប្រយោជន៍អ្វីទៅ? ដំណឹងនៃព្រះអង្គសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញត្រូវបានពាំនាំទៅកាន់ចុងបំផុតនៃផែនដី។ នៅពេលពួកសាវ័កបានប្រកាសដំណឹងអំពីព្រះគុណដែលប្រោសលោះ ចិត្តមនុស្សជាច្រើនបានទោរទន់មករកសាររបស់ពួកគេ។ ពួកជំនុំបានឃើញមនុស្សចូលមកទាំងហ្វូងៗ ពីគ្រប់ទិសទី។ ពួកអ្នកបោះបង់ជំនឿ បានវិលត្រឡប់មកវិញ។ ពួកអ្នកមានបាបបានរួបរួមជាមួយនឹងពួកអ្នកជឿក្នុងការស្វែងរកត្បូងពេជ្រដ៏មានតម្លៃ ពួកអ្នកដែលធ្លាប់តែប្រឆាំងនឹងដំណឹងល្អយ៉ាងជូរចត់ បានក្លាយជាជើងឯកនៃដំណឹងល្អ។ បទទំនាយត្រូវបានសម្រេចដោយចែងថា «អ្នកណាក្នុងពួកគេដែលខ្សោយ នោះនឹងបានដូចជាដាវីឌវិញ ហើយពួកវង្សរបស់ដាវីឌ ... គឺដូចជាទេវតានៃព្រះយេហូវ៉ា» (សាការី ១២:៨)។ គ្រិស្តបរិស័ទរាល់រូបបានឃើញការបើកសម្ដែងពីសេចក្ដីស្រឡាញ់ និងចិត្តត្រាប្រណីរបស់ព្រះ នៅក្នុងបងប្អូនរបស់ពួកគេ។ ចំណាប់អារម្មណ៍មួយត្រូវបានឈ្នះ ហើយប្រធានបទនៃការប្រកួតប្រជែងមួយបានលេបត្របាក់ប្រធានបទផ្សេងទៀតទាំងអស់។ សេចក្ដីប្រាថ្នារបស់ពួកអ្នកជឿព្រះយេស៊ូវគឺការបង្ហាញពីអត្តចរិតដូចជាព្រះយេស៊ូវ និងការបំពេញកិច្ចការដើម្បីពង្រីកនគររបស់ទ្រង់ ។

«ពួកសាវ័កក៏ធ្វើបន្ទាល់ ដោយព្រះចេស្ដាដ៏ធំ ពីដំណើរដែលព្រះអម្ចាស់យេស៊ូវមានព្រះជន្មរស់ឡើងវិញ ហើយមានព្រះគុណជាធំសណ្ឋិតលើគេទាំងអស់គ្នាដែរ» (កិច្ចការ ៤:៣៣) ។ នៅក្រោមកិច្ចការរបស់ពួកគេនេះបានបន្ថែមមនុស្សដែលបានជ្រើសរើសទៅក្នុងពួកជំនុំថែមទៀត ជាអ្នកដែលទទួលព្រះបន្ទូលនៃសេចក្ដីពិត ដោយលះបង់ជីវិតរបស់ពួកគេចំពោះកិច្ចការដែលផ្ដល់សេចក្ដីសង្ឃឹមដល់អ្នកដទៃ ដោយបំពេញចិត្តពួកគេជាមួយនឹងសេចក្ដីសុខសាន្តនិងក្ដីអំណរ ។ គ្មានការគំរាមកំហែងណាអាចរំខានឬបន្ទុចបង្អាក់ដល់ពួកគេបានឡើយ។ ព្រះជាម្ចាស់មានបន្ទូលតាមរយៈពួកគេ

ហើយនៅពេលដែលពួកគេបានធ្វើដំណើរពីកន្លែងមួយ ទៅកន្លែងមួយ ពួកគេបានអធិប្បាយពីដំណឹងល្អដល់អ្នកក្រីក្រនិងបានធ្វើការអស្ចារ្យជាច្រើន ។

ដូច្នេះ ព្រះអាចធ្វើការយ៉ាងអស្ចារ្យ នៅពេលមនុស្សថ្វាយជីវិតរបស់ពួកគេឲ្យព្រះវិញ្ញាណគ្រប់គ្រង ។

សេចក្តីសន្យានៃព្រះវិញ្ញាណបរិសុទ្ធមិនមានដែនកំណត់ចំពោះសម័យកាលណា ឬពូជមនុស្សណាឡើយ ។ ព្រះគ្រិស្តបានមានបន្ទូលថា ឥទ្ធិពលរបស់ព្រះនឹងគង់នៅជាមួយនឹងអ្នកដើរតាមទ្រង់ រហូតដល់បំផុតកល្ប។ ចាប់តាំងពីថ្ងៃប៉ង់តាកូស រហូតដល់សម័យបច្ចុប្បន្ន ព្រះបានចាត់ព្រះដ៏ជាជំនួយមកឯអស់អ្នកដែលថ្វាយខ្លួនដាច់ទៅព្រះជាម្ចាស់និងកិច្ចការរបស់ទ្រង់ ព្រះវិញ្ញាណបរិសុទ្ធបានយាងមកធ្វើជាព្រះដ៏ជាជំនួយគំនិត ជាព្រះដែលញែកជាបរិសុទ្ធ ជាអ្នកដឹកនាំ និងជាទីបន្ទាល់ ដល់អស់អ្នកដែលបានទទួលយកព្រះគ្រិស្តជាព្រះអង្គសង្គ្រោះរបស់គេផ្ទាល់។ ពួកអ្នកជឿបានដើរជាមួយនឹងព្រះកាន់តែកៀក ពួកគេនឹងបានឃើញសេចក្តីស្រឡាញ់និងព្រះគុណនៃព្រះអង្គសង្គ្រោះរបស់គេកាន់តែច្បាស់ និងរឹតតែមានអំណាច។ បុរសនារីដែលបានឆ្លងកាត់ការបៀតបៀននិងការពិបាកជាច្រើនសតវត្សរ៍កន្លងមកបានរីករាយជាមួយនឹងព្រះវត្តមាននៃព្រះវិញ្ញាណបរិសុទ្ធដ៏ធំមហិមា នៅក្នុងជីវិតរបស់ពួកគេ បានឈរជាសញ្ញានិងជាការអស្ចារ្យ នៅក្នុងពិភពលោក។ ពួកគេបានបើកបង្ហាញនូវអំណាចនៃការកែប្រែចិត្តក្នុងសេចក្តីស្រឡាញ់របស់ព្រះដ៏ប្រោសលោះ នៅចំពោះពួកទេវតានិងមនុស្សលោក។

**<u>ច័ន្ទ-៦ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ២៧**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ហើយគ្មានសេចក្តីសង្គ្រោះ ដោយសារអ្នកណាទៀតសោះ ដ្បិតនៅក្រោមមេឃ គ្មាននាមឈ្មោះណាទៀតបានប្រទានមកមនុស្សលោក ឲ្យយើងរាល់គ្នាបានសង្គ្រោះនោះឡើយ។ កិច្ចការ ៤:១២*

ពួកអ្នកដែលបានចូលរួមនៅថ្ងៃប៉ង់តាកូសដែលបានទទួលអំណាចមកពីឋានលើ ក៏មិនបានរួចផុតពីសេចក្តីល្បួងនិងការពិបាកផ្សេងៗដែរ។

នៅពេលពួកគេបានធ្វើទីបន្ទាល់អំពីសេចក្តីពិតនិងសេចក្តីសុចរិត ពួកគេត្រូវបានគំរាមកំហែងម្តងហើយម្តងទៀត ពីសំណាក់សត្រូវនៃសេចក្តីពិត ដែលបានខំប្រឹងប្រែងប្លន់យកបទពិសោធន៍នៃគ្រិស្តបរិស័ទពីពួកគេ។ ព្រះបានបង្គាប់ឲ្យពួកគេខិតខំតស៊ូជាមួយនឹងអំណាចដែលព្រះអង្គបានប្រទានឲ្យ ដើម្បីទាក់ទាញលក្ខណៈរបស់បុរសនារីទាំងឡាយឲ្យបានដូចជាព្រះយេស៊ូវគ្រិស្ត។ ពួកគេបានអធិដ្ឋានសូមព្រះគុណថ្មីៗ ជារៀងរាល់ថ្ងៃ ដើម្បីឲ្យឈានដល់ភាពគ្រប់លក្ខណ៍កាន់តែខ្ពស់ឡើងៗ។ នៅក្រោមកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ សូម្បីតែអ្នកខ្សោយបំផុត ដែលមានបទពិសោធន៍ជាមួយនឹងព្រះក៏បានរៀនបង្កើនអំណាចដែលព្រះប្រទានឲ្យរបស់ពួកគេ ហើយបានក្លាយជាមនុស្សបរិសុទ្ធ ស្អាតស្អំ និងថ្លៃថ្នូរដែរ។ ក្នុងនាមជាមនុស្ស ពួកគេបានចុះចូលជាមួយនឹងឥទ្ធិពលនៃការប៉ាន់ថ្មៃនៃព្រះវិញ្ញាណបរិសុទ្ធ ពួកគេបានទទួលភាពគ្រប់លក្ខណ៍របស់ព្រះត្រៃសរណៈ ហើយបានធ្វើតាមគំរូពីព្រះដល់អ្នកដទៃ។

ពេលវេលាដែលកន្លងផុតទៅ មិនបានផ្លាស់ប្តូរសេចក្តីសន្យាចុងក្រោយរបស់ព្រះយេស៊ូវ ថានឹងប្រទានព្រះវិញ្ញាណបរិសុទ្ធ មកធ្វើជាតំណាងរបស់ព្រះអង្គនោះឡើយ ។ ការដែលព្រះគុណរបស់ព្រះមិនបានហូរធ្លាក់មកដល់មនុស្សនៅលើផែនដីនេះ នោះមិនមែនជាកំហុសរបស់ព្រះទេ។ ប្រសិនបើការសម្រេចតាមសេចក្តីសន្យានោះមិនបានកើតឡើងតាមការដែលត្រូវកើតមកនោះ គឺមកពីមនុស្សមិនបានកោតសរសើរដល់ការដែលនឹងកើតឡើងតាមសេចក្តីសន្យានោះទៅវិញទេ។ ប្រសិនបើមនុស្សទាំងអស់ចង់បាន ពួកគេទាំងអស់នឹងត្រូវបំពេញដោយព្រះវិញ្ញាណបរិសុទ្ធ។ នៅទីណាដែលមនុស្សមិនសូវត្រូវការព្រះវិញ្ញាណបរិសុទ្ធ គេនឹងមើលឃើញព្រះវិញ្ញាណមានភាពក្រៀមស្ងួត មានភាពខ្មៅងងឹត មានការបាក់បែក និងសេចក្តីស្លាប់នៅទីនោះដែរ។ នៅពេលណាដែលមានការចាប់អារម្មណ៍តិចតួច អំណាចរបស់ព្រះដែលជាសេចក្តីត្រូវការចាំបាច់សម្រាប់ការលូតលាស់របស់ពួកជំនុំ និងដែលនឹងនាំមកនូវព្រះពរទាំងឡាយនៅក្នុងបណ្តាញរបស់ខ្លួននោះ ក៏

មានការខ្វះខាតដែរ ទោះបីជាព្រះបានប្រទានមកច្រើនឥតគណនាយ៉ាងណាក៏ដោយ ។

ដោយសារការនេះគឺជាមធ្យោបាយដែលយើងទទួលអំណាច តើហេតុអ្វីបានជាយើងមិនស្រេកឃ្លានចង់បានអំណោយទាននៃព្រះវិញ្ញាណនេះ? តើហេតុអ្វីបានយើងមិននិយាយអំពីអំណោយទាននេះ មិនអធិដ្ឋានសុំអំណោយទាននេះ មិនអធិប្បាយអំពីអំណោយទាននេះ?ព្រះជាម្ចាស់សព្វព្រះហឫទ័យចង់ប្រទានអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ដល់អ្នកដែលបម្រើទ្រង់ ខ្លាំងជាងឪពុកម្ដាយដែលចង់ផ្ដល់រង្វាន់ដល់កូនៗទៅទៀត។ ព្រោះការជ្រមុជដោយព្រះវិញ្ញាណជារៀងរាល់ថ្ងៃ អ្នកបម្រើកិច្ចការនឹងទូលថ្វាយការចង់បានរបស់គេដល់ព្រះ។ ក្រុមនៃពួកគ្រិស្តបរិស័ទគួរជួបជុំគ្នាដើម្បីទូលសុំជំនួយដ៏ពិសេសនេះ សុំប្រាជ្ញានៃឋានសួគ៌ ដើម្បីឲ្យពួកគេអាចធ្វើផែនការនិងអនុវត្តផែនការនោះបានយ៉ាងល្អប្រពៃ។ ជាពិសេស ពួកគេគួរតែអធិដ្ឋានសុំឲ្យព្រះជ្រមុជដល់រាជទូតដែលបានជ្រើសតាំងរបស់ព្រះអង្គ ដែលនៅតាមកន្លែងបំពេញបេសកកម្មផ្សេងៗ ដោយព្រះវិញ្ញាណបរិសុទ្ធដ៏បរិបូរ។ ព្រះវត្តមាននៃព្រះវិញ្ញាណជាមួយនឹងអ្នកបម្រើការរបស់ព្រះនឹងផ្ដល់អំណាចដល់ការប្រកាសសេចក្ដីពិត ដែលមិនមានកិត្តិយសឬសិរីល្អណាក្នុងលោកនេះអាចផ្ដល់ឲ្យបានឡើយ។ នៅកន្លែងណាដែលគេទៅដល់ ព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយនឹងអ្នកធ្វើការដែលហ៊ានលះបង់។ ព្រះបន្ទូលដែលព្រះបានមានបន្ទូលជាមួយនឹងពួកសាវ័ក ព្រះអង្គក៏មានបន្ទូលមកយើងដែរ។ ព្រះវិញ្ញាណដែលជួយកម្សាន្តចិត្តរបស់យើង ព្រះអង្គក៏ជារបស់ពួកគេដែរ។ ព្រះវិញ្ញាណប្រទានកម្លាំងដល់អ្នកដែលខំប្រឹងប្រែង ដល់មនុស្សដែលពុះពារជាមួយនឹងបញ្ហាបន្ទាន់ៗ នៅកណ្ដាលសម្អប់នៃពិភពលោក និងធ្វើឲ្យស្គាល់ការបរាជ័យនិងកំហុសរបស់ពួកគេផ្ទាល់។ នៅក្នុងទុក្ខកង្វល់និងការពិបាកវេទនា នៅពេលដែលសភាពការមើលទៅហាក់ដូចជាងងឹតសូន្យសុង ហើយអនាគតហាក់ដូចជាច្របូកច្របល់ រួចយើងមានអារម្មថាអស់សង្ឃឹមនិងឯកោ ទាំងអស់នេះគឺជាពេលដែលព្រះវិញ្ញាណបរិសុទ្ធនាំ

មកនូវការកម្សាន្តចិត្តដល់យើង ជាការឆ្លើយតបទៅនឹងការអធិដ្ឋានដោយសេចក្តីជំនឿ។

មិនមែនដោយការចូលរួមនៅក្នុងកម្មវិធីពិសេសៗរបស់ព្រះវិហារ គឺជាភស្តុតាងបញ្ជាក់ថាមនុស្សម្នាក់បានក្លាយជាគ្រិស្តបរិស័ទដែលមានព្រលឹងវិញ្ញាណខ្ពស់នោះទេ។ ភាពបរិសុទ្ធមិនមែនជាអារម្មណ៍រីករាយនោះទេ ប៉ុន្តែគឺជាការចុះចូលជាមួយនឹងព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ព្រះ គឺជាការធ្វើតាមព្រះហឫទ័យនៃព្រះវរបិតាដែលគង់នៅឋានសួគ៌ គឺជាការទុកចិត្តដល់ព្រះនៅគ្រាពិបាក នៅក្នុងភាពងងឹត ក៏ដូចជានៅក្នុងពន្លឺដែរគឺជាការដើរដោយជំនឿ មិនមែនដោយការមើលឃើញទេ គឺជាការទីពឹងទៅលើព្រះដោយការទុកចិត្តឥតសង្ស័យ និងជាការសម្រាកនៅក្នុងសេចក្តីស្រឡាញ់របស់ទ្រង់ ។

**<u>អង្គារ-៧ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ២៨**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *កាលណាទ្រង់បានយាងមកហើយ នោះទ្រង់នឹងសំដែងឲ្យមនុស្សលោកដឹងច្បាស់ ពីអំពើបាប ពីសេចក្តីសុចរិត ហើយពីសេចក្តីជំនុំជំរះ គឺពីអំពើបាបដោយព្រោះគេមិនជឿដល់ខ្ញុំ ពីសេចក្តីសុចរិត ដោយព្រោះខ្ញុំទៅឯព្រះវរបិតាខ្ញុំ ហើយអ្នករាល់គ្នាមិនឃើញខ្ញុំទៀតទេ និងពីសេចក្តីជំនុំជំរះ ដោយព្រោះចៅហ្វាយរបស់លោកីយ៍នេះត្រូវទោសហើយ។ យ៉ូហាន១៦:៨-១១*

យើងមិនចាំបាច់អាចផ្តល់និយមន័យពីព្រះវិញ្ញាណបរិសុទ្ធនោះទេ។ ព្រះគ្រិស្តមានបន្ទូលប្រាប់យើងថា ព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះដែលជួយកម្សាន្តចិត្ត «គឺជាព្រះវិញ្ញាណនៃសេចក្តីពិត ដែលចេញពីព្រះវរបិតាមក» ។ ព្រះបានមានបន្ទូលយ៉ាងច្បាស់អំពីព្រះវិញ្ញាណបរិសុទ្ធថា នៅក្នុងកិច្ចការនៃការដឹកនាំមនុស្សឲ្យចូលក្នុងសេចក្តីពិត «ដ្បិតទ្រង់នឹងមានព្រះបន្ទូលមិនមែនដោយអាងព្រះអង្គទ្រង់ទេ» (យ៉ូហាន ១៥:២៦ និង ១៦:១៣) ។

និស្ស័យនៃព្រះវិញ្ញាណបរិសុទ្ធគឺមានអាថ៌កំបាំង។ មនុស្សមិនអាច

ពន្យល់ពីព្រះអង្គបានទេ ពីព្រោះព្រះជាម្ចាស់មិនបានបើកបង្ហាញអំពីរឿងនោះប្រាប់គេ ។ មនុស្សមានគំនិតរវើរវាយ អាចរួមបញ្ចូលសារនៃព្រះគម្ពីរបញ្ចូលគ្នា ហើយបង្កើតជាប្រយោគនៅលើសារទាំងនោះ ប៉ុន្តែ ការទទួលគំនិតទាំងនោះនឹងមិនពង្រឹងកម្លាំងដល់ពួកជំនុំឡើយ។ ទាក់ទងទៅនឹងអាថ៌កំបាំងដ៏ជ្រាលជ្រៅដែលមនុស្សមិនអាចយល់បានបែបនេះ ការនៅស្ងៀមនោះប្រសើរជាង តួនាទីរបស់ព្រះវិញ្ញាណបរិសុទ្ធត្រូវបានបញ្ជាក់ប្រាប់ផ្សេងៗគ្នា នៅក្នុងព្រះបន្ទូលរបស់ព្រះគ្រិស្ត៖ «កាលណាទ្រង់បានយាងមកហើយ នោះទ្រង់នឹងសម្តែងឲ្យមនុស្សលោកដឹងច្បាស់ ពីអំពើបាបពីសេចក្តីសុចរិត ហើយពីសេចក្តីជំនុំជម្រះ» (យ៉ូហាន ១៦:៨)។ គឺព្រះវិញ្ញាណបរិសុទ្ធដែលធ្វើឲ្យយើងស្គាល់បាប។ ប្រសិនបើបាបជនឆ្លើយតបទៅនឹងឥទ្ធិពលដ៏រហ័សនៃព្រះវិញ្ញាណ នោះព្រះអង្គនឹងនាំមកនូវការកែប្រែចិត្ត និងការភ្ញាក់រឭកឲ្យស្តាប់បង្គាប់ដល់តម្រូវការរបស់ព្រះ។

ព្រះវិញ្ញាណបរិសុទ្ធបានបង្ហាញនូវកូនចៀមដែលដោះបាបមនុស្សលោកដល់បាបជនដែលកំពុងតែស្រេកឃ្លានសេចក្តីសុចរិត។ «ទ្រង់នឹងតម្កើងខ្ញុំ ដ្បិតទ្រង់នឹងយកសេចក្តីដែលតម្រូវពីខ្ញុំ មកប្រាប់ដល់អ្នករាល់គ្នា»។ ព្រះគ្រិស្តបានមានបន្ទូលថា «ទ្រង់នឹងបង្រៀនអ្នករាល់គ្នា ពីគ្រប់សេចក្តីទាំងអស់ក៏នឹងរំឭកពីគ្រប់ទាំងសេចក្តីដែលខ្ញុំបានប្រាប់ដល់អ្នករាល់គ្នាដែរ» (យ៉ូហាន ១៦:១៤ និង ១៤:២៦) ។

ព្រះបានប្រទានព្រះវិញ្ញាណមក ជាភ្នាក់ងារនៃការបំផ្លាស់បំប្រែ ដើម្បីធ្វើឲ្យសេចក្តីសង្គ្រោះដែលកើតឡើង ដោយការសុគតរបស់ព្រះអង្គដ៏ប្រោសលោះរបស់យើងមានប្រសិទ្ធិភាព។ ព្រះវិញ្ញាណកំពុងស្វែងរកទាក់ទាញអារម្មណ៍របស់មនុស្ស ឲ្យបែរទៅរកតង្វាយយញ្ញបូជាដែលបានថ្វាយនៅឯឈើឆ្កាងនៃភ្នំកាល់វ៉ារី ដើម្បីបើកបង្ហាញពីសេចក្តីស្រឡាញ់របស់ព្រះ ដល់លោកិយ និងដើម្បីបើកចិត្តអ្នកដែលបានកែប្រែ អំពីរឿងដ៏មានតម្លៃនៅក្នុងព្រះគម្ពីរ ។

ដោយធ្វើឲ្យមនុស្សបានស្គាល់អំពើបាប និងការបង្ហាញពីស្តង់ដារនៃ

សេចក្តីសុចរិតនៅចំពោះគំនិតមនុស្ស ព្រះវិញ្ញាណបរិសុទ្ធដកសេចក្តីស្រឡាញ់ចេញពីរឿងរ៉ាវទាំងឡាយនៅលើផែនដី ហើយបំពេញគំនិតដោយសេចក្តីប្រាថ្នានូវភាពបរិសុទ្ធ។ ព្រះអង្គសង្គ្រោះបានមានបន្ទូលថា «នោះទ្រង់នឹងនាំអ្នករាល់គ្នាចូលក្នុងគ្រប់ទាំងសេចក្តីពិត» (យ៉ូហាន ១៦:១៣)។ ប្រសិនបើមនុស្សចង់ឲ្យព្រះវិញ្ញាណកែច្នៃ ព្រះអង្គនឹងនាំមកនូវការញែកជាបរិសុទ្ធដល់មនុស្សទាំងមូល។ ព្រះវិញ្ញាណនឹងយករឿងរ៉ាវរបស់ព្រះ ហើយបោះត្រារឿងទាំងនោះនៅក្នុងចិត្តរបស់មនុស្ស។ ដោយអំណាចរបស់ទ្រង់ ផ្លូវជីវិតនឹងត្រូវបានធ្វើឲ្យត្រង់ ដែលមិនមានអំពើខុសឆ្គងណាមួយនៅក្នុងនោះឡើយ។

ព្រះបានកំពុងធ្វើការដោយព្រះវិញ្ញាណបរិសុទ្ធ តាមរយៈមនុស្សធ្វើជាឧបករណ៍ដើម្បីសម្រេចព្រះរាជគោលបំណងរបស់ទ្រង់ ជំនួសពូជមនុស្សដែលធ្លាក់ចុះ តាំងពីដើមដំបូងមក ។ ការនេះត្រូវបានបង្ហាញនៅក្នុងជីវិតនៃពួកអយ្យកោ (ចាស់ទុំពីបុរាណ)។ នៅសម័យលោកម៉ូសេ ព្រះក៏បានប្រទាន «ព្រះវិញ្ញាណដ៏ល្អរបស់ទ្រង់ មកបង្ហាត់បង្រៀន» (នេហេមា ៩:២០) ដល់ពួកជំនុំនៅទីរហោស្ថានផងដែរ។ ហើយនៅសម័យពួកសាវ័ក ព្រះអង្គបានធ្វើការយ៉ាងអស្ចារ្យ តាមរយៈភ្នាក់ងារនៃព្រះវិញ្ញាណបរិសុទ្ធ។ ព្រះចេស្តាដដែល ដែលបានទ្រទ្រង់ពួកអយ្យកោ បានប្រទានជំនឿនិងសេចក្តីក្លាហានដល់លោកកាលែប និងយ៉ូស្វេ  និងដែលធ្វើឲ្យកិច្ចការនៃពួកជំនុំសម័យពួកសាវ័កមានជោគជ័យ ក៏បានលើកតម្កើងកូនៗដ៏ស្មោះត្រង់របស់ព្រះឲ្យមានជោគជ័យគ្រប់សម័យកាលផងដែរ។ គឺដោយសារព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធនេះហើយ ដែលពួកវ៉លឌិនសៀននៅយុគសម័យខ្មៅងងឹតបានជួយរៀបចំឲ្យមានការកែទម្រង់ឡើង ។ គឺព្រះចេស្តាដដែលនោះឯងដែលធ្វើឲ្យការខំប្រឹងប្រែងរបស់បុរសនារីដ៏ថ្លៃថ្នូរមានជោគជ័យដែលត្រួសត្រាយផ្លូវដើម្បីបង្កើតបេសកកម្មសម័យទំនើប និងបកប្រែព្រះគម្ពីរទៅជាភាសារបស់មនុស្សគ្រប់សាសន៍ ។

ហើយសព្វថ្ងៃនេះ ព្រះក៏កំពុងប្រើពួកជំនុំរបស់ទ្រង់ឲ្យប្រកាសប្រាប់

ពីព្រះរាជគោលបំណងរបស់ព្រះ ប្រាប់ដល់មនុស្សនៅលើផែនដីនេះ ។ សព្វថ្ងៃនេះ អ្នកនាំដំណឹងពីឈើឆ្កាងកំពុងធ្វើដំណើរពីទីក្រុងមួយ ទៅទីក្រុងមួយ និងពីទឹកដីមួយ ទៅទឹកដីមួយ ដើម្បីរៀបចំផ្លូវសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះគ្រិស្ត ។ ស្តង់ដារនៃក្រឹត្យវិន័យរបស់ព្រះកំពុងត្រូវបានមនុស្សលើកតម្កើង។ ព្រះវិញ្ញាណដែលមានសព្វព្រះចេស្តាកំពុងជំរុញចិត្តមនុស្ស ហើយអ្នកដែលឆ្លើយតបទៅនឹងឥទ្ធិពលរបស់ទ្រង់បានក្លាយជាទីបន្ទាល់ពីព្រះ និងសេចក្តីពិត។ នៅទីកន្លែងជាច្រើន គេបានឃើញបុរសនារីដែលមានការលះបង់ទាំងឡាយពាំនាំពន្លឺដល់មនុស្សដទៃ ដើម្បីបង្ហាញឲ្យពួកគេដឹងច្បាស់ពីផ្លូវនៃការសង្គ្រោះដោយសារព្រះគ្រិស្ត។ ហើយនៅពេលដែលពួកគេកំពុងបន្តជះពន្លឺរបស់គេឲ្យភ្លឺចែងចាំង ដូចជាពួកអ្នកដែលបានទទួលបុណ្យជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធនៅថ្ងៃប៉ង់តាកូសដែរនោះ ពួកគេទទួលព្រះចេស្តារបស់ព្រះវិញ្ញាណច្រើនឡើងៗ។ ដូច្នេះ ផែនដីក៏ត្រូវបានបំភ្លឺដោយសិរីល្អរបស់ព្រះ។

<u>ពុធ-៨ កក្កដា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ២៩**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ក្រោយគ្រានោះ អញនឹងចាក់វិញ្ញាណរបស់អញទៅលើគ្រប់ទាំងមនុស្ស នោះកូនប្រុសស្រីរបស់ឯងនឹងទាយ ពួកចាស់ៗរបស់ឯងនឹងយល់សប្តិឃើញ ហើយពួកកំឡោះៗរបស់ឯងនឹងឃើញការជាក់ស្តែង។ យ៉ូអែល ២:២៨*

ម្យ៉ាងវិញទៀត អ្នកខ្លះកំពុងរង់ចាំឱកាសពិសេសនៃភាពស្រស់ស្រាយខាងវិញ្ញាណ ដើម្បីបំភ្លឺដល់មនុស្សដទៃ ជំនួសឲ្យការបង្កើនឱកាសដែលកំពុងមានស្រាប់នោះ ពួកគេបានប្រើឱកាសដែលមាននៅក្នុងដៃជាការឥតប្រយោជន៍ទទេទៅវិញ ។ ពួកគេបានបដិសេធភារកិច្ចនិងឱកាស ហើយបណ្តោយឲ្យពន្លឺរបស់ពួកគេមានភាពស្រអាប់ នៅពេលដែលពួកគេសម្លឹងមើលទៅខាងមុខ ទៅកាន់ពេលដែលព្រះប្រទានព្រះពរពិសេសដល់ពួកគេ ដោយគេត្រូវបានផ្លាស់ប្រែ ហើយមានសមត្ថភាពស្របទៅតាមកិច្ចការរបស់

ព្រះ ដោយមិនបានខិតខំប្រឹងប្រែងខ្លួនឯងសោះ ។

ជាការពិតណាស់ដែលថានៅសម័យចុងក្រោយ ពេលដែលកិច្ចការនៅលើផែនដីកំពុងបញ្ចប់ ការខំប្រឹងប្រែងដ៏ស្មោះត្រង់ដែលធ្វើឡើងដោយពួកអ្នកជឿ ដែលមានការលះបង់ នៅក្រោមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ ត្រូវតែសម្រេចបានដោយនិមិត្តរូបនៃការគាប់ព្រះទ័យដល់ព្រះ។ នៅក្រោមរូបភាពនៃភ្លៀងដើមរដូវ និងភ្លៀងចុងរដូវ ដែលធ្លាក់មកលើទឹកដីភាគខាងកើត នៅរដូវសាបព្រោះ និងរដូវប្រមូលផល ហោរាសាសន៍ហេព្រើរបានទស្សទាយពីការប្រទានព្រះគុណខាងព្រះវិញ្ញាណ ដែលមានទំហំធំធេងខុសពីធម្មតា មកលើពួកជំនុំរបស់ព្រះ ការចាក់បង្ហូរព្រះវិញ្ញាណនៅថ្ងៃប៉ង់តាកូសរបស់ពួកសាវ័ក គឺជាការចាប់ផ្ដើមនៃភ្លៀងដើមឆ្នាំ ឬដើមរដូវ ហើយមានលទ្ធផលដ៏រុងរឿង ។ នៅគ្រាអវសាន្ត (គ្រាចុងក្រោយបង្អស់) ព្រះវត្តមាននៃព្រះវិញ្ញាណត្រូវគង់នៅជាមួយនឹងពួកជំនុំស្មោះត្រង់។

ប៉ុន្តែ នៅជិតទីចុងបំផុតនៃចម្រូតនៅផែនដី ការប្រទានព្រះគុណជាពិសេសត្រូវបានសន្យា ដើម្បីរៀបចំពួកជំនុំសម្រាប់ការយាងមករបស់កូនមនុស្ស (ព្រះយេស៊ូវ) ។ ការចាក់បង្ហូរព្រះវិញ្ញាណប្រៀបដូចជាការធ្លាក់មកនៃភ្លៀងចុងឆ្នាំ ហើយការនេះគឺសម្រាប់ព្រះចេស្ដាបន្ថែមដែលគ្រិស្តបរិស័ទត្រូវតែទូលថ្វាយសំណូមពររបស់ពួកគេដល់ព្រះជាម្ចាស់នៃចម្រូត«នៅវេលាភ្លៀងចុងរដូវ»។ ជាចម្លើយ «ពីព្រោះទ្រង់ប្រទានភ្លៀងដំបូងមកតាមខ្នាតត្រឹមត្រូវ ... គឺជាភ្លៀងដើម និងភ្លៀងចុងរដូវ» (សាការី ១០:១ និង យ៉ូអែល ២:២៣)។

ប៉ុន្តែ ដរាបណាពួកជំនុំរបស់ព្រះសព្វថ្ងៃនេះមានទំនាក់ទំនងដ៏រស់ជាមួយនឹងព្រះដែលជាប្រភពនៃការចម្រើនលូតលាស់ខាងព្រលឹងវិញ្ញាណ នោះពួកគេមិនទាន់រៀបចំខ្លួនសម្រាប់ពេលប្រមូលផលនៅឡើយ។ ដរាបណាពួកគេមិនរក្សាចង្កៀងរបស់ពួកគេឲ្យបានរៀបរយនិងឆេះជានិច្ចនោះទេ ពួកគេនឹងបរាជ័យក្នុងការទទួលព្រះគុណដែលជាជំនួយ នៅពេលដែលមានសេចក្ដីត្រូវការហើយ ។

អស់អ្នកដែលគ្រាន់តែបន្តទទួលការផ្ដល់ព្រះគុណដ៏ស្រស់ថ្លា នឹង

ទទួលព្រះចេស្ដាសមស្របទៅនឹងសេចក្ដីត្រូវការប្រចាំថ្ងៃនិងលទ្ធភាពរបស់ពួកគេ ក្នុងការប្រើប្រាស់ព្រះចេស្ដានោះ ជំនួសឲ្យការសម្លឹងមើលទៅខាងមុខ ឆ្ពោះទៅពេលអនាគត ជាពេលដែលពួកគេនឹងទទួលការអស្ចារ្យ តម្រូវទៅតាមការនេសាទមនុស្ស តាមរយៈការប្រទានព្រះចេស្ដា ជាពិសេសពួកគេបន្ទាបខ្លួនទៅរកព្រះ ដែលព្រះអង្គនឹងធ្វើឲ្យពួកគេក្លាយទៅជាភាជន៍សម្រាប់ការប្រើប្រាស់របស់ទ្រង់។ ពួកគេកំពុងបង្កើនឱកាសសម្រាប់ការងារដែលនៅក្នុងដែនកំណត់របស់ពួកគេ ។ ពួកគេកំពុងធ្វើទីបន្ទាល់ពីព្រះដែលជាថៅហ្វាយរបស់ពួកគេ ទោះបីជាពួកគេរស់នៅកន្លែងណាក៏ដោយ នៅក្នុងកន្លែងធ្វើការជាសាធារណៈដ៏មានប្រយោជន៍ ឬធ្វើការនៅក្នុងការបន្ទាបខ្លួននៅកន្លែងធ្វើការនៅតាមផ្ទះក្ដី ។

ចំពោះអ្នកធ្វើការដ៏បរិសុទ្ធមានការកម្សាន្តចិត្តដ៏អស្ចារ្យ នៅក្នុងចំណេះដឹងដែលថា សូម្បីតែព្រះគ្រិស្ដក៏បានស្វែងរកព្រះវរបិតាទ្រង់ជារៀងរាល់ថ្ងៃ ដើម្បីប្រទានព្រះគុណថ្មីតាមតម្រូវការដែរ កាលព្រះអង្គមានព្រះជន្មនៅលើផែនដី ហើយចេញពីទំនាក់ទំនងជាមួយនឹងព្រះនេះមក ព្រះអង្គបានយាងចេញទៅពង្រឹងកម្លាំងនិងប្រទានពរដល់មនុស្សដទៃ។ មើលន៍ព្រះរាជបុត្រានៃព្រះបានអធិដ្ឋានទៅព្រះវរបិតា! ព្រះរាជបុត្រានៃព្រះទ្រង់ពង្រឹងជំនឿដោយការអធិដ្ឋាន ហើយដោយការរួបរួមជាមួយនឹងឋានសួគ៌ ព្រះអង្គបានប្រមូលកម្លាំងដើម្បីទប់ទល់ជាមួយនឹងអារក្ស និងដើម្បីបម្រើដល់សេចក្ដីត្រូវការរបស់មនុស្ស។ ក្នុងនាមជាបងប្រុសនៃមនុស្សជាតិរបស់យើង ព្រះអង្គជ្រាបពីភាពចាំបាច់នៃអស់អ្នកដែលនៅតែមានបំណងចង់បម្រើដល់ទ្រង់ដែលបានហ៊ុំព័ទ្ធដោយការពិបាក និងដែលកំពុងរស់នៅក្នុងពិភពលោកនៃអំពើបាប ព្រះអង្គជ្រាបថា ពួកអ្នកនាំសារដែលព្រះអង្គទតឃើញថាគួរនឹងចាត់ឲ្យទៅនោះ ជាមនុស្សកម្សោយ ជាមនុស្សមានកំហុស ប៉ុន្តែ ចំពោះអស់អ្នកណាដែលបានថ្វាយខ្លួនដាច់ចំពោះព្រះរាជកិច្ចរបស់ទ្រង់ ព្រះអង្គសន្យាថានឹងប្រទានជំនួយដែលមកពីព្រះ។ គំរូរបស់ព្រះអង្គគឺជាការធានាអះអាងយ៉ាងស្មោះស្ម័គ្រ គឺការទូលអង្វរទៅព្រះដោយជំនឿជាប្រចាំ ជំនឿដែលដឹក

នាំទៅរកការទីពឹងដល់ព្រះទាំងស្រុង និងលះបង់ដើម្បីកិច្ចការរបស់ទ្រង់ឥតសំចៃទុកអ្វីសោះ នឹងជួយនាំជំនួយនៃព្រះវិញ្ញាណដល់មនុស្ស នៅក្នុងសមរភូមិជាមួយនឹងអំពើបាប ។

ព្រះនឹងរៀបចំអ្នកធ្វើការដែលដើរតាមគំរូរបស់ព្រះគ្រិស្ត ឲ្យទទួល និងប្រើប្រាស់ព្រះចេស្តាដែលព្រះបានសន្យាដល់ពួកជំនុំ ដើម្បីប្រមូលផលនៃចម្រូតនៅផែនដីនេះ។ ពីព្រឹកមួយទៅព្រឹកមួយ ខណៈដែលអ្នកផ្សាយដំណឹងល្អលុតជង្គង់នៅចំពោះព្រះ ហើយរំឭកអំពីការសច្ចានៃការថ្វាយជីវិតដល់ទ្រង់ ព្រះអង្គនឹងប្រទានដល់ពួកគេនូវព្រះវត្តមាននៃព្រះវិញ្ញាណរបស់ទ្រង់ជាមួយនឹងព្រះចេស្តាដ៏រស់និងដ៏បរិសុទ្ធនៃព្រះវិញ្ញាណនោះ។ នៅពេលដែលពួកគេចេញទៅបំពេញកិច្ចការប្រចាំថ្ងៃ ពួកគេមានការធានារ៉ាប់រងថាភ្នាក់ងារនៃព្រះវិញ្ញាណបរិសុទ្ធដែលមនុស្សមើលមិនឃើញជំរុញពួកគេឲ្យអាច «ធ្វើការជាមួយនឹងព្រះ» ។

## ជំពូកទី ៦

# នៅត្រង់មាត់ទ្វារព្រះវិហារ

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ជំពូក៣ និង ៤:១-៣១ ។*

ព្រហស្បតិ៍-៩ កក្កដា អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ៣០

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *តែពេត្រុសនិយាយថា ឯប្រាក់ ហើយនិងមាស ខ្ញុំគ្មានទេ តែរបស់ដែលខ្ញុំមាន នោះខ្ញុំនឹងឲ្យដល់អ្នក គឺដោយសារព្រះនាម ព្រះយេស៊ូវគ្រីស្ទ ពីស្រុកណាសារ៉ែត ចូរអ្នកក្រោកឡើងដើរទៅចុះ រួចក៏ចាប់ដៃស្តាំលើកគាត់ឡើង ស្រាប់តែប្រអប់ជើង និងភ្នែកគោររបស់គាត់ មានកំឡាំងឡើងភ្លាម គាត់ក៏ស្ទុះឈរឡើងដើរទៅមក ហើយចូលទៅក្នុងព្រះវិហារជាមួយនឹងអ្នកទាំង២នោះ ទាំងដើរ ទាំងលោត ទាំងសរសើរព្រះផង បណ្តាជនទាំងអស់គ្នាក៏ឃើញគាត់ដើរ ទាំងសរសើរព្រះដូច្នោះ។*
*កិច្ចការ ៣:៦-៩*

ពួកសាវ័ករបស់ព្រះគ្រិស្តដឹងយ៉ាងច្បាស់អំពីកង្វះសមត្ថភាពរបស់ពួកគេ ហើយពួកគេបានបង្រួបបង្រួមភាពកម្សោយរបស់ពួកគេជាមួយនឹងកម្លាំងរបស់ព្រះ ភាពល្ងិតល្ងង់របស់ពួកគេ ជាមួយនឹងព្រះតម្រិះរបស់ព្រះ ភាពគ្មានតម្លៃរបស់ពួកគេ ជាមួយនឹងសេចក្តីសុចរិតរបស់ព្រះ ភាពក្រីក្ររបស់ពួកគេ ជាមួយនឹងសម្បត្តិមហាសាលរបស់ព្រះ ។ ដោយបានពង្រឹងកម្លាំងនិងរៀបចំខ្លួនដូច្នេះ ពួកគេមិនញញើតនឹងបោះជំហានទៅមុខដើម្បីបម្រើកិច្ចការរបស់ព្រះដែលជាថៅហ្វាយរបស់ពួកគេឡើយ ។

មិនយូរប៉ុន្មាន បន្ទាប់ពីការយាងចុះមករបស់ព្រះវិញ្ញាណបរិសុទ្ធ និងបន្ទាប់ពីការអធិដ្ឋានដោយស្មោះអស់ពីចិត្តភ្លាមៗមក លោកពេត្រុសនិង

យ៉ូហានក៏ធ្វើដំណើរទៅព្រះវិហារដើម្បីថ្វាយបង្គំព្រះ ហើយបានឃើញជនពិការម្នាក់ មានអាយុសែសិបឆ្នាំ នៅមាត់ទ្វារលម្អនៃព្រះវិហារ ជីវិតរបស់គាត់ពោរពេញដោយការឈឺចាប់និងពិការភាពតាំងពីកំណើតមក។ បុរសដ៏កម្សត់នេះប្រាថ្នាចង់ជួបព្រះយេស៊ូវជាយូរមកហើយ ដើម្បីឲ្យខ្លួនបានជាពីពិការភាពនេះ ប៉ុន្តែ សេចក្ដីសង្ឃឹមរបស់គាត់ហៀបតែនឹងរលាយបាត់ទៅហើយ ហើយដំណឹងពីកិច្ចការរបស់មហាគ្រូពេទ្យ (ព្រះយេស៊ូវ) នោះក៏ត្រូវបានឃ្លាតឆ្ងាយពីគំនិតគាត់ដែរ។ ទីបំផុតការអង្វរកររបស់គាត់បានទាក់ទាញឲ្យមិត្តភក្តិរបស់គាត់ខ្លះនាំគាត់ទៅកាន់មាត់ទ្វារព្រះវិហារ ប៉ុន្តែ នៅពេលដែលគាត់បានទៅដល់ទីនោះគាត់បានដឹងថាគ្រូពេទ្យដែលជាសេចក្ដីសង្ឃឹមរបស់គាត់នោះ ត្រូវបានគេសម្លាប់យ៉ាងឃោរឃៅបាត់ទៅហើយ ។

ការខកចិត្តរបស់គាត់បានទាក់ទាញការអាណិតអាសូរពីសំណាក់អ្នកដែលបានដឹងពីការអន្ទះសាចង់បានការព្យាបាលពីព្រះយេស៊ូវជាយូរអង្វែងហើយនោះ ហើយពួកគេបាននាំគាត់មកកាន់ព្រះវិហារជារៀងរាល់ថ្ងៃដើម្បីឲ្យភាពលំបាកវេទនានោះអាចទាក់ទាញការអាណិតអាសូរ ហើយផ្ដល់ប្រាក់បន្តិចបន្តួច សម្រាប់ជួយបន្ធូរចំណង់របស់គាត់។ នៅពេលដែលលោកពេត្រុសនិងយ៉ូហានបានមកដល់ គាត់ក៏បានសុំទានខ្លះពីលោកទាំងពីរ។ សាវ័កទាំងពីរបានសម្លឹងមើលទៅគាត់ដោយការអាណិតអាសូរ រួចពេត្រុសនិយាយថា «ចូរមើលមកយើងឯណេះ គាត់ក៏ស្ដាប់តាមដោយសង្ឃឹមថានឹងបានអ្វីខ្លះ តែពេត្រុសនិយាយថា ឯប្រាក់ ហើយនិងមាស ខ្ញុំគ្មានទេ»។ ខណៈដែលលោកពេត្រុសបានមានប្រសាសន៍អំពីភាពក្រីក្ររបស់លោកដូច្នេះ ទឹកមុខរបស់ជនពិការនោះក៏ធ្លាក់ក្រៀមចុះ ប៉ុន្តែ ទឹកមុខនោះបានភ្លឺចាំងចែងឡើងវិញជាមួយនឹងសេចក្ដីសង្ឃឹម នៅពេលដែលសាវ័កបន្តទៅទៀតថា «តែរបស់ដែលខ្ញុំមាន នោះខ្ញុំនឹងឲ្យដល់អ្នក គឺដោយសារព្រះនាមព្រះយេស៊ូវគ្រិស្ត ពីស្រុកណាសារ៉ែត ចូរអ្នកក្រោកឡើងដើរទៅចុះ»។ «រួចក៏ចាប់ដៃស្ដាំលើកគាត់ឡើង ស្រាប់តែប្រអប់ជើង និងភ្នែកគោររបស់គាត់ មានកម្លាំង

ឡើងភ្លាម គាត់ក៏ស្ទុះឈរឡើងដើរទៅមក ហើយចូលទៅក្នុងព្រះវិហារជាមួយនឹងអ្នកទាំងពីរនោះ ទាំងដើរ ទាំងលោត ទាំងសរសើរព្រះផង បណ្ដាជនទាំងអស់គ្នាក៏ឃើញគាត់ដើរ ទាំងសរសើរព្រះដូច្នោះ ហើយគេស្គាល់គាត់ថាជាអ្នកដែលតែងតែអង្គុយសូមទានគេ នៅត្រង់មាត់ទ្វារលម្អរបស់ព្រះវិហារនោះគេក៏មានពេញជាសេចក្ដីអស្ចារ្យ ហើយមមីងមមាំងពីការដែលកើតមកនោះ»។ «ដូច្នេះកំពុងដែលគាត់ចាប់តោងឃាត់ពេត្រុស និងយ៉ូហាននោះបណ្ដាជនទាំងអស់ក៏រត់មូលមកឯគេ នៅត្រង់បាំងសាចដែលហៅថាបាំងសាចសាឡូម៉ូន ហើយគេមានសេចក្ដីអស្ចារ្យក្នុងចិត្តណាស់»។ ពួកគេមានការភ្ញាក់ផ្អើលជាខ្លាំងដោយបានឃើញពួកសាវ័កអាចសម្ដែងបាដិហារ្យដូចជាការដែលព្រះយេស៊ូវបានសម្ដែងដូច្នោះដែរ។ ហើយឥឡូវនេះបុរសដែលបានពិការសែសិបឆ្នាំមកហើយនេះកំពុងតែមានអំណរនៅក្នុងការប្រើប្រាស់អវយវៈរបស់គាត់ មានសេរីភាពពីការឈឺចាប់ និងមានសេចក្ដីរីករាយជាមួយនឹងជំនឿលើព្រះយេស៊ូវ។ នៅពេលពួកសាវ័កបានឃើញការភ្ញាក់ផ្អើលរបស់ពួកបណ្ដាជន លោកពេត្រុសបានសួរថា «ឱសាសន៍អ៊ីស្រាអែលរាល់គ្នាអើយ ហេតុអ្វីបានជាមានសេចក្ដីប្លែកក្នុងចិត្តពីការនេះ ហើយសម្លឹងមើលមកយើងខ្ញុំ ហាក់ដូចជាយើងខ្ញុំបានធ្វើឲ្យមនុស្សនេះដើររួច ដោយអាងអំណាច ឬគុណានុភាពរបស់ខ្លួនយើងខ្ញុំដូច្នេះ?» លោកបានបញ្ជាក់ថាការព្យាបាលនេះបានកើតឡើងដោយព្រះនាមនិងតាមរយៈការអស្ចារ្យនៃព្រះយេស៊ូវពីស្រុកណាសារ៉ែត ដែលព្រះបានប្រោសឲ្យមានព្រះជន្មរស់ឡើងវិញទេតើ។ សាវ័កនេះបានមានប្រសាសន៍ថា «ហើយគឺដោយសារសេចក្ដីជំនឿ ជឿដល់ព្រះនាមទ្រង់ នោះព្រះនាមទ្រង់បានប្រោសមនុស្សនេះដែលអ្នករាល់គ្នាឃើញ ហើយស្គាល់ ឲ្យមានកម្លាំងឡើង គឺជាសេចក្ដីជំនឿដែលកើតមក ដោយសារព្រះអង្គនោះឯង បានធ្វើឲ្យគាត់ជាស្រឡះ នៅមុខអ្នករាល់គ្នាដូច្នេះ» ។

## ស្សុក្រ-១០ កក្កដា អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី១ ជំពូក ៣១

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ដូច្នេះ ចូរប្រែចិត្ត ហើយវិលមកចុះ ដើម្បីឲ្យបាបរបស់អ្នករាល់គ្នាបានលុបចេញ ប្រយោជន៍ឲ្យមានពេលលំហើយ មកពីចំពោះព្រះអម្ចាស់។ កិច្ចការ ៣:១៩*

ពួកសាវ័កបាននិយាយយ៉ាងច្បាស់ពីអំពើបាបយ៉ាងធ្ងន់របស់សាសន៍យូដា ក្នុងការបដិសេធន៍និងការធ្វើគុតព្រះអម្ចាស់នៃជីវិត ប៉ុន្តែ ពួកគេប្រុងប្រយ័ត្នមិនបណ្តាលឲ្យអ្នកស្តាប់របស់ពួកគាត់មានការអស់សង្ឃឹមឡើយ។ លោកពេត្រុសបានមានប្រសាសន៍ថា អ្នករាល់គ្នា «មិនព្រមទទួលព្រះដ៏បរិសុទ្ធ ហើយសុចរិតនោះឯង បែរជាសូមឲ្យលោកលែងមនុស្សដែលសម្លាប់គេ ដល់អ្នករាល់គ្នាវិញ អ្នករាល់គ្នាបានសម្លាប់ព្រះអម្ចាស់ជីវិតនោះទៅ តែព្រះបានប្រោសឲ្យទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញ យើងខ្ញុំនេះជាទីបន្ទាល់ពីការនោះឯង»។ «ហើយគឺដោយសារសេចក្តីជំនឿជឿដល់ព្រះនាមទ្រង់ នោះព្រះនាមទ្រង់បានប្រោសមនុស្សនេះ ដែលអ្នករាល់គ្នាឃើញហើយស្គាល់ ឲ្យមានកម្លាំងឡើង គឺជាសេចក្តីជំនឿដែលកើតមកដោយសារព្រះអង្គនោះឯង បានធ្វើឲ្យគាត់ជាស្រឡះ នៅមុខអ្នករាល់គ្នាដូច្នេះ ឥឡូវនេះបងប្អូនអើយ ខ្ញុំដឹងថា អ្នករាល់គ្នា ព្រមទាំងពួកនាហ្មឺននៃអ្នករាល់គ្នាបានប្រព្រឹត្តការនោះ ដោយមិនបានយល់ទេ ប៉ុន្តែ សេចក្តីដែលព្រះបានប្រកាសប្រាប់ជាមុន ដោយសារមាត់នៃអស់ទាំងហោរារបស់ទ្រង់ពីដំណើរព្រះគ្រិស្តថា ទ្រង់ត្រូវរងទុក្ខលំបាកនោះព្រះទ្រង់ក៏បានសម្រេចតាមយ៉ាងដូច្នោះឯង»។ លោកបានមានប្រសាសន៍ថាព្រះវិញ្ញាណបរិសុទ្ធកំពុងបានអំពាវនាវឲ្យពួកគេកែប្រែចិត្ត ហើយវិលមកវិញ លោកបានបញ្ជាក់ប្រាប់ដល់ពួកគេថានឹងមិនមានសេចក្តីសង្ឃឹមអំពីសេចក្តីសង្គ្រោះឡើយ លើកលែងតែតាមរយៈសេចក្តីមេត្តាករុណារបស់ព្រះយេស៊ូវដែលអ្នករាល់គ្នាបានឆ្កាងនោះប៉ុណ្ណោះ មានតែតាមរយៈសេចក្តីជំនឿជឿដល់ព្រះអង្គប៉ុណ្ណោះ ទើបបាបរបស់ពួកគេត្រូវបានអត់ទោស ។

លោកបានស្រែកឡើងថា «ដូច្នេះ ចូរប្រែចិត្ត ហើយវិលមកចុះ ដើម្បីឲ្យបាបរបស់អ្នករាល់គ្នាបានលុបចេញ ប្រយោជន៍ឲ្យមានពេលលម្ហើយមកពីចំពោះព្រះអម្ចាស់»។ «អ្នករាល់គ្នាជាតំណវង្សនៃពួកហោរា និងសេចក្ដីសញ្ញា ដែលព្រះបានតាំងនឹងពួកអយ្យកោយើងរាល់គ្នា ដោយមានព្រះបន្ទូលនឹងលោកអ័ប្រាហាំថា អស់ទាំងគ្រួសារនៅផែនដីនឹងបានពរដោយសារពូជឯង រីឯដែលព្រះបានតាំងព្រះយេស៊ូវ ជាអ្នកបម្រើទ្រង់ឡើង នោះគឺសម្រាប់អ្នករាល់គ្នាជាដើម ហើយក៏ចាត់ទ្រង់មក ដើម្បីនឹងប្រទានពរដល់អ្នករាល់គ្នា ដោយបង្វែរអ្នករាល់គ្នាពីសេចក្ដីអាក្រក់របស់ខ្លួនចេញ»។ ដូច្នេះ ពួកសាវ័កក៏បានអធិប្បាយអំពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រិស្ត។ ពួកអ្នកស្ដាប់ជាច្រើនកំពុងរង់ចាំការអស្ចារ្យនេះ ហើយនៅពេលដែលពួកគេបានឮអំពីដំណឹងនេះ ពួកគេក៏បានជឿ។ ការនេះបាននាំឲ្យពួកគេនឹកឃើញនូវព្រះបន្ទូលដែលព្រះយេស៊ូវធ្លាប់បានមានបន្ទូល ហើយពួកគេបានឈរនៅក្នុងជួរនៃអ្នកដែលបានទទួលដំណឹងល្អ។ គ្រាប់ពូជដែលព្រះគ្រិស្តបានសាបព្រោះបានដុះពន្លក ហើយបានបង្កើតផលផ្លែ។

ខណៈដែលពួកសាវ័កកំពុងតែនិយាយជាមួយនឹងពួកបណ្ដាជន «នោះពួកសង្ឃនិងពួកសាឌូស៊ីព្រមទាំងមេទ័ពរក្សាព្រះវិហារក៏មកដល់គេ មានសេចក្ដីអាក់អន់ចិត្តពីដំណើរដែលគាត់បង្រៀនដល់ពួកជន ហើយក៏សម្ដែងប្រាប់ដល់បណ្ដាជនពីសេចក្ដីរស់ពីស្លាប់ឡើងវិញ ដោយសារព្រះយេស៊ូវ»។ បន្ទាប់ពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវ ពួកសង្ឃបានផ្សព្វផ្សាយដំណឹងកុហកនៅគ្រប់ទីជិតឆ្ងាយទាំងអស់ថា ពួកសិស្សបានលួចព្រះសពរបស់ព្រះយេស៊ូវ នៅពេលទាហានរ៉ូមដេកលក់។ ដូច្នេះការដែលពួកគេមិនសប្បាយចិត្តដោយបានឮការអធិប្បាយរបស់លោកពេត្រុស អំពីការមានព្រះជន្មរស់ឡើងវិញរបស់អ្នកដែលពួកគេបានសម្លាប់នោះ មិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ។ ពួកសាឌូស៊ីបានផ្ទុះកំហឹងពុះពោរឡើង។ ពួកគេបានដឹងថាគោលលទ្ធិសំខាន់បំផុតរបស់ពួកគេកំពុងជួប

នឹងគ្រោះថ្នាក់ហើយ ហើយកិត្តិយសរបស់ពួកគេក៏ត្រូវបានគាំងដំណើរដែរ។

ការកែប្រែចិត្តទទួលជំនឿថ្មីបានកើនឡើងយ៉ាងឆាប់រហ័ស ហើយទាំងពួកសង្ឃនិងពួកសាឌូស៊ីបានឯកភាពគ្នាថា ប្រសិនបើបណ្តោយឲ្យពួកគ្រូបង្រៀនថ្មីនេះចេះតែបន្តទៅទៀតដោយគ្មានការគ្រប់គ្រងទេ នោះឥទ្ធិពលរបស់ពួកគេនឹងត្រូវប្រឈមនឹងគ្រោះថ្នាក់ខ្លាំងជាង កាលព្រះយេស៊ូវមានព្រះជន្មរស់នៅលើផែនដីនេះទៅទៀត។ ដោយព្រោះហេតុនោះ មេដឹកនាំព្រះវិហារ បានចាប់លោកពេត្រុសនិងយ៉ូហានដាក់គុក ដោយមានការគាំទ្រពីសំណាក់ពួកសាឌូស៊ីមួយចំនួនផង ប៉ុន្តែ ពេលនោះល្ងាចពេក ហួសពេលនឹងជំនុំជម្រះទោសទៅហើយពួកសាវ័កមិនអាចបង្វែរគំនិតសត្រូវរបស់ពួកគេឲ្យជឿថាព្រះគ្រិស្តមានព្រះជន្មរស់ពីសុគតឡើងវិញបានទេ។ ភ័ស្តុតាងទាំងឡាយច្បាស់លាស់គ្មានសង្ស័យ។ តែទោះជាយ៉ាងនេះក៏ដោយក៏ពួកគេនៅតែមានចិត្តរឹង មិនព្រមកែប្រែពីទង្វើដ៏អាក្រក់ដែលពួកគេបានធ្វើក្នុងការធ្វើគុតព្រះយេស៊ូវនោះដែរ ។ ពួកសាវ័កបាននិយាយនិងបង្ហាញសកម្មភាពអំពីភស្តុតាងជាច្រើន ប្រាប់ដល់ពួកមេដឹកនាំសាសន៍យូដា នៅក្រោមការបណ្តាលចិត្តពីព្រះវិញ្ញាណ ប៉ុន្តែ ពួកគេនៅតែប្រឆាំងយ៉ាងដាច់ខាតទៅនឹងដំណឹងនៃសេចក្តីពិតនេះ។ ព្រះគ្រិស្តមិនបានយាងមកនៅក្នុងលក្ខណៈដែលពួកគេបានរំពឹងទុកនោះទេ ហើយទោះបីជានៅពេលដែលពួកគេបានដឹងថាព្រះអង្គគឺជាព្រះរាជបុត្រារបស់ព្រះក៏ដោយ ក៏ពួកគេនៅតែមិនព្រមទទួលយកការពិតនោះដែរ ហើយគេក៏បានឆ្កាងទ្រង់ ។ ដោយសេចក្តីមេត្តាករុណា ព្រះបានប្រទានភ័ស្តុតាងដល់គេបន្ថែមទៀត ហើយឥឡូវនេះ ព្រះអង្គបានប្រទានឱកាសមួយទៀតដល់គេ ឲ្យបែរមករកទ្រង់វិញ។ ព្រះអង្គបានចាត់ពួកសាវ័កឲ្យមកប្រាប់ពួកគេថាពួកគេបានធ្វើគុតព្រះដែលជាម្ចាស់ជីវិតហើយនៅក្នុងការចោទប្រកាន់យ៉ាងធ្ងន់នេះ ព្រះអង្គបានប្រទានការអំពាវនាវឲ្យកែប្រែចិត្តម្តងទៀត។ ប៉ុន្តែ ដោយមានទំនុកចិត្តទៅនឹងសេចក្តីសុចរិតរបស់ខ្លួន ពួកគ្រូសាសន៍យូដាបានបដិសេធមិនទទួលស្គាល់ថាពួកមនុស្ស

ដែលកំពុងតែថ្កោលទោសដល់ពួកគេពីបទឆ្កាងព្រះគ្រិស្តនេះកំពុងនិយាយដោយមានការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធឡើយ។

**<u>សៅរ៍-១១ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ១**

**ខព្រះគម្ពីរប្រចាំសប្តាហ៍:** *តែពេត្រុស និងយ៉ូហាន ឆ្លើយតបថា បើគួរគប្បីនៅចំពោះព្រះ ឲ្យយើងខ្ញុំស្តាប់តាមលោករាល់គ្នា ជាជាងស្តាប់តាមព្រះ នោះសូមពិចារណាចុះ ដ្បិតយើងខ្ញុំនឹងលែងនិយាយពីការដែលយើងខ្ញុំបានឃើញ ហើយឮ ពុំបានទេ។ កិច្ចការ ៤:១៩-២០*

ដោយបានតាំងខ្លួនជាអ្នកប្រឆាំងទៅនឹងព្រះគ្រិស្ត រាល់សកម្មភាពនៃការប្រឆាំងរបស់ពួកគេបានក្លាយទៅជាភ័ស្តុតាងនៃការលើកទឹកចិត្តបន្ថែមទៀតដល់ពួកសង្ឃឲ្យរក្សាអាកប្បកិរិយាដូចមុនដដែល ។ ការប្រឆាំងរឹងរូសរបស់ពួកគេកាន់តែខ្លាំងក្លាឡើង។ មិនមែនថាពួកគេមិនអាចទោរទន់បាននោះទេ តាមពិតពួកគេអាចធ្វើបាន ប៉ុន្តែ ពួកគេមិនធ្វើ ។ មិនមែនគ្រាន់តែដោយសារពួកគេមានកំហុស ហើយសមនឹងទទួលសេចក្តីស្លាប់ប៉ុណ្ណោះទេ មិនត្រឹមតែដោយសារពួកគេបានធ្វើគុតព្រះរាជបុត្រានៃព្រះប៉ុណ្ណោះទេ ដែលពួកគេត្រូវកាត់ចេញពីសេចក្តីសង្គ្រោះ ប៉ុន្តែ គឺដោយសារពួកគេបានប្រដាប់ខ្លួនដោយការប្រឆាំងជាមួយនឹងព្រះថែមទៀតផង ។ ពួកគេបានបដិសេធពន្លឺជាបន្តបន្ទាប់  ហើយមិនព្រមទទួលការបំភ្លឺពីព្រះវិញ្ញាណ ឥទ្ធិពលដែលគ្រប់គ្រងកូនចៅដែលមិនស្តាប់បង្គាប់បានធ្វើការនៅក្នុងចិត្តពួកគេ ដឹកនាំពួកគេឲ្យប្រឆាំងជាមួយនឹងមនុស្សដែលព្រះកំពុងធ្វើការ។ ភាពអាក្រក់នៃការប្រឆាំងបះបោររបស់ពួកគេ ត្រូវបានពង្រឹងដោយសកម្មភាពនៃការប្រឆាំងដ៏មានជោគជ័យ ទាស់នឹងព្រះ និងសារដែលទ្រង់បានប្រទានដល់អ្នកបម្រើរបស់ទ្រង់ឲ្យប្រកាសផ្សព្វផ្សាយ ។ នៅក្នុងការប្រឆាំងមិនព្រមកែប្រែរបស់ពួកគេ ជារៀងរាល់ថ្ងៃពួកគ្រូសាសន៍យូដាបានដំឡើងការប្រឆាំងបះបោរឲ្យកាន់តែថ្មីឡើង ហើយរៀបចំច្រូតកាត់ប្រមូលផលនូវអ្វី

ដែលពួកគេបានសាបព្រោះ ។

សេចក្តីក្រោធរបស់ព្រះមិនត្រូវបានប្រកាសប្រឆាំងទាស់នឹងបាបជនដែលមិនបានកែប្រែចិត្ត ដោយសារតែអំពើបាបដែលខ្លួនបានប្រព្រឹត្តនោះទេ ប៉ុន្តែ ដោយសារតែពួកគេជ្រើសរើសនៅតែបន្តប្រព្រឹត្តអំពើបាបដដែល នៅពេលដែលមានការអំពាវនាវឲ្យកែប្រែចិត្ត ពួកគេនៅតែសម្រេចចិត្តបន្តប្រឆាំងមិនព្រមកែប្រែដដែល ដោយបន្តប្រព្រឹត្តអំពើបាបកាលពីអតីតកាលជម្នះទៅនឹងពន្លឺដែលព្រះបានប្រទានដល់ពួកគេដដែល ។

នៅថ្ងៃនៃការព្យាបាលជនពិការនោះ អាន និងកៃផា ជាមួយនឹងអ្នកមានបណ្តាស័ក្តិខ្ពង់ខ្ពស់នៅក្នុងព្រះវិហារ បានជួបជុំគ្នាដើម្បីជំនុំជម្រះ ហើយគេក៏បាននាំអ្នកទោសចូលមកនៅចំពោះពួកលោក។ នៅក្នុងបន្ទប់នោះឯង ហើយនៅចំពោះមុខពួកមនុស្សដែលនៅទីនោះមួយចំនួននោះហើយ ដែលលោកពេត្រុសបានបដិសេធព្រះជាម្ចាស់របស់គាត់យ៉ាងគួរឲ្យអៀនខ្មាស។ ការនេះមានភាពខុសគ្នាបានចូលមកក្នុងគំនិតរបស់លោក នៅពេលដែលគេបានកាត់ទោសខ្លួនលោកដោយផ្ទាល់ ។ ឥឡូវនេះ លោកមានឱកាសលុបលាងភាពកម្សាករបស់គាត់ ។

អ្នកដែលមានវត្តមាននៅទីនោះ ដែលបាននឹកឃើញពីការដែលលោកពេត្រុសបានប្រព្រឹត្តនៅពេលដែលគេជំនុំជម្រះព្រះជាម្ចាស់របស់លោក បានតម្កើងខ្លួនថា ឥឡូវនេះពួកគេអាចបំភ័យលោកដោយការគំរាមកំហែងដាក់គុកច្រវាក់ និងការកាប់សម្លាប់បាន ។ ប៉ុន្តែ លោកពេត្រុសដែលបានបដិសេធព្រះគ្រិស្ត នៅពេលដែលព្រះអង្គត្រូវការការគាំទ្រជាចាំបាច់នោះ ឥឡូវនេះមានភាពរឹងមាំនិងមានទំនុកចិត្ត ខុសគ្នាដាច់ស្រឡះពីពេត្រុសដែលបាននៅចំពោះពួកសាន់ហ៊ីឌ្រីន ដើម្បីតាមពិនិត្យមើលការកាត់ទោសព្រះយេស៊ូវ។ ដោយសារតែលោកបានដួលចុះ លោកត្រូវបានបំផ្លាស់បំប្រែ ។ លោកលែងមានអំនួតក្អេងក្អាងទៀតហើយ ប៉ុន្តែ មានភាពរម្យទមនិងមិនទុកចិត្តខ្លួនឯងទៀតឡើយ។ លោកមានពេញដោយព្រះវិញ្ញាណបរិសុទ្ធ

ហើយដោយមានជំនួយពីព្រះចេស្តានៃព្រះវិញ្ញាណនេះ លោកអាចកម្ចាត់ស្នាមនៃការបោះបង់ជំនឿ ដោយលើកតម្កើងព្រះនាមដែលលោកធ្លាប់បានបដិសេធ ។

ចាប់ពីពេលនោះមក ពួកសង្ឃបានចៀសវាងមិនពណ៌នាអំពីការសុគតនិងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវទៀត។ ប៉ុន្តែ ឥឡូវនេះ ដើម្បីឲ្យគោលបំណងរបស់ពួកគេនេះបានសម្រេច ពួកគេត្រូវបានបង្ខំសួរដល់ចុងចោទអំពីរបៀបព្យាបាលជនពិការដែលគេបានធ្វើនោះ។ ពួកគេបានសួរថា «ឯងបានធ្វើការនោះដោយអាងអំណាចអ្វី ឬដោយអាងឈ្មោះណា?»

**<u>អាទិត្យ-១២ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ២**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *នៅថ្ងៃនេះ បើសិនជាលោកអ្នករាល់គ្នា គិតពិចារណាសួរយើងខ្ញុំ ពីដំណើរការល្អ ដែលបានធ្វើដល់មនុស្សពិការនោះថា គាត់បានជាដោយសារអ្វី នោះសូមឲ្យលោករាល់គ្នាជ្រាបដូច្នេះ ហើយឲ្យសាសន៍អ៊ីស្រាអែលទាំងអស់ដឹងផង ថា ដែលមនុស្សនេះបានជាស្រឡះ ហើយឈរនៅមុខលោករាល់គ្នាដូច្នេះ គឺដោយសារព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ពីស្រុកណាសារ៉ែត ដែលលោករាល់គ្នាបានឆ្កាងទ្រង់ តែព្រះបានប្រោសឲ្យមានព្រះជន្មរស់ពីស្លាប់ឡើងវិញ។ កិច្ចការ ៤:៩-១០*

លោកពេត្រុសបានប្រកាសដោយសេចក្ដីក្លាហានដ៏បរិសុទ្ធនិងដោយគ្មានភ័យខ្លាចថា «ឱលោកដ៏ធំលើបណ្ដាជន និងពួកលោកចាស់ទុំទាំងឡាយនៃសាសន៍អ៊ីស្រាអែលអើយ នៅថ្ងៃនេះ បើសិនជាលោកអ្នករាល់គ្នា គិតពិចារណាសួរយើងខ្ញុំ ពីដំណើរការល្អ ដែលបានធ្វើដល់មនុស្សពិការនោះថា គាត់បានជាដោយសារអ្វី នោះសូមឲ្យលោករាល់គ្នាជ្រាបដូច្នេះ ហើយឲ្យសាសន៍អ៊ីស្រាអែលទាំងអស់ដឹងផងថា ដែលមនុស្សនេះបានជាស្រឡះ ហើយឈរនៅមុខលោករាល់គ្នាដូច្នេះ គឺដោយសារព្រះនាមនៃព្រះយេស៊ូវ

គ្រិស្តពីស្រុកណាសារ៉ែត ដែលលោករាល់គ្នាបានឆ្កាងទ្រង់ តែព្រះបាន ប្រោសឲ្យមានព្រះជន្មរស់ពីស្លាប់ឡើងវិញ ព្រះអង្គនោះ ជាថ្មដែលលោក រាល់គ្នា ជាជាងសង់ផ្ទះ បានមើលងាយ ប៉ុន្តែ ទ្រង់បានត្រឡប់ជាថ្មជ្រុង យ៉ាងឯកវិញ ហើយគ្មានសេចក្តីសង្គ្រោះដោយសារអ្នកណាទៀតសោះ ដ្បិតនៅក្រោមមេឃ គ្មាននាមឈ្មោះណាទៀតបានប្រទានមកមនុស្សលោក ឲ្យយើងរាល់គ្នាបានសង្គ្រោះនោះឡើយ» ។

ការការពារខ្លួនដោយក្លាហាននេះបានធ្វើឲ្យពួកមេដឹកនាំសាសន៍ យូដាភ័យញ័ររន្ធត់ ។ ពួកគេបានសង្ឃឹមថា ពួកសាវ័កនឹងភិតភ័យស្លន់ស្លោ នៅពេលដែលគេត្រូវបាននាំមកនៅចំពោះក្រុមប្រឹក្សាសាន់ហ៊ីឌ្រីន ។ ប៉ុន្តែ ផ្ទុយទៅវិញ ស្មរបន្ទាល់ទាំងនេះបាននិយាយដូចជាព្រះគ្រិស្តបានមាន ព្រះបន្ទូលជាមួយនឹងអំណាចនៃសេចក្តីជំនឿ ដែលបានធ្វើឲ្យពួកសត្រូវ របស់គេស្ងាត់មាត់យ៉ាងដូច្នោះដែរ។ នៅពេលដែលលោកមានប្រសាសន៍ អំពីព្រះគ្រិស្ត មិនមានសញ្ញានៃការភ័យខ្លាចនៅក្នុងសំឡេងរបស់លោកពេត្រុស បន្តិចសោះឡើយ «ព្រះអង្គនោះ ជាថ្មដែលលោករាល់គ្នា ជាជាងសង់ផ្ទះ បានមើលងាយ ប៉ុន្តែ ទ្រង់បានត្រឡប់ជាថ្មជ្រុងយ៉ាងឯកវិញ»។

នៅទីនេះ លោកពេត្រុសបានប្រើរូបភាពនៃសម្តីដែលពួកសង្ឃធ្លាប់ ដឹង។ ពួកហោរាបាននិយាយអំពីថ្មជ្រុងដែលគេបានចោល ហើយមានពេល មួយ ព្រះគ្រិស្តបានមានបន្ទូលដោយផ្ទាល់ទៅកាន់ពួកសង្ឃនិងពួកចាស់ទុំ ទ្រង់បានមានបន្ទូលថា «ហើយគ្រប់ទាំងសេចក្តីអ្វីដែលអ្នករាល់គ្នានឹងអធិដ្ឋាន សូមដោយមានចិត្តជឿ នោះនឹងបានសម្រេចទាំងអស់ ។ កាលទ្រង់បាន យាងចូលទៅក្នុងព្រះវិហារហើយ នោះពួកសង្គ្រាជ និងពួកចាស់ទុំនៃបណ្តា ជន គេមកឯទ្រង់ដែលកំពុងតែបង្រៀន ហើយទូលកាត់សួរថា អ្នកធ្វើការ ទាំងនេះ តើអាងអំណាចអ្វី តើអ្នកណាបានបើកអំណាចនេះឲ្យអ្នក ព្រះយេស៊ូវ មានព្រះបន្ទូលតបថា ខ្ញុំនឹងសួរអ្នករាល់គ្នាពីសេចក្តីមួយដែរ បើអ្នកឆ្លើយ ប្រាប់ខ្ញុំ នោះខ្ញុំក៏នឹងប្រាប់ឲ្យអ្នកដឹងពីអំណាចដែលខ្ញុំអាងដើម្បីនឹងធ្វើ

ការទាំងនេះដែរ» (ម៉ាថាយ ២១:២២-២៤) ។

នៅពេលដែលពួកសង្ឃបានស្តាប់សម្តីដោយគ្មានការភ័យខ្លាចរបស់ពួកសាវ័ករួចមក ពួកគេ «យល់ឃើញថា គេធ្លាប់នៅជាមួយនឹងព្រះយេស៊ូវ»។ សម្រាប់ពួកសាវ័ក បន្ទាប់ពីការផ្លាស់ប្រែព្រះភក្ត្ររបស់ព្រះគ្រិស្តមក ព្រះគម្ពីរបានចែងថា នៅចុងបញ្ចប់នៃទស្សនីយភាពនោះថា«នោះមិនបានឃើញអ្នកណាសោះឃើញតែព្រះយេស៊ូវតែប៉ុណ្ណោះ» (ម៉ាថាយ ១៧:៨)។ «ឃើញតែព្រះយេស៊ូវមួយប៉ុណ្ណោះ» នៅក្នុងពាក្យនេះមានអាថ៌កំបាំងនៃជីវិតនិងអំណាចដែលកំណត់ប្រវត្តិសាស្ត្រនៃពួកជំនុំដំបូង។ នៅពេលដែលពួកសាវ័កបានឮព្រះបន្ទូលរបស់ព្រះយេស៊ូវដំបូង ពួកគេដឹងថាពួកគេត្រូវការទ្រង់ ។ ពួកគេបានស្វែងរក ពួកគេបានដើរតាមទ្រង់។ ពួកគេបាននៅជាមួយនឹងទ្រង់នៅក្នុងព្រះវិហារ នៅតុអាហារ នៅជើងភ្នំ នៅតាមវាល។ ពួកគេហាក់ដូចជាសិស្សនៅជាមួយនឹងគ្រូដែលទទួលមេរៀននៃសេចក្តីពិតអស់កល្បពីទ្រង់ជារៀងរាល់ថ្ងៃ ។

បន្ទាប់ពីការយាងឡើងទៅឋានសួគ៌របស់ព្រះអង្គសង្គ្រោះមក វិញ្ញាណនៃព្រះវត្តមាន ដែលពោរពេញដោយសេចក្តីស្រឡាញ់និងពន្លឺបានគង់នៅជាមួយនឹងពួកគេនៅឡើយ។ គឺជាព្រះវត្តមានផ្ទាល់។ ព្រះយេស៊ូវជាព្រះអង្គសង្គ្រោះ ដែលបានយាងជាមួយពួកគេ បានមានបន្ទូល និងអធិដ្ឋានជាមួយពួកគេជាព្រះដែលធ្លាប់មានបន្ទូលពីសេចក្តីសង្ឃឹមនិងការកម្សាន្តចិត្តទៅកាន់ចិត្តរបស់ពួកគេត្រូវបានព្រះលើកយកទៅឋានសួគ៌ ខណៈដែលសារនៃសេចក្តីសុខសាន្តបិតនៅក្នុងព្រះឱស្ឋទ្រង់នៅឡើយ។ នៅពេលរាជរថនៃពួកទេវតាបានទទួលទ្រង់ ព្រះអង្គបានមានបន្ទូលមកកាន់ពួកគេថា «មើលខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរ ដរាបដល់បំផុតកល្ប» (ម៉ាថាយ ២៨:២០) ។ ព្រះអង្គបានយាងឡើងទៅក្នុងសណ្ឋានជាមនុស្ស។ ពួកគេបានដឹងថាព្រះអង្គកំពុងមានព្រះវត្តមាននៅចំពោះព្រះ ហើយនៅតែជាមិត្តសម្លាញ់និងជាព្រះអង្គសង្គ្រោះរបស់ពួកគេដដែល ដែលសេចក្តី

អាណិតអាសូររបស់ទ្រង់មិនចេះផ្លាស់ប្រែ ហើយដែលទ្រង់បានជ្រាបពីការឈឺចាប់របស់មនុស្សជារៀងរហូត។ ពួកគេបានដឹងថាព្រះអង្គកំពុងបង្ហាញដល់ព្រះនូវគុណូបការៈនៃព្រះលោហិតរបស់ទ្រង់ កំពុងបង្ហាញស្នាមរបួសនៅនឹងព្រះហស្តនិងព្រះបាទរបស់ទ្រង់ជាការរំឭកពីតម្លៃដែលព្រះអង្គបានបង់ជំនួសអ្នកដែលទ្រង់បានប្រោសលោះ ហើយគំនិតនេះបានពង្រឹងកម្លាំងពួកគេឲ្យទ្រាំទ្រជាមួយនឹងការស្តីបន្ទោសដោយសារព្រះអង្គ។ ឥឡូវនេះការរួបរួមរបស់ពួកគេជាមួយនឹងទ្រង់កាន់តែរឹងមាំជាងកាលដែលពួកគេបាននៅជាមួយនឹងព្រះអង្គដោយផ្ទាល់ទៅទៀត។ ពន្លឺសេចក្តីស្រឡាញ់ និងព្រះចេស្តារបស់ព្រះគ្រិស្ត ដែលគង់នៅក្នុងចិត្តបានចែងចាំងតាមរយៈពួកគេ ដើម្បីឲ្យមនុស្សទាំងឡាយបានឃើញភាពអស្ចារ្យ។

**<u>ច័ន្ទ-១៣ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ៣**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *កាលបានឃើញថា ពេត្រុស និងយ៉ូហានមានចិត្តក្លាហាន នោះពួកលោកទាំងនោះក៏មានសេចក្តីអស្ចារ្យ ដោយដឹងថា គេជាមនុស្សមិនសូវចេះជ្រៅជ្រះ ហើយឥតបានរៀនសូត្រប៉ុន្មានផង បានជាលោកយល់ឃើញថា គេធ្លាប់នៅជាមួយនឹងព្រះយេស៊ូវ។ កិច្ចការ ៤:១៣*

ព្រះគ្រិស្តបានបោះត្រារបស់ទ្រង់នៅលើពាក្យដែលលោកពេត្រុសបាននិយាយ នៅក្នុងការពាររបស់ទ្រង់ ។ បុរសដែលទទួលការព្យាបាលដ៏អស្ចារ្យនោះបានឈរនៅក្បែរពួកសាវ័ក ជាសាក្សីនៃជំនឿដ៏រឹងមាំ។ កាលពីប៉ុន្មានម៉ោងមុននេះ សណ្ឋាននៃបុរសនេះគឺជាជនពិការដែលអស់សង្ឃឹមម្នាក់ តែឥឡូវនេះ បានក្រោកឈរជាមនុស្សដែលមានសុខភាពមាំមួន បានបន្ថែមទម្ងន់ទៅលើសម្តីនៃទីបន្ទាល់របស់លោកពេត្រុសថែមទៀត។ ពួកសង្ឃនិងពួកមេដឹកនាំសាសនាបានស្ងាត់មាត់។ ពួកគេមិនអាចជំទាស់ទៅនឹងប្រយោគរបស់លោកពេត្រុសបានឡើយ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយក៏ពួកគេបានប្តេជ្ញាចិត្តថានឹងបញ្ឈប់ការបង្រៀនរបស់ពួកសាវ័កឲ្យទាល់តែ

បានដែរ។

ការប្រោសទ្បាសារឲ្យរស់ឡើងវិញ គឺជាការអស្ចារ្យដ៏ធំបំផុតរបស់ព្រះគ្រិស្ត បានបោះត្រានៅលើការតាំងចិត្តរបស់ពួកសង្ឃឲ្យកម្ចាត់ព្រះបន្ទូលរបស់ព្រះយេស៊ូវ និងកិច្ចការរបស់ទ្រង់ ដែលបំផ្លាញឥទ្ធិពលរបស់ពួកគេទៅលើពួកបណ្តាជនយ៉ាងឆាប់រហ័ស។ ពួកគេបានឆ្កាងទ្រង់ ប៉ុន្តែ មានភស្តុតាងនៃសេចក្តីជំនឿនៅទីនេះ ដែលពួកគេមិនបានបញ្ឈប់កិច្ចការនៃការអស្ចារ្យនៅក្នុងព្រះនាមរបស់ទ្រង់ ឬការប្រកាសអំពីសេចក្តីពិតដែលព្រះអង្គបានបង្រៀនទេ  ការព្យាបាលជនពិការ និងការប្រកាសផ្សាយរបស់ពួកសាវ័កបានបំពេញទីក្រុងយេរូសាឡិមដោយក្តីរំភើប។

ដើម្បីបិទបាំងភាពអល់អែករបស់ពួកគេ ពួកសង្ឃនិងពួកមេដឹកនាំសាសនាបានបញ្ជាឲ្យគេនាំយកពួកសាវ័កចេញទៅ ដើម្បីឲ្យពួកគេមានឱកាសពិភាក្សាគ្នា។ ពួកគេបានឯកភាពគ្នាថាការបដិសេធន៍មិនទទួលស្គាល់បុរសនោះ មិនមានប្រយោជន៍អ្វីឡើយ។ ពួកគេអាចបិទបាំងការអស្ចារ្យនេះដោយភាពក្លែងក្លាយ ប៉ុន្តែ ការនេះមិនអាចធ្វើទៅបានទេ ព្រោះបានកើតឡើងនៅកណ្តាលថ្ងៃថែស នៅចំពោះមនុស្សជាច្រើននាក់ ហើយបានដឹងសុសសាយដល់មនុស្សរាប់ពាន់នាក់ទៅហើយ។ ពួកគេបានដឹងថាកិច្ចការរបស់ពួកសាវ័កត្រូវតែបញ្ឈប់ បើពុំនោះទេសិស្សរបស់ព្រះយេស៊ូវនឹងកើនឡើងកាន់តែច្រើនជាក់ជាមិនខាន ។ ភាពអាម៉ាស់របស់ពួកគេនឹងកើតឡើង ព្រោះពួកគេមានកំហុសដោយការធ្វើគុតព្រះរាជបុត្រានៃព្រះ។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយក៏សេចក្តីប្រាថ្នារបស់ពួកគេ ក្នុងការបំផ្លាញពួកសាវ័កនេះ ពួកសង្ឃមិនហ៊ានធ្វើអ្វីក្រៅពីគំរាមកំហែងដល់ពួកគេដោយការដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុតប្រសិនបើពួកគេនៅតែបន្តនិយាយ ឬធ្វើការដោយនូវព្រះនាមព្រះយេស៊ូវតទៅទៀតប៉ុណ្ណោះឡើយ។ ដោយបានហៅពួកគេមកកាន់ក្រុមប្រឹក្សាសាន់ហ៊ីឌ្រីនម្តងទៀត ពួកសង្ឃបានបង្គាប់ដល់ពួកសាវ័កមិនឲ្យនិយាយឬបង្រៀននៅក្នុងព្រះនាមព្រះយេស៊ូវតទៅទៀត។ ប៉ុន្តែ លោកពេត្រុសនិងយ៉ូហាន

បានឆ្លើយថា៖ «បើគួរគប្បីនៅចំពោះព្រះឲ្យយើងខ្ញុំស្តាប់តាមលោករាល់គ្នាជាជាងស្តាប់តាមព្រះ នោះសូមពិចារណាចុះ ដ្បិតយើងខ្ញុំនឹងលែងនិយាយពីការដែលយើងខ្ញុំបានឃើញ ហើយឮពុំបានទេ» ។

ពួកសង្ឃគួរតែដាក់ទណ្ឌកម្មដោយរីករាយទៅលើបុរសទាំងនេះ ដោយសារភក្តីភាពទៅនឹងការត្រាស់ហៅដ៏ពិសិដ្ឋរបស់ពួកគេ តាមរយៈចម្លើយរបស់ពួកគេនេះ ប៉ុន្តែ ពួកគេភ័យខ្លាចចំពោះហ្វូងមនុស្ស «ដ្បិតទាំងអស់គ្នាកំពុងតែសរសើរតម្កើងដល់ព្រះ ពីការនោះដែលទើបនឹងកើតមក» ដូច្នេះ គេក៏បានដោះលែងពួកសាវ័ក ជាមួយនឹងការគំរាមកំហែង និងការហាមឃាត់យ៉ាងតឹងតែង ។

នៅពេលដែលលោកពេត្រុសនិងយ៉ូហានកំពុងជាប់គុកនៅឡើយ ពួកសាវ័កដទៃទៀតក៏បានអធិដ្ឋានឲ្យបងប្អូនរបស់ពួកគេឥតឈប់ឈរ ដោយព្រួយបារម្ភក្រែងគេនឹងប្រព្រឹត្តអំពើឃោរឃៅទៅលើពួកលោក ដូចជាគេបានធ្វើទៅលើព្រះគ្រិស្តទៀត ដោយពួកគេបានដឹងអំពីចិត្តអាក្រក់របស់ពួកយូដា។ បន្ទាប់ពីសាវ័កទាំងពីរត្រូវបានគេដោះលែងភ្លាម គេបានទៅរកពួកសាវ័កដទៃទៀត ហើយរាយការណ៍អំពីលទ្ធផលនៃការជំនុំជម្រះ។ ពួកអ្នកជឿទាំងនោះមានអំណរជាខ្លាំង។ «កាលពួកជំនុំបានឮដូច្នោះ នោះក៏បន្លឺឧទានព្រមគ្នា ទូលដល់ព្រះថា ឱព្រះដ៏ជាម្ចាស់ធំបំផុតអើយ គឺទ្រង់ជាព្រះដែលបង្កើតផ្ទៃមេឃ ផែនដី និងសមុទ្រ ហើយរបស់ទាំងអស់ ដែលនៅឋានទាំងនោះផង ទ្រង់បានមានព្រះបន្ទូល ដោយសារព្រះឱស្ឋហ្លួងដាវីឌ ជាអ្នកបម្រើទ្រង់ថា ហេតុអ្វីបានជាអស់ទាំងសាសន៍ជ្រួលជ្រើមឡើង ហើយជនជាតិទាំងប៉ុន្មាន មានគំនិតជាអសារឥតការដូច្នេះ ពួកមហាក្សត្រនៅផែនដី លើកគ្នាឡើង ពួកគ្រប់គ្រងទាំងប៉ុន្មានក៏ប្រឹក្សាគ្នាទាស់នឹងព្រះអម្ចាស់ ហើយទាស់នឹងព្រះគ្រិស្តនៃទ្រង់ ប្រាកដមែនហើយ ដ្បិតនៅក្រុងនេះស្តេចហេរ៉ូឌ និងលោកប៉ុនទាសពីឡាត់ បានប្រជុំគ្នា ព្រមទាំងពួកសាសន៍ដទៃ និងសាសន៍អ៊ីស្រាអែល ទាស់នឹងព្រះយេស៊ូវជាអ្នកបម្រើបរិសុទ្ធរបស់ទ្រង់ ដែលទ្រង់

បានចាក់ប្រេងតាំងឲ្យ ដើម្បីនឹងធ្វើអស់ទាំងការដែលព្រះហស្តទ្រង់ និងព្រះតម្រិះទ្រង់ បានគិតសម្រេចជាមុន ឥឡូវនេះ ឱព្រះអម្ចាស់អើយ សូមទតមើលសេចក្តីកំហែងរបស់គេ ហើយសូមប្រទានឲ្យពួកអ្នកបម្រើទ្រង់ បានផ្សាយព្រះបន្ទូល ដោយសេចក្តីក្លាហានដ៏ពេញលេញ» ។

«ដោយទ្រង់លូកព្រះហស្តមក សម្រាប់នឹងប្រោសមនុស្សឲ្យបានជា ហើយនិងធ្វើទីសម្គាល់ និងការអស្ចារ្យដោយសារព្រះនាមព្រះយេស៊ូវ ជាអ្នកបម្រើបរិសុទ្ធរបស់ទ្រង់» ។

**<u>អង្គារ-១៤ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ៤**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *កាលបានអធិស្ឋានរួចហើយ នោះកន្លែងដែលគេប្រជុំគ្នាក៏រញ្ជួយ ហើយគេបានពេញជាព្រះវិញ្ញាណបរិសុទ្ធទាំងអស់គ្នា រួចក៏ផ្សាយព្រះបន្ទូលដោយចិត្តក្លាហាន។ កិច្ចការ ៤:៣១*

ពួកសាវ័កបានអធិដ្ឋានសុំឲ្យព្រះប្រទានព្រះចេស្តាដ៏ធំដល់ពួកគេនៅក្នុងការបំពេញកិច្ចការបម្រើដល់ទ្រង់នេះ ព្រោះពួកគេបានមើលឃើញថា ពួកគេបានជួបនឹងការប្រឆាំងយ៉ាងធ្ងន់ធ្ងរ ដូចជាព្រះគ្រិស្តបានឆ្លងកាត់កាលព្រះអង្គគង់នៅលើផែនដីដូច្នោះដែរ។ នៅពេលដែលការអធិដ្ឋានរួមគ្នាដោយជំនឿបានឡើងទៅដល់ឋានសួគ៌ ចម្លើយក៏បានកើតឡើង។ កន្លែងដែលពួកសាវ័កបានជួបប្រជុំគ្នានោះបានកក្រើកឡើង ព្រះក៏បានប្រទានព្រះវិញ្ញាណបរិសុទ្ធជាថ្មីម្តងទៀត។ ចិត្តគេក៏ពេញដោយសេចក្តីក្លាហាន ពួកគេក៏ចេញទៅប្រកាសព្រះបន្ទូលរបស់ព្រះពាសពេញទាំងទីក្រុងយេរូសាឡិម។ «ពួកសាវ័កក៏ធ្វើបន្ទាល់ ដោយព្រះចេស្តាដ៏ធំ ពីដំណើរដែលព្រះអម្ចាស់យេស៊ូវមានព្រះជន្មរស់ឡើងវិញ ហើយមានព្រះគុណជាធំសណ្ឋិតលើគេទាំងអស់គ្នាដែរ»។ ហើយព្រះក៏បានប្រទានព្រះពរដ៏អស្ចារ្យដល់ការខំប្រឹងប្រែងរបស់ពួកគេ។

គោលការដែលពួកសាវ័កបានឈរដោយគ្មានការភ័យខ្លាច នៅ

ពេលដែលពួកគេបានប្រកាសថា «បើគួរគប្បីនៅចំពោះព្រះឲ្យយើងខ្ញុំស្តាប់តាមលោករាល់គ្នា ជាជាងស្តាប់តាមព្រះ នោះសូមពិចារណាចុះ» ជាការឆ្លើយតបទៅនឹងការហាមប្រាមមិនឲ្យនិយាយនៅក្នុងព្រះនាមព្រះយេស៊ូវតទៅទៀត គឺជាអ្នកផ្សាយដំណឹងល្អ ដែលមានការពិបាក ដូចជានៅក្នុងសម័យការកែទម្រង់ដូច្នោះដែរ ។ នៅឆ្នាំ ១៥២៩ ព្រះអម្ចាស់នៃប្រទេសអាឡឺម៉ង់បានជួបប្រជុំគ្នា នៅអើតស្ប៉ាយមានបង្ហាញពីព្រះរាជក្រឹត្យរបស់ព្រះចៅអធិរាជដែលរិតបន្តឹងដល់សេរីភាពសាសនា និងការហាមប្រាមការផ្សព្វផ្សាយបន្តទៅទៀតអំពីគោលលទ្ធិនៃការកែទម្រង់។ សេចក្តីសង្ឃឹមនៃពិភពលោកហាក់បីដូចជាត្រូវបានកិនកម្ទេច។ តើព្រះអម្ចាស់នោះទទួលព្រះរាជក្រឹត្យនោះដែរឬទេ? តើពន្លឺនៃដំណឹងល្អត្រូវបានបិទបាំងពីហ្វូងមនុស្ស នៅតែក្នុងភាពងងឹតដដែលដែរឬទេ? បញ្ហាដ៏ធំធេងនៃពិភពលោកត្រូវបានជាប់គាំង។ ពួកអ្នកដែលបានទទួលជំនឿនៃការកែទម្រង់បានជួបជុំគ្នា ហើយសេចក្តីសម្រេចចិត្តជាឯកច្ឆន្ទរបស់ពួកគេគឺ «ចូរយើងបដិសេធព្រះរាជក្រឹត្យនេះ។ ដោយហេតុផលខាងមនសិការ មតិភាគច្រើនគ្មានអំណាចឡើយ» សៀវភៅប្រវត្តិសាស្ត្រនៃការកែទម្រង់របស់លោកមើល ដូប៊ីញ៉េ (merle d'Aubigne) ទំព័រ ១៣ ជំពូក ៥ ។

យើងក៏ត្រូវរក្សាគោលការនេះយ៉ាងរឹងមាំនៅពេលសព្វថ្ងៃនេះដែរ ។ ផ្ទាំងបដានៃសេចក្តីពិតនិងសេរីភាពខាងសាសនាត្រូវបានលើកតម្កើង ដោយពួកអ្នករកឃើញពួកជំនុំនៃដំណឹងល្អ និងដោយទីបន្ទាល់របស់ព្រះ នៅក្នុងអំឡុងពេលជាច្រើនសតវត្សរ៍ ដែលបានកន្លងផុតទៅចាប់តាំងពី ពេលនោះមក ដែលព្រះបានប្រទានមកដល់ដៃរបស់យើង នៅក្នុងទំនាស់ ចុងក្រោយបង្អស់នេះ ។ ការទទួលខុសត្រូវចំពោះអំណោយទានដ៏ធំនេះ ឋិត នៅលើពួកអ្នកដែលព្រះបានប្រទានព្រះពរជាមួយនឹងចំណេះដឹងនៃព្រះបន្ទូលរបស់ទ្រង់។ យើងត្រូវតែទទួលព្រះបន្ទូលនេះជាអំណាចគ្រប់គ្រងដ៏ខ្ពស់។ យើងត្រូវតែទទួលស្គាល់រដ្ឋាភិបាលរបស់មនុស្ស ថាជាអំណាចដែលព្រះបាន តែងតាំង

ឡើង និងបង្រៀនពីការស្តាប់បង្គាប់ដល់រដ្ឋាភិបាលនេះជាភារកិច្ចដ៏ពិសិដ្ឋ នៅក្នុងរង្វង់ដែលស្របច្បាប់នៃរដ្ឋអំណាចនោះ។ ប៉ុន្តែ នៅពេល ដែលការទាមទាររបស់អំណាចនោះ ផ្ទុយពីការទាមទាររបស់ព្រះ យើងត្រូវ តែស្តាប់បង្គាប់ព្រះ ជាជាងស្តាប់បង្គាប់មនុស្ស។ មនុស្សត្រូវតែទទួលស្គាល់ព្រះបន្ទូលរបស់ព្រះថាខ្ពស់ជាងច្បាប់របស់មនុស្ស «ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ» មិនត្រូវដកយកចេញដោយសារតែ «ពួកជំនុំបាននិយាយថា ដូច្នេះ» ឬ «រដ្ឋបាននិយាយដូច្នេះ» នោះទេ។ យើងត្រូវតែលើកតម្កើងមកុដរបស់ព្រះគ្រិស្តឲ្យខ្ពស់ជាងក្បាំងរបស់ព្រះចៅមហាចក្រពត្រាធិរាជនៅលើផែនដី។

ព្រះមិនបានតម្រូវឲ្យយើងបំពានទៅនឹងរដ្ឋអំណាចទេ។ ពាក្យសម្ដីរបស់យើង ទោះដោយការនិយាយ ឬសរសេរក៏ដោយ យើងត្រូវតែពិចារណាដោយប្រុងប្រយ័ត្ន ក្រែងយើងដាក់ខ្លួនយើងទៅលើកំណត់ត្រាជាការបញ្ចេញសំឡេងដែលធ្វើឲ្យខ្លួនយើងក្លាយជាអ្នកប្រឆាំងទៅនឹងច្បាប់ ឬសណ្ដាប់ធ្នាប់សង្គម។ យើងមិនត្រូវនិយាយឬប្រព្រឹត្តអ្វីដែលនឹងបិទផ្លូវយើងជាចាំបាច់នោះឡើយ។ យើងត្រូវតែបោះជំហានទៅមុខនៅក្នុងព្រះនាមរបស់ព្រះគ្រិស្ត ដោយគាំទ្រដល់សេចក្ដីពិតដែលព្រះបានប្រទានដល់យើង ។ ប្រសិនបើមនុស្សហាមឃាត់យើងមិនឲ្យធ្វើការនេះ នោះយើងអាចនិយាយដូចជាពួកសាវ័កដែរថា «បើគួរគប្បីនៅចំពោះព្រះ ឲ្យយើងខ្ញុំស្តាប់តាមលោករាល់គ្នា ជាជាងស្តាប់តាមព្រះ នោះសូមពិចារណាចុះ ដ្បិតយើងខ្ញុំនឹងលែងនិយាយពីការដែលយើងខ្ញុំបានឃើញ ហើយឮពុំបានទេ» ។

ជំពូកទី
៧

# ការព្រមានប្រឆាំងទាស់នឹងភាពកំពុត

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ជំពូក ៤:៣២-៥:១១ ។*

<u>ពុធ-១៥ កក្កដា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ៥**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ឯមនុស្សទាំងហ្វូងដែលបានជឿ គេក៏មានចិត្តមានគំនិតតែ១ គ្មានអ្នកណាប្រកាន់ថា អ្វីៗ ដែលខ្លួនមានជារបស់ផងខ្លួននោះទេ គឺគ្រប់របស់ទាំងប៉ុន្មាន ជារបស់សំរាប់ប្រើជាមួយគ្នាទាំងអស់។ កិច្ចការ ៤:៣២*

នៅពេលពួកសាវ័កបានប្រកាសផ្សាយដំណឹងល្អនៅទីក្រុងយេរូសាឡិម ព្រះបានប្រទានទីសម្គាល់ដល់ពាក្យសម្ដីរបស់ពួកគេ ហើយមនុស្សជាច្រើនបានជឿ។ ពួកអ្នកមានជំនឿថ្មីទាំងនេះជាច្រើនត្រូវបានកាត់ចេញពីគ្រួសារ ឬមិត្តភក្តិរបស់ពួកគេភ្លាមៗ ដោយពួកយូដាដែលច្រណែននឹងជំនឿសាសនា ហើយពួកសាវ័កចាំបាច់ត្រូវតែផ្ដល់ចំណីអាហារនិងជម្រកដល់ពួកនោះ។

កំណត់ត្រានៃព្រះគម្ពីរបានចែងថា «នៅក្នុងពួកគេគ្មានអ្នកណាខ្វះខាតអ្វីសោះ»។ ហើយគម្ពីរក៏បានចែងទៀតដែរថា ការខ្វះខាតរបស់ពួកគេត្រូវបានបំពេញតាមសេចក្ដីត្រូវការក្នុងចំណោមពួកអ្នកជឿដែលមានលុយកាក់ និងទ្រព្យសម្បត្តិ បានបរិច្ចាគដើម្បីបំពេញសេចក្ដីត្រូវការជាបន្ទាន់ទាំងនេះ ដោយរីករាយ។ ពួកគេបានលក់ទ្រព្យសម្បត្តិនិងផ្ទះសម្បែងរបស់ពួកគេ យកលុយមកដាក់នៅទៀបជើងពួកសាវ័ក «ហើយគេក៏ចែកដល់គ្រប់គ្នាតាមត្រូវការ»។

ចិត្តសប្បុរសរបស់ពួកគេទៅលើពួកអ្នកដែលមានជំនឿថ្មីគឺជាលទ្ធផលនៃការចាក់បង្ហូរព្រះវិញ្ញាណបរិសុទ្ធ។ ពួកអ្នកជឿដល់ដំណឹងល្អ «គេក៏មាន

ចិត្តមានគំនិតតែមួយ»។ ចំណាប់អារម្មណ៍រួមតែមួយបានគ្រប់គ្រងលើពួកគេ គឺជោគជ័យនៃបេសកកម្មដែលព្រះបានប្រទានដល់ពួកគេ ហើយមិនមានការលោភលន់ណានៅក្នុងជីវិតពួកគេឡើយ។ សេចក្ដីស្រឡាញ់ចំពោះបងប្អូននិងកិច្ចការរបស់ពួកគេ ធំធេងជាងសេចក្ដីស្រឡាញ់លុយកាក់និងទ្រព្យសម្បត្តិ ។ កិច្ចការរបស់ពួកគេបានបង្ហាញថាពួកគេឲ្យតម្លៃដល់ជីវិតរបស់មនុស្ស ខ្ពស់ជាងតម្លៃទ្រព្យសម្បត្តិខាងលោកិយ ។

រឿងដូច្នេះតែងតែកើតឡើងជានិច្ច នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធគ្រប់គ្រងលើជីវិត។ អស់អ្នកដែលមានចិត្តពោរពេញទៅដោយសេចក្ដីស្រឡាញ់របស់ព្រះគ្រិស្ដ នឹងយកគំរូតាមព្រះ ដែលសុខចិត្តក្លាយ ជាអ្នកក្រីក្រដោយសារតែយើងរាល់គ្នា ដើម្បីយើងរាល់គ្នាបានក្លាយជាអ្នកមានដោយសារភាពកម្សត់របស់ទ្រង់។ លុយកាក់ ពេលវេលា និងឥទ្ធិពល ពោលគឺអំណោយទានទាំងអស់នេះ ដែលពួកគេបានទទួលពីព្រះហស្តរបស់ព្រះ ពួកគេនឹងយកទៅនឹងយកទៅប្រើប្រាស់ដើម្បីជំរុញដំណឹងល្អឆ្ពោះទៅមុខប៉ុណ្ណោះ។ ពួកជំនុំដំបូងមានលក្ខណៈយ៉ាងដូច្នេះឯង។ ហើយនៅពេលដែលពួកជំនុំនាពេលសព្វថ្ងៃនេះបានដកចិត្តចេញពីរបស់នៃលោកិយ បែរមកលះបង់ដើម្បីមនុស្សដូចគ្នាបានឮដំណឹងល្អ ធ្វើឲ្យសេចក្ដីពិតដែលគេបានប្រកាសផ្សាយមានឥទ្ធិពលដោយសារព្រះចេស្ដានៃព្រះវិញ្ញាណយ៉ាងខ្លាំងក្លាទៅលើអ្នកស្ដាប់ទាំងឡាយមិនខាន។

អាកប្បកិរិយារបស់អាន្នាំនាសនិងសាភីរ៉ា ដែលបទពិសោធន៍របស់ពួកគេបានកត់ត្រាដោយស្លាបប៉ាកកាដែលព្រះវិញ្ញាណបានបណ្ដាល បានបន្សល់ទុកជាស្លាកស្នាមដ៏ខ្មៅងងឹតនៅក្នុងប្រវត្តិសាស្ត្រនៃពួកជំនុំដំបូងនោះ ផ្ទុយគ្នាស្រឡះពីគំរូដែលប្រកបដោយចិត្តមេត្តារបស់ពួកអ្នកមានជំនឿ។ អ្នកទាំងពីរនេះបានទទួលឱកាសនៃការឮការអធិប្បាយដំណឹងល្អដោយពួកសាវ័កជាមួយនឹងពួកអ្នកជឿដទៃទៀតដែរ។ ពួកគេបាននៅជាមួយនឹងពួកអ្នកជឿដទៃទៀត នៅពេលមានការរញ្ជួយដី បន្ទាប់ពីពួកសាវ័កបានអធិដ្ឋាន

«នោះកន្លែងដែលគេប្រជុំគ្នាក៏រញ្ជួយ ហើយគេបានពេញជាព្រះវិញ្ញាណបរិសុទ្ធទាំងអស់គ្នា» (កិច្ចការ ៤:៣១) ។ នៅក្រោមឥទ្ធិពលដោយផ្ទាល់របស់ព្រះវិញ្ញាណនៃព្រះ។ គ្រប់គ្នាដែលមានវត្តមាននៅទីនោះមានការជឿជាក់យ៉ាងខ្លាំង អាណានាសនិងសាភីរ៉ាបានសន្យាថានឹងថ្វាយទៅព្រះជាម្ចាស់នូវលុយដែលបានមកពីការលក់ដីមួយកន្លែង។

<u>ព្រហស្បតិ៍-១៦ កក្កដា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ៦**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *តែពេត្រុសសួរថា អាន្នាំនាសអើយ ហេតុអ្វីបានជាអារក្សសាតាំងមកនៅពេញក្នុងចិត្តអ្នក ឲ្យអ្នកហ៊ានកុហកដល់ព្រះវិញ្ញាណបរិសុទ្ធ ដោយតែទុកដំឡៃដ៏១ចំណែកដូច្នេះ។ កិច្ចការ ៥:៣*

ក្រោយមកអាន្នាំនាសនិងសាភីរ៉ាបានធ្វើឲ្យព្រះវិញ្ញាណបរិសុទ្ធព្រួយព្រះទ័យដោយការទោរទន់ទៅរកចិត្តលោភលន់។ ពួកគេបានចាប់ផ្ដើមស្ដាយក្រោយនូវសេចក្ដីសន្យារបស់ពួកគេ ហើយមិនយូរប៉ុន្មានក៏បានបាត់បង់ឥទ្ធិពលដ៏ផ្អែមល្ហែមនៃព្រះពរដែលបានព្រមានដល់ចិត្តរបស់ពួកគេជាមួយនឹងសេចក្ដីប្រាថ្នាចង់ធ្វើកិច្ចការយ៉ាងធំ ដែលជាតំណាងឲ្យកិច្ចការរបស់ព្រះគ្រិស្ដនោះ។ ពួកគេបានគិតថាពួកគេបានធ្វើកិច្ចសន្យានោះប្រញាប់ប្រញាល់ពេក ដូច្នេះពួកគេត្រូវពិចារណាពីការសម្រេចចិត្តនោះជាថ្មីឡើងវិញ។ ពួកគេបានពិភាក្សាអំពីរឿងនោះឡើងវិញ ហើយបានសម្រេចចិត្តមិនធ្វើតាមពាក្យសន្យានោះទេ។ ទោះជាយ៉ាងនេះក៏ដោយ ពួកគេបានឃើញថាអ្នកដែលបានលះបង់ទ្រព្យសម្បត្តិរបស់ខ្លួន ដើម្បីផ្គត់ផ្គង់ដល់សេចក្ដីត្រូវការនៃបងប្អូនដែលជាអ្នកក្រីក្ររបស់ពួកគេ ទទួលបាននូវតម្លៃយ៉ាងខ្ពង់ខ្ពស់ នៅក្នុងចំណោមពួកអ្នកជឿ ហើយដោយមានការអៀនខ្មាសមិនចង់ឲ្យបងប្អូនគេដឹងអំពីចិត្តអាត្មានិយមរបស់ខ្លួន ដោយច្រណែនទៅនឹងអ្វីដែលពួកគេបានថ្វាយទៅព្រះ នោះពួកគេបានសម្រេចចិត្តលះបង់លក់ដីមួយកន្លែងរបស់គេ ហើយធ្វើហាក់ដូចជាបានប្រគល់លុយដែលបានពីការលក់ដីនោះទាំងអស់សម្រាប់

ជាថវិការួម ប៉ុន្តែ តាមពិតពួកគេបានកេងទុកមួយចំណែកធំសម្រាប់ខ្លួនឯង ធ្វើដូច្នេះ ពួកគេនឹងមានសុវត្ថិភាពនៃជីវិតរបស់ពួកគេពីឃ្លាំងប្រាក់នៅលោកិយផង និងទទួលបានតម្លៃខ្ពង់ខ្ពស់ពីបងប្អូនរួមជំនឿផង នៅពេលតែមួយ។

ប៉ុន្តែ ព្រះស្អប់ការកំពុតនិងអំពើខុសឆ្គងខ្លាំងណាស់។ អាន្នានាស និងសាភីរ៉ាបានប្រព្រឹត្តការកេងបំបាត់នៅក្នុងដំណោះស្រាយរបស់ពួកគេជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធ ហើយអំពើបាបរបស់ពួកគេក៏បានចូលមក ជាមួយនឹងការជំនុំជម្រះយ៉ាងធ្ងន់ធ្ងរនិងឆាប់រហ័ស។ នៅពេលដែលអាន្នានាសយកតង្វាយចូលមក លោកពេត្រុសបានមានប្រសាសន៍ថា «អាន្នានាសអើយ ហេតុអ្វីបានជាអារក្សសាតាំងមកនៅពេញក្នុងចិត្តអ្នក ឲ្យអ្នកហ៊ានកុហកដល់ព្រះវិញ្ញាណបរិសុទ្ធ ដោយគៃទុកតម្លៃដ៏ធំមួយចំណែកដូច្នេះ កាលនៅៗឡើយ តើមិនមែនជារបស់ផងអ្នកទេឬអី ហើយដែលលក់ទៅ តើប្រាក់មិននៅក្នុងអំណាចអ្នកដែរទេឬអី ហេតុអ្វីបានជាអ្នកកាត់ចិត្តធ្វើដូច្នេះ នេះមិនមែនកុហកដល់មនុស្សទេ គឺឈ្មោះថាកុហកដល់ព្រះវិញ»។

«កាលអាន្នានាសបានឮពាក្យនេះ ក៏ដួលដាច់ខ្យល់ស្លាប់ទៅ។ រីឯអស់អ្នកដែលបានឮដំណឹងនេះ ក៏ស្ញែងខ្លាចជាខ្លាំង»។

លោកពេត្រុសបានសួរថា «កាលនៅៗឡើយ តើមិនមែនជារបស់ផងអ្នកទេឬអី?»។ ពួកសាវ័កមិនបានបង្ខិតបង្ខំដល់អាន្នានាសឲ្យថ្វាយទ្រព្យសម្បត្តិរបស់គាត់ សម្រាប់ការល្អជាទូទៅនោះទេ។ គាត់បានធ្វើដោយជម្រើសរបស់គាត់។ ប៉ុន្តែ ដោយការប៉ុនប៉ងបោកបញ្ឆោតដល់ពួកសាវ័កដូច្នេះ គាត់បានកុហកដល់ព្រះដ៏មានព្រះចេស្តាហើយ ។

«នៅគ្រាប្រហែលជាបីម៉ោងក្រោយមក ប្រពន្ធគាត់ក៏ចូលមក ឥតដឹងការដែលកើតមកនោះសោះ ពេត្រុសសួរថា សូមប្រាប់ខ្ញុំ តើបានលក់ដីថ្លៃប៉ុណ្ណោះមែនឬ នាងឆ្លើយតបថា ចាសពិតមែនហើយ រួចពេត្រុសនិយាយថា ហេតុអ្វីបានជាព្រមព្រៀងគ្នា និងល្បងដល់ព្រះវិញ្ញាណនៃព្រះអម្ចាស់ដូច្នេះ

មើល ពួកអ្នកដែលកប់ខ្មោចប្ដីអ្នក គេមកដល់មាត់ទ្វារហើយ គេនឹងសែងអ្នកយកទៅដែរ នោះស្រាប់តែនាងដួល ដាច់ខ្យល់មួយរំពេច នៅទៀបជើងពេត្រុសទៀត កាលពួកកំឡោះបានចូលមក ឃើញនាងស្លាប់ នោះក៏សែងយកទៅកប់នៅជិតខ្មោចប្ដីទៅ រួចពួកជំនុំទាំងប៉ុន្មាន និងអស់អ្នកណាដែលឮនិយាយពីការនោះ ក៏កើតមានសេចក្ដីស្ញែងខ្លាចទាំងអស់គ្នា» ។

ព្រះប្រាជ្ញាញាណដែលគ្មានដែនកំណត់បានទតឃើញថាសញ្ញានៃការបង្ហាញសេចក្ដីក្រោធរបស់ព្រះនេះ គឺជាការចាំបាច់ដើម្បីរក្សាពួកជំនុំដ៏ក្មេងខ្ចីនេះឲ្យចាកផុតពីការក្លាយទៅជាការបង្ខូចទឹកចិត្ត ។ ពួកជំនុំត្រូវតែទទួលខុសត្រូវ ប្រសិនបើនៅពេលដែលពួកអ្នកជឿកំពុងតែកើនឡើងយ៉ាងឆាប់

រហ័ស ហើយបុរសទាំងឡាយដែលបានបន្ថែមទៅក្នុងព្រះវិហារនោះកំពុងថ្វាយបង្គំទ្រព្យសម្បត្តិ នៅពេលដែលពួកគេកំពុងតែប្រកាសថាបម្រើដល់ព្រះ ។ ការជំនុំជម្រះនេះបញ្ជាក់ថាមនុស្សមិនអាចបោកបញ្ឆោតព្រះបានឡើយ បញ្ជាក់ថា ទ្រង់ទតឃើញអំពើបាបរបស់កូនៗនៅក្នុងចិត្ត និងថាមនុស្សមិនត្រូវសើចចំអកដល់ទ្រង់ទេ ។ ព្រះបានរៀបចំការជំនុំជម្រះនេះសម្រាប់ពួកជំនុំ ដើម្បីដឹកនាំគេឲ្យចៀសវាងពីការកំពុត និងមិនត្រូវល្បួចប្លន់ពីព្រះឡើយ។

**<u>សុក្រ-១៧ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក៧ខព្រះគម្ពីរប្រចាំថ្ងៃ:** *កាលនៅៗឡើយ តើមិនមែនជារបស់ផងអ្នកទេឬអី ហើយដែលលក់ទៅ តើប្រាក់មិននៅក្នុងអំណាចអ្នកដែរទេឬអី ហេតុអ្វីបានជាអ្នកកាត់ចិត្តធ្វើដូច្នេះ នេះមិនមែនកុហកដល់មនុស្សទេ គឺឈ្មោះថាកុហកដល់ព្រះវិញ។ កិច្ចការ ៥:៤*

ព្រះបានប្រទានគំរូនៃការស្អប់ខ្ពើមចំពោះការលោភលន់ អំពើខុសឆ្គង និងការកំពុត ដែលជាសញ្ញានៃគ្រោះថ្នាក់នេះ មិនមែនត្រឹមតែដល់ពួកជំនុំដំបូងប៉ុណ្ណោះទេ ប៉ុន្តែ គឺដល់មនុស្សគ្រប់ជំនាន់ផងដែរ។ គឺជាសេចក្ដីលោភ

លន់ដែលអាន្នានាសនិងសាភីរ៉ាបានស្រឡាញ់ជាទីបំផុតជាលើកដំបូង។ សេចក្តីប៉ងប្រាថ្នារក្សាទុកចំណែកដែលគេបានសន្យាថានឹងថ្វាយទៅព្រះនោះសម្រាប់ខ្លួនឯង បានដឹកនាំឲ្យពួកគេធ្លាក់ចូលទៅក្នុងកំហុសឆ្គងនិងការកំពុត។

ព្រះបានធ្វើឲ្យការប្រកាសដំណឹងល្អទីពឹងលើកិច្ចការ និងអំណោយទាននៃរាស្ត្ររបស់ទ្រង់។ តង្វាយដោយសទ្ធានិងតង្វាយដប់ហូតមួយទុកសម្រាប់ជាផលទុននៃកិច្ចការរបស់ព្រះជាម្ចាស់។ ព្រះទាមទារចំណែកណាមួយពីមធ្យោបាយដែលព្រះបានប្រទានដល់មនុស្ស គឺតង្វាយមួយក្នុងដប់។ ព្រះអង្គទុកសេរីភាពឲ្យមនុស្សទាំងអស់និយាយថាគេនឹងថ្វាយច្រើនជាងនេះ។ ប៉ុន្តែនៅពេលដែលព្រះវិញ្ញាណបរិសុទ្ធបំផុសចិត្ត ហើយគេបានសន្យាថានឹង

ថ្វាយនូវចំនួនណាមួយ អ្នកដែលបានសន្យាមិនមានសិទ្ធិចំពោះចំណែកដែលបានលះបង់ថ្វាយនោះឡើយ។ សេចក្តីសន្យាដែលធ្វើចំពោះមនុស្សបែបនេះត្រូវបានគេចាត់ទុកថា ជាការដែលត្រូវតែគោរពឲ្យបានត្រឹមត្រូវ ប៉ុន្តែចុះសេចក្តីសន្យាដែលធ្វើជាមួយនឹងព្រះ តើមិនមែនជាការដែលត្រូវតែគោរពទេឬអី? តើយើងគួរគោរពសេចក្តីសន្យាដែលបានធ្វើនៅក្នុងតុលាការនៃមនសិការរបស់មនុស្ស តិចជាងកិច្ចសន្យាជាលាយលក្ខណ៍អក្សររបស់ព្រះឬអី?

នៅពេលពន្លឺរបស់ព្រះបានចែងចាំងចូលទៅក្នុងចិត្ត ជាមួយនឹងភាពភ្លឺថ្លានិងអំណាចខុសពីធម្មតា កណ្តាប់ដៃនៃភាពអាត្មានិយមក៏បានចុះថយហើយមានចិត្តចង់ថ្វាយដល់កិច្ចការរបស់ព្រះ។ ប៉ុន្តែ មនុស្សត្រូវតែគិតថាព្រះអនុញ្ញាតឲ្យពួកគេបំពេញតាមសេចក្តីសន្យាដែលបានធ្វើនៅពេលនោះដោយគ្មានការជំទាស់ពីសាតាំង។ សាតាំងវាមិនសប្បាយចិត្តនឹងឃើញនគរនៃព្រះដ៏ប្រោសលោះត្រូវបានស្ថាបនានៅលើផែនដីទេ។ វាឲ្យយោបល់ថាសេចក្តីសន្យាដែលមនុស្សបានធ្វើនោះធ្ងន់ធ្ងរពេកណាស់ វាថាអាចធ្វើឲ្យពួកគេគាំងដំណើរក្នុងការខំប្រឹងប្រែងរកទ្រព្យសម្បត្តិឬការបំពេញដល់សេចក្តី

ប្រាថ្នារបស់ក្រុមគ្រួសារ ។

គឺព្រះដែលបានប្រទានព្រះពរឲ្យមនុស្សមានទ្រព្យសម្បត្តិ ហើយបានធ្វើដូច្នេះដើម្បីឲ្យពួកគេអាចជំរុញកិច្ចការរបស់ព្រះអង្គឲ្យបោះជំហានទៅមុខ។ ព្រះបានប្រទានពន្លឺព្រះអាទិត្យនិងទឹកភ្លៀង។ ព្រះអង្គបានធ្វើឲ្យរុក្ខជាតិដុះលូតលាស់ឡើង។ ព្រះអង្គបានប្រទានសុខភាពនិងសមត្ថភាពឲ្យទទួលបានទ្រព្យសម្បត្តិ។ ព្រះពរទាំងអស់របស់យើងមកតែពីព្រះហស្តដ៏សប្បុរសរបស់ទ្រង់ប៉ុណ្ណោះ។ ព្រះអង្គចង់ឲ្យបុរសនារីទាំងឡាយបង្ហាញការដឹងគុណត្រឡប់ទៅទ្រង់វិញមួយចំណែក ដោយបង្វិលតង្វាយដប់ហូតមួយនិងតង្វាយសទ្ធា និងតង្វាយអរព្រះគុណ តង្វាយស្ម័គ្រពីចិត្ត ក្នុងតង្វាយដោយព្រោះការប្រព្រឹត្តិរំលង។ នឹងមានទ្រព្យសម្បត្តិហូរចូលទៅក្នុងឃ្លាំងយោងទៅតាមផែនការដែលព្រះបានរៀបចំ គឺតង្វាយដប់ហូតមួយពីចំណូលទាំងអស់ និងតង្វាយសទ្ធា កិច្ចការរបស់ព្រះជាម្ចាស់នឹងមានការចម្រើនលូតលាស់ទៅមុខយ៉ាងខ្លាំងក្លា។

<u>សៅរ៍-១៨ កក្កដា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ៨**

**ខព្រះគម្ពីរប្រចាំសប្តាហ៍:** *ដូច្នេះ ចូរឲ្យឈរមាំមួនចុះ ដោយក្រវាត់សេចក្ដីពិតនៅចង្កេះ ហើយពាក់សេចក្ដីសុចរិតទុកជាប្រដាប់បាំងដើមទ្រូង។*
*អេភេសូរ ៦:១៤*

ប៉ុន្តែ ចិត្តរបស់មនុស្សបានត្រឡប់ជារឹងរូសដោយសារតែភាពអាត្មានិយម ហើយសាតាំងបានល្បួងពួកគេឲ្យលាក់ទុកនូវតម្លៃមួយចំណែក នៅពេលដែលពួកគេធ្វើពុតជាធ្វើតាមតម្រូវការរបស់ព្រះ ដូចជាអាន្នានាសនិងសាភីរ៉ាដូច្នោះដែរ។ មនុស្សជាច្រើនបានចាយវាយខ្ជះខ្ជាយ សម្រាប់បំពេញចិត្តផ្ទាល់ខ្លួន។ បុរសនារីជាច្រើនតម្រូវតាមការសប្បាយរបស់ខ្លួន ហើយបំពេញចិត្តខ្លួនឯង នៅពេលដែលពួកគេសឹងតែមិនចង់នាំយកតង្វាយបន្តិចបន្តួចទៅថ្វាយព្រះផង។ ពួកគេបានភ្លេចថានៅថ្ងៃណាមួយព្រះអង្គនឹងទាមទារបញ្ជី

នៃរបៀបដែលមនុស្សបានប្រើប្រាសរបស់ល្អរបស់ទ្រង់ ហើយថាទ្រង់នឹងលែងទទួលការផ្គត់ផ្គង់ដែលពួកគេបានដាក់ក្នុងឃ្លាំង ដូចជាទ្រង់បានទទួលតង្វាយពីអាន្នានាសនិងសាភីរ៉ាដូច្នោះដែរ។

ចេញពីការដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរដែលបានកើតឡើងដល់ពួកអ្នកភូតភរ ព្រះក៏ចង់ឲ្យយើងរៀនសូត្រអំពីជម្រៅនៃការស្អប់ខ្ពើមនិងការប៉ុនប៉ងប្រព្រឹត្តកំពុត និងការបោកបញ្ឆោតទាំងឡាយផងដែរ។ ក្នុងការពុតធ្វើជាថ្វាយទាំងអស់ អាន្នានាសនិងសាភីរ៉ាបានកុហកដល់ព្រះវិញ្ញាណបរិសុទ្ធ ហើយជាលទ្ធផល ពួកគេបានបាត់បង់ជីវិតនៅលោកិយនេះ និងជីវិតដែលនឹងកើតឡើងនៅពេលខាងមុខ (ពេលព្រះយេស៊ូវយាងមកវិញ)។ ព្រះដដែលដែលបានដាក់ទណ្ឌកម្មដល់អ្នកទាំងពីរនេះ ព្រះអង្គក៏ថ្កោលទោសដល់អ្នកដែលប្រព្រឹត្តខុសនាពេលបច្ចុប្បន្ននេះដែរ។ បបូរមាត់ដែលពោលពាក្យកុហកជាទីស្អប់ខ្ពើមដល់ទ្រង់។ ព្រះអង្គបានមានបន្ទូលថានៅក្នុងទីក្រុងបរិសុទ្ធ «ក៏គ្មានអ្វីស្មោកគ្រោក ឬអ្នកណាដែលប្រព្រឹត្តបែបគួរខ្ពើម ឬសេចក្ដីកំភូតណាចូលទៅក្នុងទីក្រុងនោះឡើយ ...» (វិវរណៈ ២១:១៧)។ ចូរយើងប្រកាន់នូវការនិយាយពីសេចក្ដីពិតជានិច្ច។ ចូរឲ្យការនិយាយតែពីការពិតក្លាយជាផ្នែកនៃជីវិតរបស់យើង។ ការស្មោះត្រង់ និងការធូរលុងជាមួយនឹងសេចក្ដីពិត និងការបន្លំដើម្បីតម្រូវទៅតាមផែនការអាត្មានិយម មានន័យថាបំផ្លាញសេចក្ដីជំនឿ។ «ដូច្នេះ ចូរឲ្យឈរមាំមួនចុះ ដោយក្រវាត់សេចក្ដីពិតនៅចង្កេះ ហើយពាក់សេចក្ដីសុចរិតទុកជាប្រដាប់បាំងដើមទ្រូង» (អេភេសូរ ៦:១៤)។ អ្នកណាដែលពោលពាក្យមិនពិតគឺលក់ព្រលឹងរបស់ខ្លួននៅក្នុងទីផ្សារយ៉ាងថោកហើយ ។ កំហុសឆ្គងរបស់គេអាចហាក់ដូចជាធ្ងន់ធ្ងរនៅក្នុងសភាពការបន្ទាន់ៗ គេហាក់ដូចជាធ្វើឲ្យមុខជំនួញរបស់គេជឿនលឿនទៅមុខ ដែលគេអាចទទួលបានផលចំណេញដោយដំណោះស្រាយត្រឹមត្រូវ ប៉ុន្តែ ទីបំផុតគេបានមកដល់កន្លែងដែលគេមិនអាចទុកចិត្តអ្នកណាសោះ។ រូបគេគឺជាអ្នកកុហក គេមិនមានទំនុកចិត្តទៅលើសម្ដីរបស់អ្នកដទៃ។

នៅក្នុងករណីរបស់អាន្នានាសនិងសាភីរ៉ា អំពើបាបនៃការខុសឆ្គងប្រឆាំងនឹងព្រះត្រូវបានទទួលទណ្ឌកម្មភ្លាមៗ ។ អំពើបាបដូចគ្នានេះតែងតែកើតឡើងជាបន្តបន្ទាប់នៅក្នុងប្រវត្តិសាស្រ្តនៃពួកជំនុំក្រោយៗមកទៀត ហើយមនុស្សជាច្រើននៅសម័យយើងសព្វថ្ងៃនេះកំពុងប្រព្រឹត្តអំពើបាបនោះ។ ប៉ុន្តែ ទោះបីជាអំពើបាបនោះមិនបានបង្ហាញឲ្យឃើញពីការមិនសព្វព្រះទ័យរបស់ព្រះក៏ដោយ ក៏អំពើបាបនោះមានទោសមិនតិចជាងសម័យពួកសាវ័កដែរ។ ព្រះបានប្រទានការព្រមាន ព្រះបានបង្ហាញយ៉ាងច្បាស់អំពីការស្អប់ខ្ពើមរបស់ព្រះអង្គដល់អំពើបាបនេះ ហើយអស់អ្នកណាដែលបានប្រគល់ខ្លួនទៅឲ្យការកំពុតនិងការលោភលន់ អ្នកនោះប្រាកដជាបានបំផ្លាញខ្លួនឯងហើយ ។

## ជំពូកទី ៨

# នៅចំពោះក្រុមប្រឹក្សាសាន់ហ៊ីឌ្រីន

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ៥:១២-៤២ ។*

<u>អាទិត្យ-១៩ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ៩

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ហើយពួកអ្នកដែលជឿដល់ព្រះអម្ចាស់ ក៏បានចំរើនកាន់តែច្រើនឡើង មានមនុស្សសន្ធឹក ទាំងប្រុសទាំងស្រី) ដល់ម៉្លេះបានជាគេយកមនុស្ស ដែលមានជំងឺផ្សេងៗ ចេញមកនៅផ្លូវ ផ្តេកលើគ្រែ និងពូក ដើម្បីកាលណាពេត្រុសដើរមក នោះសូម្បីហោចណាស់ ឲ្យគ្រាន់តែស្រមោលគាត់ចោលទៅលើពួកនោះខ្លះប៉ុណ្ណោះ។ កិច្ចការ ៥:១៤-១៥*

គឺឈើឆ្កាងដែលជាឧបករណ៍សម្រាប់ដាក់ទណ្ឌកម្មដ៏គួរឲ្យអាម៉ាស់នោះហើយ ដែលនាំមកនូវសេចក្តីសង្ឃឹមនិងសេចក្តីសង្គ្រោះមកកាន់ពិភពលោក។ ពួកសាវ័កជាមនុស្សដែលបន្ទាបខ្លួន ហើយគ្មានទ្រព្យសម្បត្តិនិងអាវុធយុទ្ធភ័ណ្ឌអ្វីក្រៅពីព្រះបន្ទូលរបស់ព្រះឡើយ ដែលធ្វើឲ្យពួកគេបានបោះជំហានទៅមុខជាមួយនឹងកម្លាំងរបស់ព្រះយេស៊ូវ ដើម្បីនិយាយប្រាប់ពីរឿងរ៉ាវនៃស្នូកដាក់ចំណីសត្វនិងឈើឆ្កាង និងអំពីជោគជ័យទៅលើពួកអ្នកប្រឆាំង។ ពួកគេជាវីរបុរសនៃសេចក្តីជំនឿដោយគ្មានកិត្តិយស ឬការទទួលស្គាល់នៃលោកិយនេះឡើយ។ ព្រះបន្ទូលនៃព្រះប្រកបដោយវោហាកោសល្យដែលចេញពីបបូរមាត់ពួកគេ បានចាប់អង្រួនពិភពលោក។

ពួកសាវ័កបានបន្តនិយាយដោយក្លាហានអំពីព្រះបន្ទូលនៃជីវិត ដោយបង្ហាញនៅពីមុខពួកយូដានូវកិច្ចការនិងបេសកកម្មរបស់ព្រះគ្រិស្ត ការជាប់ឆ្កាង ការមានព្រះជន្មរស់ឡើងវិញ និងការយាងឡើងទៅឋានសួគ៌របស់

ព្រះអង្គ នៅទីក្រុងយេរូសាឡិមដែលមានការប្រកាន់ពូជសាសន៍ជាខ្លាំង និងជាកន្លែងដែលគំនិតច្រឬកច្របល់ទាក់ទងនឹងព្រះយេស៊ូវដែលត្រូវគេឆ្កាងដូចជាមនុស្សរំលងច្បាប់ មានជ័យជម្នះនោះ។ ពួកសង្ឃនិងពួកមេសាសនាបានឮទីបន្ទាល់យ៉ាងច្បាស់និងដោយក្លាហានរបស់ពួកសាវ័ក ដោយភ្ញាក់ផ្អើល។ ព្រះចេស្ដារបស់ព្រះអង្គសង្គ្រោះដែលបានមានព្រះជន្មរស់ឡើងវិញពិតជាបានធ្លាក់មកលើពួកសាវ័ក ហើយកិច្ចការរបស់ពួកគេត្រូវបានសម្រេចដោយទីបន្ទាល់និងការអស្ចារ្យ ដែលធ្វើឲ្យចំនួនអ្នកជឿកាន់តែកើនឡើងជារៀងរាល់ថ្ងៃ។ នៅតាមផ្លូវដែលពួកសាវ័កនឹងធ្វើដំណើរ ពួកបណ្ដាជនបានដាក់អ្នកមានជំងឺរបស់ពួកគេ «ផ្ដេកលើគ្រែ និងលើពូកដើម្បីកាលណាពេត្រុសដើរមក នោះសូម្បីហោចណាស់ ឲ្យគ្រាន់តែស្រមោលគាត់ (លោកពេត្រុស) ចោលទៅលើពួកនោះខ្លះប៉ុណ្ណោះ»។ នៅទីនេះគេក៏បាននាំអ្នកដែលមានវិញ្ញាណអារក្សចូលមកផងដែរ។ ហ្វូងមនុស្សបានព័ទ្ធជុំវិញពួកគេ ហើយពួកដែលបានស្រែកសរសើរតម្កើងដល់ព្រះនិងថ្វាយសិរីល្អដល់ព្រះនាមព្រះដ៏ប្រោសលោះ។

ពួកសង្ឃនិងពួកមេសាសនាបានឃើញថាពួកបណ្ដាជនបានសរសើរតម្កើងដល់ព្រះយេស៊ូវខ្ពស់ជាងពួកគេហើយ។ ខណៈដែលពួកសាឌូស៊ីជាពួកដែលមិនជឿលើការរស់ឡើងវិញ បានឮថាព្រះគ្រិស្ដបានមានព្រះជន្មរស់ឡើងវិញដូច្នេះ ពួកគេក៏មានកំហឹងពុះពោរឡើង ដោយបានដឹងថាប្រសិនបើបណ្ដោយឲ្យពួកសាវ័កផ្សព្វផ្សាយ អំពីព្រះអង្គសង្គ្រោះដែលបានមានព្រះជន្មរស់ឡើងវិញ និងធ្វើការដោយនូវព្រះនាមរបស់ទ្រង់តទៅទៀត នោះគោលលទ្ធិដែលថែងថា មិនមានការរស់ឡើងវិញនឹងត្រូវមនុស្សទាំងអស់ច្រានចោលជាមិនខាន ហើយមិនយូរប៉ុន្មាន គណៈសាឌូស៊ីនឹងត្រូវវិនាសសាបសូន្យជាប្រាកដ។ ចំណែកពួកផារិស៊ីឯណោះវិញ ក៏បានខឹងសម្បាដែរខណៈដែលពួកគេបានដឹងថា ទំនោរនៃការបង្រៀនរបស់ពួកសាវ័កបានបំផ្លាញដល់ពិធីផ្សេងៗ និងការថ្វាយតង្វាយយញ្ញបូជារបស់សាសន៍យូដា

ឲ្យលែងមានប្រសិទ្ធិភាព។

ចាប់តាំងពីពេលនោះមក ការខំប្រឹងប្រែងទាំងប៉ុន្មាន ដើម្បីបង្រាបដល់ការបង្រៀនថ្មីនោះត្រូវបានអសារឥតការ ឥឡូវនេះទាំងពួកសាឌូស៊ី និងពួកផារិស៊ីបានប្ដេជ្ញាចិត្តថា នឹងបញ្ឈប់កិច្ចការរបស់ពួកសាវ័កឲ្យទាល់តែបាន ព្រោះការនេះកំពុងបង្ហាញដល់ពួកគេអំពីទោសកំហុសនៃការសុគតរបស់ព្រះយេស៊ូវ។ ពោរពេញទៅដោយការឈឺចិត្ត ពួកគេបានប្រើអំពើហិង្សាទៅលើលោកពេត្រុសនិងយ៉ូហាន ហើយបានចាប់ពួកសាវ័កឃុំទុក។

<u>ច័ន្ទ-២០ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ១០

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *តែខ្ញុំនិយាយសេចក្ដីទាំងនេះ ប្រាប់ដល់អ្នករាល់គ្នា ដើម្បីកាលណាពេលវេលានោះមកដល់ នោះឲ្យអ្នករាល់គ្នាបាននឹកឃើញថា ខ្ញុំប្រាប់ហើយ ខ្ញុំមិនបានប្រាប់កាលពីដើមទេ ពីព្រោះខ្ញុំកំពុងនៅជាមួយនឹងអ្នករាល់គ្នានៅឡើយ។ យ៉ូហាន ១៦:៤*

ពួកអ្នកដឹកនាំសាសន៍យូដាបរាជ័យ ដោយសញ្ញានៃការមិនបានបំពេញតាមព្រះរាជគោលបំណងរបស់ព្រះ សម្រាប់ការជ្រើសរើសរាស្ត្ររបស់ទ្រង់។ អ្នកដែលព្រះបានផ្ញើសេចក្ដីពិតជាមួយបានបង្ហាញការមិនស្មោះត្រង់ទៅនឹងភារកិច្ចរបស់ខ្លួន ហើយព្រះបានជ្រើសរើសអ្នកដទៃផ្សេងឲ្យបំពេញកិច្ចការនោះវិញ។ ឥឡូវនេះ ដោយភាពងងឹតងងល់ ពួកអ្នកដឹកនាំទាំងនោះបានប្រគល់ឥទ្ធិពលរបស់ខ្លួនទាំងស្រុងទៅឲ្យអ្វីដែលគេហៅថា ការខូចចិត្តនៃសេចក្ដីសុចរិតប្រឆាំងនឹងអ្នកដែលបានដកយកគោលលទ្ធិដ៏រីករាយរបស់ពួកគេចេញ។ ពួកគេមិនបានទាំងទទួលស្គាល់សូម្បីតែការទទួលខុសត្រូវថា ពួកគេមិនបានយល់ច្បាស់នូវព្រះបន្ទូល ឬដែលពួកគេបានបកស្រាយបទព្រះគម្ពីរខុស ឬអនុវត្តមិនបានត្រឹមត្រូវនោះផង។ ពួកគេបានប្រព្រឹត្តដូចជាមនុស្សដែលគ្មានហេតុផល។ ពួកគេបាននិយាយថា ពួកសាវ័កមួយចំនួនគ្រាន់តែជាអ្នកនេសាទប៉ុណ្ណោះ តើពួកគ្រូទាំងនេះមានសិទ្ធិអ្វីនឹងបង្ហាញពី

គំនិតនៃគោលលទ្ធិផ្ទុយពីការដែលយើងបានបង្រៀនដល់ប្រជារាស្ត្រដូច្នេះ? ក្នុងគោលបំណងបង្ក្រាបដល់ការបង្រៀនទាំងនេះ ពួកគេបានចាប់អ្នកដែលបង្រៀនពីរឿងនោះដាក់គុក។

ពួកសាវ័កមិនមានការតក់ស្លុតឬព្រួយបារម្ភដោយសារការប្រព្រឹត្តបែបនេះឡើយ។ ព្រះវិញ្ញាណបរិសុទ្ធបាននាំព្រះបន្ទូលដែលព្រះគ្រិស្តបានមានព្រះបន្ទូលមកប្រាប់ពួកគេថា «បាវមិនមែនធំជាងចៅហ្វាយទេ បើគេបានបៀតបៀនដល់ខ្ញុំ នោះគេនឹងបៀតបៀនដល់អ្នករាល់គ្នា ហើយបើគេបានកាន់តាមពាក្យខ្ញុំ នោះគេនឹងកាន់តាមពាក្យរបស់អ្នករាល់គ្នាដែរ គេនឹងប្រព្រឹត្តការទាំងនោះដល់អ្នករាល់គ្នា ដោយយល់ដល់ឈ្មោះខ្ញុំ ពីព្រោះគេមិនស្គាល់ព្រះដែលចាត់ឲ្យខ្ញុំមកទេ»។ «គេនឹងកាត់អ្នករាល់គ្នា ចេញពីពួកជំនុំរបស់គេ ក៏នឹងមានពេលវេលាមកនោះអស់អ្នកណាដែលសម្លាប់អ្នករាល់គ្នា នឹងគិតស្មានថា ខ្លួនបម្រើដល់ព្រះដែរ តែខ្ញុំនិយាយសេចក្ដីទាំងនេះ ប្រាប់ដល់អ្នករាល់គ្នា ដើម្បីកាលណាពេលវេលានោះមកដល់ នោះឲ្យអ្នករាល់គ្នាបាននឹកឃើញថា ខ្ញុំប្រាប់ហើយ ខ្ញុំមិនបានប្រាប់កាលពីដើមទេ ពីព្រោះខ្ញុំកំពុងនៅជាមួយនឹងអ្នករាល់គ្នានៅឡើយ» (យ៉ូហាន ១៥:២០, ២១ និង ១៦:២, ៤)។

ព្រះនៃឋានសួគ៌ ជាអ្នកគ្រប់គ្រងដ៏មានអំណាចនៅលើចក្រវាលបានយករឿងរ៉ាវនៃការចាប់ដាក់គុករបស់ពួកសាវ័កទៅដាក់លើព្រះហស្តរបស់ព្រះអង្គផ្ទាល់ ព្រោះមនុស្សកំពុងបានច្បាំងតទល់នឹងកិច្ចការរបស់ទ្រង់។ នៅពេលយប់ ទេវតានៃព្រះជាម្ចាស់បានបើកទ្វារគុក ហើយមានបន្ទូលទៅកាន់សាវ័កទាំងពីរថា «ចូរទៅឈរអធិប្បាយនៅក្នុងព្រះវិហារឲ្យបណ្ដាជនស្ដាប់អស់ទាំងព្រះបន្ទូល ពីជីវិតថ្មីនេះទៅ»។ ការត្រាស់បង្គាប់នេះផ្ទុយគ្នាស្រឡះពីបញ្ជាដែលចេញដោយពួកមេដឹកនាំសាសន៍យូដា ប៉ុន្តែ តើពួកសាវ័កបាននិយាយថា យើងមិនអាចធ្វើកិច្ចការនេះបានទេ លុះត្រាតែយើងបានពិភាក្សាជាមួយពួកតុលាការ ហើយទទួលការអនុញ្ញាតពីពួកគេជាមុនសិន ដែរឬទេ? ទេ ព្រះបានមានបន្ទូលថា «ទៅ» ហើយពួកគេក៏ស្ដាប់តាម

«នោះក៏នាំគ្នាចូលទៅបង្រៀន ក្នុងព្រះវិហារពីព្រលឹម» ។

កាលលោកពេត្រុសបានបង្ហាញខ្លួននៅចំពោះពួកអ្នកមានជំនឿ និងរៀបរាប់ប្រាប់អំពីការដែលទេវតាបានដឹកនាំពួកគេចេញពីគុក ឆ្លងកាត់ក្រុមទាហានដែលយាមគុក បង្ខំឲ្យពួកគេបន្តកិច្ចការដែលកំពុងតែមានការរំខាននេះ តទៅមុខទៀត បងប្អូនរួមជំនឿទាំងអស់នោះពោរពេញទៅដោយការភ្ញាក់ផ្អើលនិងក្តីអំណរ។

<u>អង្គារ-២១ កក្កដា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ១១**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *បើអ្នករាល់គ្នាជារបស់ផងលោកីយ៍ នោះលោកីយ៍នឹងស្រឡាញ់អ្នករាល់គ្នា តែដោយព្រោះខ្ញុំបានរើសចេញពីលោកីយ៍មក ហើយអ្នករាល់គ្នាមិនមែនជារបស់ផងលោកីយ៍ទៀត នោះបានជាលោកីយ៍ស្អប់អ្នករាល់គ្នាវិញ។ យ៉ូហាន ១៥:១៩*

នៅពេលជាមួយគ្នានោះ សម្តេចសង្ឃនិងពួកដែលនៅជាមួយនឹងលោក «ក៏មកហៅពួកក្រុមជំនុំ និងពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែលទាំងអស់ឲ្យប្រជុំគ្នា»។ ពួកសង្ឃនិងពួកមេដឹកនាំសាសនាបានសម្រេចចិត្តកំណត់ចោទប្រកាន់ពួកសាវ័កពីបទប្រឆាំងបះបោរ  ដោយចោទប្រកាន់ពួកគេពីបទធ្វើឃាតអាន្ន៉ានាសនិងសាភីរ៉ា និងពីបទរួមគំនិតក្បត់ ចង់ដកហូតតំណែងរបស់ពួកសង្ឃនៃរដ្ឋអំណាច។ ពួកគេបានសង្ឃឹមថាធ្វើដូច្នេះនឹងជំរុញហ្វូងមនុស្សឲ្យទាមទារយករឿងក្តីនេះទៅកាន់នៅក្នុងកណ្តាប់ដៃរបស់ពួកគេ ហើយនិងដោះស្រាយជាមួយនឹងពួកសាវ័កដូចជាពួកគេបានដោះស្រាយជាមួយនឹងព្រះយេស៊ូវយ៉ាងដូច្នោះដែរ។ ពួកគេបានដឹងថាមនុស្សជាច្រើនដែលមិនបានទទួលយកការបង្រៀនរបស់ព្រះគ្រិស្ត បានធុញទ្រាន់ទៅនឹងច្បាប់ដែលរំលោភបំពានរបស់រដ្ឋអំណាចយូដា ហើយចង់បានការផ្លាស់ប្តូរ។ ពួកសង្ឃបារម្ភក្រែងពួកអ្នកដែលមិនពេញចិត្តទាំងនេះទទួលយកសេចក្តីពិត ដែលពួកសាវ័កបានប្រកាស ហើយទទួលយកព្រះយេស៊ូវថាជាព្រះមែស៊ី នោះ

កំហឹងរបស់ប្រជារាស្ត្រទាំងមូលនឹងងើបឡើង ប្រឆាំងនឹងមេដឹកនាំ សាសនា ពេលនោះពួកបណ្តាជននឹងឲ្យពួកគេឆ្លើយទៅនឹងសំណួរនៃការធ្វើគុតដល់ព្រះគ្រិស្ត ជាក់ជាមិនខាន។ ពួកគេបានសម្រេចចិត្តថានឹងការពារខ្លួនឲ្យរួចផុតពីបញ្ហានេះឲ្យបានជាដាច់ខាត។

នៅពេលដែលពួកគេបានចាត់ពួកអាជ្ញាឲ្យទៅនាំពួកសាវ័កចូលមក នោះគេ មានការភ្ញាក់ផ្អើលជាខ្លាំង ដោយពួកអាជ្ញាបានរាយការណ៍ថា ទ្វារគុកនៅតែបិទយ៉ាងប្រុងប្រយ័ត្នគ្រប់ជំពូក ទាំងមានពួកយាមល្បាតឈរនៅមាត់ទ្វារផង ប៉ុន្តែ ពួកអ្នកទោសមិនដឹងជាទៅឯណាបាត់ទេ។

រំពេចនោះមានរបាយការណ៍ដ៏គួរឲ្យភ្ញាក់ផ្អើមួយមកជម្រាបថា «មើលពួកមនុស្សដែលលោកបានដាក់គុកនោះ ឥឡូវនេះ គេកំពុងតែឈរ បង្រៀនដល់ពួកជននៅក្នុងព្រះវិហារវិញ» ។

ទោះបីជាទេវតាបានរំដោះពួកសាវ័កចេញពីគុកដោយការអស្ចារ្យយ៉ាងនេះក៏ដោយ ក៏ពួកគេមិនអាចរួចផុតពីការជំនុំជម្រះនិងការដាក់ទណ្ឌកម្មដែរ។ កាលព្រះអង្គគង់នៅជាមួយនឹងពួកគេ ព្រះគ្រិស្តបានមានបន្ទូលថា «ប៉ុន្តែឲ្យអ្នករាល់គ្នាប្រយ័ត្នខ្លួន ពីព្រោះគេនឹងបញ្ជូនអ្នករាល់គ្នាទៅឯក្រុមជំនុំ» (ម៉ាកុស ១៣:៩)។ ដោយការចាត់ទេវតាមករំដោះពួកគេ ព្រះគ្រិស្តបានប្រទាននិមិត្តរូបនៃសេចក្តីស្រឡាញ់និងការធានាអះអាងនៃព្រះវត្តមានរបស់ទ្រង់ដល់ពួកគេ។ ឥឡូវនេះគឺជាចំណែកដែលពួកគេត្រូវរងទុក្ខដោយសារព្រះដែលពួកគេបានប្រកាសផ្សាយដំណឹងល្អរបស់ទ្រង់។

នៅក្នុងរឿងពួកហោរានិងពួកសាវ័ក មានគំរូដ៏ថ្លៃថ្នូរជាច្រើនស្តីអំពីភក្តីភាពចំពោះព្រះនេះ។ ស្មរបន្ទាល់របស់ព្រះគ្រិស្តបានរងទ្រាំនូវការដាក់គុកច្រវាក់ ទារុណកម្ម និងសេចក្តីស្លាប់ ជាជាងបំពាននឹងបញ្ញត្តិរបស់ព្រះ។ កំណត់ត្រាដែលបន្សល់ដោយលោកពេត្រុសនិងលោកយ៉ូហាន មានភាពអង់អាចក្លាហានដូចជាការចែកចាយដំណឹងល្អនៅកន្លែងផ្សេងៗទៀតដែរ។ កាលពួកគេបានឈរនៅចំពោះមុខមនុស្សដែលហាក់ដូចជាបម្រុង

នឹងបំផ្លាញពួកគេបង់ជាលើកទីពីរ គេគ្មានការភ័យខ្លាចនៅក្នុងពាក្យសម្ដីនិងអាកប្បកិរិយារបស់ពួកគេឡើយ។ ហើយនៅពេលសម្ដេចសង្ឃបានសួរថា «តើយើងមិនបានហាមផ្ដាច់ មិនឲ្យឯងរាល់គ្នាបង្រៀនពីឈ្មោះនោះទៀតទេឬអី តែមើលឯងរាល់គ្នាបានបង្រៀនសេចក្ដីនោះ នៅពេញក្រុងយេរូសាឡិមទាំងមូលវិញ ព្រមទាំងគិតទម្លាក់ទោសពីឈាមមនុស្សនោះមកលើយើងផង»។ លោកពេត្រុសបានឆ្លើយតបថា «ត្រូវតែស្ដាប់បង្គាប់របស់ព្រះជាជាងមនុស្ស»។ គឺទេវតាបានមកពីឋានសួគ៌ដែលបានរំដោះពួកគេចេញពីគុក ហើយបង្គាប់ឲ្យពួកគេបង្រៀននៅក្នុងព្រះវិហារ។ នៅក្នុងការធ្វើតាមការណែនាំរបស់ទេវតា ពួកគេកំពុងស្ដាប់បង្គាប់តាមការត្រាស់បង្គាប់របស់ព្រះ ហើយទង្វើនេះ ពួកគេត្រូវតែបន្តធ្វើទោះបីមានរឿងអ្វីកើតឡើងដល់ពួកគេក៏ដោយ។

ពេលនោះព្រះវិញ្ញាណនៃការលើកទឹកចិត្តបានយាងមកសណ្ឋិតលើពួកសាវ័ក ចុងចោទបានក្លាយទៅជាដើមចោទ ដោយចោទប្រកាន់ពីបទធ្វើគុតព្រះ ទៅលើពួកអ្នកដែលចងក្រងជាក្រុមប្រឹក្សានេះ លោកពេត្រុសបានប្រកាសថា «រីឯព្រះនៃពួកអយ្យកោយើងរាល់គ្នា ទ្រង់បានប្រោសព្រះយេស៊ូវដែលលោករាល់គ្នាបានសម្លាប់ដោយព្យួរនៅជាប់លើឈើឲ្យទ្រង់ មានព្រះជន្មរស់ឡើងវិញ ហើយព្រះបានតម្កើងទ្រង់ឡើង ដោយសារព្រះហស្តស្តាំ ឲ្យធ្វើជាព្រះអម្ចាស់ នឹងជាព្រះអង្គសង្គ្រោះ ដើម្បីនឹងប្រោសប្រទានការប្រែចិត្តដល់សាសន៍អ៊ីស្រាអែល ប្រយោជន៍ឲ្យបានរួចពីបាប យើងខ្ញុំនេះ ព្រមទាំងព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះបានប្រទានដល់អស់អ្នកដែលស្ដាប់បង្គាប់ទ្រង់ជាស្មរបន្ទាល់ពីការទាំងនោះ»។

**<u>ពុធ-២២ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ១២**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ដូច្នេះ ខ្ញុំទូន្មានអ្នករាល់គ្នាថា ចូរដកខ្លួនពីមនុស្សទាំងនេះចេញ កុំឲ្យធ្វើអ្វីដល់គេឡើយ ដ្បិតបើសិនជាគំនិតគេ ឬការគេធ្វើនេះកើត*

*ឡើងពីមនុស្ស នោះនឹងត្រូវវិនាសទៅជាមិនខាន តែបើកើតមកពីព្រះវិញ នោះអ្នករាល់គ្នាពុំអាចនឹងធ្វើឲ្យវិនាសបានទេ ក្រែងអ្នករាល់គ្នាជាប់ទោសជាពួកអ្នកតយុទ្ធនឹងព្រះដែរ។ កិច្ចការ ៥:៣៨-៣៩*

ពួកយូដាបានខឹងនឹងសម្ដីនេះជាខ្លាំង ទើបពួកគេបានសម្រេចចិត្តថា យកច្បាប់មកដាក់នៅក្នុងកណ្ដាប់ដៃរបស់ពួកគេ ហើយកាត់ទោសប្រហារជីវិតពួកអ្នកជាប់គុកទាំងនេះ ដោយមិនចាំបាច់មានការជំនុំជម្រះឬមានការអនុញ្ញាតពីរដ្ឋអំណាចរ៉ូមឡើយ។ ដោយមានទោសជាមួយនឹងព្រះលោហិតព្រះគ្រិស្តរួចទៅហើយ ឥឡូវនេះពួកគេបានលូកដៃឲ្យប្រឡាក់ឈាមពួកសាវ័ករបស់ទ្រង់ថែមទៀត ។

ប៉ុន្ដែ នៅក្នុងចំណោមក្រុមប្រឹក្សានេះមានបុរសម្នាក់ដែលបានស្គាល់ព្រះសូរសៀងរបស់ព្រះ ដែលពួកសាវ័កបាននិយាយ។ បុរសនេះគឺលោកកាម៉ាលាល ជាអ្នកផារិស៊ីដែលមានមនុស្សគោរពកោតខ្លាច និងជាមនុស្សដែលមានចំណេះដឹង និងមានមុខតំណែងខ្ពង់ខ្ពស់ផង។ គំនិតដ៏វាងវៃរបស់លោកបានមើលឃើញថាជំហាននៃអំពើហិង្សាដោយពួកសង្ឃនឹងដឹកនាំទៅរកផលវិបាកដ៏អាក្រក់។ មុននឹងបង្ហាញយោបល់របស់លោក លោកបានសុំឲ្យនាំពួកអ្នកទោសចេញទៅក្រៅសិន។ លោកបានដឹងយ៉ាងច្បាស់អំពីបញ្ហាដែលលោកត្រូវដោះស្រាយ លោកបានជ្រាបថាការធ្វើគុតព្រះគ្រិស្តមិនមានប្រយោជន៍អ្វីដល់ការអនុវត្តន៍គោលបំណងរបស់ពួកគេឡើយ។

បន្ទាប់មក លោកបានមានប្រសាសន៍ដោយការត្រិះរិះពិចារណា និងដោយភាពស្ងៀមស្ងាត់ថា «ពួកសាសន៍អ៊ីស្រាអែលអើយ ចូរប្រយ័ត្នខ្លួនពីដំណើរមនុស្សទាំងនេះ ដែលអ្នករាល់គ្នាគិតធ្វើអ្វីដល់គេ ដ្បិតពីដើមមានឈ្មោះ ធើដាស លើកខ្លួនឡើងថាជាអ្វីៗ ក៏មានមនុស្សចំនួនជាងបួនរយនាក់បានចូលពួកវា តែវាត្រូវគេសម្លាប់ទៅ ហើយពួកអ្នកទាំងប៉ុន្មាន ដែលចុះចូលចំពោះវា ក៏ត្រូវខ្ចាត់ខ្ចាយសូន្យអស់ទៅដែរ ក្រោយនោះមកនៅវេលាធ្វើបញ្ជីកត់ត្រារាស្ត្រ នោះមានឈ្មោះយូដាស ជាអ្នកស្រុកកាលីឡេទៀត

បានលើកខ្លួនឡើង បញ្ចុះបញ្ចូលមនុស្សជាច្រើនឲ្យទៅតាមខ្លួន វាក៏វិនាសបាត់ទៅដែរ ហើយពួកអ្នកដែលចុះចូលតាម ក៏ត្រូវខ្ចាត់ខ្ចាយទាំងអស់គ្នាទៅដូច្នេះ ខ្ញុំទូន្មានអ្នករាល់គ្នាថា ចូរដកខ្លួនពីមនុស្សទាំងនេះចេញកុំឲ្យធ្វើអ្វីដល់គេឡើយ ដ្បិតបើសិនជាគំនិតគេ ឬការគេធ្វើនេះកើតឡើងពីមនុស្ស នោះនឹងត្រូវវិនាសទៅជាមិនខាន តែបើកើតមកពីព្រះវិញ នោះអ្នករាល់គ្នាពុំអាចនឹងធ្វើឲ្យវិនាសបានទេ ក្រែងអ្នករាល់គ្នាជាប់ទោសជាពួកអ្នកតយុទ្ធនឹងព្រះដែរ»។

ពួកសង្ឃបានយល់ឃើញថានេះគឺជាគំនិតសមហេតុផល ហើយក៏បានឯកភាពជាមួយនឹងលោកកាម៉ាលាលទាំងបង្ខំចិត្ត។ ប៉ុន្តែ ការប្រកាន់ ពូជសាសន៍និងសម្អប់របស់ពួកគេមិនងាយលុបបំបាត់បានឡើយ។ បន្ទាប់ពីបានវាយពួកសាវ័ក និងការថ្កោលទោសប្រហារជីវិតដល់ពួកសាវ័ក ប្រសិនបើពួកគេមិនព្រមឈប់អធិប្បាយនូវព្រះនាមព្រះយេស៊ូវតទៅទៀត រួចមកពួកគេក៏បានដោះលែងពួកសាវ័កទាំងស្នាក់ស្នើរ។ «ពួកសាវ័កក៏ចេញពីពួកក្រុមជំនុំទៅ ដោយអរសប្បាយ ពីព្រោះព្រះបានរាប់ជាអ្នកគួរនឹងទ្រាំសេចក្តីដំនៀល ដោយព្រោះព្រះនាមទ្រង់ ហើយអ្នកទាំងនោះចេះតែបង្រៀន ព្រមទាំងប្រាប់ដំណឹងល្អពីព្រះយេស៊ូវគ្រិស្ត»។

នៅមុនការជាប់ឆ្កាងរបស់ព្រះអង្គបន្តិច ព្រះគ្រិស្តបានបន្សល់ទុកនូវសេចក្តីសុខសាន្ត ជាកេរ្តិ៍មរតកដល់ពួកសាវ័ករបស់ទ្រង់។ ព្រះអង្គបានមានបន្ទូលថា «ខ្ញុំទុកសេចក្តីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឲ្យសេចក្តីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា ហើយដែលខ្ញុំឲ្យ នោះមិនមែនដូចជាលោកិយឲ្យទេ កុំឲ្យចិត្តអ្នករាល់គ្នាថប់បារម្ភ ឬភ័យឡើយ» (យ៉ូហាន ១៤:២៧)។ សេចក្តីសុខសាន្តនេះ មិនមែនជាសេចក្តីសុខសាន្តដែលកើតឡើងដោយសារការសម្របតាមលោកិយទេ។ ព្រះគ្រិស្តមិនដែលទិញសេចក្តីសុខសាន្តដោយការសម្របសម្រួលជាមួយនឹងអារក្សទេ។ សេចក្តីសុខសាន្តដែលព្រះគ្រិស្តបានទុកជាកេរ្តិ៍មរតកដល់ពួកសាវ័ក គឺជាសេចក្តីសុខសាន្តនៅក្នុងចិត្ត មិន

មែនជាសេចក្តីសុខសាន្តតែខាងក្រៅនោះទេ និងជាសេចក្តីសុខសាន្តដែលនៅជាមួយនឹងស្មារបន្ទាល់របស់ទ្រង់ជារៀងរហូត តាមរយៈសេចក្តីវេទនា និងរឿងរ៉ាវនៃវិវាទទាំងឡាយ។

**ព្រហស្បតិ៍-២៣ កក្កដា អំណានព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ១៣**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ពួកអ្នកដែលទុកចិត្តនឹងព្រះយេហូវ៉ា គេដូចជាភ្នំស៊ីយ៉ូន ដែលនឹងរង្គើមិនបាន គឺបានជាប់នៅជាដរាប។ ទំនុកតម្កើង ១២៥:១*

ព្រះគ្រិស្តបានមានបន្ទូលដោយផ្ទាល់ថា «កុំឲ្យស្មានថា ខ្ញុំមកនឹងតាំងឲ្យមានសេចក្តីមេត្រីនៅផែនដីឡើយ ខ្ញុំមិនមែនមកដើម្បីតាំងឲ្យមានសេចក្តីមេត្រីទេ គឺឲ្យមានដាវវិញ» (ម៉ាថាយ ១០:៣៤)។ ជាព្រះអម្ចាស់ នៃសេចក្តីសុខសាន្ត ព្រះអង្គក៏ជាកត្តានៃការបែកបាក់ផងដែរ ព្រះអង្គដែលបានយាងមកដើម្បីនឹងប្រកាសអំពីសេចក្តីស្រឡាញ់របស់ព្រះ និងដើម្បីបង្កើត សេចក្តីសង្ឃឹមនិងអំណរនៅក្នុងចិត្តកូនៗរបស់មនុស្ស ក៏បានបើកឲ្យមានទំនាស់ដែលនឹងឆេះយ៉ាងសន្ធោសន្ធៅ និងបំផុសឲ្យមានតណ្ហាយ៉ាងខ្លាំងនៅក្នុងចិត្តរបស់មនុស្សផងដែរ។ ហើយព្រះព្រមានដល់សិស្សរបស់ទ្រង់ថា «នៅលោកិយនេះ នោះអ្នករាល់គ្នាមានសេចក្តីវេទនាមែន» «គេនឹងចាប់អ្នករាល់គ្នាធ្វើទុក្ខ បញ្ជូនទៅសាលាប្រជុំ ហើយដាក់គុក ព្រមទាំងនាំអ្នករាល់គ្នាទៅចំពោះស្តេច និងចៅហ្វាយខេត្ត ដោយព្រោះឈ្មោះខ្ញុំផង»។ «ប៉ុន្តែ ទោះទាំងឪពុកម្តាយ បងប្អូន ញាតិសន្តាន ហើយមិត្រសំឡាញ់ក៏នឹងបញ្ជូនអ្នករាល់គ្នា ហើយនិងសម្លាប់អ្នករាល់គ្នាខ្លះដែរ» (យ៉ូហាន ១៦:៣៣ និង លូកា ២១:១២, ១៦)។

បទទំនាយនេះបានសម្រេចនៅក្នុងលក្ខណៈគួរឲ្យកត់សម្គាល់។ ការប្រមាថមើលងាយ ការស្តីបន្ទោស អំពើឃោរឃៅ ដែលសាតាំងបានញុះញង់ចិត្តមនុស្សឲ្យបង្កឡើង បានកើតឡើងដល់ពួកសិស្សរបស់ព្រះយេស៊ូវ។ ហើយការនេះនឹងត្រូវបានសម្រេចម្តងទៀតនៅក្នុងលក្ខណៈគួរឲ្យកត់សម្គាល់

ដល់ចិត្តនៃសាច់ឈាមដែលនៅតែជាសត្រូវដល់ក្រឹត្យវិន័យរបស់ព្រះនិងអ្នកដែលមិនព្រមស្តាប់តាមការត្រាស់បង្គាប់នៃក្រឹត្យវិន័យនោះ។ សព្វថ្ងៃនេះ ពិភពលោកលែងសម្របគ្នាទៅនឹងគោលការណ៍របស់ព្រះគ្រិស្ត ខ្លាំងជាងសម័យពួកសាវ័កទៅទៀត។ សម្ពប់ដែលបង្កឲ្យមានសំឡេងស្រែកឡើងថា «ឆ្កាងវាទៅ ឆ្កាងវាទៅ!» សម្អប់ដដែលបានដឹកនាំឲ្យមានការបៀតបៀនដល់ពួកសាវ័ក នៅតែធ្វើការនៅក្នុងចិត្តកូនៗដែលមិនស្តាប់បង្គាប់ព្រះដដែល ។ វិញ្ញាណដដែលបានដាក់ទោសដល់បុរសនារីនៅយុគសម័យដ៏ខ្មៅងងឹត ឲ្យជាប់គុក ឲ្យត្រូវនិរទេស និងត្រូវស្លាប់ ដែលបង្កឲ្យមានការដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរដល់ការស៊ើបអង្កេតយ៉ាងម៉ឺងម៉ាត់ ដែលបានដាក់ផែនការនិងប្រហារជីវិតសន្តុបុគ្គលម៉ាសាក បាតូឡូមី និងដែលសម្លាប់ភ្លើងនៃស្មីតហ្វៀលកំពុងធ្វើការនៅក្នុងភ្នាក់ងារនៃការមួលបង្កាច់នៃចិត្តដែលមិនអាចកែប្រែបាន។ ប្រវត្តិសាស្ត្រនៃសេចក្តីពិតត្រូវបានកត់ត្រាពីទំនាស់រវាងការល្អនិងការអាក្រក់។ ការប្រកាសដំណឹងល្អត្រូវបានបន្តទៅមុខនៅលើពិភពលោក នៅចំពោះមុខការប្រឆាំង សេចក្តីវេទនា ការបាត់បង់ និងការឈឺចាប់ ។

តើអ្វីទៅដែលជាកម្លាំងដល់អ្នកដែលរងការឈឺចាប់ពីការបៀតបៀនដោយសារតែព្រះនាមរបស់ព្រះគ្រិស្ត កាលពីអតីតកាលនោះ? គឺការរួបរួមជាមួយព្រះ ការរួបរួមជាមួយព្រះវិញ្ញាណបរិសុទ្ធ និងការរួបរួមជាមួយនឹងព្រះគ្រិស្ត ។ ការស្តីបន្ទោស និងការបៀតបៀនបានបំបែកមនុស្សជាច្រើនចេញពីមិត្តភក្តិ ប៉ុន្តែ មិនអាចបំបែកពួកគេចេញពីសេចក្តីស្រឡាញ់របស់ព្រះគ្រិស្តបានឡើយ ។ មិនដែលមានអ្នកដែលត្រូវសេចក្តីល្បួងយ៉ាងធ្ងន់ធ្ងរបំផុតបានទទួលសេចក្តីស្រឡាញ់ពេញព្រះឫទ័យបំផុតពីព្រះអង្គសង្គ្រោះជាងពេលដែលគេកំពុងឈឺចាប់ដោយសារការស្តីបន្ទោសដោយសារសេចក្តីពិតនោះឡើយ។ ព្រះគ្រិស្តបានមានបន្ទូលថា «ខ្ញុំនឹងស្រឡាញ់អ្នកនោះដែរ ក៏នឹងសម្តែងខ្លួនឲ្យអ្នកនោះស្គាល់ផង» (យ៉ូហាន ១៤:២១) ។ នៅពេលដែលពួកអ្នកជឿឈរនៅមុខទីជំនុំជម្រះនៃតុលាការនៅផែនដី

ព្រះគ្រិស្តក៏ឈរនៅក្បែរពួកគេដែរ ។ នៅពេលដែលពួកគេជាប់នៅក្នុងជញ្ជាំងគុក ព្រះគ្រិស្តបង្ហាញអង្គទ្រង់ឲ្យគេឃើញ ហើយលើកទឹកចិត្តដល់គេដោយសេចក្តីស្រឡាញ់របស់ទ្រង់ ។ នៅពេលដែលគេរងគ្រោះដល់ស្លាប់ដោយសារព្រះគ្រិស្ត ព្រះអង្គសង្គ្រោះបានមានបន្ទូលទៅគេថា ពួកគេអាចសម្លាប់បានតែរូបកាយប៉ុណ្ណោះ ប៉ុន្តែ ពួកគេមិនអាចធ្វើឲ្យព្រលឹងឈឺចាប់បានឡើយ ។ «ពួកអ្នកដែលទុកចិត្តនឹងព្រះយេហូវ៉ា គេដូចជាភ្នំស៊ីយ៉ូនដែលនឹងរង្គើមិនបាន គឺបានជាប់នៅជាដរាប មានភ្នំនៅព័ទ្ធជុំវិញក្រុងយេរូសាឡិមយ៉ាងណា នោះព្រះយេហូវ៉ាក៏គង់នៅជុំវិញរាស្ត្រទ្រង់យ៉ាងនោះដែរ ចាប់តាំងពីឥឡូវនេះ ដរាបដល់អស់កល្បជានិច្ច ពីព្រោះដំបងនៃសេចក្តីអាក្រក់ នឹងមិនគ្របលើចំណែកនៃមនុស្សសុចរិតឡើយ ប្រយោជន៍កុំឲ្យមនុស្សសុចរិតលូកដៃទៅចាប់សេចក្តីទុច្ចរិតឲ្យសោះ»។

«ទ្រង់នឹងលោះជីវិតគេ ឲ្យរួចពីការសង្កត់សង្កិន និងការច្រឡោតឯឈាមគេនឹងបានវិសេសនៅព្រះនេត្រទ្រង់ដែរ» (ទំនុកតម្កើង ១២៥:១-៣ និង ៧២:១៤) ។

«ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់នឹងការពារគេ ... ព្រះយេហូវ៉ាជាព្រះនៃគេ ទ្រង់នឹងជួយសង្គ្រោះគេ ទុកដូចជាហ្វូងចៀម ជារាស្ត្ររបស់ទ្រង់ ដ្បិតគេនឹងបានដូចជាត្បូងដាំនៅមកុដដែលភ្លឺផ្លេក នៅលើស្រុករបស់ទ្រង់» (សាការី ៩:១៥, ១៦) ។

ជំពូកទី
៩

# អ្នកជំនួយការ(បុរស)ប្រាំពីរនាក់

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ៦:១-៧ ។*

<u>សុក្រ-២៤ កក្កដា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ១៤**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *នៅគ្រានោះ កាលពួកសិស្សបានចំរើនច្រើនឡើង នោះពួកហេលេនចាប់តាំងរទូរទាំទាស់នឹងពួកហេព្រើរ អំពីការចែកចាយរាល់តែថ្ងៃ ដោយព្រោះគេតែងធ្វេសការនឹងស្រីមេម៉ាយរបស់ពួកហេលេននោះ។ កិច្ចការ ៦:១*

«នៅគ្រានោះ ចំនួនសិស្សចេះតែកើនឡើងជាលំដាប់។ ជនជាតិយូដាដែលនិយាយភាសាក្រិក នាំគ្នារអ៊ូរទាំទាស់នឹងជនជាតិយូដាដែលនិយាយភាសាហេព្រើរថា នៅពេលចែកម្ហូបអាហារប្រចាំថ្ងៃ ពួកហេព្រើរមិនសូវយកចិត្តទុកដាក់នឹងស្រ្តីមេម៉ាយខាងពួកខ្លួនទេ» (គម្ពីរភាសាខ្មែរបច្ចុប្បន្ន) ។

ពួកជំនុំដំបូងត្រូវបានបង្កើតឡើងដោយមនុស្សជាច្រើនស្រទាប់វណ្ណៈដែលមកពីជាតិសាសន៍ជាច្រើន។ នៅពេលនៃការចាក់បង្ហូរព្រះវិញ្ញាណនៅថ្ងៃប៉ង់តាកូស «មានពួកសាសន៍យូដា ជាអ្នកកោតខ្លាចដល់ព្រះ ដែលមកពីគ្រប់នគរនៅក្រោមមេឃ» (កិច្ចការ ២:៥) នៅក្នុងចំណោមសាសន៍ហេព្រើរដែលមានជំនឿ ដែលបានមកប្រជុំគ្នានៅទីក្រុងយេរូសាឡិម មានប្រជាជនយូដាខ្លះដែលគេស្គាល់ជាទូទៅថាជាសាសន៍ហេលេន (ជាជនជាតិយូដាដែលនិយាយភាសាក្រិក) ដែលនៅចន្លោះពួកគេនិងសាសន៍យូដាកាត់ប៉ាលេស្ទីនមានមនុស្សដែលមិនជឿនិងរហូតដល់អ្នកប្រឆាំងជាយូរយារមកហើយ ។

ចិត្តរបស់អ្នកដែលបានកែប្រែនៅក្រោមកិច្ចការរបស់ពួកសាវ័កត្រូវ

បានបន្ទន់ ហើយរួបរួមគ្នាដោយសេចក្ដីស្រឡាញ់បែបគ្រិស្តបរិស័ទ។ ទោះបីជាមានការប្រកាន់ពូជសាសន៍នៅពេលកន្លងមកក៏ដោយ ក៏មនុស្សទាំងអស់បានរួបរួមគ្នាជាធ្លុងមួយដែរ។ សាតាំងបានដឹងថាដរាបណាការរួបរួមគ្នានៅតែបន្ដកើតមានឡើង វានឹងមិនមានអំណាចដើម្បីគ្រប់គ្រងការជឿនលឿននៃដំណឹងល្អបានទេ ហើយវាក៏ស្វះស្វែងរកកេងចំណេញពីទម្លាប់នៃគំនិតចាស់ពីអតីតកាល ដោយសង្ឃឹមថាធ្វើដូច្នោះវានឹងអាចនាំនូវការបែកបាក់គ្នាចូលមកក្នុងពួកជំនុំបាន ។

ដូច្នេះ នៅពេលដែលពួកសិស្សកាន់តែចម្រើនកើនឡើង សត្រូវមានជោគជ័យក្នុងការបំផុសមន្ទិលសង្ស័យនៅក្នុងចំណោមអ្នកខ្លះ ដែលធ្លាប់មានទម្លាប់សម្លឹងមើលទៅបងប្អូនរួមជំនឿដោយការច្រណែន និងស្វែងរកចាប់កំហុសពួកអ្នកដឹកនាំខាងព្រលឹងវិញ្ញាណ ហើយដូច្នេះ «ពួកហេលេនចាប់តាំងរទូរទាំទាស់នឹងពួកហេព្រើរ»។ មូលហេតុនៃទំនាស់នេះកើតឡើងដោយការធ្វេសប្រហែសក្នុងការចែកអាហារប្រចាំថ្ងៃដល់ស្ដ្រីមេម៉ាយ ដែលនិយាយភាសាក្រិក។ មានការមិនស្មើភាពដែលផ្ទុយពីវិញ្ញាណនៃដំណឹងល្អ ហើយសាតាំងមានជោគជ័យក្នុងការបំផុសមន្ទិលសង្ស័យ។ ឥឡូវនេះ ដំណោះស្រាយជាបន្ទាន់ត្រូវតែបង្កើតឡើងដើម្បីដកយកចេញនូវឱកាសនៃការមិនពេញចិត្តទាំងប៉ុន្មាន ក្រែងសត្រូវមានជោគជ័យក្នុងការខំប្រឹងប្រែងរបស់វាដើម្បីនាំឲ្យមានការបែកបាក់នៅក្នុងចំណោមពួកអ្នកមានជំនឿ។

ពួកសិស្សរបស់ព្រះយេស៊ូវបានជួបប្រទះនឹងវិបត្ដិនៅក្នុងបទពិសោធន៍របស់ពួកគេ។ នៅក្រោមការដឹកនាំដ៏វាងវៃរបស់ពួកសាវ័ក ដែលបានធ្វើការជាមួយនឹងព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធយ៉ាងស្អិតរមួត កិច្ចការដែលបានប្ដេជ្ញាចិត្តចំពោះដំណឹងល្អកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស។ ពួកជំនុំកាន់តែរីកធំឡើងជាលំដាប់ ហើយការរីកចម្រើនខាងចំនួននេះ ក៏បាននាំមកនូវបន្ទុកកាន់តែធ្ងន់ដល់អ្នកទទួលខុសត្រូវផងដែរ។ មិនមានមនុស្សណាម្នាក់ឬក្រុមណាដែលអាចបន្ដទទួលបន្ទុកនេះតែម្នាក់ឯងបានទេ បើគ្មានគ្រោះថ្នាក់

នៃការរីកចម្រើននៃពួកជំនុំនាពេលអនាគតទេនោះ ។
មានការចាំបាច់សម្រាប់ការចែកចាយការទទួលខុសត្រូវដែលត្រូវបានកើតឡើងយ៉ាងស្មោះត្រង់ដោយមនុស្សមួយចំនួន នៅក្នុងអំឡុងពេលនៃពួកជំនុំដំបូង ។ ឥឡូវនេះ ពួកសាវ័កត្រូវតែបោះជំហានដ៏សំខាន់មួយ ក្នុងការធ្វើឲ្យរបៀបរៀបរយនៅក្នុងពួកជំនុំមានភាពគ្រប់លក្ខណ៍ ដោយចែករំលែកបន្ទុកដែលពួកគេទទួលខុសត្រូវទៅឲ្យអ្នកដទៃ។

<u>សៅរ៍-២៥ កក្កដា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ១៥**

**ខព្រះគម្ពីរប្រចាំសប្ដាហ៍:** *ដូច្នេះ បងប្អូនអើយ ចូររើសយក៧នាក់ក្នុងពួកអ្នករាល់គ្នា ជាអ្នកមានឈ្មោះល្អ ពេញជាព្រះវិញ្ញាណបរិសុទ្ធ និងប្រាជ្ញា នោះយើងខ្ញុំនឹងតាំងគេ ឲ្យត្រួតត្រាលើការងារនេះ។ កិច្ចការ ៦:៣*

ពួកសាវ័កដែលបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ បានកោះប្រជុំពួកអ្នកមានជំនឿទាំងអស់ ដើម្បីរៀបចំផែនការធ្វើឲ្យការចាត់ចែងកម្លាំងធ្វើការនៅក្នុងពួកជំនុំឲ្យកាន់តែប្រសើរឡើង។ ពេលវេលាបានមកដល់ពួកសាវ័កកបានអង្គុយចុះ នៅពេលដែលអ្នកដឹកនាំខាងព្រលឹងវិញ្ញាណដែលមើលថែរក្សាពួកជំនុំគួរតែត្រូវបានដកឃ្លាចេញពីកិច្ចការនៃការចែកចាយចំណីអាហារដល់អ្នកក្រីក្រ និងបន្ទុកស្រដៀងគ្នានេះ ដើម្បីឲ្យពួកគេមានពេលទំនេរសម្រាប់បោះជំហានទៅមុខក្នុងការអធិប្បាយដំណឹងល្អ។ ពួកគេនិយាយថា «ដូច្នេះ បងប្អូនអើយ ចូររើសយក៧នាក់ក្នុងពួកអ្នករាល់គ្នា ជាអ្នកមានឈ្មោះល្អ ពេញជាព្រះវិញ្ញាណបរិសុទ្ធ និងប្រាជ្ញា នោះយើងខ្ញុំនឹងតាំងគេ ឲ្យត្រួតត្រាលើការងារនេះ ឯយើងខ្ញុំ នឹងខំព្យាយាមក្នុងសេចក្ដីអធិដ្ឋាន និងការផ្សាយព្រះបន្ទូលវិញ»។ ដំបូន្មាននេះត្រូវបានអនុវត្ត ហើយដោយការអធិដ្ឋានដាក់ដៃលើ គេបានញែកមនុស្សប្រាំពីរនាក់ចេញជាពិសេសឲ្យបំពេញភារកិច្ចជាអ្នកជំនួយការ។

ការចាត់តាំងមនុស្សប្រាំពីរនាក់ឲ្យទទួលបន្ទុកកិច្ចការពិសេសនេះ បាន

បង្ហាញពីព្រះពរដ៏ធំដល់ពួកជំនុំ។ ពួកមន្ត្រីទាំងនេះផ្តល់ការយកចិត្តទុកដាក់យ៉ាងប្រុងប្រយ័ត្ន ក្នុងការចែកចាយតម្រូវការផ្ទាល់ខ្លួន ព្រមទាំងចំណាប់អារម្មណ៍នៃថវិកាទូទៅសម្រាប់ពួកជំនុំផងដែរ ហើយដោយការចាត់ចែងយ៉ាងប្រុងប្រយ័ត្ន និងដោយគំរូនៃព្រះរបស់ពួកគេ ពួកគេបានក្លាយជាជំនួយដ៏សំខាន់ដល់មន្ត្រីដទៃទៀត ក្នុងការរួបរួមគ្នាក្នុងកិច្ចការផ្សេងៗនៃពួកជំនុំឲ្យក្លាយជាពួកជំនុំរួមមួយ ។

ជំហាននេះគឺជារបៀបរៀបរយរបស់ព្រះ ដែលត្រូវបានបង្ហាញនៅក្នុងលទ្ធផលជាបន្ទាន់សម្រាប់ការល្អដែលគេមើលឃើញ។ «ព្រះបន្ទូលក៏បានផ្សាយទៅកាន់តែច្រើនឡើង ហើយចំនួនពួកសិស្សបានចម្រើនឡើងក្រៃលែង នៅក្រុងយេរូសាឡិម ឯពួកសង្ឃក៏មានសន្ធឹកចុះចូលជឿដែរ»។ ការប្រមូលមនុស្សនេះ កើតឡើងដោយសារសេរីភាពដ៏ទូលំទូលាយដែលពួកសាវ័កបានទទួល និងដោយសារចិត្តពុះកញ្ជ្រោលនិងអំណាចដែលបង្ហាញដោយអ្នកជំនួយការបុរសទាំងប្រាំពីរនាក់នោះ ។ ការដែលបងប្អូនទាំងប្រាំពីរនាក់ត្រូវបានញែកចេញសម្រាប់កិច្ចការដ៏ពិសេសនៃការថែរក្សាសេចក្តីត្រូវការរបស់អ្នកក្រីក្រនេះ ក៏មិនបានផាត់ពួកគេចេញពីការបង្រៀនខាងសេចក្តីជំនឿដែរ ។ ផ្ទុយទៅវិញ ពួកគេមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការបង្ហាត់បង្រៀនដល់អ្នកដទៃអំពីសេចក្តីពិត ហើយពួកគេបានចូលរួមនៅក្នុងកិច្ចការដោយភាពស្មោះត្រង់ និងប្រកបដោយជោគជ័យយ៉ាងធំធេង ។

ព្រះបានប្រទានកិច្ចការនៃការរីកចម្រើនជាបន្ត ដល់ពួកជំនុំដំបូង គឺការបង្កើតមជ្ឈមណ្ឌលនៃពន្លឺនិងព្រះពរ អ្វីក៏ដោយ មនុស្សស្មោះត្រង់ទាំងនោះសុខចិត្តលះបង់ដើម្បីបម្រើដល់កិច្ចការរបស់ព្រះគ្រិស្ត។ ការប្រកាសដំណឹងល្អត្រូវតែធ្វើជាសកល ហើយអ្នកនាំសារនៃឈើឆ្កាងមិនអាចសង្ឃឹមថានឹងបំពេញបេសកកម្មដ៏សំខាន់របស់ពួកគេនេះបាន ដោយគ្មានការរួបរួមនៅក្នុងចំណងឯកភាពនៃគ្រិស្តបរិស័ទឡើយ ហើយធ្វើដូច្នេះ ពួកគេបានបង្ហាញដល់ពិភពលោកថាពួកគេបានរួបរួមគ្នាតែមួយ ជាមួយនឹងព្រះគ្រិស្តនិងជា

មួយនឹងព្រះ។ តើអ្នកដឹកនាំនៃព្រះរបស់ពួកគេមិនបានអធិដ្ឋានទៅព្រះវរបិតា សុំឲ្យ «ពួកអ្នកដែលទ្រង់បានប្រទានមកទូលបង្គំ នោះសូមទ្រង់រក្សាគេដោយព្រះនាមទ្រង់ផង ដើម្បីឲ្យគេបានរួមគ្នាតែមួយ ដូចជាយើងដែរ» ទេឬអី? ហើយតើព្រះមិនបានប្រកាសពីពួកសាវ័ករបស់ទ្រង់ថា «ហើយលោកិយបានស្អប់គេ ពីព្រោះគេមិនមែនជារបស់លោកិយទេ ដូចជាទូលបង្គំក៏មិនមែនជារបស់លោកិយដែរ» ទេឬ? តើព្រះអង្គមិនបានអង្វរដល់ព្រះវរបិតា «ដើម្បីឲ្យគេបានគ្រប់លក្ខណ៍ឡើង" "ប្រយោជន៍ឲ្យលោកិយបានជឿថា ទ្រង់ចាត់ឲ្យទូលបង្គំមកពិត» ទេឬអី? (យ៉ូហាន ១៧:១១, ១៤, ២៣, ២១) ជីវិតខាងវិញ្ញាណនិងអំណាចរបស់ពួកគេពឹងផ្អែកទៅលើទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងព្រះដែលបានត្រាស់បង្គាប់ឲ្យពួកគេប្រកាសផ្សាយដំណឹងល្អនោះ ។

<u>អាទិត្យ-២៦ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ១៦

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ព្រះបន្ទូលក៏បានផ្សាយទៅកាន់តែច្រើនឡើង ហើយចំនួនពួកសិស្ស បានចំរើនឡើងក្រៃលែង នៅក្រុងយេរូសាឡិម ឯពួកសង្ឃ ក៏មានសន្ធឹកចុះចូលជឿដែរ។ កិច្ចការ ៦:៧*

មានតែការរួបរួមជាមួយនឹងព្រះគ្រិស្តប៉ុណ្ណោះទេ ទើបពួកសាវ័កមានសង្ឃឹមថានឹងបានរួបរួមជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធ និងសហការជាមួយនឹងទេវតានៃឋានសួគ៌។ ជាមួយនឹងភ្នាក់ងាររបស់ព្រះទាំងពីរនេះ ពួកគេបានបង្ហាញនៅចំពោះពិភពលោកនូវការរួបរួមគ្នានៅចំពោះមុខ និងមានជោគជ័យទៅលើទំនាស់ដែលពួកគេត្រូវបានគេបង្ខំឲ្យតយុទ្ធឥតឈប់ឈរ ប្រឆាំងនឹងអំណាចនៃសេចក្តីងងឹត ។ នៅពេលដែលពួកគេបានបន្តធ្វើការដោយការរួបរួមគ្នា ពួកអ្នកនាំសារនៃឋានសួគ៌បានយាងនាំមុខពួកគេ ដើម្បីរៀបចំផ្លូវរៀបចំចិត្តមនុស្សសម្រាប់ការទទួលសេចក្តីពិត ហើយពួកគេបានបញ្ចុះបញ្ចូលមនុស្សជាច្រើនឲ្យមកឯព្រះគ្រិស្ត។ នៅពេលដែលពួកគេនៅតែរួបរួមគ្នា ពួក

ជំនុំនៅតែបោះជំហានទៅមុខជានិច្ច «ស្រស់ល្អដូចជាព្រះចន្ទ ហើយភ្លឺត្រចះដូចជាព្រះអាទិត្យ ក៏គួរស្ញែងខ្លាចដូចជាពលទ័ព មានទាំងទង់ជ័យផង»។ បទចម្រៀង (សាឡូម៉ូន ៦:១០) ។ គ្មានអ្វីអាចទប់ទល់នឹងការជឿនលឿនឆ្ពោះទៅមុខរបស់ពួកជំនុំបានឡើយ។ ពួកជំនុំបានបោះជំហានទៅមុខពីជោគជ័យមួយទៅជោគជ័យមួយ ដោយសម្រេចបានយ៉ាងត្រចះត្រចង់នូវបេសកកម្ម នៃការប្រកាសផ្សាយដំណឹងល្អរបស់ព្រះដល់លោកិយ ។

រចនាសម្ព័ន្ធនៃពួកជំនុំនៅតាមកន្លែងផ្សេងៗទៀត ដែលពួកអ្នកនាំសារនៃសេចក្តីពិតបាននាំមនុស្សឲ្យកែប្រែចិត្តមកឯដំណឹងល្អត្រូវតែបម្រើតាមគំរូរបស់រចនាសម្ព័ន្ធនៃពួកជំនុំនៅទីក្រុងយេរូសាឡិម។ អស់អ្នកដែលបានទទួលខុសត្រូវការថែរក្សាដល់ពួកជំនុំជាទូទៅ មិនត្រូវជិះជាន់ដល់មរតករបស់ព្រះឡើយ។ ប៉ុន្តែ ក្នុងនាមជាអ្នកគង្វាលដ៏ឆ្លាតវាងវៃ ពួកគេត្រូវតែ «ឃ្វាលហ្វូងចៀមរបស់ព្រះ ... គឺដើម្បីឲ្យបានធ្វើជាគំរូដល់ហ្វូងចៀមវិញប៉ុណ្ណោះ» (ពេត្រុសទី១ ៥:២, ៣) ហើយអ្នកជំនួយការត្រូវតែ «ជាអ្នកមានឈ្មោះល្អពេញជាព្រះវិញ្ញាណបរិសុទ្ធ និងប្រាជ្ញា»។ ដូច្នេះ ពួកគេនឹងមានឥទ្ធិពលនៃការរួបរួមគ្នាជាមួយហ្វូងចៀមទាំងមូល ។

ចំណេរក្រោយមកទៀត នៅក្នុងប្រវត្តិសាស្ត្រនៃពួកជំនុះដំបូង ពេលដែលពួកអ្នកជឿនៅកន្លែងផ្សេងៗនៃពិភពលោកត្រូវបានរៀបចំជាពួកជំនុំ រចនាសម្ព័ន្ធនៃពួកជំនុំក៏កាន់តែមានភាពគ្រប់លក្ខណ៍ឡើង ដូច្នេះ របៀបរៀបរយនិងសកម្មភាពនៃការចុះសម្រុងគ្នានោះត្រូវបានគេថែរក្សា។ សមាជិករាល់រូបត្រូវបានណែនាំឲ្យប្រព្រឹត្តត្រឹមត្រូវទៅតាមផ្នែករៀងៗខ្លួន ។អ្នកខ្លះត្រូវបានព្រះវិញ្ញាណបរិសុទ្ធប្រទានអំណោយទានពិសេសៗ «មុនដំបូង គឺពួកសាវ័កទីពីរពួកគ្រូអធិប្បាយ ទីបីពួកគ្រូបង្រៀន រួចមកមានការឫទ្ធិបារមី មានអំណោយទានជាការប្រោសឲ្យជា ជាការជំនួយ ជាការគ្រប់គ្រង ហើយជាភាសាដទៃផង» (កូរិនថូសទី១ ១២:២៨)។ ប៉ុន្តែ អ្នកធ្វើការគ្រប់ស្រទាប់ទាំងអស់នេះត្រូវតែធ្វើការដោយឯកភាពគ្នា ។

«រីឯអំណោយទាន នោះមានផ្សេងៗពីគ្នា តែគឺជាព្រះវិញ្ញាណដដែលទេ ហើយក៏មានមុខងារផ្សេងៗពីគ្នា តែគឺជាព្រះអម្ចាស់ដដែលទេ ព្រមទាំងមានរបៀបធ្វើផ្សេងៗពីគ្នាទៀត តែគឺជាព្រះដដែលនោះឯង ដែលទ្រង់ធ្វើគ្រប់ទាំងអស់ ក្នុងមនុស្សទាំងអស់ ហើយទ្រង់ប្រទានឲ្យព្រះវិញ្ញាណសម្តែងមកក្នុងគ្រប់គ្នា ដើម្បីឲ្យបានកើតផល ដ្បិតទ្រង់ប្រទានឲ្យម្នាក់មានពាក្យសម្តីនៃប្រាជ្ញាវាងវៃ ដោយសារព្រះវិញ្ញាណឲ្យម្នាក់ទៀតមានពាក្យសម្តីនៃចំណេះចេះស្ទាត់ តាមព្រះវិញ្ញាណដដែល ហើយឲ្យម្នាក់ផ្សេងទៀត មានសេចក្តីជំនឿ ដោយនូវព្រះវិញ្ញាណដដែលឲ្យមួយទៀតបានអស់ទាំងអំណោយទាននឹងអាចប្រោសឲ្យជា ដោយនូវព្រះវិញ្ញាណដដែល ឲ្យមួយទៀតបានសម្តែងការឫទ្ធិបារមី និងឲ្យមួយទៀតចេះអធិប្បាយ ឲ្យមួយទៀតសង្កេតស្គាល់អស់ទាំងវិញ្ញាណ ឲ្យមួយទៀតចេះនិយាយភាសាដទៃទៀត ហើយឲ្យមួយទៀតចេះបកប្រែភាសាដទៃ តែគឺជាព្រះវិញ្ញាណ តែមួយដដែលនោះឯង ដែលធ្វើគ្រប់ការទាំងនោះ ទាំងចែកដល់គ្រប់គ្នាដោយមុខៗផង តាមដែលទ្រង់សព្វព្រះហឫទ័យ ។ ដ្បិតដូចជារូបកាយមួយ មានអវយវៈជាច្រើនតែអវយវៈទាំងនោះ ទោះមានច្រើនក៏ពិត គង់តែរួមគ្នាមកជារូបតែមួយទេ នោះព្រះគ្រិស្តក៏ដូច្នោះដែរ» (កូរិនថូសទី១ ១២:៤-១២) ។

អ្នកដែលព្រះបានត្រាស់ហៅឲ្យបំពេញតួនាទីជាអ្នកដឹកនាំពួកជំនុំរបស់ព្រះ មានការទទួលខុសត្រូវយ៉ាងធំ។ នៅសម័យទេវាធិបតេយ្យ (របបដឹកនាំដែលមានព្រះជាប្រមុខ) កាលលោកម៉ូសេកំពុងខិតខំប្រឹងប្រែងទទួលបន្ទុកយ៉ាងធ្ងន់តែម្នាក់ឯង ដែលនឹងនាំឲ្យលោកនឹងថយកម្លាំងទៅនៅក្នុងអំឡុងពេលដ៏ខ្លី នៅក្រោមបន្ទុកទាំងនោះ លោកយេត្រូបានផ្តល់ដំបូន្មានឲ្យរៀបចំផែនការចែកចាយការទទួលខុសត្រូវដ៏ឆ្លាតវាងវៃ លោកយេត្រូបានទូន្មានថា «សូមឲ្យព្រះគង់ជាមួយនឹងឯងផង គឺឲ្យឯងបានឈរជាជំនួសបណ្តាជនទាំងឡាយនៅចំពោះព្រះ ដើម្បីនឹងនាំរឿងគេទាំងប៉ុន្មានទៅទូលដល់ទ្រង់ ហើយឯងនឹងបង្រៀនអស់ទាំង  សេចក្តីបញ្ញត្តិ និងច្បាប់ដល់គេ ទាំងបង្ហាញ

ផ្លូវដែលគេត្រូវដើរ និងការដែលគេត្រូវធ្វើដែរ» ។ លោកយេត្រូបានទូន្មានបន្តទៀតថាមនុស្សដែលត្រូវតែងតាំងជាមេដឹកនាំត្រូវតែជា «មនុស្សប៉ិនប្រសប់ ដែលមានចិត្តកោតខ្លាចដល់ព្រះក្នុងពួកជន ជាមនុស្សទៀងត្រង់ ដែលស្អប់ការសំណូក» ។ ពួកគេត្រូវតែ «ជំនុំជម្រះពួកជនជាដរាប» ដូច្នេះ ជាការបន្ធូរបន្ទុកយ៉ាងធ្ងន់ពីលោកម៉ូសេ ក្នុងការពិចារណាអំពីរឿងរ៉ាវតូចតាច ដែលពួកអ្នកជំនួយការដែលមានការលះបង់អាចដោះស្រាយបាន ។

**<u>ច័ន្ទ-២៧ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ១៧**

**ខព្រះគម្ពីរប្រចាំថ្ងៃ**: *ដូច្នេះ ចូរអ្នករាល់គ្នាស្វែងរក ហើយកាន់តាមអស់ទាំងក្រឹត្យក្រមនៃព្រះយេហូវ៉ា ជាព្រះនៃអ្នករាល់គ្នាចុះ ដើម្បីឲ្យបានស្រុកល្អនេះ ទុកជាកេរអាករនៃអ្នករាល់គ្នា ហើយទុកជាមរដកដល់កូនចៅអ្នករាល់គ្នាខាងក្រោយតទៅ។ របាក្សត្រទី១ ២៨:៨*

ពេលវេលានិងកម្លាំងរបស់អ្នកដែលព្រះបានរៀបចំទុកសម្រាប់ដាក់ក្នុងតំណែងជាអ្នកដឹកនាំក្នុងពួកជំនុំ គួរតែចំណាយទៅលើដំណោះស្រាយរឿងរ៉ាវធំៗ ដែលតម្រូវការប្រាជ្ញាពិសេស និងចិត្តទូលាយ។ វាមិនមែនជារបៀបរៀបរយរបស់ព្រះទេ ដែលមនុស្សបែបនេះត្រូវបង្ហាញខ្លួននៅក្នុងការដោះស្រាយរឿងរ៉ាវកំប៉ិកកំប៉ុក ដែលអ្នកដទៃក៏មានសមត្ថភាពអាចធ្វើបានដែរនោះ។ «លោកយេត្រូបានស្នើយោបល់ដល់លោកម៉ូសេថា» «ឯអស់ទាំងរឿងណាធំៗ នោះត្រូវឲ្យគេនាំមកដល់ឯង តែបើជារឿងតូចៗទេ ត្រូវឲ្យគេកាត់សេចក្តីដោយខ្លួនគេចុះ នោះឯងនឹងត្រូវបានស្រួលជាង ឯអ្នកទាំងនោះនឹងបានជាជំនួយដល់ឯង បើឯងព្រមធ្វើដូច្នោះ ហើយព្រះទ្រង់ក៏បង្គាប់ផង នោះឯងនឹងនៅឋិតថេរបាន ហើយបណ្តាជននេះនឹងបានទៅដល់កន្លែងគេដោយសុខសាន្តទាំងអស់គ្នាដែរ» ។

នៅក្នុងការស្រុះស្រួលគ្នាជាមួយនឹងផែនការនេះ «គឺលោក (ម៉ូសេ) រើសយកមនុស្ស ដែលប៉ិនប្រសប់ក្នុងពួកអ៊ីស្រាអែលទាំងអស់ តាំងឡើងឲ្យ

ធ្វើជាមេត្រួតត្រាលើបណ្ដាជនទាំងឡាយ ជាមេលើមនុស្សមួយពាន់នាក់ ជាមេលើមួយរយនាក់ ជាមេលើហាសិបនាក់ ហើយជាមេលើដប់នាក់ ដូច្នោះ អ្នកទាំងនោះក៏ជំនុំជម្រះពួកជនជាដរាបទៅ គេនាំអស់ទាំងរឿងរ៉ាវណាដែលពិបាកៗមកដល់ម៉ូសេ តែអស់ទាំងរឿងរ៉ាវណាដែលតូចៗ នោះគេកាត់សេចក្ដីដោយខ្លួនគេវិញ» (និក្ខមនំ ១៨:១៩-២៦) ។

ក្រោយមកទៀត នៅពេលជ្រើសរើសអ្នកដឹកនាំចិតសិបនាក់ ដើម្បីចែករំលែកការទទួលខុសត្រូវជាមេដឹកនាំជាមួយនឹងគាត់ លោកម៉ូសេបានជ្រើសរើសដោយប្រុងប្រយ័ត្ន ជាអ្នកជំនួយការរបស់លោក អ្នកនោះត្រូវតែមានភាពថ្លៃថ្នូរ ចេះវិនិច្ឆ័យត្រឹមត្រូវ និងមានបទពិសោធន៍។ នៅក្នុងការទូន្មានដល់មេដឹកនាំទាំងនេះ នៅពេលបំពេញសិទ្ធឲ្យកាន់មុខតំណែងរបស់ពួកគេ លោកបានរៀបរាប់សង្ខេបអំពីគុណសម្បត្តិមួយចំនួន ដែលតម្រូវឲ្យមនុស្សមានលក្ខណៈសមស្របជាអ្នកដឹកនាំពួកជំនុំ។ លោកម៉ូសេបានមានប្រសាសន៍ថា «នៅវេលានោះ អញក៏បានផ្ដាំនឹងពួកកូនចៅក្រមនៃឯងរាល់គ្នាថា ចូរប្រុងស្ដាប់រឿងក្ដីរបស់ពួកបងប្អូនអ្នករាល់គ្នាចុះ ហើយជំនុំជម្រះដល់បង និងប្អូន និងអ្នកដែលស្នាក់នៅជាមួយនឹងគេដោយយុត្តិធម៌ មិនត្រូវឲ្យអ្នករាល់គ្នាល្អៀងទៅខាងណាក្នុងការកាត់ក្ដីឡើយ ត្រូវស្ដាប់អ្នកតូចដូចជាអ្នកធំដែរ មិនត្រូវខ្លាចមុខមនុស្សណាឲ្យសោះ ដ្បិតការវិនិច្ឆ័យ នោះស្រេចនៅព្រះវិញ ឯរឿងណាដែលពិបាកពេកដល់អ្នករាល់គ្នា នោះត្រូវនាំមកឯខ្ញុំវិញ ខ្ញុំនឹងជំនុំជម្រះឲ្យ» (ចោទិយកថា ១:១៦, ១៧)។

នៅចុងរជ្ជកាលរបស់ទ្រង់ ស្ដេចដាវីឌបានប្រទានដំបូន្មានដ៏ឧឡារិកដល់អ្នកដែលទទួលបន្ទុកបម្រើកិច្ចការរបស់ព្រះនៅសម័យព្រះអង្គ។ ដោយកោះហៅឲ្យប្រជារាស្ត្រមកជួបជុំគ្នានៅទីក្រុងយេរូសាឡិម «ដែលជាប្រធានក្នុងសាសន៍អ៊ីស្រាអែល ពួកចៅហ្វាយនៃពូជអំបូរទាំងប៉ុន្មាន ពួកនាយដែលត្រួតលើពួកអ្នកផ្គត់ផ្គង់ស្បៀងថ្វាយស្ដេចតាមវេន ពួកមេទ័ពធំតូច ពួកអ្នកដែលត្រួតលើព្រះរាជ្យទ្រព្យរបស់ស្ដេច និងពួកបុត្រាទ្រង់ទាំងប៉ុន្មាន និង

ពួកឧកញ៉ា គឺជាពួកខ្លាំងពូកែ» ព្រះរាជាដ៏ចំណាស់នេះបានទូន្មានដល់ពួកគេថា «ឥឡូវនេះ អ្នករាល់គ្នានៅចំពោះពួកអ៊ីស្រាអែលទាំងអម្បាលម៉ានជាពួកជំនុំនៃព្រះយេហូវ៉ា ហើយនៅចំពោះព្រះនៃយើងរាល់គ្នា» ដូច្នេះ «ចូរអ្នករាល់គ្នាស្វែងរក ហើយកាន់តាមអស់ទាំងក្រឹត្យក្រមនៃព្រះយេហូវ៉ាជាព្រះនៃអ្នករាល់គ្នាចុះ ដើម្បីឲ្យបានស្រុកល្អនេះ ទុកជាកេរអាករនៃអ្នករាល់គ្នា ហើយទុកជាមរតកដល់កូនចៅអ្នករាល់គ្នាខាងក្រោយតទៅ» (របាក្សត្រទី១ ២៨:១-៨) ។

ស្តេចដាវីឌបានប្រទានដំបូន្មានជាពិសេសដល់ស្តេចសាឡូម៉ូន ជាការត្រាស់ហៅឲ្យកាន់តំណែងជាមេដឹកនាំថា៖ «ហើយឯងឯង ឱសាឡូម៉ូនជាកូនអញអើយ ចូរឲ្យឯងបានស្គាល់ព្រះនៃឪពុកឯងចុះ ព្រមទាំងប្រតិបត្តិតាមទ្រង់ ដោយអស់ពីចិត្ត ហើយស្ម័គ្រស្មោះផង ដ្បិតព្រះយេហូវ៉ាទ្រង់ស្ទង់អស់ទាំងចិត្ត ក៏យល់អស់ទាំងសេចក្តីដែលយើងគិតដែរ បើឯងរកទ្រង់ នោះនឹងបានឃើញមែន តែបើឯងបោះបង់ចោលទ្រង់វិញ នោះទ្រង់ក៏នឹងបោះបង់ចោលឯងជាដរាបទៅ ឥឡូវនេះ ចូរឯងប្រុងប្រយ័ត្ន ដ្បិតព្រះយេហូវ៉ាបានរើសឯង ... ដូច្នេះ ចូរឯងមានកម្លាំងឡើង ហើយធ្វើសម្រេចចុះ» (របាក្សត្រទី១ ២៨:៩, ១០) ។

**<u>អង្គារ-២៨ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ១៨**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ដ្បិតគួរឲ្យអ្នកដែលត្រួតត្រាបានឥតសៅហ្មង ដូចជាអ្នកជំនួយរបស់ព្រះដែរ មិនត្រូវមានចិត្តមានះ ឆាប់ខឹង ចំណូលស្រា ច្រឡោត ឬស៊ីសំណូកឡើយ ត្រូវមានចិត្តចៅរ៉ៅ ស្រឡាញ់ការល្អ មានចិត្តធ្ងន់ធ្ងរ ហើយសុចរិត បរិសុទ្ធ ដឹងខ្នាតវិញ។ ទីតុស ១:៧-៨*

ពួកអ្នកដែលព្រះបានប្រទានបន្ទុកនៃកិច្ចការដឹកនាំរចនាសម្ព័ន្ធនៃពួកជំនុំថ្មី នៅក្នុងការចែកចាយដំណឹងល្អ ក៏ត្រូវតែធ្វើតាមគោលការណ៍នៃសេចក្តីស្រឡាញ់ដោយគោរព និងសេចក្តីយុត្តិធម៌ ដូចគ្នានឹងការបានណែនាំអ្នក

ដឹកនាំនាសម័យលោកម៉ូស និងសម័យស្ដេចដាវីឌនោះដែរ។ នៅក្នុងការរៀបចំកិច្ចការឲ្យមានរបៀបរៀបរយក្នុងពួកជំនុំ និងការញែកមនុស្សដែលមានសមត្ថភាពឲ្យបំពេញតួនាទីជាមន្ត្រីផ្សេងៗ ពួកសាវ័កបានប្រកាន់ខ្ជាប់នូវស្តង់ដារនៃភាពជាអ្នកដឹកនាំយ៉ាងខ្ពស់ ដែលបានសង្ខេបនៅក្នុងគម្ពីរសញ្ញាចាស់។ ពួកគេបានអះអាងថា អ្នកណាដែលត្រូវបានត្រាស់ហៅឲ្យទទួលខុសត្រូវលើពួកជំនុំ «គួរឲ្យអ្នកដែលត្រួតត្រាបានឥតសៅហ្មង ដូចជាអ្នកជំនួយរបស់ព្រះដែរ មិនត្រូវមានចិត្តមានះឆាប់ខឹង ចំណូលស្រា ច្រឡោត ឬស៊ីសំណូកឡើយ ត្រូវមានចិត្តថៅរ៉ៅ ស្រឡាញ់ការល្អ មានចិត្តធ្ងន់ធ្ងរ ហើយសុចរិត បរិសុទ្ធ ដឹងខ្នាតវិញ ព្រមទាំងកាន់ខ្ជាប់ តាមព្រះបន្ទូលដ៏ពិត ដូចជាបានបង្រៀនមកយើងហើយ ដើម្បីឲ្យអាចនឹងកម្សាន្តចិត្តគេ ដោយសេចក្តីបង្រៀនដ៏ត្រឹមត្រូវ ហើយឲ្យបានផ្ចាញ់ដល់ពួកអ្នកដែលស្រដីទទឹង» (ទីតុស ១:៧-៩) ។

របៀបរៀបរយដែលគេបានរក្សានៅក្នុងពួកជំនុំគ្រិស្តបរិស័ទដំបូងធ្វើឲ្យពួកគេអាចបោះជំហានទៅមុខយ៉ាងរឹងមាំ ដូចជាកងទ័ពដ៏មានវិន័យដែលបំពាក់ដោយគ្រឿងសឹករបស់ព្រះ ទោះបីជាត្រូវបែកគ្នាទៅរស់នៅក្នុងដែនដីដ៏ធំធេងយ៉ាងណាក៏ដោយ ក៏ក្រុមនៃអ្នកមានជំនឿនៅតែជាសមាជិកនៃរាងកាយតែមួយដដែលដែរ ទាំងអស់គ្នារួបរួមសាមគ្គីគ្នាស្រុះស្រួលគ្នា ទៅវិញទៅមក។ នៅពេលមានវិវាទកើតឡើងនៅក្នុងពួកជំនុំមូលដ្ឋាន ខណៈដែលក្រោយមកកើតឡើងនៅអាន់ទីយ៉ូក និងនៅទីកន្លែងផ្សេងៗ ហើយពួកអ្នកមានជំនឿមិនអាចឈានដល់ការព្រមព្រៀងគ្នាក្នុងចំណោមពួកគេ ពួកគេមិនបណ្តោយឲ្យបញ្ហានេះបង្កើតការបែងចែកនៅក្នុងពួកជំនុំឡើយ ប៉ុន្តែពួកគេបានបញ្ជូនរឿងនោះទៅកាន់ក្រុមប្រឹក្សាកណ្តាលនៃពួកអ្នកមានជំនឿដែលបង្កើតឡើងដោយប្រតិភូមកពីពួកជំនុំមូលដ្ឋានផ្សេងៗ ជាមួយនឹងពួកសាវ័កនិងពួកមេដឹកនាំដែលមានតួនាទីក្នុងការដឹកនាំផ្សេងៗ។ ដូច្នេះ ការខំប្រឹងប្រែងរបស់សាតាំងដើម្បីវាយប្រហារមកលើពួកជំនុំនៅក្នុងកន្លែងដាច់

ស្រយាលត្រូវបានជួបប្រទះនឹងសកម្មភាពនៃការរួបរួមគ្នានៅគ្រប់ផ្នែកទាំងអស់ ហើយផែនការរបស់សត្រូវដើម្បីរំខាននិងបំផ្លាញដល់ពួកជំនុំក៏ត្រូវបានទប់ស្កាត់ ។

«ដ្បិតព្រះទ្រង់មិនមែនជាព្រះនៃសេចក្ដីវឹកវរទេ គឺទ្រង់ជាព្រះនៃសេចក្ដីសុខសាន្តវិញ ដូចក្នុងអស់ទាំងពួកជំនុំរបស់ពួកបរិសុទ្ធដែរ» (កូរិនថូសទី១ ១៤:៣៣) ។ ព្រះអង្គតម្រូវឲ្យរក្សារបៀបរៀបរយនិងប្រព័ន្ធនៅក្នុងការដឹកនាំនៃកិច្ចការរបស់ពួកជំនុំនាពេលបច្ចុប្បននេះ មិនឲ្យអន់ថយជាងសម័យដើមឡើយ។ ព្រះអង្គប្រាថ្នាចង់ឲ្យព្រះរាជកិច្ចរបស់ទ្រង់ត្រូវបានអនុវត្តឆ្ពោះទៅមុខដោយភាពហ្មត់ចត់និងភាពត្រឹមត្រូវ ដើម្បីឲ្យទ្រង់អាចបោះត្រាទទួលយកកិច្ចការនោះ។ គ្រិស្តបរិស័ទត្រូវតែរួបរួមជាមួយនឹងគ្រិស្តបរិស័ទ ពួកជំនុំជាមួយនឹងពួកជំនុំ មនុស្សដែលជាឧបករ សហការណ៍ជាមួយនឹងព្រះភ្នាក់ងារក្រោមបង្គាប់ទាំងឡាយ រួបរួមជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធ ហើយទាំងអស់គ្នារួបរួមក្នុងការចែកចាយដំណឹងពីសេចក្ដីស្រឡាញ់ដ៏បវរនៃព្រះគុណរបស់ព្រះ ដល់ពិភពលោកទាំងមូល។

## ជំពូកទី
## ១០

# ទុក្ករបុគ្គល (អ្នកសុខចិត្តស្លាប់ដោយសារជំនឿ) គ្រិស្តបរិស័ទដំបូងបង្អស់

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ៦:៨-១៥ ដល់ ជំពូក ៧ ។*

**<u>ពុធ-២៩ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ១៩**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ដ្បិតខ្ញុំនឹងឲ្យអ្នករាល់គ្នាមានថ្វីមាត់ ហើយនិងប្រាជ្ញាវិញ ដែលពួកអ្នកតតាំងពុំអាចនឹងឆ្លើយឆ្លង ឬទទឹងទាស់បានឡើយ។*

*លូកា ២១:១៥*

លោកស្ទេផានជាមនុស្សសំខាន់ជាងគេ នៅក្នុងចំណោមអ្នកជំនួយការទាំងប្រាំពីរនាក់នោះ លោកជាមនុស្សដែលមានសេចក្តីស្រឡាញ់យ៉ាងជ្រាលជ្រៅ និងមានជំនឿដ៏ទូលំទូលាយ ទោះបីជាលោកមានកំណើតជាសាសន៍យូដាក៏ដោយ ក៏លោកអាចនិយាយភាសាក្រិក និងស្គាល់ប្រពៃណីនិងលក្ខណៈរបស់សាសន៍ក្រិកយ៉ាងច្បាស់ផងដែរ។ ហេតុដូច្នេះ លោកបានរកឱកាសអធិប្បាយដំណឹងល្អនៅក្នុងសាលាប្រជុំរបស់សាសន៍យូដាដែលនិយាយភាសាក្រិក។ លោកជាមនុស្សដែលសកម្មក្នុងកិច្ចការរបស់ព្រះគ្រិស្ត ហើយបានប្រកាសពីជំនឿរបស់លោកយ៉ាងក្លាហាន។ ពួកគ្រូអាចារ្យដែលមានចំណេះដឹងខ្ពស់ និងពួកបណ្ឌិតច្បាប់បានចូលមកជជែកជាសាធារណៈជាមួយនឹងលោក ដោយរំពឹងជឿជាក់ថានឹងទទួលបានជ័យជម្នះយ៉ាងងាយស្រួល។ ប៉ុន្តែ «គេពុំអាចទប់ទល់នឹងប្រាជ្ញា ហើយនិងព្រះវិញ្ញាណ ដែលគាត់អាងនឹងនិយាយនោះបានទេ»។ លោកមិនមែនគ្រាន់តែនិយាយនៅក្នុងព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះទេ ប៉ុន្តែ សម្តីរបស់លោកបានបញ្ជាក់ច្បាស់ថាលោកជាសិស្សនៃសេចក្តីទំនាយ ហើយបានសិក្សាអំពីច្បាប់

គ្រប់បែបយ៉ាង ។ លោកបានការពារសេចក្តីពិតដែលលោកបានគាំទ្រ និង យកជ័យជម្នះលើគូប្រជែងរបស់លោកយ៉ាងគួរជាទីពេញចិត្ត។ លោកគឺជាមនុស្សដែលសម្រេចតាមបទទំនាយដែលបានចែងថា «ដូច្នេះ ចូរសម្រេចក្នុងចិត្តថា អ្នករាល់គ្នានឹងមិនគិតជាមុន អំពីពាក្យដែលត្រូវដោះសាទេ ដ្បិតខ្ញុំនឹងឲ្យអ្នករាល់គ្នាមានថ្វីមាត់ ហើយនិងប្រាជ្ញាវិញ ដែលពួកអ្នកតតាំងពុំអាចនឹងឆ្លើយឆ្លង ឬទទឹងទាស់បានឡើយ» (លូកា ២១:១៤, ១៥) ។

នៅពេលដែលពួកសង្ឃនិងពួកមេសាសនាបានឃើញមានអំណាចនៅជាមួយនឹងការអធិប្បាយរបស់លោកស្ទេផានដូច្នេះ ពួកគេមានកំហឹងយ៉ាងជូរចត់។ ជំនួសឲ្យការទោរទន់ទៅរកភ័ស្តុតាងដែលលោកបានបង្ហាញ ពួកគេបានប្តេជ្ញាថា នឹងបំបាត់សំឡេងគាត់ដោយសម្លាប់គាត់បង់។ ពួកគេបានសូកប៉ាន់រដ្ឋអំណាចរ៉ូមជាច្រើនដង ឲ្យប្រគល់អំណាចមកក្នុងកណ្តាប់ដៃពួកយូដា ហើយសាកសួរ កាត់ទោស និងប្រហារជីវិតដល់អ្នកទោសទៅតាមទម្លាប់នៃប្រទេសរបស់គេ។ សត្រូវរបស់លោកស្ទេផានមិនបានសង្ស័យឡើយថាពួកគេអាចអនុវត្តទង្វើនេះម្តងទៀត ដោយមិនមានគ្រោះថ្នាក់ដល់ខ្លួនគេនោះឡើយ។ ពួកគេបានតាំងចិត្តប្រថុយនឹងគ្រោះថ្នាក់ដែលកើតឡើងពីទង្វើនេះ ហើយបានហ៊ុំព័ទ្ធលោកស្ទេផាន រួចចាប់នាំលោកមកកាន់ក្រុមប្រឹក្សាសាន់ហ៊ីឌ្រីនដើម្បីកាត់ទោស។

ពួកអ្នកប្រាជ្ញសាសន៍យូដាបានប្រមូលគ្នាមកពីជុំវិញប្រទេស ដើម្បីជជែកតទល់ជាមួយនឹងអ្នកទោសនេះ។ លោកសុលជាអ្នកស្រុកតើសុសក៏បាននៅទីនោះ ហើយមានចំណែកក្នុងការដឹកនាំប្រឆាំងនឹងស្ទេផានដែរ។ លោកសុលបាននាំមកនូវទម្ងន់នៃវោហារកោសល្យ និងតក្កវិជ្ជានៃពួកគ្រូអាចារ្យមកបញ្ចេញនៅក្នុងករណីនេះ ដើម្បីទាក់ទាញពួកបណ្តាជនឲ្យជឿថាលោកស្ទេផានកំពុងអធិប្បាយអំពីគោលលទ្ធិបោកបញ្ឆោត និងមានគ្រោះថ្នាក់ ប៉ុន្តែ ចំណែកលោកស្ទេផានវិញ លោកបានជួបនឹងអ្នកដែលយល់យ៉ាងច្បាស់អំពីព្រះរាជគោលបំណងរបស់ព្រះ នៅក្នុងការអធិប្បាយដំណឹងល្អដល់

សាសន៍ដទៃ ។

ដោយសារពួកសង្ឃនិងពួកមេសាសនា មិនអាចយកជ័យជម្នះលើប្រាជ្ញាយ៉ាងច្បាស់លាស់និងស្ងៀមស្ងាត់របស់លោកស្ទេផានបាន ពួកគេបានប្ដេជ្ញាចិត្តធ្វើឲ្យលោកក្លាយជាគំរូមួយ ហើយនៅពេលដែលការធ្វើដូច្នេះបានបំពេញសម្អប់ដ៏ឃោរឃៅរបស់ពួកគេ ពួកគេបានការពារអ្នកដទៃមិនឲ្យទទួលយកជំនឿរបស់លោក ដោយការភ័យខ្លាច។ ពួកគេបានជួលសាក្សីក្លែងក្លាយឲ្យធ្វើទីបន្ទាល់ក្លែងថា ពួកគេបានឮលោកនិយាយប្រមាថដល់ព្រះវិហារនិងប្រមាថដល់ក្រឹត្យវិន័យផង។ ពួកសាក្សីទាំងនេះបានថ្លែងថា «ដ្បិតយើងខ្ញុំបានឮវាថា ឈ្មោះយេស៊ូវ ពីស្រុកណាសារ៉ែតនោះនឹងបំផ្លាញទីនេះបង់ព្រមទាំងបំផ្លាស់បំប្រែទំនៀមទម្លាប់ ដែលលោកម៉ូសេបានទុកឲ្យយើងរាល់គ្នាចេញ» ។

**<u>ព្រហស្បតិ៍-៣០ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ២០**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *តែអស់អ្នកដែលអង្គុយនៅក្នុងក្រុមជំនុំ ក៏ជាប់ភ្នែកមើលមុខគាត់ ឃើញដូចជាមុខទេវតា។ កិច្ចការ ៦:១៥*

នៅពេលដែលលោកស្ទេផានបានឈរទល់មុខនឹងចៅក្រមរបស់លោក ដើម្បីឆ្លើយតបទៅនឹងការចោទប្រកាន់ពីបទប្រមាថនោះ ពន្លឺរស្មីដ៏បរិសុទ្ធបានចែងចាំងនៅលើមុខលោក ហើយ «អស់អ្នកដែលអង្គុយនៅក្នុងក្រុមជំនុំក៏ជាប់ភ្នែកមើលមុខគាត់ ឃើញដូចជាមុខទេវតា» មនុស្សជាច្រើនដែលបានឃើញពន្លឺនេះ បានញ័ររន្ធត់ ហើយគ្របមុខរបស់ខ្លួន ប៉ុន្តែ ពួកអ្នកដឹកនាំសាសនាដែលមានចិត្តរឹងរូសនៅតែមិនរង្គើដដែល។

នៅពេលដែលគេបានសាកសួរលោកស្ទេផាន ពីការចោទប្រកាន់ទាស់នឹងគាត់ថាជាការពិត លោកបានចាប់ផ្ដើមការពារខ្លួនដោយសំឡេងរលាក់និងច្បាស់ៗ ដែលឮទ្រហឹងពេញសាលជំនុំជម្រះ។ លោកបានបង្រៀនអំពីប្រវត្តិសាស្ត្រនៃរាស្ត្រដែលព្រះបានជ្រើសរើស នៅក្នុងពាក្យសម្ដីដែលធ្វើឲ្យ

ពួកបណ្ដាជនដែលប្រជុំគ្នានោះចាប់ចិត្តយ៉ាងក្រៃលែង។ លោកបានបង្ហាញពីចំណេះដឹងខាងសេដ្ឋកិច្ចរបស់សាសន៍យូដាយ៉ាងហ្មត់ចត់ និងការបកស្រាយខាងព្រលឹងវិញ្ញាណ ដែលឥឡូវនេះបានបង្ហាញយ៉ាងច្បាស់តាមរយៈព្រះគ្រិស្ត។ លោកបានរំឭកពីប្រសាសន៍របស់លោកម៉ូសេ ដែលបានទស្សទាយអំពីព្រះមែស្ស៊ី៖ «ព្រះអម្ចាស់ដ៏ជាព្រះនៃអ្នករាល់គ្នា ទ្រង់នឹងបង្កើតហោរាម្នាក់ ពីពួកបងប្អូនអ្នករាល់គ្នាមក ឲ្យដូចជាខ្ញុំ ត្រូវឲ្យអ្នករាល់គ្នាស្ដាប់តាមហោរានោះចុះ»។ លោកបានបញ្ជាក់ប្រាប់យ៉ាងច្បាស់អំពីភក្ដីភាពរបស់លោកចំពោះព្រះ និងចំពោះជំនឿរបស់សាសន៍យូដា នៅពេលដែលលោកបានបង្ហាញថាច្បាប់ដែលសាសន៍យូដាបានទុកចិត្តសម្រាប់សេចក្ដីសង្គ្រោះនោះមិនអាចជួយសង្គ្រោះរាស្ត្រអ៊ីស្រាអែលចេញពីការថ្វាយបង្គំរូបព្រះបានទេ។ លោកបានយោងទៅការសាងសង់ព្រះវិហារដោយស្ដេចសាឡូម៉ូន និងទៅព្រះបន្ទូលរបស់ស្ដេចសាឡូម៉ូន និងប្រសាសន៍របស់ហោរាអេសាយថា៖ «ប៉ុន្តែ ឯព្រះដ៏ខ្ពស់បំផុត ទ្រង់មិនគង់នៅក្នុងព្រះវិហារដែលដៃមនុស្សធ្វើនោះឡើយ ដូចជាហោរាបានទាយថាឋានសួគ៌ជាបល្ល័ង្កអញ ហើយផែនដីជាកំណល់កល់ជើងអញ ព្រះអម្ចាស់មានព្រះបន្ទូលថា តើឯងរាល់គ្នានឹងស្អាងដំណាក់ណាឲ្យអញ ឬកន្លែងណាឲ្យអញឈប់សម្រាកបាន តើមិនមែនដៃអញ ដែលបង្កើតរបស់ទាំងនេះទេឬអី?»

នៅពេលលោកស្ទេផានមានប្រសាសន៍ដល់ចំណុចនេះ នោះមានភាពជ្រួលច្របល់នៅក្នុងចំណោមពួកបណ្ដាជនឡើង។ នៅពេលលោកបានភ្ជាប់ព្រះគ្រិស្តទៅនឹងបទទំនាយនិងបាននិយាយដូចកាលលោកបាននិយាយនៅក្នុងព្រះវិហារនោះ ពួកសង្ឃបានធ្វើពុតជាមានការរន្ធត់ជាខ្លាំងដោយបានហែកអាវរបស់ខ្លួន។ ចំពោះលោកស្ទេផានសកម្មភាពនេះគឺជាសញ្ញាបញ្ជាក់ថាសំឡេងរបស់លោកនឹងត្រូវស្ងៀមស្ងាត់ជារៀងរហូត។ លោកបានឃើញការប្រឆាំងទាស់នឹងសម្ដីរបស់លោក ហើយលោកក៏ដឹងផងដែរថាលោកកំពុងតែធ្វើទីបន្ទាល់ចុងក្រោយបង្អស់របស់លោក។ ទោះបីជាសេចក្ដីអធិប្

បាយរបស់លោកទើបតែនឹងបានពាក់កណ្តាល ក៏ដោយក៏លោកបាន ប្រញាប់ប្រញាល់បញ្ចប់ដែរ។

រំពេចនោះ លោកបានបង្វែរប្រធានបទពីខ្សែប្រវត្តិសាស្រ្តដែលលោកកំពុងតែតាមដាន ហើយត្រឡប់ទៅឯចៅក្រមដែលកំពុងតែក្រោធខឹងរបស់លោកម្តងវិញ លោកបានស្រែកថា «ឱពួកមនុស្សក្បាលរឹង ដែលមានចិត្តមានត្រចៀកមិនកាត់ស្បែកអើយ អ្នករាល់គ្នាចេះតែទាស់ទទឹងនឹងព្រះវិញ្ញាណបរិសុទ្ធជាដរាប ពួកអយ្យកោអ្នករាល់គ្នាយ៉ាងណា នោះអ្នករាល់គ្នាក៏យ៉ាងនោះដែរ តើមានហោរាណាមួយ ដែលពួកអយ្យកោអ្នករាល់គ្នាមិនបានធ្វើទុក្ខបៀតបៀន ហើយគេបានសម្លាប់ពួកអ្នកដែលទាយពីដំណើរព្រះដ៏សុចរិតត្រូវយាងមកដែរ ឥឡូវនេះ អ្នករាល់គ្នាក៏បានក្បត់ ហើយសម្លាប់ព្រះអង្គនោះ អ្នករាល់គ្នាជាអ្នកដែលបានទទួលក្រឹត្យវិន័យ ដោយព្រះចាត់ថែងពួកទេវតាមក តែមិនបានកាន់តាមសោះ»។

<u>សុក្រ-៣១ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ២១

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *តែដែលគាត់បានពេញជាព្រះវិញ្ញាណបរិសុទ្ធ នោះក៏សំឡឹងមើលទៅលើមេឃ ឃើញសិរីល្អនៃព្រះ និងព្រះយេស៊ូវឈរនៅខាងព្រះហស្តស្តាំ រួចគាត់មានវាចាថាមើល ខ្ញុំឃើញមេឃចំហ និងកូនមនុស្សឈរនៅខាងព្រះហស្តស្តាំនៃព្រះ។ កិច្ចការ ៧:៥៥-៥៦*

ពួកសង្ឃនិងពួកមេដឹកនាំសាសនាបានផ្ទុះកំហឹងជាខ្លាំង ចំពោះសម្តីនេះ។ ពួកគេបានស្ទុះទៅរកលោកស្ទេផានដោយសង្កៀតធ្មេញ ទាំងប្រព្រឹត្តដូចជាខ្លាឃើញចំណី។ នៅក្នុងទឹកមុខដ៏ឃោរឃៅរបស់របស់ពួកគេ អ្នកជាប់គុករូបនេះបានដឹងយ៉ាងច្បាស់ពីជោគវាសនារបស់ខ្លួន ប៉ុន្តែ លោកនៅតែរឹងមាំឥតរង្កើដដែល ។ សម្រាប់លោក ការភ័យខ្លាចចំពោះសេចក្តីស្លាប់បានរលាយបាត់អស់ទៅហើយ។ ចំពោះលោក លោកមិនមានការភ័យខ្លាចចំពោះពួកសង្ឃដែលមានកំហឹង និងហ្វូងមនុស្សនេះឡើយ។ ទស្សនីយភាពនៅចំពោះមុខលោកបានហោះចេញពីចក្ខុនិម្មិតរបស់លោក។ ទ្វារនៃឋានសួគ៌

បានបង្ហើបបន្តិចនៅចំពោះមុខលោក ហើយលោកក៏បានសម្លឹងមើលទៅកាន់ទីនោះ បានឃើញសិរីល្អនៃព្រះរាជវាំងរបស់ព្រះ និងព្រះគ្រិស្តហាក់ដូចជាទើបតែយាងចេញពីបល្ល័ង្ក ក្រោកឈរប្រុងនឹងជួយទ្រទ្រង់ដល់អ្នកបម្រើរបស់ទ្រង់។ លោកស្ទេផានបានឧទានដោយសម្តីនៃជ័យជម្នះថា «មើលខ្ញុំឃើញមេឃចំហ និងកូនមនុស្សឈរនៅខាងព្រះហស្តស្តាំនៃព្រះ»។

នៅពេលដែលលោកបានពណ៌នាអំពីទស្សនីយភាពដ៏មានសិរីរុងរឿងដែលលោកបានមើលឃើញ នោះគឺជារឿងដែលពួកអ្នកបៀតបៀនដល់លោកមិនអាចអត់ទ្រាំបាន។ គេបានចុកត្រចៀកគេមិនឲ្យឮសម្តីរបស់លោក ហើយបញ្ចេញសម្រែកយ៉ាងឮ ពួកគេបានរត់សម្រុកសំដៅទៅរកលោកព្រមៗគ្នា «គេកញ្ឆក់នាំគាត់ចេញទៅខាងក្រៅទីក្រុង» ។ «រួចចោលនឹងថ្ម ឯពួកស្មរបន្ទាល់ គេក៏ផ្ញើអាវគេដាក់នៅទៀបជើងមនុស្សកំឡោះម្នាក់ ឈ្មោះសុលគេចោលស្ទេផាននឹងថ្ម កំពុងដែលគាត់ទូលអង្វរដល់ព្រះថា ឱព្រះអម្ចាស់យេស៊ូវអើយ សូមទទួលវិញ្ញាណទូលបង្គំផង នោះគាត់លុតជង្គង់ចុះ រួចស្រែកឡើងជាសំឡេងខ្លាំងថា ឱព្រះអម្ចាស់អើយ សូមកុំរាប់បាបនេះដល់គេឡើយ កាលគាត់បានពោលដូច្នោះហើយ នោះក៏ដេកលក់ (ស្លាប់) ទៅ»។

គេមិនបានកាត់ទោសលោកស្ទេផានតាមច្បាប់ទេ ប៉ុន្តែ ពួកគេបានសូកប៉ាន់រដ្ឋអំណាចដោយលុយកាក់ជាច្រើន ធ្វើឲ្យមិនមានការស៊ើបអង្កេតចំពោះករណីនេះសោះ។

ទុក្ករកម្ម (ការរងការឈឺចាប់ដោយសារសេចក្តីជំនឿ) របស់លោកស្ទេផានបានធ្វើឲ្យពួកមនុស្សដែលបានឃើញការនេះចាប់អារម្មណ៍ជាខ្លាំង។ ការនឹកចាំអំពីត្រារបស់ព្រះនៅលើមុខរបស់លោក ពាក្យសម្តីរបស់លោក ដែលបានកន្ត្រាក់ចិត្តពួកដែលបានឃើញនិងបានឮទាំងឡាយ បាននៅជាប់ក្នុងគំនិតរបស់អ្នកដែលបានឃើញជានិច្ច ហើយពួកគេបានធ្វើជាកសិណសាក្សីនៃសេចក្តីពិតដែលលោកស្ទេផានបានប្រកាសនោះ។ មរណភាពរបស់លោកគឺជាការសាកល្បងដ៏ឈឺចាប់របស់ពួកជំនុំ ប៉ុន្តែ លទ្ធផលនៃមរណភាពនោះបានធ្វើឲ្យមានការកែប្រែចិត្តរបស់មនុស្សជាច្រើន ដែលមិនអាចលុបបំបាត់

នូវសេចក្តីជំនឿនិងភាពខ្ជាប់ខ្ជួនរបស់ទុក្ករបុគ្គល ព្រមទាំងសិរីល្អដែលបាន
ឋិតនៅលើមុខរបស់លោក ចេញពីគំនិតរបស់ពួកគេបានឡើយ។

នៅក្នុងឆាកនៃការឈឺចាប់និងការស្លាប់របស់លោកស្ទេផាននោះ លោកសុលហាក់ដូចជាមានចិត្តរំជើបរំជួលយ៉ាងពុះកញ្ជ្រោល។ បន្ទាប់មកទៀត គាត់មានកំហឹងដោយចិត្តអាថ៌កំបាំងរបស់លោក ដែលព្រះបានលើកតម្កើងលោកស្ទេផាន នៅពេលដែលហ្វូងមនុស្សមិនបានលើកតម្កើងដល់លោកសុលនោះ។ លោកសុលបានបន្តធ្វើទុក្ខបៀតបៀនដល់ពួកជំនុំរបស់ព្រះ ដោយតាមរកចាប់ពួកគេ ព័ទ្ធចាប់ខ្លួននៅតាមផ្ទះ រួចបញ្ជូនពួកគេទៅឲ្យសម្តេចសង្ឃនិងពួកមេសាសនាដើម្បីដាក់គុក ឬសម្លាប់ចោល។ ចិត្តពុះកញ្ជ្រោលរបស់លោកក្នុងការជំរុញការធ្វើទុក្ខបៀតបៀននេះបានបង្កឲ្យមានភាពរឹកររជាខ្លាំង ដល់ពួកជំនុំនៅទីក្រុងយេរូសាឡិម។ រដ្ឋអំណាចរ៉ូមមិនបានខំប្រឹងប្រែងបង្ក្រាបអំពើឃោរឃៅនេះទេ តែគេបានចេញបញ្ជាបន្ថែមស្ងាត់ៗដល់ពួកយូដាឲ្យសម្រុះសម្រួលពួកគេ ដើម្បីរក្សាសុវត្ថិភាពប្រជាប្រិយរបស់ពួកគេ។

បន្ទាប់ពីមរណភាពរបស់លោកស្ទេផានមក លោកសុលត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាសាន់ហ៊ីឌ្រីន ដោយសារតែសកម្មភាពរបស់លោកនៅពេលនោះ។ លោកបានក្លាយជាឧបករណ៍ដ៏មានអំណាចរបស់សាតាំង ដើម្បីអនុមតិការប្រឆាំងបះបោរទាស់នឹងព្រះរាជបុត្ររបស់ព្រះមួយរយៈ។ ប៉ុន្តែ មិនយូរប៉ុន្មាន ព្រះបានប្រើការធ្វើទុក្ខបៀតបៀនគ្មានក្តីមេត្តានេះ ដើម្បីស្ថាបនាពួកជំនុំដែលលោកសុលកំពុងហែកហួរនៅពេលនេះទៅវិញ។ ព្រះដែលមានព្រះចេស្តាខ្លាំងជាងសាតាំង បានជ្រើសរើសលោកសុលឲ្យជំនួសទុក្ករបុគលស្ទេផាន ឲ្យអធិប្បាយ និងឲ្យឈឺចាប់ដើម្បីព្រះនាមរបស់ទ្រង់ និងឲ្យពង្រីកសេចក្តីស្រឡាញ់នៃសេចក្តីសង្គ្រោះតាមរយៈព្រះលោហិតរបស់ព្រះអង្គ ឲ្យបានសុះសាយយ៉ាងទូលំទូលាយ ។

ជំពូកទី
១១

# ដំណឹងល្អនៅស្រុកសាម៉ារី

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ជំពូក ៨ ។*

**សៅរ៍-១ សីហា** អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ២១

**ខព្រះគម្ពីរប្រចាំសប្តាហ៍:** *ឯសុលបានធ្វើទុក្ខដល់ពួកជំនុំខ្លាំងណាស់ ដោយចូលគ្រប់តែផ្ទះ ចាប់ទាញអូសទាំងប្រុសទាំងស្រី បញ្ជូនទៅដាក់គុក។ ចំណែកអស់អ្នកដែលត្រូវខ្ចាត់ខ្ចាយនោះ គេដើរចុះឡើងទាំងផ្សាយដំណឹងល្អ គឺជាព្រះបន្ទូល។ កិច្ចការ ៨:៣-៤*

បន្ទាប់ពីមរណភាពរបស់លោកស្ទេផានមក មានការបៀតបៀនឥតស្រាកស្រាន្តដល់ពួកអ្នកមានជំនឿដែល «ពួកជំនុំត្រូវខ្ចាត់ខ្ចាយទៅនៅតែពាសពេញក្នុងស្រុកយូដានិងស្រុកសាម៉ារី» ឯសុល «បានធ្វើទុក្ខដល់ពួកជំនុំខ្លាំងណាស់ ដោយចូលគ្រប់តែផ្ទះ ចាប់ទាញអូសទាំងប្រុសទាំងស្រី បញ្ជូនទៅដាក់គុក»។ នៅថ្ងៃក្រោយមកទៀត លោកបានមានប្រសាសន៍អំពីចិត្តពុះកញ្ជ្រោលនៅក្នុងកិច្ចការយ៉ាងឃោរឃៅនេះថា «សូម្បីទូលបង្គំក៏បានគិតស្មានថា គួរឲ្យទូលបង្គំធ្វើទាស់ទទឹងជាច្រើន ដល់ព្រះនាមព្រះយេស៊ូវ ពីស្រុកណាសារ៉ែតដែរ គឺទូលបង្គំបានធ្វើ ការទាំងនោះនៅក្រុងយេរូសាឡិមបានទាំងចាប់ពួកអ្នកបរិសុទ្ធជាច្រើនយកទៅដាក់គុក ដោយទទួលអំណាចពីពួកសង្គ្រាជមក ហើយកាលគេសម្លាប់អ្នកទាំងនោះ ទូលបង្គំក៏យល់ព្រមដែរ ទូលបង្គំបានធ្វើទោសគេជាញឹកញយ នៅគ្រប់ទាំងសាលាប្រជុំទាំងបង្ខំឲ្យគេពោលពាក្យប្រមាថដល់ព្រះផង ហើយដោយព្រោះទូលបង្គំមានចិត្តក្តៅក្រហាយជ្រុលពេក ទាស់នឹងគេដូច្នេះ បានជាទូលបង្គំធ្វើទុក្ខបៀតបៀនដល់គេ រហូតដល់ក្រុងនៃសាសន៍ដទៃផង» (កិច្ចការ ២៦:៩-១១) ។

នៅពេលដែលមានគ្រោះថ្នាក់នេះ លោកនីកូដេមបានចេញមកប្រកាសដោយគ្មានភ័យខ្លាចអំពីជំនឿរបស់លោកក្នុងការឆ្កាងព្រះអង្គសង្គ្រោះ។ លោកនីកូដេមគឺជាសមាជិកនៃក្រុមប្រឹក្សាសាន់ហ៊ីឌ្រីន ហើយធ្លាប់បានធ្វើឲ្យរញ្ជួយដោយការបង្រៀនរបស់ព្រះយេស៊ូវ ជាមួយនឹងមនុស្សដទៃទៀតផងដែរ។ នៅពេលដែលលោកបានឃើញកិច្ចការដ៏អស្ចារ្យរបស់ព្រះគ្រិស្ដ លោកបានយល់យ៉ាងច្បាស់ថាអ្នកនេះពិតជាព្រះបានចាត់មកមែន។ ដោយមានអំនួតមិនហ៊ានបង្ហាញខ្លួននៅចំពោះការអាណិតអាសូរនៃគ្រូនៅស្រុកកាលីឡេនេះ លោកបានស្វែងរកឱកាសជួបទ្រង់ជាសម្ងាត់។ នៅក្នុងបទសម្ភាសន៍នេះ ព្រះយេស៊ូវបានបើកបង្ហាញដល់លោកអំពីផែនការនៃសេចក្ដីសង្គ្រោះ និងព្រះរាជបេសកកម្មរបស់ទ្រង់នៅលើផែនដី តែលោកនីកូដេមនៅតែស្ទាក់ស្ទើរ។ លោកបានលាក់សេចក្ដីពិតនៅតែក្នុងចិត្តរបស់លោក ហើយអស់រយៈពេលបីឆ្នាំ ឃើញមានផលផ្លែយ៉ាងតិចតួច។ ប៉ុន្តែ នៅពេលដែលលោកនីកូដេមមិនបានទទួលស្គាល់ព្រះគ្រិស្ដជាសាធារណៈ នៅក្នុងក្រុមប្រឹក្សាសាន់ហ៊ីឌ្រីន លោកបានរារាំងផែនការណ៍ចង់ធ្វើគុតព្រះយេស៊ូវរបស់ពួកសង្ឃជាច្រើនដង។ នៅទីចុងបំផុត ពេលដែលព្រះយេស៊ូវត្រូវគេឆ្កាង លោកបាននឹកឃើញព្រះបន្ទូលដែលព្រះអង្គមានបន្ទូល នៅក្នុងរាត្រីនៃបទសម្ភាសន៍មួយនៅភ្នំដើមអូលីវ «ហើយដែលលោកម៉ូសេបានលើកសត្វពស់ឡើង នៅទីរហោស្ថានជាយ៉ាងណា នោះកូនមនុស្សនឹងត្រូវគេលើកលោកឡើងយ៉ាងនោះដែរ» (យ៉ូហាន ៣:១៤) ហើយលោកបានមើលឃើញថាព្រះយេស៊ូវ គឺជាព្រះដែលជួយសង្គ្រោះមនុស្សលោក ។

លោកនីកូដេមបានចេញថ្លៃចំណាយជាច្រើន ជាមួយនឹងលោកយ៉ូសែបពីស្រុកអរីម៉ាថេ ក្នុងការបញ្ចុះព្រះសពព្រះយេស៊ូវ។ ពួកសិស្សមិនហ៊ានបង្ហាញខ្លួនថាជាសិស្សព្រះយេស៊ូវដោយចំហទេ ប៉ុន្តែ លោកនីកូដេមនិងលោកយ៉ូសែបបានចេញមុខជួយពួកគេដោយក្លាហាន។ ពួកសិស្សត្រូវការជំនួយពីអ្នកមានទ្រព្យសម្បត្តិ និងមានអំណាចបែបនេះជាខ្លាំង នៅក្នុងឱកាសដ៏ខ្មៅងងឹងនេះ។ ពួកលោកបានជួយដល់ព្រះគ្រូរបស់ពួកគេដែលបានសុគតទៅហើយ

នោះ នូវកិច្ចការដែលពួកសិស្សដ៏ក្រីក្រមិនអាចធ្វើបាន ហើយទ្រព្យសម្បត្តិនិងកិត្តិយសរបស់ពួកលោកបានការពារពួកគេឲ្យរួចពីការព្យាបាទរបស់ពួកសង្ឃ និងពួកមេដឹកនាំសាសនា។

ឥឡូវនេះ នៅពេលដែលសាសន៍យូដាកំពុងប្រឹងប្រែងបំផ្លាញពួកជំនុំដ៏ក្មេងខ្ចីនេះ លោកនីកូដេមបានចេញមុខការពារ។ លោកបានលើកទឹកចិត្តដល់ជំនឿរបស់ពួកសាវ័ក និងបានប្រើប្រាស់ទ្រព្យសម្បត្តិរបស់លោកដោយគ្មានការប្រុងប្រយ័ត្ន និងសង្ស័យតទៅទៀត ហើយដើម្បីជួយទ្រទ្រង់ពួកជំនុំនៅទីក្រុងយេរូសាឡិម និងដើម្បីជំរុញកិច្ចការនៃដំណឹងល្អ។ ពួកអ្នកដែលធ្លាប់តែគោរពដល់លោកកាលពីមុន ឥឡូវនេះបានប្រមាថនិងបៀតបៀនដល់លោកវិញ ហើយលោកបានត្រឡប់ជាអ្នកក្រីក្រទ្រព្យសម្បត្តិខាងលោកិយតែលោកមិនស្វាក់ស្ទើរក្នុងការការពារជំនឿរបស់លោកឡើយ ។

**<u>អាទិត្យ-២ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ២៣**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ដូច្នេះ កាលពួកសាសន៍សាម៉ារីបានមកដល់ទ្រង់ហើយនោះគេសូមទ្រង់ ឲ្យនៅជាមួយនឹងគេ ទ្រង់ក៏គង់នៅទីនោះអស់២ថ្ងៃ ហើយមានមនុស្សជាច្រើនទៀតបានជឿ ដោយសារព្រះបន្ទូលទ្រង់។ យ៉ូហាន ៤:៤០-៤១*

ការធ្វើទុក្ខបៀតបៀនដល់ពួកជំនុំនៅទីក្រុងយេរូសាឡិម បានផ្តល់កម្លាំងយ៉ាងធំដល់កិច្ចការនៃដំណឹងល្អ។ ជោគជ័យបានកើតឡើងដល់កិច្ចការនៅកន្លែងនោះ ហើយប្រសិនបើពួកសិស្សបន្តរស់នៅទីនោះយូរតទៅទៀតនោះនឹងមានគ្រោះថ្នាក់ជាក់ជាមិនខាន និងជាការមិនអើពើទៅនឹងការត្រាស់បង្គាប់របស់ព្រះអង្គសង្គ្រោះឲ្យចេញទៅគ្រប់ទីកន្លែងនៅលើពិភពលោកផង។ ដោយភ្លេចថាកម្លាំងដើម្បីទប់ទល់ជាមួយនឹងអារក្សកើតឡើងបានល្អបំផុតដោយសារកិច្ចការនៃការឈ្លានពាន ពួកគេបានចាប់ផ្តើមគិតថាពួកគេមិនមានកិច្ចការសំខាន់អ្វីដែលត្រូវធ្វើ ក្រៅពីការការពារពួកជំនុំនៅទីក្រុងយេរូសាឡិមពីការវាយប្រហារពីសំណាក់សត្រូវនោះឡើយ។ ជំនួសឲ្យការបង្រៀនដល់

អ្នកជឿថ្មីឲ្យពាំនាំយកដំណឹងល្អទៅប្រាប់ដល់អ្នកដែលមិនធ្លាប់បានឮ ពួកគេបិតនៅក្នុងគ្រោះថ្នាក់នៃការបំពេញកិច្ចការដែលនឹងដឹកនាំមនុស្សទាំងអស់ឲ្យស្កប់ចិត្តទៅនឹងកិច្ចការដែលអ្នកដទៃបានសម្រេចរួចហើយទៅវិញ ។ ព្រះបានអនុញ្ញាតឲ្យមានការធ្វើទុក្ខបៀតបៀនកើតឡើងដល់ពួកគេ ដើម្បីបំបែកព្រះរាជតំណាងរបស់ទ្រង់ទៅកាន់គ្រប់ទិសទី ជាកន្លែងដែលពួកគេអាចធ្វើការសម្រាប់អ្នកដទៃបាន។ ដោយការបណ្តេញចេញពីទីក្រុងយេរូសាឡិម ពួកសាវ័កបាន «ដើរចុះឡើងទាំងផ្សាយដំណឹងល្អ គឺជាព្រះបន្ទូល» ។

នៅក្នុងចំណោមពួកអ្នកដែលព្រះបានប្រទានព្រះរាជបញ្ជាឲ្យ «ទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍» (ម៉ាថាយ ២៨:១៩) មានមនុស្សជាច្រើនដែលជាអ្នកមានជីវិតទន់ទាបបំផុត ជាបុរសនិងនារីដែលបានស្រឡាញ់ព្រះជាម្ចាស់ និងបានប្តេជ្ញាចិត្តដើរតាមគំរូនៃការបម្រើមិនអាត្មានិយមរបស់ព្រះអង្គ។ ព្រះបានប្រទានកិច្ចការដ៏មានតម្លៃដល់ពួកអ្នកទន់ទាបទាំងនេះ ព្រមទាំងពួកសិស្សដែលធ្លាប់បាននៅជាមួយព្រះអង្គ កាលទ្រង់បំពេញព្រះរាជកិច្ចនៅលើផែនដី។ ពួកគេត្រូវពាំនាំសេចក្តីស្រឡាញ់នៃសេចក្តីសង្គ្រោះទៅកាន់ពិភពលោកទាំងមូល។

នៅពេលដែលពួកគេត្រូវបានបែកខ្ញែកដោយការធ្វើទុក្ខបៀតបៀន ពួកគេបានចេញទៅទាំងមានចិត្តពុះកញ្ជ្រោលចង់ផ្សាយដំណឹងល្អ។ ពួកគេបានដឹងពីការទទួលខុសត្រូវនៃបេសកកម្មរបស់ពួកគេ។ ពួកគេបានដឹងថាពួកគេមានដំប៉ុងជីវិតនៅនឹងដៃ សម្រាប់ចែកចាយដល់ពិភពលោកដែលកំពុងអត់ឃ្លាន ហើយសេចក្តីស្រឡាញ់របស់ព្រះគ្រិស្តបានបង្គាប់ឲ្យពួកគេកាច់នំប៉ុងនេះចែកដល់មនុស្សទាំងឡាយ ដែលមានសេចក្តីត្រូវការ។ ព្រះជាម្ចាស់បានធ្វើការតាមរយៈពួកគេ។ ពួកគេទៅដល់កន្លែងណា ពួកគេបានព្យាបាលអ្នកជំងឺ បានផ្សាយដំណឹងល្អដល់អ្នកក្រីក្រ នៅទីនោះ ។

លោកភីលីព ជាមនុស្សម្នាក់នៅក្នុងចំណោមអ្នកជំនួយការទាំងប្រាំពីរនាក់នោះ ក៏នៅក្នុងចំណោមអ្នកដែលរត់គេចចេញពីទីក្រុងយេរូសាឡិមដែរ។ លោក «ចុះទៅឯទីក្រុងមួយនៅស្រុកសាម៉ារី ប្រាប់គេពីព្រះគ្រិស្ត

ហើយបណ្ដាមនុស្សក៏ស្រុះចិត្តគ្នា និងប្រុងស្ដាប់អស់ទាំងសេចក្ដីដែលភីលីពនិយាយ ដោយគេឮ ហើយឃើញទីសម្គាល់ដែលគាត់ធ្វើ ព្រោះមានអារក្សអសោច ...រួចចេញមក ក៏មានមនុស្សស្លាប់ដៃស្លាប់ជើង និងមនុស្សខ្វិនជាច្រើនបានជាដែរ ហើយនៅទីក្រុងនោះ គេមានសេចក្ដីអំណរជាខ្លាំង» ។

ព្រះរាជសាររបស់ព្រះគ្រិស្ត ដែលបានមានបន្ទូលទៅកាន់ស្ត្រីសាសន៍សាម៉ារីបានបង្កើតផលផ្លែ។ បន្ទាប់ពីបានស្ដាប់ព្រះបន្ទូលរបស់ទ្រង់រួចមក ស្ត្រីនោះក៏បានចូលទៅក្នុងទីក្រុង ដោយនិយាយថា «ចូរមកមើល មានមនុស្សម្នាក់ ដែលប្រាប់ខ្ញុំពីគ្រប់អំពើទាំងអស់ ដែលខ្ញុំបានប្រព្រឹត្ត តើអ្នកនោះមិនមែនជាព្រះគ្រិស្តទេឬអី?» ពួកគេក៏បានចេញទៅជាមួយនាង ហើយបានស្ដាប់ព្រះយេស៊ូវ រួចក៏បានជឿដល់ទ្រង់។ ព្រះអង្គបានស្នាក់នៅជាមួយពួកគេពីរថ្ងៃ «ហើយមានមនុស្សជាច្រើនទៀតបានជឿ ដោយសារព្រះបន្ទូលទ្រង់» (យ៉ូហាន ៤២:៩, ៤១) ។

**<u>ច័ន្ទ-៣ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាំយូអែលទី២ ជំពូក ២៤**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ឯភីលីព គាត់ចុះទៅឯទីក្រុង១នៅស្រុកសាម៉ារី ប្រាប់គេពីព្រះគ្រីស្ទ ហើយបណ្ដាមនុស្សក៏ស្រុះចិត្តគ្នា និងប្រុងស្ដាប់អស់ទាំងសេចក្ដីដែលភីលីពនិយាយ ដោយគេឮ ហើយឃើញទីសំគាល់ដែលគាត់ធ្វើ។ កិច្ចការ ៨:៥-៦*

ហើយនៅពេលដែលពួកសិស្សត្រូវបានបណ្ដេញចេញពីទីក្រុងយេរូសាឡិម ពួកគេមួយចំនួនរកបានសិទ្ធិជ្រកកោននៅស្រុកសាម៉ារី។ ពួកសាសន៍សាម៉ារីបានស្វាគមន៍ដល់ពួកអ្នកនាំសារនៃដំណឹងល្អទាំងនេះ ហើយពួកសាសន៍យូដាដែលបានកែប្រែចិត្តបានប្រមូលផលដ៏មានតម្លៃចេញពីអ្នកដែលធ្លាប់ជាសត្រូវដ៏ជូរចត់របស់ពួកគេ។

កិច្ចការរបស់លោកភីលីពនៅស្រុកសាម៉ារីទទួលបានជោគជ័យយ៉ាងធំធេង ដោយការលើកទឹកចិត្តយ៉ាងដូច្នេះ គេក៏បញ្ជូនលោកឲ្យទៅជួយនៅទីក្រុងយេរូសាឡិមវិញ។ ឥឡូវនេះ ពួកសិស្សបានយល់កាន់តែច្បាស់អំពីព្រះ

បន្ទូលរបស់ព្រះគ្រិស្តថា «នោះអ្នករាល់គ្នានឹងបានព្រះចេស្តា ហើយនិងធ្វើជាទីបន្ទាល់ពីខ្ញុំ នៅក្រុងយេរូសាឡិម ព្រមទាំងស្រុកយូដា និងស្រុកសាម៉ារីទាំងមូល ហើយរហូតដល់ចុងផែនដីបំផុតផង» ( កិច្ចការ ១:៨) ។

កាលលោកភីលីពនៅស្រុកសាម៉ារីនៅឡើយ ទេវតាដែលជាអ្នកនាំសាររបស់ព្រះបានណែនាំដល់លោកថា «ចូរក្រោកឡើងទៅឯខាងត្បូង តាមផ្លូវដែលចុះពីក្រុងយេរូសាឡិម ទៅឯក្រុងកាសា ...គាត់ក៏ក្រោកឡើងដើរទៅ»។ លោកមិនបានសួរនាំទៅនឹងការត្រាស់បង្គាប់នេះ ឬស្ទាក់ស្ទើរក្នុងការស្តាប់បង្គាប់ឡើយ ព្រោះលោកបានរៀនសូត្រនូវមេរៀននៃភាពម៉ឺងម៉ាត់នៃព្រះហឫទ័យរបស់ព្រះនេះ ។

«នោះឃើញមានសាសន៍អេធីយ៉ូពីម្នាក់ ជាមនុស្សកម្រៀវដែលមានអំណាចក្រោមព្រះនាងកានដេស មហាក្សត្រីដែលសោយរាជ្យក្នុងស្រុកអេធីយ៉ូពី លោកជាអ្នកត្រួតត្រាលើអស់ទាំងព្រះរាជទ្រព្យរបស់ស្តេច ហើយបានមកឯក្រុងយេរូសាឡិម ដើម្បីនឹងថ្វាយបង្គំ ។ លោកកំពុងតែជិះរថត្រឡប់ទៅវិញក៏មើលគម្ពីរហោរាអេសាយ»។ បុរសអេធីយូពីម្នាក់នេះគឺជាមនុស្សដែលមានជំហរល្អ និងមានឥទ្ធិពលទូលំទូលាយ។ ព្រះបានទតឃើញថា នៅពេលដែលបុរសនេះផ្លាស់ប្តូរជំនឿ គាត់អាចចែកចាយពន្លឺដែលគាត់បានទទួលនោះ ដល់មនុស្សដទៃហើយនិងបន្ថែមឥទ្ធិពលយ៉ាងខ្លាំងក្លាដល់កិច្ចការនៃដំណឹងល្អ។ ទេវតារបស់ព្រះបានគង់នៅជាមួយនឹងបុរសដែលស្វែងរកពន្លឺរូបនេះ ហើយទេវតាក៏បានទាញគាត់មកឯព្រះអង្គសង្គ្រោះ។ ព្រះបាននាំគាត់ឲ្យជួបជាមួយនឹងអ្នកដែលអាចដឹកនាំគាត់ទៅឯពន្លឺ ដោយសារកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ។ ទេវតាបានណែនាំលោកភីលីពឲ្យទៅជួបជាមួយនឹងបុរសអេធីយូពី ហើយពន្យល់គាត់អំពីបទទំនាយដែលគាត់កំពុងអាន។ ព្រះវិញ្ញាណបានមានបន្ទូលថា «ឲ្យចូលទៅប្រកៀកនឹងរថនោះទៅ»។ នៅពេលលោកភីលីពបានចូលទៅជិតហើយលោកក៏សួរទៅអ្នកកម្រៀវនោះថា «លោកមើលយល់ឬទេ ឯលោកក៏ឆ្លើយឡើងថា បើគ្មានអ្នកណាដឹកនាំខ្ញុំ នោះធ្វើដូចម្តេចឲ្យយល់បាន រួចលោកក៏

សូមឲ្យភីលីពឡើងជិះរថជាមួយគ្នា»។ បទគម្ពីរដែលគាត់កំពុងអាននោះគឺជាបទទំនាយរបស់ហោរាអេសាយ ទាក់ទងទៅនឹងព្រះគ្រិស្តៈ «ទ្រង់ត្រូវគេដឹកនាំទៅ ដូចជាដឹកចៀមទៅសម្លាប់ ទ្រង់មិនបានហើបព្រះឱស្ឋសោះ ដូចជាកូនចៀមដែលគ នៅមុខអ្នកកាត់រោមវា នៅគ្រាដែលទ្រង់ត្រូវបន្ទាបបន្ថោក នោះគេបានដកសេចក្ដីយុត្តិធម៌ចេញពីទ្រង់ទៅ តើអ្នកណានឹងថ្លែងពីព្រះវង្សាទ្រង់បាន ដ្បិតគេបានដកព្រះជន្មទ្រង់ពីផែនដីចេញហើយ» ។

អ្នកកម្រៀវនោះសួរភីលីពថា «តើហោរានិយាយដូច្នេះ គឺនិយាយពីអ្នកណាពីខ្លួនលោកឬពីអ្នកដទៃ?» បន្ទាប់មកលោកភីលីបបានបើកបង្ហាញដល់គាត់អំពីសេចក្ដីពិតដ៏ធំ។ ដោយចាប់ផ្ដើមពីជំពូកដដែលនេះ គឺលោក «ប្រាប់ដំណឹងល្អពីព្រះយេស៊ូវ»។

ចិត្តរបស់បុរសនេះមានចំណាប់អារម្មណ៍ជាខ្លាំង នៅពេលដែលលោកភីលីពបានពន្យល់បទគម្ពីរនេះដល់គាត់ ហើយនៅពេលដែលសិស្សរូបនេះបានបញ្ចប់ គាត់បានរៀបចំខ្លួនរួចជាស្រេចដើម្បីនឹងទទួលពន្លឺដែលលោកពេព្រុសបានផ្ដល់ឲ្យ ។ គាត់មិនបានយកតំណែងខ្ពង់ខ្ពស់របស់គាត់មកធ្វើជាលេសដើម្បីបដិសេធដំណឹងល្អឡើយ។ «ហើយអ្នកកម្រៀវនិយាយថា មើល នុ៎ះន៏ទឹក តើមានអ្វីឃាត់មិនឲ្យខ្ញុំទទួលបុណ្យជ្រមុជទឹកបាន ភីលីពឆ្លើយថា បើលោកជឿអស់ពីចិត្ត នោះទទួលបាន លោកឆ្លើយឡើងថា ខ្ញុំជឿហើយ ថាព្រះយេស៊ូវគ្រិស្តជាព្រះរាជ្យបុត្រានៃព្រះ នោះលោកបង្គាប់ឲ្យបញ្ឈប់រថ រួចភីលីពនិងអ្នកកម្រៀវ ក៏ចុះទៅក្នុងទឹកទាំងពីរនាក់ ហើយភីលីព គាត់ធ្វើបុណ្យជ្រមុជទឹកឲ្យ» ។

«លុះឡើងពីទឹកមក នោះព្រះវិញ្ញាណនៃព្រះអម្ចាស់ ទ្រង់ឆក់យកភីលីពបាត់ទៅ ហើយអ្នកកម្រៀវមិនបានឃើញគាត់ទៀតទេ ក៏ទៅតាមផ្លូវទៅដោយអរសប្បាយ ឯភីលីព គេបានឃើញគាត់នៅក្រុងអាសូតវិញ គាត់ក៏ដើរទៅទាំងផ្សាយដំណឹងល្អនៅគ្រប់អស់ទាំងទីក្រុងរៀងទៅ រហូតទៅដល់ក្រុងសេសារា» ។

អង្គារ-៤ សីហា អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតាក្សត្រទី១ ជំពូក ១

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *នោះទេវតានៃព្រះអម្ចាស់ មានព្រះបន្ទូលទៅភីលីពថា ចូរក្រោកឡើងទៅឯខាងត្បូង តាមផ្លូវដែលចុះពីក្រុងយេរូសាឡិម ទៅឯក្រុងកាសា ដែលជាទីរហោស្ថានទៅ គាត់ក៏ក្រោកឡើងដើរទៅ នោះឃើញមានសាសន៍អេធីយ៉ូពីម្នាក់ ជាមនុស្សកំរៀវ ដែលមានអំណាចក្រោមព្រះនាងកានដេស មហាក្សត្រីដែលសោយរាជ្យក្នុងស្រុកអេធីយ៉ូពី លោកជាអ្នកត្រួតត្រាលើអស់ទាំងព្រះរាជទ្រព្យរបស់ស្តេច ហើយបានមកឯក្រុងយេរូសាឡិម ដើម្បីនឹងថ្វាយបង្គំ។ កិច្ចការ ៨:២៦-២៧*

បុរសអេធីយូពីម្នាក់នេះតំណាងឲ្យមនុស្សដែលមានឋានៈខ្ពស់ជាច្រើន ដែលត្រូវការបង្រៀនពីបេសកជនដូចលោកភីលីព ជាពួកមនុស្សដែលនឹងឮព្រះបន្ទូលរបស់ព្រះ និងសុខចិត្តចេញទៅកន្លែងណាដែលព្រះចាត់គេឲ្យទៅ។ មានមនុស្សជាច្រើនដែលកំពុងអានព្រះគម្ពីរតែមិនយល់អត្ថន័យ។ មនុស្សទាំងប្រុសទាំងស្រីនៅលើពិភពលោកកំពុងរង់ចាំនគរឋានសួគ៌ដោយចិត្តអន្ទះសា។ សេចក្តីអធិដ្ឋាននិងទឹកភ្នែកនិងការអង្វរករបានផុសចេញពីចិត្តរបស់មនុស្សដែលចង់បានពន្លឺ ព្រះគុណ និងព្រះវិញ្ញាណបរិសុទ្ធ។ មនុស្សជាច្រើនដែលកំពុងឈរនៅព្រំដែននៃនគររបស់ព្រះរង់ចាំការអញ្ជើញឲ្យចូលទៅខាងក្នុង ។

ទេវតាបានដឹកនាំលោកភីលីពទៅជួបនឹងបុរសដែលកំពុងស្វែងរកពន្លឺ និងជាអ្នកដែលបានរៀបចំខ្លួនទទួលដំណឹងល្អ ហើយសព្វថ្ងៃនេះ ទេវតាក៏នឹងដឹកនាំជំហានរបស់អ្នកធ្វើការដែលអនុញ្ញាតឲ្យព្រះវិញ្ញាណបរិសុទ្ធសម្អាតអណ្តាតរបស់គេ និងជម្រះ ព្រមទាំងពង្រឹងដល់ចិត្តរបស់ពួកគេ ដូចគ្នាដែរ ។ ទេវតាដែលព្រះបានចាត់ឲ្យទៅឯលោកភីលីពនោះ អាចធ្វើការជាមួយនឹងបុរសអេធីយូពីនោះដោយខ្លួនឯងបាន ប៉ុន្តែ នោះមិនមែនជារបៀបដែលព្រះធ្វើការទេ  ផែនការរបស់ព្រះគឺឲ្យមនុស្សធ្វើការជាមួយនឹងមនុស្សដូចគ្នា ។

កិច្ចការដែលព្រះបានប្រទានដល់ពួកសិស្សដំបូង ពួកអ្នកជឿគ្រប់ជំនាន់ក៏មានចំណែកដូចគ្នាដែរ។ ព្រះបានប្រទានសេចក្តីពិតដ៏ពិសិដ្ឋដល់អ្នកដែល

បានទទួលដំណឹងល្អឲ្យចែកចាយសេចក្តីពិតដល់ពិភពលោកទាំងមូល។ រាស្ត្ររបស់ព្រះដែលស្មោះត្រង់ តែងតែជាបេសកជនដ៏ក្លៀវក្លា ថ្វាយធនធានរបស់ខ្លួនដើម្បីលើកតម្កើងព្រះនាមរបស់ទ្រង់ និងប្រើប្រាស់អំណោយទានរបស់ខ្លួនដោយប្រុងប្រយ័ត្ន នៅក្នុងព្រះរាជកិច្ចរបស់ទ្រង់។

អ្នកបម្រើការជាគ្រិស្តបរិស័ទនៅសម័យដើម គឺជាមេរៀននិងជាការលើកទឹកចិត្តសម្រាប់យើង។ សមាជិកនៃពួកជំនុំរបស់ព្រះ ត្រូវតែមានចិត្តពុះពោរចង់បំពេញកិច្ចការល្អៗ ដោយញែកខ្លួនចេញពីការលោភលន់ខាងលោកិយ និងដើរតាមលំអានរបស់ព្រះដែលបានយាងចុះឡើងធ្វើការល្អ។ ពួកគេត្រូវតែធ្វើការបម្រើដល់អ្នកដែលមានសេចក្តីត្រូវការជំនួយ ដោយចិត្តពោរពេញទៅដោយសេចក្តីមេត្តានិងការអាណិតអាសូរ ដោយនាំនូវចំណេះដឹងពីសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះទៅចែកដល់បាបជនទាំងឡាយ។ ការងារបែបនេះទាមទារនូវការខំប្រឹងប្រែង ប៉ុន្តែ នឹងនាំមកនូវរង្វាន់ជាច្រើន។ អ្នកដែលចូលរួមនៅក្នុងការងារនេះដោយចិត្តស្មោះស្ម័គ្រ នឹងឃើញមនុស្សចូលមកឯព្រះអង្គសង្គ្រោះ ព្រោះឥទ្ធិពលដែលចូលរួមនៅក្នុងការបំពេញបេសកកម្មរបស់ព្រះនោះមិនមានអ្នកណាអាចទប់ទល់បានឡើយ ។

ការទទួលខុសត្រូវក្នុងការចេញទៅបំពេញព្រះរាជបេសកកម្មរបស់ព្រះនេះមិនមែនបិតនៅតែលើគ្រូគង្វាលពេញសិទ្ធិប៉ុណ្ណោះទេ។ ព្រះអង្គបានត្រាស់ហៅមនុស្សទាំងអស់ដែលបានទទួលព្រះគ្រិស្តឲ្យធ្វើការដើម្បីសេចក្តីសង្គ្រោះរបស់មនុស្សលោក។ «ព្រះវិញ្ញាណ និងប្រពន្ធថ្មោងថ្មីពោលថា អញ្ជើញមក ហើយអ្នកណាដែលឮ ក៏ថា អញ្ជើញមកដែរ» (វិវរណៈ ២២:១៧) ការអំពាវនាវឲ្យទទួលសេចក្តីអញ្ជើញនេះ រាប់បញ្ចូលទាំងពួកជំនុំទាំងមូលផងដែរ។ អ្នករាល់គ្នាដែលបានឮសេចក្តីអញ្ជើញនេះត្រូវតែកំពុងបន្ត ចេញពីជ្រោះជ្រងជ្រលងដងភ្នំ ដោយនិយាយថា «អញ្ជើញមក» ។

ការដែលសន្មតិថាកិច្ចការនេសាទមនុស្សគឺជាភារកិច្ចរបស់គ្រូគង្វាលតែម្នាក់ឯង គឺជាកំហុសមួយយ៉ាងធ្ងន់ធ្ងរ។ បងប្អូនអ្នកជឿដ៏សុភាពរាបសាដែលម្ចាស់ចម្ការទំពាំងបាយជូរបានប្រគល់បន្ទុកនៃការនេសាទមនុស្សឲ្យ

ត្រូវតែផ្តល់ការលើកទឹកចិត្តដោយមនុស្សដែលព្រះប្រទានការទទួលខុសត្រូវធំៗ។ អស់អ្នកដែលឈរជាអ្នកដឹកនាំពួកជំនុំរបស់ព្រះ ត្រូវតែដឹងថាព្រះបានប្រទានព្រះរាជបញ្ជាដល់មនុស្សទាំងអស់ ដែលជឿដល់ព្រះនាមរបស់ទ្រង់។ ព្រះនឹងចាត់មនុស្សឲ្យទៅធ្វើការនៅក្នុងចម្ការទំពាំងបាយជូររបស់ទ្រង់ ដែលមិនទាន់បានញែកឲ្យបំពេញកិច្ចការរបស់ទ្រង់ ដោយការដាក់ដៃពីលើនៅឡើយ ។

មនុស្សរាប់រយ រាប់ពាន់នាក់ដែលបានឮសារនៃសេចក្តីសង្គ្រោះកំពុងត្រេតត្រតនៅឯទីផ្សារនៅឡើយ នៅពេលដែលពួកគេគួរតែចូលរួមនៅក្នុងកិច្ចការដ៏សកម្មផ្នែកណាមួយនោះ។ ព្រះគ្រិស្តកំពុងមានបន្ទូលទៅកាន់ពួកអ្នកទាំងនេះថា «ហេតុអ្វីបានជាអ្នករាល់គ្នាឈរទំនេរនៅទីនេះ តាំងពីព្រលឹមមកដូច្នេះ?» រួចទ្រង់ប្រាប់ថា «ចូរអ្នករាល់គ្នាទៅធ្វើការក្នុងចម្ការរបស់ខ្ញុំទៅនោះអ្នកនឹងទទួលឈ្នួលតាមត្រឹមត្រូវ» (ម៉ាថាយ ២០:៦, ៧) ។ តើហេតុអ្វីបានជាមនុស្សជាច្រើនមិនឆ្លើយតបទៅនឹងការត្រាស់ហៅនេះ? តើមិនមែនដោយគេយកលេសថាគេមិនមានភារកិច្ចឈរនៅលើអាសនាទេឬអី? សូមឲ្យពួកគេយល់ថាមានកិច្ចការយ៉ាងធំដែលអ្នកស្ម័គ្រចិត្តរាប់ពាន់នាក់ត្រូវបំពេញនៅក្រៅអាសនា ។

ព្រះបានរង់ចាំឲ្យព្រះវិញ្ញាណនៃការងារគង់នៅលើពួកជំនុំទាំងមូលជាយូរយារ ដើម្បីឲ្យមនុស្សគ្រប់គ្នាធ្វើកិច្ចការស្របទៅតាមសមត្ថភាពរបស់ខ្លួន។ នៅពេលដែលសមាជិកនៃពួកជំនុំរបស់ព្រះធ្វើកិច្ចការរបស់គេ ដែលព្រះបានចាត់តាំង នៅតាមទីកន្លែងដែលមានសេចក្តីត្រូវការ នៅតាមផ្ទះ និងនៅក្រៅប្រទេស ដើម្បីសម្រេចតាមការត្រាស់បង្គាប់នៃដំណឹងល្អ មិនយូរទេ ពិភពលោកទាំងមូលនឹងត្រូវបានប្រកាសប្រាប់ឲ្យដឹង ហើយព្រះយេស៊ូវនឹងយាងត្រឡប់មកកាន់ផែនដីវិញ ដោយព្រះចេស្តា និងសិរីរុងរឿង។ «ដំណឹងល្អនេះ ដែលសម្តែងពីនគរ នឹងត្រូវប្រកាសប្រាប់ទូទៅគ្រប់ក្នុងលោកិយ ទុកជាទីបន្ទាល់ដល់អស់ទាំងសាសន៍ នោះទើបនឹងបានដល់ចុងបំផុត» (ម៉ាថាយ ២៤:១៤) ។

ជំពូកទី
១២

# ពីអ្នកបៀតបៀន មកជាសិស្ស

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ៩:១-១៨ ។*

<u>ពុធ-៥ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ ជំពូក ២

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ប៉ុន្តែ សេចក្តីអ្វីដែលមានប្រយោជន៍ដល់ខ្ញុំពីមុន នោះខ្ញុំបានរាប់ជាខាតវិញ ដោយព្រោះព្រះគ្រីស្ទ ។ ភីលីព ៣:៧*

អ្នកដែលលេចធ្លោជាងគេ នៅក្នុងចំណោមអ្នកដឹកនាំសាសន៍យូដាដែលបានភ្ញាក់រឭកដោយសារជោគជ័យនៃការចូលរួមនៅក្នុងការប្រកាសដំណឹងល្អនោះ គឺលោកសុលមកពីតើសុស។ ទោះបីជាមានសញ្ជាតិជាសាសន៍រ៉ូមពីកំណើតក៏ដោយ ក៏លោកសុលជាជនជាតិយូដាដោយការប្តូរសញ្ជាតិ ហើយបានសិក្សានៅទីក្រុងយេរូសាឡិមដោយគ្រូអាចារ្យដ៏ខ្ពស់បំផុតដែរ។ លោកសុលគឺជា «សាសន៍អ៊ីស្រាអែល ក្នុងពូជអំបូរបេនយ៉ាមីន ជាអ្នកហេព្រើរកើតពីពួកហេព្រើរ ឯខាងក្រឹត្យវិន័យ នោះខ្ញុំជាពួកផារិស៊ី ខាងឯសេចក្តីឧស្សាហ៍ នោះខ្ញុំជាអ្នកដែលបានធ្វើទុក្ខបៀតបៀនដល់ពួកជំនុំ ចំណែកខាងសេចក្តីសុចរិតក្នុងក្រឹត្យវិន័យ នោះខ្ញុំគ្មានទោសសោះ» (ភីលីព ៣:៥, ៦) ។ ពួកគ្រូអាចារ្យបានចាត់ទុកលោកជាយុវជននៃសេចក្តីសន្យាដ៏ឧត្តមម្នាក់ ហើយពួកគេមានសេចក្តីសង្ឃឹមយ៉ាងខ្ពស់ទៅលើលោកថា ជាអ្នកការពារជំនឿពីបុរាណរបស់ពួកគេ។ ការលើកតម្កើងលោកជាសមាជិកនៃក្រុមប្រឹក្សាសាន់ហ៊ីឌ្រីនបានដាក់លោកនៅក្នុងមុខតំណែងមួយដ៏មានអំណាច។

លោកសុលបានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការជំនុំជម្រះនិងកាត់ទោសលោកស្ទេផាន ហើយភស្តុតាងយ៉ាងរន្ធត់នៃព្រះវត្តមានរបស់ព្រះ ដែល

គង់នៅជាមួយនឹងទុក្ករបុគ្គលនេះបានដឹកនាំលោកសុលឲ្យសង្ស័យអំពីសេចក្ដីសុចរិត នៃកិច្ចការដែលលោកបានប្រកាន់ទាស់នឹងពួកសិស្សរបស់ព្រះយេស៊ូវ។ មានការច្របូកច្របល់ក្នុងគំនិតរបស់លោកជាខ្លាំង។ នៅក្នុងភាពអល់អែក លោកបានអំពាវនាវដល់អ្នកដែលមានទំនុកចិត្តទាំងស្រុងទៅលើប្រាជ្ញានិងការវិនិច្ឆ័យរបស់ពួកគេ។ ទីបំផុត ការតវ៉ារបស់ពួកសង្ឃនិងពួកមេដឹកនាំសាសនាបានធ្វើឲ្យលោកជឿថាលោកស្ទេផានគឺជាជនដែលប្រមាថមើលងាយ ហើយថាព្រះគ្រិស្ដដែលពួកសាវ័កជឿជាក់ប្ដូរផ្ដាច់រហូតហ៊ានលះបង់ជីវិតបានអធិប្បាយនោះគឺជាជនក្លែងបន្លំខ្លួន និងថាពួកអ្នកដែលបម្រើការនៅក្នុងកន្លែងបរិសុទ្ធគឺជាមនុស្សត្រឹមត្រូវ។

លោកសុលបានធ្វើការសន្និដ្ឋានដូច្នេះ ដោយគ្មានការសាកល្បងឲ្យបានច្បាស់លាស់ឡើយ។ ប៉ុន្តែ ទីបំផុត នៅក្នុងចំណេះដឹងនិងការប្រកាន់ពូជសាសន៍របស់លោក ការគោរពរបស់លោកដល់អតីតគ្រូបង្រៀន ព្រមទាំងអំនួតនៃប្រជាប្រិយរបស់លោក បានជំរុញលោកឲ្យប្រឆាំងបះបោរជាមួយនឹងសំឡេងនៃសម្បជញ្ញៈ និងព្រះគុណរបស់ព្រះ។ ហើយដោយបានសម្រេចថាពួកសង្ឃនិងពួកអាចារ្យត្រូវទាំងស្រុង នោះលោកសុលបានក្លាយជាសត្រូវដ៏ជូរចត់ជាមួយនឹងគោលលទ្ធិដែលពួកសិស្សរបស់ព្រះយេស៊ូវបានបង្រៀន។ សកម្មភាពរបស់លោកក្នុងការកៀបសង្កត់ឲ្យបុរសនិងនារីបរិសុទ្ធទាំងឡាយត្រូវប្រឈមមុខនៅចំពោះតុលាការ ជាកន្លែងដែលមនុស្សមួយចំនួនត្រូវបានចោទប្រកាន់ឲ្យត្រូវជាប់គុក ហើយខ្លះទៀតត្រូវប្រហារជីវិតដោយសារតែជំនឿរបស់ពួកគេ ទៅលើព្រះយេស៊ូវនោះ បាននាំមកនូវភាពក្រៀមក្រំនិងទុក្ខវេទនាដល់ពួកជំនុំដែលទើបតែនឹងបានរៀបចំថ្មីថ្មោង ហើយបណ្ដាលឲ្យមនុស្សជាច្រើនស្វែងរកកន្លែងមានសុវត្ថិភាពដោយការរត់គេចខ្លួន។

ពួកអ្នកដែលត្រូវបានបណ្ដេញចេញពីទីក្រុងយេរូសាឡិម ដោយការធ្វើទុក្ខបៀតបៀននេះ «គេដើរចុះឡើងទាំងផ្សាយដំណឹងល្អ គឺជាព្រះបន្ទូល» (កិច្ចការ ៨:៤)។ នៅក្នុងចំណោមទីក្រុងទាំងឡាយដែលពួកគេបានភៀសខ្លួន

ទៅនោះ គឺទីក្រុងដាម៉ាស ជាកន្លែងដែលពួកអ្នកជឿថ្មីទទួលបានអ្នកកែប្រែចិត្តទទួលជឿជាច្រើននាក់។

<u>ព្រហស្បតិ៍-៦ សីហា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ ជំពូក ៣ ខ**

**ព្រះគម្ពីរប្រចាំថ្ងៃ:** *ប៉ុន្តែ កំពុងដែលគាត់ដើរតាមផ្លូវ ទៅជិតនឹងដល់ក្រុងដាម៉ាសហើយ នោះស្រាប់តែមានពន្លឺពីលើមេឃ ភ្លឺមកនៅជុំវិញខ្លួន គាត់ក៏ដួលដល់ដី រួចឮសំឡេងមានព្រះបន្ទូលមកថា សុល នែសុល ហេតុអ្វីបានជាអ្នកបៀតបៀនដល់ខ្ញុំដូច្នេះ គាត់ទូលឆ្លើយថា ឱព្រះអម្ចាស់អើយ ព្រះអង្គណានុ៎ះ រួចព្រះអម្ចាស់ទ្រង់តបថា ខ្ញុំនេះជាព្រះយេស៊ូវ ដែលអ្នកបៀតបៀន អ្នកធាក់ជល់នឹងជន្លួញដូច្នេះ នោះពិបាកដល់អ្នកណាស់។ កិច្ចការ ៩:៣-៥*

ពួកសង្ឃនិងពួកមេដឹកនាំសាសនាបានសង្ឃឹមថា ដោយការខំប្រឹងប្រែងយ៉ាងប្រុងប្រយ័ត្ននិងការធ្វើទុក្ខបៀតបៀនយ៉ាងតឹងរ៉ឹង ពួកអ្នកមានជំនឿនឹងត្រូវបានបង្ក្រាប។ ឥឡូវនេះ ពួកគេបានគិតថា ពួកគេត្រូវតែពង្រីកការធ្វើទុក្ខបៀតបៀនប្រឆាំងទៅនឹងការបង្រៀនថ្មី ដែលពួកគេបានអនុវត្តនៅទីក្រុងយេរូសាឡិមនិងកន្លែងផ្សេងៗទៀត។ សម្រាប់កិច្ចការពិសេសដែលពួកគេបានសម្រេចចិត្តនឹងបង្ហើយនៅទីក្រុងដាម៉ាស លោកសុលបានស្ម័គ្រចិត្តចេញទៅបំពេញភារកិច្ចនេះ។ «ឯសុល គាត់នៅតែបញ្ចេញសេចក្តីគំរាម និងពាក្យកំហែង ព្រមទាំងការសម្លាប់ ដល់ពួកសិស្សនៃព្រះអម្ចាស់នៅឡើយ» លោក «ក៏ទៅឯសម្តេចសង្ឃ សូមសំបុត្រកាន់យកទៅឯសាលាប្រជុំទាំងប៉ុន្មាន នៅក្រុងដាម៉ាស ប្រយោជន៍ដើម្បី បើឃើញមានអ្នកណាខ្លះ ដែលប្រតិបត្តិតាមផ្លូវនោះ ទោះប្រុសឬស្រីក្តី នោះនឹងចាប់ចងគេ នាំមកឯក្រុងយេរូសាឡិម។ នោះ «ទូលបង្គំបានទទួលអំណាច និងសេចក្តីបង្គាប់មកពីពួកសង្គ្រាជ» (កិច្ចការ ២៦:១២) ដោយកម្លាំងនិងសម្បទារបស់មនុស្ស និងភ្លើងនៃចិត្តពុះកញ្ជ្រោលក្នុងការប្រព្រឹត្តខុស លោកសុលនៃស្រុកតើសុសបានចេញដំណើរដែលមិនអាចបំភ្លេចបាននោះ មានហេតុការណ៍ដ៏ចម្លែក

មួយបានកើតឡើង ដែលបានផ្លាស់ប្តូរខ្សែជីវិតទាំងស្រុង ។

នៅចុងក្រោយបង្អស់នៃការធ្វើដំណើរនេះ «នៅកណ្តាលថ្ងៃត្រង់» ពេលដែលអ្នកធ្វើដំណើរយ៉ាងហោរហាត់បានមកជិតដល់ទីក្រុងដាម៉ាស ពួកគេបានមកដល់វាលដ៏សំបូរជីវជាតិមួយ ដែលមានសួនច្បារស្រស់បំព្រង និងផល្លានុផលជាច្រើន ស្រោចស្រពដោយទឹកជ្រោះដែលហូរមកពីជួរភ្នំដែលព័ទ្ធជុំវិញ ។ ក្រោយពីការធ្វើដំណើរកាត់វាលយ៉ាងកណ្តោចកណ្តែងអស់ពេលជាច្រើនថ្ងៃមក ទស្សនីយភាពបែបនេះ ពិតជាធ្វើឲ្យអារម្មណ៍រីករាយយ៉ាងក្រៃលែង ។ នៅពេលដែលលោកសុលនិងអ្នករួមដំណើរជាមួយលោកបានឃើញទីវាលដែលមានផ្លែឈើគ្រប់មុខ និងទីក្រុងដ៏ល្អឆើតនៅពីក្រោមរំពេចនោះស្រាប់តែ ដូចលោកបានមានប្រសាសន៍ថា «នោះស្រាប់តែមានពន្លឺពីលើមេឃ ភ្លឺមកជុំវិញទូលបង្គំ និងពួកអ្នកដើរជាមួយ ជាពន្លឺភ្លឺជាងថ្ងៃ» (កិច្ចការ ២៦:១៣) ភ្លឺចាំងចែងដែលភ្នែកមនុស្សមិនអាចទ្រាំទ្របាន។ លោកសុលបានដួលទៅនឹងដីទាំងខ្វាក់ភ្នែក និងវិលវល់គំនិត ។

នៅពេលដែលពន្លឺបានបន្តចែងចាំងនៅជុំវិញពួកគេ លោកសុលបានឮសំឡេងថា «សុល នែសុល ហេតុអ្វីបានជាអ្នកបៀតបៀនដល់ខ្ញុំដូច្នេះ គាត់ទូលឆ្លើយថា ឱព្រះអម្ចាស់អើយ ព្រះអង្គណាន៎ុះ រួចព្រះអម្ចាស់ទ្រង់តបថា ខ្ញុំនេះជាព្រះយេស៊ូវ ដែលអ្នកបៀតបៀន អ្នកធាក់ជល់នឹងជន្លួញដូច្នេះ នោះពិបាកដល់អ្នកណាស់»។ ពោរពេញទៅដោយការភ័យខ្លាច និងសឹងតែងងឹតភ្នែកដោយសារពន្លឺដ៏ភ្លឺចាំងនោះ ពួកអ្នករួមដំណើរជាមួយនឹងលោកសុលបានឮសំឡេង តែមើលមិនឃើញមនុស្សឡើយ។ ប៉ុន្តែ សម្រាប់លោកសុល លោកយល់នូវព្រះបន្ទូលដែលបានមានបន្ទូលមកកាន់លោក ហើយព្រះដែលបានមានបន្ទូលនេះបានបង្ហាញអង្គទ្រង់ឲ្យលោកបានឃើញ គឺព្រះរាជបុត្រនៃព្រះ។ លោកបានឃើញព្រះដែលគេបានឆ្កាងឈរនៅចំពោះលោក។ រូបភាពនៃព្រះភក្ត្ររបស់ព្រះអង្គសង្គ្រោះបានជិតជាប់នៅក្នុងចិត្តបុរសសាសន៍យូដាដែលត្រូវវាយប្រហាររូបនេះជារៀងរហូត។ ពាក្យពេចន៍ដែលលោកបានឮ

ដក់ជាប់ក្នុងចិត្តជាមួយនឹងកម្លាំងដ៏គួរឲ្យភ័យញ័ររន្ធត់។ នៅក្នុងបន្ទប់ដ៏ងងឹតខាងគំនិតមានពន្លឺធ្លាក់មកហូរហៀរដូចទឹកជំនន់ បង្ហាញពីភាពល្ងិតល្ងង់និងកំហុសនៃជីវិតអតីតកាលរបស់លោក ហើយពេលនេះលោកត្រូវការការបំភ្លឺនៃព្រះវិញ្ញាណបរិសុទ្ធ។

ឥឡូវនេះ លោកសុលបានដឹងថាការធ្វើទុក្ខបៀតបៀនដល់ពួកសិស្សរបស់ព្រះយេស៊ូវ លោកកំពុងតែធ្វើកិច្ចការរបស់សាតាំងហើយ។ លោកបានឃើញថាការយល់ត្រូវ និងភារកិច្ចរបស់លោកបានពឹងផ្អែកទាំងស្រុងទៅលើពួកសង្ឃនិងពួកដឹកនាំសាសនា។ លោកបានជឿពួកគេ នៅពេលគេបានប្រាប់លោកថារឿងការមានព្រះជន្មរស់ឡើងវិញ គឺជារឿងប្រឌិតដ៏ចំឡែករបស់ពួកសិស្ស។ ឥឡូវនេះ ខណៈដែលព្រះយេស៊ូវបានឈរនៅក្បែរលោកសុលហើយលោកសុលបានជឿនូវសេចក្តីពិតដែលពួកសិស្សបានប្រកាស ។

<u>សុក្រ-៧ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ ជំពូក ៤

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ចូរក្រោកឈរឡើង ដ្បិតខ្ញុំបានលេចមកឲ្យអ្នកឃើញ ដើម្បីនឹងតាំងអ្នក ឲ្យធ្វើជាអ្នកបំរើ ហើយជាទីបន្ទាល់ ពីអស់ទាំងការដែលអ្នកបានឃើញហើយ ព្រមទាំងការដែលខ្ញុំនឹងលេចមក ឲ្យអ្នកឃើញទៅមុខទៀត។ កិច្ចការ ២៦:១៦*

នៅពេលដែលមានការបំភ្លឺព្រោងព្រាតពីព្រះនៃឋានសួគ៌ នោះគំនិតរបស់លោកសុលបានធ្វើសកម្មភាពយ៉ាងរហ័សគួរឲ្យកត់សម្គាល់។ កំណត់ត្រានៃបទទំនាយស្តីពីការត្រាស់បង្គាប់នៃព្រះវិញ្ញាណត្រូវបានបើកចំហឲ្យលោកបានយល់។ លោកឃើញថាការបដិសេធន៍ព្រះយេស៊ូវពីសំណាក់សាសន៍យូដា ការជាប់ឆ្កាងរបស់ទ្រង់ ការមានព្រះជន្មរស់ឡើងវិញ និងការយាងឡើងទៅឋានសួគ៌របស់ទ្រង់ ត្រូវបានពួកហោរាប្រាប់ឲ្យដឹងជាមុន និងបានបញ្ជាក់ថាព្រះអង្គគឺជាព្រះមែស៊ីដែលព្រះបានសន្យាពិតប្រាកដមែន ។ សេចក្តីអធិប្បាយរបស់លោកស្ទេផាន នៅពេលទុក្ករកម្មរបស់លោក

បានកើតឡើងនៅក្នុងគំនិតរបស់លោកសុលដោយបង្ខំ ហើយលោកបានទទួលស្គាល់ថាទុក្ករបុគ្គលពិតជាបានឃើញ «សិរីល្អរបស់ព្រះ» ប្រាកដមែន នៅពេលដែលលោកបាននិយាយថា «មើល ខ្ញុំឃើញមេឃចំហ និងកូនមនុស្សឈរនៅខាងព្រះហស្តស្តាំនៃព្រះ» (កិច្ចការ ៧:៥៥, ៥៦)។ ពួកសង្ឃបានប្រកាសថាពាក្យទាំងនេះគឺជាការប្រមាថ ប៉ុន្តែ ឥឡូវនេះ លោកសុលបានដឹងថាពាក្យទាំងនោះគឺជាពាក្យពិត។

ការទាំងអស់នេះត្រូវបានបើកបង្ហាញយ៉ាងច្បាស់ដល់អ្នកធ្វើទុក្ខបៀតបៀនម្នាក់នេះ! ឥឡូវនេះ លោកសុលបានដឹងពីសេចក្តីពិតដែលថាព្រះមែស្ស៊ីដែលព្រះបានសន្យាថា ទ្រង់បានយាងមកកាន់ផែនដីនេះ ជាព្រះយស៊ូវនៃស្រុកណាសារ៉ែត ហើយត្រូវបានមនុស្សដែលទ្រង់បានយាងមកជួយសង្គ្រោះត្រូវបានបដិសេធទ្រង់។ លោកក៏បានដឹងផងដែរថាព្រះអង្គសង្គ្រោះបានមានព្រះជន្មរស់ចេញពីផ្នូរដោយជោគជ័យ ហើយបានយាងឡើងទៅឋានសួគ៌។ នៅក្នុងឱកាសនៃការបើកបង្ហាញរបស់ព្រះនេះ លោកសុលបាននឹកឃើញទាំងរន្ធត់ពីលោកស្ទេផានដែលបានផ្តល់ទីបន្ទាល់នៃព្រះអង្គសង្គ្រោះដែលគេបានឆ្កាង និងបានមានព្រះជន្មរស់ពីសុគតឡើងវិញ ដែលមនុស្សមានជំនឿលើទ្រង់បានលះបង់ដើម្បីព្រះអង្គ ហើយដែលក្រោយមកទៀតតាមរយៈពួកគេ ដែលជាឧបករណ៍របស់ទ្រង់ មនុស្សជាច្រើនទៀតដែលជាសិស្សដ៏មានតម្លៃរបស់ព្រះយេស៊ូវ បានជួបប្រទះនឹងសេចក្តីស្លាប់ ដោយសារការធ្វើទុក្ខបៀតបៀនយ៉ាងឃោរឃៅ។

ព្រះអង្គសង្គ្រោះបានមានបន្ទូលទៅកាន់លោកសុលតាមរយៈលោកស្ទេផាន ដែលគ្មានអ្នកណាអាចប្រឆាំងនឹងការគិតគូរពិចារណារបស់លោកបានឡើយ។ អ្នកប្រាជ្ញសាសន៍យូដានេះបានឃើញទឹកមុខរបស់ទុក្ករបុគ្គលស្ទេផានឆ្លុះបញ្ចាំងពីសិរីល្អរបស់ព្រះអង្គសង្គ្រោះ ដែលមានលក្ខណៈដូចជា «មុខទេវតា» (កិច្ចការ ៦:១៥)។ លោកធ្លាប់បានឃើញការអត់ទ្រាំរបស់លោកស្ទេផាន ជាមួយនឹងសត្រូវរបស់លោក និងការអត់ឱនទោសរបស់លោក

ចំពោះពួកគេ។ លោកក៏ធ្លាប់បានឃើញការអត់ធ្មត់និងការលះបង់ដ៏រីករាយរបស់មនុស្សជាច្រើន ដែលលោកធ្លាប់បានធ្វើឲ្យឈឺចាប់និងរងទុក្ខវេទនា។ លោកក៏ធ្លាប់បានឃើញពួកអ្នកខ្លះហ៊ានលះបង់រហូតដល់អាយុជីវិតរបស់ខ្លួនដោយអំណរដើម្បីជាប្រយោជន៍ដល់សេចក្តីជំនឿរបស់ពួកគេផងដែរ។

រឿងទាំងអស់នេះបានស្រែកអំពាវនាយ៉ាងឮ នៅក្នុងគំនិតរបស់លោកប៉ុល ហើយលោកបានទុកចិត្តដល់គំនិតរបស់លោកជាច្រើនដង ហើយលោកសឹងតែជឿជាក់យ៉ាងច្បាស់ថាព្រះយេស៊ូវពិតជាព្រះមែស្ស៊ីដែលព្រះបានសន្យាប្រាកដមែន។ នៅក្នុងឱកាសទាំងនោះ លោកបានតស៊ូពុះពារពេញមួយយប់ តទល់នឹងមនសិការរបស់ខ្លួនឯង ហើយលោកតែងតែបញ្ចប់បញ្ហានោះទៅដោយការទទួលស្គាល់ជាដាច់ខាតថា ព្រះយេស៊ូវមិនមែនជាព្រះមែស្ស៊ីទេ ហើយពួកសិស្សរបស់ព្រះអង្គគឺជាពួកបោកបញ្ឆោតដ៏ប៉ិនប្រសប់។

ឥឡូវនេះ ព្រះគ្រិស្តបានមានបន្ទូលមកកាន់លោកសុលដោយព្រះសូរសៀងផ្ទាល់របស់ព្រះអង្គថា «សុល នែសុល ហេតុអ្វីបានជាអ្នកបៀតបៀនដល់ខ្ញុំដូច្នេះ?» ហើយជាចម្លើយតបទៅនឹងសំណួររបស់លោកសុលថា «ឱព្រះអម្ចាស់អើយ ព្រះអង្គណានុ៎ះ?» ព្រះអង្គបានមានបន្ទូលថា «ខ្ញុំនេះជាព្រះយេស៊ូវ ដែលអ្នកបៀតបៀន»។ នៅទីនេះព្រះគ្រិស្តបានបង្ហាញអង្គទ្រង់ឲ្យរាស្ត្ររបស់ព្រះអង្គបានស្គាល់។ ដោយការធ្វើទុក្ខបៀតបៀនដល់ពួកសិស្សរបស់ព្រះយេស៊ូវ លោកសុលបានវាយប្រហារទៅលើព្រះអម្ចាស់នៃឋានសួគ៌ដោយផ្ទាល់។ ដោយការចោទប្រកាន់ខុស និងបានធ្វើទីបន្ទាល់ប្រឆាំងទៅនឹងពួកគេ ក៏ដូចជាបានចោទប្រកាន់ខុស និងបានធ្វើទីបន្ទាល់ទាស់នឹងព្រះអង្គសង្គ្រោះនៃពិភពលោកដោយផ្ទាល់ដែរ។

<u>សៅរ៍-៨ សីហា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ ជំពូក ៥**

**ខព្រះគម្ពីរប្រចាំសប្តាហ៍:** *នោះគាត់ក៏ញាប់ញ័រ ទាំងអស្ចារ្យក្នុងចិត្ត ហើយទូលថា ព្រះអម្ចាស់អើយ តើទ្រង់សព្វព្រះហឫទ័យឲ្យទូលបង្គំធ្វើដូចម្តេច*

*ព្រះអម្ចាស់មានព្រះបន្ទូលថា ចូរក្រោកឡើងចូលទៅក្នុងទីក្រុងទៅ នោះគេនឹងប្រាប់អ្នក ឲ្យដឹងពីការដែលអ្នកត្រូវធ្វើ។ កិច្ចការ ៩:៦*

សេចក្តីពិតឥតសង្ស័យបានកើតឡើងនៅក្នុងគំនិតរបស់លោកសុលថាអ្នកដែលនិយាយជាមួយនឹងលោក គឺពិតជាព្រះយេស៊ូវនៃស្រុកណាសារ៉ែតយ៉ាងច្បាស់ ជាព្រះមែស្ស៊ីដែលលោកបានរង់ចាំជាយូរមកហើយ ជាព្រះដ៏ជួយដោះទុក្ខនិងជាព្រះអង្គដ៏ប្រោសលោះនៃសាសន៍អ៊ីស្រាអែល។ លោកបាន «ញាប់ញ័រ ទាំងអស្ចារ្យក្នុងចិត្ត ហើយទូលថា ព្រះអម្ចាស់អើយ តើទ្រង់សព្វព្រះហឫទ័យឲ្យទូលបង្គំធ្វើដូចម្តេច? ព្រះអម្ចាស់មានព្រះបន្ទូលថា ចូរក្រោកឡើងចូលទៅក្នុងទីក្រុងទៅ នោះគេនឹងប្រាប់អ្នកឲ្យដឹងពីការដែលអ្នកត្រូវធ្វើ»។

នៅពេលដែលព្រះបានដកយកសិរីល្អរបស់ទ្រង់ទៅវិញ ហើយលោកសុលក៏បានក្រោកចេញពីដី លោកបានដឹងថាលោកមើលអ្វីមិនឃើញឡើយ។ ពន្លឺភ្លឺចែងចាំងនៃសិរីល្អរបស់ព្រះគ្រិស្តភ្លឺខ្លាំងពេក ធ្វើឲ្យភ្នែករបស់មនុស្សមិនអាចទ្រាំទ្របានឡើយ ហើយនៅពេលដែលព្រះបានដកយកពន្លឺនេះចេញ រាត្រីកាលដ៏ងងឹតសូន្យសុងបានគ្របដណ្តប់គំហើញរបស់លោក ។ លោកបានជឿថាភាពងងឹតរបស់លោកគឺជាទណ្ឌកម្មមកពីព្រះ ដោយការធ្វើទុក្ខបៀតបៀនដ៏ឃោរឃៅរបស់លោកដល់ពួកសិស្សរបស់ព្រះយេស៊ូវជាប្រាកដ។ លោកបានដើររាវផ្លូវទាំងភាពងងឹតយ៉ាងពិបាក ហើយពួកអ្នកដែលធ្វើដំណើរជាមួយលោក «ក៏ដឹកដៃគាត់នាំទៅឯដាម៉ាស» ទាំងអស្ចារ្យក្នុងចិត្ត ។

នាពេលព្រឹកនៃថ្ងៃដែលព្រឹត្តិការណ៍នោះបានកើតឡើង លោកសុលបានមកជិតដល់ក្រុងដាម៉ាសជាមួយនឹងអារម្មណ៍ពេញចិត្ត ដោយសារទំនុកចិត្តដែលសម្តេចសង្ឃបានប្រគល់ដល់លោក។ សម្តេចសង្ឃបានផ្តល់ការទទួលខុសត្រូវយ៉ាងធ្ងន់ដល់លោក។ លោកបានទទួលបញ្ជាឲ្យជំរុញសាសនាយូដាទៅមុខ ដោយបញ្ឈប់ការរីករាលដាលជំនឿថ្មីនៅទីក្រុងដាម៉ាស ។

លោកបានតាំងចិត្តថាបេសកកម្មរបស់លោកនឹងទទួលបានជោគជ័យយ៉ាងធំធេង និងបានទន្ទឹងរង់ចាំដោយសេចក្ដីប្រាថ្នាដ៏ពុះពោរនូវបទពិសោធន៍ដែលលោកបានរំពឹងទុកនៅចំពោះមុខ ។

ប៉ុន្ដែ ឥឡូវនេះ ផ្ទុយស្រះឡះពីបំណងប្រាថ្នារបស់លោក តើលោកនៅតែចូលទៅក្នុងទីក្រុងដែរឬទេ? ដោយបានវាយប្រហារដោយភាពងងឹត គ្មានសង្ឃឹម ញាំញីដោយវិប្បដិសារី មិនដឹងថាការវិនិច្ឆ័យនៅពេលអនាគតនឹងទៅជាយ៉ាងណាសម្រាប់លោក លោកបានស្វែងរកផ្ទះរបស់លោកយូដាសដែលជាសិស្សរបស់ព្រះយេស៊ូវ ជាកន្លែងដែលលោកមានឱកាសគ្រប់គ្រាន់ដើម្បីឆ្លុះបញ្ចាំងនិងអធិដ្ឋានតែម្នាក់ឯង ។

ក្នុងរវាងបីថ្ងៃ «គាត់មើលមិនឃើញឡើយ ក៏មិនបរិភោគអ្វីផង»។ ក្នុងអំឡុងពេលដ៏សែនឈឺចាប់នេះ បីថ្ងៃ ហាក់ដូចជារាប់ឆ្នាំសម្រាប់លោកសុល។ ដោយចិត្តតានតឹង លោកបាននឹកឃើញម្ដងហើយម្ដងទៀត ពីចំណែកដែលលោកបានធ្វើទៅលើទុក្ករកម្មរបស់លោកស្ទេផាន។ លោកបានគិតអំពីទោសកំហុសរបស់លោកដោយចិត្តញាប់ញ័រ ដោយបានបណ្ដោយខ្លួនឲ្យការព្យាបាទនិងការប្រកាន់ពូជសាសន៍របស់ពួកសង្ឃនិងពួកមេដឹកនាំសាសនាគ្រប់គ្រងលើរូបលោក ទោះបីជាលោកបានឃើញមុខរបស់លោកស្ទេផានត្រូវបានបំភ្លឺដោយកាំរស្មីនៃឋានសួគ៌ក៏ដោយ។ ដោយចិត្តក្រៀមក្រំនិងទុក្ខព្រួយលោកបាននឹកឃើញនូវការដែលលោកបានបិទភ្នែក ចុកត្រចៀក ជាច្រើនដង ប្រឆាំងទៅនឹងភស្ដុតាងជាក់ស្ដែងបំផុត ហើយជំរុញឲ្យគេធ្វើទុក្ខបៀតបៀនដល់ពួកអ្នកជឿលើព្រះយេស៊ូវពីស្រុកណាសារ៉ែត ដោយគ្មានមេត្ដា ។

លោកបានចំណាយពេលឆ្លុះបញ្ចាំងពីខ្លួនឯងយ៉ាងដិតដល់ និងការបន្ទន់ចិត្តនេះដាច់ដោយឡែកតែម្នាក់ឯង។ ពួកសិស្សបានទទួលដំណឹងពីគោលបំណងរបស់លោកសុលក្នុងការធ្វើដំណើរមកកាន់ទីក្រុងដាម៉ាស គេបានភ័យខ្លាចក្រែងលោកធ្វើសកម្មភាពក្លែងបន្លំ ដើម្បីបំភ័ន្ដពួកគេ ហើយពួកគេក៏បានលាក់ខ្លួន មិនព្រមផ្ដល់ការអាណិតអាសូរដល់លោកឡើយ។ លោក

មិនមានសេចក្តីប្រាថ្នាបង្ហាញខ្លួនជាសាសន៍យូដាដែលបានកែប្រែចិត្តទេ លោកបានមានគម្រោងការណ៍ចង់រួបរួមក្នុងការបៀតបៀនដល់ពួកអ្នកជឿ ព្រោះលោកបានជឿថា ពួកគេនឹងមិនព្រមស្តាប់រឿងរបស់លោកឡើយ។ ដូច្នេះ លោកហាក់ដូចជាត្រូវបានកាត់ផ្តាច់ចេញពីការអាណិតអាសូររបស់មនុស្ស។ សេចក្តីសង្ឃឹមនៃជំនួយតែមួយគត់របស់លោកគឺមានតែព្រះដែលពោរពេញដោយសេចក្តីមេត្តាករុណាប៉ុណ្ណោះ ហើយលោកក៏បានអំពាវនាវរកទ្រង់ដោយចិត្តខ្វេចខ្ទាំ ។

**<u>អាទិត្យ-៩ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ ជំពូក ៦**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ដូច្នេះ អាន់នាសក៏ទៅ ហើយចូលក្នុងផ្ទះនោះ ដាក់ដៃលើគាត់ និយាយថា អ្នកសុលអើយ ព្រះអម្ចាស់ គឺព្រះយេស៊ូវ ដែលលេចមកឲ្យអ្នកឃើញតាមផ្លូវ ទ្រង់បានចាត់ខ្ញុំមក ដើម្បីឲ្យអ្នកបានភ្លឺភ្នែក ហើយឲ្យអ្នកបានពេញជាព្រះវិញ្ញាណបរិសុទ្ធ។ កិច្ចការ ៩:១៧*

នៅក្នុងអំឡុងពេលដែលលោកសុលនៅដាច់ពីអ្នកដទៃយ៉ាងយូរ តែពីរនាក់ជាមួយនឹងព្រះនោះ លោកបានរំឭកពីបទគម្ពីរជាច្រើនដែលសម្តែងពីការយាងមកជាលើកទីមួយរបស់ព្រះគ្រិស្ត។ លោកបានតាមដានបទទំនាយយ៉ាងយកចិត្តទុកដាក់ ជាមួយនឹងការចងចាំដែលបានដុសខាត់ដោយការភ្ញាក់រឭកដែលបានកើតឡើងនៅក្នុងគំនិតរបស់លោក។ នៅពេលដែលលោកបានឆ្លុះបញ្ចាំងពីអត្ថន័យនៃបទទំនាយទាំងនេះ លោកមានការភ្ញាក់ផ្អើលជាខ្លាំងចំពោះភាពងងឹតងងល់នៃការមិនបានយល់កន្លងមករបស់លោក និងភាពងងឹតងងល់របស់សានស៍យូដាជាទូទៅ ដែលបានដឹកនាំឲ្យមានការបដិសេធន៍ព្រះយេស៊ូវថាជាព្រះមែស្ស៊ីតាមបទទំនាយ ។

ខណៈដែលលោកសុលបានទោរទន់ទៅតាមការណែនាំរបស់ព្រះវិញ្ញាណបរិសុទ្ធទាំងស្រុង នោះលោកបានឃើញទោសកំហុសនៃជីវិតរបស់លោក ហើយបានទទួលស្គាល់ការទាមទារយ៉ាងទូលំទូលាយនៃក្រឹត្យវិន័យរបស់

ព្រះ។ លោកសុលដែលធ្លាប់ជាអ្នកផារិស៊ីដ៏អំនួត ឥឡូវនេះបានឱនក្រាបនៅចំពោះព្រះដោយការបន្ទាបខ្លួននិងភាពសាមញ្ញដូចជាកូនក្មេង ដោយលន់តួភាពគ្មានតម្លៃរបស់លោក ហើយទូលអង្វរករសុំសេចក្តីមេត្តាករុណានៃព្រះអង្គសង្គ្រោះដែលគេបានឆ្កាងនិងបានមានព្រះជន្មរស់ឡើងវិញ។ លោកសុលអន្ទះសាចង់រួបរួមជាមួយនឹងព្រះវរបិតានិងព្រះរាជបុត្រា ហើយនៅក្នុងកម្លាំងនៃសេចក្តីប្រាថ្នាចង់បានការអត់ឱនទោសនិងការទទួលយករបស់លោក លោកបានទូលថ្វាយដោយអង្វរករដល់បល្ល័ង្កនៃព្រះគុណ ។

ការអធិដ្ឋានរបស់អ្នកផារិស៊ីដែលមានវិប្បដិសារីរូបនេះមិនឥតប្រយោជន៍ទេ។ ព្រះគុណនៃព្រះបានបំផ្លាស់បំប្រែចិត្តនិងអារម្មណ៍ពីខាងក្នុងរបស់លោក ហើយព្រះអង្គក៏បាននាំឲ្យញាណសតិរបស់លោកឲ្យបានស្រុះស្រួលគ្នា ជាមួយនឹងព្រះរាជគោលបំណងដ៏អស់កល្បរបស់ព្រះ ។ ព្រះគ្រិស្តនិងសេចក្តីសុចរិតរបស់ទ្រង់មានតម្លៃចំពោះលោកសុលជាងពិភពលោកទាំងមូលទៅទៀត។

ការផ្លាស់ប្តូរជំនឿរបស់លោកសុលគឺជាភស្តុតាងជាក់ស្តែងមួយនៃព្រះចេស្តាដ៏អស្ចារ្យនៃព្រះវិញ្ញាណបរិសុទ្ធដើម្បីបង្ហាញមនុស្សឲ្យស្គាល់បាប។ លោកបានជឿជាក់ថាព្រះយេស៊ូវពីស្រុកណាសារ៉ែតបានប្រមាថដល់ក្រឹត្យវិន័យរបស់ព្រះ ហើយបានបង្រៀនដល់ពួកសិស្សរបស់ទ្រង់ថាក្រឹត្យវិន័យនោះលែងមានប្រសិទ្ធិភាពតទៅទៀតហើយ ។ ប៉ុន្តែ បន្ទាប់ពីការផ្លាស់ប្តូរជំនឿរបស់លោកមក លោកសុលបានទទួលស្គាល់ថាព្រះយេស៊ូវគឺជាព្រះដែលបានយាងមកកាន់ពិភពលោកនេះ ដើម្បីបង្ហាញប្រាប់ពីព្រះរាជគោលបំណងនៃការបង្ហាញឲ្យឃើញថាក្រឹត្យវិន័យរបស់ព្រះវរបិតាគឺជាច្បាប់ដ៏ត្រឹមត្រូវ។ ព្រះបានធ្វើឲ្យលោកបានយល់ថាព្រះយេស៊ូវគឺជាប្រភពនៃប្រព័ន្ធថ្វាយតង្វាយយញ្ញបូជារបស់សាសន៍យូដាទាំងស្រុង ។ លោកបានឃើញថាការឆ្កាងដែលជានិមិត្តរូប បានជួបជាមួយនឹងការឆ្កាងពិតប្រាកដ ដែលព្រះយេស៊ូវបានសម្រេចតាមបទទំនាយនៃគម្ពីរសញ្ញាចាស់ ទាក់ទងទៅនឹង

ព្រះដ៏ប្រោសលោះនៃសាសន៍អ៊ីស្រាអែល ។

នៅក្នុងកំណត់ត្រានៃការកែប្រែចិត្តរបស់លោកសុល ព្រះបានប្រទានគោលការណ៍ដ៏សំខាន់ដល់យើងគ្រប់គ្នា ដែលយើងត្រូវតែចងចាំនៅក្នុងគំនិតជារៀងរហូត។ ព្រះវិញ្ញាណបាននាំលោកសុលទៅឯព្រះវត្តមានរបស់ព្រះគ្រិស្តដោយផ្ទាល់។ លោកគឺជាមនុស្សដែលព្រះគ្រិស្តបានបម្រុងទុកសម្រាប់កិច្ចការដ៏សំខាន់បំផុត ជាអ្នកដែលនឹងក្លាយជា «ប្រដាប់រើសតាំង»សម្រាប់ទ្រង់ ប៉ុន្តែ ព្រះជាម្ចាស់មិនបានប្រាប់លោកអំពីកិច្ចការដែលទ្រង់នឹងចាត់ឲ្យលោកធ្វើនោះនៅឡើយទេ។ ព្រះអង្គបានចាប់លោកទុកនៅតាមផ្លូវរបស់លោក ហើយបានបង្ហាញឲ្យលោកបានស្គាល់បាប ប៉ុន្តែ នៅពេលលោកសុលបានសួរថា «ព្រះអម្ចាស់អើយ តើទ្រង់សព្វព្រះហឫទ័យឲ្យទូលបង្គំធ្វើដូចម្ដេច?» ព្រះអង្គសង្គ្រោះបានដាក់ជនជាតិយូដាដែលមានសំណួរនេះភ្ជាប់ទៅនឹងពួកជំនុំរបស់ទ្រង់ នៅទីនោះលោកនឹងទទួលបាននូវចំណេះដឹងពីព្រះរាជគោលបំណងរបស់ទ្រង់ ទាក់ទងទៅនឹងរូបលោក ។

<u>ច័ន្ទ-១០ សីហា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ ជំពូក ៧**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ប៉ុន្តែ ព្រះអម្ចាស់មានព្រះបន្ទូលថា ចូរទៅចុះ ពីព្រោះអ្នកនោះជាប្រដាប់រើសតាំងដល់ខ្ញុំ សំរាប់នឹងប្រកាសឈ្មោះខ្ញុំ ដល់ពួកសាសន៍ដទៃ និងពួកស្តេច ហើយនិងពួកកូនចៅសាសន៍អ៊ីស្រាអែលផង។*
*កិច្ចការ ៩:១៥*

ពន្លឺដ៏អស្ចារ្យដែលបានចែងចាំងបំបាត់ភាពងងឹតរបស់លោកសុល គឺជាកិច្ចការរបស់ព្រះជាម្ចាស់ ប៉ុន្តែ ក៏មានកិច្ចការដែលពួកសិស្សត្រូវធ្វើផងដែរ។ ព្រះគ្រិស្តបានសម្ដែងការបើកបង្ហាញនិងការកាត់ទោស ហើយឥឡូវនេះ ជនដែលមានវិប្បដិសារីនេះឋិតនៅក្នុងលក្ខខណ្ឌមួយនៃការរៀនសូត្រពីអ្នកទាំងឡាយ ដែលព្រះបានតែងតាំងឲ្យបង្រៀនពីសេចក្ដីពិតរបស់ទ្រង់។

ខណៈដែលលោកសុលនៅតែម្នាក់ឯង ក្នុងផ្ទះរបស់លោកយូដាស

បន្តអធិដ្ឋាននិងទូលអង្វរករ ព្រះជាម្ចាស់បានលេចមកនៅក្នុងការបើកសម្តែងមួយ «រឹងដាម៉ាស នោះមានសិស្សម្នាក់ឈ្មោះអាន្នាស» ដោយប្រាប់លោកថា លោកសុលជាអ្នកស្រុកតើសុសកំពុងតែអធិដ្ឋានហើយត្រូវការជំនួយ ។ ទេវតានៃឋានសួគ៌បានមានបន្ទូលថា «ក្រោកឡើង ទៅឯផ្លូវដែលហៅថាផ្លូវត្រង់ ហើយរកមនុស្សម្នាក់ឈ្មោះសុល ជាអ្នកស្រុកតើសុសនៅក្នុងផ្ទះយូដាស ដ្បិតមើល គាត់កំពុងតែអធិដ្ឋាន ហើយក្នុងការជាក់ស្តែងគាត់បានឃើញថា មានមនុស្សម្នាក់ឈ្មោះអាន្ន៉ានាស ចូលមកដាក់ដៃលើគាត់ឲ្យបានភ្លឺភ្នែកឡើង»។

លោកអាន្ន៉ានាសសឹងតែមិនជឿបន្ទូលរបស់ទេវតា ព្រោះដំណឹងនៃការធ្វើទុក្ខបៀតបៀនដ៏ជូរចត់របស់លោកសុល ដល់ពួកបរិសុទ្ធនៅទីក្រុងយេរូសាឡិមបានឮសុសសាយពាសពេញទីជិតឆ្ងាយ។ លោកបានសំអាងទៅលើកំហុសរបស់សុល ដោយទូលតបទៅព្រះវិញថា «ព្រះអម្ចាស់អើយទូលបង្គំបានឮមនុស្សជាច្រើន និយាយពីការអាក្រក់ទាំងប៉ុន្មាន ដែលអ្នកនោះបានប្រព្រឹត្ត ដល់ពួកបរិសុទ្ធរបស់ទ្រង់ នៅក្រុងយេរូសាឡិម ហើយនៅទីនេះ គាត់ក៏មានអំណាចពីពួកសង្គ្រាជ អាចនឹងទៅចាប់ចងនូវអស់អ្នកណាដែលអំពាវនាវដល់ព្រះនាមទ្រង់ដែរ» ប៉ុន្តែ ព្រះអម្ចាស់មានព្រះបន្ទូលថា «ចូរទៅចុះ ពីព្រោះអ្នកនោះជាប្រដាប់រើសតាំងដល់ខ្ញុំ សម្រាប់នឹងប្រកាសឈ្មោះខ្ញុំ ដល់ពួកសាសន៍ដទៃ និងពួកស្តេច ហើយនិងពួកកូនចៅសាសន៍អ៊ីស្រាអែលផង» ។

ដោយស្តាប់តាមការណែនាំរបស់ទេវតា អាន្ន៉ានាសស្វែងរកបុរសដែលថ្មីៗនេះបានពេញចិត្តនឹងការគំរាមកំហែងដល់អ្នកដែលជឿដល់ព្រះនាមរបស់ព្រះយេស៊ូវ ហើយដាក់ដៃលើក្បាលរបស់អ្នកឈឺចាប់ដែលមានវិប្បដិសារីនេះ លោកបាននិយាយថា «អ្នកសុលអើយ ព្រះអម្ចាស់ គឺព្រះយេស៊ូវ ដែលលេចមកឲ្យអ្នកឃើញតាមផ្លូវ ទ្រង់បានចាត់ខ្ញុំមក ដើម្បីឲ្យអ្នកបានភ្លឺភ្នែក ហើយឲ្យអ្នកបានពេញជាព្រះវិញ្ញាណបរិសុទ្ធ»។

«ស្រាប់តែមានដូចជាស្រកាជ្រុះចុះពីភ្នែកគាត់មក ហើយគាត់ក៏បានភ្លឺ ជាមួយរំពេច រួចក្រោកឡើងទទួលបុណ្យជ្រមុជទឹក» ។

ដូច្នេះ ព្រះយេស៊ូវបានប្រទានការយល់ព្រមដល់អំណាចនៃពួកជំនុំពេញសិទ្ធិរបស់ព្រះអង្គ ហើយបានដាក់លោកសុលនៅក្នុងទំនាក់ទំនងជាមួយនឹងភ្នាក់ងារដែលទ្រង់បានតែងតាំងនៅលើផែនដី។ ឥឡូវនេះ ព្រះគ្រិស្ដមានពួកជំនុំដែលជាតំណាងរបស់ទ្រង់នៅលើផែនដី ហើយពួកជំនុំនេះមានកិច្ចការជួយតម្រង់ទិសដល់បាបជន ដែលបានកែប្រែចិត្តនៅក្នុងរបៀបនៃការរស់នៅ ។

មនុស្សជាច្រើនមានគំនិតថា ពួកគេមានទំនួលខុសត្រូវចំពោះតែព្រះគ្រិស្ដមួយគត់ សម្រាប់ពន្លឺនិងបទពិសោធន៍របស់ពួកគេ មិនទីពឹងទៅលើពួកសិស្សរបស់ទ្រង់នៅលើផែនដីនេះទេ។ ព្រះយេស៊ូវគឺជាមិត្តសម្លាញ់របស់បាបជន ហើយព្រះអង្គមានព្រះទ័យក្ដួលអាណិតចំពោះសេចក្ដីវេទនារបស់ពួកគេជាខ្លាំង។ ព្រះអង្គមានសព្វព្រះចេស្ដា ទាំងនៅឋានសួគ៌ និងនៅផែនដី ប៉ុន្តែ ព្រះអង្គគោរពភ្នាក់ងារដែលទ្រង់បានតែងតាំង សម្រាប់ពន្លឺនិងសេចក្ដីសង្គ្រោះរបស់មនុស្ស ព្រះអង្គបានណែនាំបាបជនទៅឯពួកជំនុំដែលទ្រង់បានបង្កើតឡើងសម្រាប់ជាប្រឡាយនៃពន្លឺដល់ពិភពលោក។

នៅពេលដែលព្រះបានប្រទានការបើកសម្ដែងអំពីព្រះគ្រិស្ដ ជាព្រះដែលលោកកំពុងតែធ្វើទុក្ខបៀតបៀន ដល់លោកសុល នៅកណ្ដាលកំហុសឆ្គងនិងការប្រកាន់ពូជសាសន៍ដ៏ងងឹតងងល់របស់លោក ព្រះអង្គបានដាក់លោកឲ្យមានទំនាក់ទំនងជាមួយនឹងពួកជំនុំ ដែលជាពន្លឺនៃលោកិយ។ នៅក្នុងករណីនេះ លោកអាន្នានាសតំណាងឲ្យព្រះគ្រិស្ដ ហើយក៏ជាតំណាងឲ្យគ្រូគង្វាលរបស់ព្រះគ្រិស្ដ ដែលព្រះអង្គបានតែងតាំងឲ្យធ្វើការជាតំណាងព្រះអង្គនៅលើផែនដីនេះផងដែរ។ ជាអ្នកតំណាងឲ្យព្រះគ្រិស្ដ លោកអាន្នានាសបានពាល់ភ្នែករបស់លោកសុល ដើម្បីឲ្យលោកអាចទទួលពន្លឺ។ លោកបានដាក់ដៃលើក្បាលគាត់ជំនួសព្រះគ្រិស្ដ ហើយនៅពេលដែល

លោកបានអធិដ្ឋានដោយនូវព្រះនាមរបស់ព្រះគ្រិស្ត លោកសុលក៏បានទទួលព្រះវិញ្ញាណបរិសុទ្ធ។ គ្រប់ទាំងអស់ត្រូវបានសម្រេចដោយនូវព្រះចេស្តារបស់ព្រះគ្រិស្ត។ ព្រះគិស្រ្តគឺជារន្ធទឹក ហើយពួកជំនុំគឺជាប្រឡាយនៃទំនាក់ទំនង។

ជំពូកទី
១៣

# ថ្ងៃនៃការរៀបចំ

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ៩:១៩-៣០ ។*

<u>អង្គារ-១១ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ ជំពូក ៨

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *សុលក៏នៅក្រុងដាម៉ាស ជាមួយនឹងពួកសិស្សជាយូរថ្ងៃ នោះស្រាប់តែគាត់ប្រកាសប្រាប់ពីព្រះយេស៊ូវ នៅក្នុងសាលាប្រជុំទាំងប៉ុន្មាន ថា ទ្រង់ជាព្រះរាជបុត្រានៃព្រះ។ កិច្ចការ ៩:២០*

បន្ទាប់ពីពិធីបុណ្យជ្រមុជទឹករបស់លោករួចមក លោកប៉ុល (ប្តូរមកឈ្មោះសុលវិញ) លោកបានតមអាហារ ហើយបាននៅ «ក្រុងដាម៉ាសជាមួយនឹងពួកសិស្សជាយូរថ្ងៃ នោះស្រាប់តែគាត់ប្រកាសប្រាប់ពីព្រះយេស៊ូវនៅក្នុងសាលាប្រជុំទាំងប៉ុន្មានថា ទ្រង់ជាព្រះរាជបុត្រានៃព្រះ» លោកបានប្រកាសដោយក្លាហាន អំពីព្រះយេស៊ូវពីស្រុកណាសារ៉ែតថាជាព្រះមែស៊ីដែលមនុស្សបានរង់ចាំជាយូរមកហើយ ជាព្រះដែល «បានសុគត ដោយព្រោះបាបរបស់យើងរាល់គ្នាតាមបទគម្ពីរ ហើយថា ទ្រង់ត្រូវគេបញ្ចុះក្នុងផ្នូរ រួចដល់ថ្ងៃទីបីនោះទ្រង់មានព្រះជន្មរស់ឡើងវិញ ក៏តាមបទគម្ពីរ» ក្រោយមកទៀត ពួកសិស្ស និងមនុស្សដទៃឯទៀតក៏បានមើលឃើញទ្រង់។ លោកប៉ុលបានបន្ថែមថា «រួចទ្រង់បានលេចមកឲ្យខ្ញុំឃើញ ជាខាងក្រោយគេបង្អស់ដូចជាលេចមកដល់កូនកើតមុនកំណត់ដែរ» (កូរិនថូសទី១ ១៥:៣, ៤, ៨)។ ការវែកញែករបស់លោកចេញពីបទទំនាយមានភាពប្រាកដប្រជាជាខ្លាំង ហើយព្រះចេស្តារបស់ព្រះបានគង់នៅជាប់ជាមួយនឹងការខំប្រឹងប្រែងរបស់លោក ដែលធ្វើឲ្យពួកយូដាស្រឡាំងកាំង មិនអាចឆ្លើយទៅលោកវិញបានឡើយ។

ដំណឹងពីការកែប្រែជំនឿរបស់លោកប៉ុលបានឮដល់ពួកសាសន៍យូដា ជាការភ្ញាក់ផ្អើលយ៉ាងធំ។ លោកសុលដែលបានធ្វើដំណើរទៅកាន់ទីក្រុងដាម៉ាស «ដោយទទួលអំណាចពីពួកសង្គ្រាជមក» (កិច្ចការ ២៦:១០) ដើម្បីចាប់ចងនិងធ្វើទុក្ខបៀតបៀនដល់ពួកអ្នកជឿ ឥឡូវនេះបានក្លាយមកជាអ្នកអធិប្បាយអំពីដំណឹងល្អនៃការជាប់ឆ្កាង និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គសង្គ្រោះ ទាំងជួយពង្រឹងកម្លាំងដល់អ្នកដែលបានក្លាយជាសិស្សរបស់ទ្រង់រួចទៅហើយ និងបាននាំមកនូវអ្នកមានជំនឿថ្មីៗជាបន្ត ដែលលោកធ្លាប់តែប្រឆាំងយ៉ាងជូរចត់នោះទៅវិញ ។

លោកប៉ុលជាមនុស្សដែលគេធ្លាប់ស្គាល់ថាជាអ្នកការពារសាសនាយូដាដាច់ខាតម្នាក់ និងជាអ្នកធ្វើទុក្ខបៀតបៀនដែលមិនចេះនឿយហត់ ដល់ពួកសិស្សរបស់ព្រះយេស៊ូវ។ ទេពកោសល្យនិងចំណេះដឹងដែលលោកបានសិក្សាបានធ្វើឲ្យលោកអាចបម្រើការបានសឹងតែនៅក្នុងគ្រប់ផ្នែកទាំងអស់ដោយក្លាហាន មានភាពឯករាជម្ចាស់ការ និងការតស៊ូស្វិតស្វាញ។ លោកអាចពិចារណារកហេតុផលបានយ៉ាងច្បាស់លាស់ខុសពីធម្មតា ហើយដោយសារការចំអកបញ្ឈឺចិត្តយ៉ាងស្អិតរមួតរបស់លោក អាចដាក់អ្នកប្រឆាំងនេះទៅក្នុងពន្លឺដែលគួរឲ្យចង់បាន។ ហើយឥឡូវនេះ ពួកយូដាបានឃើញថាយុវជនដែលមានជំនាញពិសេសខុសពីធម្មតា បានរួបរួមជាមួយនឹងអតីតមនុស្សអ្នកដែលគេធ្លាប់តែធ្វើទុក្ខបៀតបៀន ហើយកំពុងអធិប្បាយដោយនូវព្រះនាមព្រះយេស៊ូវតតខ្លាចរអែង។

មេបញ្ជាការកងទ័ពបានស្លាប់នៅក្នុងសមរភូមិ គឺជាការបាត់បង់នៃកងទ័ពរបស់គាត់ ប៉ុន្តែ មរណភាពរបស់មេបញ្ជាការនេះមិនបានផ្តល់កម្លាំងអ្វីដល់កងទ័ពឡើយ។ ប៉ុន្តែ នៅពេលដែលបុរសដែលលេចធ្លោជាងគេបែរទៅរួបរួមជាមួយនឹងកម្លាំងនៃក្រុមប្រឆាំង មិនមែនបាត់បង់ត្រឹមតែការងាររបស់អ្នកនោះប៉ុណ្ណោះទេ ប៉ុន្តែ ក្រុមដែលអ្នកនោះបានរួបរួមជាមួយនឹងទទួលបាននូវអត្ថប្រយោជន៍យ៉ាងធំធេងទៀតផង។ ព្រះជាម្ចាស់អាចប្រហារជីវិតលោក

សុលជាអ្នកស្រុកតើសុស នៅក្នុងការធ្វើដំណើររបស់លោកទៅកាន់ក្រុងដាម៉ាសបានយ៉ាងងាយ ហើយព្រះអង្គអាចដកហូតកម្លាំងចេញពីអំណាចនៃការធ្វើទុក្ខបៀតបៀនជាច្រើន។ ប៉ុន្តែ ដោយទិព្វញ្ញាណរបស់ទ្រង់ ព្រះមិនត្រឹមតែបានរក្សាទុកអាយុជីវិតរបស់លោកសុលប៉ុណ្ណោះទេ ប៉ុន្តែ ព្រះអង្គបានប្តូរជំនឿរបស់លោកទៅវិញ ដូច្នេះ នេះគឺជាការបំផ្លាស់បំប្រែអ្នកកំពូលជើងឯក ពីខាងខ្មាំងសត្រូវ មកខាងព្រះគ្រិស្តវិញ។ ការនិយាយដែលប្រកបដោយវោហារ កោសល្យ និងការរិះគន់ធ្ងន់ៗ ជាមួយនឹងគោលបំណងយ៉ាងរឹងមាំ លោកប៉ុលមានគុណសម្បត្តិដែលពួកជំនុំដំបូងត្រូវការជាចាំបាច់។ នៅពេលដែលលោកប៉ុលបានអធិប្បាយអំពីព្រះគ្រិស្តនៅក្រុងដាម៉ាស អ្នកដែលបានស្តាប់លោកមានការភ្ញាក់ផ្អើលជាខ្លាំង ហើយបាននិយាយថា «តើមិនមែនអ្នកនេះទេឬអី ដែលបំផ្លាញពួកអ្នកអំពាវនាវដល់ព្រះនាមនោះនៅក្រុងយេរូសាឡិម ហើយគាត់បានមកទីនេះ ដើម្បីនឹងចាប់ចងគេ បញ្ជូនទៅឲ្យពួកសង្គ្រាជដែរ?» តែលោកប៉ុលបានអះអាងថាការផ្លាស់ប្តូរជំនឿរបស់លោកមិនមែនកើតឡើងដោយកម្លាំងជំរុញ ឬដោយចិត្តពុះកញ្ជ្រោលនោះទេ ប៉ុន្តែ ត្រូវបាននាំមកដោយភ័ស្តុតាងដ៏ចំឡែកអស្ចារ្យ។ នៅក្នុងការបង្ហាញអំពីដំណឹងល្អរបស់លោក លោកបានខំប្រឹងប្រែងបង្ហាញឲ្យបានឃើញច្បាស់អំពីបទទំនាយដែលទាក់ទងទៅនឹងព្រឹត្តិការណ៍នៃការយាងមកជាលើទីមួយរបស់ព្រះគ្រិស្ត។ លោកបានបង្ហាញយ៉ាងប្រាកដថា បទទំនាយនេះត្រូវបានសម្រេចពិតប្រាកដ ដោយព្រះយេស៊ូវពីស្រុកណាសារ៉ែត។ គ្រឹះនៃជំនឿរបស់លោកគឺជាពាក្យនៃសេចក្តីទំនាយយ៉ាងពិតប្រាកដ។

<u>ពុធ-១២ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ ជំពូក ៩

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *គឺទូលបង្គំបានប្រាប់ឲ្យមនុស្សទាំងអស់ប្រែចិត្ត ហើយងាកបែរមកឯព្រះវិញ ទាំងប្រព្រឹត្តបែបសំណំនឹងការប្រែចិត្តផង គឺប្រាប់ដល់ពួកអ្នកដែលនៅក្រុងដាម៉ាសជាមុនដំបូង រួចនៅក្រុងយេរូសាឡិម និងគ្រប់*

*ក្នុងខេត្តយូដា ហើយដល់អស់ទាំងសាសន៍ដទៃផង។ កិច្ចការ ២៦:២០*

នៅពេលដែលលោកប៉ុលបានបន្តអំពាវនាវដល់អ្នកស្តាប់ ដែលកំពុងតែភ្ញាក់ផ្អើលរបស់លោកឲ្យ «ប្រែចិត្តហើយងាកបែរមកឯព្រះវិញទាំងប្រព្រឹត្តបែបសំណាំនឹងការប្រែចិត្តផង» (កិច្ចការ ២៦:២០) លោកប៉ុល «មានកម្លាំងកាន់តែខ្លាំងឡើង ក៏ផ្ចាញ់ផ្ចាល់ដល់ពួកសាសន៍យូដា ដែលនៅក្រុងដាម៉ាសវិញ ដោយសម្តែងបញ្ជាក់ពីព្រះអង្គនេះថា ទ្រង់ជាព្រះគ្រិស្តពិតមែន»។ ប៉ុន្តែពួកគេជាច្រើនបានពង្រឹងចិត្តរបស់ពួកគេ មិនព្រមឆ្លើយតបទៅនឹងសាររបស់លោកឡើយ ហើយមិនយូរប៉ុន្មាន ការភ្ញាក់ផ្អើលចំពោះការផ្លាស់ប្តូរជំនឿរបស់លោកពីសំណាក់ពួកគេក៏បានប្រែក្លាយទៅជាសម្អប់ដ៏ខ្លាំងក្លា ដូចជាសម្អប់ដែលពួកគេធ្លាប់មានចំពោះព្រះយេស៊ូវកន្លងមកនោះដែរ។

ការប្រឆាំងបានរីករាលដាលឡើងយ៉ាងសាហាវឃោរឃៅ ដែលធ្វើឲ្យលោកប៉ុលមិនអាចបន្តធ្វើការនៅទីក្រុងដាម៉ាសតទៅទៀតបាន។ ទេវតាដែលជាអ្នកនាំសារនៃឋានសួរបានសុំឲ្យលោកចាកចេញមួយរយៈសិន ហើយឲ្យ «ទៅឯស្រុកអារ៉ាប់» (កាឡាទី ១:១៧) ជាទីដែលលោកបានរកឃើញកន្លែងសម្រាកដោយសុវត្ថិភាព។

នៅទីនេះ លោកប៉ុលមានឱកាសជាច្រើនសម្រាប់សិក្សានិងពិចារណាដោយស្ងៀមស្ងាត់។ លោកបានរំឭកឡើងវិញពីបទពិសោធន៍អតីតកាលរបស់លោក និងបានបញ្ជាក់យ៉ាងច្បាស់អំពីកិច្ចការនៃការកែប្រែចិត្តរបស់លោក។ លោកបានស្វែងរកព្រះអស់ពីចិត្ត មិនឈប់ឈរឡើយ រហូតទាល់តែលោកបានដឹងប្រាកដថាព្រះបានទទួលយកការកែប្រែចិត្តរបស់លោក និងបានអត់ទោសដល់អំពើបាបរបស់លោកហើយ។ លោកចង់បានការធានាអះអាងថាព្រះយេស៊ូវនឹងគង់នៅជាមួយនឹងកិច្ចការរបស់លោក ដែលនឹងចូលមកដល់នៅពេលខាងមុខនេះ។ លោកបានជម្រះចិត្តប្រកាន់ពូជសាសន៍ និងប្រពៃណីរបស់លោក ដែលបានសំលៀងជីវិតរបស់លោកចាប់តាំងពីពេលនោះមក ហើយលោកបានទទួលការណែនាំពីព្រះដែលជាប្រភពនៃ

សេចក្តីពិត។ ព្រះយេស៊ូវបានរួបរួមជាមួយនឹងលោក ហើយបង្កើតសេចក្តីជំនឿនៅក្នុងចិត្តលោក ដោយបានប្រទានប្រាជ្ញានិងព្រះគុណដ៏បរិបូរដល់លោក។

នៅពេលដែលគំនិតរបស់មនុស្សបានរួបរួមជាមួយនឹងព្រះតម្រិះរបស់ព្រះ គំនិតដែលមានដែនកំណត់ជាមួយនឹងព្រះតម្រិះដែលគ្មានដែនកំណត់នោះអានុភាពនៅលើផ្នែករាងកាយ គំនិត និងព្រលឹងមានឥទ្ធិពលគ្មានគូប្រៀប។ យើងរកឃើញចំណេះដឹងដ៏ភ្លឺថ្លាបំផុតនៅក្នុងការរួបរួមបែបនេះ។ នេះគឺជាវិធីសាស្ត្រនៃការអភិវឌ្ឍន៍របស់ព្រះ។ «ដូច្នេះ ចូរអ្នកផ្គាប់ផ្គុនទ្រង់ ហើយមានសេចក្តីមេត្រីនឹងទ្រង់ចុះ» (យ៉ូប ២២:២១) គឺជាព្រះរាជសាររបស់ទ្រង់ចំពោះមនុស្សជាតិ។

ការទូន្មានដ៏អស្ចារ្យដែលព្រះបានប្រទានដល់លោកប៉ុល នៅក្នុងឱកាសនៃការធ្វើបទសម្ភាសន៍ជាមួយនឹងលោកអាន្នាំនាសបានដក់ជាប់នៅក្នុងទម្ងន់ដែលចេះតែកើនឡើងនៅក្នុងចិត្តរបស់លោកជានិច្ច។ ពេលលោកបានឆ្លើយតបទៅនឹងពាក្យថា «អ្នកសុលអើយ សូមឲ្យភ្នែកអ្នកបានភ្លឺឡើង» លោកប៉ុលបានសម្លឹងមើលមុខបុរសដែលមានជំនឿដាច់ខាតជាលើកដំបូងបង្អស់នៅក្រោមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ លោកអាន្នាំនាសបានមានប្រសាសន៍ទៅកាន់លោកប៉ុលថា «ព្រះនៃពួកអយ្យកោយើងបានតម្រូវឲ្យអ្នកស្គាល់ចំណង់នៃព្រះហឫទ័យទ្រង់ ហើយឲ្យឃើញព្រះដ៏សុចរិត ព្រមទាំងឮសំឡេងពីព្រះឱស្ឋទ្រង់ ដ្បិតអ្នកត្រូវធ្វើជាស្មរបន្ទាល់ពីទ្រង់ដល់មនុស្សទាំងអស់ ពីគ្រប់ការដែលអ្នកបានឃើញ បានឮ ឥឡូវនេះ តើអ្នកបង្អង់ចាំអ្វីទៀត ចូរក្រោកឡើង ទទួលបុណ្យជ្រមុជទឹក ហើយលាងបាបអ្នកចេញចុះ ដោយការអំពាវនាវដល់ព្រះនាមព្រះអម្ចាស់»
(កិច្ចការ ២២:១៣-១៦)។

សម្តីនេះស្របគ្នាទៅនឹងព្រះបន្ទូលរបស់ព្រះយេស៊ូវដោយផ្ទាល់ នៅពេលដែលព្រះអង្គបានចាប់លោកសុលនៅតាមផ្លូវទៅកាន់ទីក្រុងដាម៉ាស

ដោយបានមានបន្ទូលថា «ដ្បិតខ្ញុំបានលេចមកឲ្យអ្នកឃើញ ដើម្បីនឹងតាំងអ្នកឲ្យធ្វើជាអ្នកបម្រើ ហើយជាទីបន្ទាល់ ពីអស់ទាំងការដែលអ្នកបានឃើញហើយ ព្រមទាំងការដែលខ្ញុំនឹងលេចមក ឲ្យអ្នកឃើញទៅមុខទៀត ខ្ញុំបានញែកអ្នកចេញពីបណ្តាជន និងពីពួកសាសន៍ដទៃ ដើម្បីនឹងចាត់អ្នកឲ្យទៅឯគេវិញ ប្រយោជន៍នឹងបំភ្លឺភ្នែកគេឲ្យបានបែរចេញពីសេចក្តីងងឹតមកឯពន្លឺ ហើយពីអំណាចអារក្សសាតាំង មកឯព្រះវិញ ដើម្បីឲ្យគេបានរួចពីបាប ហើយបានទទួលមរតក ជាមួយនឹងពួកអ្នកដែលបានញែកជាបរិសុទ្ធ ដោយសារសេចក្តីជំនឿជឿដល់ខ្ញុំ» (កិច្ចការ ២៦:១៦-១៨) ។

<u>ព្រហស្បតិ៍-១៣ សីហា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ ជំពូក ១០**
**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ឯពាក្យសំដី និងពោហារអធិប្បាយរបស់ខ្ញុំ ក៏មិនមែនដោយពាក្យឧត្តុង្គឧត្តម ដែលពូកែបញ្ចុះបញ្ចូលនោះដែរ គឺដោយការសំដែងចេញជាព្រះវិញ្ញាណ និងព្រះចេស្តាវិញទេតើ ដើម្បីកុំឲ្យសេចក្តីជំនឿរបស់អ្នករាល់គ្នាបានតាំងនៅ ដោយប្រាជ្ញារបស់មនុស្សឡើយ គឺដោយព្រះចេស្តានៃព្រះវិញ។ កូរិនថូសទី១ ២:៤-៥*

នៅពេលដែលលោកបានសញ្ជឹងគិតអំពីរឿងទាំងនេះនៅក្នុងចិត្តកាន់តែខ្លាំង លោកប៉ុលបានយល់អំពីការត្រាស់ហៅឲ្យ «មកធ្វើជាសាវ័ករបស់ទ្រង់ តាមបំណងព្រះហឫទ័យព្រះ» (កូរិនថូសទី១ ១:១) នេះកាន់តែច្បាស់ឡើងៗ។ ការត្រាស់ហៅរបស់លោកនេះ «មិនមែនដោយពាក្យឧត្តុង្គឧត្តមឡើយ ក្រៃងឈើឆ្កាងនៃព្រះគ្រិស្តទៅជាអសារឥតការវិញ» «គឺដោយការសម្តែងចេញជាព្រះវិញ្ញាណ និងព្រះចេស្តាវិញទេតើ» (កូរិនថូសទី១ ១:១៧ និង ២:៤,៥) ។

ខណៈដែលលោកសុលបានស្រាវជ្រាវព្រះគម្ពីរ លោកបានដឹងថានៅគ្រប់សម័យកាល «ក្នុងពួកអ្នកដែលទ្រង់បានហៅ មិនសូវមានអ្នកប្រាជ្ញច្រើនខាងឯសាច់ឈាម ឬច្រើននាក់មានអំណាច និងច្រើននាក់ដែលមានត្រកូល

ខ្ពស់នោះទេ ព្រះទ្រង់បានរើសពួកល្ងង់ល្ងើនៅលោកិយនេះ ដើម្បីនឹងធ្វើឲ្យអ្នកប្រាជ្ញមានសេចក្ដីខ្មាសវិញ ទ្រង់បានរើសពួកកម្សោយនៅលោកិយនេះ ដើម្បីនឹងធ្វើឲ្យពួកខ្លាំងពូកែមានសេចក្ដីខ្មាស ហើយទ្រង់បានរើសអ្នកទាបថោកនៅលោកិយនេះ និងពួកអ្នកដែលគេមើលងាយ ព្រមទាំងរបស់ដែលគ្មានផង ដើម្បីនឹងលើកចោលរបស់ដែលមានចេញ ប្រយោជន៍កុំឲ្យមនុស្សណាបានអួតខ្លួន នៅចំពោះព្រះឡើយ» (កូរិនថូសទី១ ១:២៦-២៩)។ ហើយដោយមើលឃើញប្រាជ្ញានៃលោកិយនៅក្នុងពន្លឺនៃឈើឆ្កាង លោកប៉ុល «បានផ្ដាច់ចិត្តថា ... មិនព្រមស្គាល់រឿងអ្វីទៀត ក្រៅពីព្រះយេស៊ូវគ្រិស្ដទេ ហើយគឺដែលទ្រង់ត្រូវឆ្កាងផង» (កូរិនថូសទី១ ២:២)។ នៅពាសពេញទាំងកិច្ចការរបស់លោក នៅពេលក្រោយៗមកទៀត លោកប៉ុលមិនដែលមើលរំលងព្រះដែលជាប្រភពនៃប្រាជ្ញានិងកម្លាំងឡើយ ។ ជាច្រើនឆ្នាំក្រោយមកទៀត គេនៅតែឮលោកមានប្រសាសន៍ថា «ដ្បិតឯខ្ញុំ ដែលខ្ញុំរស់នៅ នោះគឺសម្រាប់ព្រះគ្រិស្ដទេ» (ភីលីព ២:២១)។ ហើយម្ដងទៀត «ហើយខ្ញុំក៏រាប់គ្រប់ទាំងអស់ទុកដូចជាខាតដែរ ដោយព្រោះសេចក្ដីដែលប្រសើរជាង គឺដោយស្គាល់ព្រះគ្រិស្ដយេស៊ូវ ជាព្រះអម្ចាស់នៃខ្ញុំ ដែលដោយយល់ដល់ទ្រង់ខ្ញុំបានខាតគ្រប់ទាំងអស់ ... ប្រយោជន៍ឲ្យបានព្រះគ្រិស្ដវិញ ហើយឲ្យគេបានឃើញខ្ញុំ នៅក្នុងទ្រង់ ដោយសេចក្ដីសុចរិតដែលមកពីសេចក្ដីជំនឿដល់ព្រះគ្រិស្ដ មិនមែនដោយសេចក្ដីសុចរិតរបស់ខ្លួនខ្ញុំ ដែលមកពីក្រឹត្យវិន័យនោះទេ គឺជាសេចក្ដីសុចរិតដែលមកពីព្រះដោយសេចក្ដីជំនឿវិញ» (ភីលីព ៣:៨-១០) ។

ដោយចេញពីស្រុកអារ៉ាប់ លោកប៉ុលបាន «ត្រឡប់ទៅក្រុងដាម៉ាសវិញ» (កាឡាទី ១:១៧) ហើយបាន «អធិប្បាយដោយក្លាហាន ... ដោយនូវព្រះនាមព្រះយេស៊ូវ» ។ ដោយមិនអាចបង្ក្រាបប្រាជ្ញានៃការជជែកវែកញែករបស់លោក «ពួកសាសន៍យូដា គេពិគ្រោះគ្នានឹងសម្លាប់គាត់ចេញ»។ គេក៏ចាំទ្វារក្រុងទាំងយប់ទាំងថ្ងៃ ដើម្បីកុំឲ្យលោករត់ចេញបាន។ វិបត្តិនេះបានធ្វើឲ្យពួកសិស្សបានស្វែងរកព្រះអស់ពីចិត្ត ហើយទីបំផុត «ពួកសិស្សយកកញ្ជើ

មកដាក់គាត់សម្រូតចុះតាមកំផែងក្រុងទៅ» (កិច្ចការ ៩:២៥) ។

បន្ទាប់ពីការគេចខ្លួនពីទីក្រុងដាម៉ាសមក លោកប៉ុលបានធ្វើដំណើរទៅកាន់ទីក្រុងយេរូសាឡិម ប្រហែលបីឆ្នាំបានកន្លងផុត គិតចាប់តាំងពីការផ្លាស់ប្តូរជំនឿរបស់លោកមក។ វត្ថុបំណងដ៏ធំរបស់លោកនៅក្នុងដំណើរនេះ ដូចលោកបានថ្លែងនៅពេលក្រោយមកទៀតនោះគឺ «ដើម្បីឲ្យបានស្គាល់លោកពេត្រុស» (កាឡាទី ១:១៨)។ ក្នុងការមកដល់ទីក្រុងដែលគេធ្លាប់ស្គាល់លោកថា«សុលជាអ្នកបៀតបៀន» «គាត់ខំចូលទៅឯពួកសិស្ស តែគេខ្លាចគាត់ទាំងអស់គ្នា គេមិនជឿថា គាត់ជាសិស្សទេ» ។ ពួកគេពិបាកនឹងជឿណាស់ថា អ្នកផារិស៊ីដែលមានជំនឿស៊ប់ និងជាអ្នកដែលបានធ្វើកិច្ចការជាច្រើនដើម្បីបំផ្លាញពួកជំនុំនេះ អាចក្លាយមកជាសិស្សដ៏ស្មោះត្រង់របស់ព្រះយេស៊ូវទៅវិញនោះ។ «តែបាណាបាសនាំគាត់ទៅឯពួកសាវ័ក រ៉ាយរឿងប្រាប់គេ ពីដំណើរដែលគាត់បានឃើញព្រះអម្ចាស់តាមផ្លូវ ហើយទ្រង់បានមានព្រះបន្ទូលនឹងគាត់ ក៏និយាយពីបែបយ៉ាងណា ដែលគាត់មានចិត្តក្លាហាននឹងអធិប្បាយ ដោយនូវព្រះនាមព្រះយេស៊ូវ នៅក្រុងដាម៉ាសផង»។

<u>សុក្រ-១៤ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ជំពូក ១១

**ខព្រះគម្ពីរប្រចាំថ្ងៃ**: *ដ្បិតអ្នកត្រូវធ្វើជាស្មរបន្ទាល់ពីទ្រង់ ដល់មនុស្សទាំងអស់ពីគ្រប់ការដែលអ្នកបានឃើញបានឮ។ នោះទ្រង់មានព្រះបន្ទូលមកខ្ញុំថា ចូរទៅចុះ ដ្បិតខ្ញុំនឹងចាត់អ្នកឲ្យទៅឯសាសន៍ដទៃដែលនៅឆ្ងាយ។*

*កិច្ចការ ២២:១៥ និង ២១*

ដោយបានឮរឿងនេះ ពួកសិស្សក៏បានទទួលយកលោកជាសមាជិកម្នាក់របស់ពួកគេ។ មិនយូរប៉ុន្មាន ពួកគេក៏មានភស្តុតាងជាច្រើនដែលបានបញ្ជាក់ពីបទពិសោធន៍ជាគ្រិស្តបរិស័ទរបស់លោក។ ឥឡូវនេះ អនាគតជាសាវ័កសម្រាប់សាសន៍ដទៃកំពុងនៅក្នុងទីក្រុងដែលមានអ្នកធ្លាប់ទាក់ទងជាមួយលោកជាច្រើនរស់នៅ ហើយលោកប៉ុលចង់បង្ហាញដល់ពួកមេដឹកនាំសាសន៍

យូដាទាំងនេះឲ្យបានឃើញច្បាស់អំពីបទទំនាយដែលទាក់ទងទៅនឹងព្រះមែស៊ី ដែលត្រូវបានសម្រេចដោយការយាងមករបស់ព្រះអង្គសង្គ្រោះ។ លោកប៉ុលជឿជាក់ថាពួកគ្រូនៃសាសន៍អ៊ីស្រាអែលទាំងនេះ ជាពួកអ្នកដែលលោកធ្លាប់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ នឹងជឿជាក់ហើយស្មោះត្រង់ចំពោះព្រះយេស៊ូវដូចជាលោកដែរ ជាក់ជាមិនខាន។ ប៉ុន្តែ លោកបានប៉ាន់ស្មានចិត្តបងប្អូនសាសន៍យូដារបស់លោកខុសស្រឡះ ហើយនៅក្នុងសេចក្តីសង្ឃឹមថាពួកគេនឹងកែប្រែជំនឿយ៉ាងឆាប់រហ័សនោះ លោកបានទទួលរងនូវការខកចិត្តយ៉ាងជូរចត់ទៅវិញ។ ទោះបីជា «បានអធិប្បាយដោយនូវព្រះនាមនៃព្រះអម្ចាស់យេស៊ូវ ដោយក្លាហាន គាត់សម្តែងហើយជជែកជាមួយនឹងពួកហេលេន» ក៏ដោយ ក៏ពួកអ្នកដែលជាមេលើពួកជំនុំសាសន៍យូដាមិនព្រមជឿដែរតែ «ពួកនោះរករឿងសម្លាប់គាត់វិញ»។ លោកមានទុក្ខកង្វល់ពេញក្នុងដួងចិត្ត លោកសុខចិត្តលះបង់អាយុជីវិតរបស់លោក ប្រសិនបើការនោះអាចនាំឲ្យពួកគេមួយចំនួនមានចំណេះដឹងពីសេចក្តីពិត។ លោកបានគិតដោយអៀនខ្មាសអំពីផ្នែកដ៏សកម្មដែលលោកបានចូលរួមប្រព្រឹត្តទៅលើទុក្ករកម្មរបស់លោកស្ទេផាន ហើយឥឡូវនេះ លោកបានលុបបំបាត់ស្លាកស្នាម ដែលជិតដាមនៅលើអ្នកដែលបានចោទប្រកាន់ខុសទាំងនេះ ដោយក្តីថប់បារម្ភ លោកបានស្វះស្វែងបញ្ជាក់ពីសេចក្តីពិតដែលលោកស្ទេផានសុខចិត្តលះបង់ជីវិតនោះ ។

ដោយទទួលបន្ទុកជំនួសពួកអ្នកដែលបដិសេធមិនព្រមជឿ លោកប៉ុលកំពុងអធិដ្ឋាននៅក្នុងព្រះវិហារ ដូចលោកបានបញ្ជាក់នៅពេលក្រោយមកទៀត កាលលោកបានលង់ស្មារតីទៅ ខណៈនោះទេវតាដែលជាអ្នកនាំសារនៃឋានសួគ៌ បានលេចមកនៅចំពោះលោក ហើយបានមានបន្ទូលថា «ចូរប្រញាប់ចេញពីក្រុងយេរូសាឡិមទៅជាឆាប់ ពីព្រោះគេមិនទទួលពាក្យដែលអ្នកធ្វើបន្ទាល់ពីខ្ញុំទេ» (កិច្ចការ ២២:១៨)។

លោកប៉ុលនៅតែចង់នៅក្នុងទីក្រុងយេរូសាឡិម ជាកន្លែងដែលលោក

អាចប្រឈមនឹងការប្រឆាំងបន្តទៅទៀត ចំពោះលោក ការគេចខ្លួនហាក់ដូចជាសកម្មភាពដ៏កំសាកមួយ ប្រសិនបើលោកបន្តស្នាក់នៅទីនោះបន្តទៅទៀត លោកប្រហែលជាអាចបំផ្លាស់បំប្រែពួកយូដាដែលចចេសរឹងរូសមួយចំនួន អំពីសេចក្តីពិតពីសារនៃដំណឹងល្អ ទោះបីជាការបន្តស្នាក់នៅទីនោះនាំឲ្យលោកត្រូវបាត់បង់ជីវិតក៏ដោយ។ ហេតុដូច្នេះ លោកបានឆ្លើយថា «ព្រះអម្ចាស់អើយ អ្នកទាំងនោះដឹងថាទូលបង្គំបានចាប់ពួកអ្នកដែលជឿដល់ទ្រង់ដាក់គុកហើយ ព្រមទាំងវាយគេនៅក្នុងគ្រប់ទាំងសាលាប្រជុំផង កាលដែលឈាមស្ទេផាន ជាស្មរបន្ទាល់របស់ទ្រង់ បានត្រូវខ្ចាយ នោះទូលបង្គំក៏ឈរនៅទីនោះដែរ បានទាំងយល់ព្រមឲ្យសម្លាប់គាត់ ហើយនៅចាំអាវនៃពួកអ្នកដែលសម្លាប់គាត់ផង»។ ប៉ុន្តែ ការនេះមិនស្របទៅនឹងបំណងព្រះហឫទ័យរបស់ព្រះទេ ដែលអ្នកបម្រើរបស់ទ្រង់មិនចាំបាច់យកជីវិតទៅប្តូរដូច្នេះឡើយ ហើយទេវតាដែលជាអ្នកនាំសារនៃឋានសួគ៌ក៏បានឆ្លើយតបមកវិញថា «ចូរទៅចុះ ដ្បិតខ្ញុំនឹងចាត់អ្នកឲ្យទៅឯសាសន៍ដទៃដែលនៅឆ្ងាយ» (កិច្ចការ ២២:១៩-២១) ។

ដោយបានដឹងពីការបើកសម្តែងនេះ បងប្អូនលោកបានបង្ខំឲ្យលោកប៉ុលគេចខ្លួនពីទីក្រុងយេរូសាឡិម ដោយខ្លាចក្រែងគេសម្លាប់លោក។ «នោះគេជូនគាត់ទៅត្រឹមសេសារារួចឲ្យទៅឯតើសុស»។ ការចាកចេញរបស់លោកប៉ុលបានផ្អាកការប្រឆាំងដ៏ហិង្សារបស់សាសន៍យូដាមួយរយៈ ពួកជំនុំក៏មានឱកាសបានសម្រាក ដែលមានមនុស្សជាច្រើនត្រូវបានបញ្ចូលបន្ថែមទៅក្នុងចំនួនពួកអ្នកជឿ។

## ជំពូកទី
## ១៤

# អ្នកស្វែងរកសេចក្ដីពិត

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ៩:៣២ ដល់ ១១:១៨ ។*

<u>សៅរ៍-១៥ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ ជំពូក ១២

**ខព្រះគម្ពីរប្រចាំសប្ដាហ៍:** *ក៏និយាយទៅគាត់ថា អ្នកអេនាសអើយ ព្រះយេស៊ូវ ដ៏ជាព្រះគ្រីស្ទ ទ្រង់ប្រោសឲ្យអ្នកបានជាហើយ ចូរក្រោកឡើងរៀបគ្រែអ្នក ទៅ ស្រាប់តែគាត់ក៏ក្រោកឡើងភ្លាម ឯមនុស្សទាំងប៉ុន្មាន ដែលនៅភូមិលីដា និងស្រុកសារ៉ូន ក៏ឃើញគាត់ ហើយគេប្រែចិត្តជឿដល់ព្រះអម្ចាស់។ កិច្ចការ ៩:៣៤-៣៥*

នៅក្នុងការបំពេញកិច្ចការរបស់លោក សាវ័កពេត្រុសបានមកសួរសុខទុក្ខពួកអ្នកជឿនៅលីដា។ នៅទីនោះលោកបានព្យាបាលជំងឺស្លាប់ដៃស្លាប់ជើងរបស់បុរសម្នាក់ឈ្មោះ អេនាស ដែលបានសម្រាន្តនៅតែលើគ្រែអស់៨ឆ្នាំមកហើយ។ សាវ័កពេត្រុសបានមានប្រសាសន៍ថា «អ្នកអេនាសអើយ ព្រះយេស៊ូវដ៏ជាព្រះគ្រិស្ដ ទ្រង់ប្រោសឲ្យអ្នកបានជាហើយ ចូរក្រោកឡើងរៀបគ្រែអ្នកទៅ ស្រាប់តែគាត់ក៏ក្រោកឡើងភ្លាម ឯមនុស្សទាំងប៉ុន្មាន ដែលនៅភូមិលីដានិងស្រុកសារ៉ូនក៏ឃើញគាត់ហើយគេប្រែចិត្តជឿដល់ព្រះអម្ចាស់»។

នៅយ៉ុបប៉េងនោះវិញ ដែលនៅមិនឆ្ងាយប៉ុន្មានពីលីដានោះ មានស្ត្រីម្នាក់ឈ្មោះឌ័រខាស ដែលមានមនុស្សជាច្រើនបានស្រឡាញ់រាប់អាននាងដោយសារតែទង្វើល្អរបស់នាង។ នាងគឺជាសិស្សដ៏មានតម្លៃរបស់ព្រះយេស៊ូវហើយជីវិតរបស់នាងពោរពេញទៅដោយសកម្មភាពនៃសេចក្ដីសប្បុរស។ នាងបានដឹងថាអ្នកណាត្រូវការសម្លៀកបំពាក់សមរម្យ អ្នកណាត្រូវការការអាណិតអាសូរ

ហើយនាងបានជួយបម្រើដល់អ្នកក្រីក្រនិងអ្នកមានទុក្ខកង្វល់ ដោយឥតគិតកម្រៃអ្វីឡើយ។ ម្រាមដៃដ៏ប៉ិនប្រសប់របស់នាងមានសកម្មភាពខ្លាំងជាងអណ្ដាតរបស់នាង។

«នៅគ្រានោះ នាងមានជំងឺឈឺ ហើយស្លាប់ទៅ» ពួកជំនុំនៅយ៉ុបប៉េបានដឹងពីការបាត់បង់ដ៏ធំរបស់ពួកគេ ហើយបានឮថាលោកពេត្រុសនៅឯលីដា ពួកអ្នកជឿក៏បានជូនដំណឹងទៅលោក «ដើម្បីនឹងសូមអង្វរឲ្យមកឯគេដោយឥតបង្អង់ ពេត្រុសក៏ក្រោកឡើងទៅជាមួយ កាលបានដល់ហើយ នោះគេនាំគាត់ទៅបន្ទប់ខាងលើនោះ ហើយពួកស្រីមេម៉ាយក៏ឈរជិតគាត់ទាំងយំព្រមទាំងបង្ហាញអាវ និងសម្លៀកបំពាក់ទាំងប៉ុន្មាន ដែលតេប៊ីថាបានធ្វើឲ្យពីកាលនាងនៅជាមួយនៅឡើយ»។ ដោយបានរំឭកពីជីវិតដែលនាងឌ័រខាសធ្លាប់បានរស់នៅ ពួកគេបានយំទួញ ធ្វើឲ្យទឹកភ្នែកក្ដៅឱណ្ហៗហូរកាត់ផែនថ្ពាល់ដោយមិនដឹងខ្លួន ។

ខណៈដែលលោកបានឃើញទុក្ខសោករបស់ពួកគេ ចិត្តរបស់សាវ័កពេត្រុសមានពេញទៅដោយការអាណិតអាសូរ ។ រួចលោកបានបង្គាប់ឲ្យមិត្តភក្តិដែលកំពុងយំសោកទាំងអស់ចេញក្រៅបន្ទប់ លោកបានលុតជង្គង់អធិដ្ឋាននិងទូលអង្វរករសុំឲ្យព្រះប្រទានជីវិតនិងសុខភាពដល់នាងឌ័រខាស (ដែលគម្ពីរខ្មែរហៅថានាងតេប៊ីថា ឬនាងក្ដាន់)។ លោកបានមានប្រសាសន៍ទាំងបែរទៅរកបុគ្គលដែលស្លាប់នោះ ដោយមានប្រសាសន៍ថា «តេប៊ីថាអើយចូរនាងក្រោកឡើង នាងក៏បើកភ្នែកឃើញពេត្រុស រួចឡើងអង្គុយ គាត់ក៏ហុចដៃទៅឲ្យនាងតោងឡើង រួចគាត់ហៅពួកបរិសុទ្ធ និងពួកស្រីមេម៉ាយមក ប្រគល់នាងទៅគេទាំងរស់»។ នាងឌ័រខាសធ្លាប់ជាអ្នកបម្រើដ៏ឧត្ដមដល់ពួកជំនុំ ហើយបានមើលឃើញនូវភាពត្រឹមត្រូវក្នុងការនាំនាងត្រឡប់មកទឹកដីនៃបច្ចាមិត្ត (ពីសេចក្តីស្លាប់) មកវិញ  ដើម្បីឲ្យទេពកោសល្យនិងកម្លាំងរបស់នាងបានក្លាយជាព្រះពរដល់អ្នកដទៃ និងដើម្បីឲ្យការបង្ហាញពីព្រះចេស្ដារបស់ព្រះអង្គនេះ បុព្វហេតុនៃព្រះគ្រិស្តត្រូវបានពង្រឹងកាន់តែរឹងមាំ

ឡើង។

គឺនៅគ្រាដែលលោកពេត្រុសស្នាក់នៅឯយ៉ុបប៉េនោះហើយ ដែលព្រះបានត្រាស់ហៅឲ្យលោកនាំដំណឹងល្អទៅប្រាប់ដល់លោកកូនេលាសនៅសេសារា។

លោកកូនេលាសគឺជាមេទ័ពរ៉ូម (ដែលហៅថាទ័ពអ៊ីតាលី) ម្នាក់។ លោកគឺជាបុរសដែលមានទ្រព្យសម្បត្តិនិងមានត្រកូលខ្ពង់ខ្ពស់ ហើយមុខនាទីរបស់លោកគឺជាមុខនាទីដែលមានភាពស្មោះត្រង់និងមានកិត្តិយស។ ជាសាសន៍ដទៃពីកំណើតបានសិក្សានិងអប់រំតាមរយៈទំនាក់ទំនងជាមួយនឹងសាសន៍យូដា លោកបានទទួលចំណេះដឹងអំពីព្រះ ហើយលោកបានថ្វាយបង្គំដល់ទ្រង់អស់អំពីចិត្ត ដែលបានបង្ហាញភាពស្មោះត្រង់នៃជំនឿរបស់លោកដោយការអាណិតអាសូរដល់អ្នកក្រីក្រ។ មានមនុស្សស្រឡាញ់រាប់អានលោកនៅគ្រប់ទីជិតឆ្ងាយ ដោយសារតែសេចក្តីមេត្តាករុណារបស់លោក ហើយជីវិតនៃសេចក្តីសុចរិតរបស់លោក ធ្វើឲ្យលោកមានកេរ្តិ៍ឈ្មោះល្អទាំងនៅក្នុងចំណោមសាសន៍យូដា និងសាសន៍ដទៃ។ ឥទ្ធិពលរបស់លោកបានក្លាយជាព្រះពរដល់អ្នកទាំងឡាយដែលលោកបានប្រស្រ័យទាក់ទង។ កំណត់ត្រានៃព្រះគម្ពីរបានពណ៌នាអំពីលោកថា «ជាអ្នកគោរព ហើយកោតខ្លាចដល់ព្រះ ព្រមទាំងពួកគ្រួសាររបស់លោកទាំងអស់ផង លោកក៏ដាក់ទានជាច្រើនដល់ពួកជន ហើយអំពាវនាវដល់ព្រះជានិច្ច»។

**<u>អាទិត្យ-១៦ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ ជំពូក ១៣**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *លោកក៏សំឡឹងមើលទៅទេវតាទាំងភ័យ ហើយឆ្លើយថា ព្រះអម្ចាស់អើយ តើមានការអ្វី ទេវតាប្រាប់ថា សេចក្តីអធិស្ឋាន និងការដាក់ទានរបស់អ្នក បានឡើងទៅទុកជាសេចក្តីរំឭក នៅចំពោះព្រះហើយ។ កិច្ចការ ១០:៤*

ដោយមានជំនឿថាព្រះគឺជាព្រះអាទិករ ដែលបានបង្កើតផ្ទៃមេឃនិង

ផែនដី លោកកូនេលាសបានបម្រើដល់ទ្រង់ទទួលស្គាល់ព្រះចេស្ដារបស់ទ្រង់ ហើយបានស្វែងរកដំបូន្មានរបស់ទ្រង់នៅគ្រប់ទាំងកិច្ចការនៃជីវិត។ លោកបានស្មោះត្រង់ជាមួយនឹងព្រះទាំងនៅក្នុងកិច្ចការផ្ទះ និងភារកិច្ចនៅឯការិយាល័យរបស់លោក។ លោកបានកសាងអាសនារបស់ព្រះនៅផ្ទះរបស់លោក ព្រោះលោកមិនហ៊ានអនុវត្តផែនការណាមួយដោយមិនបានសុំជំនួយពីព្រះនោះឡើយ ។

ទោះបីជាលោកកូនេលាសបានជឿលើបទទំនាយ និងកំពុងរង់ចាំការយាងមករបស់ព្រះមែស្ស៊ីក៏ដោយ ក៏លោកមិនបានដឹងពីដំណឹងល្អ ដូចដែលបានបង្ហាញនៅក្នុងព្រះជន្មនិងការសុគតរបស់ព្រះគ្រិស្តដែរ។ លោកមិនមែនជាសមាជិកនៃពួកជំនុំសាសន៍យូដាទេ ហើយត្រូវបានពួកគ្រូអាចារ្យចាត់ទុកថាជាសាសន៍ដទៃដែលមិនស្អាតថែមទៀតផង។ ប៉ុន្តែ ព្រះជាអ្នកឃ្លាំមើលដែលធ្លាប់បានមានបន្ទូលទៅកាន់លោកអ័ប្រាហាំថា «អញស្គាល់គាត់» ក៏បានមានបន្ទូលទៅកាន់លោកកូនេលាស និងចាត់ទេវតាពីឋានសួគ៌ឲ្យមកជួបលោកដែរ។

ទេវតាមួយអង្គបានមកជួបលោកកូនេលាស កាលលោកកំពុងតែអធិដ្ឋាននៅឡើយ។ នៅពេលមេទ័ពរូបនេះបានឮទេវតាហៅលោកចំឈ្មោះដូច្នេះ លោកមានការភ័យខ្លាចជាខ្លាំង ទោះបីជាលោកបានដឹងថាជាទេវតាដែលនាំសារមកពីឋានសួគ៌ក៏ដោយ ហើយលោកបានមានប្រសាសន៍ថា «ព្រះអម្ចាស់អើយ តើមានការអ្វី?» ទេវតាប្រាប់ថា «សេចក្តីអធិដ្ឋាន និងការដាក់ទានរបស់អ្នក បានឡើងទៅទុកជាសេចក្តីរំឭក នៅចំពោះព្រះហើយដូច្នេះ ចូរអ្នកប្រើគេឲ្យទៅយ៉ុបប៉េ ហៅស៊ីម៉ូន ដែលមានឈ្មោះថា ពេត្រុសឲ្យមកឥឡូវ គាត់ស្នាក់នៅផ្ទះរបស់ជាងសម្លាប់ស្បែកម្នាក់ ឈ្មោះស៊ីម៉ូននៅក្បែរមាត់សមុទ្រ» ។

ការណែនាំយ៉ាងច្បាស់នេះ ដែលបានប្រាប់ឈ្មោះ និងមុខការរបស់មនុស្សដែលលោកពេត្រុសបានស្នាក់នៅជាមួយផងនោះ បង្ហាញប្រាប់ថាព្រះនៃឋាន

សួគ៌ស្គាល់ប្រវត្តិនិងកិច្ចការរបស់មនុស្សយ៉ាងច្បាស់ នៅគ្រប់ទាំងស្ថានភាពនៃជីវិតទាំងអស់។ ព្រះទ្រង់ជ្រាបច្បាស់ពីបទពិសោធន៍និងការងាររបស់អ្នកធ្វើការដ៏ទន់ទាប ព្រមទាំងស្តេចដែលគង់លើបល្ល័ង្ករាជ្យផង ។

«ដូច្នេះ ចូរអ្នកប្រើគេឲ្យទៅយ៉ុបប៉េ ហៅស៊ីម៉ូន ដែលមានឈ្មោះថាពេត្រុសឲ្យមកឥឡូវ»។ ដូច្នេះ ព្រះបានប្រទានភស្តុតាងនៃការគោរពរបស់ទ្រង់ដល់អ្នកបម្រើដំណឹងល្អ និងដល់ពួកជំនុំពេញសិទ្ធិរបស់ទ្រង់។ ព្រះមិនបានបង្គាប់ឲ្យទេវតាប្រាប់លោកកូនេលាសអំពីរឿងរ៉ាវនៃឈើឆ្កាងទេ។ គឺមនុស្សដែលមានភាពផុយស្រួយនិងត្រូវល្បួងដែលត្រូវធ្វើការនោះ សូម្បីតែលោកមេទ័ពផ្ទាល់ ក៏ត្រូវការថ្លែងប្រាប់ពីការជាប់ឆ្កាងនិងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គសង្គ្រោះដែរ។

ព្រះមិនបានជ្រើសរើសទេវតា ដែលមិនធ្លាប់មានបាប ឲ្យធ្វើជាតំណាងរបស់ទ្រង់ នៅក្នុងចំណោមមនុស្សលោកទេ ប៉ុន្តែ ទ្រង់បានជ្រើសរើសមនុស្សលោកជាអ្នកដែលមានតណ្ហាដូចជាអ្នកដែលទ្រង់ស្វែងរកជួយសង្គ្រោះដូច្នោះដែរ។ ព្រះគ្រិស្តបានកើតជាមនុស្ស ដើម្បីឲ្យទ្រង់អាចចូលទៅឯមនុស្ស។ ព្រះអង្គសង្គ្រោះដែលមានភាពជាមនុស្ស ត្រូវការនាំយកសេចក្តីសង្គ្រោះមកជូនដល់ពិភពលោកនេះ។ ហើយព្រះអង្គបានប្រទានកិច្ចការដ៏ពិសេសនេះដល់បុរសនារីទាំងឡាយឲ្យប្រកាសប្រាប់ឲ្យដឹង «គឺជាសម្បត្តិរបស់ព្រះគ្រិស្តដ៏ប្រមាណមិនបាន» (អេភេសូរ ៣:៨) ។

នៅក្នុងព្រះប្រាជ្ញាញាណរបស់ព្រះអង្គ ព្រះបាននាំអ្នកដែលស្វែងរកសេចក្តីពិត ឲ្យបានជួបនឹងមនុស្សដូចគ្នា ដែលបានដឹងពីសេចក្តីពិតនោះ។ ផែនការនៃឋានសួគ៌គឺត្រូវឲ្យអ្នកដែលមានពន្លឺ ចែកចាយពន្លឺនោះ ដល់អ្នកដែលនៅក្នុងភាពងងឹត។ មនុស្សលោកដែលបានទាញយកផលល្អចេញពីព្រះដែលជាប្រភពនៃប្រាជ្ញា ត្រូវបានព្រះប្រើប្រាស់ជាឧបករណ៍ ធ្វើជាភ្នាក់ងារដែលផ្លាស់ប្រែចិត្តនិងគំនិតតាមរយៈការអនុវត្តន៍ដំណឹងល្អ។

លោកកូនេលាសបានស្តាប់តាមការបើកសម្តែងនោះដោយរីករាយ។

នៅពេលទេវតាបានយាងត្រឡប់ទៅបាត់ហើយ នោះលោកមេទ័ព «ហៅអ្នកបម្រើពីរនាក់ និងទាហានម្នាក់ ដែលកោតខ្លាចដល់ព្រះ ពីពួកមនុស្សដែលតែងតែបម្រើលោកឲ្យមក រួចប្រាប់រឿងរ៉ាវសព្វគ្រប់ ហើយប្រើឲ្យទៅឯយ៉ុបប៉េ» ។

<u>ច័ន្ទ-១៧ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ ជំពូក ១៤

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *រួចគាត់និយាយទៅគេថា អ្នករាល់គ្នាដឹងថា មនុស្សសាសន៍យូដាគ្មានច្បាប់នឹងសេពគប់នឹងសាសន៍ដទៃ ឬនឹងចូលទៅជិតគេឡើយ តែព្រះទ្រង់បានសំដែងឲ្យខ្ញុំដឹងថា មិនត្រូវរាប់អ្នកណាថាមិនស្អាត ឬមិនបរិសុទ្ធឡើយ ។ កិច្ចការ ១០:២៨*

បន្ទាប់ពីធ្វើបទសម្ភាសជាមួយនឹងលោកកូនេលាសរួចមក ទេវតានោះក៏បានយាងទៅឯលោកពេត្រុសនៅយ៉ុបប៉េ។ នៅពេលនោះលោកពេត្រុសកំពុងតែអធិដ្ឋាននៅលើដំបូលផ្ទះដែលលោកស្នាក់អាស្រ័យនៅ ហើយយើងបានអានដឹងថាលោក «គាត់នឹកឃ្លានជាខ្លាំង ចង់បរិភោគតែកំពុងដែលគេចាត់ចែងឲ្យ នោះគាត់លង់ស្មារតីទៅ»។ លោកពេត្រុសមិនមែនឃ្លានត្រឹមតែអាហារខាងរាងកាយប៉ុណ្ណោះទេ។ នៅពេលលោកបានសម្លឹងមើលពីលើដំបូលផ្ទះទៅ លោកបានឃើញទីក្រុងយ៉ុបប៉េនិងតំបន់ជនបទទាំងឡាយដែលនៅជុំវិញនោះ លោកបានស្រេកឃ្លានចង់បានសេចក្ដីសង្គ្រោះសម្រាប់បងប្អូនរួមជាតិរបស់លោកជាខ្លាំង។ លោកមានបំណងពុះពោរចង់ចង្អុលបង្ហាញប្រាប់ដល់ពួកគេអំពីបទទំនាយដែលទាក់ទងទៅនឹងការឈឺចាប់និងការសុគតរបស់ព្រះគ្រិស្ត។

នៅក្នុងការបើកសម្ដែងនោះលោកពេត្រុស «គាត់ឃើញមេឃចំហហើយមានប្រដាប់ ដូចជាសំពត់កម្រាលយ៉ាងធំ បានចុះមកចងទាំងបួនជ្រុងសម្រូតមកដល់ដី នៅក្នុងសំពត់នោះ មានសត្វជើងបួន សត្វព្រៃ សត្វលូនវារគ្រប់មុខ ដែលនៅលើដី និងសត្វហើរលើអាកាសដែរ ក៏ឮសំឡេងមាន

ព្រះបន្ទូលមកថា ពេត្រុសអើយ ចូរក្រោកឡើងសម្លាប់ ហើយបរិភោគទៅ តែពេត្រុសប្រកែកថា ទេព្រះអម្ចាស់ ដ្បិតទូលបង្គំមិនដែលទទួលទានអ្វី ដែលមិនស្អាតមិនបរិសុទ្ធនោះសោះ រួចឮសំឡេងនោះមកម្តងទៀតថា របស់អ្វីដែលព្រះបានសម្អាតហើយ នោះកុំឲ្យអ្នករាប់ថាជាមិនស្អាតឡើយ ការនោះមានមកគ្រប់បីដង រួចបានលើកប្រដាប់នោះ ឡើងទៅលើមេឃវិញ» ។

ការបើកសម្តែងនេះបាននាំមកឲ្យលោកពេត្រុសទាំងការស្តីបន្ទោស និងការបង្ហាត់បង្រៀន។ ការបើកសម្តែងនោះបានបង្ហាញពីព្រះរាជគោលបំនងរបស់ព្រះដល់លោក ដែលមានសេចក្តីថា ដោយការសុគតរបស់ព្រះគ្រិស្ត បានធ្វើឲ្យសាសន៍ដទៃបានទទួលមរតកជាមួយនឹងសាសន៍យូដា ជាអ្នកទទួលព្រះពរនៃសេចក្តីសង្គ្រោះដូចគ្នាដែរ។ ខណៈនោះពួកសិស្សមិនទាន់បានផ្សព្វផ្សាយដំណឹងល្អដល់សាសន៍ដទៃនៅឡើយទេ។ ជញ្ជាំងបែងចែកនៅកណ្តាលពួកគេ ដែលបានបំបែកដោយសារការសុគតរបស់ព្រះគ្រិស្តទៅហើយនោះ នៅមានក្នុងគំនិតរបស់ពួកគេនៅឡើយ ហើយការងាររបស់ពួកគេត្រូវបានកំណត់ព្រំដែនជាមួយនឹងសាសន៍យូដា ព្រោះពួកគេនៅតែសម្លឹងមើលទៅពួកសាសន៍ដទៃថាជាអ្នកដែលត្រូវកាត់ផ្តាច់ចេញពីដំណឹងល្អនៅឡើយ។ ឥឡូវនេះ ព្រះជាម្ចាស់បានស្វះស្វែងបង្រៀនដល់លោកពេត្រុសអំពីផែនការរបស់ព្រះដែលត្រូវលាតសន្ធឹងពាសពេញសកលលោក។

ពួកសាសន៍ដទៃជាច្រើនធ្លាប់ជាអ្នកស្តាប់ការអធិប្បាយរបស់លោកពេត្រុស និងសាវ័កដទៃទៀត យ៉ាងយកចិត្តទុកដាក់ ហើយពួកសាសន៍យូដាដែលនិយាយភាសាក្រិកជាច្រើននាក់បានទទួលជឿព្រះគ្រិស្ត ប៉ុន្តែ ការបើកសម្តែងដល់លោកកូនេលាសគឺជារឿងដ៏សំខាន់ដំបូងបង្អស់មួយនៅក្នុងចំណោមសាសន៍ដទៃ។

ពេលវេលាបានមកដល់ ដែលតំណាក់ការនៃកិច្ចការថ្មីទាំងស្រុងត្រូវបានធ្លាក់មកលើពួកជំនុំរបស់ព្រះគ្រិស្ត។ ទ្វារដែលពួកអ្នកជឿសាសន៍យូដា

ជាច្រើនបានបិទ ប្រឆាំងនឹងសាសន៍ដទៃនោះ ឥឡូវនេះត្រូវបានព្រះទាញបើកវិញហើយ។ ហើយពួកសាសន៍ដទៃដែលបានទទួលដំណឹងល្អត្រូវបានគេគោរពឲ្យមានភាពស្មើគ្នាជាមួយនឹងពួកសិស្សដែលជាសាសន៍យូដា ដោយមិនចាំបាច់ធ្វើពិធីផ្សេងៗ ឬកាត់ស្បែកឡើយ។

ព្រះបានធ្វើការប្រុងប្រយ័ត្នយ៉ាងអស្ចារ្យ ដើម្បីយកជ័យជម្នះលើការប្រកាន់ពូជសាសន៍ទាស់នឹងសាសន៍ដទៃ ដែលបានដក់ជាប់នៅក្នុងគំនិតរបស់លោកពេត្រុស ដោយសារការអប់រំជាសាសន៍យូដារបស់លោកនេះ! ដោយការបើកសម្តែងអំពីផ្ទាំងសំពត់និងសត្វដែលនៅក្នុងនោះ ព្រះបានស្វះស្វែងបង្វែរគំនិតនៃការប្រកាន់ពូជសាសន៍ របស់ពួកសាវ័ក និងដើម្បីបង្រៀនពីសេចក្តីពិតដ៏សំខាន់ថា នៅនគរឋានសួគ៌នឹងមិនមានការឲ្យតម្លៃចំពោះមនុស្សមិនស្មើគ្នាឡើយ គឺសាសន៍យូដានិងសាសន៍ដទៃសុទ្ធតែមានតម្លៃដូចៗគ្នា នៅចំពោះព្រះនេត្ររបស់ព្រះ និងថាសាសន៍ដទៃត្រូវបានបង្កើតជាអ្នកទទួលព្រះពរនិងកិត្តិយសនៃដំណឹងល្អ តាមរយៈព្រះគ្រិស្ត។

**<u>អង្គារ-១៨ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ ជំពូក ១៥**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ដូច្នេះ កំពុងដែលពេត្រុសគិតរំពឹងពីការជាក់ស្តែង នោះព្រះវិញ្ញាណមានព្រះបន្ទូលមកគាត់ថា មើល មានមនុស្ស៣នាក់មករកអ្នក ចូរក្រោកឡើងចុះទៅ ហើយទៅជាមួយនឹងគេចុះ កុំប្រកាន់ឡើយ ពីព្រោះគឺខ្ញុំហើយ ដែលចាត់ឲ្យគេមក ។ កិច្ចការ ១០:១៩-២០*

ខណៈដែលលោកពេត្រុសកំពុងតែពិចារណាអំពីអត្ថន័យនៃការបើកសម្តែនោះ បុរសដែលលោកកូនេលាសបានចាត់ឲ្យមកនោះក៏បានមកដល់ទីក្រុងយ៉ុបប៉េ ហើយឈរនៅមាត់ទ្វារផ្ទះជាងសម្លាប់ស្បែកនោះ។ បន្ទាប់មកព្រះវិញ្ញាណបានមានបន្ទូលទៅលោកថា «មើល មានមនុស្សបីនាក់មករកអ្នក ចូរក្រោកឡើងចុះ ហើយទៅជាមួយនឹងគេចុះ កុំប្រកាន់ឡើយ ពីព្រោះគឺខ្ញុំហើយ ដែលចាត់ឲ្យគេមក» ។

ចំពោះលោកពេត្រុសនេះគឺជាបញ្ហាដាច់ណាត់ ហើយជាបញ្ហាដែលលោកមានការស្ទាក់ស្ទើរនៅរៀងរាល់ជំហានដែលលោកបានឈានដើរដើម្បីបំពេញភារកិច្ចដែលនៅចំពោះមុនលោកនេះ ប៉ុន្តែ លោកមិនហ៊ានប្រកែកឡើយ។ លោក «ក៏ចុះទៅទទួលគេ ដោយពាក្យថា គឺខ្ញុំនេះហើយដែលអ្នករាល់គ្នារក តើមានការអ្វី?» ពួកគេក៏បានជម្រាបលោកអំពីភារកិច្ចតែមួយគត់របស់ពួកគេ ដោយនិយាយឡើងថា «លោកមេទ័ពកូនេលាសដែលជាមនុស្សសុចរិត ហើយកោតខ្លាចដល់ព្រះ មានសាសន៍យូដាទាំងអស់ធ្វើបន្ទាល់ល្អឲ្យលោកបានទទួលបង្គាប់នៃព្រះ ដោយសារទេវតាបរិសុទ្ធឲ្យចាត់មកអញ្ជើញលោកគ្រូទៅឯផ្ទះលោក ដើម្បីនឹងបានស្តាប់លោកគ្រូអធិប្បាយខ្លះ»។

ដោយស្តាប់បង្គាប់តាមការត្រាស់បង្គាប់ដែលលោកទើបតែនឹងបានទទួលពីព្រះនៅពេលថ្មីៗនេះ លោកក៏បានសន្យាថានឹងធ្វើដំណើរទៅជាមួយពួកគេ។ លុះព្រឹកស្អែកឡើង លោកក៏បានចេញដំណើរទៅសេសារាជាមួយនឹងបងប្អូនរួមជំនឿប្រាំមួយនាក់ ។ ឯអ្នកទាំងអស់នេះគឺជាសាក្សីអំពីពាក្យសម្តីដែលលោកបាននិយាយ និងសកម្មភាពទាំឡាយដែលលោកនឹងធ្វើនៅក្នុងអំឡុងពេលទៅសួរសុខទុក្ខមេទ័ពដែលជាសាសន៍ដទៃនេះ ព្រោះលោកពេត្រុសបានជ្រាបច្បាស់ថាគេនឹងកោះហៅលោកទៅសាកសួរ អំពីការបំពានដោយផ្ទាល់ទៅនឹងការបង្រៀនរបស់សាសន៍យូដានេះ។

នៅពេលលោកពេត្រុសបានចូលដល់ផ្ទះរបស់មេទ័ពដែលជាសាសន៍ដទៃនេះ លោកកូនេលាសមិនបានគោរពដូចជាមនុស្សធម្មតាទេ ប៉ុន្តែលោកបានស្វាគមន៍ក្នុងឋានៈជាភ្ញៀវកិត្តិយសដែលមកពីឋានសួគ៌ ដែលព្រះបានបញ្ជូនឲ្យមកជួបលោក។ ជាប្រពៃណីនៃបូព៌ាប្រទេស គេតែងតែឱនក្រាបនៅចំពោះស្តេច ឬអ្នកមានកិត្តិយសខ្ពង់ខ្ពស់ណាមួយ ឬកូនចៅឱនក្រាបនៅចំពោះឪពុកម្តាយ ប៉ុន្តែ លោកកូនេលាសបានគោរពដល់អ្នកដែលព្រះបានបញ្ជូនឲ្យមកបង្រៀនដល់លោកនេះ ដោយរបៀបដ៏គួរឲ្យរំភើប

គឺលោកបានលុតជង្គង់នៅទៀបជើងសាវ័ក ហើយថ្វាយបង្គំដល់លោក។ លោកពេត្រុសមានការរន្ធត់ជាខ្លាំង លោកបានលើកលោកមេទ័ពឡើង ដោយពោលថា «សូមក្រោកឡើង ខ្លួនខ្ញុំជាមនុស្សដូចលោកដែរ»។

កាលអ្នកបម្រើរបស់លោកមេទ័ពបានចេញទៅបំពេញកិច្ចការរបស់ពួកគេ ហើយលោកមេទ័ព «បានទាំងប្រមូលញាតិសន្តាន និងសំឡាញ់ស្និទ្ធស្នាលរបស់លោកមកផង» ដើម្បីឲ្យពួកគេអាចឮការអធិប្បាយរបស់លោកពេត្រុសផងដែរ ។ កាលលោកពេត្រុសបានចូលទៅដល់ លោកបានសង្កេតឃើញមនុស្សមួយក្រុមធំ រង់ចាំស្ដាប់ប្រសាសន៍របស់លោក។

លោកពេត្រុសបានមានប្រសាសន៍ទៅកាន់ពួកអ្នកបានមកជួបជុំគ្នានេះជាដំបូងអំពីប្រពៃណីរបស់សាសន៍យូដា ដោយមានប្រសាសន៍ថាការដែលសាសន៍យូដារស់នៅលាយឡំជាមួយនឹងសាសន៍ដទៃដូច្នេះ នោះត្រូវបានគេចាត់ទុកថាជាអំពើខុសច្បាប់ ព្រោះទង្វើនេះពាក់ព័ន្ធទៅនឹងការប្រមាថដល់ពិធីខាងជំនឿសាសនា។ លោកបានមានប្រសាសន៍ថា «អ្នករាល់គ្នាដឹងថា មនុស្សសាសន៍យូដាគ្មានច្បាប់នឹងសេពគប់នឹងសាសន៍ដទៃឬនឹងចូលទៅជិតគេឡើយ តែព្រះទ្រង់បានសម្ដែងឲ្យខ្ញុំដឹងថា មិនត្រូវរាប់អ្នកណាថាមិនស្អាត ឬមិនបរិសុទ្ធឡើយ ហេតុនោះបានជាកាលលោកចាត់គេឲ្យទៅហៅខ្ញុំ នោះខ្ញុំបានមកដោយឥតប្រកែកសោះ ដូច្នេះ ខ្ញុំសូមសួរលោក តើលោកឲ្យខ្ញុំមកមានការអ្វី?» ។

បន្ទាប់មក លោកកូនេលាសបានរៀបរាប់អំពីបទពិសោធន៍របស់លោក និងបន្ទូលរបស់ទេវតា ដោយមានប្រសាសន៍ជាសេចក្ដីសន្និដ្ឋានថា «ដូច្នេះ ខ្ញុំបានចាត់គេឲ្យទៅឯលោកភ្លាម ដែលលោកអញ្ជើញមកនេះក៏ល្អហើយ ឥឡូវនេះ យើងទាំងអស់នៅចំពោះព្រះ ដើម្បីនឹងស្ដាប់គ្រប់ទាំងសេចក្ដីដែលព្រះបានបង្គាប់មកលោក» ។

ពុធ-១៩ សីហា អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ ជំពូក ១៦

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ពេត្រុសក៏បើកមាត់និយាយថា ប្រាកដមែន ខ្ញុំយល់ឃើញថា ព្រះមិនរើសមុខអ្នកណាទេ គឺនៅក្នុងគ្រប់ទាំងសាសន៍ អស់អ្នកណាដែលកោតខ្លាចដល់ទ្រង់ ព្រមទាំងប្រព្រឹត្តសេចក្តីសុចរិត នោះគាប់ដល់ព្រះហឫទ័យទ្រង់ដែរ ។ កិច្ចការ ១០:៣៤-៣៥*

លោកពេត្រុសបានមានបប្រសាសន៍ថា «ប្រាកដមែន ខ្ញុំយល់ឃើញថា ព្រះមិនរើសមុខអ្នកណាទេ គឺនៅក្នុងគ្រប់ទាំងសាសន៍ អស់អ្នកណាដែលកោតខ្លាចដល់ទ្រង់ ព្រមទាំងប្រព្រឹត្តសេចក្តីសុចរិត នោះគាប់ដល់ព្រះហឫទ័យទ្រង់ដែរ»។

បន្ទាប់មក សាវ័កពេត្រុសបានអធិប្បាយជម្រាបដល់អ្នកស្តាប់ដ៏យកចិត្តទុកដាក់របស់លោកអំពីព្រះគ្រិស្ត ពីព្រះជន្មរបស់ទ្រង់ ការអស្ចារ្យរបស់ទ្រង់ ការក្បត់និងការឆ្កាងទ្រង់ ការមានព្រះជន្មរស់ឡើងវិញ និងការយាងឡើងទៅកាន់ឋានសួគ៌របស់ទ្រង់ និងអំពីព្រះរាជកិច្ចរបស់ទ្រង់នៅឯឋានសួគ៌ជាតំណាងនិងជាមេធាវីរបស់មនុស្សលោក។ ខណៈដែលលោកពេត្រុសបានចង្អុលបង្ហាញអំពីព្រះយេស៊ូវ ទៅកាន់អ្នកដែលមានវត្តមាននៅទីនោះ ថាជាសេចក្តីសង្ឃឹមរបស់បាបជនតែមួយគត់ លោកបានយល់ដោយខ្លួនឯងកាន់តែច្បាស់អំពីអត្ថន័យនៃការបើកសម្តែងដែលលោកបានឃើញ ហើយចិត្តរបស់លោកបានត្រេកត្រអាលជាមួយនឹងវិញ្ញាណនៃសេចក្តីពិតដែលលោកកំពុងបង្ហាញដល់ពួកគេនោះ ។

រំពេចនោះ សេចក្តីថ្លែងការណ៍នោះត្រូវបានរំខានដោយការយាងចុះមកនៃព្រះវិញ្ញាណបរិសុទ្ធ។ «កាលពេត្រុសកំពុងតែអធិប្បាយនៅឡើយ នោះព្រះវិញ្ញាណបរិសុទ្ធក៏យាងចុះមក សណ្ឋិតលើអស់អ្នកដែលកំពុងតែស្តាប់ព្រះបន្ទូល ឯពួកអ្នកជឿ ក្នុងពួកកាត់ស្បែកទាំងប៉ុន្មាន ដែលមកជាមួយនឹងពេត្រុស គេក៏មានសេចក្តីអស្ចារ្យជាខ្លាំង ពីដំណើរដែលអំណោយទាន ជាព្រះវិញ្ញាណបរិសុទ្ធ បានចាក់មកលើពួកសាសន៍ដទៃដូច្នេះដែរ

ផ្សិតគេឮអ្នកទាំងនោះនិយាយភាសាដទៃ ហើយសរសើរតម្កើងដល់ព្រះ»។

«នោះពេត្រុសសួរថា តើមានអ្នកណាអាចនឹងឃាត់ មិនឲ្យធ្វើបុណ្យជ្រមុជទឹកដល់អ្នកទាំងនេះបានឬទេ ដែលពួកគេបានទទួលព្រះវិញ្ញាណបរិសុទ្ធដូចជាយើងដែរ គាត់ក៏បង្គាប់ឲ្យធ្វើបុណ្យជ្រមុជឲ្យគេដោយនូវព្រះនាមព្រះអម្ចាស់» ។

ដូច្នេះ ដំណឹងល្អត្រូវបាននាំនាំទៅកាន់ជនចំឡែកនិងជនបរទេស ធ្វើឲ្យពួកគេបានក្លាយទៅជាពលរដ្ឋជាមួយនឹងពួកបរិសុទ្ធ និងជាក្រុមគ្រួសាររបស់ព្រះផងដែរ ។ ការផ្លាស់ប្តូរជំនឿរបស់លោកកូនេលាសនិងក្រុមគ្រួសាររបស់លោកគឺជាផលផ្លែនៃចម្រូតដំបូងបង្អស់ដែលត្រូវប្រមូលទុកដាក់។ កិច្ចការនៃព្រះគុណត្រូវបានផ្សព្វផ្សាយពាសពេញទីក្រុងនៃសាសន៍ដទៃមួយនេះ ចេញពីគ្រួសារនោះ ។

សព្វថ្ងៃនេះ ព្រះក៏កំពុងស្វែងរកមនុស្សទាំងអ្នកមានត្រកូលខ្ពស់ និងទាំងអ្នកទន់ទាបផងដែរ។ មានមនុស្សដូចជាលោកកូនេលាសនេះជាច្រើនអ្នកដែលព្រះជាម្ចាស់ចង់ភ្ជាប់ទំនាក់ទំនងទៅនឹងកិច្ចការរបស់ទ្រង់នៅលើពិភពលោកនេះ។ ពួកគេមានការអាណិតអាសូរដល់រាស្ត្ររបស់ព្រះ ប៉ុន្តែចំណងដែលចងគេភ្ជាប់ជាមួយនឹងលោកិយមាំខ្លាំងណាស់។ ដើម្បីទទួលយកតួនាទីបំពេញកិច្ចការថ្វាយព្រះគ្រិស្ត នោះតម្រូវការឲ្យមានសេចក្តីក្លាហានខាងសីលធម៌។ ពួកជំនុំត្រូវតែខំប្រឹងប្រែងដើម្បីមនុស្សទាំងនេះ ដែលកំពុងឋិតនៅក្នុងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ ដោយសារតែការទទួលខុសត្រូវនិងការសេពគប់របស់ពួកគេ។

ព្រះត្រាស់ហៅអ្នកធ្វើការដ៏ស្មោះត្រង់និងបន្ទាបខ្លួន ឲ្យធ្វើការជាមួយមនុស្សដែលមានវណ្ណៈខ្ពង់ខ្ពស់។ ព្រះនឹងនាំមកនូវការអស្ចារ្យដើម្បីឲ្យមានការផ្លាស់ប្តូរជំនឿ ជាការអស្ចារ្យដែលឥឡូវនេះមនុស្សមើលមិនឃើញ ។ មនុស្សដ៏ឧដុង្គឧត្តមបំផុតនៅលើលោកិយនេះ មិនហួសពីព្រះចេស្តានៃព្រះដែលធ្វើការយ៉ាងអស្ចារ្យនោះឡើយ។ ប្រសិនបើមនុស្សដែលជាអ្នកធ្វើការ

ជាមួយនឹងព្រះរាជបំណងព្រះហឫទ័យរបស់ព្រះ គឺជាមនុស្សដែលចេះឆ្លៀតឱកាស ដោយធ្វើកិច្ចការរបស់ខ្លួនយ៉ាងក្លាហាន និងស្មោះត្រង់ ព្រះនឹងបំផ្លាស់បំប្រែមនុស្សដែលមានតួនាទីជាអ្នកទទួលខុសត្រូវ ជាមនុស្សដែលមានប្រាជ្ញានិងមានឥទ្ធិពល ។ មនុស្សជាច្រើននឹងទទួលយកគោលការណ៍របស់ព្រះតាមរយៈព្រះចេស្តារបស់ព្រះវិញ្ញាណបរិសុទ្ធ។ អ្នកដែលបានផ្លាស់ប្រែមកឯសេចក្តីពិត ពួកគេនឹងក្លាយជាភ្នាក់ងារនៅក្នុងព្រះហស្តរបស់ព្រះសម្រាប់បញ្ជូនពន្លឺ។ ពួកគេនឹងមានបន្ទុកពិសេសសម្រាប់មនុស្សដទៃ ក្នុងស្រទាប់វណ្ណៈដែលគេបោះបង់ចោលនេះ មនុស្សនឹងលះបង់ពេលវេលានិងលុយកាក់សម្រាប់កិច្ចការរបស់ព្រះជាម្ចាស់ ហើយលទ្ធផលល្អៗ និងអំណាចនឹងត្រូវបន្ថែមទៅក្នុងពួកជំនុំ។

<u>ព្រហស្បតិ៍-២០ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃះពង្សាវតារក្សត្រទី១ ជំពូក ១៧

**ខព្រះគម្ពីរប្រចាំថ្ងៃ**: *គឺពីព្រះយេស៊ូវ ពីស្រុកណាសារ៉ែត ដែលព្រះបានចាក់ព្រះវិញ្ញាណបរិសុទ្ធ និងព្រះចេស្តាឲ្យមកសណ្ឋិតលើទ្រង់ ហើយទ្រង់បានយាងចុះឡើងធ្វើការល្អ ព្រមទាំងប្រោសឲ្យអស់អ្នក ដែលត្រូវអារក្សសង្កត់សង្កិនបានជាផង ដ្បិតព្រះបានគង់ជាមួយនឹងទ្រង់។ កិច្ចការ ១០:៣៨*

ដោយសារតែលោកកូនេលាសកំពុងបានរស់នៅដោយការស្តាប់បង្គាប់នូវគ្រប់ទាំងការណែនាំដែលលោកបានទទួល នោះព្រះបានបង្គាប់ឲ្យលោកបានទទួលសេចក្តីពិតកាន់តែច្រើនថែមទៀត។ ព្រះបានចាត់អ្នកនាំសារចេញពីព្រះរាជវាំងនៃឋានសួគ៌ មកឯនាយទាហានសាសន៍រ៉ូម និងលោកពេត្រុសដើម្បីនាំលោកកូនេលាសឲ្យជួបជាមួយនឹងអ្នកដែលអាចដឹកនាំលោកឲ្យទទួលពន្លឺកាន់តែធំ ។

នៅលើពិភពលោកយើងនេះមានមនុស្សជាច្រើនដែលនៅជិតនគររបស់ព្រះ ជាងការដែលយើងគិត។ ព្រះជាម្ចាស់មានអលង្កាជាច្រើនសម្រាប់អ្នកដែលទ្រង់នឹងដឹកនាំអ្នកនាំសាររបស់ទ្រង់ឲ្យទៅជួប នៅក្នុងពិភពលោក

ដែលមានបាបនេះ ។ មានមនុស្សដែលឈរនៅខាងព្រះគ្រិស្តនៅគ្រប់ទិសទី។ មនុស្សជាច្រើនដែលផ្តល់តម្លៃដល់ព្រះប្រាជ្ញាញាណរបស់ព្រះធំជាងអត្ថប្រយោជន៍នានានៅក្នុងលោកិយ ហើយដែលនឹងក្លាយជាអ្នកបញ្ចេញពន្លឺដ៏ស្មោះត្រង់ ។ ដោយបានជំរុញដោយសេចក្តីស្រឡាញ់របស់ព្រះគ្រិស្តពួកគេនឹងទាក់ទាញមនុស្សជាច្រើនឲ្យមកឯទ្រង់ ។

ពេលដែលពួកបងប្អូននៅយូដាបានឮថា លោកពេត្រុសបានទៅផ្ទះលោកកូនេលាស ហើយបានអធិប្បាយប្រាប់ដល់អ្នកដែលបានជួបប្រជុំគ្នានៅទីនោះ ពួកគេមានការភ្ញាក់ផ្អើលជាខ្លាំង ហើយក៏បានប្រឆាំងនឹងលោក ។ ពួកគេបារម្ភក្រែងកិច្ចការនោះនឹងជះឥទ្ធិពលផ្ទុយពីការបង្រៀនរបស់ពួកគេដែលមើលទៅហាក់ដូចជាការព្រហើនសម្រាប់ពួកគេ។ ហើយកាលពួកគេបានជួបនឹងលោកពេត្រុសនៅពេលក្រោយមកទៀត ពួកគេក៏បានស្តីបន្ទោសលោកយ៉ាងធ្ងន់ធ្ងរ ដោយបាននិយាយថា «លោកបានចូលទៅឯពួកមនុស្សដែលមិនកាត់ស្បែក ក៏បានពិសាជាមួយនឹងគេផង»។

លោកពេត្រុសបានលាតត្រដាងរឿងរ៉ាវបង្ហាញប្រាប់ដល់ពួកគេ។ លោកបានភ្ជាប់បទពិសោធន៍របស់លោកទៅនឹងការបើកសម្តែងរបស់លោក និងបានអង្វរករថាការបើកសម្តែងនោះបានទូន្មានលោកឲ្យលែងរក្សាការបែងចែករវាងការកាត់ស្បែកនិងការមិនកាត់ស្បែកតទៅទៀត ឬឈប់ឲ្យសម្លឹងមើលទៅសាសន៍ដទៃថាជាមនុស្សមិនស្អាតតទៅទៀតផងដែរ។ លោកបានប្រាប់ដល់ពួកគេអំពីការត្រាស់បង្គាប់របស់ព្រះឲ្យលោកចេញទៅឯពួកសាសន៍ដទៃ អំពីការមកដល់របស់អ្នកបម្រើលោកកូនេលាស អំពីការធ្វើដំណើរទៅសេសារា និងអំពីការជួបប្រជុំជាមួយនឹងលោកកូនេលាសថែមទៀតផង។ លោកបានរៀបរាប់អំពីសាច់រឿងនៃបទសម្ភាសន៍ជាមួយនឹងលោកមេទ័ពដែលក្រោយមកបានជម្រាបដល់លោកអំពីការបើកសម្តែងដែលព្រះបានណែនាំឲ្យចាត់អ្នកបម្រើឲ្យទៅរកលោកពេត្រុសនោះ។

លោកបានមានប្រសាសន៍ ទាក់ទងទៅនឹងបទពិសោធន៍របស់លោក

យ៉ាងដូច្នេះថា «កាលខ្ញុំចាប់តាំងនិយាយទៅនោះព្រះវិញ្ញាណបរិសុទ្ធក៏យាងចុះមកសណ្ឋិតលើគេ ដូចជាបានសណ្ឋិតលើយើងរាល់គ្នាកាលពីដើមដែរ នោះខ្ញុំបាននឹកឃើញពីសេចក្ដីដែលព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា លោកយ៉ូហានបានធ្វើបុណ្យជ្រមុជដោយទឹក តែអ្នករាល់គ្នានឹងទទួលបុណ្យជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធវិញ ដូច្នេះ បើសិនជាព្រះបានប្រទានអំណោយទានទៅគេ ដូចជាបានប្រទានមកយើងដែរ ដោយជឿដល់ព្រះអម្ចាស់យេស៊ូវគ្រិស្ដ ចុះតើខ្ញុំជាអ្វីដែលអាចនឹងឃាត់ព្រះបាន?»

ដោយបានឮរឿងរ៉ាវទាំងនោះ ពួកបងប្អូនទាំងនោះក៏ស្ងៀមស្ងាត់ទៅ ។ ពួកគេបានជឿជាក់ថាកិច្ចការរបស់លោកពេត្រុសគឺជាការសម្រេចតាមផែនការរបស់ព្រះដោយផ្ទាល់ និងថាការប្រកាន់ពូជសាសន៍និងការបែងចែករបស់ពួកគេ គឺផ្ទុយទៅនឹងផែនការនៃដំណឹងល្អទាំងស្រុង ពួកគេបានសរសើរតម្កើងដល់ព្រះ ដោយនិយាយថា «ដូច្នេះ ព្រះទ្រង់ក៏ប្រោសប្រទានការប្រែចិត្តដល់ពួកសាសន៍ដទៃឲ្យគេមានជីវិតដែរហ្ន៎!»

ដូច្នេះ ការប្រកាន់ពូជសាសន៍ត្រូវបានបំបែក ដោយគ្មានទំនាស់អ្វីកើតឡើងឡើយ ការបែងចែកដែលបានបង្កើតឡើងដោយសារប្រពៃណីជាច្រើនជំនាន់មកហើយ នោះក៏ត្រូវបានបោះបង់ចោល ហើយព្រះបានបើកផ្លូវឲ្យដំណឹងល្អត្រូវបានប្រកាសដល់សាសន៍ដទៃយ៉ាងទូលំទូលាយ។

**ជំពូកទី**
**១៥**

# ការរំដោះចេញពីគុក

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ១២:១-២៣ ។*

<u>សុក្រ-២១ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ ជំពូក ១៨

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *នៅគ្រានោះ ស្ដេចហេរ៉ូឌ ទ្រង់លូកព្រះហស្តទៅ ចាប់ធ្វើទុក្ខដល់ពួកជំនុំខ្លះ ក៏សំឡាប់យ៉ាកុប ជាបងយ៉ូហាន ដោយដាវផង។ កិច្ចការ ១២:១-២*

«នៅគ្រានោះ ស្ដេចហេរ៉ូឌ ទ្រង់លូកព្រះហស្តទៅចាប់ធ្វើទុក្ខដល់ពួកជំនុំខ្លះ»។ កាលណោះរដ្ឋាភិបាលនៃប្រទេសយូដាឋិតនៅក្នុងកណ្ដាប់ដៃរបស់ស្ដេចហេរ៉ូឌ អ័គ្រីប៉ា ព្រះនាងក្លូឌាសនៅក្រោមអំណាចព្រះចៅអធិរាជរ៉ូម។ ស្ដេចហេរ៉ូឌក៏បានគ្រប់គ្រងនគរទាំងបួននៅសមុទ្រកាលីឡេផងដែរ ។ ព្រះអង្គជាស្ដេចដែលវង្វេងចេញពីជំនឿសាសនាសាសន៍យូដាយ៉ាងក្អេងក្អាងហើយពុះកញ្ជ្រោលក្នុងការអនុវត្តន៍ពិធីសាសនាតាមច្បាប់នៃសាសន៍យូដាយ៉ាងជាក់ស្ដែង។ ដោយចង់ផ្គាប់ចិត្តសាសន៍យូដា ដោយសង្ឃឹមថាធ្វើដូច្នេះនឹងអាចរក្សារាជបល្ល័ង្កនិងព្រះកិត្តិនាមរបស់ទ្រង់បាន ព្រះអង្គបានចាត់ចែងអនុវត្តការធ្វើទុក្ខបៀតបៀនដល់ពួកជំនុំរបស់ព្រះគ្រិស្ដ រឹបអូសយកផ្ទះសម្បែងនិងទ្រព្យសម្បត្តិរបស់ពួកអ្នកជឿ ហើយចាប់សមាជិកសំខាន់ៗរបស់ពួកជំនុំដាក់គុក។ ព្រះអង្គបានចាប់លោកយ៉ាកុបជាបងរបស់លោកយ៉ូហានដាក់គុកហើយបានបញ្ជូនពេជ្ឈឃាតឲ្យទៅប្រហារជីវិតលោកដោយដាវទៀតផង ហើយស្ដេចហេរ៉ូឌមួយអង្គទៀត បានធ្វើឲ្យហោរាយ៉ូហានត្រូវបានគេកាត់ក្បាលផងដែរ។ ដោយឃើញដូច្នោះ ពួកយូដាក៏ពេញចិត្តទៅនឹងការចាប់

លោកពេត្រុសដាក់គុកផងដែរ ។

ស្តេចបានអនុវត្តការពិឃាតដ៏ឃោរឃៅនេះនៅក្នុងឱកាសបុណ្យរំលង។ នៅពេលដែលសាសន៍យូដាកំពុងប្រារព្ធពិធីរំដោះចេញពីប្រទេសអេស៊ីព្ទរបស់ពួកគេ និងធ្វើពុតជាខ្វល់ខ្វាយជាខ្លាំងចំពោះក្រឹត្យវិន័យរបស់ព្រះ នៅពេលជាមួយគ្នានោះ ពួកគេក៏កំពុងបំពានទៅនឹងគោលការណ៍នៃក្រឹត្យវិន័យរបស់ព្រះ ដោយការធ្វើទុក្ខបៀតបៀននិងការសម្លាប់អ្នកដែលជឿដល់ព្រះគ្រិស្តផងដែរ ។

មរណភាពរបស់លោកយ៉ាកុបបានធ្វើឲ្យមានសេចក្តីទុក្ខសោក និងភាពស្រឡាំងកាំងជាពន់ពេក នៅក្នុងចំណោមពួកអ្នកជឿ។ កាលលោកពេត្រុសនៅក្នុងគុកនៅឡើយ ពួកជំនុំទាំងមូលបានប្រជុំគ្នាអធិដ្ឋាននិងតមអត់ ។

សកម្មភាពរបស់ស្តេចហេរ៉ូឌក្នុងការសម្លាប់លោកយ៉ាកុប ត្រូវបានសាសន៍យូដាអបអរសាទរ ទោះបីជាមានអ្នកខ្លះបានត្អូញត្អែរក្នុងលក្ខណៈជាសម្ងាត់ក៏ដោយ ព្រោះការប្រហារជីវិតសាធារណៈនេះនឹងបានសម្លុតគំរាមដល់ពួកអ្នកជឿ និងអ្នកដែលអាណិតអាសូរដល់ពួកគេ បានកាន់តែខ្លាំង។ ហេតុដូច្នេះ ស្តេចហេរ៉ូឌបានទតឃើញថាការសម្លាប់លោកពេត្រុសឲ្យប្រជារាស្ត្រមើលឃើញជាសាធារណៈ នឹងបំពេញចិត្តដល់សាសន៍យូដាបានខ្លាំងជាងការគ្រាន់តែឃុំឃាំងលោកទុក។ ប៉ុន្តែ មានអ្នកខ្លះបានស្នើយោបល់ថាប្រសិនបើនាំសាវ័កជើងចាស់នេះចេញទៅប្រហារជីវិតនៅខាងក្រៅទីក្រុងយេរូសាឡិមនោះមានសុវត្ថិភាពជាង។ ពួកគេបារម្ភក្រែងការមើលឃើញការប្រហារជីវិតសាវ័កនឹងបំផុសការអាណិតអាសូររបស់ពួកបណ្តាជនឡើង។

ពួកសង្ឃនិងពួកចាស់ទុំក៏ព្រួយបារម្ភខ្លាចក្រែងលោកពេត្រុសអាចនឹងធ្វើការអំពាវនាវដ៏មានអំណាចណាមួយដែលនឹងបំផុសប្រជារាស្ត្រឲ្យសិក្សាអំពីព្រះជន្ម និងអត្តចរិតរបស់ព្រះយេស៊ូវ ជាញឹកញាប់ ជាការអំពាវនាវដែលពួកគេធ្លាប់ទប់ទល់មិនបាន ជាមួយនឹងការជជែកវែកញែកទាំងឡាយនោះ ។ ចិត្តពុះកញ្ជ្រោលរបស់លោកពេត្រុសក្នុងការគាំទ្រដល់កិច្ចការរបស់ព្រះគ្រិស្ត

បានដឹកនាំមនុស្សជាច្រើន ឲ្យប្រកាន់ជំហរនៅខាងដំណឹងល្អ ហើយពួកមេដឹកនាំសាសនាបារម្ភក្រែងលោកមានឱកាសការពារជំនឿរបស់លោកនៅចំពោះហ្វូងមនុស្ស ដែលបានធ្វើដំណើរមកកាន់ទីក្រុងដើម្បីថ្វាយបង្គំព្រះ ធ្វើឲ្យពួកគេទាមទារឲ្យស្តេចក៏ដោះលែងលោកពីកណ្តាប់ដៃទ្រង់ ។

**<u>សៅរ៍-២២ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ ជំពូក ១៩**

**ខព្រះគម្ពីរប្រចាំសប្តាហ៍:** *ព្រះយេហូវ៉ាទ្រង់ជាថ្មដា ជាបន្ទាយ ហើយជាអ្នកជួយសង្គ្រោះរបស់ទូលបង្គំ គឺជាព្រះនៃទូលបង្គំ ជាថ្មដាដែលទូលបង្គំយកជាទីពឹង ក៏ជាខែល ជាស្នែងនៃសេចក្តីសង្គ្រោះរបស់ទូលបង្គំ ហើយជាប៉មយ៉ាងខ្ពស់ផង។ ទំនុកតម្កើង ១៨:២*

នៅពេលផ្អាកការប្រហារជីវិតជាបណ្តោះអាសន្ននេះ ខណៈដែលការប្រហារជីវិតដល់លោកពេត្រុសត្រូវបានគេលើកពេលទៅធ្វើនៅក្រោយពិធីបុណ្យរំលងវិញ សមាជិកពួកជំនុំមានឱកាសពិនិត្យមើលចិត្តខ្លួនឯង និងអធិដ្ឋានយ៉ាងស្មោះអស់ពីចិត្ត។ ពួកគេបានអធិដ្ឋានឲ្យលោកពេត្រុសឥតឈប់ឈរ ព្រោះពួកគេបានដឹងថាលោកមិនរួចផុតពីការប្រហារជីវិតបានឡើយ។ ពួកគេបានដឹងថាពួកគេបានមកដល់តំណាក់ការមួយដែលពួកជំនុំរបស់ព្រះគ្រិស្តនឹងត្រូវគេបំផ្លាញ ជាក់ជាមិនខាន ប្រសិនបើគ្មានជំនួយពិសេសមកពីព្រះទេនោះ។

នៅពេលជាមួយគ្នានេះដែរ ពួកអ្នកថ្វាយបង្គំព្រះដែលបានមកពីគ្រប់ជាតិសាសន៍បានស្វែងរកព្រះវិហារដែលបានថ្វាយដល់ព្រះសម្រាប់ថ្វាយបង្គំ។ ព្រះវិហារនោះបានចែងចាំងដោយមាសនិងត្បូងដ៏មានតម្លៃ ធ្វើឲ្យពួកបណ្តាជនមើលទៅឃើញមានសម្រស់ល្អឆើតនិងមានភាពរុងរឿងជាខ្លាំង។ ប៉ុន្តែ ពួកគេមិនអាចរកព្រះយេហូវ៉ាឃើញនៅកន្លែងដ៏ជាទីស្រឡាញ់នោះទៀតទេ។ សាសន៍អ៊ីស្រាអែលបានលែងលះខ្លួនឯងចេញពីព្រះហើយ ។ នៅពេលដែលព្រះគ្រិស្តបានទតមើលទៅខាងក្នុងព្រះវិហារជាពេលចុងក្រោយ

បង្អស់ នៅជិតចុងបញ្ចប់នៃព្រះរាជកិច្ចរបស់ព្រះអង្គនៅលើផែនដី ព្រះអង្គបានមានបន្ទូលថា «មើល ផ្ទះឯងនឹងត្រូវចោលស្ងាត់ទុកឲ្យឯង» (ម៉ាថាយ ២៣:៨)។ ចាប់តាំងពីពេលនោះមក ព្រះអង្គបានហៅព្រះវិហារនោះថាជាតំណាក់នៃព្រះវរបិតារបស់ទ្រង់។ ប៉ុន្តែ នៅពេលដែលព្រះរាជបុត្រានៃព្រះបានយាងហួសកំផែងទាំងនេះ ព្រះវត្តមានរបស់ព្រះក៏ត្រូវបានដកចេញពីព្រះវិហារដែលបានសាងសង់សម្រាប់សិរីល្អរបស់ទ្រង់នេះ ជារៀងរហូតដែរ ។

ការប្រហារជីវិតរបស់លោកពេត្រុសគឺជាការកំណត់ទុកចុងក្រោយបង្អស់ ប៉ុន្តែ ការអធិដ្ឋានរបស់បងប្អូនអ្នកជឿបានឡើងទៅដល់ឋានសួគ៌ ហើយនៅពេលដែលកម្លាំងនិងការអាណិតអាសូររបស់ពួកគេបានអំពាវនាវ ស្វែងរកជំនួយយ៉ាងខ្លាំងក្លា ពួកទេវតារបស់ព្រះកំពុងតែឃ្លាំមើលពីលើសាវ័កដែលកំពុងតែជាប់គុកនោះ ។

ដោយនឹកចាំពីការរំដោះចេញពីគុករបស់ពួកសាវ័កកាលពីលើកមុន លើកនេះស្តេចហេរ៉ូឌបានបន្ថែមការប្រុងប្រយ័ត្នទ្វេមួយជាពីរ។ ដើម្បីការពារកុំឲ្យមានលទ្ធភាពអាចចេញរួច ស្តេចបានដាក់ទាហាន ១៦ នាក់ឲ្យយាមលោកពេត្រុស តាមវេនខុសៗគ្នា ទាំងយប់ទាំងថ្ងៃ។ នៅក្នុងបន្ទប់ឃុំឃាំងរបស់លោក គេបានដាក់ច្រវាក់លោកជាប់នឹងទាហានពីរនាក់។ លោកមិនអាចកម្រើកខ្លួនដោយមិនឲ្យទាហានទាំងពីរនាក់ដឹងបានឡើយ។ ដោយទ្វារគុកមាំៗបិទយ៉ាងជិត ហើយមានអ្នកយាមដ៏រឹងមាំនៅតាមទ្វារទាំងនោះផង មិនមានមធ្យោបាយរបស់មនុស្សណាមួយអាចរំដោះឬគេចខ្លួនបានឡើយ។ ប៉ុន្តែ ការតឹងតែងរបស់មនុស្សគឺជាឱកាសរបស់ព្រះ ។

ស្តេចបានដាក់លោកពេត្រុសក្នុងបន្ទប់ឃុំឃាំងដែលមានជញ្ជាំងធ្វើពីថ្មមានទ្វារធ្វើពីចម្រឹងនិងរនុកមាំៗ ហើយមានទាហានយាមដើម្បីរក្សាសុវត្ថិភាពអ្នកទោស ។ ប៉ុន្តែ របានិងរនុកនិងទាហានរ៉ូម ដែលកាត់ផ្តាច់លទ្ធភាពនៃជំនួយរបស់មនុស្ស រឹតតែធ្វើឲ្យជោគជ័យរបស់ព្រះក្នុងការរំដោះលោកពេត្រុស

កាន់តែពេញខ្នាតឡើង។ ស្ដេចហេរ៉ូឌបានលើកព្រះហស្តប្រឆាំងនឹងព្រះដែលមានសព្វព្រះចេស្ដា ហើយព្រះអង្គ (ស្ដេច) ត្រូវបរាជ័យយ៉ាងធ្ងន់ធ្ងរ។ ដោយការបញ្ចេញព្រះចេស្ដារបស់ទ្រង់ ព្រះអង្គហៀបនឹងជួយសង្គ្រោះជីវិតដ៏មានតម្លៃដែលសាសន៍យូដាមានផែនការនឹងបំផ្លាញនេះ ។

<u>អាទិត្យ-២៣ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ ជំពូក ២០

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ទេវតានៃព្រះយេហូវ៉ាចោមរោមនៅជុំវិញនៃអស់អ្នកដែលកោតខ្លាចដល់ទ្រង់ ហើយក៏ជួយគេឲ្យរួច។ ទំនុកតម្កើង ៣៤:៧*

ពេលនោះជាយប់ចុងក្រោយបង្អស់នៃការស្នើកាត់ទោសប្រហារជីវិត។ ព្រះបានចាត់ទេវតាដ៏មានអំណាចពីឋានសួគ៌  ឲ្យមករំដោះលោកពេត្រុស។ ទ្វារដ៏រឹងមាំដែលបិទឃុំឃាំងមនុស្សបរិសុទ្ធរបស់ព្រះ បានរបើកឡើងដោយគ្មានដៃមនុស្សបើក។ ទេវតានៃព្រះដ៏ខ្ពស់បំផុតបានយាងចេញមក ហើយទ្វារនោះក៏បានបិទយ៉ាងជិតដូចដើមវិញ នៅពីក្រោយខ្នងលោក ។ លោកបានយាងចូលទៅក្នុងបន្ទប់ឃុំឃាំង ហើយលោកពេត្រុសកំពុងតែសម្រាន្តលង់លក់នៅទីនេះ។

ពន្លឺនៅជុំវិញទេវតាបានបំភ្លឺពាសពេញទាំងបន្ទប់ឃុំឃាំង ប៉ុន្តែ មិនបានដាស់សាវ័ក ពេត្រុសឲ្យភ្ញាក់ទេ។ លោកសម្រាន្តលង់លក់ រហូតទាល់តែប៉ះនឹងដៃទេវតា និងឮសំឡេងមានបន្ទូលថា «ចូរក្រោកឡើងជាប្រញាប់» ទើបលោកភ្ញាក់ឡើង ឃើញបន្ទប់ឃុំឃាំងភ្លឺព្រោងព្រាតដោយពន្លឺនៃឋានសួគ៌ ហើយឃើញទេវតាមួយអង្គដែលមានសិរីរុងរឿងអស្ចារ្យឈរនៅក្បែរលោក ។ លោកបានស្ដាប់តាមបន្ទូលរបស់ទេវតាដែលបានថ្លែងមកកាន់លោក ហើយនៅពេលដែលលោកបានក្រោកឡើង លោកបានលើកដៃរបស់លោក ហើយបានដឹងទាំងស្រពិចស្រពិលថាច្រវាក់បានរបូតជ្រុះពីកដៃរបស់លោក។

សំឡេងនៃទេវតាដែលជាអ្នកនាំសារនៃឋានសួគ៌បានបង្គំលោកម្ដងទៀតថា «ចូរក្រវាត់ខ្លួន ហើយពាក់ស្បែកជើងទៅ» ។ លោកពេត្រុសក៏បានស្ដាប់

តាមភ្លាមដូចមុន ដោយសម្លឹងមើលទេវតាមិនដាក់ភ្នែក ទាំងងឿងឆ្ងល់ ដោយគិតថាខ្លួនកំពុងតែយល់សប្តិឬកំពុងតែនិម្មិតឃើញ។ ទេវតាបានបង្គាប់ម្តងទៀតថា «ចូរពាក់អាវមកតាមខ្ញុំចុះ»។ ទេវតាបានរំកិលខ្លួនឆ្ពោះទៅមាត់ទ្វារដោយមានលោកពេត្រុសដែលធ្លាប់តែនិយាយប៉ប៉ោចដើរតាមផង ឥឡូវនេះបែរជាស្ងាត់មាត់ដោយការភ្ញាក់ផ្អើលទៅវិញ។ អ្នកទាំងពីរបានដើររំលងទាហាន ហើយបានមកដល់ទ្វារដែលមានរនុកធំៗ ដែលរបើកឡើងហើយបិទទៅវិញជាបន្ទាន់ ដោយខ្លួនឯង ខណៈដែលអ្នកយាមទាំងខាងក្នុងនិងទាំងខាងក្រៅកំពុងនៅស្ងៀមឥតកម្រើក នៅតាមកន្លែងរៀងៗខ្លួន ។

ពួកលោកក៏បានមកដល់មាត់ទ្វារទីពីរដែលមានទាហានយាមទាំងខាងក្នុង និងទាំងខាងក្រៅដូចគ្នា។ ទ្វារនោះក៏បានរបើកឡើងដូចទ្វារទីមួយដែរ ដោយមិនមានឮសូរកកិតអ្វីបន្តិចឡើយ ។ លោកទាំងពីរក៏បានចេញផុត ហើយទ្វារនោះក៏បានបិទទៅវិញដោយខ្លួនឯងយ៉ាងជិតដូចដើម ។ លោកក៏បានឆ្លងកាត់ទ្វារទីបីដូចលើកមុនៗ ហើយបានដឹងថាពួកលោកកំពុងតែនៅលើផ្លូវមួយ។ ទេវតាហោះសំកាំងនៅពីមុខហ៊ុំព័ទ្ធដោយពន្លឺនៃភាពត្រចះត្រចង់ ហើយលោកពេត្រុសបានវិលវល់គំនិត ហើយដើរតាមអ្នករំដោះរបស់លោក ដោយនៅតែជឿថាលោកនៅក្នុងយល់សប្តិនៅឡើយ ។ ដូច្នេះ ពួកលោកក៏បានដើរឆ្លងកាត់ផ្លូវមួយ ហើយបន្ទាប់មកបេសកកម្មរបស់ទេវតាក៏បានបញ្ចប់ លោកក៏បានបាត់ខ្លួនពីលោកពេត្រុសទៅ។

ពន្លឺនៃឋានសួគ៌ក៏រលាយបាត់ដែរ ហើយលោកពេត្រុសបានដឹងថាលោកនៅក្នុងភាពងងឹតចាក់ភ្នែកមិនយល់ ប៉ុន្តែ បន្តិចក្រោយមកភ្នែករបស់លោកក៏ស៊ាំនឹងភាពងងឹត ហើយភាពងងឹតនោះក៏ហាក់ដូចជាបានធូរស្បើយបន្តិច ទើបលោកបានដឹងខ្លួនថាលោកកំពុងតែនៅលើផ្លូវមួយដ៏ស្ងាត់ជ្រងំតែម្នាក់ឯង ដែលមានតែជំនោររាត្រីដ៏ត្រជាក់បក់ផាត់មកលើថ្ពាសរបស់លោកប៉ុណ្ណោះ។ ឥឡូវនេះ លោកបានដឹងថាលោករួចពីគុកហើយ លោកបានស្គាល់ថាកន្លែងនោះជាទីដែលលោកធ្លាប់បានធ្វើដំណើរឆ្លងកាត់ជាញឹក

ញ្ញាប់ នៅក្នុងផ្ទែកមួយនៃទីក្រុង ហើយលោកបានរំពឹងទុកថាថ្ងៃស្អែកគឺជាពេលចុងក្រោយបង្អស់ដែលលោកនឹងដើរកាត់ផ្លូវនេះ។

**ច័ន្ទ-២៤ សីហា** **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ ជំពូក ២១**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ឱអស់អ្នកដែលសង្ឃឹមដល់ព្រះយេហូវ៉ាអើយ ចូរមានកំឡាំងឡើង ហើយឲ្យចិត្តអ្នករាល់គ្នា បានក្លាហានចុះ។ ទំនុកតម្កើង ៣១:២៤*

លោកបានព្យាយាមនឹកគិតពីព្រឹត្តិកាណ៍ដែលទើបតែនឹងកើតឡើងកាលពីប៉ុន្មាននាទីមុននេះ។ លោកបាននឹកពីការដែលលោកកំពុងតែសម្រាន្តលង់លក់ ទាំងដាក់ច្រវាក់ភ្ជាប់ទៅនឹងទាហានពីរនាក់ ដោយបានដោះទាំងស្បែកជើងនិងអាវក្រៅចេញផង។ លោកបានពិនិត្យមើលខ្លួនឯងឃើញមានសម្លៀកបំពាក់និងក្រវាត់ត្រឹមត្រូវ។ កដៃរបស់លោកហើមដោយសារការពាក់ច្រវាក់ដែកយ៉ាងឃោរឃៅ ត្រូវបានដោះលែងឲ្យរួចពីខ្នោះ។ លោកបានដឹងថាសេរីភាពរបស់លោកនេះមិនមែនជាការបោកបញ្ឆោតទេ ក៏មិនមែនជាការស្រមៃឬជាការបើកសម្តែងដែរ ប៉ុន្តែ គឺជាការពិតដ៏មានពរ។ នៅថ្ងៃស្អែកលោកនឹងត្រូវគេនាំយកទៅប្រហារជីវិតហើយ ប៉ុន្តែ មើលន៏ ទេវតាមួយអង្គបានមករំដោះលោកចេញពីគុក និងឲ្យរួចចាកផុតពីការសម្លាប់។ «លុះពេត្រុសដឹងខ្លួនឡើង ក៏នឹកឃើញថា ឥឡូវនេះ អញដឹងប្រាកដថា ព្រះអម្ចាស់បានចាត់ទេវតានៃទ្រង់ ឲ្យមកដោះអញឲ្យរួចពីកណ្តាប់ដៃនៃស្តេចហេរ៉ូឌ ហើយពីគ្រប់ទាំងបំណង ដែលសាសន៍យូដាបានរង់ចាំដែរ» ។

ភ្លាមនោះ សាវ័កនេះបានធ្វើដំណើរឆ្ពោះទៅកាន់ផ្ទះដែលបងប្អូនរួមជំនឿរបស់លោកកំពុងជួបជុំគ្នា និងជាកន្លែងដែលពួកគេកំពុងតែអធិដ្ឋានយ៉ាងស្មោះអស់ពីចិត្តសម្រាប់រូបលោក។ «គាត់ក៏គោះទ្វារមុខ នោះមានស្រីបម្រើម្នាក់ ឈ្មោះរ៉ូដា មកផ្ទៀងស្តាប់ លុះស្គាល់សំឡេងពេត្រុសហើយនោះនាងមានសេចក្តីអំណរដ៏ពន្លឹក ដល់ម៉្លេះបានជាភ្លេចទាំងបើកទ្វារ រត់ចូលទៅប្រាប់គេវិញថា លោកពេត្រុសឈរនៅមាត់ទ្វារ តែគេស្តីថា ឯង

វង្វេងហើយ តែនាងនៅតែថា ប្រាកដមែនៗ រួចគេថាជាទេវតារបស់គាត់ទេ »។

«ឯពេត្រុស គាត់ចេះតែគោះទ្វារថែម កាលគេបានបើកទ្វារឃើញ នោះគេមានសេចក្ដីស្រឡាំងកាំង តែគាត់ធ្វើគ្រឿងសម្គាល់នឹងដៃឲ្យគេស្ងៀមទៅ រួចក៏រ៉ាយរឿងប្រាប់គេ ពីដំណើរដែលព្រះអម្ចាស់បាននាំគាត់ចេញពីគុកជាយ៉ាងណា ហើយគាត់ផ្ដាំគេថា សូមប្រាប់រឿងនេះដល់យ៉ាកុប និងពួកបងប្អូនឲ្យដឹងផង នោះគាត់ចេញទៅឯកន្លែងមួយទៀតទៅ»។ សេចក្ដីអំណរ និងការសរសើរតម្កើងបានបំពេញចិត្តពួកសិស្សទាំងអស់ ព្រោះព្រះបានឆ្លើយតបទៅនឹងការអធិដ្ឋានរបស់ពួកគេ ហើយបានរំដោះលោកពេត្រុសចេញពីកណ្ដាប់ដៃស្ដេចហេរ៉ូឌ។

លុះព្រឹកស្អែកឡើង មនុស្សជាច្រើនកុះករបានមកប្រជុំគ្នាដើម្បីមើលការប្រហារជីវិតរបស់សាវ័កពេត្រុស។ ស្ដេចហេរ៉ូឌបានបញ្ជានាយតម្រួតឲ្យទៅនាំលោកពេត្រុសចេញពីគុកមក ដោយមានកងទ័ពនិងអ្នកយាមការពារជាច្រើន ដើម្បីមិនគ្រាន់តែការពារកុំឲ្យលោករត់រួចប៉ុណ្ណោះទេ ប៉ុន្តែ ដើម្បីទប់ទល់នឹងពួកអ្នកដែលអាណិតអាសូរដល់លោក និងដើម្បីបង្ហាញពីអំណាចរបស់ស្ដេចផង ។

កាលអ្នកយាមទ្វារបានឃើញថាលោកពេត្រុសបានគេចខ្លួនបាត់ដូច្នេះ ពួកគេមានការភ័យរន្ធត់ជាខ្លាំង។ ដ្បិតមានច្បាប់ចែងថាស្ដេចនឹងទាមទារជីវិតរបស់ពួកគេជំនួសជីវិតអ្នកទោសរបស់ពួកគេ ហើយដោយសារហេតុនេះបានជាពួកគេមានការប្រុងប្រយ័ត្នជាខ្លាំង។ នៅពេលដែលនាយតម្រួតមករកលោកពេត្រុស ពួកគេបានឃើញទាហាននៅយាមទ្វារគុកដដែលរនុកនិងរបានៅជាប់ដដែល ហើយច្រវាក់ក៏នៅជាប់កដៃរបស់ទាហានទាំងពីរនាក់ដដែល ប៉ុន្តែ អ្នកទោសបានរត់បាត់ទៅហើយ ។

នៅពេលដែលនាយតម្រួតបានទូលថ្វាយពីការរត់រួចខ្លួនរបស់លោកពេត្រុសថ្វាយដល់ស្ដេចហេរ៉ូឌ ព្រះអង្គទ្រង់ព្រះពិរោធជាខ្លាំង។ ដោយចោទ

ប្រកាន់ពួកអ្នកយាមគុកពីបទមិនស្មោះត្រង់ ព្រះអង្គបានបញ្ជាឲ្យយកពួកគេទៅសម្លាប់។ ស្ដេចហេរ៉ូឌបានជ្រាបច្បាស់ថាគ្មានអំណាចរបស់មនុស្សណាអាចរំដោះលោកពេត្រុសបានទេ ប៉ុន្តែ ព្រះអង្គបានតាំងចិត្តមិនព្រមទទួលស្គាល់ថាព្រះចេស្ដារបស់ព្រះបានបំផ្លាញផែនការរបស់ទ្រង់នោះទេ ហើយព្រះអង្គបានតាំងខ្លួនប្រឆាំងនឹងព្រះដោយផ្ទាល់យ៉ាងក្លាហាន។

**<u>អង្គារ-២៥ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី១ ជំពូក ២២**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *អ្នកណាដែលគ្រប់បាំងការរំលងរបស់ខ្លួន នោះនឹងមិនចំរើនឡើងទេ តែអ្នកណាដែលលន់តួ ហើយលះបង់អំពើនោះ នឹងប្រទះបានសេចក្តីមេត្តាករុណាវិញ។ សុភាសិត ២៨:១៣*

មិនយូរប៉ុន្មាន បន្ទាប់ពីការរំដោះលោកពេត្រុសចេញពីគុកហើយ ស្ដេចហេរ៉ូឌបានយាងទៅកាន់ទីក្រុងសេសារា។ នៅទីនោះ ព្រះអង្គបានប្រារព្ធពិធីបុណ្យដ៏ធំមួយដើម្បីជំរុញឲ្យមានការកោតសរសើរនិងដើម្បីឲ្យមានការគាំទ្រពីសំណាក់ប្រជារាស្ត្រ ។ ពិធីបុណ្យនេះមានអ្នកចូលចិត្តការសប្បាយចូលរួមជាច្រើន មកពីគ្រប់ទីកន្លែង និងមានពិធីជប់លៀងយ៉ាងធំ ដែលមានស្រាទំពាំងបាយជូរជាច្រើនផង។ ស្ដេចហេរ៉ូឌបានបង្ហាញអង្គទ្រង់នៅចំពោះមនុស្សជាច្រើន ហើយបានថ្លែងទៅកាន់ពួកគេដោយព្រះបន្ទូលយ៉ាងប៉ិនប្រសប់ ។

ប្រដាប់អង្គដោយព្រះពស្ត្រដែលរំលេចដោយមាសនិងប្រាក់ ដែលចាំងនឹងពន្លឺព្រះអាទិត្យពណ៌មាស ធ្វើឲ្យទស្សនិកជនស្រវាំងភ្នែកគ្រប់គ្នា ព្រះអង្គមានរូបរាងល្អឆើតអស្ចារ្យ។ សិរីរុងរឿងនៃលក្ខណៈរបស់ទ្រង់ និងកម្លាំងនៃព្រះបន្ទូលដ៏ពីរោះរបស់ទ្រង់ បានអង្រួនពួកអ្នកចូលរួមនៅក្នុងពិធីបុណ្យនេះដោយអំណាចដ៏អស្ចារ្យ វិញ្ញាណរបស់ពួកគេបានវង្វេងដោយការជប់លៀងនិងការស៊ីផឹក ពួកគេជាប់ចិត្តទៅនឹងការតុបតែងលម្អរបស់ស្ដេចហេរ៉ូឌ និងលង់លក់ដោយសំនួនវោហារដ៏ពីរោះរបស់ទ្រង់ ហើយវង្វេង

ដោយភាពរីករាយ ពួកគេបានបង្ហាញការលើកតម្កើងដល់ទ្រង់ ដោយនិយាយថាគ្មានមនុស្សរស់ណាអាចបង្ហាញលក្ខណៈឬបញ្ចេញវោហារបានដូចទ្រង់ឡើយ។ ពួកគេបានថ្លែងបន្តទៅទៀតថា ចាប់តាំងពីពេលដែលពួកគេបានគោរពទ្រង់ថាជាមេដឹកនាំរបស់ពួកគេមក គេក៏បានថ្វាយបង្គំទ្រង់ទុកដូចជាព្រះផងដែរ ។

ពួកគេខ្លះដែលកំពុងបញ្ចេញសំឡេងសរសើរតម្កើងដល់មនុស្សមានបាបដ៏អាក្រក់នេះ គឺជាអ្នកដែលធ្លាប់បានស្រែកយ៉ាងអន្ទះសាថាឆ្កាងវាទៅឆ្កាងវាទៅ! កាលពីប៉ុន្មានឆ្នាំមុន។ ពួកសាសន៍យូដាបានបដិសេធមិនទទួលព្រះគ្រិស្ត ដែលមានព្រះពស្ត្រគ្របដណ្តប់ដោយសេចក្តីស្រឡាញ់របស់ព្រះដែលប្រឡាក់ដោយភាពសៅហ្មង។ ភ្នែករបស់ពួកគេមិនអាចមើលឃើញព្រះជាម្ចាស់នៃជីវិតនិងសិរីល្អរបស់ទ្រង់ទេ ទោះបីជាព្រះចេស្តារបស់ព្រះគ្រិស្តត្រូវបានបង្ហាញនៅចំពោះពួកគេ នៅក្នុងកិច្ចការដែលគ្មានមនុស្សណាម្នាក់អាចធ្វើបានក៏ដោយ។ ប៉ុន្តែ ពួកគេបានរៀបចំខ្លួនដើម្បីថ្វាយបង្គំដល់ស្តេចដែលក្រអឺតក្រទម ដែលពាក់អាវផាយរំលេចដោយមាសនិងប្រាក់គ្របដណ្តប់ដោយអំពើពុករលួយនិងចិត្តឃោរឃៅ ថាជាព្រះទៅវិញ។

ស្តេចហេរ៉ូឌបានជ្រាបថាព្រះអង្គមិនគួរនឹងទទួលការសរសើរតម្កើងនិងការគោរពបូជាដែលគេថ្វាយដល់ទ្រង់ទេ តែទ្រង់បានទទួលការថ្វាយបង្គំរូបព្រះពីសំណាក់ប្រជារាស្ត្រថាជាការគួរសមរបស់ទ្រង់។ ព្រះទ័យរបស់ទ្រង់ប៉ោងឡើងដោយជោគជ័យនិងការត្រេកត្រអាលនៃអំនួតដ៏ជាទីគាប់ព្រះទ័យពាសពេញទឹកព្រះភក្ត្ររបស់ទ្រង់ នៅពេលដែលទ្រង់បានឮសម្រែកស្រែកឡើងថា «នេះជាសំឡេងព្រះទេវីយ មិនមែនជាសំឡេងមនុស្សទេ»។

ប៉ុន្តែ រំពេចនោះ ការផ្លាស់ប្តូរដ៏រន្ធត់មួយបានកើតឡើងដល់ទ្រង់។ ព្រះភក្ត្ររបស់ទ្រង់ឡើងស្លេកស្លាំងដូចមនុស្សស្លាប់ ហើយរមូលខ្លួនដោយការឈឺចាប់។ តំណក់ញើសធំៗបានធ្លាក់ចុះពីរន្ធញើសរបស់ទ្រង់។ ព្រះអង្គបានក្រោកឈរមួយសន្ទុះ ហាក់បីដូចជាមានការចាក់ដោតនៃការឈឺចាប់

និងញ័ររន្ធត់ជាខ្លាំង បន្ទាប់មក ទ្រង់បានបែរព្រះភក្ត្រដ៏ស្លេកស្លាំងរបស់ទ្រង់ទៅរកមិត្តភក្តិរបស់ទ្រង់ដែលកំពុងភ័យញ័ររន្ធត់ ព្រះអង្គបានស្រែកទាំងសំឡេងស្អកៗថា ស្តេចដែលអ្នករាល់គ្នាបានលើកតម្កើងថាជាព្រះនោះឥឡូវនេះត្រូវបានព្រះវាយប្រហារឲ្យស្លាប់ហើយ ។

**<u>ពុធ-២៦ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ១ ខ**ព្រះគម្ពីរប្រចាំថ្ងៃ: *ឫកខ្ពស់នឹងចិត្តអំនួត គឺចង្កៀងរបស់មនុស្សអាក្រក់នោះ ហៅថាជាអំពើបាបទាំងអស់។ សុភាសិត ២១:៤*

ដោយការឈឺចាប់ពីទណ្ឌកម្មយ៉ាងទង្គឹះចិត្តជាទីបំផុត ព្រះអង្គត្រូវបានគេនាំចេញពីទស្សនីយភាពដ៏អ៊ឹកធឹកនិងភាពសម្ញែងនោះ។ មួយសន្ទុះមុននេះ ព្រះអង្គគឺជាស្តេចដ៏អំនួតដែលទទួលការសរសើរតម្កើងនិងការថ្វាយបង្គំពីសំណាក់ហ្វូងមនុស្ស ប៉ុន្តែ ឥឡូវនេះ ព្រះអង្គបានជ្រាបថាទ្រង់កំពុងឋិតនៅក្នុងព្រះហស្តនៃព្រះមួយអង្គដែលមានអំណាចខ្លាំងជាងទ្រង់ទៅទៀត។ វិប្បដិសារីបានហ៊ុំព័ទ្ធជុំវិញទ្រង់ ព្រះអង្គបាននឹកឃើញនូវការធ្វើទុក្ខបៀតបៀនដែលមិនចេះនឿយណាយ ដល់ពួកសិស្សរបស់ព្រះគ្រិស្ត ព្រះអង្គបាននឹកឃើញនូវការប្រហារជីវិតលោកយ៉ាកុប ដែលជាជនគ្មានទោសពៃរ៍ និងផែនការរបស់ទ្រង់ប្រុងនឹងសម្លាប់លោកពេត្រុសថែមទៀត ព្រះអង្គនឹកឃើញនូវការដាក់ទណ្ឌកម្មយ៉ាងតឹងរ៉ឹងនិងសាហាវឃោរឃៅឥតពិចារណាទៅលើពួកអ្នកយាមគុក។ ឥឡូវនេះព្រះអង្គបានជ្រាបថាព្រះបានដោះស្រាយជាមួយនឹងទ្រង់ជាអ្នកបៀតបៀនដែលមិនចេះនឿយហត់នេះ។ ព្រះអង្គមិនបានស្រាកស្រាន្តពីការឈឺចាប់ខាងរាងកាយ និងការទង្គឹះខ្សឹកខ្សួលខាងផ្លូវចិត្តឡើយ ហើយព្រះអង្គគ្មានរំពឹងអ្វីទៀតសោះឡើយ។

ស្តេចហេរ៉ូឌបានដឹងពីក្រឹត្យវិន័យរបស់ព្រះ ដែលបានចែងថា «កុំឲ្យមានព្រះឯណាទៀតនៅចំពោះអញឲ្យសោះ» (និក្ខមនំ ២០:៣) ហើយព្រះអង្គក៏បានជ្រាបផងដែរថា ការទទួលការថ្វាយបង្គំពីសំណាក់ប្រជារាស្ត្រ គឺទ្រង់

បានបំពេញរង្វាស់នៃសេចក្តីទុច្ចរិតរបស់ទ្រង់ ហើយទ្រង់បាននាំមកដល់ព្រះអង្គឯងនូវសេចក្តីក្រោធដ៏យុត្តិធម៌របស់ព្រះយេហូវ៉ា។

ទេវតាមួយអង្គដែលបានយាងចុះមកពីព្រះរាជវាំងនៃឋានសួគ៌មកជួយរំដោះលោកពេត្រុសនោះ គឺជាអ្នកនាំសារនៃសេចក្តីក្រោធនិងការជំនុំជម្រះដល់ស្តេចហេរ៉ូឌ។ ទេវតានោះបានទះលោកពេត្រុសដើម្បីដាស់លោកពីការសម្រាន្តលង់លក់ ប៉ុន្តែ ការនោះខុសគ្នាដាច់ស្រឡះពីការវាយប្រហារមកលើស្តេចដ៏កំណាច ដោយបានបន្ទាបអំនួតរបស់ទ្រង់ និងបាននាំមកដល់ទ្រង់នូវទណ្ឌកម្មនៃព្រះដ៏មានព្រះចេស្តា។ ស្តេចហេរ៉ូឌបានសុគតដោយការឈឺចាប់ខាងរាងកាយនិងគំនិតយ៉ាងធ្ងន់ធ្ងរ នៅក្រោមការជំនុំជម្រះរបស់ព្រះតាមអំពើដែលទ្រង់បានប្រព្រឹត្ត។

ការបង្ហាញភាពយុត្តិធម៌របស់ព្រះមានឥទ្ធិពលយ៉ាងខ្លាំងក្លា មកលើប្រជារាស្ត្រ។ ដំណឹងដែលថាសាវ័ករបស់ព្រះត្រូវបានរំដោះឲ្យរួចពីគុកនិងពីសេចក្តីស្លាប់ ខណៈដែលអ្នកបៀតបៀនរបស់លោកត្រូវបានទេវតាវាយប្រហារដោយសារបណ្តាសាររបស់ព្រះ ត្រូវបានផ្សព្វផ្សាយពាសពេញផែនដី ហើយបានក្លាយជាមធ្យោបាយនៃការដឹកនាំមនុស្សជាច្រើនឲ្យជឿដល់ព្រះគ្រិស្ត។

បទពិសោធន៍របស់លោកភីលីព ដែលបានណែនាំដោយទេវតាមកពីឋានសួគ៌ ទៅកាន់កន្លែងដែលលោកបានជួបនឹងមន្ត្រីម្នាក់ដែលកំពុងស្វែងរកសេចក្តីពិត ការដែលអ្នកនាំសារមកពីព្រះបានទៅជួបលោកកូនេលាសលោកពេត្រុសនៅក្នុងគុក និងការកាត់ទោសប្រហារជីវិត ដល់លោក ហើយត្រូវបានទេវតានាំចេញមកដោយសុវត្ថិភាព ទាំងអស់នេះបានបង្ហាញពីភាពជិតស្និទ្ធនៃទំនាក់ទំនងរវាងឋានសួគ៌និងផែនដី ។

កំណត់ត្រានៃការយាងមកជួបនឹងអ្នកបម្រើការរបស់ព្រះពីសំណាក់ទេវតានេះ បាននាំមកនូវកម្លាំងនិងសេចក្តីក្លាហាន។ សព្វថ្ងៃនេះ ក៏នៅតែពិតដូចជានៅសម័យពួកសាវ័កដែរ ទេវតាដែលជាអ្នកនាំសារនៃឋានសួគ៌

កំពុងហោះពាសពេញបណ្តោយនិងទទឹងផែនដី ស្វែងរកកម្សាន្តចិត្តដល់អ្នកដែលមានទុក្ខព្រួយ ដើម្បីការពារអ្នកស្តាយក្រោយ ដើម្បីទាក់ទាញទឹកចិត្តមនុស្សមកឯព្រះគ្រិស្ត ។ យើងមិនអាចមើលឃើញពួកលោកដោយផ្ទាល់ទេ ទោះបីជាពួកលោកគង់នៅជាមួយនឹងយើង កំពុងដឹកនាំយើង បង្ហាត់បង្រៀនដល់យើង និងការពារយើងក៏ដោយ។

<u>ព្រហស្បតិ៍-២៧ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ២

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ព្រះយេហូវ៉ាទ្រង់គង់ជិតបង្កើយនឹងអស់អ្នក ដែលមានចិត្តសង្រេង ហើយទ្រង់ជួយសង្គ្រោះដល់អស់អ្នកដែលមានវិញ្ញាណទន់ទាប។ ទំនុកតម្កើង ៣៤:១៨*

ព្រះបាននាំយកឋានសួគ៌ឲ្យមកនៅកាន់តែជិតផែនដី ដោយសារជណ្តើរដែលប្រកបដោយអាថ៌កំបាំង ជាមូលដ្ឋានគ្រឹះដែលព្រះបានដាក់យ៉ាងរឹងមាំនៅលើផែនដីខណៈដែលកាំខាងលើបង្អស់ឈានដល់បល្ល័ង្កនៃព្រះដែលគ្មានដែនកំណត់។ ពួកទេវតាបានបន្តឡើងចុះតាមជណ្តើរដែលមានពន្លឺដ៏ត្រចះត្រចង់នេះ ដោយនាំយកសេចក្តីអធិដ្ឋានរបស់អ្នកក្រីក្រនិងអ្នកដែលមានទុក្ខកង្វល់ទៅទូលដល់ព្រះវរបិតាដែលគង់នៅខាងលើ និងនាំមកនូវព្រះពរនិងសេចក្តីសង្ឃឹម សេចក្តីក្លាហាននិងជំនួយមកដល់កូនៗរបស់មនុស្ស។ ពពួកទេវតានៃពន្លឺទាំងនេះបង្កើតជាបរិយាកាសនៃឋានសួគ៌នៅជុំវិញមនុស្សលោក ដោយលើកយើងឆ្ពោះទៅកាន់ព្រះដែលយើងមើលមិនឃើញ និងជាព្រះដ៏អស់កល្ប ។ យើងមិនអាចមើលពួកទេវតាទាំងនោះឃើញដោយភ្នែកពីកំណើតរបស់យើងទេ យើងអាចមើលឃើញរឿងរ៉ាវនៃឋានសួគ៌ដោយសារតែទស្សនវិស័យនៃព្រលឹងវិញ្ញាណប៉ុណ្ណោះ។ មានតែត្រចៀកខាងវិញ្ញាណប៉ុណ្ណោះ ដែលអាចស្តាប់ព្រះសូរសៀងដ៏ពីរោះនៃពួកទេវតាបាន។

«ទេវតានៃព្រះយេហូវ៉ាចោមរោមនៅជុំវិញនៃអស់អ្នកដែលកោតខ្លាច

ដល់ទ្រង់ ហើយក៏ជួយគេឲ្យរួច» (ទំនុកតម្កើង ៣៤:៧)។ ព្រះបានត្រាស់បង្គាប់ដល់ពួកទេវតារបស់ទ្រង់ឲ្យជួយសង្គ្រោះពួកអ្នករើសតាំងរបស់ទ្រង់ឲ្យរួចពីទុក្ខលំបាក ថែរក្សាពួកគេឲ្យរួចពី «សេចក្ដីវេទនាដែលតែងមាននៅក្នុងទីងងឹត ឬសេចក្ដីហិនវិនាសដែលបំផ្លាញនៅពេលថ្ងៃត្រង់ផង» (ទំនុកតម្កើង ៩១:៦)។ ពួកទេវតាបានមានបន្ទូលជាមួយនឹងមនុស្ស ដូចជាមនុស្សនិយាយជាមួយនឹងមិត្តភក្តិ ហើយបានដឹកនាំពួកគេទៅកាន់កន្លែងដែលមានសុវត្ថិភាព ម្ដងហើយម្ដងទៀត។ បន្ទូលនៃការលើកទឹកចិត្តរបស់ពួកទេវតាបានពង្រឹងវិញ្ញាណដែលធ្លាក់ចុះ របស់ពួកអ្នកស្មោះត្រង់ម្ដងហើយម្ដងទៀត ហើយធ្វើឲ្យពួកគេសម្លឹងមើលដោយសេចក្ដីជំនឿទៅអាវផាយពណ៌ស ទៅឯមកុដ ទៅឯធាងចាកនៃជ័យជម្នះ ដោយពាំនាំគំនិតរបស់ពួកគេទៅកាន់រឿងរ៉ាវនៃឋានលើ ដែលពួកអ្នកឈ្នះនឹងទទួលបាន នៅពេលដែលពួកគេនៅជុំវិញបល្ល័ង្កពណ៌សដ៏ធំ ។

គឺជាកិច្ចការរបស់ពួកទេវតា ដែលត្រូវចូលទៅជិតពួកអ្នកដែលជួបការលំបាក ជួបការឈឺចាប់ និងសេចក្ដីល្បួង។ ពួកលោកធ្វើការដោយមិនចេះនឿយហត់ តំណាងឲ្យពួកអ្នកដែលព្រះគ្រិស្តបានសុគតជំនួស។ នៅពេលដែលបាបជនត្រូវបាននាំឲ្យថ្វាយខ្លួនទៅឯព្រះអង្គសង្គ្រោះ ពួកទេវតាបាននាំដំណឹងនោះឆ្ពោះទៅកាន់ឋានសួគ៌ ហើយនឹងមានអំណរយ៉ាងធំនៅក្នុងចំណោមពពួកទេវតានៃឋានសួគ៌។ « ខ្ញុំប្រាប់អ្នករាល់គ្នាថា នៅឋានសួគ៌នឹងមានសេចក្ដីអំណរយ៉ាងនោះដែរ ដោយសារមនុស្សបាបតែ១នាក់ដែលប្រែចិត្តវិញ ជាជាងមនុស្សសុចរិត៩៩នាក់ ដែលមិនត្រូវការប្រែចិត្តទេ» (លូកា ១៥:៧)។ ទេវតានឹងនាំរបាយការណ៍ស្ដីពីការខំប្រឹងប្រែងដ៏មានជោគជ័យរបស់យើង នៃការកម្ចាត់ភាពងងឹតនិងការផ្សព្វផ្សាយចំណេះដឹងអំពីព្រះគ្រិស្តរបស់យើង ទៅកាន់ឋានសួគ៌ ។ នៅពេលដែលទង្វើទាំងនេះត្រូវបានលាតត្រដាងនៅចំពោះព្រះវរបិតា នោះនឹងមានក្ដីអំណរពាសពេញទាំងពួកទេវតានៃឋានសួគ៌ ។

មេលើពពួកទេវតានិងអំណាចនៃឋានសួគ៌កំពុងសម្លឹងមើលមកកិច្ចការដែលអ្នកបម្រើរបស់ព្រះកំពុងបំពេញ និងកំពុងឋិតនៅក្រោមបរិយាកាសនៃការបាក់ទឹកចិត្ត។ ពួកគេនឹងទទួលបានជោគជ័យថ្មីៗ និងបានទទួលកិត្តិយសថ្មីៗ ដរាបណាពួកគ្រិស្តបរិស័ទប្រមូលផ្តុំគ្នានៅជុំវិញផ្ទាំងបដានៃព្រះដ៏ប្រោសលោះរបស់ពួកគេ បោះជំហានទៅមុខ ប្រយុទ្ធយ៉ាងអង់អាចក្លាហានដោយសេចក្តីជំនឿ។ ពពួកទេវតានៃឋានសួគ៌គង់នៅជាមួយនឹងកិច្ចការនៃរាស្ត្ររបស់ព្រះ ដែលមានជំនឿនិងបន្ទាបខ្លួន ហើយនៅពេលដែលកងទ័ពនៃអ្នកបម្រើរបស់ព្រះនៅផែនដីច្រៀងបទចម្រៀងសរសើរតម្កើងរបស់ពួកគេ ក្រុមចម្រៀងនៃឋានសួគ៌ក៏បានចូលរួមជាមួយពួកគេ ក្នុងការច្រៀងរៀបរាប់សរសើរតម្កើងដល់ព្រះ និងព្រះរាជបុត្រារបស់ទ្រង់ដែរ។

យើងត្រូវតែដឹងឲ្យច្បាស់ថាយើងបំពេញបេសកកម្មរបស់ពួកទេវតា។ ជាការល្អដែលត្រូវចងចាំថាកូនរបស់ព្រះដែលស្មោះត្រង់រាល់រូប មានទេវតានៃឋានសួគ៌មួយអង្គចាំជួយសហការ។ កងទ័ពនៃពន្លឺនិងអំណាចដែលមនុស្សមើលមិនឃើញគង់នៅជាមួយនឹងអ្នកដែលជឿ និងអ្នកដែលទាមទារសេចក្តីសន្យារបស់ព្រះ។ ទេវតាចេរ៉ូប៊ីន និងសេរ៉ាភីម ព្រមទាំងពួកទេវតាដែលពោរពេញទៅដោយកម្លាំងដែលនៅខាងស្តាំនៃព្រះ «ជាវិញ្ញាណបម្រើដែលទ្រង់បានចាត់មក សម្រាប់ការងារជួយដល់ពួកដែលត្រូវទទួលសេចក្តីសង្គ្រោះជាមរតក» (ហេព្រើរ ១:១៤) ។

ជំពូកទី
១៦

# សារនៃដំណឹងល្អនៅទីក្រុងអាន់ទីយ៉ូក

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ១១:១៩-២១ និង ១៣:១-៣ ។*

<u>សុក្រ-២៨ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ៣

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ដ្បិតខ្ញុំគ្មានសេចក្តីខ្មាស ចំពោះដំណឹងល្អនៃព្រះគ្រីស្ទ ទេ ពីព្រោះជាព្រះចេស្តានៃព្រះ សំរាប់នឹងជួយសង្គ្រោះដល់អស់អ្នកណាដែលជឿ គឺដល់ទាំងសាសន៍យូដាជាដើម និងសាសន៍ក្រេកផង។ រ៉ូម ១:១៦*

បន្ទាប់ពីពួកសិស្សត្រូវបានបណ្តេញចេញពីទីក្រុងយេរូសាឡិម ដោយការធ្វើទុក្ខបៀតបៀនមក សារនៃដំណឹងល្អបានរីករាលដាលយ៉ាងឆាប់រហ័សនៅពាសពេញទាំងតំបន់ទាំងឡាយ ដែលនៅឆ្ងាយពីព្រំប្រទល់ប្រទេសភីលីស្ទីន ហើយពួកគេបានបង្កើតក្រុមតូចៗនៃអ្នកមានជំនឿ ជាច្រើននៅក្នុងតំបន់សំខាន់ៗ។ ពួកសិស្សមួយចំនួន «ក៏ដើររហូតទៅដល់ស្រុកភេនីស ស្រុកគីប្រុស និងក្រុងអាន់ទីយ៉ូក ហើយបានផ្សាយព្រះបន្ទូល»។ កិច្ចការរបស់ពួកគេធ្លាប់តែត្រូវបានបង្ខាំងទុកសម្រាប់តែពួកហេព្រើរនិងពួកសាសន៍ក្រិកដែលនិយាយភាសាយូដាប៉ុណ្ណោះ នៅសម័យនោះគេបានរកឃើញរដ្ឋចំណុះជាច្រើន នៅសឹងតែគ្រប់ទីក្រុងទាំងអស់នៅលើពិភពលោក ។

នៅក្នុងចំណោមទីកន្លែងទាំងឡាយដែលបានពណ៌នាខាងលើនេះ ទីក្រុងដែលមានមនុស្សបានទទួលដំណឹងល្អដោយរីករាយនោះគឺទីក្រុងអាន់ទីយ៉ូកដែលកាលសម័យនោះជារាជធានីនៃប្រទេសស៊ីរី។ ជំនួញធំៗត្រូវបានគេនាំចេញពីតំបន់ដែលមានប្រជាប្រិយនេះ យកទៅកាន់ទីក្រុងដែលមានមនុស្ស

ជាច្រើននៃប្រទេសផ្សេងៗ។ ក្រៅពីនេះ ទីក្រុងអាន់ទីយ៉ូក គឺជាកន្លែងកម្សាន្តដែលគេចូលចិត្តមកសម្រាកលំហែ ដោយសារតែស្ថានភាពដែលប្រកបដោយសុខុមាលភាព សម្រស់ឆើតឆាយដែលនៅព័ទ្ធជុំវិញ និងមានវប្បធម៌សំបូររុងរឿង គេរកឃើញកន្លែងសម្រាកបង្កើនកម្លាំងនៅទីនោះ។ នៅសម័យពួកសាវ័កទីក្រុងនេះបានក្លាយជាកន្លែងដ៏ស្រស់ឆើតឆាយ និងមានអំពើអបាយមុខជាច្រើន។

ដំណឹងល្អត្រូវបានបង្រៀនជាសាធារណៈនៅអាន់ទីយ៉ូក ដោយពួកសិស្សដែលមកពីកោះគីប្រុសនិងស្រុកគីរេន ដែល «បានទៅដល់ក្រុងអាន់ទីយ៉ូក ក៏ផ្សាយដំណឹងល្អពីព្រះអម្ចាស់យេស៊ូវ»។ «ព្រះហស្តព្រះអម្ចាស់ក៏នៅជាមួយនឹងគេ»។ ហើយកិច្ចការរបស់ពួកគេបានបង្កើតផលផ្លែជាច្រើន «ហើយមានមនុស្សជាច្រើនបែរមកឯព្រះអម្ចាស់វិញដោយមានសេចក្តីជំនឿ»។

«រឿងនោះបានឮដល់ត្រចៀកពួកជំនុំនៅក្រុងយេរូសាឡិម រួចគេចាត់បាណាបាស ឲ្យទៅត្រឹមអាន់ទីយ៉ូក»។ នៅក្នុងចំណោមពួកអ្នកដែលបានចូលមកធ្វើការថ្មីនោះ មានបាណាបាសដែលបានឃើញថាត្រូវបានបំពេញដោយព្រះគុណរបស់ព្រះហើយ «កាលគាត់ទៅដល់ ហើយបានឃើញព្រះគុណនៃព្រះ នោះគាត់មានសេចក្តីអំណរ ក៏ទូន្មានគេគ្រប់គ្នា ឲ្យសម្រេចចិត្តនឹងនៅជាប់ក្នុងព្រះអម្ចាស់» ។

ព្រះបានប្រទានព្រះពរជាច្រើនដល់កិច្ចការរបស់លោកបាណាបាសនៅអាន់ទីយ៉ូក ហើយមានមនុស្សជាច្រើនត្រូវបានបន្ថែមទៅក្នុងចំណោមពួកអ្នកជឿនៅទីនោះ។ លុះកិច្ចការកាន់តែចម្រើនឡើង លោកបាណាបាសត្រូវការជំនួយឲ្យបានសមរម្យដើម្បីជំរុញដល់ការបើកទិព្វញ្ញាណរបស់ព្រះ ហើយលោកក៏បានធ្វើដំណើរទៅកាន់ស្រុកតើសុសដើម្បីស្វែងរកលោកប៉ុលដែលកំពុងតែធ្វើការនៅ «ក្នុងស្រុកស៊ីរី និងស្រុកគីលីគា» ដោយកំពុងផ្សាយ «ពីសេចក្តីជំនឿ ដែលខ្លួនបានបំផ្លាញពីដើមនោះវិញ» (កាឡាទី ១:២១, ២៣)។

លោកបាណាបាសមានជោគជ័យក្នុងការស្វែងរកលោកប៉ុល និងការបញ្ចុះបញ្ចូលលោកឲ្យរួមដំណើរជាមួយលោកនៅក្នុងការបម្រើកិច្ចការនោះ ។

<u>សៅរ៍-២៩ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ៤

**ខព្រះគម្ពីរប្រចាំសប្តាហ៍:** *ដ្បិតគឺជាព្រះហើយ ដែលបណ្តាលចិត្តអ្នករាល់គ្នាឲ្យមានទាំងចំណងចង់ធ្វើ ហើយឲ្យបានប្រព្រឹត្តតាមបំណងព្រះហឫទ័យទ្រង់ដែរ ។ ភីលីព ២:១៣*

លោកប៉ុលបានរកឃើញតំបន់ប្រតិបត្តិការណ៍ដ៏ល្អប្រពៃ នៅក្នុងទីក្រុងអាន់ទីយ៉ូកដ៏មានប្រជាប្រិយ ។ ចំណេះដឹង ប្រាជ្ញា និងទឹកចិត្តពុះកញ្ជ្រោលរបស់លោក រួមបញ្ចូលគ្នាបានជាឥទ្ធិពលដ៏មានអំណាចទៅលើពួកអ្នកស្រុក និងទៅលើទីក្រុងដែលមានវប្បធម៌ដ៏សំបូររុងរឿងនោះ ហើយលោកបានបង្ហាញថា លោកពិតជាជំនួយដែលលោកបាណាបាសត្រូវការប្រាកដមែន។ សិស្សទាំងពីរនាក់នេះ បានធ្វើការដោយរួបរួមគ្នាយ៉ាងស្អិតរមូតអស់ពេលមួយឆ្នាំ ក្នុងការបំពេញកិច្ចការដោយស្មោះត្រង់ ដោយបាននាំយកនូវចំណេះដឹងពីសេចក្តីសង្គ្រោះរបស់ព្រះយេស៊ូវពីស្រុកណាសារ៉ែត ដែលជាព្រះដ៏ប្រោសលោះនៃពិភពលោកនេះ មកចែកជូនដល់មនុស្សជាច្រើន។

គឺនៅអាន់ទីយ៉ូកនេះហើយ ដែលគេហៅពួកសិស្សថា ពួកគ្រីស្ទានដំបូងបង្អស់។ គេបានដាក់ឈ្មោះឲ្យយ៉ាងដូច្នេះ ពីព្រោះព្រះគ្រិស្តគឺជាប្រធានបទនៃការអធិប្បាយ ការបង្រៀន និងការសន្ទនារបស់ពួកគេ។ ពួកគេបានរំឭកជាបន្តបន្ទាប់ពីឧប្បត្តិហេតុទាំងឡាយដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃព្រះរាជកិច្ចរបស់ទ្រង់នៅលើផែនដី នៅពេលដែលព្រះអង្គបានប្រទានព្រះពរដល់ពួកសិស្សដោយព្រះវត្តមានរបស់ព្រះអង្គផ្ទាល់។ ពួកគេបានអះអាងពីការបង្រៀននិងពីការអស្ចារ្យនៃការព្យាបាលរបស់ទ្រង់ ឥតឈប់ឈរ។ ពួកគេបាននិយាយទាំងញ័រមាត់ និងទាំងទឹកភ្នែក អំពីការឈឺចាប់របស់ទ្រង់នៅឯសួនច្បារ ការក្បត់ទ្រង់ ការជំនុំជម្រះ

និងការកាត់ទោសដល់ទ្រង់ ការអត់ធ្មត់និងភាពអាម៉ាស់ដែលទ្រង់បានរងទ្រាំ សម្ដីព្រហើននិងទារុណកម្មដែលពួកខ្មាំងសត្រូវបានដាក់មកលើទ្រង់ និង សេចក្ដីអាណិតមេត្តាជាព្រះ ដែលព្រះអង្គបានអធិដ្ឋានឲ្យពួកអ្នកដែលធ្វើទុក្ខបៀតបៀនដល់ទ្រង់។ ការមានព្រះជន្មរស់ឡើងវិញ និងការយាងឡើងទៅកាន់ឋានសួគ៌របស់ទ្រង់ និងព្រះរាជកិច្ចរបស់ទ្រង់នៅនគរឋានសួគ៌ ជាព្រះដែលសម្របសម្រួលជំនួសមនុស្សលោកដែលមានបាបទាំងអស់នេះ គឺជាប្រធានបទដែលពួកគេចូលចិត្តពណ៌នា។ ពួកសាសន៍ដទៃសឹងតែទាំងអស់បានហៅពួកគេថាគ្រីស្ទាន(គ្រិស្តបរិស័ទ)ព្រោះពួកគេបានអធិប្បាយអំពីព្រះគ្រិស្ត និងបានអធិដ្ឋានទូលទៅព្រះតាមរយៈព្រះអង្គ (ព្រះគ្រិស្ត) ។

គឺព្រះដែលបានប្រទាននាមថាគ្រីស្ទាននេះដល់ពួកគេ។ នេះគឺជានាមតាមរាជស័ព្ទ ដែលព្រះបានប្រទានដល់មនុស្សទាំងឡាយដែលបានភ្ជាប់ខ្លួនគេជាមួយនឹងព្រះគ្រិស្ត។ គឺដោយសារឈ្មោះនេះហើយដែលលោកយ៉ាកុបបានសរសេរសំបុត្រថា «តែអ្នករាល់គ្នាបន្ទុះ បង្អាប់អ្នកក្រនោះវិញ តើពួកអ្នកមានមិនសង្កត់សង្កិន ហើយអូសអ្នករាល់គ្នាទៅនៅមុខទីជំនុំជម្រះ ទេឬអី តើគេមិនប្រមាថដល់ព្រះនាមល្អ ដែលបានឲ្យដល់អ្នករាល់គ្នាទេឬអី?» (យ៉ាកុប២:៦, ៧) ។ ហើយលោកពេត្រុសបានមានប្រសាសន៍ថា «តែបើរងទុក្ខ ដោយព្រោះពួកគ្រីស្ទានវិញ នោះកុំឲ្យខ្មាសឲ្យសោះ ចូរសរសើរតម្កើងដល់ព្រះ ដោយព្រោះនាមនោះវិញ» ។ «បើសិនជាគេតិះដៀលអ្នករាល់គ្នា ដោយព្រោះព្រះគ្រិស្ត នោះមានពរហើយ ពីព្រោះព្រះវិញ្ញាណដ៏មានសិរីល្អ គឺជាព្រះវិញ្ញាណនៃព្រះ ទ្រង់សណ្ឋិតលើអ្នករាល់គ្នាហើយ» (ពេត្រុសទី១ ៤:១៦, ១៤) ។

ពួកអ្នកជឿនៅក្រុងអាន់ទីយ៉ូកបានដឹងថាព្រះសព្វព្រះទ័យចង់ធ្វើការនៅក្នុងជីវិតរបស់ពួកគេ «ឲ្យមានទាំងចំណង់ចង់ធ្វើ ហើយឲ្យបានប្រព្រឹត្តតាមបំណងព្រះហឫទ័យទ្រង់ដែរ» (ភីលីព ២:១៣) ។ ខណៈដែលពួកគេកំពុងតែរស់នៅកណ្ដាលចំណោមមនុស្សដែលហាក់ដូចជាមិនសូវគិតគូរអំពី

ដំណើររឿងដែលមានតម្លៃដ៏អស់កល្ប ពួកគេបានស្វះស្វែងរកទាក់ទាញអារម្មណ៍របស់មនុស្សដែលមានចិត្តស្មោះត្រង់ និងធ្វើទីបន្ទាល់ជាវិជ្ជមានទាក់ទងទៅនឹងព្រះដែលពួកគេបានស្រឡាញ់និងបានបម្រើ។ នៅក្នុងកិច្ចការនៃការបន្ទាបខ្លួនរបស់ពួកគេ គេបានរៀនសូត្រទីពឹងដល់ព្រះវិញ្ញាណបរិសុទ្ធ ដើម្បីធ្វើឲ្យព្រះបន្ទូលនៃជីវិតមានប្រសិទ្ធិភាព។ ហេតុដូច្នេះ ពួកគេបានធ្វើទីបន្ទាល់អំពីជំនឿរបស់ពួកគេ ទៅលើព្រះគ្រិស្ត នៅក្នុងកិច្ចការនៃជីវិតប្រចាំថ្ងៃរបស់ពួកគេ ។

<u>អាទិត្យ-៣០ សីហា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ៥**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ខ្ញុំក៏អធិស្ឋានសូមសេចក្តីនេះ គឺឲ្យសេចក្តីស្រឡាញ់របស់អ្នករាល់គ្នា បានចំរើនកាន់តែច្រើនឡើង ដោយនូវសេចក្តីចេះដឹង និងយោបល់គ្រប់ជំពូក។ ភីលីព ១:៩*

គំរូរបស់ពួកអ្នកជឿនៅក្រុងអាន់ទីយ៉ូក គួរតែជាការលើកទឹកចិត្តដល់ពួកអ្នកជឿទាំងឡាយ ដែលកំពុងរស់នៅក្នុងទីក្រុងធំៗ នៅលើពិភពលោកនាសម័យបច្ចុប្បន្ននេះ ។ នៅពេលការរៀបចំរបស់ព្រះដែលតម្រូវឲ្យអ្នកធ្វើការដែលមានការលះបង់ និងមានទេពកោសល្យ ត្រូវតាំងទីលំនៅ នៅក្នុងទីក្រុងសំខាន់ៗ ដើម្បីដឹកនាំការខំប្រឹងប្រែងជាសាធារណៈនោះ ព្រះអង្គក៏មានគោលបំណងចង់ឲ្យសមាជិកពួកជំនុំរបស់ទ្រង់ ដែលរស់នៅក្នុងទីក្រុងទាំងនោះប្រើប្រាស់ទេពកោសល្យរបស់ពួកគេ ដែលព្រះបានប្រទានឲ្យដើម្បីធ្វើការបម្រើដល់មនុស្សដូចគ្នាដែរ។ មានព្រះពរហូរហៀរនៅក្នុងឃ្លាំងបម្រុងទុកសម្រាប់អ្នកដែលចុះចូលទាំងស្រុងទៅនឹងការត្រាស់ហៅរបស់ព្រះ។ នៅពេលដែលអ្នកបម្រើការបែបនេះខំប្រឹងស្ទុះស្ទានេសាទមនុស្សមកថ្វាយដល់ព្រះយេស៊ូវ ពួកគេនឹងរកឃើញមនុស្សជាច្រើន ដែលមធ្យោបាយផ្សេងៗទៀតមិនអាចបញ្ចុះបញ្ចូលបាន កំពុងរៀបចំខ្លួនឆ្លើយតបទៅនឹងការខំប្រឹងប្រឹងផ្ទាល់ខ្លួនដ៏ប៉ិនប្រសប់នោះ។

កិច្ចការរបស់ព្រះនៅលើផែនដីនាពេលសព្វថ្ងៃនេះត្រូវការអ្នកតំណាងដ៏រស់នៃសេចក្ដីពិតរបស់ព្រះគម្ពីរ។ គ្រូគង្វាលពេញសិទ្ធិតែម្នាក់ឯងមិនស្មើនឹងកិច្ចការនៃការព្រមានដល់ទីក្រុងធំៗទាំងនោះទេ។ ព្រះកំពុងត្រាស់ហៅមិនត្រឹមតែគ្រូគង្វាលប៉ុណ្ណោះទេ ប៉ុន្តែ ទ្រង់កំពុងត្រាស់ហៅ វេជ្ជបណ្ឌិត គិលានុប្បដ្ឋ/បដ្ឋាយិកា អ្នកលក់សៀវភៅ គ្រូបង្រៀនព្រះគម្ពីរ និងគ្រូបង្រៀនព្រះគម្ពីរស្ម័គ្រចិត្តដទៃទៀត ដែលមានជំនាញផ្សេងៗ ហើយមានចំណេះដឹងពីព្រះបន្ទូលរបស់ព្រះ និងជាអ្នកស្គាល់ព្រះចេស្ដានៃព្រះគុណ ឲ្យពិចារណាពីសេចក្ដីត្រូវការរបស់ទីក្រុងដែលមិនទាន់បានឮការព្រមានទាំងនោះ ។ ពេលវេលាកំពុងតែកន្លងផុតទៅយ៉ាងឆាប់រហ័ស ហើយនៅមានការងារជាច្រើនដែលត្រូវបង្ហើយ។ យើងត្រូវតែចាត់ភ្នាក់ងារឲ្យបំពេញភារកិច្ចគ្រប់ទីកន្លែង ដើម្បីបង្កើនការប្រើប្រាស់ឱកាស នាពេលបច្ចុប្បន្ននេះដោយប៉ិនប្រសប់។

កិច្ចការរបស់លោកប៉ុលនៅអាន់ទីយ៉ូក ក្នុងទំនាក់ទំនងជាមួយលោកបាណាបាស បានពង្រឹងដល់លោកក្នុងការផ្លាស់ប្ដូរជំនឿ ដែលព្រះជាម្ចាស់បានត្រាស់ហៅរូបលោកឲ្យបំពេញកិច្ចការជាពិសេស ដល់ពិភពនៃសាសន៍ដទៃ ។ នៅពេលនៃការផ្លាស់ប្ដូរជំនឿរបស់លោកប៉ុល ព្រះជាម្ចាស់បានមានបន្ទូលថា ព្រះអង្គនឹងធ្វើឲ្យលោកក្លាយជាអ្នកបម្រើដល់សាសន៍ដទៃ «ប្រយោជន៍នឹងបំភ្លឺភ្នែកគេ ឲ្យបានបែរចេញពីសេចក្ដីងងឹត មកឯពន្លឺ ហើយពីអំណាចអារក្សសាតាំង មកឯព្រះវិញ ដើម្បីឲ្យគេបានរួចពីបាប ហើយបានទទួលមរតកជាមួយនឹងពួកអ្នកដែលបានញែកជាបរិសុទ្ធ ដោយសារសេចក្ដីជំនឿជឿដល់ខ្ញុំ» (កិច្ចការ ២៦:១៨) ។ ទេវតាដែលបានលេចមកឯលោកអាន្នានាស បានមានបន្ទូលទៅកាន់លោកប៉ុលថា «ពីព្រោះអ្នកនោះជាប្រដាប់រើសតាំងដល់ខ្ញុំ សម្រាប់នឹងប្រកាសឈ្មោះខ្ញុំ ដល់ពួកសាសន៍ដទៃ និងពួកស្ដេច ហើយនិងពួកកូនចៅសាសន៍អ៊ីស្រាអែលផង» (កិច្ចការ ៩:១៥)។ ហើយក្រោយមក នៅក្នុងបទពិសោធន៍ជាគ្រិស្ដបរិស័ទរបស់លោក កាល

លោកកំពុងតែអធិដ្ឋាននៅក្នុងព្រះវិហារ នៅក្រុងយេរូសាឡិម លោកបាន ជួបជាមួយនឹងទេវតាដែលយាងចុះមកពីឋានសួគ៌ ដោយផ្ទាល់ ហើយបាន សុំលោកឲ្យ «ទៅចុះ ដ្បិតខ្ញុំនឹងចាត់អ្នកឲ្យទៅឯសាសន៍ដទៃដែលនៅ ឆ្ងាយ» (កិច្ចការ ២២:២១)។

<u>ច័ន្ទ-៣១ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ៦

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ឯអ្នករាល់គ្នា ក៏បានឮព្រះបន្ទូលនៃសេចក្តីពិត គឺជា ដំណឹងល្អពីសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នាដោយសារទ្រង់ដែរ ហើយ កាលអ្នករាល់គ្នាបានជឿហើយ នោះទ្រង់ក៏ដៅចំណាំដោយព្រះវិញ្ញាណ បរិសុទ្ធ ដែលបានសន្យា។ អេភេសូរ ១:១៣*

ដូច្នេះ ព្រះបានត្រាស់បង្គាប់ដល់លោកប៉ុលឲ្យចូលទៅក្នុងតំបន់បេសក កម្មនៅក្រៅប្រទេសនៃពិភពសាសន៍ដទៃ។ ដើម្បីរៀបចំលោកសម្រាប់កិច្ច ការដ៏ទូលំទូលាយ និងដ៏ពិបាកនេះ ព្រះបាននាំលោកឲ្យមានទំនាក់ទំនង យ៉ាងជិតស្និទ្ធជាមួយនឹងព្រះអង្គ ហើយបានបើកបង្ហាញអំពីទស្សនីយភាព និងសិរីល្អដ៏ស្រស់ត្រកាលនៃនគរឋានសួគ៌ នៅក្នុងការបើកសម្តែងដ៏អណ្តែត អណ្តូងរបស់លោក។ ចំពោះលោក ការបើកសម្តែងអំពី «ការអាថ៌កំបាំង» ដែលបាន «លាក់ទុកនៅអស់ទាំងកល្បរៀងមក» (រ៉ូម ១៦:២៥) «សេចក្តីអាថ៌ កំបាំងនៃព្រះហឫទ័យទ្រង់» (អេភេសូរ ១:១៩) «ជាការអាថ៌កំបាំងដែល កាលនៅអស់ទាំងគ្រាជាន់មុន មិនបានប្រទានឲ្យពួកមនុស្សជាតិស្គាល់ដូច ជាបានសម្តែងមកឲ្យពួកសាវ័ក និងពួកហោរាបរិសុទ្ធស្គាល់ ដោយសារ ព្រះវិញ្ញាណសព្វថ្ងៃនេះទេ គឺដែលពួកសាសន៍ដទៃ បានត្រឡប់ជាអ្នកគ្រង មរតកជាមួយគ្នា នឹងជារូបកាយជាមួយគ្នា ហើយជាអ្នកទទួលចំណែកនៃ សេចក្តីសន្យារបស់ទ្រង់ ជាមួយគ្នាក្នុងព្រះគ្រិស្តដែរ»។ លោកប៉ុលមាន ប្រសាសន៍ថា «ខ្ញុំបានធ្វើជាអ្នកបម្រើដំណឹងល្អនោះ ... ដែលទ្រង់ប្រទាន មកខ្ញុំ តាមដែលព្រះចេស្តាទ្រង់ពូកែនឹងធ្វើ ទ្រង់បានប្រទានព្រះគុណនេះ គឺ

ជាសម្បត្តិរបស់ព្រះគ្រិស្តដ៏ប្រមាណមិនបានមកខ្ញុំ ដែលជាអ្នកតូចជាងគេបំផុតក្នុងពួកបរិសុទ្ធទាំងអស់ឲ្យខ្ញុំបានផ្សាយដំណឹងល្អក្នុងពួកសាសន៍ដទៃ ហើយឲ្យខ្ញុំបានបំភ្លឺដល់គ្រប់មនុស្សទាំងអស់ ពីសេចក្តីប្រកបក្នុងការអាថ៌កំបាំងដែលលាក់ទុកក្នុងព្រះ តាំងពីអស់កល្បរៀងមក ជាព្រះដែលទ្រង់បង្កើតរបស់សព្វសារពើ ដោយសារព្រះយេស៊ូវគ្រិស្ត ដើម្បីឲ្យពួកគ្រប់គ្រង និងពួកមានអំណាចនៅស្ថានដ៏ខ្ពស់ បានស្គាល់ពីប្រាជ្ញានៃព្រះដ៏មានជាច្រើនយ៉ាងណាស់ ដោយសារពួកជំនុំ តាមគំនិតសម្រេចតាំងពីអស់កល្បរៀងមកដែលទ្រង់បានគិតស្រេចក្នុងព្រះគ្រិស្តយេស៊ូវ ជាព្រះអម្ចាស់នៃយើង» (អេភេសូរ ៣:៥-១១) ។

ព្រះបានប្រទានពរជាច្រើនដល់កិច្ចការរបស់លោកប៉ុលនិងលោកបាណាបាស កាលពួកលោកនៅជាមួយនឹងពួកអ្នកជឿនៅក្រុងអាន់ទីយ៉ូក ។ ប៉ុន្តែ លោកទាំងពីរនាក់មិនទាន់មានអ្នកណាមួយបានទទួលការបំពេញសិទ្ធិឲ្យទៅជាគ្រូគង្វាលនៃដំណឹងល្អពេញសិទ្ធិនៅឡើយទេ ឥឡូវនេះ ពួកគេបានឈានដល់តំណាក់ការនៅក្នុងបទពិសោធន៍ជាគ្រិស្តបរិស័ទរបស់ពួកគេ ដែលព្រះរៀបនឹងប្រទានដល់ពួកគេឲ្យបំពេញបេសកកម្មជាបេសកជនដ៏ពិបាក នៅក្នុងការធ្វើទុក្ខបៀតបៀន ដែលពួកគេត្រូវការរាល់ផលប្រយោជន៍ដែលពួកគេអាចទទួលបានតាមរយៈភ្នាក់ងារនៃពួកជំនុំ ។

«រីឯក្នុងពួកជំនុំនៅក្រុងអាន់ទីយ៉ូក នោះមានគ្រូអធិប្បាយ និងគ្រូបង្រៀនខ្លះ គឺបាណាបាសមួយ ស៊ីម្មានដែលហៅថា នីគើរមួយ លូគាសជាសាសន៍គីរេនមួយ ម៉ាណាអេន ... និងសុលមួយ កំពុងដែលអ្នកទាំងនោះធ្វើការងារថ្វាយព្រះអម្ចាស់ទាំងតមអត់នោះព្រះវិញ្ញាណបរិសុទ្ធមានព្រះបន្ទូលប្រាប់ថា ចូរញែកបាណាបាស និងសុលចេញឲ្យខ្ញុំ សម្រាប់ការងារដែលខ្ញុំហៅគេឲ្យធ្វើ»។ មុននឹងចាត់លោកឲ្យទៅបំពេញភារកិច្ចជាបេសកជនសម្រាប់ពិភពនៃសាសន៍ដទៃ ពួកសិស្សបានឧទ្ទិសអ្នកទាំងពីនេះយ៉ាងឧឡារិកថ្វាយទៅព្រះ ដោយការតមអត់និងអធិដ្ឋានដាក់ដៃពីលើ។ ធ្វើដូច្នេះ ពួកជំនុំមិន

គ្រាន់តែផ្ដល់សិទ្ធិ ឲ្យពួកគេអាចបង្រៀនពីសេចក្ដីពិតប៉ុណ្ណោះទេ ប៉ុន្ដែ ឲ្យអាចមានសិទ្ធិពេញលេញដើម្បីប្រារព្ធពិធីបុណ្យជ្រមុជទឹក និងពិធីបំពេញសិទ្ធិ (បំបួស) ព្រះវិហារថែមទៀតផង។

<u>អង្គារ-១ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ៧

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ឯសេចក្ដីឯទៀត បងប្អូនអើយ ចូរឲ្យមានកំឡាំងឡើងក្នុងព្រះអម្ចាស់ ដោយឫទ្ធិបារមីរបស់ព្រះចេស្ដាទ្រង់ ចូរពាក់គ្រប់គ្រឿងសឹករបស់ព្រះ ដើម្បីឲ្យអាចនឹងឈរមាំមួន ទាស់នឹងឧបាយកលទាំងអម្បាលម៉ានរបស់អារក្ស។ អេភេសូរ ៦:១០-១១*

នៅពេលនេះ ពួកជំនុំគ្រិស្ដបរិស័ទបានឈានចូលទៅក្នុងកិច្ចការដ៏សំខាន់មួយ។ ឥឡូវនេះកិច្ចការប្រកាសដំណឹងល្អនៅក្នុងចំណោមសាសន៍ដទៃត្រូវបានទទួលការបៀតបៀនយ៉ាងខ្លាំងក្លា ហើយជាលទ្ធផល ពួកជំនុំត្រូវបានពង្រឹងកម្លាំងដោយការជួបជុំមនុស្សជាច្រើន។ ពួកសាវ័កដែលបានទទួលាការតែងតាំងឲ្យដឹកនាំការងារនេះកន្លងមក ត្រូវទទួលរងនូវភាពមន្ទិលសង្ស័យ ការប្រកាន់ពូជសាសន៍ និងការច្រណែននិន្ទា ។ ការបង្រៀនរបស់ពួកគេ ទាក់ទងនឹងការរុះ «ជញ្ជាំងដែលខ័ណ្ឌកណ្ដាលចេញ» (អេភេសូរ ២:១៤) ដែលបានបំបែកពួកសាសន៍យូដាចេញពីពិភពនៃសាសន៍ដទៃជាយូរមកហើយនោះ  បានធ្វើឲ្យពួកគេទទួលរងនូវការចោទប្រកាន់ពីបទប្រកាន់លទ្ធិខុសពីជំនឿសាសនា ហើយអំណាចរបស់ពួកគេ ក្នុងនាមជាគ្រូគង្វាលនៃដំណឹងល្អត្រូវបានសង្ស័យដោយពួកអ្នកជឿសាសន៍យូដាដែលមានចិត្តពុះកញ្ជ្រោល ។ ព្រះទ្រង់បានជ្រាបជាមុននូវការពិបាក ដែលព្រះអង្គនឹងបណ្ដោយឲ្យអ្នកបម្រើរបស់ទ្រង់ជួបប្រទះ ហើយដើម្បីឲ្យកិច្ចការរបស់ពួកគេបានខ្ពស់ជាងការពិបាកទាំងឡាយនោះ ព្រះអង្គបានណែនាំពួកជំនុំដោយការបើកសម្ដែងឲ្យញែកពួកគេចេញជាសាធារណៈសម្រាប់កិច្ចការបម្រើដំណឹងល្អ ។ ភារកិច្ចចម្បងរបស់ពួកគេគឺជាការទទួលស្គាល់ជា

សាធារណៈ នូវការតែងតាំងរបស់ពួកគេដោយព្រះជាម្ចាស់ ដើម្បីនាំសេចក្តីស្រឡាញ់នៃដំណឹងល្អទៅកាន់សាសន៍ដទៃ ។

ទាំងលោកប៉ុលនិងទាំងបាណាបាសធ្លាប់បានទទួលការតែងតាំងពីព្រះដោយផ្ទាល់រួចមកហើយ ហើយពិធីដាក់ដៃលើក្បាលនៅពេលនេះ មិនបានបន្ថែមព្រះគុណថ្មី ឬគុណតម្លៃអ្វីទេ។ ពិធីនេះគឺជាទម្រង់នៃការប្រកាសតែងតាំងដល់មុខតំណែងដែលព្រះបានរៀបចំ និងជាការទទួលស្គាល់អំណាចរបស់អ្នកណាម្នាក់នៅក្នុងមុខតំណែងនោះប៉ុណ្ណោះ។ ដោយពិធីនេះ ត្រារបស់ពួកជំនុំត្រូវបានបោះនៅលើកិច្ចការរបស់ព្រះ។

នេះគឺជាពិធីដ៏សំខាន់មួយ សម្រាប់សាសន៍យូដា ។ នៅពេលឪពុកសាសន៍យូដាឲ្យពរដល់កូនៗ លោកដាក់ដៃលើក្បាលពួកគេដោយគោរព។ នៅពេលដែលគេថ្វាយសត្វជាតង្វាយយញ្ញបូជា អ្នកដែលទទួលអំណាចជាសង្ឃ ត្រូវដាក់ដៃលើសត្វរងគ្រោះនោះ។ ហើយនៅពេលដែលពួកអ្នកជឿនៅក្រុងអាន់ទីយ៉ូកបានដាក់ដៃលើក្បាលលោកប៉ុលនិងបាណាបាស តាមរយៈសកម្មភាពនោះ ពួកគេបានសុំឲ្យព្រះប្រទានព្រះពររបស់ទ្រង់ដល់ពួកសាវ័កដែលគេបានជ្រើសតាំងដើម្បីឲ្យបំពេញភារកិច្ចជាក់លាក់ដែលពួកគេត្រូវបានតែងតាំងនោះ ។

ចំណេរក្រោយមកទៀត ពិធីតែងតាំងដោយការដាក់ដៃលើក្បាលនេះត្រូវបានគេបំពានយ៉ាងធ្ងន់ធ្ងរ គឺគេបានភ្ជាប់សារៈសំខាន់ដែលមិនអាចអត់ទោសឲ្យបានទៅនឹងសកម្មភាពនោះ ថាអ្នកដែលបានទទួលពិធីនេះនឹងមានអំណាចភ្លាម ដែលធ្វើឲ្យអ្នកនោះមានគុណសម្បត្តិអាចបំពេញតួនាទីជាគ្រូគង្វាលបានភ្លាមៗ។ ប៉ុន្តែ នៅក្នុងការញែកសាវ័កទាំងពីរនេះ មិនកំណត់ត្រាណាដែលបញ្ជាក់ថាមានគុណតម្លៃបន្ថែមបានកើតឡើង ដោយសារពិធីដាក់ដៃលើក្បាលនេះទេ ។ មានកំណត់ត្រាត្រឹមតែអំពីពិធីរបស់ពួកគេ និងការបង្ហាញអំពីកិច្ចការរបស់ពួកគេនៅពេលអនាគតតែប៉ុណ្ណោះ។

បរិយាកាសដែលភ្ជាប់ទំនាក់ទំនងទៅនឹងការបំបែកលោកប៉ុលនិង

បាណាបាសដោយព្រះវិញ្ញាណបរិសុទ្ធ សម្រាប់បំពេញកិច្ចការដ៏ជាក់លាក់ នោះបានបង្ហាញយ៉ាងច្បាស់ថាព្រះជាម្ចាស់ធ្វើការតាមរយៈភ្នាក់ងារដែលទ្រង់បានតែងតាំងនៅក្នុងពួកជំនុំពេញសិទ្ធិរបស់ទ្រង់។ ជាច្រើនឆ្នាំមុនកាលព្រះអង្គសង្គ្រោះបានបង្ហាញព្រះរាជគោលបំណងរបស់ទ្រង់ដោយផ្ទាល់ទាក់ទងនឹងលោកប៉ុល ជាលើកដំបូង បន្ទាប់មក គេបាននាំលោកប៉ុលទៅជួបនឹងសមាជិកនៃពួកជំនុំដែលទើបនឹងរៀបចំថ្មីនៅទីក្រុងដាម៉ាសភ្លាម។ លើសពីនោះទៅទៀត ពួកជំនុំនៅទីនោះ លែងងងឹតងងល់អំពីចំណេះដឹងខាងបទពិសោធន៍នៃការផ្លាស់ប្តូរជំនឿរបស់បុរសដែលជាពួកផារិស៊ីនេះតទៅទៀតហើយ។ ហើយឥឡូវនេះ កាលដែលព្រះបានប្រទានការត្រាស់បង្គាប់នៅពេលនោះ លោកអនុវត្តតាមកាន់តែពេញលេញ ព្រះវិញ្ញាណបរិសុទ្ធបានធ្វើទីបន្ទាល់ម្តងទៀត ទាក់ទងទៅនឹងលោកប៉ុល ជាប្រដាប់រើសតាំងសម្រាប់ផ្សាយដំណឹងល្អដល់សាសន៍ដទៃ ទ្រង់បានប្រទានភារកិច្ចដល់ពួកជំនុំ ក្នុងការតែងតាំងលោកនិងអ្នករួមការងាររបស់លោក ជាអ្នកដឹកនាំនៃពួកជំនុំអាន់ទីយ៉ូក «កំពុងដែលអ្នកទាំងនោះធ្វើការងារថ្វាយព្រះអម្ចាស់ទាំងតមនោះព្រះវិញ្ញាណបរិសុទ្ធមានព្រះបន្ទូលប្រាប់ថា ចូរញែកបាណាបាសនិងសុលចេញឲ្យខ្ញុំ សម្រាប់ការងារដែលខ្ញុំហៅគេឲ្យធ្វើ» ។

**<u>ពុធ-២ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ៨**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ដូច្នេះ ចូរឲ្យឈរមាំមួនចុះ ដោយក្រវាត់សេចក្តីពិតនៅចង្កេះ ហើយពាក់សេចក្តីសុចរិតទុកជាប្រដាប់បាំងដើមទ្រូង។ អេភេសូរ ៦:១៤*

ព្រះបានធ្វើឲ្យពួកជំនុំរបស់ទ្រង់នៅលើផែនដីក្លាយជាបណ្តាញនៃពន្លឺ ហើយព្រះអង្គប្រស្រ័យទាក់ទងអំពីព្រះរាជគោលបំណងនិងព្រះហឫទ័យរបស់ទ្រង់ តាមរយៈពួកជំនុំនេះ ។ ព្រះអង្គមិនបានប្រទានឲ្យអ្នកបម្រើរបស់ទ្រង់ណាម្នាក់មានបទពិសោធន៍ដាច់ដោយឡែក ឬផ្ទុយពីបទពិសោធន៍របស់ពួកជំនុំដោយផ្ទាល់នោះឡើយ ។ ឬមួយក៏ព្រះអង្គមិនដែលប្រទានដល់អ្នក

ណាម្នាក់ នូវចំណេះដឹងអំពីព្រះហឫទ័យរបស់ទ្រង់សម្រាប់ពួកជំនុំទាំងមូល នៅពេលដែលពួកជំនុំដែលជារាងកាយរបស់ព្រះគ្រិស្តឋិតនៅក្នុងភាពងងឹត (មិនដឹង) នោះដែរ។ នៅក្នុងទិព្វញ្ញាណរបស់ទ្រង់ ព្រះអង្គបានដាក់អ្នកបម្រើរបស់ទ្រង់ ឲ្យមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងពួកជំនុំរបស់ទ្រង់ ដើម្បីកុំឲ្យពួកគេមានទំនុកចិត្តលើខ្លួនឯង ហើយឲ្យមានទំនុកចិត្តនៅលើអ្នកដទៃដែលព្រះកំពុងដឹកនាំឲ្យជំរុញកិច្ចការឆ្ពោះទៅមុខ។

មិនដែលមានអ្នកណាម្នាក់នៅក្នុងពួកជំនុំ ដែលក្រាញនៀលទីពឹងទៅលើបុគ្គលណាម្នាក់ឡើយ ។ ពួកគេហាក់ដូចជាមិនអាចដឹងថាការមិនទីពឹងលើព្រះវិញ្ញាណ ទទួលខុសត្រូវក្នុងការដឹកនាំភ្នាក់ងារមនុស្សឲ្យទីពឹងនិងទុកចិត្តតែទៅលើការវិនិច្ឆ័យរបស់ខ្លួនឯង ខ្លាំងជាងការគោរពជំបូន្មាននិងតម្លៃនៃការវិនិច្ឆ័យដ៏ខ្ពង់ខ្ពស់របស់បងប្អូន ជាពិសេស អ្នកដែលព្រះបានតែងតាំងឲ្យមានតំណែងជាមេដឹកនាំលើរាស្ត្ររបស់ទ្រង់ ។ ព្រះបានប្រទានការគ្រប់គ្រងនិងអំណាចពិសេសដល់ពួកជំនុំរបស់ទ្រង់ ដែលគ្មានអ្នកណាអាចសម្របសម្រួលក្នុងការមិនគោរពនិងប្រមាថមើលងាយឡើយ ដ្បិតអ្នកដែលធ្វើដូច្នោះ ឈ្មោះថាបានប្រមាថដល់ព្រះហើយ។

អស់អ្នកទាំងឡាយណាដែលក្រាញនៀលក្នុងការគោរពតែការវិនិច្ឆ័យរបស់ខ្លួនឯងជាធំ គឺកំពុងនៅក្នុងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរហើយ។ គឺជាការខំប្រឹងប្រែងយ៉ាងចំណានរបស់សាតាំងក្នុងការបំបែកអ្នកដែលជាបណ្តាញនៃពន្លឺជាអ្នកដែលព្រះស្វះស្វែងស្ថាបនានិងពង្រីកកិច្ចការរបស់ទ្រង់នៅលើផែនដីនេះ តាមរយៈពួកគេ។ ការមិនយកចិត្តទុកដាក់និងការប្រមាថដល់អ្នកដែលព្រះបានតែងតាំងឲ្យទទួលខុសត្រូវជាអ្នកដឹកនាំ ក្នុងការភ្ជាប់ទំនាក់ទំនងនៃការជឿនលឿនខាងឯសេចក្តីពិត គឺបានន័យថា បដិសេធមធ្យោបាយដែលព្រះបានតែងតាំងដើម្បីជួយលើកទឹកចិត្ត និងពង្រឹងដល់រាស្ត្ររបស់ទ្រង់ ។ ចំពោះអ្នកដែលបម្រើកិច្ចការរបស់ព្រះណាដែលរំលងនឹងបញ្ញត្តិទាំងនេះ និងដែលគិតថាពន្លឺរបស់ខ្លួន មិនត្រូវមកពីបណ្តាញណាក្រៅពីព្រះដោយ

ផ្ទាល់ទេនោះ គឺបានដាក់ខ្លួនឯងក្រៅក្នុងកន្លែងដែលទទួលការបោកបញ្ឆោត និងទាញទម្លាក់ដោយសត្រូវហើយ ។ នៅក្នុងព្រះប្រាជ្ញាញាណរបស់ទ្រង់ ព្រះបានរៀបចំថាដោយមធ្យោបាយនៃទំនាក់ទំនងយ៉ាងជិតស្និទ្ធដែលពួកអ្នកជឿទាំងអស់បានរក្សា គឺគ្រិស្តបរិស័ទត្រូវរួបរួមជាមួយនឹងគ្រិស្តបរិស័ទពួកជំនុំនិងពួកជំនុំ។ ធ្វើដូច្នេះ មនុស្សដែលជាឧបករណ៍អាចសហការជាមួយនឹងព្រះ។ រាល់ភ្នាក់ងារទាំងអស់នឹងត្រូវតែនៅក្រោមបង្គាប់ព្រះវិញ្ញាណបរិសុទ្ធ ហើយពួកអ្នកជឿទាំងអស់ត្រូវតែរួបរួមជាមួយនឹងការខំប្រឹងប្រែងដែលមានរបៀបរៀបរយនិងការដឹកនាំត្រឹមត្រូវ ដើម្បីផ្តល់នូវដំណឹងល្អអំពីព្រះគុណរបស់ព្រះដល់ពិភពលោក ។

លោកប៉ុលបានចាត់ទុកឱកាសនៃការតែងតាំងកាលពីកន្លងមករបស់លោក ថាជាការចាប់ផ្តើមយុគសម័យថ្មីដ៏សំខាន់មួយ នៅក្នុងជីវិតនៃកិច្ចការរបស់លោក។ គឺលោកបានកំណត់កាលបរិច្ឆេទការចាប់ផ្តើមភាពជាសាវ័ករបស់លោកនៅក្នុងពួកជំនុំគ្រិស្ទបរិស័ទ ចាប់តាំងពីពេលនោះមក។

កាលពន្លឺនៃដំណឹងល្អបានចែងចាំងដ៏ត្រចះត្រចង់នៅក្រុងអាន់ទីយ៉ូក ពួកសាវ័កដែលនៅទីក្រុងយេរូសាឡិមបានបន្តកិច្ចការដ៏សំខាន់។ សាសន៍យូដាជាច្រើនបានមកទីគ្រប់ទិសទីនៅក្នុងនគរ មកចូលរួមធ្វើបុណ្យនៅព្រះវិហារនៃទីក្រុងយេរូសាឡិមជារៀងរាល់ឆ្នាំ។ ក្នុងចំណោមពួកអ្នកដែលបានធ្វើដំណើរមកពីឆ្ងាយទាំងនោះ អ្នកខ្លះជាអ្នកស្រឡាញ់និងគោរពសាសនាយ៉ាងក្លៀវក្លា និងជាអ្នកសិក្សាបទទំនាយដោយស្មោះត្រង់។ ពួកគេកំពុងរង់ចាំនិងកំពុងចង់បានព្រះមែស្ស៊ីដែលព្រះបានសន្យា ដែលជាសេចក្តីសង្ឃឹមនៃសាសន៍អ៊ីស្រាអែល។ នៅគ្រាដែលមានជនបរទេសជាច្រើននៅទីក្រុងយេរូសាឡិម ពួកសាវ័កបានអធិប្បាយអំពីព្រះគ្រិស្តដោយក្តីក្លាហានឥតរង្កើ ទោះបីជាពួកគេបានដឹងថាការធ្វើដូច្នេះ ពួកគេកំពុងយកជីវិតរបស់ពួកគេទៅប្រថុយនឹងគ្រោះថ្នាក់ក៏ដោយ។ ព្រះវិញ្ញាណរបស់ព្រះបានបោះត្រានៅលើកិច្ចការរបស់ពួកគេ មនុស្សជាច្រើនបានផ្លាស់ប្តូរជំនឿ ហើយពួកអ្នក

ទាំងនេះបានវិលត្រឡប់ទៅកាន់ទីលំនៅរបស់ពួកគេវិញ ដែលបានធ្វើឲ្យគ្រាប់ពូជនៃសេចក្តីពិតបានរាលដាលទៅកាន់គ្រប់ជាតិសាសន៍ និងគ្រប់ស្រទាប់វណ្ណៈក្នុងសង្គម ។

ក្នុងចំណោមពួកសាវ័ក អ្នកដែលលេចធ្លោជាងគេមានលោកពេត្រុស យ៉ាកុប និងលោកយ៉ូហាន ដែលមានទំនុកចិត្តថាព្រះតែងតាំងពួកលោកឲ្យអធិប្បាយអំពីព្រះគ្រិស្តនៅក្នុងបងប្អូនរួមជាតិរបស់លោកនៅតាមផ្ទះ។ ទីបំផុត ពួកគេបានធ្វើការយ៉ាងឆ្លាតវាងវៃដោយបង្ហាញពីអ្វីដែលពួកលោកបានឃើញនិងបានឮ ហើយបានអំពាវនាវពី «ពាក្យទំនាយដ៏ពិតជាង» (ពេត្រុសទី២ ១:១៩) នៅក្នុងការខំប្រឹងប្រែងទាក់ទាញ «ដូច្នេះ ចូរឲ្យពួកវង្សអ៊ីស្រាអែលដឹងប្រាកដថា ... ព្រះទ្រង់បានលើកព្រះយេស៊ូវនេះ» ដែលអ្នករាល់គ្នាបានឆ្កាង «ឲ្យទ្រង់ធ្វើជាព្រះអម្ចាស់ ហើយជាព្រះគ្រិស្តផង» (កិច្ចការ ២:៣៦) ។

# ជំពូកទី ១៧

# ការប្រកាសដំណឹងល្អ

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ១៣:៤-៥២ ។ៗ*

<u>ព្រហស្បតិ៍-៣ កញ្ញា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ៩**
**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ទាំងពាក់សេចក្តីប្រុងប្រៀបរបស់ដំណឹងល្អនៃសេចក្តីសុខសាន្ត ទុកជាស្បែកជើង។ អេភេសូរ ៦:១៥*

«ដោយព្រះវិញ្ញាណបរិសុទ្ធចាត់ឲ្យទៅ» បន្ទាប់ពីពិធីបំពេញសិទ្ធិរបស់ពួកលោករួចមក លោកប៉ុលនិងបាណាបាស «ក៏ចុះទៅដល់សេលើស៊ា នៅទីនោះ គេចុះសំពៅចេញទៅឯកោះគីប្រុស»។ ដូច្នេះ សាវ័កទាំងពីរនាក់ក៏បានចាប់ផ្តើមដំណើរជាបេសកជនរបស់លោក។

កោះគីប្រុសគឺជាកន្លែងដែលពួកអ្នកជឿបានរត់គេចខ្លួន ចេញពីទីក្រុងយេរូសាឡិម ដោយសារការបៀតបៀន បន្ទាប់ពីមរណភាពរបស់លោកស្ទេផានមក។ គឺកោះគីប្រុសនេះហើយដែលមនុស្សមួយចំនួនបានធ្វើដំណើរទៅកាន់ទីក្រុងអាន់ទីយ៉ូក «ក៏ផ្សាយដំណឹងល្អពីព្រះអម្ចាស់យេស៊ូវ» (កិច្ចការ ១១:២០) ។

បាណាបាសគឺជាអ្នក «ដែលកើតនៅកោះគីប្រុស» (កិច្ចការ ៤:៣៦) ហើយឥឡូវនេះ លោកនិងលោកប៉ុល អមដំណើរដោយលោកយ៉ូហានម៉ាកុស ដែលជាញាតិសន្តាននឹងលោកបាណាបាសបានមកធ្វើទស្សនកិច្ចនៅកោះនេះ ។

ម្តាយរបស់លោកម៉ាកុសគឺជាអ្នកដែលបានផ្លាស់ប្តូរជំនឿមកកាន់សាសនាគ្រិស្ត ហើយផ្ទះរបស់លោកស្រីនៅទីក្រុងយេរូសាឡិមគឺជាទីស្នាក់

អាស្រ័យរបស់ពួកសាវ័ក។ នៅទីនោះ ពួកគេតែងតែទទួលបាននូវការស្វាគមន៍យ៉ាងរាក់ទាក់ និងមានពេលសម្រាកយ៉ាងល្អ។ គឺនៅក្នុងអំឡុងពេលនៃការសួរសុខទុក្ខមួយរបស់ពួកសាវ័ក មកកាន់ផ្ទះម្ដាយរបស់លោកនេះហើយ ដែលលោកម៉ាកុសបានស្នើសុំដល់លោកប៉ុល និងបាណាបាសឲ្យលោកបានរួមដំណើរជាមួយពួកគាត់ ក្នុងដំណើរបេសកជនរបស់ពួកលោកផង។ គាត់បានដឹងពីកិច្ចការរបស់ព្រះនៅក្នុងចិត្ត ហើយចង់លះបង់ខ្លួនឯងទាំងស្រុងដើម្បីបំពេញកិច្ចការផ្សាយដំណឹងល្អ ។

កាលបានមកដល់សាឡាមីនហើយ ពួកសាវ័ក «គេក៏ផ្សាយព្រះបន្ទូលនៅក្នុងសាលាប្រជុំទាំងប៉ុន្មានរបស់ពួកសាសន៍យូដា មានទាំងយ៉ូហានជាអ្នកជំនួយដែរ កាលបានដើរកាត់កោះទៅ ត្រឹមប៉ាផុសហើយ នោះក៏ប្រទះនឹងសាសន៍យូដាម្នាក់ ដែលធ្វើជាគ្រូអាបធ្មប់ ជាហោរាក្លែងក្លាយ ឈ្មោះបារយេស៊ូវ គ្រូនោះនៅជាមួយនឹងអ្នកតំណាងជាតិរ៉ូមម្នាក់ ឈ្មោះសើគាសប៉ូឡុស ជាអ្នកឆ្លៀវឆ្លាត លោកក៏ហៅបាណាបាស និងសុលមក ដើម្បីចង់ស្តាប់ព្រះបន្ទូល តែអេលីម៉ាស ជាគ្រូអាបធ្មប់នោះ (ដ្បិតឈ្មោះនោះប្រែមកដូច្នេះ) ក៏តាំងខ្លួនទាស់នឹងគេ ដើម្បីបង្វែរលោកមិនឲ្យជឿ» ។

សាតាំងមិនបានបណ្ដោយឲ្យពួកសាវ័កស្ថាបនានគររបស់ព្រះ នៅលើផែនដីនេះដោយមិនមានឧបសគ្គនោះទេ។ កងកម្លាំងរបស់អារក្សបានចូលរួមតតឈប់ឈរ នៅក្នុងសង្គ្រាមប្រឆាំងនឹងភ្នាក់ងារដែលព្រះបានតែងតាំងឲ្យផ្សព្វផ្សាយដំណឹងល្អ ហើយអំណាចនៃសេចក្ដីងងឹតទាំងនេះបញ្ចេញសកម្មភាពជាពិសេស នៅពេលដែលសេចក្ដីពិតត្រូវបានប្រកាសនៅចំពោះមុខមនុស្សដែលមានគេរាប់អានច្រើន និងមានកេរ្តិ៍ឈ្មោះនិងលុយកាក់ច្រើន។ រឿងនេះបានកើតឡើងនៅពេលដែលសើគាសប៉ូឡុស ជាតំណាងនៅកោះគីប្រុសកំពុងស្តាប់សារនៃដំណឹងល្អ។ អ្នកដែលជាតំណាងនោះបានចាត់គេឲ្យទៅហៅពួកសាវ័ក ដើម្បីមកបង្ហាត់បង្រៀនដល់លោកអំពីសារដែលពួកគេមក ដើម្បីនឹងផ្សព្វផ្សាយ ប៉ុន្តែ ឥឡូវនេះ កងកម្លាំងរបស់

អារក្សកំពុងធ្វើការតាមរយៈអេលីម៉ាស ជាគ្រូអាបធ្មប់នោះ ដោយបានធ្វើការស្ទើយោបល់អាក្រក់ដើម្បីបង្វែរលោកពីជំនឿ ហើយបានរំខានដល់ព្រះរាជគោលបំណងរបស់ព្រះវិញ ។

<u>សុក្រ-៤ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ១០

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ថែមទាំងយកសេចក្តីជំនឿទុកជាខែលផង ដែលអ្នករាល់គ្នានឹងអាចរំលត់ អស់ទាំងព្រួញឆេះរបស់មេកំណាច ដោយសារខែលនោះបាន។ អេភេសូរ ៦:១៦*

ដូច្នេះ កម្លាំងរបស់អារក្សតែងតែធ្វើការដើម្បីរក្សាមនុស្សដ៏មានឥទ្ធិពលដែលអាចចុះចូលជាមួយនឹងកិច្ចការរបស់ព្រះដ៏មានប្រសិទ្ធិភាព ប្រសិនបើមនុស្សនោះបានកែប្រែជំនឿ។ ប៉ុន្តែ អ្នកបម្រើដំណឹងល្អមិនត្រូវភ័យខ្លាចបរាជ័យដោយដៃសត្រូវទេ ព្រោះពួកគេមានឯកសិទ្ធិក្នុងការទទួលព្រះចេស្តាពីឋានលើ ដើម្បីទប់ទល់ជាមួយនឹងឥទ្ធិពលរបស់អារក្ស។

ទោះបីជាមានការរំខានយ៉ាងឈឺចាប់ពីសំណាក់សាតាំងក៏ដោយ ក៏លោកប៉ុលនៅតែមានសេចក្តីក្លាហាន ក្នុងការស្តីបន្ទោសដល់អ្នកដែលសត្រូវកំពុងប្រើប្រាស់នោះដែរ ។ សាវ័កប៉ុល «បានពេញជាព្រះវិញ្ញាណបរិសុទ្ធ ក៏សម្លឹងមើលទៅគ្រូនោះ ដោយនិយាយថា នែមនុស្សដែលពេញដោយកិច្ចកល និងសេចក្តីល្បិចគ្រប់យ៉ាង ជាកូននៃអារក្ស ហើយជាខ្មាំងសត្រូវដល់គ្រប់ទាំងសេចក្តីសុចរិតអើយ តើមិនព្រមឈប់បង្ខូចផ្លូវត្រង់របស់ព្រះអម្ចាស់ទេឬអី  មើលឥឡូវនេះ ព្រះហស្តនៃព្រះអម្ចាស់បានមកលើឯងហើយ ឯងនឹងត្រូវខ្វាក់ភ្នែក មើលមិនឃើញពន្លឺថ្ងៃជាយូរបន្តិច នោះស្រាប់តែភ្នែករបស់គ្រូនោះបានទៅជាព្រិលៗ ហើយងងឹតសូន្យទៅរួចក៏ដើរវិលវល់រកអ្នកណាឲ្យដឹកដៃ កាលលោកដំណាងជាតិឃើញ ការដែលកើតមកដូច្នោះនោះក៏ជឿ ព្រមទាំងមានសេចក្តីអស្ចារ្យក្នុងចិត្ត អំពីសេចក្តីបង្រៀនរបស់ព្រះអម្ចាស់ផង» ។

គ្រូធ្មប់នោះបានបិទភ្នែករបស់គាត់នៅចំពោះភស្តុតាងនៃសេចក្ដីពិតខាងដំណឹងល្អ ហើយដោយសេចក្ដីក្រោធដ៏សុចរិតរបស់ទ្រង់ ព្រះជាម្ចាស់បានបណ្ដាលឲ្យភ្នែកកំណើតរបស់គាត់ត្រូវបានបិទមើលពន្លឺថ្ងៃលែងឃើញ ។ ការងងឹតភ្នែកនេះមិនបាននៅជាអចិន្ត្រៃយ៍ទេ គឺនៅតែមួយរយៈប៉ុណ្ណោះ ដើម្បីឲ្យគ្រូធ្មប់នោះត្រូវបានព្រមានឲ្យកែប្រែចិត្ត ហើយស្វែងរកការអត់ទោសពីព្រះដែលគាត់បានប្រឆាំងយ៉ាងធ្ងន់ធ្ងរនោះ។ ការភ័ន្តភាំងដែលបានកើតឡើងដល់គាត់យ៉ាងដូច្នេះ បានធ្វើឲ្យភាពប៉ិនប្រសប់របស់គាត់លែងមានឥទ្ធិពលប្រឆាំងនឹងគោលលទ្ធិរបស់ព្រះគ្រិស្តបានទៀត។ រឿងពិតដែលគាត់ត្រូវតែរាវផ្លូវដោយភាពងងឹតដូច្នេះ បានបង្ហាញដល់មនុស្សទាំងអស់ថា ការអស្ចារ្យដែលពួកសាវ័កបានធ្វើ ត្រូវបាននាំមកដោយព្រះចេស្ដារបស់ព្រះ ហើយដែលអេលីម៉ាសបានប្រកាសថាជាដៃដ៏ប៉ិនប្រសប់។ អ្នកតំណាងនោះបានទទួលជឿសេចក្ដីពិតដែលពួកសាវ័កបានបង្រៀន ហើយក៏បានទទួលដំណឹងល្អ ។

អេលីម៉ាសជាមនុស្សមិនមានចំណេះដឹងទេ ហើយជាមនុស្សដែលសមនឹងធ្វើកិច្ចការរបស់សាតាំង។ អ្នកដែលអធិប្បាយអំពីសេចក្ដីពិតរបស់ព្រះនឹងជួបប្រទះនឹងសត្រូវដែលមានឧបាយកលនៅក្នុងទម្រង់ខុសៗគ្នាជាច្រើន ជួនកាលសត្រូវនោះអាចជាមនុស្សមានចំណេះដឹង ប៉ុន្តែ ជាញឹកញាប់ ជាមនុស្សដែលល្ងិតល្ងង់ ដែលសាតាំងបានបង្វឹកឲ្យក្លាយទៅជាឧបករណ៍ដ៏មានជោគជ័យរបស់វា សម្រាប់បោកបញ្ឆោតមនុស្ស។ គឺជាភារកិច្ចរបស់អ្នកបម្រើការងាររបស់ព្រះគ្រិស្តដែលត្រូវឈរយ៉ាងស្មោះត្រង់នៅនឹងកន្លែងរបស់ខ្លួន ដោយកោតខ្លាចព្រះនិងនៅក្នុងព្រះចេស្ដានៃឫទ្ធានុភាពរបស់ទ្រង់។ ធ្វើដូច្នេះ អ្នកនោះអាចនឹងធ្វើឲ្យពួកទេវតារបស់សាតាំងច្របូកច្របល់ ហើយនឹងមានជោគជ័យដោយនូវព្រះនាមនៃព្រះជាម្ចាស់ផង ។

លោកប៉ុលនិងគូកនរបស់លោកបានបន្តដំណើរទៅពើកា នៅស្រុកប៉ាមភីលា។ ផ្លូវដែលពួកគេត្រូវធ្វើដំណើរនោះពិបាកខ្លាំងណាស់ ពួកគេបាន

ជួបប្រទះនឹងការពិបាកនិងការខ្វះខាតជាច្រើន ហើយត្រូវប្រឈមតទល់នឹងគ្រោះថ្នាក់មកពីគ្រប់ទិសទីថែមទៀតផង។ នៅក្នុងទីក្រុងនិងទីប្រជុំជនដែលពួកគេបានឆ្លងកាត់ និងនៅតាមផ្លូវដ៏ស្ងាត់ជ្រងំ ពួកគេត្រូវបានសត្រូវហ៊ុំព័ទ្ធជុំវិញ ទាំងសត្រូវដែលមើលឃើញនិងសត្រូវដែលមើលមិនឃើញ ។ ប៉ុន្តែលោកប៉ុលនិងបាណាបាសបានរៀនទុកចិត្តលើព្រះចេស្ដារបស់ព្រះឲ្យជួយរំដោះ។ ចិត្តរបស់ពួកលោកពោរពេញទៅដោយសេចក្ដីស្រឡាញ់យ៉ាងក្លៀវក្លាដល់ពួកមនុស្សដែលត្រូវវិនាស ។ ក្នុងនាមជាអ្នកគង្វាលដ៏ស្មោះត្រង់ដែលស្វែងរកចៀមបាត់បង់ ពួកលោកមិនបានគិតគូរពីភាពស្រណុកសុខស្រួលផ្ទាល់ខ្លួនទេ។ ដោយបានបំភ្លេចភាពសុខស្រួលផ្ទាល់ខ្លួន ពួកលោកមិនបានស្ទាក់ស្ទើរឡើយ ទោះបីជាមានការហត់នឿយ ការស្រេកឃ្លាន ឬក្ដៅត្រជាក់យ៉ាងណាក៏ដោយ ពួកលោកគិតតែពីវត្ថុបំណងមួយប៉ុណ្ណោះ គឺសេចក្ដីសង្គ្រោះដល់អ្នកដែលបានវង្វេងចេញពីហ្វូង។

**<u>សៅរ៍-៥ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ១១**

**ខព្រះគម្ពីរប្រចាំសប្ដាហ៍:** *ចូរយកសេចក្ដីសង្គ្រោះទុកជាមួកសឹក និងដាវរបស់ព្រះវិញ្ញាណដែរ គឺជាព្រះបន្ទូល។ អេភេសូរ ៦:១៧*

គឺនៅទីនោះហើយដែលលោកម៉ាកុសមានការភ័យខ្លាច និងបាក់ទឹកចិត្ត ដោយស្ទាក់ស្ទើរក្នុងការថ្វាយខ្លួនដាច់ដល់កិច្ចការរបស់ព្រះជាម្ចាស់មួយរយៈ ។ ដោយមិនធ្លាប់ជួបប្រទះនឹងការពិបាក លោកបានរួញរាដោយការវេទនា និងការខ្វះខាតនៅតាមផ្លូវ។ លោកធ្លាប់ធ្វើការមានជោគជ័យនៅក្រោមបរិយាកាសសុខស្រួល ប៉ុន្តែ ឥឡូវនេះនៅកណ្ដាលការប្រឆាំងនិងសេចក្ដីវេទនា ដែលតែងតែឡោមព័ទ្ធពួកអ្នកត្រួសត្រាយផ្លូវ លោកមិនអាចទ្រាំទ្រនិងការពិបាក ក្នុងឋានៈជាទាហានដ៏ក្លាហានរបស់ឈើឆ្កាងបានឡើយ។ លោកមិនធ្លាប់បានរៀនប្រឈមនឹងគ្រោះថ្នាក់ និងការធ្វើទុក្ខបៀតបៀន ព្រមទាំងភាពខ្វះខាតដោយចិត្តក្លាហានទេ។ ខណៈដែលពួកសាវ័ក

បានបោះជំហានទៅមុខ ហើយត្រូវឆ្លងកាត់ការពិបាកៗជាច្រើន នោះលោកម៉ាកុសភ័យតក់ស្លុត បាត់បង់ភាពក្លាហាន ហើយប្រកែកលែងទៅមុខទៀត រួចក៏បានវិលត្រឡប់ទៅកាន់ទីក្រុងយេរូសាឡិមវិញ ។

ការរត់ចោលជួរនេះបានធ្វើឲ្យលោកប៉ុលថ្កោលទោសលោកម៉ាកុសមិនត្រឹមត្រូវ និងយ៉ាងធ្ងន់ធ្ងរមួយរយៈ។ ម្យ៉ាងវិញទៀត លោកបាណាបាស ចង់អត់ទោសឲ្យគាត់ដោយសារបទពិសោធន៍របស់លោកម៉ាកុស។ លោកខ្វល់ខ្វាយជាខ្លាំង ព្រោះលោកម៉ាកុសមិនត្រូវបោះបង់ការងារទេ ដ្បិតលោកបានមើលឃើញលោកម៉ាកុសមានគុណសម្បត្តិអាចក្លាយទៅជាអ្នកធ្វើការថ្វាយព្រះគ្រិស្តដ៏មានជោគជ័យ ។ ប៉ុន្មានឆ្នាំក្រោយមក ព្រះបានប្រទានរង្វាន់ដ៏បរិបូរដល់ការយកចិត្តទុកដាក់របស់លោកជំនួសលោកម៉ាកុសនេះ ព្រោះយុវជននេះបានលះបង់ខ្លួនឯងដល់ព្រះជាម្ចាស់និងដល់កិច្ចការផ្សាយសារនៃដំណឹងល្អ ដោយឥតស្តាយស្រណោះ នៅកន្លែងដែលពិបាកៗ។ នៅក្រោមការប្រទានព្រះពររបស់ព្រះ និងក្រោមការបង្ហាត់បង្រៀនរបស់លោកបាណាបាស ម៉ាកុសបានរីកចម្រើនក្លាយទៅជាអ្នកបម្រើការដ៏មានតម្លៃ ។

ក្រោយមកទៀត លោកប៉ុលបានផ្សះផ្សាជាមួយនឹងម៉ាកុស ហើយបានទទួលយកលោកជាអ្នករួមការងារជាថ្មីឡើងវិញ ។ លោកក៏បានណែនាំឲ្យពួកជំនុំនៅទីក្រុងកូឡុសទទួលស្គាល់ម៉ាកុសថាជាអ្នករួមការងារ «ឯពួកអ្នកដែលធ្វើការជាមួយនឹងខ្ញុំខាងឯនគរព្រះ មានតែប៉ុណ្ណឹងទេ» ដែល «កម្សាន្តចិត្តខ្ញុំ» (កូឡុស ៤:១១) ។ មុនពេលរៀបស្លាប់ លោកប៉ុលបានមានប្រសាសន៍អំពីម៉ាកុសម្តងទៀត ថា «ដ្បិតគាត់ជាអ្នកមានប្រយោជន៍ក្នុងការងារខ្ញុំ» (ធីម៉ូថេទី២ ៤:១១) ។

បន្ទាប់ពីម៉ាកុសបានចាកចេញទៅ លោកប៉ុលនិងបាណាបាសបានធ្វើដំណើរទៅអាន់ទីយ៉ូកវិញនៅស្រុកពីស៊ីឌា នៅថ្ងៃសប្បាតហ៍លោកទាំងពីរបានទៅសាលាប្រជុំនៃសាសន៍យូដា ហើយបានអង្គុយចុះ។ «ក្រោយការដែលអានមើលក្រឹត្យវិន័យ និងគម្ពីរពួកហោរាហើយ នោះមេសាលាក៏ប្រើ

មនុស្សឲ្យទៅប្រាប់ថា បងប្អូនអើយ បើមានសេចក្ដីអ្វីនឹងទូន្មានដល់ពួកជននោះ សូមបងប្អូនមានប្រសាសន៍ចុះ» ។ ដោយបានទទួលការអញ្ជើញឲ្យនិយាយដូច្នេះ «ប៉ុលក៏ក្រោកឡើង ធ្វើគ្រឿងសម្គាល់នឹងដៃ និយាយថា ពួកសាសន៍អ៊ីស្រាអែល និងអស់អ្នកដែលកោតខ្លាចដល់ព្រះអើយ សូមស្ដាប់ចុះ»។ បន្ទាប់មក លោកបានថ្លែងសន្ទរកថាដ៏អស្ចារ្យ។ លោកបានបន្តផ្ដល់រឿងរ៉ាវអំពីលក្ខណៈដែលព្រះជាម្ចាស់បានដោះស្រាយជាមួយនឹងសាសន៍យូដាតាំងពីសម័យនៃការរំដោះរបស់ពួកគេចេញពីចំណាងទាសករនៅស្រុកអេស៊ីព្ទ និងពីសេចក្ដីសន្យានៃព្រះអង្គសង្គ្រោះនិងពូជនៃស្ដេចដាវីឌ ហើយលោកបានប្រកាសដោយក្លាហានថា «គឺពីព្រះវង្សាស្ដេចនោះហើយ ដែលព្រះបានបង្កើតព្រះអង្គសង្គ្រោះមួយអង្គ ដល់សាសន៍អ៊ីស្រាអែល តាមសេចក្ដីសន្យា គឺជាព្រះយេស៊ូវ តែមុនដែលទ្រង់យាងមក នោះលោកយ៉ូហានបានប្រកាសប្រាប់ពីបុណ្យជ្រមុជទឹក ខាងឯការប្រែចិត្ត ដល់សាសន៍អ៊ីស្រាអែលទាំងអស់គ្នាជាស្រេចហើយ កាលលោកយ៉ូហានកំពុងតែធ្វើសម្រេចការងារនោះលោកមានប្រសាសន៍ថា តើអ្នករាល់គ្នាស្មានថាខ្ញុំជាអ្នកណា ខ្ញុំមិនមែនជាព្រះអង្គនោះទេ តែមើល ព្រះអង្គនោះយាងមកក្រោយខ្ញុំ ខ្ញុំមិនគួរនឹងស្រាយខ្សែសុព័ណ៌បាទទ្រង់ផង»។ ដូច្នេះ លោកបានអធិប្បាយអំពីព្រះយេស៊ូវថា ជាព្រះអង្គសង្គ្រោះនៃមនុស្ស ជាព្រះមែស៊ីតាមបទទំនាយ ។

<u>អាទិត្យ-៦ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ១២

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ព្រមទាំងប្រើសេចក្ដីអធិស្ឋាន និងសេចក្ដីទូលអង្វរគ្រប់យ៉ាង ដើម្បីអធិស្ឋានដោយព្រះវិញ្ញាណរាល់ពេលរាល់វេលា ហើយចាំយាមក្នុងសេចក្ដីនោះឯង ដោយនូវគ្រប់ទាំងសេចក្ដីខ្ជាប់ខ្ជួន និងសេចក្ដីទូលអង្វរឲ្យពួកបរិសុទ្ធទាំងអស់។ អេភេសូរ ៦:១៨*

ដោយបានធ្វើការប្រកាសនេះ លោកប៉ុលបានមានប្រសាសន៍ថា «ឱបងប្អូន ជាកូនចៅពូជអ័ប្រាហាំ និងអស់អ្នកក្នុងពួកអ្នករាល់គ្នា ដែលកោតខ្លាច

ដល់ព្រះអើយ ទ្រង់បានផ្ញើព្រះបន្ទូលពីសេចក្ដីសង្គ្រោះនេះ មកដល់អ្នករាល់គ្នា ដ្បិតដោយព្រោះពួកមនុស្សនៅក្រុងយេរូសាឡិម ព្រមទាំងពួកមេរបស់គេមិនបានស្គាល់ទ្រង់ទេ ក៏មិនបានយល់សេចក្ដីទំនាយរបស់ពួកហោរា ដែលគេមើលរាល់តែថ្ងៃឈប់សម្រាកដែរ បានជាគេធ្វើសម្រេចតាមសេចក្ដីទំនាយនោះឯង ដោយគេបានកាត់ទោសដល់ទ្រង់» ។

លោកប៉ុលមិនញញើតនឹងនិយាយត្រង់ៗពីសេចក្ដីពិតដែលទាក់ទងនឹងការបដិសេធន៍ព្រះអង្គសង្គ្រោះ របស់ពួកមេដឹកនាំសាសនាយូដាឡើយ។ សាវ័កប៉ុលបានមានប្រសាសន៍ថា «ហើយទោះបើគេរកហេតុអ្វីនឹងសម្លាប់ទ្រង់មិនបានក៏ដោយ គង់តែគេសូមអង្វរដល់លោកពីឡាត់ ឲ្យបានសម្លាប់ទ្រង់ដែរ ក្រោយដែលគេធ្វើសម្រេចគ្រប់សេចក្ដីដែលចែងទុកពីទ្រង់រួចហើយ នោះគេក៏យកទ្រង់ចុះពីឈើឆ្កាងមកបញ្ចុះក្នុងផ្នូរ តែព្រះបានប្រោសឲ្យទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញ ហើយទ្រង់លេចមក ឲ្យពួកអ្នកដែលបានឡើងពីស្រុកកាលីឡេ មកឯក្រុងយេរូសាឡិមជាមួយនឹងទ្រង់បានឃើញជាយូរថ្ងៃ អ្នកទាំងនោះជាស្មរបន្ទាល់ពីទ្រង់ដល់ពួកជនទាំងឡាយ»។

សាវ័កនេះបានបន្តទៀតថា «យើងខ្ញុំក៏ប្រាប់ដំណឹងល្អនេះ ដល់អ្នករាល់គ្នា គឺជាសេចក្ដីសន្យា ដែលបានតាំងនឹងពួកអយ្យកោយើងថា ព្រះបានធ្វើសម្រេចតាមសេចក្ដីសន្យាទ្រង់ ដល់យើងជាពូជនៃពួកអយ្យកោនោះហើយ ដោយទ្រង់បានប្រោសឲ្យព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ ដូចមានសេចក្ដីចែងទុកមក» ក្នុងគម្ពីរទំនុកតម្កើងជំពូកទីពីរថា «ឯងជាកូនអញ អញបានបង្កើតឯងនៅថ្ងៃនេះ» ហើយដែលព្រះបានប្រោស ឲ្យទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញ ដើម្បីមិនឲ្យទ្រង់ត្រឡប់ទៅឯសេចក្ដីពុករលួយទៀតឡើយ នោះទ្រង់មានព្រះបន្ទូលដូច្នេះថា «អញនឹងផ្តល់សេចក្ដីមេត្តាករុណាស្មោះត្រង់ដែលឲ្យដល់ដាវីឌ ដល់ឯងរាល់គ្នាដែរ» ហេតុដូច្នេះបានជាទ្រង់មានព្រះបន្ទូលក្នុងបទមួយទៀតថា «ទ្រង់មិនទុកឲ្យអ្នកបរិសុទ្ធនៃទ្រង់ ឃើញសេចក្ដីពុករលួយឡើយ រីឯហ្លួងដាវីឌ កាលទ្រង់បានធ្វើការងារចំពោះ

មនុស្សជំនាន់ទ្រង់ តាមព្រះហឫទ័យព្រះ រួចស្រេចហើយ នោះក៏ផុំលក់ទៅ ហើយបានប្រមូលទៅមូលនឹងពួកអយ្យកោទ្រង់ ក៏ឃើញសេចក្ដីពុករលួយដែរ» ។

បន្ទាប់ពីបាននិយាយត្រង់ៗអំពីបទទំនាយដែលពួកគេធ្លាប់បានដឹងទាក់ទងនឹងព្រះមែស្ស៊ីរួចមក ឥឡូវនេះ លោកប៉ុលបានអធិប្បាយប្រាប់ពួកគេអំពីការកែប្រែចិត្តនិងការអត់ឱនទោសបាប តាមរយៈសេចក្ដីសុចរិតរបស់ព្រះយេស៊ូវដែលជាព្រះអង្គសង្គ្រោះ។ លោកបានមានប្រសាសន៍ថា «ដូច្នេះ អ្នករាល់គ្នា ជាបងប្អូនអើយ សូមជ្រាបថា ដែលមានសេចក្ដីប្រោសឲ្យរួចពីបាប បានប្រកាសប្រាប់ដល់អ្នករាល់គ្នា នោះគឺដោយសារព្រះអង្គនោះឯង មួយទៀត ដោយសារទ្រង់ អស់អ្នកណាដែលជឿ បានរាប់ជាសុចរិតរួចពីគ្រប់ការទាំងអស់ ដែលពុំអាចនឹងបានរាប់ជាសុចរិត ដោយសារក្រឹត្យវិន័យលោកម៉ូសេបានឡើយ» ។

ព្រះវិញ្ញាណបានគង់ជាមួយនឹងសម្ដីដែលលោកប៉ុលបាននិយាយ ហើយបានចាក់ចុចចិត្តមនុស្សជាច្រើន។ ការអំពាវនាវរបស់សាវ័កប៉ុលអំពីបទទំនាយនៃគម្ពីរសញ្ញាចាស់ និងការប្រកាសរបស់លោកថាបទទំនាយទាំងនេះត្រូវបានសម្រេចនៅក្នុងព្រះរាជកិច្ចរបស់ព្រះយេស៊ូវពីស្រុកណាសារ៉ែត បាននាំឲ្យមនុស្សជាច្រើនដែលកំពុងរង់ចាំព្រះមែស្ស៊ីដែលព្រះបានសន្យាផ្លាស់ប្ដូរជំនឿ ។ ហើយប្រសាសន៍នៃការធានាអះអាងរបស់លោកប៉ុលដែលថា «ដំណឹងល្អ» នៃសេចក្ដីសង្គ្រោះគឺសម្រាប់សាសន៍យូដានិងសាសន៍ដទៃដូចៗគ្នា បាននាំមកនូវអំណរនិងសេចក្ដីសង្ឃឹមដល់អ្នកដែលមិនបានរាប់បញ្ចូលទៅក្នុងពូជរបស់លោកអ័ប្រាហាំតាមសាច់ឈាម ។

**<u>ច័ន្ទ-៧ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ១៣**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ដ្បិតឯខ្ញុំ ដែលខ្ញុំរស់នៅ នោះគឺសំរាប់ព្រះគ្រីស្ទទេ ហើយដែលស្លាប់ទៅ នោះជាកំរៃវិញ។ ភីលីព ១:២១*

«កាលពួកសាសន៍យូដា បានចេញពីសាលាប្រជុំទៅហើយ នោះពួកសាសន៍ដទៃ ក៏សូមឲ្យប៉ុលអធិប្បាយ តាមសេចក្ដីទាំងនោះ នៅថ្ងៃឈប់សម្រាកមួយក្រោយទៀត»។ ទីចុងបំផុត ពួកអ្នកប្រជុំនោះបានបែកចេញពីគ្នាទៅ «នោះមានពួកសាសន៍យូដា និងពួកចូលសាសន៍ជាច្រើន ដែលមកថ្វាយបង្គំ គេដើរតាមប៉ុល និងបាណាបាស ដែលទូន្មានឲ្យគេកាន់ខ្ជាប់ក្នុងព្រះគុណនៃព្រះ» ។

អ្នកដែលបានភ្ញាក់រឭកដោយសង្កត់ថារបស់លោកប៉ុលនៅអាន់ទីយ៉ូកនៃស្រុកភីស៊ីឌា បានមកប្រជុំគ្នាម្ដងទៀតនៅថ្ងៃសប្បាតហ៍ក្រោយ «នោះពួកអ្នកក្រុងស្ទើរតែទាំងអស់ ក៏មកប្រជុំគ្នា ដើម្បីនឹងស្ដាប់ព្រះបន្ទូល តែកាលពួកសាសន៍យូដា បានឃើញមនុស្សទាំងហ្វូងដូច្នេះ នោះកើតមានចិត្តពេញដោយសេចក្ដីច្រណែន ហើយក៏ឆ្លើយទទឹងទាស់នឹងសេចក្ដីដែលប៉ុលអធិប្បាយនោះ ទាំងជម្មុះហើយប្រមាថផង» ។

«ប៉ុន្តែ ប៉ុល និងបាណាបាសនិយាយដោយក្លាហានថា មុខគួរឲ្យយើងខ្ញុំថ្លែងប្រាប់ព្រះបន្ទូល ដល់អ្នករាល់គ្នាជាមុនដំបូង ប៉ុន្តែ ដោយព្រោះអ្នករាល់គ្នាបោះបង់ចោលព្រះបន្ទូលនោះ ហើយជំនុំជម្រះកាត់ទោសដល់ខ្លួនឯងថាមិនគួរនឹងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចនោះទេ ហេតុដូច្នេះបានជាយើងខ្ញុំបែរទៅឯពួកសាសន៍ដទៃវិញ ដ្បិតព្រះអម្ចាស់ ទ្រង់បានបង្គាប់មកយើងខ្ញុំដូច្នេះថា អញបានតាំងឯងសម្រាប់ជាពន្លឺដល់សាសន៍ដទៃ ដើម្បីឲ្យឯងបានសម្រាប់ជាសេចក្ដីសង្គ្រោះដល់ចុងផែនដីបំផុត» ។

«កាលពួកសាសន៍ដទៃបានឮ ដូច្នេះ នោះគេមានសេចក្ដីអំណរ ហើយក៏សរសើរព្រះបន្ទូលនៃព្រះអម្ចាស់ ចំណែកអស់អ្នកដែលត្រូវបានជីវិតអស់កល្បជានិច្ច នោះក៏បានជឿ» ។ ពួកគេមានអំណរយ៉ាងក្រៃលែង ដែលព្រះគ្រិស្ដបានទទួលស្គាល់ពួកគេថាជាកូនរបស់ព្រះ ហើយពួកគេបានស្ដាប់ព្រះបន្ទូលដែលពួកសាវ័កបានអធិប្បាយដោយមានចិត្តអរព្រះគុណ ។ ពួកអ្នកដែលបានជឿមានចិត្តពុះកញ្ជ្រោលក្នុងការចែកចាយសារនៃដំណឹងល្អបន្ត

ដល់អ្នកដទៃ ហើយដូច្នេះ «ព្រះបន្ទូលនៃព្រះអម្ចាស់ បានផ្សាយសុសសាយទូទៅពេញក្នុងស្រុកនោះ» ។

ស្លាបប៉ាកាដែលព្រះវិញ្ញាណបានបណ្តាល បានរៀបរាប់ពីការជួបប្រជុំគ្នានៃសាសន៍ដទៃនេះជាច្រើនសតវត្សរ៍កន្លងមកហើយ ប៉ុន្តែ បទទំនាយដែលចេញពីមាត់ហោរានេះមិនសូវមានមនុស្សយល់ឡើយ។ លោកហូសេបានមានប្រសាសន៍ថា៖ «ប៉ុន្តែ ពួកកូនចៅអ៊ីស្រាអែលនឹងមានចំនួនដូចជាខ្សាច់នៅសមុទ្រ ដែលនឹងវាល់ ឬរាប់មិនបានឡើយ រួចក្រោយមក នឹងកើតមានដូច្នេះ គឺពាក្យដែលបានពោលទុកថា ឯងរាល់គ្នាមិនមែនជារាស្ត្រអញទេ នោះនឹងផ្លាស់ទៅជាថា ឯងរាល់គ្នាជាកូននៃព្រះដ៏មានព្រះជន្មរស់នៅវិញ» ។ ហើយម្តងទៀត៖ «អញនឹងសាបព្រោះពូជនាងនៅលើផែនដីសម្រាប់អញ រួចអញនឹងអាណិតមេត្តាដល់ពួកឡូរ៉ូហាម៉ា ហើយនិងនិយាយដល់ពួកឡូអាំមីថា ឯងជារាស្ត្ររបស់អញ នោះគេនឹងឆ្លើយតបថា ទ្រង់ជាព្រះនៃយើងខ្ញុំ» (ហូសេ ១:១០ និង ២:២៣) ។

នៅក្នុងព្រះរាជកិច្ចរបស់ព្រះអង្គនៅលើផែនដី ព្រះអង្គសង្គ្រោះបានទាយទុកជាមុនអំពីការរីករាលដាលនៃដំណឹងល្អនៅក្នុងចំណោមសាសន៍ដទៃនេះ។ នៅក្នុងរឿងប្រៀបប្រដូចអំពីចម្ការទំពាំងបាយជូរ ព្រះអង្គបានមានបន្ទូលទៅកាន់សាសន៍យូដាដែលរឹងចចេសថា «នគរព្រះនឹងត្រូវហូតចេញពីអ្នករាល់គ្នា ប្រគល់ទៅឲ្យសាសន៍មួយទៀត ដែលគេនឹងបង្កើតផលរបស់នគរនោះ» (ម៉ាថាយ ២១:៤៣) ។ ហើយបន្ទាប់ពីការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ព្រះអង្គបានមានបន្ទូលទៅកាន់ពួកសិស្សរបស់ព្រះអង្គថា ចូរ «ទៅពេញសព្វក្នុងលោកិយទាំងមូល» ហើយ «ផ្សាយដំណឹងល្អទូទៅដល់គ្រប់មនុស្សទាំងអស់ចុះ» (ម៉ាថាយ ២៨:១៩ និង ម៉ាកុស ១៦:១៥) ។

<u>អង្គារ-៨ កញ្ញា </u>អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ១៤

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *មួយទៀត បងប្អូនអើយ ឯសេចក្តីណាដែលពិត សេចក្តី*

*ណាដែលគួររាប់អាន សេចក្ដីណាដែលសុចរិត សេចក្ដីណាដែលបរិសុទ្ធ សេចក្ដីណាដែលគួរស្រឡាញ់ សេចក្ដីណាដែលមានឈ្មោះល្អ បើមានសគុណណា ឬជាសេចក្ដីសរសើរណា នោះចូរពិចារណាពីសេចក្ដីទាំងនោះចុះ។ ភីលីព ៤:៨*

ដោយបែរទៅរកសាសន៍ដទៃនៅអាន់ទីយ៉ូកនៃស្រុកភីស៊ីឌា លោកប៉ុលនិងបាណាបាសមិនបានឈប់ធ្វើការដើម្បីសាសន៍យូដានៅកន្លែងដទៃៗទៀតទេ នៅកន្លែងណាដែលមានឱកាសល្អក្នុងការទទួលបានអ្នកស្ដាប់។ ចំណេរក្រោយមកទៀត លោកប៉ុលនិងគូកនរបស់លោកបានធ្វើការអធិប្បាយដំណឹងល្អ ដល់សាសន៍យូដានិងសាសន៍ដទៃនៅទីក្រុងថែស្សាឡូនីចទីក្រុងកូរិនថូសទីក្រុងអេភេសូរ និងតំបន់សំខាន់ៗដទៃផ្សេងៗទៀត។ ប៉ុន្ដែ ថាមពលចម្បងរបស់ពួកគេចាប់តាំងពីពេលនេះតទៅ គឺសំដៅទៅស្ថាបនានគរព្រះនៅក្នុងទឹកដីនៃសាសន៍ដទៃ និងនៅក្នុងចំណោមមនុស្សដែលមានចំណេះដឹងពីសេចក្ដីពិតពីព្រះ និងព្រះរាជបុត្រារបស់ទ្រង់តិចតួចឬគ្មានសោះ។

ចិត្តរបស់លោកប៉ុលនិងសហការីរបស់លោកមានភាពក្រៀមក្រំជំនួសអ្នកដែល«នៅទីទៃពីព្រះគ្រិស្ដ ក៏ឃ្លាតចេញពីអំណាចជាតិអ៊ីស្រាអែលផងជាមនុស្សដទៃខាងឯសេចក្ដីសញ្ញា ដែលទ្រង់បានសន្យាទុក ក៏ឥតមានទីសង្ឃឹម ហើយគ្មានព្រះក្នុងលោកិយនេះដែរ» ។ នៅពាសពេញទាំងកិច្ចការដែលមិនចេះនឿយហត់ដល់សាសន៍ដទៃរបស់ពួកសាវ័កនោះអ្នករាល់គ្នាដែល «ពីដើមនៅឆ្ងាយ» បានដឹងថា ពួកគេ «បានមកជិតវិញ ដោយសារព្រះលោហិតទ្រង់» ហើយថាដោយសារសេចក្ដីជំនឿទៅលើតង្វាយធួននឹងបាបរបស់ទ្រង់ ពួកគេនឹងក្លាយជា «ជាតិតែមួយនឹងពួកបរិសុទ្ធ ជាពួកដំណាក់ព្រះវិញ» (អេភេសូរ ២:១២, ១៣, ១៩) ។

ដោយមានការលូតលាស់ខាងជំនឿ លោកប៉ុលបានធ្វើការឥតឈប់ឈរ ដើម្បីស្ថាបនានគររបស់ព្រះនៅក្នុងចំណោមអ្នកដែលគ្រូបង្រៀនសាសន៍អ៊ីស្រាអែលបានបោះបង់ចោល។ លោកបានលើកតម្កើងព្រះយេស៊ូវ

ជាបន្តបន្ទាប់ ថាជា «ស្តេចលើអស់ទាំងស្តេច ហើយជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់» (ធីម៉ូថេទី១ ៦:១៥) ហើយបានជំរុញពួកអ្នកជឿឲ្យ «បានចាក់ឫស ហើយស្អាងឡើងក្នុងទ្រង់ ទាំងតាំងនៅខ្ជាប់ខ្ជួនក្នុងសេចក្តីជំនឿ» (កូឡុស ២:៧) ។

ព្រះគ្រិស្តគឺជាគ្រឹះដ៏រឹងមាំសម្រាប់អ្នកដែលជឿ។ ទាំងពួកសាសន៍យូដា និងសាសន៍ដទៃអាចកសាងជីវិតនៅលើថ្មដានេះ។ ថ្មដានេះមានទំហំធំល្មម និងរឹងមាំសម្រាប់ទ្រទ្រង់ទម្ងន់និងបន្ទុកនៃពិភពលោកទាំងមូល។ នេះគឺជារឿងពិតដែលលោកប៉ុលបានទទួលស្គាល់ដោយផ្ទាល់ ។ នៅថ្ងៃចុងក្រោយបង្អស់នៃការបម្រើរបស់លោក កាលលោកមានប្រសាន៍ទៅកាន់ពួកអ្នកជឿដែលជាសាសន៍ដទៃ ដែលនៅតែឈររឹងមាំនៅក្នុងសេចក្តីស្រឡាញ់របស់សេចក្តីពិតនៃដំណឹងល្អ លោកបានសរសេរថា «អ្នករាល់គ្នា ... ដែលបានស្អាងឡើងលើជើងជញ្ជាំងនៃពួកសាវ័ក និងពួកហោរា ហើយព្រះយេស៊ូវគ្រិស្តនោះឯង ទ្រង់ជាថ្មជ្រុងយ៉ាងឯក» (អេភេសូរ ២:១៩, ២០) ។

ខណៈដែលសារនៃដំណឹងល្អបានរីករាលដាលនៅស្រុកភីស៊ីឌា ពួកសាសន៍យូដានៅអាន់ទីយ៉ូកដែលមិនជឿបាន «ញុះញង់ពួកស្ត្រីអ្នកមុខអ្នកការ ដែលមកថ្វាយបង្គំ និងពួកអ្នកធំនៅក្នុងទីក្រុងនោះ បណ្តាលឲ្យមានសេចក្តីបៀតបៀនដល់ប៉ុល និងបាណាបាស ក៏ដេញអ្នកទាំងពីរនោះ» ចេញពីស្រុកគេទៅ ទាំងងឹតងងល់ ។

ពួកសាវ័កមិនបានបាក់ទឹកចិត្តដោយសារការគំរាមកំហែងនេះទេ ដោយនឹកចាំពីព្រះបន្ទូលនៃព្រះជាចៅហ្វាយរបស់ពួកគេ ដែលបានមានបន្ទូលថាៈ «អ្នករាល់គ្នាមានពរ ក្នុងកាលដែលគេជេរ បៀតបៀន ហើយនិយាយបង្ខុសគ្រប់ទាំងសេចក្តីអាក្រក់ ពីអ្នករាល់គ្នា ដោយព្រោះខ្ញុំ ចូរមានចិត្តអំណរ ហើយរីករាយជាខ្លាំងចុះ ដ្បិតអ្នករាល់គ្នាមានរង្វាន់ជាធំនៅឯឋានសួគ៌ ពីព្រោះគេក៏បានធ្វើទុក្ខដល់ពួកហោរាដែលនៅមុនអ្នករាល់គ្នា បែបដូច្នោះដែរ» (ម៉ាថាយ ៥:១១, ១២) ។

សារនៃដំណឹងល្អកំពុងតែរីករាលដាលឆ្ពោះទៅមុខ ហើយពួកសាវ័កមានហេតុផលគ្រប់គ្រាន់ដើម្បីនឹងមានទឹកចិត្តក្លាហាន ។ ព្រះបានប្រទានព្រះពរហូរហៀរដល់កិច្ចការរបស់ពួកគេនៅក្នុងចំណោមអ្នកស្រុកភីស៊ីឌា និងអាន់ទីយ៉ូក ហើយពួកអ្នកជឿដែលគិតថាធ្វើការតែឯងកន្លងមក «គេមានចិត្តពេញដោយសេចក្តីអំណរ ហើយនិងព្រះវិញ្ញាណបរិសុទ្ធ» ។

## ជំពូកទី ១៨

# ការអធិប្បាយនៅក្នុងចំណោមសាសន៍ដទៃ

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ១៤:១-២៦ ។*

ពុធ-៩ កញ្ញា អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ១៥

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ឥឡូវនេះ ខ្ញុំមានចិត្តអំណរក្នុងការរងទុក្ខលំបាក ដែលខ្ញុំទ្រាំដោយព្រោះអ្នករាល់គ្នា ហើយសេចក្ដីវេទនាណារបស់ព្រះគ្រីស្ទ ដែលខ្វះក្នុងរូបសាច់ខ្ញុំ នោះខ្ញុំកំពុងតែបំពេញឡើង ដោយព្រោះរូបកាយទ្រង់ គឺជាពួកជំនុំ។ កូឡុស ១:២៤*

ចេញពីអាន់ទីយ៉ូកនៃស្រុកភីស៊ីឌា លោកប៉ុលនិងលោកបាណាបាស បានធ្វើដំណើរទៅកាន់ទីក្រុងអ៊ីកូនាម។ នៅកន្លែងនេះ ពួកលោកក៏បានចាប់ផ្ដើមកិច្ចការរបស់លោកនៅក្នុងសាលាប្រជុំនៃរាស្ត្ររបស់លោកផ្ទាល់ ដូចជានៅអាន់ទីយ៉ូកដែរ។ ពួកលោកទទួលបានជោគជ័យយ៉ាងធំធេង ដ្បិត «ទាំងពួកសាសន៍យូដា និងសាសន៍ក្រិកយ៉ាងសន្ធឹកបានជឿ»។ ប៉ុន្តែ នៅទីក្រុងអ៊ីកូនាមជាកន្លែងដែលពួកសាវ័កបានធ្វើការនោះ ក៏មិនខុសពីកន្លែងផ្សេងៗទៀតដែរ «ឯពួកសាសន៍យូដាដែលមិនព្រមជឿ គេញុះញង់ ហើយចាក់រុកពួកសាសន៍ដទៃ ឲ្យគេទាស់នឹងពួកជំនុំវិញ»។

ទោះបីជាយ៉ាងនេះក៏ដោយ ក៏ពួកសាវ័កមិនបានងាកបែរចេញពីបេសកកម្មរបស់ពួកគេដែរ ព្រោះមានមនុស្សជាច្រើនកំពុងទទួលដំណឹងល្អរបស់ព្រះគ្រិស្ដ។ ពួកគេបានបន្តការងាររបស់ពួកគេទៅមុខ នៅចំពោះមុខការប្រឆាំង ការច្រណែន និងការប្រកាន់ពូជសាសន៍ ដោយ «គេអធិប្បាយយ៉ាងក្លៀវក្លាដោយនូវព្រះអម្ចាស់» ហើយព្រះ «ទ្រង់ក៏ធ្វើបន្ទាល់ អំពីព្រះបន្ទូល

នៃព្រះគុណទ្រង់ ដោយទ្រង់ប្រោសប្រទានឲ្យមានទីសម្គាល់ និងការអស្ចារ្យកើតមក ដោយសារដៃអ្នកទាំងពីរនោះ» ។ ភស្តុតាងនៃការឯកភាពពីព្រះទាំងនេះមានឥទ្ធិពលដ៏មានអំណាចទៅលើអ្នកដែលមានគំនិតបើកចំហទទួលការបំផ្លាស់បំប្រែ ហើយបានប្តូរជំនឿមកបង្កើនដំណឹងល្អវិញ។

កំណើនប្រជាប្រិយនៃសារ ដែលពួកសាវ័កបានផ្សព្វផ្សាយបានបំពេញចិត្តសាសន៍យូដាដែលមិនបានជឿដោយការច្រណែននិងសម្អប់ ហើយពួកគេបានប្តេជ្ញាចិត្តថានឹងបញ្ឈប់កិច្ចការរបស់លោកប៉ុលនិងបាណាបាសភ្លាម។ ដោយរបាយការណ៍ខុសនិងបំផ្លើស ពួកគេបានដឹកនាំរដ្ឋអំណាចឲ្យបារម្ភក្រែងទីក្រុងទាំងមូលមានគ្រោះថ្នាក់ ដោយសារតែការញុះញង់ និងការបះបោរ។ ពួកគេបានអះអាងថាមនុស្សជាច្រើនបានចូលរួមជាមួយនឹងពួកសាវ័ក ហើយពួកគេបានស្នើយោបល់ថាការនោះគឺជាការរៀបចំដ៏សម្ងាត់និងមានគ្រោះថ្នាក់។

ជាលទ្ធផលនៃការចោទប្រកាន់នេះ ពួកគេបាននាំពួកសាវ័កទៅកាន់រដ្ឋអំណាចម្តងទៀត ប៉ុន្តែ ការការពាររបស់ពួកគេច្បាស់លាស់ និងសមហេតុផលជាខ្លាំង ហើយសេចក្តីថ្លែងការណ៍អំពីអ្វីដែលពួកគេកំពុងបង្រៀនមានលក្ខណៈស្ងៀមស្ងាត់និងអាចយល់បាន ដែលធ្វើឲ្យឥទ្ធិពលយ៉ាងខ្លាំងនោះពេញចិត្តដល់ពួកអាជ្ញាធរ។  ទោះបីជាតុលាការមានការប្រកាន់ពូជសាសន៍ចំពោះអ្វីដែលពួកលោកបានថ្លែងការណ៍ក៏ដោយ ក៏ពួកគេមិនហានធ្វើអ្វីដល់ពួកសាវ័កដែរ។ ប៉ុន្តែ ពួកគេបានទទួលស្គាល់ថាការបង្រៀនរបស់លោកប៉ុលនិងបាណាបាសលម្អៀងទៅរកការធ្វើឲ្យមនុស្សមានគុណធម៌ ជាពលរដ្ឋដែលចេះគោរពច្បាប់ ហើយថាសីលធម៌និងរបៀបរៀបរយនៃទីក្រុងនឹងកាន់តែប្រសើរឡើង ប្រសិនបើប្រជារាស្ត្រនៅក្នុងទីក្រុងបានទទួលយកសេចក្តីពិតដែលពួកសាវ័កបានបង្រៀននេះ។

តាមរយៈការប្រឆាំងដែលពួកសាវ័កបានជួបប្រទះ សារនៃសេចក្តីពិតទទួលបាននូវភាពឧត្តុង្គឧត្តមជាសាធារណៈ ពួកយូដាបានឃើញថាការខំប្រឹងប្រែងដើម្បីបន្ទុចបង្អាក់ដល់កិច្ចការរបស់ពួកគ្រូបង្រៀនថ្មីនេះបានត្រឹមតែ

បន្ថែមចំនួនពួកអ្នកជឿថ្មី ឲ្យកាន់តែច្រើនឡើងប៉ុណ្ណោះ។ «ឯមនុស្សទាំងឡាយនៅទីក្រុងនោះ គេបែកបាក់គ្នា អ្នកខ្លះកាន់ខាងសាសន៍យូដា ខ្លះខាងពួកសាវ័ក»។

<u>ព្រហស្បតិ៍-១០ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ១៦

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ដូច្នេះ ដែលអ្នករាល់គ្នាបានទទួលព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់ បែបយ៉ាងណា នោះចូរដើរក្នុងទ្រង់តាមបែបយ៉ាងនោះចុះ។ កូឡុស ២:៦*

ពួកមេសាសនា នៅក្នុងចំណោមសាសន៍យូដាខឹងសម្បាជាខ្លាំង ដោយសារការក្រឡាប់ចាក់នេះ ហើយពួកគេក៏បានប្ដេជ្ញាចិត្តថានឹងបញ្ចប់សកម្មភាពនេះដោយប្រើអំពើហិង្សា ដោយបំផុសចំណង់នៃពួកអ្នកល្ងិតល្ងង់ ពួកគេមានជោគជ័យដោយបង្កើតការជ្រួលច្របល់នៅក្នុងហ្វូងមនុស្សដែលស្រែកខ្ញៀវខ្ញា ដែលពួកគេបានសន្មតថាជាការបង្រៀនរបស់ពួកសាវ័ក។ ដោយការចោទប្រកាន់ខុសនេះ ពួកគេបានសង្ឃឹមថានឹងទទួលបានជំនួយពីពួកតុលាការក្នុងការអនុវត្តន៍គោលបំណងរបស់ពួកគេ។ ពួកគេបានប្ដេជ្ញាចិត្តថាពួកសាវ័កនឹងមិនមានឱកាសដើម្បីនឹងការពារខ្លួនឲ្យរួចផុតពីទោសឡើយ ហើយថាហ្វូងមនុស្សនឹងរំខានដល់លោកប៉ុលនិងបាណាបាសដោយចោលពួកលោកនឹងថ្ម ជាក់ជាមិនខាន ធ្វើដូច្នេះនឹងបញ្ចប់កិច្ចការរបស់លោកទាំងពីរបានជាប្រាកដ។

មិត្តភក្តិរបស់ពួកសាវ័កបានព្រមានពួកសាវ័កឲ្យដឹងជាមុនពីអំពីអាក្រក់របស់សាសន៍យូដា ទោះបីជាពួកគេមិនមែនជាអ្នកជឿក៏ដោយ ហើយបានបង្ខំកុំឲ្យពួកលោកបង្ហាញខ្លួននៅចំពោះហ្វូងមនុស្សដែលកំពុងក្រេវក្រោធនេះឲ្យសោះ តែសូមឲ្យគេចខ្លួនឲ្យបានរួចជីវិតមួយគ្រាសិន។ លោកប៉ុលនិងបាណាបាសក៏បានគេចខ្លួនតាមសំណូមពរនេះ ចេញពីទីក្រុងអ៊ីកូនាមដោយសម្ងាត់ ទុកឲ្យពួកអ្នកជឿបន្តការងារដោយខ្លួនឯងមួយរយៈ។ ប៉ុន្តែ

មិនមែនមានន័យថាពួកលោកចាកចេញជារៀងរហូតនោះទេ ពួកលោកមានគោលបំណងនឹងវិលត្រឡប់មកវិញ បន្ទាប់ពីការជ្រួលច្របល់នេះបានស្ងៀមស្ងាត់ទៅវិញ ហើយនឹងបង្ហើយកិច្ចការដែលពួកលោកបានចាប់ផ្ដើមនោះ ។

នៅគ្រប់សម័យកាល និងគ្រប់ទីកន្លែង អ្នកនាំសាររបស់ព្រះត្រូវបានហៅឲ្យជួបនឹងការប្រឆាំងពីសំណាក់អ្នកដែលមានសេរីភាពជ្រើសរើសបដិសេធពន្លឺនៃឋានសួគ៌។ ជាញឹកញាប់សត្រូវនៃដំណឹងល្អហាក់ដូចជាមានជ័យជម្នះ ដោយការយល់ខុស និងពាក្យកុហក ដោយបិទទ្វារដែលអ្នកនាំសាររបស់ព្រះត្រូវចូលទៅកាន់មនុស្ស។ ប៉ុន្តែ ទ្វារទាំងនេះមិននៅតែបិទបែបនេះជារៀងរហូតនោះទេ ជាញឹកញាប់ នៅពេលដែលអ្នកបម្រើរបស់ព្រះបានវិលត្រឡប់មកវិញនៅពេលក្រោយមកទៀត ដើម្បីបង្ហើយកិច្ចការដែលពួកគេបានធ្វើនោះ ព្រះជាម្ចាស់បានធ្វើការដ៏អស្ចារ្យជំនួសពួកគេ ធ្វើឲ្យពួកគេអាចបង្កើតការនឹកចាំពីសិរីល្អនៃព្រះនាមរបស់ព្រះអង្គនៅក្នុងចិត្តមនុស្សជាច្រើន ។

ដោយត្រូវបានបណ្ដេញចេញពីទីក្រុងអ៊ីកូនាម ព្រោះការធ្វើទុក្ខបៀតបៀន ពួកសាវ័កបានធ្វើដំណើរទៅកាន់ទីក្រុងលីស្ត្រា ក្រុងឌើបេព្រមទាំងស្រុកដែលនៅជុំវិញ។ ទីក្រុងទាំងនេះមានពួកសាសន៍ដទៃរស់នៅច្រើនជាមនុស្សដែលមានជំនឿខ្ពង់ខ្ពស់ ប៉ុន្តែ ក៏មានអ្នកដែលចង់ស្ដាប់និងទទួលសារនៃដំណឹងល្អ នៅក្នុងចំណោមពួកគេនេះដែរ។ ពួកសាវ័កបានសម្រេចចិត្តធ្វើការនៅកន្លែងទាំងនេះ ដោយសង្ឃឹមថានឹងចៀសផុតពីការប្រកាន់ពូជសាសន៍និងការបៀតបៀន ពីសំណាក់សាសន៍យូដា។

នៅក្រុងលីស្ត្រាមិនមានសាលាប្រជុំរបស់សាសន៍យូដាទេ ទោះបីជាមានសាសន៍យូដាមួយចំនួនតូចរស់នៅក្នុងទីក្រុងនេះក៏ដោយ។ ពួកអ្នកស្រុកលីស្ត្រាជាច្រើនបានថ្វាយបង្គំនៅឯព្រះវិហារដែលគេបានឧទ្ទិសថ្វាយដល់ព្រះយេស្ទូស។ កាលលោកប៉ុលនិងបាណាបាសបានមកដល់ទីក្រុង លោក

បានប្រមូលអ្នកក្រុងលីស្ត្រាមកជុំវិញលោក ហើយបានពន្យល់អំពីសេចក្តីពិតនៃដំណឹងល្អងាយៗ ពួកគេជាច្រើនបានភ្ជាប់គោលលទ្ធិនេះទៅនឹងជំនឿសាសនារបស់ពួកគេ ក្នុងការថ្វាយបង្គំដល់ព្រះយេស៊ូវ។

**<u>សុក្រ-១១ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ១៧**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ឯអស់ទាំងសេចក្តីដែលអ្នកបានឮអំពីខ្ញុំ នៅមុខស្មរបន្ទាល់ជាច្រើន នោះក៏ត្រូវផ្ញើទុកនឹងមនុស្សស្មោះត្រង់ ដែលអាចនឹងបង្រៀនតទៅអ្នកឯទៀតដែរ ដូច្នេះ ចូរឲ្យអ្នកទ្រាំទ្រទុក្ខលំបាក ដូចជាទាហានយ៉ាងល្អរបស់ព្រះយេស៊ូវគ្រីស្ទចុះ។ ធីម៉ូថេទី២ ២:២-៣*

ពួកសាវ័កបានព្យាយាមចែកចាយជាមួយពួកគេនូវចំណេះដឹងនៃព្រះអាទិករ និងព្រះរាជបុត្ររបស់ទ្រង់ ដែលជាព្រះអង្គសង្គ្រោះនៃមនុស្សលោក។ ដំបូង ពួកសាវ័កបានទាញអារម្មណ៍របស់អ្នកស្តាប់ទៅកាន់កិច្ចការដ៏អស្ចារ្យរបស់ព្រះ មានព្រះអាទិត្យ ព្រះចន្ទ និងផ្កាយ លំដាប់លំដោយដ៏ល្អអស្ចារ្យនៃរង្វិលរបស់រដូវ គម្របភ្នំទឹកកកដ៏អស្ចារ្យ ដើមឈើខ្ពស់ស្កឹមស្កៃ និងសម្រស់ធម្មជាតិដទៃផ្សេងៗទៀត ដែលបង្ហាញពីជំនាញដែលគំនិតមនុស្សមិនអាចយល់បាន ។ ពួកសាវ័កបានដឹកនាំគំនិតប្រជាជាតិនានាឲ្យត្រិះរិះពិចារណា អំពីព្រះដែលជាអ្នកដឹកនាំដ៏ធំនៅលើចក្រវាល។

ដោយបានបញ្ជាក់យ៉ាងច្បាស់អំពីសេចក្តីពិតដែលជាគ្រឹះទាក់ទងនឹងព្រះអាទិករនេះ ពួកសាវ័កបានប្រាប់ពួកអ្នកក្រុងលីស្ត្រាអំពីព្រះរាជបុត្រារបស់ព្រះ ដែលបានយាងចុះពីឋានសួគ៌មកកាន់ពិភពលោកយើង ពីព្រោះព្រះអង្គបានស្រឡាញ់កូនៗរបស់មនុស្ស។ ពួកគេបាននិយាយអំពីព្រះជន្ម និងព្រះរាជកិច្ចរបស់ព្រះអង្គ ការបដិសេធន៍ទ្រង់ ពីសំណាក់មនុស្សដែលព្រះអង្គបានយាងមកជួយសង្គ្រោះ ការកាត់ទោស និងការជាប់ឆ្កាងរបស់ទ្រង់ ការមានព្រះជន្មរស់ឡើងវិញ និងការយាងឡើងទៅកាន់ឋានសួគ៌របស់ព្រះអង្គ ហើយនៅទីនោះ ព្រះអង្គកំពុងបំពេញព្រះរាជតួនាទីជាមេធាវីរបស់

មនុស្ស។ ហេតុដូច្នេះ លោកប៉ុលនិងបាណាបាសបានអធិប្បាយអំពីដំណឹងល្អនៅទីក្រុងលីស្ត្រា ។

មានពេលមួយ កាលលោកប៉ុលកំពុងនិយាយប្រាប់ដល់ពួកបណ្តាជនអំពីព្រះរាជកិច្ចរបស់ព្រះគ្រិស្ត ជាអ្នកព្យាបាលអ្នកឈឺ និងអ្នកដែលត្រូវគេមើលងាយ លោកបានឃើញជនពិការម្នាក់នៅក្នុងចំណោមហ្វូងមនុស្សដែលបានសម្លឹងមើលមុខលោក និងជាអ្នកដែលបានទទួលនិងជឿដំណឹងល្អ។ ចិត្តរបស់លោកប៉ុលបានចេញទៅដោយសេចក្តីអាណិតអាសូរចំពោះបុរសដែលពិការរូបនេះ ជាមនុស្សម្នាក់ដែលលោកបានចាត់ទុកថា «គាត់មានសេចក្តីជំនឿល្មម ដើម្បីឲ្យបានជា» ។ នៅចំពោះវត្តមាននៃពួកអ្នកថ្វាយបង្គំរូបព្រះ លោកប៉ុលបានបង្គាប់ដល់ជនពិការនោះឲ្យក្រោកឈរឡើង ហើយដើរដោយជើងរបស់គាត់ទាំងពីរ។ កន្លងមក ជនពិការដ៏ឈឺចាប់នេះអាចត្រឹមតែអង្គុយប៉ុណ្ណោះ ប៉ុន្តែ ឥឡូវនេះ គាត់បានស្តាប់តាមការបង្គាប់របស់លោកប៉ុលភ្លាម ហើយពេលនោះគឺជាឱកាសលើកទីមួយក្នុងជីវិតរបស់គាត់ ដែលគាត់អាចក្រោកឈរបាន។ កម្លាំងបានកើតឡើងជាមួយនឹងការខំប្រឹងប្រែងដោយក្តីជំនឿ ហើយមនុស្សដែលធ្លាប់តែពិការនេះ «ក៏ស្ទុះឡើងដើរ» ។

«កាលហ្វូងមនុស្សបានឃើញការដែលប៉ុលធ្វើ នោះគេបន្លឺឡើងជាភាសាលូកៅនាថា ពួកព្រះបានកាឡានិម្មិតជាមនុស្ស ចុះមកឯយើងហើយ គេក៏ហៅបាណាបាស ជាព្រះសេយូស ហើយប៉ុល ជាព្រះហើមេស ពីព្រោះគាត់ជាមេសម្តែង ហើយសង្ឃរបស់ព្រះសេយូស ដែលនៅមុខក្រុងគេក៏នាំយកគោឈ្មោល ហើយនិងភួងទៅដល់ក្លោងទ្វារក្រុង ចង់ថ្វាយយញ្ញបូជាជាមួយនឹងបណ្តាមនុស្ស»។ ប្រយោគនេះស្របទៅតាមប្រពៃណីរបស់ពួកគេដែលថាយូរៗម្តងព្រះបានយាងមកកាន់ផែនដីដោយផ្ទាល់។ ពួកគេបានហៅបាណាបាសថាព្រះយេសួស ដែលមានន័យថាបិតានៃព្រះទាំងឡាយ ដោយព្រោះតែលក្ខណៈដ៏គួរឲ្យគោរពរបស់លោក អាកប្បកិរិយាដ៏ថ្លៃថ្នូរ និងបទ

ពិសោធន៍ដ៏ឱនលំទោន និងមានសេចក្តីមេត្តា នៅលើទឹកមុខរបស់លោក ចំណែកលោកប៉ុលវិញ ពួកគេបានជឿថាលោកជាព្រះ ហើមេស «ពីព្រោះគាត់គឺជាមេសម្តែង» ដ៏ស្មោះត្រង់ សកម្ម និងមានវោហារជាមួយនឹងពាក្យព្រមាននិងការទូន្មានក្រើនរំឭក ។

ពួកអ្នកក្រុងលីស្ត្រាអន្ទះសាចង់បង្ហាញភាពកត្តញ្ញូរបស់ពួកគេ បានបញ្ចុះបញ្ចូលសង្ឃនៃព្រះយេស៊ូសឲ្យផ្តល់កិត្តិយសដល់ពួកសាវ័ក ហើយគេ «ក៏នាំយកគោឈ្មោល ហើយនិងភួងទៅដល់ក្លោងទ្វារក្រុង ចង់ថ្វាយយញ្ញបូជាជាមួយនឹងបណ្តាមនុស្ស» ។ លោកប៉ុលនិងបាណាបាសដែលកំពុងតែរកកន្លែងសម្រាកនោះមិនបានដឹងពីការរៀបចំនេះទេ។ ទោះជាយ៉ាងនេះក៏ដោយមិនយូរប៉ុន្មាន ពួកលោកមានការចាប់អារម្មណ៍ទៅលើសំឡេងដូរតន្ត្រីនិងសម្រែកអបអរសាទរនៃហ្វូងមនុស្សយ៉ាងធំ ដែលកំពុងតែធ្វើដំណើរសំដៅមកផ្ទះដែលពួកលោកកំពុងតែស្នាក់នៅ។

**<u>សៅរ៍-១២ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ១៨**

**ខព្រះគម្ពីរប្រចាំសប្តាហ៍:** *អ្នករាល់គ្នាអើយ ហេតុអ្វីបានជាធ្វើដូច្នេះ យើងខ្ញុំជាមនុស្សវិស័យដូចជាអ្នករាល់គ្នាដែរ មួយទៀត យើងក៏ប្រកាសប្រាប់ដំណឹងល្អដល់អ្នករាល់គ្នា ឲ្យបានបែរចេញពីអស់ទាំងការ ដែលឥតប្រយោជន៍យ៉ាងនេះ ទៅឯព្រះដ៏មានព្រះជន្មរស់វិញ ដែលទ្រង់បង្កើតផ្ទៃមេឃ ផែនដី សមុទ្រ និងរបស់ទាំងអស់ដែលនៅស្ថានទាំងនោះផង។ កិច្ចការ ១៤:១៥*

កាលពួកសាវ័កបានដឹងប្រាកដអំពីមូលហេតុនៃការចូលមកជួបរបស់ពួកគេ និងការចូលរួមយ៉ាងរំភើបនៅក្នុងដំណើរនេះ «នោះក៏ហែកអាវខ្លួនរត់ចូលទៅកណ្តាលហ្វូងមនុស្ស» ដោយសង្ឃឹមថានឹងអាចទប់ស្កាត់ដំណើរនេះកុំឲ្យបន្តទៅមុខទៀត» ។ លោកប៉ុលបានស្រែកបង្គាប់ឲ្យពួកហ្វូងមនុស្សប្រុងស្តាប់ដោយសំឡេងឮក្រលួច ខ្លាំងជាងសំឡេងរបស់ហ្វូងមនុស្ស ហើយ

ខណៈហ្វូងមនុស្សដែលកំពុងតែមានសំឡេងអ៊ូអរបានឈប់ភ្លាម លោកបានមានប្រសាសន៍ថា «អ្នករាល់គ្នាអើយ ហេតុអ្វីបានជាធ្វើដូច្នេះ យើងខ្ញុំជាមនុស្សវិស័យដូចជាអ្នករាល់គ្នាដែរ មួយទៀត យើងក៏ប្រកាសប្រាប់ដំណឹងល្អដល់អ្នករាល់គ្នា ឲ្យបានបែរចេញពីអស់ទាំងការដែលឥតប្រយោជន៍យ៉ាងនេះ ទៅឯព្រះដ៏មានព្រះជន្មរស់វិញ ដែលទ្រង់បង្កើតផ្ទៃមេឃ ផែនដី សមុទ្រ និងរបស់ទាំងអស់ដែលនៅឋានទាំងនោះផង ក្នុងកាលជំនាន់មនុស្សពីបុរាណនោះទ្រង់បានអនុញ្ញាតឲ្យគ្រប់ទាំងសាសន៍ ដើរតាមផ្លូវរបស់គេរៀងខ្លួន ប៉ុន្តែ ទ្រង់មិនដែលលែងមានទីបន្ទាល់ ពីព្រះអង្គទ្រង់ទេ ដោយទ្រង់តែងតែផ្សាយព្រះគុណមក គឺទ្រង់ប្រោសប្រទានឲ្យភ្លៀងធ្លាក់ចុះពីលើមេឃ ឲ្យមានរដូវដ៏សំបូរ ដើម្បីនឹងបំពេញចិត្តយើង ដោយអាហារ និងសេចក្តីអំណរ» ។

ទោះបីជាការប្រកែកដ៏សមហេតុផលរបស់ពួកសាវ័កថាពួកគេមិនមែនជាព្រះ ហើយទោះបីជាលោកប៉ុលបានព្យាយាមទាញគំនិតរបស់ពួកបណ្តាជនទៅឯព្រះដ៏ពិតតែមួយអង្គគត់ដែលគួរទទួលការសរសើតម្កើងពីមនុស្សក៏ដោយ ក៏លោកសឹងតែមិនអាចបង្វែងសាសន៍ដទៃនេះឲ្យឈប់ថ្វាយតង្វាយយញ្ញបូជាដល់ពួកលោកបានដែរ។ ពួកគេមានជំនឿជឿជាក់ថាបុរសទាំងពីរនាក់នេះពិតជាព្រះរបស់គេ ហើយពួកគេមានអំណរជាខ្លាំងដែលពួកសាវ័កមិនបានទទួលយកចំណេះដឹងខុសឆ្គងរបស់ពួកគេ។ ព្រះគម្ពីរបានចែងថាពួកលោក «ឃាត់គេមិនឲ្យថ្វាយយញ្ញបូជាសឹងតែមិនបាន» ។

ពួកអ្នកក្រុងលីស្ត្រាបានពិចារណាថាពួកគេបានមើលឃើញអំណាចដ៏អស្ចារ្យដែលពួកសាវ័កបានសម្តែង ដោយផ្ទាល់នឹងភ្នែក។ ពួកគេបានឃើញជនពិការដែលមិនធ្លាប់អាចដើរបានមានអំណរនៅក្នុងសុខភាពនិងកម្លាំងមាំមួន។ គឺបន្ទាប់ពីការបញ្ចុះបញ្ចូលយ៉ាងជាក់លាក់របស់លោកប៉ុល និងការពន្យល់យ៉ាងប្រុងប្រយ័ត្នទាក់ទងនឹងបេសកកម្មរបស់លោកផ្ទាល់និងបាណាបាស ដែលជាតំណាងរបស់ព្រះនៃឋានសួគ៌ និងព្រះរាជបុត្រានៃទ្រង់

ជាព្រះនៃការប្រោសឲ្យជា (ការព្យាបាល) ដ៏ឧត្តម មកទើបហ្វូងមនុស្សព្រមលះបង់គោលបំណងរបស់ពួកគេ។

កិច្ចការរបស់លោកប៉ុល និងបាណាបាសនៅលីស្ត្រាស្រាប់តែត្រូវបានបញ្ឈប់ភ្លាមដោយការព្យាបាទរបស់ «ពួកសាសន៍យូដាខ្លះ មកពីអាន់ទីយ៉ូក និងអ៊ីកូនាម» ដែលបានដឹងពីជោគជ័យនៃកិច្ចការរបស់ពួកសាវ័កនៅក្នុងចំណោមពួកអ្នកក្រុងលីស្ត្រា ហើយបានប្ដេជ្ញាចិត្តតាមដាននិងបៀតបៀនដល់ពួកលោក។ កាលមកដល់ទីក្រុងលីស្ត្រា ពួកយូដាទាំងនោះ បានបំផុសនូវភាពល្ងឹងងូរចត់ដល់ពួកបណ្ដាជន ដែលមាននៅក្នុងគំនិតរបស់ពួកគេ។ ដោយពាក្យពេចន៍នៃការបកស្រាយខុសនិងមូលបង្កាច់ ពួកបណ្ដាជនដែលថ្មីៗនេះបានគោរពលោកប៉ុលនិងបាណាបាសថាជាព្រះ ឥឡូវនេះ ត្រូវបានអូសទាញឲ្យយល់ថាការពិតពួកសាវ័កអាក្រក់ជាងឃាតករទៅទៀត ហើយពួកនេះគួរតែស្លាប់ទៅវិញ ។

<u>អាទិត្យ-១៣ កញ្ញា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ១៩**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ព្រះយេហូវ៉ាទ្រង់ជាពន្លឺ ហើយជាសេចក្ដី សង្គ្រោះរបស់ខ្ញុំ តើខ្ញុំនឹងត្រូវខ្លាចចំពោះអ្នកណា ព្រះយេហូវ៉ាទ្រង់ជាទីពឹងពំនាក់នៃជីវិតខ្ញុំ តើត្រូវឲ្យខ្ញុំភ័យចំពោះអ្នកណា។ ទំនុកតម្កើង ២៧:១*

ការខកចិត្តដែលបណ្ដាជននៅលីស្ត្រាបានទទួលរងដោយការបដិសេធន៍មិនឲ្យថ្វាយតង្វាយយញ្ញបូជាដល់ពួកសាវ័ក បានរៀបចំពួកគេឲ្យបែរមកប្រឆាំងនឹងលោកប៉ុលនិងបាណាបាស ដោយដំណោះស្រាយយ៉ាងរីករាយដូចកាលដែលពួកគេគោរពពួកលោកថាជាព្រះដូច្នោះដែរ។ ដោយការញុះញង់ពីពួកយូដា ពួកគេបានរៀបចំប្រយុទ្ធជាមួយនឹងពួកសាវ័កដោយកម្លាំង។ ពួកយូដាបានប្រាប់ពួកគេកុំឲ្យលោកប៉ុលមានឱកាសនឹងនិយាយដោយបានអះអាងថា ប្រសិនបើពួកគេផ្ដល់ឱកាសឲ្យពួកសាវ័កនិយាយ លោកនឹងធ្វើឲ្យពួកបណ្ដាជនត្រេកត្រអាលជាក់ជាមិនខាន។

មិនយូរប៉ុន្មាន ការរៀបចំធ្វើឃាតនៃសត្រូវរបស់ដំណឹងល្អត្រូវបាន អនុវត្ត។ ដោយទោរទន់ទៅតាមឥទ្ធិពលរបស់អារក្ស ពួកអ្នកក្រុងលីស្ត្រា បានត្រូវសេចក្តីក្រេវក្រោធរបស់សាតាំងគ្រប់គ្រង ហើយបានព័ទ្ធជុំវិញ លោកប៉ុល រួចចោលលោកនឹងថ្មដោយគ្មានមេត្តា។ សាវ័កប៉ុលបានគិតថា ទីបញ្ចប់របស់លោកបានមកដល់ហើយ។ ទុក្ករកម្មរបស់លោកស្ទេផាននិង ចំណែកដ៏ឃោរឃៅរទៅលើរូបលោកផ្ទាល់ ដែលបានបញ្ចេញសកម្មភាព នៅពេលនោះ បានកើតឡើងយ៉ាងរហ័សនៅក្នុងគំនិតរបស់លោក។ គ្រប ដណ្តប់ដោយស្នាមជាំនិងការឈឺចុកចាប់ លោកបានដួលទៅនឹងដី ហើយ ហ្វូងមនុស្សដ៏ក្រេវក្រោធ «គេអូសគាត់ចេញទៅក្រៅ (ទីក្រុង) ទុកចោល ដោយស្មានថា បានស្លាប់ហើយ» ។

នៅក្នុងពេលដ៏ខ្មៅងងឹតនិងតានតឹងនេះ ក្រុមនៃពួកអ្នកជឿនៅក្រុង លីស្ត្រា ដែលបានកែប្រែចិត្តមកមានជំនឿលើព្រះយេស៊ូវដោយសារកិច្ចការ របស់លោកប៉ុលនិងបាណាបាស នៅតែមានភក្តីភាពនិងស្មោះត្រង់ដដែល។ ការប្រឆាំងដែលគ្មានហេតុផល និងការធ្វើទុក្ខបៀតបៀនយ៉ាងឃោរឃៅ ដោយពួកសត្រូវនេះ បានត្រឹមតែបញ្ជាក់ឲ្យឃើញកាន់តែច្បាស់ពីជំនឿ របស់បងប្អូនរួមជំនឿទាំងនេះប៉ុណ្ណោះ ហើយឥឡូវនេះ នៅចំពោះមុខគ្រោះ ថ្នាក់និងការប្រមាថមើលងាយ ពួកគេបានបង្ហាញភក្តីភាពរបស់ពួកគេដោយ ការប្រមូលផ្តុំគ្នានៅជុំវិញរាងកាយរបស់លោកប៉ុល ដែលពួកគេបានជឿថា លោកបានស្លាប់ទៅហើយនេះ។

នេះគឺជាការភ្ញាក់ផ្អើលជាខ្លាំងចំពោះពួកគេ ដោយនៅកណ្តាលទុក្ខ សោករបស់ពួកគេ ស្រាប់តែសាវ័កប៉ុលបានងើបក្បាល ហើយក្រោកឈរ ឡើង ដោយការសរសើរតម្កើងដល់ព្រះនៅនឹងបបូរមាត់។ ចំពោះពួកអ្នកជឿ ការស្តារឡើងវិញដែលមិនបានរំពឹងទុកនូវកិច្ចការនៃពួកសាវ័ករបស់ព្រះនេះ ត្រូវបានគេចាត់ទុកថាជាការអស្ចារ្យនៃអំណាចរបស់ព្រះ ហើយហាក់ដូចជា ការបោះត្រារបស់ព្រះនៃឋានសួគ៌ នៅលើការផ្លាស់ប្តូរជំនឿរបស់ពួកគេ ។

ពួកគេមានអំណររកថ្លែងពុំបាន ហើយបានសរសើរតម្កើងដល់ព្រះដោយជំនឿរបស់ពួកគេ ដែលបានធ្វើឲ្យថ្មីឡើងវិញនេះ ។

នៅក្នុងចំណោមពួកអ្នកដែលបានផ្លាស់ប្តូរជំនឿនៅទីក្រុងលីស្ត្រា និងជាអ្នកដែលបានឃើញការឈឺចាប់របស់លោកប៉ុលផ្ទាល់នឹងភ្នែក ជាអ្នកដែលក្រោយមកបានក្លាយជាអ្នកបម្រើការរបស់ព្រះគ្រិស្តដែលលេចធ្លោជាងគេ និងជាអ្នកដែលបានចែករំលែកជាមួយពួកសាវ័កនូវការពិបាកនិងក្តីអំណារនៃកិច្ចការជាអ្នកត្រួសត្រាយ នៅតាមតំបន់ដែលពិបាកៗ។ អ្នកនោះឯងគឺយុវជនដែលមានឈ្មោះថាធីម៉ូថេ។ កាលគេបានអូសលោកប៉ុលចេញពីទីក្រុងសាវ័កដ៏ក្មេងខ្ចីនេះក៏នៅក្នុងចំណោមហ្វូងមនុស្សដែលបានឈរនៅក្បែររាងកាយស្តូកស្តឹង ដូចគ្មានដង្ហើមរបស់លោកប៉ុល ហើយបានឃើញលោកក្រោកឡើងទាំងមានស្នាមជាំដោយឈាម ប៉ុន្តែ បបូរមាត់លោកនៅតែសរសើរតម្កើងដល់ព្រះ ព្រោះព្រះអង្គបានអនុញ្ញាតឲ្យលោកឈឺចាប់ដើម្បីជាប្រយោជន៍ដល់ព្រះគ្រិស្ត ។

**<u>ច័ន្ទ-១៤ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ២០**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ដ្បិតព្រះទ្រង់មិនបានប្រទានឲ្យយើងមានវិញ្ញាណ ដែលតែងតែខ្លាចឡើយ គឺឲ្យមានវិញ្ញាណដ៏មានអំណាច សេចក្តីស្រឡាញ់ និងប្រាជ្ញានឹងធឹងវិញ។ ធីម៉ូថេទី២ ១:៧*

នៅថ្ងៃបន្ទាប់ពីការចោលលោកប៉ុលនឹងថ្មមក ពួកសាវ័កបានចេញដំណើរទៅកាន់ទីក្រុងឌើបេ ជាកន្លែងដែលព្រះបានប្រទានពរដល់កិច្ចការរបស់ពួកគេ ហើយពួកគេបានដឹកនាំមនុស្សជាច្រើនឲ្យទទួលព្រះគ្រិស្តជាព្រះអង្គសង្គ្រោះ ។ ប៉ុន្តែ «ក្រោយដែលប្រកាសប្រាប់ដំណឹងល្អ ហើយបានសិស្សជាច្រើននៅក្រុងនោះ» ទាំងលោកប៉ុលនិងទាំងលោកបាណាបាសមានបំណងទៅបំពេញកិច្ចការនៅកន្លែងផ្សេងទៀត ដោយមិនបានបញ្ជាក់អះអាងពីជំនឿរបស់ពួកអ្នកដែលបានកែប្រែចិត្ត ដែលពួកលោកបានបង្គាប់

ឲ្យនៅតែឯងមួយរយៈ នៅនឹងកន្លែងដែលលោកបានធ្វើការកាលពីពេលថ្មីៗនេះឡើយ ។ ដូច្នេះ ដោយមិនតក់ស្លុតដោយសារគ្រោះថ្នាក់នោះ ពួកគេ «ក៏ត្រឡប់ទៅឯលីស្ត្រា អ៊ីកូនាម និងអាន់ទីយ៉ូកវិញ ព្រមទាំងចម្រើនកម្លាំងដល់ពួកសិស្ស ឲ្យមានចិត្តរឹងប៉ឹងឡើង ហើយទូន្មានឲ្យនៅឋិតថេរក្នុងសេចក្ដីជំនឿ» ។ មនុស្សជាច្រើនបានទទួលសេចក្ដីស្រឡាញ់នៃដំណឹងល្អ ហើយបានរងទ្រាំនូវការស្តីបន្ទោសនិងការធ្វើទុក្ខបៀតបៀន។ ពួកអ្នកទាំងនេះហើយដែលពួកសាវ័កបានស្វះស្វែងស្ថាបនាសេចក្ដីជំនឿ ដើម្បីឲ្យកិច្ចការដែលត្រូវធ្វើអាចនឹងប្រតិបត្តិទៅបាន។

ជាកត្តាសំខាន់នៅក្នុងការរីកលូតលាស់ខាងព្រលឹងវិញ្ញាណរបស់ពួកអ្នកជឿថ្មីៗ ពួកសាវ័កបានព័ទ្ធជុំវិញពួកគេដោយប្រុងប្រយ័ត្ន ដោយការការពាររបៀបរៀបរយនៃដំណឹងល្អ។ ពួកគេបានរៀបចំពួកជំនុំយ៉ាងត្រឹមត្រូវគ្រប់ទីកន្លែង នៅលីកូនា និងភីស៊ីឌា ជាកន្លែងដែលមានពួកអ្នកជឿ។ មន្ត្រីនិងពួកចាស់ទុំត្រូវបានតាំងឡើងនៅតាមពួកជំនុំនីមួយៗ ហើយពួកគេបានបង្កើតប្រព័ន្ធនិងរបៀបរៀបរយដើម្បីណែនាំដល់កិច្ចការទាំងឡាយ ដែលជាប់ទាក់ទងទៅនឹងសុខុមាលភាពខាងព្រលឹងវិញ្ញាណរបស់ពួកអ្នកជឿ។

ការនេះស្របទៅតាមផែនការនៃដំណឹងល្អ ក្នុងការបង្រួបបង្រួមពួកជំនុំទាំងអស់ឲ្យក្លាយជាតែមួយនៅក្នុងរាងកាយរបស់ព្រះគ្រិស្ត ហើយលោកប៉ុលបានអនុវត្តផែនការនេះយ៉ាងប្រុងប្រយ័ត្ន នៅក្នុងកិច្ចការរបស់លោក។ មនុស្សទាំងឡាយនៅតាមកន្លែងដែលលោកបានធ្វើការដើម្បីដឹកនាំមនុស្សឲ្យទទួលព្រះគ្រិស្តជាព្រះអង្គសង្គ្រោះ លោកបានរៀបចំជាពួកជំនុំទៅតាមពេលវេលាដ៏សមស្រប ។ ទោះបីជាពួកអ្នកជឿមានចំនួនតិចក៏ដោយក៏លោកបានធ្វើកិច្ចការនេះដែរ។ ដូច្នេះ ពួកគ្រិស្តបរិស័ទត្រូវបានបង្រៀនឲ្យចេះជួយគ្នាទៅវិញទៅមក និងឲ្យនឹកចាំពីសេចក្ដីសន្យាថា «ដ្បិតកន្លែងណាដែលមានពីរឬបីនាក់ ប្រជុំជាមួយគ្នា ដោយនូវឈ្មោះខ្ញុំ នោះខ្ញុំក៏នៅកណ្ដាលចំណោមអ្នកទាំងនោះដែរ» (ម៉ាថាយ ១៨:២០)។

ហើយលោកប៉ុលមិនដែលភ្លេចពួកជំនុំដែលបានរៀបចំដូច្នេះឡើយ។ ការថែរក្សាពួកជំនុំទាំងនេះនៅក្នុងគំនិតរបស់លោក ជាបន្ទុកដែលចេះតែកើនឡើងជានិច្ច ។ ទោះបីជាក្រុមតូចយ៉ាងណាក៏ដោយក៏ជាកង្វល់ឥតឈប់ឈររបស់លោកដែរ។ លោកបានថែរក្សាពួកជំនុំតូចៗយ៉ាងទន់ភ្លន់ដោយដឹងថា ពួកគេត្រូវការថែរក្សាជាពិសេស ដើម្បីឲ្យសមាជិកត្រូវបានស្ថាបនាឡើងយ៉ាងម៉ត់ចត់នៅក្នុងសេចក្ដីពិត និងត្រូវបានបង្រៀនឲ្យមានភាពស្មោះត្រង់ ការខិតខំប្រឹងប្រែងដោយមិនអាត្មានិយម ដើម្បីបម្រើដល់អ្នកដែលនៅជុំវិញពួកគេ ។

នៅក្នុងការខំប្រឹងប្រែងបំពេញភារកិច្ចរបស់ពួកគេ លោកប៉ុលនិងបាណាបាសបានធ្វើតាមគំរូនៃការលះបង់និងស្មោះត្រង់របស់ព្រះយេស៊ូវ ដោយធ្វើការសម្រាប់មនុស្សដោយស្មោះត្រង់។ ដោយការភ្ញាក់រឭកយ៉ាងទូលំទូលាយ ទឹកចិត្តពុះកញ្ជ្រោល មិនប្រែប្រួល ពួកលោកមិនបានស្វែងរកភាពស្រណុកសុខស្រួលសម្រាប់ខ្លួនឯងឡើយ ប៉ុន្តែ ពួកគេបានសាបព្រោះគ្រាប់ពូជនៃសេចក្ដីពិតដោយការអធិដ្ឋានទាំងថប់បារម្ភ និងមានសកម្មភាពឥតឈប់ឈរ ។ ហើយជាមួយនឹងការសាបព្រោះគ្រាប់ពូជនៃសេចក្ដីពិតនេះ ពួកសាវ័កបានបង្រៀនមេរៀនដ៏មានតម្លៃរកថ្លៃងមិនបាន យ៉ាងប្រុងប្រយ័ត្នដល់អ្នកដែលបានឈរនៅខាងដំណឹងល្អ ។ វិញ្ញាណនៃភាពស្មោះត្រង់និងការកោតខ្លាចព្រះ បានកើតឡើងនៅក្នុងគំនិតរបស់ពួកសាវ័កថ្មីៗជាស្នាមដិតដាមដែលមិនចេះរលុបទាក់ទងនឹងសារៈសំខាន់អំពីសារនៃដំណឹងល្អ ។

កាលណាមានមនុស្សនៃសេចក្ដីសន្យានិងមានសមត្ថភាពបានកែប្រែចិត្តដូចជាករណីលោកធីម៉ូថេ លោកប៉ុល និងបាណាបាសបានធ្វើការយ៉ាងស្មោះស្ម័គ្រ ដើម្បីបង្ហាញដល់ពួកគេអំពីភាពចាំបាច់នៃការធ្វើការនៅក្នុងចម្ការទំពាំងបាយជូរ។ ហើយនៅពេលដែលពួកសាវ័កបានចាកចេញទៅកាន់កន្លែងផ្សេងទៀត ជំនឿរបស់បុរសទាំងនេះមិនបានធ្លាក់ចុះឡើយ ប៉ុន្តែ កាន់តែ

កើនឡើងទៅវិញ។ ពួកគេបានទទួលការបង្រៀនយ៉ាងស្មោះត្រង់ អំពីផ្លូវរបស់ព្រះជាម្ចាស់ និងអំពីការធ្វើការដោយមិនអាត្មានិយម ដោយស្មោះត្រង់ និងតស៊ូស្វិតស្វាញ ដើម្បីសេចក្តីសង្គ្រោះដល់មនុស្សដូចគ្នា។ ការបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ដល់អ្នកមានជំនឿថ្មីនេះ គឺជាកត្តាដ៏សំខាន់នៅក្នុងជោគជ័យដ៏ត្រចះត្រចង់ ដែលលោកប៉ុលនិងបាណាបាសមានខណៈដែលលោកអធិប្បាយអំពីដំណឹងល្អនៅក្នុងទឹកដីនៃសាសន៍នានា។

ដំណើរបេសកជនលើកទីមួយនេះបានឈានដល់ទីបញ្ចប់យ៉ាងឆាប់រហ័ស។ ការលើកតម្កើងពួកជំនុំថ្មីៗថ្វាយដល់ព្រះជាម្ចាស់ សាវ័កប៉ុលបានចេញដំណើរទៅកាន់ស្រុកប៉ាមភីលា «ក្រោយដែលអធិប្បាយតាមព្រះបន្ទូលនៅក្រុងពើការួចហើយ នោះក៏ចុះទៅឯអាតាលា ក៏ចុះសំពៅពីទីនោះត្រឡប់ទៅឯអាន់ទីយ៉ូកវិញ» ។

# ជំពូកទី ១៩

# សាសន៍យូដានិងសាសន៍ដទៃ

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ១៥:១-៣៥ ។*

<u>អង្គារ-១៥ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ២១

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *លុះដល់ហើយ ក៏ប្រមូលពួកជំនុំមក ថ្លែងប្រាប់ពីការដែលព្រះបានធ្វើដោយសារខ្លួន ហើយពីទ្រង់បានបើកទ្វារនៃសេចក្តីជំនឿដល់សាសន៍ដទៃដែរ។ កិច្ចការ ១៤:២៧*

នៅក្នុងការមកដល់ទីក្រុងអាន់ទីយ៉ូក នៅស្រុកសេរី ត្រឡប់មកពីកន្លែងដែលព្រះបានចាត់ឲ្យទៅបំពេញបេសកកម្មមក លោកប៉ុលនិងបាណាបាសបានឆក់យកឱកាសដំបូងនេះដើម្បីប្រជុំពួកអ្នកជឿ ហើយថ្លែងប្រាប់ «ពីការដែលព្រះបានធ្វើដោយសារខ្លួន ហើយពីទ្រង់បានបើកទ្វារនៃសេចក្តីជំនឿដល់សាសន៍ដទៃដែរ» (កិច្ចការ ១៤:២៧)។ ពួកជំនុំនៅក្រុងអាន់ទីយ៉ូកគឺជាពួកជំនុំដែលធំហើយមានការលូតលាស់មួយ។ ជាមជ្ឈមណ្ឌលនៃសកម្មភាពរបស់បេសកជន ទីក្រុងនេះជាកន្លែងដ៏សំខាន់បំផុតនៃក្រុមគ្រិស្តបរិស័ទ។ សមាជិកនៃពួកជំនុំនេះកើតឡើងដោយមនុស្សជាច្រើនស្រទាប់វណ្ណៈ នៅក្នុងចំណោមពួកសាសន៍យូដានិងសាសន៍ដទៃ។

កាលពួកសាវ័កបានរួបរួមគ្នាជាមួយនឹងពួកគ្រូគង្វាលនិងសមាជិកពួកជំនុំ នៅអាន់ទីយ៉ូក នៅក្នុងការខំប្រឹងប្រែង មនុស្សជាច្រើនមកឯព្រះគ្រិស្ត ពួកសាសន៍យូដាដែលជឿជាច្រើនមកពីស្រុកយូដា «ជាមេនៃពួកផារិស៊ី» មានជោគជ័យក្នុងការនាំមកនូវសំណួរដែលមិនយូរប៉ុន្មានបានដឹកនាំឲ្យមានទំនាស់រីករាលដាលនៅក្នុងពួកជំនុំ និងបាននាំមកនូវការភ័ន្តភាំងដល់ពួក

អ្នកជឿជាសាសន៍ដទៃ។ ពួកគ្រូសាសន៍យូដាទាំងនេះបានពោលអះអាងយ៉ាងប្រាកដថាដើម្បីឲ្យបានសង្គ្រោះ មនុស្សត្រូវតែកាត់ស្បែកនិងត្រូវតែរក្សាច្បាប់នៃពិធីបុណ្យទាំងអស់។

លោកប៉ុលនិងបាណាបាសបានជួបនឹងគោលលទ្ធិខុសឆ្គងនេះជាបន្ទាន់ ហើយបានប្រឆាំងទៅនឹងការណែនាំនៃប្រធានបទនេះរបស់ពួកសាសន៍ដទៃនោះ។ ម្យ៉ាងវិញទៀត ពួកសាសន៍យូដានៅអាន់ទីយ៉ូកជាច្រើនបានពេញចិត្តនឹងឥរិយាបទរបស់បងប្អូនដែលទើបតែនឹងមកពីស្រុកយូដាថ្មីៗនេះ ។

ជាទូទៅ ពួកអ្នកដែលបានកែប្រែចិត្តជាសាសន៍យូដាមិនបានបាក់ទឹកចិត្តយ៉ាងរហ័សដូចជាទិព្វញ្ញាណរបស់ព្រះបានបើកផ្លូវនោះទេ។ ជាលទ្ធផលនៃកិច្ចការរបស់ពួកសាវ័កនៅក្នុងចំណោមសាសន៍ដទៃ គឺជាភស្តុតាងបញ្ជាក់ថាពួកអ្នកកែប្រែចិត្តនៅក្នុងចំណោមពួកបណ្ដាជនដែលក្រោយមកមានចំនួនសាសន៍យូដាជាច្រើន ។ ពួកសាសន៍យូដាបារម្ភក្រែងប្រសិនបើបញ្ញត្តិនិងច្បាប់នៃពិធីបុណ្យផ្សេងៗរបស់ពួកគេមិនបានក្លាយទៅជាកាតព្វកិច្ចនៃសាសន៍ដទៃ ទុកជាលក្ខខណ្ឌនៃការប្រកបគ្នានៃពួកជំនុំទេ នោះលក្ខណៈពិសេសនៃជាតិយូដាដែលធ្វើឲ្យពួកគេខុសប្លែកពីសាសន៍ផ្សេងៗ តាំងពីយូរយារមកហើយនោះ ទីបំផុតនឹងត្រូវរលាយបាត់បង់ពីក្នុងចំណោមពួកអ្នកដែលបានទទួលសារនៃដំណឹងល្អជាក់ជាមិនខាន។

សាសន៍យូដាតែងតែមានអំនួតខ្លួនឯងជានិច្ច ទៅលើពិធីខាងសាសនាដែលគេបានតាក់តែង ហើយពួកអ្នកដែលបានផ្លាស់ប្ដូរជំនឿមកឯព្រះគ្រិស្តជាច្រើន នៅតែគិតថាដោយព្រះបានរៀបគម្រោងលក្ខណៈនៃការថ្វាយបង្គំរបស់សាសន៍ហេព្រើរ ព្រះអង្គក៏មិនបានប្រទានអំណាចឲ្យផ្លាស់ប្ដូរលក្ខណៈពិសេសណាមួយនៃការថ្វាយបង្គំនោះដែរ។ ពួកគេទទូចថាច្បាប់របស់សាសន៍យូដានិងពិធីបុណ្យផ្សេងៗគួរតែត្រូវបានបញ្ចូលទៅក្នុងពិធីផ្សេងៗនៃសាសនារបស់គ្រិស្តបរិស័ទ។ ពួកគេមិនងាយនឹងយល់នោះទេ ថាតង្វាយយញ្ញបូជា

ទាំងឡាយបានចង្អុលបង្ហាញទៅឯការសុគតនៃព្រះរាជបុត្រារបស់ព្រះ ដែលនិមិត្តរូបបានជួបនឹងការពិត ហើយចាប់ពីពេលនោះមក ពិធីនិងបុណ្យផ្សេងៗនៅក្នុងការចែកចាយរបស់លោកម៉ូសេលែងត្រូវបានគេអនុវត្តតទៅទៀតហើយ ។

<u>ពុធ-១៦ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ២២

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ដ្បិតពួកអ្នកដែលគ្រាន់តែស្តាប់ក្រឹត្យវិន័យ នោះមិនមែនឈ្មោះថាសុចរិត នៅចំពោះព្រះឡើយ គឺបានរាប់ជាសុចរិតតែពួកអ្នក ដែលប្រព្រឹត្តតាមក្រឹត្យវិន័យប៉ុណ្ណោះទេ ។ រ៉ូម ២:១៣*

មុនពេលការផ្លាស់ប្តូរជំនឿរបស់លោក លោកប៉ុលបានចាត់ទុកខ្លួនឯងថាជាមនុស្សល្អគ្មានកន្លែងបន្ទោសបាន «ចំណែកខាងសេចក្តីសុចរិតក្នុងក្រឹត្យវិន័យ នោះខ្ញុំគ្មានទោសសោះ» (ភីលីព ៣:៦) ។ ប៉ុន្តែ ចាប់តាំងពីលោកបានផ្លាស់ប្តូរចិត្តរបស់លោកមក លោកបានទទួលគំនិតយ៉ាងច្បាស់ពីបេសកកម្មរបស់ព្រះអង្គសង្គ្រោះ ជាព្រះដែលប្រោសលោះមនុស្សជាតិទាំងមូល ទាំងសាសន៍ដទៃព្រមទាំងសាសន៍យូដា ហើយលោកបានដឹងពីភាពខុសគ្នារវាងជំនឿរស់និងការប្រកាន់ទម្រង់ហួសហេតុដែលស្លាប់។ នោះហើយជាស្រមោលដែលបានកន្លងផុតទៅ ហើយអស់អ្នកដែលកំពុងរស់នៅក្រោមការត្រួតត្រានៃដំណឹងល្អមានសេរីភាពពីការគោរពពិធីទាំងនោះរបស់ពួកគេហើយ ។ តែទោះជាយ៉ាងនេះក៏ដោយ ក៏លោកប៉ុលនៅតែគោរពក្រឹត្យវិន័យដប់ប្រការរបស់ព្រះដែលមិនចេះប្រែប្រួល ទាំងខាងវិញ្ញាណនិងនៅក្នុងសំបុត្រជាដរាប ។

នៅក្នុងពួកជំនុំអាន់ទីយ៉ូក ការពិចារណាអំពីសំណួរនៃការកាត់ស្បែកបង្កឲ្យមានការពិភាក្សានិងរឿងវិវាទជាច្រើន។ ទីបំផុត សមាជិកនៃពួកជំនុំបារម្ភក្រែងមានការបាក់បែកនៅក្នុងចំណោមពួកគេ ដែលជាលទ្ធផលនៃការបន្តការពិភាក្សានោះ ពួកគេក៏បានសម្រេចចិត្តបញ្ជូនលោកប៉ុលនិងបាណាបាស

ជាមួយនឹងអ្នកទទួលខុសត្រូវពួកជំនុំមួយចំនួនឲ្យទៅទីក្រុងយេរូសាឡិម ដើម្បីលាតត្រដាងរឿងនេះនៅចំពោះមុខពួកសាវ័កនិងពួកចាស់ទុំ។ នៅទីនោះពួកគេត្រូវជួបជាមួយនឹងប្រតិភូមកពីពួកជំនុំផ្សេងៗ និងពួកអ្នកដែលបានមកកាន់ទីក្រុងយេរូសាឡិមដើម្បីចូលរួមក្នុងពិធីបុណ្យដែលនឹងចូលមកដល់។ នៅពេលជាមួយគ្នានោះ ទំនាស់ទាំងអស់ត្រូវតែបញ្ចប់ រហូតដល់ការសម្រេចចិត្តចុងក្រោយត្រូវបានផ្តល់ដោយក្រុមប្រឹក្សាទូទៅ។ ពេលនោះសេចក្តីសម្រេចនោះត្រូវបានទទួលយកជាទូទៅដោយពួកជំនុំផ្សេងៗនៅទូទាំងប្រទេស។

នៅតាមផ្លូវទៅកាន់ទីក្រុងយេរូសាឡិម ពួកសាវ័កបានចូលសួរសុខទុក្ខពួកអ្នកជឿនៅតាមទីក្រុងដែលពួកលោកបានឆ្លងកាត់ ហើយបានលើកទឹកចិត្តដល់ពួកគេ ដោយរៀបរាប់អំពីបទពិសោធន៍របស់ពួកលោក នៅក្នុងកិច្ចការរបស់ព្រះ និងការផ្លាស់ប្តូរជំនឿរបស់ពួកសាសន៍ដទៃ។

ប្រតិភូមកពីទីក្រុងអាន់ទីយ៉ូកបានជួបជាមួយនឹងបងប្អូនមកពីពួកជំនុំផ្សេងៗ ដែលបានប្រមូលផ្តុំគ្នាដើម្បីការប្រជុំទូទៅមួយ នៅក្រុងយេរូសាឡិម។ ហើយពួកគេបានរៀបរាប់ប្រាប់អំពីជោគជ័យនៃកិច្ចការរបស់ពួកគេនៅក្នុងចំណោមសាសន៍ដទៃ ប្រាប់ដល់ពួកជំនុំទាំងនោះ បន្ទាប់មក ពួកគេបានប្រាប់យ៉ាងច្បាស់អំពីភាពច្របូកច្របល់ដែលបានកើតឡើងដោយសារពួកផារិស៊ីដែលបានផ្លាស់ប្តូរជំនឿមកពីទីក្រុងអាន់ទីយ៉ូកបានអះអាងថា ពួកសាសន៍ដទៃដែលបានផ្លាស់ប្តូរជំនឿត្រូវតែកាត់ស្បែកនិងគោរពតាមច្បាប់របស់លោកម៉ូសេ ដើម្បីឲ្យបានសង្គ្រោះ។

សំណួរនេះត្រូវបានពិភាក្សាយ៉ាងកក់ក្តៅនៅក្នុងអង្គប្រជុំ។ ដោយភ្ជាប់ទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសំណួរនៃការកាត់ស្បែកនេះ ក៏មានការសិក្សាយ៉ាងយកចិត្តទុកដាក់អំពីសំណួរផ្សេងៗទៀតផងដែរ។ សំណួរមួយក្នុងចំណោមសំណួរទាំងនោះគឺបញ្ហាស្តីអំពីអាកប្បកិរិយានៃការបរិភោគសាច់ដែលបានថ្វាយដល់អារក្សរួចហើយ។ សាសន៍ដទៃដែលបានផ្លាស់ប្តូរ

ជំនឿជាច្រើននាក់បានរស់នៅលាយឡំជាមួយនឹងមនុស្សដែលល្ងិតល្ងង់និងសង្ស័យ ដែលតែងតែថ្វាយតង្វាយនិងយញ្ញបូជាដល់អារក្ស។ ពួកសង្ឃដែលដឹកនាំការថ្វាយបង្គំរបស់សាសន៍ទាំងនោះបានយកសាច់ដែលគេបានទទួលទាំងនោះ ទៅលក់ដូរយ៉ាងទូលំទូលាយ ហើយសាសន៍យូដាបារម្ភក្រែងពួកសាសន៍ដទៃដែលបានផ្លាស់ប្តូរជំនឿនឹងនាំគ្រិស្តសាសនាអាប់ឱនដោយសារការទិញសាច់ដែលគេបានថ្វាយទៅអារក្សរួចហើយនោះ មកបរិភោគដោយហេតុនោះនឹងយល់ព្រមតាមប្រពៃណីរបស់អារក្សតាមវិធីណាមួយដែរ ។

<u>ព្រហស្បតិ៍-១៧ កញ្ញា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ២៣**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ដូច្នេះ សេចក្តីជំនឿកើតឡើងដោយឮ ហើយដែលឮនោះ គឺដោយសារព្រះបន្ទូលនៃព្រះ។ រ៉ូម ១០:១៧*

ម្តងទៀត តាមទំនៀមទម្លាប់ សាសន៍ដទៃការបរិភោគសាច់សត្វដែលសម្លាប់ដោយច្របាច់ក ខណៈដែលសាសន៍យូដាត្រូវបានបង្រៀនតាមគោលការណ៍នៃព្រះ ថានៅពេលណាសម្លាប់សត្វសម្រាប់ជាអាហារ ត្រូវតែមានការប្រុងប្រយ័ត្នដោយបង្ហូរឈាមចេញឲ្យអស់ពីរាងកាយ បើមិនដូច្នោះទេ សាច់នោះនឹងត្រូវចាត់ទុកថាជាអាហារដែលនាំឲ្យអន្តរាយដល់សុខភាព ព្រះបានប្រទានការត្រាស់បង្គាប់នេះដល់សាសន៍យូដា ក្នុងគោលបំណងការពារសុខភាពរបស់ពួកគេ។ សាសន៍យូដាបានចាត់ទុកការប្រើប្រាស់ឈាមជាអាហារនោះថាជាអំពើបាប។ ពួកគេបានប្រកាន់ថាឈាមគឺជាជីវិត និងថាការកម្ចាយឈាមគឺជាផលវិបាកនៃអំពើបាប។

ផ្ទុយទៅវិញ សាសន៍ដទៃបានអនុវត្តការយកឈាមដែលហូរចេញពីសត្វរងគ្រោះដែលជាតង្វាយយញ្ញបូជាហើយយកទៅរៀបចំជាចំណីអាហារ។ ពួកសាសន៍យូដាមិនអាចជឿថាពួកគេគួរតែផ្លាស់ប្តូរប្រពៃណី ដែលពួកគេបានអនុវត្តនៅក្រោមការណែនាំ ជាពិសេសរបស់ព្រះដោយផ្ទាល់នោះ

បានទេ ។ ហេតុនោះ កាលរឿងដូច្នេះបានកើតឡើងនៅពេលនោះ ប្រសិនបើសាសន៍យូដានិងសាសន៍ដទៃចង់បរិភោគអាហាររួមតុជាមួយគ្នា អ្នកមុន (សាសន៍យូដា) នឹងត្រូវតក់ស្លុត ហើយបានប្រមាថយ៉ាងធ្ងន់ធ្ងរដោយអ្នកក្រោយ (សាសន៍ដទៃ)។

ពួកសាសន៍ដទៃ ជាពិសេសសាសន៍ក្រិក ជាអ្នកប្រកាន់សីលធម៌តឹងរ៉ឹង ហើយនឹងមានគ្រោះថ្នាក់ ប្រសិនបើអ្នកខ្លះដែលមិនបានកែប្រែចេញពីក្នុងចិត្តបានធ្វើការប្រកាសជំនឿដោយមិនបានបោះបង់ចោលការអនុវត្តន៍អាក្រក់របស់ខ្លួនទេ ។ ពួកគ្រិស្តបរិស័ទដែលជាសាសន៍យូដាមិនអាចសម្របសម្រួលអំពើអសីលធម៌របស់ពួកគេ ដែលមិនទាំងបានចាត់ទុកជាអំពើឧក្រិដ្ឋដោយសាសន៍ដទៃផងនោះឡើយ ។ ហេតុដូច្នេះ សាសន៍យូដាប្រកាន់ក្រមសីលធម៌នោះថាជាការត្រឹមត្រូវយ៉ាងខ្ពង់ខ្ពស់ ដែលការកាត់ស្បែកនិងការគោរពពិធីបុណ្យផ្សេងៗគួរតែត្រូវបានបង្គាប់ដល់សាសន៍ដទៃ ដែលបានផ្លាស់ប្តូរជំនឿទុកជាការសាកល្បងដល់ភាពស្មោះត្រង់និងជំនឿស៊ប់របស់ពួកគេ។ ពួកគេបានជឿថា ទង្វើនេះនឹងការពារការន្ថែមចូលទៅក្នុងពួកជំនុំនូវសមាជិកដែលបានទទួលយកជំនឿដោយមិនមានការកែប្រែចេញពីក្នុងចិត្ត ហើយដែលក្រោយមក អាចនឹងនាំមកនូវការស្តីបន្ទោសទៅលើមូលហេតុដែលបណ្តាលមកពីភាពអសីលធម៌និងអរិយភាព ។

ចំណុចផ្សេងៗដែលបានពាក់ព័ន្ធនៅក្នុងការដោះស្រាយសំណួរធំៗនៅក្នុងរឿងទាំងឡាយដែលបានលើកមកពិភាក្សានៅចំពោះក្រុមប្រឹក្សានោះហាក់ដូចជារឿងដែលពិបាកៗដែលសឹងតែមិនអាចយកជ័យជន្នះបាន។ ប៉ុន្តែ តាមពិត ព្រះវិញ្ញាណបរិសុទ្ធ បានដោះស្រាយសំណួរនេះរួចមកហើយនៅលើការសម្រេចចិត្តដែលហាក់ដូចជាពឹងផ្អែកទៅលើការរីកចម្រើន របស់ពួកជំនុំគ្រិស្តបរិស័ទ ប្រសិនបើមិនមានរឿងទាំងនោះកើតឡើងទេ។

«លុះបានជជែកគ្នាជាយូរទៅ នោះពេត្រុសក្រោកឡើងនិយាយថា បងប្អូនអើយ អ្នករាល់គ្នាដឹងហើយថា កាលពីដើម ព្រះបានរើសក្នុងពួកយើង

រាល់គ្នា ដើម្បីឲ្យពួកសាសន៍ដទៃបានឮព្រះបន្ទូលនៃដំណឹងល្អ ហើយឲ្យបានជឿដោយសារមាត់ខ្ញុំ»។ លោកបានពិចារណាថាព្រះវិញ្ញាណបរិសុទ្ធបានសម្រេចរឿងនោះនៅក្រោមការជជែកគ្នាដោយបានបន្ទាបពួកសាសន៍ដទៃដែលមិនកាត់ស្បែកឲ្យស្មើគ្នាទៅនឹងសាសន៍យូដាដែលបានកាត់ស្បែកដែរ។ លោកបានរំឭកប្រាប់ពួកគេអំពីចក្ខុនិម្មិតដែលព្រះបានបើកបង្ហាញដល់លោក អំពីផ្ទាំងសំពត់ដែលមានសត្វគ្រប់ប្រភេទ ហើយបានបង្គាប់ឲ្យលោកសម្លាប់ហើយបរិភោគទៅ។ កាលលោកបានប្រកែកដោយពោលថាលោកមិនដែលបរិភោគអ្វីដែលមិនស្អាតទេនោះ ព្រះបានឆ្លើយតបមកវិញថា «របស់អ្វីដែលព្រះបានសម្អាតហើយ នោះកុំឲ្យអ្នករាប់ថាជាមិនស្អាតឡើយ» (កិច្ចការ ១០:១៥) ។

<u>សុក្រ-១៨ កញ្ញា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ២៤**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ប៉ុន្តែ បើមែកខ្លះត្រូវកាច់ចេញ ហើយអ្នកឯងដែលជាដើមអូលីវព្រៃ បានត្រូវបំបៅកណ្តាលមែកទាំងនោះ ទាំងត្រឡប់ទៅជាស្រូបជាតិឫសនៃដើមអូលីវស្រុក ជាមួយនឹងមែកឯទៀត។ រ៉ូម ១១:១៧*

លោកពេត្រុសបានរៀបរាប់អំពីព្រះបន្ទូលទាំងនេះយ៉ាងច្បាស់ ដែលព្រះបានប្រទានដល់លោកនូវការត្រាស់ហៅឲ្យលោកទៅផ្ទះលោកមេទ័ពភ្លាម ហើយបង្រៀនដល់គាត់អំពីជំនឿនៃព្រះគ្រិស្ត។ សារនេះបានបញ្ជាក់ថាព្រះមិនមែនជាអ្នកប្រកាន់បុគ្គលទេ ប៉ុន្តែ ទ្រង់បានទទួលយកនិងទទួលស្គាល់មនុស្សទាំងអស់ដែលកោតខ្លាចដល់ទ្រង់។ លោកពេត្រុសបានប្រាប់អំពីការភ្ញាក់ផ្អើលរបស់លោក នៅពេលដែលលោកបានឃើញព្រះវិញ្ញាណបរិសុទ្ធកំពុងគង់សណ្ឋិតលើពួកអ្នកស្តាប់របស់លោក ទាំងសាសន៍ដទៃ និងសាសន៍យូដា ក្នុងការនិយាយពីព្រះបន្ទូលនៃសេចក្តីពិតដល់មនុស្សដែលកំពុងតែជួបជុំគ្នា នៅឯផ្ទះរបស់លោកកូនេលាស ។ សារនេះគឺជាការព្រមានរបស់ព្រះ ប្រាប់ថាលោកពេត្រុសមិនត្រូវចាត់ទុកអ្នកណាអន់ជាងអ្នកណា

ម្នាក់ទៀតទេ ព្រោះព្រះលោហិតរបស់ព្រះគ្រិស្តអាចសម្អាតមនុស្សទាំងអស់ពីភាពមិនស្អាតហើយ ។

កាលពីមុន មានពេលមួយ លោកពេត្រុសបានពិចារណាជាមួយនឹងបងប្អូនរួមជំនឿរបស់លោកទាក់ទងនឹងការសន្ទនាជាមួយនឹងលោកកូនេលាស និងមិត្តភក្តិរបស់គាត់ និងការប្រកបគ្នាជាមួយនឹងពួកគេ ។ ក្នុងឱកាសដែលលោកកំពុងតែរៀបរាប់អំពីរបៀបដែលព្រះវិញ្ញាណបរិសុទ្ធបានយាងមកកាន់សាសន៍ដទៃ លោកបានមានប្រសាសន៍ថា «ដូច្នេះ បើសិនជាព្រះបានប្រទានអំណោយទានទៅគេ ដូចជាបានប្រទានមកយើងដែរ ដោយជឿដល់ព្រះអម្ចាស់យេស៊ូវគ្រិស្ត ចុះតើខ្ញុំជាអ្វីដែលអាចនឹងឃាត់ព្រះបាន» (កិច្ចការ ១១:១៧) ។ ឥឡូវនេះ លោកបានមានប្រសាសន៍ដោយសេចក្តីក្លៀវក្លានិងកម្លាំងព្រមគ្នាថា «នោះព្រះដ៏ជ្រាបនូវចិត្តមនុស្សទាំងឡាយ ទ្រង់បានធ្វើបន្ទាល់ពីគេ ដោយទ្រង់ប្រទានព្រះវិញ្ញាណបរិសុទ្ធដល់គេ ដូចជាដល់យើងរាល់គ្នាដែរ ទ្រង់មិនបានរាប់ពួកយើង និងពួកគេ ខុសពីគ្នាទេ គឺបានសម្អាតចិត្តគេ ដោយសារសេចក្តីជំនឿជឿដែរ ចុះហេតុអ្វីបានជាល្បងព្រះ ដោយបំពាក់នឹមនៅកពួកសិស្សដូច្នេះ ដែលទោះទាំងពួកអយ្យកោយើង ឬយើងរាល់គ្នាក៏ពុំអាចនឹងទ្រទ្រាំបានផង»។ នឹមនេះ មិនមែនជាក្រឹត្យវិន័យដប់ប្រការដូចដែលអ្នកប្រឆាំងមួយចំនួនទាមទារការគោរពនោះទេ នៅទីនេះ លោកពេត្រុសបានសំដៅទៅលើច្បាប់នៃពិធីបុណ្យផ្សេងៗ ដែលត្រូវបានចាត់ទុកជាមោឃៈដោយការជាប់ឆ្កាងរបស់ព្រះគ្រិស្តឯណោះទេ ។

ប្រសាសន៍របស់លោកពេត្រុសបាននាំមកជូនពួកបណ្តាជនដែលកំពុងតែជួបជុំគ្នានូវចំណុចមួយដែលពួកគេអាចស្តាប់លោកប៉ុលនិងបាណាបាសដោយអត់ធ្មត់ ដែលបានរៀបរាប់អំពីបទពិសោធន៍របស់ពួកលោកក្នុងការធ្វើការជាមួយនឹងសាសន៍ដទៃ។ «ឯពួកជំនុំទាំងអស់គ្នា ក៏នៅស្ងៀមស្តាប់បាណាបាស និងប៉ុល ដែលគេរ៉ាយរឿងប្រាប់ពីទីសម្គាល់ និងការអស្ចារ្យទាំងប៉ុន្មាន ដែលព្រះបានធ្វើក្នុងពួកសាសន៍ដទៃ ដោយសារខ្លួន»។

លោកយ៉ាកុប ក៏បានបញ្ចេញទីបន្ទាល់របស់លោកជាមួយនឹងសេចក្ដីក្លាហាន ដោយប្រកាសថាគឺជាព្រះរាជគោលបំណងរបស់ព្រះ ក្នុងការប្រទានឯកសិទ្ធិនិងព្រះពរដល់សាសន៍ដទៃ ដូចជាព្រះអង្គបានប្រទានដល់សាសន៍យូដាដែរ។

ព្រះវិញ្ញាណបរិសុទ្ធបានទតឃើញថាការបង្ខំឲ្យសាសន៍ដទៃ ដែលបានផ្លាស់ប្ដូរជំនឿអនុវត្តច្បាប់នៃពិធីបុណ្យនោះមិនល្អទេ ហើយគំនិតរបស់ពួកសាវ័កទាក់ទងនឹងរឿងនេះ ក៏ដូចជាព្រះតម្រិះរបស់ព្រះវិញ្ញាណបរិសុទ្ធដែរ ។ លោកយ៉ាកុបបានធ្វើជាអធិបតីនៅក្នុងក្រុមប្រឹក្សា ហើយសេចក្ដីសម្រេចចិត្តចុងក្រោយរបស់លោកគឺ «ដូច្នេះ បើតាមគំនិតខ្ញុំ នោះមិនត្រូវធ្វើឲ្យពួកសាសន៍ដទៃ ដែលងាកបែរមកឯព្រះវិញ មានចិត្តខ្វល់ឡើយ»។

សេចក្ដីសម្រេចនេះក៏បានបញ្ចប់ការពិភាក្សានោះ ។ នៅក្នុងប្រយោគនេះ យើងមានការបដិសធន៍ទៅនឹងគោលលទ្ធិដែលប្រកាន់ដោយពួកជំនុំកាតូលិករ៉ូម ថាលោកពេត្រុសគឺជាប្រធាននៃពួកជំនុំ ។ អ្នកទាំងឡាយណាដែលមានតំណែងជាសម្ដេចប៉ាបបានអះអាងថាជាអ្នកតតំណែងអំពីលោកពេត្រុស ដោយមិនមានការគាំទ្រពីព្រះគម្ពីរចំពោះការទាមទាររបស់ពួកគេនេះឡើយ ។ គ្មានអ្វីដែលផ្ដល់ភាពបរិសុទ្ធនៅក្នុងជីវិតរបស់លោកពេត្រុសដែលធ្វើឲ្យលោកអះអាងថាលោកត្រូវបានគេលើកតម្កើងឲ្យខ្ពស់ជាងបងប្អូនរួមជំនឿរបស់លោក ជាអាវផាយពណ៌សនៃព្រះដ៏ខ្ពស់បំផុតឡើយ។ ប្រសិនបើអ្នកដែលបានអះអាងថាខ្លួនជាអ្នកបន្តតំណែងពីលោកពេត្រុស អ្នកនោះត្រូវតែធ្វើតាមគំរូរបស់លោក គឺពួកគេត្រូវតែពេញចិត្តនឹងឋានៈស្មើនឹងបងប្អូនរបស់ខ្លួន ។

នៅក្នុងហេតុការណ៍នេះ លោកយ៉ាកុបទំនងជាត្រូវបានគេជ្រើសរើសឲ្យថ្លែងការណ៍អំពីសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សានោះ។ គឺដោយសារប្រយោគនោះហើយដែលច្បាប់នៃពិធីបុណ្យផ្សេងៗ ជាពិសេស ពិធីកាត់ស្បែកត្រូវបានគេលែងបង្ខំឲ្យសាសន៍ដទៃគោរព ឬជាការបង្គាប់តទៅទៀត។

លោកយ៉ាកុបបានធ្វើការដើម្បីសង្កត់នៅក្នុងគំនិតនៃបងប្អូនរួមជំនឿរបស់លោកជាមួយនឹងហេតុការណ៍ដែលថា ការបែរមករកព្រះ នោះសាសន៍ដទៃបានផ្លាស់ប្តូរជាច្រើននៅក្នុងជីវិតរបស់ពួកគេណាស់ទៅហើយ ហើយពួកយូដាត្រូវតែប្រុងប្រយ័ត្នឲ្យមែនទែន កុំបង្កបញ្ហាដល់ពួកគេ ដោយភាពអល់អែកនិងមន្ទិលសង្ស័យឡើយ ក្រែងពួកគេបានបាក់ទឹកចិត្តក្នុងការដើរតាមព្រះគ្រិស្ត។

<u>សៅរ៍-១៩ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ពង្សាវតារក្សត្រទី២ ជំពូក ២៥

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *តែអរព្រះគុណដល់ព្រះអង្គ ដែលទ្រង់ចេះតែនាំយើងខ្ញុំឲ្យមានជ័យជំនះក្នុងព្រះគ្រីស្ទ ហើយក៏ផ្សាយក្លិនពីដំណើរដែលយើងខ្ញុំស្គាល់ព្រះ ឲ្យបានសុសសាយទូទៅគ្រប់កន្លែងផង។ កូរិនថូសទី២ ២:១៤*

ទោះបីជាយ៉ាងនេះក៏ដោយ ក៏ពួកសាសន៍ដទៃដែលបានផ្លាស់ប្តូរជំនឿត្រូវតែបោះបង់ចោលនូវទំនៀមទម្លាប់ដែលមិនស្របជាមួយនឹងគ្រិស្តសាសនាដែរ ។ ដូច្នេះ ពួកសាវ័កនិងពួកចាស់ទុំក៏បានព្រមព្រៀងគ្នាណែនាំដល់សាសន៍ដទៃដោយសំបុត្រ ឲ្យចៀសវាងពីសាច់ដែលបានថ្វាយដល់អារក្ស ពីការងុបងល់ខាងកាមតណ្ហា ពីសត្វដែលសម្លាប់ដោយច្របាច់ក និងពីឈាម។ ពួកគេត្រូវបានជំរុញឲ្យគោរពក្រឹត្យវិន័យដប់ប្រការ ហើយឲ្យរស់នៅក្នុងជីវិតបរិសុទ្ធ  ពួកគេក៏ត្រូវបានប្រាប់ឲ្យដឹងច្បាស់ផងដែរថា មនុស្សដែលបានប្រកាសឲ្យប្រកាន់យកការកាត់ស្បែកនោះមិនមែនបានទទួលការអនុញ្ញាតឲ្យធ្វើដូច្នោះពីពួកសាវ័កទេ ។

ក្រុមប្រឹក្សានោះបានផ្តល់អនុសាសន៍ថា លោកប៉ុលនិងលោកបាណាបាសគឺជាមនុស្សដែលបានយកជីវិតរបស់ខ្លួនទៅប្រថុយដើម្បីព្រះជាម្ចាស់។ គេក៏បានចាត់លោកយូដាសនិងស៊ីឡាសឲ្យទៅប្រកាសដោយផ្ទាល់មាត់អំពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានោះ ប្រាប់ដល់សាសន៍ដទៃផងដែរ៖ «ពីព្រោះព្រះវិញ្ញាណបរិសុទ្ធ និងយើងខ្ញុំរាល់គ្នា បានយល់ឃើញថា មិនគួរ

គប្បីនឹងដាក់បន្ទុកអ្វីទៀតលើអ្នករាល់គ្នា ក្រៅពីសេចក្តីទាំងនេះ ដែលត្រូវតែកាន់នោះឡើយ គឺឲ្យចៀសវាងចំពោះរបស់ដែលបានថ្វាយដល់រូបព្រះមួយឈាមមួយ សត្វដែលសម្លាប់ដោយច្របាច់កមួយ និងសេចក្តីកំផិតមួយ បើអ្នករាល់គ្នាចៀសវាងពីរបស់ទាំងនេះ នោះបានល្អហើយ សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខចុះ»។ គេក៏បានចាត់អ្នកបម្រើរបស់ព្រះទាំងបួននាក់ទៅកាន់ក្រុងអាន់ទីយ៉ូក ជាមួយនឹងសំបុត្រនិងសារដែលនឹងបញ្ចប់ទំនាស់ទាំងអស់ ដ្បិតនោះហើយដែលជាសំឡេងនៃអំណាចដ៏ខ្ពស់បំផុតនៅលើផែនដី។

ក្រុមប្រឹក្សាដែលធ្វើការសម្រេចលើករណីនេះមានសមភាពមកពីពួកសាវ័កនិងពួកគ្រូបង្រៀនដែលធ្លាប់លេចធ្លោជាងគេ នៅក្នុងាការបង្ហាត់បង្រៀនដល់ពួកជំនុំគ្រិស្តបរិស័ទ ដែលជាសាសន៍ដទៃនិងសាសន៍យូដា ដែលត្រូវបានជ្រើសតាំងជាប្រតិភូតំណាងមកពីកន្លែងផ្សេងៗ។ ពួកចាស់ទុំមកពីក្រុងអាន់ទីយ៉ូកនិងក្រុងយេរូសាឡិមក៏មានវត្តមាននៅទីនោះ ហើយក៏មានតំណាងមកពីពួកជំនុំដែលមានឥទ្ធិពលជាងគេបំផុតផងដែរ។ ក្រុមប្រឹក្សានេះបានសម្រេចទៅតាមបញ្ញានៃការវិនិច្ឆ័យដ៏ភ្លឺស្វាង និងសេចក្តីថ្លៃថ្នូររបស់ពួកជំនុំដែលបានតាំងឡើងដោយព្រះហឫទ័យរបស់ព្រះ។ ជាលទ្ធផលនៃការពិភាក្សានេះ ពួកគេទាំងអស់គ្នាបានឃើញថាព្រះបានឆ្លើយតបដោយផ្ទាល់ទៅនឹងសំណួរដែលបានចោទឡើង ដោយបានប្រទានព្រះវិញ្ញាណបរិសុទ្ធដល់សាសន៍ដទៃ ហើយពួកគេបានដឹងថាតួនាទីរបស់ពួកគេ គឺការដើរតាមការដឹកនាំរបស់ព្រះវិញ្ញាណ។

ពួកជំនុំគ្រិស្តបរិស័ទទាំងមូលមិនត្រូវបានត្រាស់ហៅ ឲ្យបោះឆ្នោតសម្រេចលើសំណួរទាំងអស់នោះទេ។ «ពួកសាវ័កនិងពួកចាស់ទុំ» ជាមនុស្សដែលមានឥទ្ធិពល និងចេះវិនិច្ឆ័យ គឺជាអ្នកបង្កើតនិងចេញច្បាប់ ដែលត្រូវបានទទួលស្គាល់ជាទូទៅដោយពួកជំនុំគ្រិស្តបរិស័ទនៅពេលនោះ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏មិនមែនគ្រិស្តបរិស័ទទាំងអស់សុទ្ធតែពេញចិត្តនឹង

សេចក្តីសម្រេចនោះដែរ មានក្រុមបងប្អូនរួមជំនឿមួយចំនួនដែលលោភលន់ និងទុកចិត្តទៅលើខ្លួនឯងមិនបានឯកភាពទៅនឹងសេចក្តីសម្រេចនោះទេ។ មនុស្សទាំងនេះបានតាំងចិត្តបំពេញកិច្ចការដោយការទទួលខុសត្រូវរបស់ខ្លួនផ្ទាល់។ ពួកគេបានបណ្តែតបណ្តោយឲ្យមានការរអ៊ូរទាំនិងការចាប់កំហុសដោយបង្កើតផែនការថ្មី ហើយស្វះស្វែងទាញទម្លាក់កិច្ចការរបស់មនុស្សដែលព្រះបានតែងតាំងឲ្យបង្រៀនពីសារនៃដំណឹងល្អ។ ពួកជំនុំធ្លាប់បានជួបនឹងឧបសគ្គនេះតាំងពីដើមដំបូងមក ហើយក៏នៅតែជួបរហូតដល់គ្រាចុងបំផុត ។

<u>អាទិត្យ-២០ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្យត្រទី១ ជំពូក ១

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ខ្ញុំក៏អធិស្ឋានសូមសេចក្តីនេះ គឺឲ្យសេចក្តីស្រឡាញ់របស់អ្នករាល់គ្នា បានចំរើនកាន់តែច្រើនឡើង ដោយនូវសេចក្តីចេះដឹង និងយោបល់គ្រប់ជំពូក។ ភីលីព ១:៩*

ក្រុងយេរូសាឡិមគឺជារាជធានីនៃសាសន៍យូដា ហើយគឺនៅទីនោះហើយដែលគេបានរកឃើញការមិនចុះសម្រុងគ្នានិងការវង្វេងសាសនា។ ពួកគ្រិស្តបរិស័ទជាសាសន៍យូដាដែលរស់នៅក្រោមក្រសែភ្នែករបស់ពួកជំនុំ បានបណ្តោយឲ្យគំនិតរបស់ពួកគេវិលត្រឡប់ទៅកាន់លក្ខណៈពិសេសនៃបុព្វសិទ្ធិរបស់សាសន៍យូដាទូទាំងនគរ យ៉ាងងាយទៅវិញ។ កាលពួកគេបានឃើញពួកជំនុំគ្រិស្តបរិស័ទបានងាកចេញពីពិធីបុណ្យផ្សេងៗ និងពីប្រពៃណីរបស់សាសន៍យូដា ហើយបានដឹងថាលក្ខណៈពិសេសដ៏ពិសិដ្ឋ ដែលប្រពៃណីសាសន៍យូដាបានបង្កើត នឹងត្រូវបាត់បង់ដោយសារតែពន្លឺនៃជំនឿថ្មី នៅពេលដ៏ខ្លីខាងមុខនេះ ពួកគេជាច្រើនបានតូចចិត្តនឹងលោកប៉ុលជាខ្លាំងដែលជាអ្នកបង្កឲ្យមានការផ្លាស់ប្តូរនេះ។ សូម្បីតែពួកសាវ័កក៏មានខ្លះមិនបានរៀបចំខ្លួនទទួលយកការសម្រេចចិត្តរបស់ក្រុមប្រឹក្សានេះដែរ ។ គេមានចិត្តពុះកញ្ជ្រោល ចំពោះច្បាប់ខាងពិធីបុណ្យផ្សេងៗនេះ ហើយពួក

គេក៏មិនបានគោរពដល់លោកប៉ុលដោយការពេញចិត្តដែរ ព្រោះពួកគេបានគិតថា គោលការណ៍របស់លោក ទាក់ទងទៅនឹងកាតព្វកិច្ចនៃច្បាប់របស់សាសន៍យូដាមានភាពធូររលុង ។

ការសម្រេចដ៏ធំនិងទូលំទូលាយរបស់ក្រុមប្រឹក្សាទូទៅ បាននាំមកនូវទំនុកចិត្តដល់ជួរពួកអ្នកជឿសាសន៍ដទៃ ហើយកិច្ចការរបស់ព្រះក៏បានរីកចម្រើន។ ពួកជំនុំនៅអាន់ទីយ៉ូកពេញចិត្តនឹងលោកយូដាសនិងស៊ីឡាស ជាអ្នកនាំសារពិសេសដែលបានត្រឡប់មកពីការប្រជុំនៅទីក្រុងយេរូសាឡិម ជាមួយនឹងពួកសាវ័ក។ លោកយូដាស និងស៊ីឡាស«ដែលជាគ្រូអធិប្បាយដែរ គេបានប្រដៅទូន្មានជាច្រើនដល់ពួកជំនុំ ព្រមទាំងតាំងឲ្យគេមានចិត្តខ្ជាប់ខ្ជួនឡើង» បុរសដែលមានព្រះទាំងពីរនាក់នេះបាននៅក្រុងអាន់ទីយ៉ូកជាយូរបន្តិច ។ «ឯប៉ុល និងបាណាបាស បានបង្អង់នៅឯក្រុងអាន់ទីយ៉ូកនោះដែរ ទាំងបង្រៀន ហើយប្រកាសប្រាប់ដំណឹងល្អ គឺជាព្រះបន្ទូលនៃព្រះអម្ចាស់ ជាមួយនឹងមនុស្សឯទៀតជាច្រើន» ។

លុះគ្រាក្រោយមកទៀត កាលលោកពេត្រុសបានមកអាន់ទីយ៉ូក លោកបានទាក់ទាញទំនុកចិត្តរបស់មនុស្សជាច្រើនដោយសារអាកប្បកិរិយាដ៏ប្រុងប្រយ័ត្នរបស់លោក ចំពោះពួកសាសន៍ដទៃដែលបានផ្លាស់ប្តូរជំនឿ។ លោកបានប្រព្រឹត្តតាមពន្លឺដែលព្រះបានប្រទានមកពីឋានសួគ៌មួយរយៈ។ លោកមានជោគជ័យលើនិស្ស័យនៃការប្រកាន់ពូជសាសន៍ពីកំណើតរបស់លោក ក្នុងការអង្គុយទទួលទានអាហារជាមួយនឹងសាសន៍ដទៃដែលបានផ្លាស់ប្តូរជំនឿ ។ ប៉ុន្តែ នៅពេលពួកយូដាខ្លះដែលប្រកាន់ច្បាប់នៃពិធីបុណ្យតឹងរ៉ឹងបានមកពីទីក្រុងយេរូសាឡិម លោកពេត្រុស បានផ្លាស់ប្តូរឥរិយាបទរបស់លោកយ៉ាងអយុត្តិធម៌ ទៅលើអ្នកដែលបានផ្លាស់ប្តូរជំនឿមកពីសាសនាដទៃ។ សាសន៍យូដាមួយចំនួន «ក៏ធ្វើជាពើជាមួយនឹងលោកដែរ ដល់ម៉្លេះបានជាបាណាបាស ត្រូវបណ្តោយតាមអំពើកំពុតរបស់គេទៀត» ។ ការបង្ហាញពីភាពកម្សោយរបស់អ្នកដែលគេគោរពនិងស្រឡាញ់ជាអ្នកដឹក

នាំបានបន្សល់ទុកនូវការឈឺចាប់ជាខ្លាំងដល់គំនិតរបស់ពួកអ្នកជឿដែលជាសាសន៍ដទៃ ។ ពួកជំនុំត្រូវបានគំរាមកំហែងដោយការបែកបាក់។ ប៉ុន្តែ លោកប៉ុលដែលបានមើលឃើញឥទ្ធិពលដ៏ស្ទៀមស្ងាត់ដែលបានប្រព្រឹត្តមិនត្រឹមត្រូវទៅកាន់ពួកជំនុំ តាមរយៈសកម្មភាពទាំងពីរផ្នែករបស់លោកពេត្រុស លោកបានស្តីបន្ទោសដោយចំហ ដោយការក្លែងបន្លំមនោសញ្ចេតនាពិតប្រាកដរបស់គាត់យ៉ាងដូច្នេះ ។ លោកប៉ុលបានសួរដល់លោកពេត្រុសនៅជំពោះពួកជំនុំថា «បើលោក ដែលជាសាសន៍យូដា មិនប្រព្រឹត្តតាមទំនៀមទម្លាប់របស់សាសន៍យូដាទេ គឺប្រព្រឹត្តតាមទំនៀមទម្លាប់សាសន៍ដទៃវិញ នោះហេតុអ្វីបានជាបង្ខំឲ្យសាសន៍ដទៃ ប្រព្រឹត្តដូចជាសាសន៍យូដាដូច្នេះ?» (កាឡាទី ២:១៣, ១៤) ។

លោកពេត្រុសបានមើលឃើញកំហុសដែលលោកបានធ្លាក់ចុះ ហើយលោកបានរៀបចំកែលម្អអំពើអាក្រក់ដែលខ្លួនបានធ្វើជាបន្ទាន់ តាមអំណាចដែលលោកអាចធ្វើបាន ។ ព្រះដែលបានជ្រាបទីបញ្ចប់តាំងពីដើមដំបូង ព្រះអង្គបានអនុញ្ញាតឲ្យលោកពេត្រុសបង្ហាញពីភាពកម្សោយខាងអត្តចរិតរបស់លោក ដើម្បីឲ្យសាវ័កដែលព្រះបានសាកល្បងនេះបានដឹងថាគ្មានអ្វីនៅក្នុងខ្លួនដែលលោកត្រូវអួតអាងឡើយ។ ទោះបីមនុស្សដែលពូកែបំផុតក៏ដោយ បើបណ្តោយឲ្យនៅតែម្នាក់ឯង ប្រាកដជាវិនិច្ឆ័យខុសជាក់ជាមិនខាន។ ព្រះក៏បានជ្រាបផងដែរថា នៅពេលខាងមុខ មនុស្សខ្លះនឹងត្រូវបានបោកបញ្ឆោតឲ្យទាមទារសិទ្ធិជាលោកពេត្រុស និងជាអ្នកក្លែងធ្វើជាអ្នកបន្តតំណែងពីលោក ដែលជាបុព្វសិទ្ធិដ៏ខ្ពង់ខ្ពស់របស់ព្រះតែមួយអង្គគត់។ ហើយកំណត់ត្រានៃភាពកម្សោយរបស់សាវ័កពេត្រុសនេះ ត្រូវទុកជាភស្តុតាងបញ្ជាក់អំពីភាពភ័ន្តច្រឡំរបស់លោក និងការពិតដែលបញ្ជាក់ប្រាប់ថាមិនមានផ្លូវណាដែលលោកអាចឈរខ្ពស់ជាងសាវ័កដទៃទៀតឡើយ។

<u>ច័ន្ទ-២១ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ២

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ដែលទ្រង់កំសាន្តចិត្តយើងរាល់គ្នា ក្នុងគ្រប់ទាំងសេចក្តីវេទនា ប្រយោជន៍ឲ្យយើងអាចនឹងកំសាន្តចិត្តអ្នកឯទៀត ក្នុងអស់ទាំងសេចក្តីវេទនារបស់គេបានដែរ គឺដោយសារសេចក្តីក្សាន្តនោះឯង ដែលព្រះបានកំសាន្តចិត្តយើងស្រេចហើយ។ កូរិនថូសទី២ ១:៤*

ប្រវត្តិនៃការចាកចេញពីគោលការណ៍ដ៏ត្រឹមត្រូវនេះ ឈរជាការព្រមានយ៉ាងឧឡារិកដល់បុរសទាំងឡាយដែលមានតួនាទីក្នុងការបំពេញកិច្ចការរបស់ព្រះ ថាពួកគេមិនត្រូវធ្លាក់ចុះខាងសេចក្តីសុចរិតទេ ប៉ុន្តែ ត្រូវប្រកាន់ខ្ជាប់តាមគោលការណ៍វិញ។ អ្នកដែលបានទទួលការទទួលខុសត្រូវកាន់តែធំ និងមានឱកាសបង្គាប់បញ្ជានិងគ្រប់គ្រងកាន់តែច្រើន អ្នកនោះកាន់តែមានការឈឺចាប់ ប្រសិនបើគេមិនបានធ្វើតាមវិធីរបស់ព្រះជាម្ចាស់ឲ្យបានត្រឹមត្រូវនិងធ្វើការឲ្យស្របទៅតាមសេចក្តីសម្រេចរបស់រចនាសម្ព័ន្ធទូទៅនៃពួកអ្នកជឿ នៅក្នុងក្រុមប្រឹក្សាដែលបានរួបរួមគ្នាទេនោះ។

បន្ទាប់ពីការបរាជ័យរបស់លោកពេត្រុសមក បន្ទាប់ពីការដួលចុះនិងការស្តារឡើងវិញរបស់លោក កិច្ចការដ៏យូរអង្វែងរបស់លោក ភាពស្និទ្ធស្នាលខាងផ្លូវចិត្តរបស់លោកជាមួយនឹងព្រះគ្រិស្ត ចំណេះដឹងនៃការអនុវត្តន៍តាមគោលការណ៍ដ៏ស្មោះត្រង់របស់ព្រះអង្គសង្គ្រោះរបស់លោក ជាពិសេស ការបង្រៀនដែលលោកបានទទួលអំណោយទាននិងចំណេះដឹងព្រមទាំងឥទ្ធិពលទាំងឡាយដែលលោកទទួលបាន តាមរយៈការអធិប្បាយនិងការបង្រៀនព្រះបន្ទូល តើមិនមែនជាការចម្លែកទេឬអីដែលលោកគួរក្លែងបន្លំនិងដោះសាគោលការណ៍នៃដំណឹងល្អ តាមរយៈការកោតខ្លាចមនុស្ស ឬដើម្បីទទួលបានតម្លៃផ្ទាល់ខ្លួននោះ? តើមិនចម្លែកទេឬ ដែលលោកងាករេក្នុងការប្រកាន់ខ្ជាប់តាមគោលការណ៍ត្រឹមត្រូវនោះ? សូមឲ្យព្រះបានប្រទាននូវចំណេះដឹងនៃភាពគ្មានជំនួយ ភាពគ្មានសមត្ថភាពរបស់ខ្លួន ដើម្បីកាច់ចង្កូតនាវារបស់ខ្លួនឲ្យបានត្រង់ និងមានសុវត្ថិភាពឆ្ពោះទៅកាន់កោះត្រើយ ។

នៅក្នុងការបំពេញបេសកកម្មរបស់គាត់ លោកប៉ុលតែងតែត្រូវបានបង្ខំឲ្យនៅតែម្នាក់ឯង ។ ព្រះតែងតែបង្រៀនដល់លោកជាពិសេស ហើយមិនហ៊ានបន្ធូរបន្ថយអ្វីដែលទាក់ទងទៅនឹងគោលការណ៍ទេ។ លោកមានបន្ទុកធ្ងន់ជាច្រើនលើកច្រើនសារ ប៉ុន្តែ លោកប៉ុលបានឈរយ៉ាងរឹងមាំនៅខាងភាពត្រឹមត្រូវ។ លោកបានដឹងថាពួកជំនុំមិនត្រូវបានដឹកនាំឲ្យនៅក្រោមការគ្រប់គ្រងនៃអំណាចរបស់មនុស្សឡើយ ។ ប្រពៃណីនិងទ្រឹស្តីរបស់មនុស្សមិនត្រូវជំនួសសេចក្តីពិតដែលបានបង្ហាញទេ។ ការជឿនលឿនទៅមុខនៃដំណឹងល្អមិនត្រូវបានរារាំងដោយការប្រកាន់ពូជសាសន៍ និងសេចក្តីលម្អៀងរបស់មនុស្សទេ ទោះបីជាអ្នកនោះមានតួនាទីនៅក្នុងពួកជំនុំក៏ដោយ។

លោកប៉ុលបានលះបង់ខ្លួនលោកនិងអំណាចទាំងអស់ ដើម្បីបម្រើកិច្ចការរបស់ព្រះ។ លោកបានទទួលសេចក្តីពិតនៃដំណឹងល្អមកពីឋានសួគ៌ដោយផ្ទាល់ ហើយនៅពេញទាំងការបំពេញកិច្ចការរបស់គាត់ លោកនៅតែភ្ជាប់ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងភ្នាក់ងារនៃឋានសួគ៌ដដែល។ លោកធ្លាប់បានទទួលការបង្រៀនពីព្រះ ទាក់ទងនឹងការគោរពភាពមិនចាំបាច់នៃគ្រិស្តបរិស័ទដែលជាសាសន៍ដទៃ ដូច្នេះ នៅពេលដែលពួកអ្នកជឿសាសន៍យូដាបាននាំមកនូវសំណួរស្តីពីការកាត់ស្បែក ចូលមកក្នុងពួកជំនុំនៅអាន់ទីយ៉ូក លោកប៉ុលបានជ្រាបអំពីព្រះតម្រិះនៃព្រះវិញ្ញាណនៃព្រះទាក់ទងនឹងការបង្រៀនបែបនេះ ហើយលោកបានប្រកាន់ជំហររឹងមាំឥតងាករេ ដែលបាននាំឲ្យពួកជំនុំមានសេរីភាពពីពិធីខាងសាសនា និងពិធីបុណ្យផ្សេងៗនៃសាសន៍យូដា ។

ទោះបីជាលោកប៉ុលត្រូវបានបង្រៀនដោយព្រះផ្ទាល់ក៏ដោយ ក៏លោកមិនមានចិត្តធំចង់ទទួលខុសត្រូវដោយខ្លួនឯងដែរ ។ ខណៈដែលលោកសម្លឹងមើលទៅឯព្រះ ដើម្បីការណែនាំដោយផ្ទាល់ លោកតែងតែទទួលស្គាល់អំណាចគ្រប់គ្រងដែលព្រះបានតែងតាំងនៅលើរចនាសម្ព័ន្ធដែលបានរួបរួមគ្នាជាពួកជំនុំនោះដែរ។ លោកបានដឹងពីសេចក្តីត្រូវការនូវដំបូន្មាន ហើយ

កាលណាមានរឿងសំខាន់ៗកើតឡើង លោករីករាយនឹងលាតត្រដាងរឿង នោះនៅចំពោះមុខពួកជំនុំ និងរួបរួមជាមួយបងប្អូនរួមជំនឿរបស់លោក ក្នុងការស្វែងរកប្រាជ្ញាពីព្រះ ដើម្បីធ្វើការសម្រេចចិត្តឲ្យបានត្រឹមត្រូវ។ លោកបានមានប្រសាសន៍ថា សូម្បីតែ «វិញ្ញាណនៃពួកអ្នកដែលអធិប្បាយ នោះនៅក្រោមអំណាចអ្នកនោះឯង ដ្បិតព្រះទ្រង់មិនមែនជាព្រះនៃសេចក្ដីវឹកវរទេ គឺទ្រង់ជាព្រះនៃសេចក្ដីសុខសាន្តវិញ ដូចក្នុងអស់ទាំងពួកជំនុំរបស់ពួកបរិសុទ្ធដែរ» (កូរិនថូសទី១ ១៤:៣២, ៣៣) ។ ជាមួយលោកពេត្រុស លោកបានបង្រៀនថា អ្នកដែលរួបរួមគ្នានៅក្នុងចំណុះពួកជំនុំគួរតែ «មានចិត្តសុភាព ដល់គ្នាទៅវិញទៅមក» (ពេត្រុសទី១ ៥:៥) ។

ជំពូកទី
២០

# ការលើកតម្កើងឈើឆ្កាង

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ១៥:៣៦-៤១ និង ១៦:១-៦ ។*

<u>អង្គារ-២២ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ៣

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ព្រោះសេចក្ដីព្រួយដែលគាប់ព្រះហឫទ័យដល់ព្រះ នោះរមែងនាំឲ្យប្រែចិត្តឡើង ប្រយោជន៍ឲ្យបានសង្គ្រោះ ជាសេចក្ដីដែលមិនត្រូវស្ដាយឡើយ តែសេចក្ដីព្រួយរបស់លោកីយ៍ នោះបង្កើតសេចក្ដីស្លាប់វិញ។ កូរិនថូសទី២ ៧:១០*

បន្ទាប់ពីចំណាយពេលមួយចំនួនដើម្បីបំពេញកិច្ចការនៅទីក្រុងអាន់ទីយ៉ូករួចមក លោកប៉ុលបានស្នើទៅអ្នករួមការងាររបស់លោកឲ្យចេញដំណើរទៅបំពេញបេសកកម្មមួយទៀត ។ លោកប៉ុលបាននិយាយទៅកាន់លោកបាណាបាសថា «ចូរយើងត្រឡប់ទៅសួរពួកបងប្អូន នៅអស់ទាំងក្រុង ជាទីដែលយើងបានផ្សាយព្រះបន្ទូលនៃព្រះអម្ចាស់ផង ដើម្បីឲ្យដឹងពីគេថាជាយ៉ាងដូចម្ដេច» ។

ទាំងលោកប៉ុលនិងលោកបាណាបាសមានចិត្តអាណិតអាសូរដោយស្រទន់ ទៅកាន់អ្នកដែលទើបតែនឹងបានទទួលដំណឹងល្អថ្មីៗនៅក្រោមកិច្ចការរបស់ពួកលោក ហើយលោកទាំងពីរចង់ជួបពួកគេជាថ្មីម្ដងទៀត។ លោកប៉ុលមិនដែលលះបង់កង្វល់នេះឡើយ។ ទោះបីនៅទីឆ្ងាយដែលលោកមិនអាចមើលឃើញកន្លែងដែលលោកធ្លាប់ធ្វើការពីមុនក៏ដោយ ក៏ចិត្តលោកនៅតែបន្តមានពេញទៅដោយបន្ទុកនៃការជំរុញដល់ពួកអ្នកមានជំនឿថ្មីឲ្យនៅតែស្មោះត្រង់ដដែល «ព្រមទាំងបង្ហើយសេចក្ដីបរិសុទ្ធ ដោយនូវសេចក្ដី

កោតខ្លាចដល់ព្រះ»។ កូរិនថូសទី២ ៧:១ ។ លោកបានព្យាយាមជួយពួកគេជាបន្តបន្ទាប់ឲ្យចេះម្ចាស់ការ ជាគ្រិស្តបរិស័ទដែលមានការចម្រើនលូតលាស់ មានជំនឿរឹងមាំ មានចិត្តក្លៀវក្លា ព្រមទាំងលះបង់ថ្វាយដល់ព្រះនិងកិច្ចការនៃការជំរុញនគររបស់ទ្រង់ទៅមុខ ដោយស្មោះអស់ពីចិត្ត ។

លោកបាណាបាសបានរៀបចំខ្លួនរួចជាស្រេច ដើម្បីធ្វើដំណើរទៅជាមួយនឹងលោក ប៉ុល ប៉ុន្តែ លោកមានបំណងចង់យកម៉ាកុស ដែលបានលះបង់ខ្លួនឯងដើម្បីបំពេញកិច្ចការម្តងទៀត ទៅជាមួយ ប៉ុន្តែ លោកប៉ុលមិនព្រម។ លោក «បានគិតថាការយកម៉ាកុសទៅជាមួយនឹងពួកលោកនោះមិនល្អទេ ... » ពីព្រោះនៅក្នុងដំណើរបំពេញបេសកកម្មលើកមុនលោកបានរត់ចោលពួកគេ នៅពេលដែលមានសេចក្តីត្រូវការចាំបាច់។ លោកមិនបានបន្ធូរ់ចិត្តអត់ឱនទោសដល់ភាពកម្សោយរបស់លោកម៉ាកុសក្នុងការរត់ចោលការងារដើម្បីសុវត្ថិភាពនិងសុខុមាលភាពផ្ទាល់ខ្លួននោះឡើយ។ លោកបានជំរុញថាអ្នកដែលមានសមត្ថភាពទ្រាំទ្រតិច មិនសមនឹងកិច្ចការដែលទាមទារឲ្យមានការអត់ធ្មត់ ការលះបង់ខ្លួនឯង សេចក្តីក្លាហាន ជំនឿរឹងមាំ និងឆន្ទៈនៃការលះបង់ រហូតដល់ហ៊ានលះបង់ជីវិតផង ប្រសិនបើចាំបាច់នោះឡើយ។ ដូច្នេះ លោកប៉ុលនិងបាណាបាសមានការខ្វែងគំនិតគ្នាជាខ្លាំង បន្ទាប់ពីការស្តីបន្ទោសនិងការមិនយកលោកម៉ាកុសទៅជាមួយ។ «ឯបាណាបាស គាត់យកម៉ាកុស ចុះសំពៅទៅឯកោះគីប្រុស តែប៉ុល គាត់រើសយកស៊ីឡាសវិញ ហើយចេញដំណើរទៅ ដោយមានពួកជំនុំផ្ទុកផ្តាក់ក្នុងព្រះគុណនៃព្រះអម្ចាស់»។

នោះគាត់ដើរកាត់ស្រុកស៊ីរី និងស្រុកគីលីគា ក៏តាំងឲ្យពួកជំនុំទាំងប៉ុន្មានបានខ្ជាប់ខ្ជួនឡើង លោកប៉ុលនិងស៊ីឡាសបានមើលឃើញស្រុកឌើបេ និងក្រុងលីស្ត្រាដែលនៅក្នុងខេត្ត លូកៅនា ពីចម្ងាយ។ គឺនៅក្រុងលីស្ត្រានេះហើយដែលលោកប៉ុលត្រូវបានពួកបណ្តាជនចោលនឹងថ្ម ហើយឥឡូវនេះយើងបានឃើញលោកនៅកន្លែងដែលធ្លាប់មានគ្រោះថ្នាក់កាលពីមុននេះម្តងទៀត ។ លោកអន្ទះសារចង់ឃើញអ្នកដែលបានទទួលដំណឹងល្អតាម

របៈបេសកកម្មរបស់លោករងទ្រាំនឹងការសាកល្បងនៃការពិបាក។ លោកមិនបានខកចិត្តឡើយ ព្រោះលោកបានឃើញពួកអ្នកជឿនៅលីស្ត្រា នៅតែរឹងមាំ នៅចំពោះមុខការប្រឆាំងយ៉ាងឃោរឃៅដដែល ។

**ពុធ-២៣ កញ្ញា អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ៤**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ខ្ញុំចង់និយាយដូច្នេះ គឺថា អ្នកណាដែលព្រោះដោយកំណាញ់ នោះនឹងច្រូតបានតិច ហើយអ្នកណាដែលព្រោះដោយសទ្ធា នោះនឹងច្រូតបានច្រើនវិញ ចូរឲ្យគ្រប់គ្នាធ្វើតាមដែលសំរេចក្នុងចិត្តចុះ មិនមែនដោយស្តាយ ឬដោយបង្ខំឡើយ ដ្បិតព្រះទ្រង់ស្រឡាញ់ដល់អ្នកណាដែលថ្វាយដោយអំណរ។ កូរិនថូសទី២ ៩:៦-៧*

នៅទីនេះលោកប៉ុលបានជួបនឹងលោកធីម៉ូថេម្តងទៀត ជាអ្នកដែលបានឃើញការឈឺចាប់របស់លោកនៅចុងបំផុតនៃបេសកកម្មរបស់លោកនៅក្រុងលីស្ត្រា និងជាអ្នកដែលមានចិត្តជិតដាមដោយសកម្មភាពនៃការធ្វើទារុណកម្មនៅពេលនោះ ដែលបានធ្វើឲ្យលោកមានការឈឺចាប់នៅពេលដែលបានកន្លងផុតទៅ រហូតដល់លោកបានជឿថាលោកមានភារកិច្ចត្រូវលះបង់ខ្លួនទាំងស្រុងដើម្បីបំពេញបេសកកម្មថ្វាយព្រះ។ ចិត្តរបស់ធីម៉ូថេត្រូវបានផ្សាភ្ជាប់ទៅនឹងចិត្តរបស់លោកប៉ុល ហើយចង់ចែករំលែកកិច្ចការរបស់សាវ័កនេះដោយជួយដល់លោកនៅពេលណាដែលផ្លូវបានបើកចំហ។

លោកស៊ីឡាស ដែលជាដៃគូរួមការងាររបស់លោកប៉ុល គឺជាអ្នកធ្វើការដ៏មានបទពិសោធន៍ ដែលមានអំណោយទានខាងវិញ្ញាននៃសេចក្តីទំនាយ ប៉ុន្តែ កិច្ចការដែលត្រូវបង្ហើយនោះធំធេងពេកដែលតម្រូវឲ្យមានអ្នកធ្វើការហ្វឹកហ្វឺនអ្នកធ្វើការដ៏សកម្មបន្ថែមទៀត។ លោកប៉ុលបានមើលឃើញនៅក្នុងជីវិតលោកធីម៉ូថេ ថាលោកជាមនុស្សដែលមានគុណតម្លៃសម្រាប់ភាពពិសិដ្ឋនៃកិច្ចការជាគ្រូគង្វាល ដែលមិនតក់ស្លុតចំពោះការឈឺចាប់និងការបៀតបៀនដែលនឹងកើតឡើងនៅពេលខាងមុខ និងជាអ្នកដែលចង់រៀន

សូត្រ។ ប៉ុន្តែ លោកប៉ុលមិនហ៊ានប្រថុយទទួលខុសត្រូវក្នុងការផ្តល់ឱកាសឲ្យលោកធីម៉ូថេ ជាយុវជនដែលមិនទាន់មានបទពិសោធន៍គ្រប់គ្រាន់ ហ្វឹកហ្វឺនក្នុងកិច្ចការនៃដំណឹងល្អ ដោយមិនបានបំពេញបន្ថែមខាងអត្តចរិតនិងជីវិតអតីតកាល ដល់គេនោះឡើយ។

ឪពុកលោកធីម៉ូថេជាសាសន៍ក្រិកហើយម្តាយជាសាសន៍យូដា។ លោកបានស្គាល់ព្រះគម្ពីរតាំងពីក្មេងមក ។ ការស្រឡាញ់និងការគោរពសាសនាដែលលោកបានឃើញនៅក្នុងគ្រួសាររបស់លោកមានភាពរឹងមាំនិងម៉ត់ចត់។ ជំនឿរបស់ម្តាយនិងជីដូនលោកទៅលើក្រឹត្យវិន័យដ៏ពិសិដ្ឋ គឺជាការរំឭកជាបន្តបន្ទាប់ដល់លោកអំពីព្រះពរក្នុងការធ្វើតាមព្រះហឫទ័យរបស់ព្រះ។ ព្រះបន្ទូលរបស់ព្រះគឺជាបន្ទាត់ដែលស្ត្រីជឿព្រះទាំងពីរនាក់នេះបានដឹកនាំធីម៉ូថេ។ អំណាចនៃមេរៀនខាងវិញ្ញាណ ដែលលោកបានទទួលពីលោកទាំងពីរ បានរក្សាលោកឲ្យមានភាពបរិសុទ្ធក្នុងការនិយាយស្តី និងមិនសៅហ្មងដោយឥទ្ធិពលអាក្រក់ដែលនៅព័ទ្ធជុំវិញលោក  ដូច្នេះ គ្រូបង្រៀនប្រចាំគ្រួសារ (ម្តាយនិងជីដូន) របស់លោកបានសហការជាមួយនឹងព្រះក្នុងការរៀបចំលោកសម្រាប់ទទួលបន្ទុកទាំងនេះ ។

លោកប៉ុលបានមើលឃើញថាធីម៉ូថេគឺជាមនុស្សស្មោះត្រង់ រឹងមាំ និងទៀងត្រង់ ហើយលោកបានជ្រើសរើសគាត់ជាដៃគូក្នុងការធ្វើការនិងការធ្វើដំណើរ ។ អ្នកដែលធ្លាប់បានបង្រៀនដល់ធីម៉ូថេកាលពីកុមារទទួលបានរង្វាន់ដោយបានឃើញកូនចៅដែលខ្លួនធ្លាប់បានថែរក្សាបានភ្ជាប់ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងសាវ័កដ៏ឧត្តមនេះ។ ធីម៉ូថេនៅជាយុវជននៅឡើយនៅពេលដែលព្រះបានជ្រើសរើសលោកឲ្យធ្វើជាគ្រូបង្រៀន ប៉ុន្តែ លោកបានស្ថាបនាគោលការណ៍នេះដោយការសិក្សាដំបូងរបស់លោក ដែលធ្វើឲ្យលោកមានសមត្ថភាពទទួលតំណែងជាអ្នកជំនួយការរបស់លោកប៉ុល ។ ទោះបីជានៅក្មេងនៅឡើយក៏ដោយ ក៏លោកបានបំពេញការទទួលខុសត្រូវដោយភាពស្លូតបូតនៃគ្រិស្តបរិស័ទដែរ ។

ជាវិធានការនៃការប្រុងប្រយ័ត្ន លោកប៉ុលបានបំបែកធីម៉ូថេយ៉ាងប្រុង

ប្រយ័ត្នឲ្យទទួលការកាត់ស្បែក មិនមែនតាមតម្រូវការរបស់ព្រះទេ ប៉ុន្តែ ដើម្បីដកយកការប្រឆាំងចេញពីគំនិតពួកយូដា ទៅនឹងការគ្រប់គ្រងរបស់លោកធីម៉ូថេ ។ នៅក្នុងកិច្ចការរបស់លោក លោកប៉ុលត្រូវធ្វើដំណើរពីទីក្រុងមួយទៅទីក្រុងមួយ នៅក្នុងទឹកដីជាច្រើន ហើយលោកតែងតែមានឱកាសអធិប្បាយអំពីព្រះគ្រិស្ត នៅក្នុងសាលាប្រជុំរបស់សាសន៍យូដា ព្រមទាំងនៅកន្លែងប្រជុំគ្នាផ្សេងៗទៀតផងដែរ ។ ប្រសិនបើគេបានដឹងថាមិត្តរួមការងាររបស់លោកម្នាក់មិនបានកាត់ស្បែកទេ នោះកិច្ចការរបស់លោកនឹងមានការរារាំងយ៉ាងខ្លាំងក្លាពីសំណាក់ពួកយូដាដែលប្រកាន់ពូជសាសន៍និងជាអ្នកដែលឈ្លក់វង្វេងនឹងសាសនា ។ សាវ័កប៉ុលបានជួបនឹងការប្រឆាំងយ៉ាងតឹងតែងនិងការធ្វើទុក្ខបៀតបៀនយ៉ាងធ្ងន់ធ្ងរ ។ លោកប្រាថ្នាចង់នាំចំណេះដឹងនៃដំណឹងល្អមកជូនដល់បងប្អូនរបស់លោកដែលជាសាសន៍យូដា ព្រមទាំងសាសន៍ដទៃផងដែរ ហេតុដូច្នោះហើយបានជាលោកបានខំប្រឹងប្រែងដោយសេចក្ដីជំនឿ កន្លងមកនិងជាបន្តបន្ទាប់ ដើម្បីកម្ចាត់ចោលនូវលេសទាំងឡាយដែលនាំឲ្យមានការប្រឆាំង។ ហើយនៅពេលដែលលោកបានយល់ព្រមទៅនឹងការប្រកាន់ពូជសាសន៍របស់សាសន៍យូដានេះ លោកបានបង្រៀនថាការកាត់ស្បែកនិងការមិនកាត់ស្បែកមិនមានបញ្ហាអ្វីទេ ហើយដំណឹងល្អរបស់ព្រះគ្រិស្តគឺជាអ្វីៗគ្រប់យ៉ាង។

<u>ព្រហស្បតិ៍-២៤ កញ្ញា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ៥**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ព្រះគុណនៃព្រះ ដែលនាំសេចក្ដីសង្គ្រោះមកដល់មនុស្សទាំងឡាយ បានលេចមកហើយ ទាំងបង្ហាត់បង្រៀនយើងរាល់គ្នា ឲ្យលះចោលសេចក្ដីទមិលល្មើស និងសេចក្ដីប៉ងប្រាថ្នាក្នុងលោកនេះ ហើយឲ្យរស់នៅក្នុងសម័យនេះ ដោយសេចក្ដីធ្ងន់ធ្ងរ សេចក្ដីសុចរិត ហើយដោយគោរពប្រតិបត្តិដល់ព្រះវិញ ។ ទីតុស ២:១១-១២*

លោកប៉ុលបានស្រឡាញ់លោកធីម៉ូថេ ថា «ជាកូនពិតក្នុងសេចក្ដីជំនឿ» (ធីម៉ូថេទី១ ១:២) ។ សាវ័កដ៏ឧត្ដមនេះតែងតែនាំសាវ័កដ៏ក្មេងខ្ចីនេះចេញទៅខាងក្រៅ សួរសំណួរដែលទាក់ទងទៅនឹងព្រះគម្ពីរដល់លោក ហើយកាលពួកគេបានធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយជាមួយគ្នា លោកបានបង្រៀនដល់ធីម៉ូថេយ៉ាងប្រុងប្រយ័ត្នអំពីរបៀបធ្វើការដែលមានជោគជ័យ។ ទាំងលោកប៉ុលនិងស៊ីឡាសបានស្វះស្វែងធ្វើយ៉ាងណាឲ្យភាពពិសិដ្ឋនៃកិច្ចការខាងដំណឹងល្អដិតដាមកាន់តែជ្រៅនៅក្នុងចិត្តរបស់ធីម៉ូថេ ដែលលោកបានដក់ជាប់នៅក្នុងគំនិតរួចទៅហើយនោះ នៅពេលដែលលោកបានប្រស្រ័យទាក់ទងជាមួយនឹងគាត់ ។

នៅក្នុងកិច្ចការរបស់លោក ធីម៉ូថេតែងតែស្វែងរកដំបូន្មាននិងការបង្រៀនពីលោកប៉ុល លោកមិនបានធ្វើការតាមកំសួលចិត្តទេ ប៉ុន្តែ លោកអនុវត្តការពិចារណានិងគំនិតរស្ងៀមស្ងាត់វិញ ដោយសួរខ្លួនឯងនៅគ្រប់ទាំងជំហានថា តើនេះគឺជាផ្លូវរបស់ព្រះឬមិនមែន? គេរកឃើញព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតលោកដែលអាចធ្វើជាគំរូនិងបានបង្ហាញជាព្រះវិហារដែលមានព្រះវត្តមានរបស់ព្រះគង់នៅ ។

ខណៈដែលពួកគេបានអនុវត្តមេរៀននៃព្រះគម្ពីរនៅក្នុងជីវិតប្រចាំថ្ងៃ ពួកគេមានអត្តចរិតដែលមានឥទ្ធិពលយ៉ាងជ្រាលជ្រៅនិងយូរអង្វែង។ លោកមិនមានទេពកោសល្យអ្វីត្រចះត្រចង់នោះទេ ប៉ុន្តែ កិច្ចការរបស់លោកមានតម្លៃ ព្រោះលោកបានប្រើសមត្ថភាពដែលព្រះបានប្រទានឲ្យ សម្រាប់បម្រើកិច្ចការរបស់ព្រះជាម្ចាស់ ។ ចំណេះដឹងខាងការគោរពនិងស្រឡាញ់សាសនារបស់លោកបានធ្វើឲ្យលោកខុសប្លែកពីអ្នកជឿដទៃ ហើយបានផ្ដល់ឥទ្ធិពលដល់លោកថែមទៀតផង។

អស់អ្នកដែលធ្វើការដើម្បីមនុស្ស ត្រូវតែសម្រេចបាននូវចំណេះដឹងអំពីព្រះ យ៉ាងជ្រាលជ្រៅ ពេញលេញ និងច្បាស់លាស់ ជាងការទទួលបានពីការខំប្រឹងប្រែងតាមវិធីធម្មតាដទៃផ្សេងៗទៀត។ ពួកគេត្រូវតែដាក់ថាមពលរបស់គេទាំងអស់ចូលទៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់។ ពួកគេបានចូលរួម

នៅក្នុងការត្រាស់ហៅដ៏ខ្ពង់ខ្ពស់និងបរិសុទ្ធ ហើយប្រសិនបើពួកគេទទួលបានមនុស្សសម្រាប់ជាថ្លៃឈ្នួលរបស់ពួកគេ គេត្រូវតែតោងព្រះឲ្យជាប់ ដោយទទួលព្រះគុណនិងព្រះចេស្តាមកពីព្រះដែលជាប្រភពនៃព្រះពរទាំងអស់។ «ព្រះគុណនៃព្រះ ដែលនាំសេចក្តីសង្គ្រោះមកដល់មនុស្សទាំងឡាយ បានលេចមកហើយ ទាំងបង្ហាត់បង្រៀន យើងរាល់គ្នាឲ្យលះចោលសេចក្តីទមិឡល្មើស និងសេចក្តីប៉ងប្រាថ្នាក្នុងលោកនេះ ហើយឲ្យរស់នៅក្នុងសម័យនេះ ដោយសេចក្តីធូន់ធូរ សេចក្តីសុចរិត ហើយដោយគោរពប្រតិបត្តិដល់ព្រះវិញ ទាំងរង់ចាំសេចក្តីសង្ឃឹមដ៏មានពរ គឺឲ្យបានឃើញដំណើរលេចមកនៃសិរីល្អរបស់ព្រះដ៏ជាធំ និងព្រះយេស៊ូវគ្រិស្ត ជាព្រះអង្គសង្គ្រោះនៃយើង ដែលទ្រង់បានថ្វាយព្រះអង្គទ្រង់ជំនួសយើងរាល់គ្នា ដើម្បីនឹងលោះយើងឲ្យរួចពីគ្រប់ទាំងសេចក្តីទទឹងច្បាប់ ហើយនិងសម្អាតមនុស្សមួយពួក ទុកដាច់ជារាស្ត្ររបស់ផងទ្រង់ ដែលឧស្សាហ៍ធ្វើការល្អ» (ទីតុស ២:១១-១៤) ។

មុននឹងចូលទៅកាន់ទឹកដីថ្មី លោកប៉ុលនិងគូកនរបស់លោកបានចូលទៅឯពួកជំនុំដែលបានបង្កើតឡើងនៅភីស៊ីឌា និងតំបន់ទាំងឡាយដែលនៅជុំវិញ ។ «កំពុងដែលដើរកាត់អស់ទាំងទីក្រុង នោះក៏ប្រគល់សេចក្តីបញ្ញត្តិទាំងប៉ុន្មានដល់គេ ជាសេចក្តីដែលពួកសាវ័ក និងពួកចាស់ទុំ ដែលនៅក្រុងយេរូសាឡិម បានជំនុំសម្រេចឲ្យកាន់តាម»។

សាវ័កប៉ុលមានការទទួលខុសត្រូវយ៉ាងជ្រាលជ្រៅ ចំពោះពួកអ្នកដែលបានផ្លាស់ប្តូរជំនឿដោយសារការងាររបស់លោក។ ពិសេសលើសអ្វីៗទាំងអស់ លោកចង់ឲ្យពួកគេបានស្មោះត្រង់ លោកបានមានប្រសាសន៍ថា«ដើម្បីដល់ថ្ងៃនៃព្រះគ្រិស្ត នោះឲ្យខ្ញុំបានសេចក្តីអំនួត អួតថា ខ្ញុំមិនបានរត់ ឬខំប្រឹងធ្វើការជាឥតប្រយោជន៍ឡើយ» (ភីលីព ២:១៦) ។ លោកមានការរន្ធត់ចំពោះលទ្ធផលនៃកិច្ចការរបស់លោក ។ លោកបានដឹងថាសូម្បីតែសេចក្តីសង្គ្រោះរបស់លោកផ្ទាល់ ក៏នឹងត្រូវអន្តរាយដែរ ប្រសិនបើលោកបរាជ័យមិនបានបំពេញភារកិច្ចរបស់លោក ហើយពួកជំនុំបរាជ័យមិនបានសហការជាមួយលោកក្នុងការនេសាទមនុស្សនោះ ។ លោកបានដឹងថាការអធិប្បាយតែមួយ

មុខក៏មិនគ្រប់គ្រាន់ដើម្បីនឹងអប់រំដល់ពួកអ្នកជឿ ឲ្យប្រកាន់ខ្ជាប់នូវព្រះបន្ទូលនៃជីវិតដែរ។ លោកបានដឹងថាត្រូវតែបង្រៀនដល់ពួកគេ មួយបន្ទាត់ហើយមួយបន្ទាត់ទៀត គំនិតមួយហើយមួយទៀត ត្រង់នេះបន្តិច ត្រង់នោះបន្តិច ដើម្បីជំរុញកិច្ចការរបស់ព្រះគ្រិស្ត។

<u>សុក្រ-២៥ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ៦

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *នោះទ្រង់បានជួយសង្គ្រោះយើង មិនមែនដោយការដែលយើងបានប្រព្រឹត្តដោយសុចរិតនោះទេ គឺដោយសេចក្តីមេត្តាករុណារបស់ទ្រង់វិញ ដោយសារការសំអាតនៃសេចក្តីកើតជាថ្មី ហើយការប្រោសជាថ្មីឡើងវិញ នៃព្រះវិញ្ញាណបរិសុទ្ធ។ ទីតុស ៣:៥*

គឺជាគោលការណ៍យ៉ាងវិសេសខុសពីធម្មតា ដែលថានៅពេលដែលអ្នកណាម្នាក់បដិសេធនមិនព្រមប្រើព្រះចេស្តាដែលព្រះបានប្រទានឲ្យ អំណាចនេះនឹងត្រូវពុករលួយនិងវិនាសបាត់ទៅ។ សេចក្តីពិតដែលមិនមានជីវិត ដែលមិនចាកចេញទៅ នឹងបាត់បង់អំណាចនៃការផ្តល់ជីវិត និងគុណសម្បត្តិនៃការប្រោសឲ្យជារបស់ខ្លួន។ ហេតុនេះការភ័យខ្លាចរបស់លោកប៉ុលគឺក្រែងលោកមិនបានបង្ហាញភាពគ្រប់លក្ខណ៍នៅក្នុងព្រះគ្រិស្ត ដល់មនុស្សរាល់គ្នា សេចក្តីសង្ឃឹមរបស់លោកប៉ុលគឺថាឋានសួគ៌នឹងត្រឡប់ជាស្រអាប់ នៅពេលដែលលោកបានសញ្ជឹងគិតអំពីការបរាជ័យទៅលើផ្នែកណាមួយរបស់លោក ដែលជាលទ្ធផលនៃការផ្តល់គំរូរបស់មនុស្សដល់ពួកជំនុំ ផ្ទុយពីជាគំរូរបស់ព្រះ ។ ចំណេះដឹងរបស់លោក វោហារ ការអស្ចារ្យ ទស្សនៃទស្សនីយភាពដ៏អស់កល្បរបស់លោក នៅពេលដែលលោកបានសម្លឹងមើលឋានសួគ៌ជាន់ទីបី ទាំងអស់នេះនឹងទៅជាឥតប្រយោជន៍ ប្រសិនបើអ្នកដែលលោកធ្វើការបម្រើខកខានមិនបានទទួលព្រះគុណរបស់ព្រះ ដោយសារតែភាពមិនស្មោះត្រង់ទៅនឹងការងាររបស់លោក។ ដូច្នេះហើយដោយពាក្យសម្តី និងដោយសំបុត្រ លោកបានអង្វរករដល់អ្នកដែលបានទទួលព្រះគ្រិស្តឲ្យស្វែងរកកិច្ចការដែលអាចនឹងធ្វើឲ្យពួកគេ «បានឥតសៅហ្មង ឥតកិច្ចកល ជាកូន

ព្រះដែលរកបន្ទោសមិនបាននៅក្នុងដំណមនុស្សវៀច ហើយខិលខូច ... ដូចជាតួពន្លឺនៅក្នុងលោក ទាំងហុចព្រះបន្ទូលនៃជីវិតដល់គេ ដើម្បីដល់ថ្ងៃនៃព្រះគ្រិស្ត នោះឲ្យខ្ញុំបានសេចក្តីអំនួតអួតថា ខ្ញុំមិនបានរត់ ឬខំប្រឹងធ្វើការជាឥតប្រយោជន៍ឡើយ» (ភីលីព ២:១៥, ១៦) ។

គ្រូគង្វាលដ៏ស្មោះត្រង់គ្រប់រូបមានការទទួលខុសត្រូវយ៉ាងធ្ងន់ ចំពោះការជឿនលឿនខាងវិញ្ញាណនៃពួកជំនុំ ដែលនៅក្រោមការថែរក្សារបស់ខ្លួន ជាសេចក្តីប្រាថ្នាដ៏ទទូចដែលពួកគេគួរធ្វើការជាមួយនឹងព្រះ។ គេដឹងថា សុខុមាលភាពរបស់ពួកជំនុំពឹងផ្អែកទាំងស្រុងទៅលើការបំពេញកិច្ចការដែលព្រះប្រទានឲ្យដល់គ្រូគង្វាល។ លោកស្វះស្វែងលើកទឹកចិត្តដល់ពួកអ្នកជឿ ដោយស្មោះត្រង់និងមិនងាករេ ដោយមានបំណងចង់នេសាទមនុស្សថ្វាយព្រះគ្រិស្ត និងចងចាំថាមនុស្សរាល់គ្នា ដែលបន្ថែមទៅក្នុងពួកជំនុំ នឹងក្លាយទៅជាភ្នាក់ងារម្នាក់ទៀត សម្រាប់អនុវត្តផែនការនៃការប្រោសលោះ។

ដោយការចូលទៅសួរសុខទុក្ខពួកជំនុំនៅភីស៊ីឌា និងតំបន់ដែលនៅជុំវិញ លោកប៉ុល ស៊ីឡាស និងធីម៉ូថេ បានដើរកាត់ «ស្រុកព្រីគា និងដែនខេត្តកាឡាទី» ជាកន្លែងដែលពួកលោកបានប្រកាសពីដំណឹងល្អនៃសេចក្តីសង្គ្រោះដោយអំណាចដ៏អស្ចារ្យ។ ពួកស្រុកកាឡាទីបានបោះបង់ការថ្វាយបង្គំរូបព្រះចេញ ប៉ុន្តែ នៅពេលដែលពួកសាវ័កបានអធិប្បាយប្រាប់ពួកគេ គេមានអំណរជាមួយនឹងសារដែលបានសន្យាពីសេរីភាពចេញពីទាសករនៃអំពើបាប ។ លោក ប៉ុលនិងសហាការីរបស់លោកបានប្រកាសអំពីគោលលទ្ធិនៃសេចក្តីសុចរិត ដោយសារសេចក្តីជំនឿនៅក្នុងតង្វាយយញ្ញបូជាឲ្យធួននឹងបាបរបស់ព្រះគ្រិស្ត។ ពួកគេបានបង្ហាញពីព្រះគ្រិស្តថាជាព្រះដែលបានទតឃើញស្ថានភាពអស់សង្ឃឹមរបស់មនុស្សលោក និងបានយាងមកដើម្បីប្រោសលោះបុរសនារីទាំងឡាយដោយលះបង់ព្រះជន្ម ក្នុងការស្តាប់បង្គាប់តាមក្រឹត្យវិន័យរបស់ព្រះ និងដោយបង់ថ្លៃទណ្ឌកម្មនៃការមិនស្តាប់បង្គាប់។ ហើយនៅក្នុងពន្លឺនៃឋានសួគ៌ មនុស្សជាច្រើនដែលមិនធ្លាប់ស្គាល់សេចក្តីពិតរបស់ព្រះកន្លងមក បានចាប់ផ្តើមយល់ពីភាព ឧត្តមនៃសេចក្តីស្រឡាញ់

របស់ព្រះវរបិតា។

ដូច្នេះ លោកបានបង្រៀនដល់អ្នកស្រុកកាឡាទីអំពីសេចក្ដីពិតដែលជាគ្រឹះ ទាក់ទងទៅនឹង «ព្រះវរបិតា» និង «ព្រះយេស៊ូវគ្រិស្ត ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានប្រគល់ព្រះអង្គទ្រង់ទៅ ដោយព្រោះបាបយើងរាល់គ្នា ដើម្បីនឹងប្រោសឲ្យយើងបានរួចពីលោកិយ ដ៏អាក្រក់សព្វថ្ងៃនេះ តាមបំណងព្រះហឫទ័យរបស់ព្រះដ៏ជាព្រះវរបិតានៃយើង»។ «ដោយបានស្ដាប់ ទាំងមានសេចក្ដីជំនឿ» ពួកគេបានទទួលព្រះវិញ្ញាណនៃព្រះ ហើយបានក្លាយជា «ជាកូនព្រះ ដោយសារសេចក្ដីជំនឿជឿដល់ព្រះគ្រិស្តយេស៊ូវ» (កាឡាទី ១:៣, ៤ និង ៣:២, ២៦) ។

**<u>សៅរ៍-២៦ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ៧**

**ខព្រះគម្ពីរប្រចាំសប្ដាហ៍:** *បងប្អូនអើយ ព្រះទ្រង់បានហៅអ្នករាល់គ្នាមក ឲ្យមានសេរីភាព តែកុំឲ្យប្រើសេរីនោះ ទុកជាឱកាសដល់សាច់ឈាមឡើយ គឺត្រូវបំរើគ្នាទៅវិញទៅមក ដោយសេចក្ដីស្រឡាញ់វិញ។ កាឡាទី ៥:១៣*

លក្ខណៈនៃជីវិតរបស់លោកប៉ុល កាលដែលលោកបាននៅជាមួយនឹងពួកជំនុំកាឡាទី ជាជីវិតដែលក្រោយមកលោកអាចមានប្រសាសន៍ថា «ខ្ញុំសូមអង្វរឲ្យអ្នករាល់គ្នាបានដូចខ្ញុំ» (កាឡាទី ៤:១២) ។ បបូរមាត់លោកត្រូវបានដុតដោយរងើកភ្លើង ដែលចេញមកពីអាសនា ហើយព្រះអាចលើកតម្កើងលោកឲ្យផុតពីគុណវិប្បត្តិទាំងឡាយ យ៉ាងអង់អាច ហើយអាចបង្ហាញពីព្រះយេស៊ូវថាជាក្ដីសង្ឃឹមតែមួយគត់របស់បាបជន ។ អស់អ្នកដែលបានឮលោកនិយាយបានដឹងថាលោកបាននៅជាមួយនឹងព្រះយេស៊ូវ ។ ដោយបានទទួលព្រះចេស្ដាមកពីឋានលើ លោកអាចប្រៀបធៀបរឿងរ៉ាវខាងព្រលឹងវិញ្ញាណ ជាមួយនឹងព្រលឹងវិញ្ញាណ និងអាចបំផ្លាញបន្ទាយរបស់សាតាំងផង ។ ចិត្តរបស់មនុស្សជាច្រើនត្រូវបានខ្ទេចខ្ទាំ ដោយការបង្ហាញពីសេចក្ដីស្រឡាញ់របស់ព្រះ ដែលបានបង្ហាញនៅក្នុងការលះបង់ព្រះរាជបុត្រាជាទីស្រឡាញ់តែមួយរបស់ព្រះអង្គ ហើយមនុស្សជាច្រើនត្រូវ

បានដឹកនាំឲ្យសួរសំណួរថា តើខ្ញុំត្រូវធ្វើដូចម្ដេចដើម្បីឲ្យបានសង្គ្រោះ?

វិធីសាស្ត្របង្ហាញពីដំណឹងល្អនេះគឺជាលក្ខណៈនៃកិច្ចការរបស់សាវ័កប៉ុល នៅពេញទាំងបេសកកម្មរបស់ពួកលោក ក្នុងចំណោមសាសន៍ដទៃ ។ លោកតែងតែបង្ហាញពីឈើឆ្កាងនៅចំពោះមុខពួកគេ។ លោកបានមានប្រសាសន៍នៅប៉ុន្មានឆ្នាំក្រោយនៃបេសកកម្មរបស់លោកថា «យើងខ្ញុំមិនប្រកាសប្រាប់ពីខ្លួនយើងខ្ញុំទេ គឺពីព្រះគ្រិស្តយេស៊ូវ ជាព្រះអម្ចាស់វិញ ហើយក៏រាប់ខ្លួនយើងខ្ញុំ ថាជាបាវបម្រើរបស់អ្នករាល់គ្នា ដោយព្រោះព្រះយេស៊ូវដែរ ដ្បិតគឺជាព្រះ ដែលមានព្រះបន្ទូលបង្គាប់ ឲ្យមានពន្លឺភ្លឺចេញពីសេចក្ដីងងឹត ទ្រង់បានបំភ្លឺមកក្នុងចិត្តយើងខ្ញុំ ឲ្យយើងខ្ញុំមានរស្មីពន្លឺនៃដំណើរស្គាល់សិរីល្អរបស់ព្រះ ដែលនៅព្រះភក្ត្រនៃព្រះយេស៊ូវគ្រិស្ត» (កូរិនថូសទី២ ៤:៥, ៦)។

អ្នកនាំសារដែលមានការលះបង់ ដែលបានពាំនាំដំណឹងល្អនៃសេចក្ដីសង្គ្រោះមកជូនពិភពលោកដែលត្រូវវិនាសនៅសម័យគ្រិស្តបរិស័ទដំបូង មិនបានអនុញ្ញាតឲ្យមានគំនិតនៃការលើកតម្កើងខ្លួនឯង មកធ្វើឲ្យស្រអាប់ដល់ការបង្ហាញពីព្រះគ្រិស្ត និងការជាប់ឆ្កាងរបស់ទ្រង់ឡើយ។ ពួកគេក៏មិនបានលោភលន់ចង់បានអំណាចឬភាពប្រសើរដាច់គេដែរ ។ ដោយលាក់ទុកភាពអាត្មានិយមនៅពីក្រោយព្រះអង្គសង្គ្រោះ ពួកគេបានលើកតម្កើងផែនការនៃសេចក្ដីសង្គ្រោះ និងព្រះជន្មរបស់ព្រះគ្រិស្ត ដែលជាអ្នករៀបចំ និងជាអ្នកបញ្ចប់ផែនការនេះ។ ព្រះគ្រិស្ត ដែលនៅដដែលតាំងពីម្សិលមិញ ថ្ងៃនេះ និងរហូតដល់អស់កល្ប គឺជាបន្ទុកនៃការបង្រៀនរបស់ពួកគេ។

ប្រសិនបើអ្នកដែលបង្រៀនអំពីព្រះបន្ទូលរបស់ព្រះនៅពេលសព្វថ្ងៃនេះ បានលើកតម្កើងឈើឆ្កាងឲ្យខ្ពស់ ហើយនៅតែខ្ពស់ នោះកិច្ចការរបស់ពួកគេនឹងមានជោគជ័យកាន់តែខ្លាំងឡើងៗ។ ប្រសិនបើគេអាចដឹកនាំឲ្យបាបជនម្នាក់សម្លឹងមើលទៅឯឈើឆ្កាង ប្រសិនបើពួកគេអាចនៅតែសម្លឹងមើលយ៉ាងពេញលេញទៅកាន់ព្រះអង្គសង្គ្រោះ ដែលត្រូវបានគេឆ្កាង ពួកគេនឹងដឹងអំពីជម្រៅនៃការអាណិតអាសូររបស់ព្រះ និងទម្ងន់នៃអំពើបាប។

ការសុគតរបស់ព្រះគ្រិស្តបង្ហាញអំពីសេចក្ដីស្រឡាញ់របស់ព្រះចំពោះ

មនុស្ស។ គឺជាពាក្យសច្ចានៃសេចក្តីសង្គ្រោះរបស់យើង។ ការដកយកឈើឆ្កាងចេញពីគ្រិស្តបរិស័ទ ប្រៀបដូចជាយកព្រះអាទិត្យចេញពីផ្ទៃមេឃ។ ឈើឆ្កាងនាំយើងទៅកាន់តែកៀកនឹងព្រះ ផ្សះផ្សាយើងជាមួយនឹងព្រះអង្គ។ ជាមួយនឹងការអាណិតអាសូរដ៏ស្រទន់នៃព្រះវរបិតា ព្រះយេហូវ៉ាបានទតមើលមកការឈឺចាប់ដែលព្រះរាជបុត្រាបានរងទ្រាំ ដើម្បីជួយសង្គ្រោះមនុស្សលោកឲ្យរួចពីសេចក្តីស្លាប់អស់កល្ប ហើយទទួលយើងជាកូនស្ងួនភ្ងា ។

បើគ្មានឈើឆ្កាងទេ មនុស្សមិនអាចរួបរួមជាមួយនឹងព្រះវរបិតាបានឡើយ។ សេចក្តីសង្ឃឹមទាំងឡាយរបស់យើងទីពឹងទៅលើឈើឆ្កាងនេះឯង។ សេចក្តីស្រឡាញ់នៃព្រះអង្គសង្គ្រោះបានចែងចេញពីឈើឆ្កាងនេះ ហើយនៅពេលដែលមនុស្សមានបាបសម្លឹងមើលទៅព្រះដែលបានសុគតដើម្បីជួយសង្គ្រោះរូបគេ នៅទៀបជើងឈើឆ្កាង ពួកគេនឹងមានអំណរដ៏ពោរពេញព្រោះបាបរបស់ពួកគេបានអត់ទោសឲ្យហើយ។ ដោយលុតជង្គង់នៅក្បែរឈើឆ្កាង គេបានឈានដល់កន្លែងដ៏ខ្ពស់បំផុតដែលមនុស្សអាចទទួលបាន។

តាមរយៈឈើឆ្កាង យើងបានដឹងថាព្រះវរបិតានៃឋានសួគ៌ស្រឡាញ់យើងដោយសេចក្តីស្រឡាញ់ឥតព្រំដែន ។ តើយើងឆ្ងល់ដែរឬទេ ដែលលោកប៉ុលបានឧទានថា «ឯខ្ញុំ កុំបីឲ្យខ្ញុំអួតខ្លួនឡើយ អួតបានតែពីឈើឆ្កាងនៃព្រះយេស៊ូវគ្រិស្ត ជាព្រះអម្ចាស់នៃយើងរាល់គ្នាប៉ុណ្ណោះ» (កាឡាទី ៦:១៤)។ យើងក៏មានឯកសិទ្ធិត្រូវអួតតែពីឈើឆ្កាងដូចលោកប៉ុលដែរជាឯកសិទ្ធសម្រាប់យើងដែលត្រូវថ្វាយរូបកាយយើងដល់ព្រះដែលបានលះបង់ព្រះអង្គទ្រង់ជំនួសយើងរាល់គ្នា ។ បន្ទាប់មក ជាមួយនឹងពន្លឺដែលចែងចាំងចេញពីកាល់វ៉ារី ចូលមកលើមុខរបស់យើងរាល់គ្នា យើងគួរតែចេញទៅបង្ហាញពន្លឺនេះដល់អ្នកដែលកំពុងតែនៅក្នុងភាពងងឹត ។

ជំពូកទី
២១

# នៅភូមិភាគឯនាយ

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ១៦:៧-៤០ ។*

<u>អាទិត្យ-២៧ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ៨

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ឯព្រះដែលទ្រង់អាចនឹងធ្វើហួសសន្ធឹក លើសជាងអស់ទាំងសេចក្តីដែលយើងសូម ឬគិតក្តី តាមព្រះចេស្តា ដែលបណ្តាលក្នុងយើងរាល់គ្នា។ អេភេសូរ ៣:២០*

ពេលវេលាបានមកដល់ ដែលដំណឹងល្អត្រូវតែប្រកាសផ្សព្វផ្សាយឲ្យហួសពីព្រំដែនអាស៊ីកណ្តាល។ ផ្លូវបានរៀបចំរួចជាស្រេចសម្រាប់លោកប៉ុល និងសហការីរបស់លោក ឲ្យឆ្លងចូលទៅកាន់ទឹកដីអឺរ៉ុប។ នៅតំបន់ត្រាអូសតាមព្រំប្រទល់សមុទ្រមេឌីទែរ៉ាណេ «នៅយប់នោះ ប៉ុលបានឃើញក្នុងការជាក់ស្តែង ជាមនុស្សពីស្រុកម៉ាសេដូនម្នាក់ ឈរអង្វរគាត់ថា សូមអញ្ជើញឆ្លងមកជួយយើងខ្ញុំ ដែលនៅស្រុកម៉ាសេដូននេះផង» ។

ការអំពាវនាវនេះគឺជាការបង្គាប់បញ្ជា មិនអនុញ្ញាតឲ្យពន្យារពេលឡើយ។ លោកលូកាដែលបានរួមដំណើរជាមួយនឹងលោកប៉ុល ស៊ីឡាស និងធីម៉ូថេ ឆ្លងកាត់ទ្វីបអឺរ៉ុបបានមានប្រសាសន៍ថា «លុះគាត់បានឃើញការជាក់ស្តែងនោះរួចហើយ នោះយើងក៏រកឱកាសនឹងទៅឯស្រុកម៉ាសេដូនភ្លាម ដោយយល់ឃើញថា ព្រះអម្ចាស់ទ្រង់ហៅយើង ឲ្យទៅផ្សាយដំណឹងល្អដល់គេ ។ កាលបានចុះសំពៅចេញពីទ្រអាសទៅ នោះក៏តម្រង់ទៅឯកោះសាម៉ូត្រាស ហើយថ្ងៃក្រោយបានដល់នាប៉ូល ពីទីនោះ យើងក៏ទៅដល់ក្រុងភីលីពជាទីក្រុងលេខមួយក្នុងដែនខេត្តម៉ាសេដូន ដែលជាស្រុកចំណុះ ហើយយើង

សំចតនៅទីនោះបានបួនដប់ថ្ងៃ» ។

លោកលូកាបានបន្តថា «ដល់ថ្ងៃឈប់សម្រាក យើងដើរចេញពីទីក្រុងទៅឯមាត់ទន្លេ ជាកន្លែងដែលគេធ្លាប់អធិដ្ឋាន ក៏អង្គុយនិយាយនឹងពួកស្រីៗដែលប្រជុំគ្នា នោះមានស្ត្រីម្នាក់ ជាអ្នកជំនួញល័ខពណ៌ស្វាយ ឈ្មោះលីឌាពីក្រុងធាទេរ៉ា ជាអ្នកដែលថ្វាយបង្គំព្រះ នាងប្រុងស្តាប់ ហើយព្រះអម្ចាស់ទ្រង់បើកចិត្តនាង ឲ្យយកចិត្តទុកដាក់តាមសេចក្តីដែលប៉ុលអធិប្បាយ» នាងលីឌាបានទទួលសេចក្តីពិតដោយអំណរ ។ នាងនិងក្រុមគ្រួសារបានកែប្រែចិត្តហើយទទួលបុណ្យជ្រមុជទឹក ហើយនាងបានទទូចឲ្យពួកសាវ័កចាត់ទុកផ្ទះរបស់នាងដូចជាផ្ទះរបស់ពួកលោកដូច្នោះដែរ។

កាលពួកអ្នកនាំសារនៃឈើឆ្កាងបានធ្វើដំណើរបំពេញកិច្ចការប្រកាសដំណឹងល្អរបស់ពួកគេ មានស្ត្រីគ្រូទាយម្នាក់ដែលមានអារក្សចូលបានដើរតាមពួកលោកទាំងស្រែកថា «អ្នកទាំងនេះជាអ្នកបម្រើនៃព្រះដ៏ខ្ពស់បំផុតដែលប្រាប់យើងពីផ្លូវសង្គ្រោះ នាងក៏ធ្វើដូច្នោះជាយូរថ្ងៃ» ។

ស្ត្រីនេះគឺជាភ្នាក់ងារពិសេសរបស់សាតាំង ហើយបាននាំប្រាក់ចំណូលជាច្រើនដល់ចៅហ្វាយរបស់នាង ដោយការទស្សទាយ ។ ឥទ្ធិពលរបស់នាងបានជួយពង្រឹងកម្លាំងដល់ការថ្វាយបង្គំរូបព្រះ។ សាតាំងបានដឹងថានគររបស់វាមានគេចូលឈ្លានពានហើយ ហើយវាក៏បានប្រើមធ្យោបាយនៃការប្រឆាំងទៅនឹងកិច្ចការរបស់ព្រះ ដោយសង្ឃឹមថានឹងបញ្ចូលពាក្យភូតកុហករបស់វាលាយឡំជាមួយនឹងសេចក្តីពិត ដែលបង្រៀនដោយពួកអ្នកដែលកំពុងប្រកាសផ្សាយសារនៃដំណឹងល្អ។ ពាក្យសម្តីដែលបញ្ចេញដោយស្ត្រីនោះគឺជាការបង្ខូចដល់បុព្វហេតុនៃសេចក្តីពិត ដោយរំខានដល់គំនិតរបស់ពួកបណ្តាជនពីការបង្រៀនរបស់ពួកសាវ័ក និងបាននាំមកនូវការប្រមាថដល់ដំណឹងល្អ ហើយដោយសារពាក្យសម្តីទាំងនេះ អាចនឹងនាំមនុស្សឲ្យជឿថាពួកសាវ័កដែលនិយាយដោយព្រះចេស្តារបស់ព្រះក៏ត្រូវបានបណ្តាលឡើងដោយអ្នកនាំពាក្យរបស់សាតាំងដែរ ។

ច័ន្ទ-២៨ កញ្ញា អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ៩

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ចូរមានចិត្តសប្បុរសនឹងគ្នាទៅវិញទៅមក ព្រមទាំងមានចិត្តទន់សន្តោស ហើយអត់ទោសគ្នា ដូចជាព្រះទ្រង់បានអត់ទោសឲ្យអ្នករាល់គ្នា ដោយព្រះគ្រីស្ទដែរ។ អេភេសូរ ៤:៣២*

នៅពេលជាមួយគ្នាដែលពួកសាវ័ករងទ្រាំនូវការប្រឆាំងនេះ លោកប៉ុលក៏បានបង្គាប់ឲ្យវិញ្ញាណអារក្សចេញពីស្ត្រីនោះ នៅក្រោមការបណ្តាលរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ភាពស្ងៀមស្ងាត់ភ្លាមៗរបស់នាងបានបញ្ជាក់ថាពួកសាវ័កគឺជាអ្នកបម្រើរបស់ព្រះ និងថាអារក្សបានទទួលស្គាល់ពួកគេថាយ៉ាងដូច្នោះ ហើយក៏បានស្តាប់តាមបង្គាប់របស់ពួកសាវ័កផងដែរ ។

ដោយបានរួចពីវិញ្ញាណអារក្ស និងត្រូវបានស្តារឲ្យមានគំនិតធម្មតាដូចដើមឡើងវិញ ស្ត្រីនោះបានសម្រេចចិត្តធ្វើជាសិស្សរបស់ព្រះគ្រិស្ត។ បន្ទាប់មក ចៅហ្វាយរបស់នាងក៏បានដឹងពីអាជីវកម្មរបស់ពួកគេ។ ពួកគេបានមើលឃើញថាសេចក្តីសង្ឃឹមនៃការទទួលលុយមកពីការគន់គូរនិងការទស្សទាយរបស់នាងបានមកដល់ទីបញ្ចប់ហើយ ហើយថាប្រភពនៃប្រាក់ចំណូលរបស់ពួកគេនឹងត្រូវកាត់ផ្តាច់ទាំងស្រុងនៅពេលដ៏ខ្លីខាងមុខនេះ ជាក់ជាមិនខាន ប្រសិនបើបណ្តោយឲ្យពួកសាវ័កនៅតែបន្តធ្វើការផ្សាយដំណឹងល្អតទៅទៀត ។

មនុស្សជាច្រើននៅក្នុងទីក្រុងនេះ មានចំណាប់អារម្មណ៍ក្នុងការរកចំណូលតាមរយៈការបោកបញ្ឆោតរបស់សាតាំង ហើយពួកទាំងនេះបានបង្កើតជាសម្រែកប្រឆាំងទៅនឹងអ្នកបម្រើរបស់ព្រះយ៉ាងខ្លាំងក្លា ដោយភ័យខ្លាចចំពោះឥទ្ធិពលដែលអាចបញ្ឈប់កិច្ចការរកចំណូលរបស់ពួកគេយ៉ាងមានប្រសិទ្ធិភាព។ ពួកគេក៏បាននាំពួកសាវ័កមកកាន់តុលាការដោយចោទប្រកាន់ថា៖ «ពួកសាសន៍យូដាទាំងនេះនាំឲ្យទីក្រុងយើងកើតវឹកវរជាខ្លាំងណាស់គេប្រកាសប្រាប់ពីទំនៀមទម្លាប់ ដែលយើងខ្ញុំជាសាសន៍រ៉ូម»។

ដោយមានភាពវឹកវរដោយការរំជើបរំជួលនិងការភ្ញាក់ផ្អើល ហ្វូងមនុស្ស

បានក្រោកឈរឡើងប្រឆាំងនឹងពួកសាវ័ក។ វិញ្ញាណនៃហ្វូងមនុស្សដែលគ្មានសណ្តាប់ធ្នាប់បានទទួលជ័យជម្នះ ហើយត្រូវបានឯកភាពពីរដ្ឋអំណាចដែលបានហែកអាវវែងរបស់ពួកសាវ័ក ហើយបានបង្គាប់ឲ្យតម្រួតវាយពួកគេ។ «ក្រោយដែលវាយ មានស្នាមជាច្រើនហើយ នោះក៏យកទៅដាក់គុកបង្គាប់មេភូឃុំ ឲ្យរក្សាដោយប្រយ័ត្នប្រយែង មេភូឃុំទទួលបង្គាប់យ៉ាងដូច្នោះហើយ ក៏នាំយកគេទៅដាក់ក្នុងគុកជ្រៅ ព្រមទាំងដាក់ខ្នោះភ្ជាប់នៅជើងផង»។

ពួកសាវ័កបានទទួលរងទារុណកម្មយ៉ាងធ្ងន់ធ្ងរ ដោយសារតែស្នាមរបួសដ៏ឈឺចុកចាប់ ប៉ុន្តែ ពួកគេមិនបានត្អូញត្អែរឡើយ ។ ផ្ទុយទៅវិញ ពួកគេបានលើកទឹកចិត្តគ្នាទៅវិញទៅមក ដោយពាក្យអធិដ្ឋាននិងបានច្រៀងសរសើរតម្កើងដល់ព្រះ នៅក្នុងបន្ទប់ឃុំឃាំងយ៉ាងងងឹតនិងពោរពេញទៅដោយទុក្ខសោក ពីព្រោះពួកគេបានរកឃើញតម្លៃនៃការទទួលរងនូវភាពអាម៉ាស់ដើម្បីជាប្រយោជន៍របស់ព្រះគ្រិស្ត។ ចិត្តរបស់ពួកគេមានពេញដោយភាពរីករាយនៃសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅនិងស្មោះត្រង់ ក្នុងបុព្វហេតុនៃព្រះដ៏ប្រោសលោះរបស់ពួកគេ ។ លោកប៉ុលបានគិតអំពីការធ្វើទុក្ខបៀតបៀនដែលលោកធ្លាប់ធ្វើជាឧបករណ៍បម្រើ ក្នុងការនាំយកការបៀតបៀនទាំងនោះមកលើពួកសាវ័ក របស់ព្រះគ្រិស្ត ហើយលោកមានអំណរដែលព្រះបានបើកភ្នែកលោកឲ្យមើលឃើញ ហើយចិត្តលោកបានដឹងអំពីព្រះចេស្តានៃសិរីរុងរឿងនៃសេចក្តីពិត ដែលលោកធ្លាប់បានប្រមាថ ។

អ្នកទោសដទៃទៀតបានឮសំឡេងអធិដ្ឋាននិងចម្រៀងចេញពីក្នុងបន្ទប់ឃុំឃាំង ដោយការភ្ញាក់ផ្អើល ។ ពួកគេធ្លាប់តែបានឮសំឡេងថ្ងូរនិងសំឡេងយំទួញ ដាក់បណ្តាសានិងស្បថស្បែ បន្លឺកាត់ភាពស្ងៀមស្ងាត់នៃរាត្រីកាល ប៉ុន្តែ ពួកគេមិនធ្លាប់បានឮសំឡេងអធិដ្ឋាន និងចម្រៀងសរសើរតម្កើង អណ្តែតឡើងចេញពីបន្ទប់ឃុំឃាំងដូច្នេះឡើយ។ ពួកឆ្មាំគុកនិងពួកអ្នកទោសមានការងឿងឆ្ងល់ថាពួកទាំងនោះគឺជាអ្នកណា បានជាទោះបីជាមានការអត់ឃ្លាន និងទទួលទារុណកម្មយ៉ាងណាក៏ដោយ ក៏នៅតែមានអំណរដូច្នេះ។

អង្គារ-២៩ កញ្ញា អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ១០

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ដ្បិតផលផ្លែនៃពន្លឺ នោះមាននៅក្នុងគ្រប់ទាំងកិរិយាល្អ សេចក្តីសុចរិត និងសេចក្តីពិត។ អេភេសូរ ៥:៩*

ស្របពេលជាមួយគ្នានេះ ពួកតុលាការបានវិលត្រឡប់ទៅផ្ទះរបស់ពួកគេវិញដោយអំណរ ដោយអបអរសាទរដល់ខ្លួនឯង ដែលបានបង្រ្កាបហ្វូងមនុស្សដែលច្របូកស្របល់បានដោយមធ្យោបាយម៉ឺងម៉ាត់និងជាបន្ទាន់ ។ ប៉ុន្តែ នៅតាមផ្លូវ ពួកគេបានឮមនុស្សមួយចំនួននៅតែព្រួយបារម្ភអំពីអត្តចរិតនិងកិច្ចការរបស់បុរសដែលពួកគេបានកាត់ទោសឲ្យទទួលទណ្ឌកម្មនិងជាប់គុកនោះ។ ពួកគេបានឃើញស្ត្រីដែលមានសេរីភាពពីឥទ្ធិពលរបស់សាតាំង ហើយត្រូវបានដោះលែងឲ្យមានទឹកមុខនិងអាការៈធម្មតាឡើងវិញ។ កាលពីដើម នាងធ្លាប់តែបង្កបញ្ហាជាច្រើននៅក្នុងទីក្រុង តែឥឡូវនេះ នាងមានភាពស្ងៀមស្ងាត់និងមានសេចក្តីសុខសាន្ត។ ខណៈដែលពួកគេបានដឹងថាពួកគេប្រហែលជាមានឱកាសទៅសួរសុខទុក្ខអ្នកទោសដែលគ្មានកំហុសទាំងពីរនាក់ ដែលរងទុក្ខទោសយ៉ាងធ្ងន់ធ្ងរ ដោយសារច្បាប់នៃទីក្រុងរ៉ូមនេះ ពួកគេបានតូចចិត្តនឹងខ្លួនឯងជាខ្លាំង ហើយបានតាំងចិត្តថានៅព្រឹកស្អែកពួកគេនឹងបង្គាប់ឲ្យដោះលែងពួកសាវ័កជាសម្ងាត់ ហើយការពារពួកគេចេញពីទីក្រុងឲ្យផុតពីគ្រោះថ្នាក់ដោយសារហ្វូងមនុស្សដែលច្របូកច្របល់នោះ។

ប៉ុន្តែ នៅពេលដែលមនុស្សប្រើអំពើឃោរឃៅ ចងគំនុំ បដិសេធយ៉ាងឧក្រិដ្ឋការទទួលខុសត្រូវយ៉ាងឧឡារិក ដែលធ្លាក់មកលើពួកគេ ព្រះមិនបានបំភ្លេចប្រទានព្រះគុណដល់អ្នកបម្រើរបស់ទ្រង់ទេ។ ទេវតានៅឋានសួគ៌យកព្រះទ័យទុកដាក់ទៅនឹងមនុស្សដែលកំពុងឈឺចាប់ដោយសារព្រះគ្រិស្ត ហើយព្រះក៏បានចាត់ពួកទេវតាមកកាន់គុក។ ផែនដីបានញ័ររញ្ជួយនៅពេលពួកទេវតាបានដាក់ជើងជាន់ផែនដី។ រនុកទ្វារគុកធំៗបានរបើក ច្រវាក់និងខ្នោះបានរបូតចេញពីដៃនិងជើងរបស់ពួកអ្នកទោស ហើយពន្លឺដ៏ភ្លឺថែងចាំងបានបំភ្លឺពាសពេញទាំងគុក។

ពួកឆ្មាំបន្ទប់ឃុំឃាំងបានឮសំឡេងអធិដ្ឋានដ៏អស្ចារ្យរបស់ពួកសាវ័ក ដែលជាប់គុក។ នៅពេលមានការអនុញ្ញាតឲ្យចូលទៅខាងក្នុង ឆ្មាំគុកនោះបានឃើញស្នាមហើមនិងរបួសចេញឈាម ហើយបានដាក់ជើងរបស់ពួកអ្នកទោសជាប់ទៅនឹងខ្នោះ។ គេរំពឹងថានឹងឮតម្អូញនិងបណ្ដាសាយ៉ាងជូរចត់ចេញពីមាត់ពួកគេ ប៉ុន្តែ ផ្ទុយទៅវិញ គេបានឮចម្រៀងនិងការសរសើរតម្កើងដោយអំណរទៅវិញ។ ដោយឮសំឡេងនេះនៅនឹងត្រចៀក អ្នកយាមបានសម្រាន្តលង់លក់នោះក៏បានភ្ញាក់ ដោយការរញ្ជួយដីនិងការញ័ររញ្ជួយនៃជញ្ជាំងគុក។

ដោយការចាប់ផ្តើមភ្ញាក់ផ្អើល គាត់បានឃើញទាំងភិតភ័យថាទ្វារគុកបានរបើកទាំងអស់ ហើយការភ័យខ្លាចបានជះមកលើរូបគាត់ ក្រែងអ្នកទោសរត់រួចអស់។ គាត់បាននឹកឃើញពីការទុកដាក់លោកប៉ុលនិងស៊ីឡាស់មកក្នុងការយាមកាមរបស់គាត់ កាលពីយប់មិញ ហើយគាត់បានដឹងច្បាស់ថាសេចក្តីស្លាប់មុខជានឹងកើតឡើងដល់គាត់ដោយសារតែការធ្វេសប្រហែសរបស់គាត់នេះជាក់ជាមិនខាន។ គាត់បានគិតថាគាត់គួរតែស្លាប់ដោយដៃខ្លួនឯងប្រសើរជាងប្រគល់ខ្លួនឲ្យគេប្រហារជីវិតដោយគ្មានមេត្តា។ គាត់បានដកដាវ បម្រុងនឹងសម្លាប់ខ្លួនឯងទៅហើយ ស្រាប់តែបានឮសំឡេងលោកប៉ុលស្រែកឡើងដោយអំណរថា «កុំធ្វើបាបខ្លួនឡើយ ដ្បិតយើងនៅឯណេះទាំងអស់គ្នាទេ»។ មនុស្សបាននៅតាមកន្លែងរបស់គេរៀងៗខ្លួន ដែលបង្ខាំងដោយព្រះចេស្តារបស់ព្រះ តាមរយៈការខំប្រឹងប្រែងដោយអ្នកទោសរួមគុកម្នាក់ ។

ការប្រព្រឹត្តទៅលើពួកសាវ័កយ៉ាងឃោរឃៅ ដោយឆ្មាំគុកមិនបានបង្កឲ្យមានការអាក់អន់ចិត្តឡើយ។ លោកប៉ុលនិងស៊ីឡាសមានវិញ្ញាណនៃព្រះគ្រិស្ត មិនមែនវិញ្ញាណនៃការសងសឹងទេ ។ ចិត្តរបស់លោកពោរពេញទៅដោយសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ មិនមានកន្លែងទំនេរសម្រាប់ការព្យាបាទតតាំងនឹងអ្នកធ្វើទុក្ខបៀតបៀនរបស់ពួកលោកឡើយ ។

ពុធ-៣០ កញ្ញា អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្យត្រទី១ ជំពូក ១១

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ចូរផ្ចង់ចិត្តទៅឯសេចក្ដីទាំងអស់ដែលនៅខាងលើ កុំឲ្យផ្ចង់ទៅឯសេចក្ដីទាំងប៉ុន្មាន ដែលនៅផែនដីឡើយ។ កូឡុស ៣:២*

ឆ្មាំគុកបានទម្លាក់ដាវចុះ ហើយប្រាប់ឲ្យគេយកភ្លើងមកបំភ្លឺក្នុងគុកជ្រៅ។ គាត់អាចមើលឃើញលក្ខណៈរបស់ពួកសាវ័កដែលបានប្រព្រឹត្តសប្បុរសតបទៅនឹងអំពើឃោរឃៅដែលខ្លួនបានទទួល។ ដោយបានចូលទៅកាន់ទីកន្លែងដែលពួកសាវ័កនៅ ហើយលុតជង្គង់នៅចំពោះពួកលោក ឆ្មាំគុកបានសុំការអត់ឱនទោស ចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តមកលើរូបលោក។ បន្ទាប់មកបាននាំលោកចេញទៅក្រៅ រួចសួរថា «លោកម្ចាស់អើយ តើត្រូវឲ្យខ្ញុំធ្វើដូចម្ដេចឲ្យបានសង្គ្រោះផង?»

ឆ្មាំគុកបានញ័ររន្ធត់ នៅពេលគាត់បានឃើញសេចក្ដីក្រោធរបស់ព្រះដែលបានបង្ហាញនៅក្នុងការរញ្ជួយដី កាលគាត់បានគិតថាអ្នកទោសរត់រួចអស់ហើយ គាត់បម្រុងនឹងសម្លាប់ខ្លួន ប៉ុន្តែ ឥឡូវនេះជាមួយនឹងការភ័យខ្លាចថ្មី និងចម្លែក ដែលបានធ្វើឲ្យរំជួលចិត្តរបស់គាត់ ឆ្មាំគុកនេះប្រាថ្នាចង់បានភាពស្ងប់សុខនិងភាពរីករាយដែលពួកសាវ័កបានបង្ហាញ នៅក្រោមការឈឺចាប់ និងការរំលោភបំពាននោះដែរ។ គាត់បានឃើញពន្លឺនៃឋានសួគ៌នៅនឹងទឹកមុខរបស់ពួកលោក គាត់បានដឹងថាព្រះបានយាងចូលមកគង់នៅកណ្ដាលលក្ខណៈដ៏អស្ចារ្យនេះ ដើម្បីជួយសង្គ្រោះជីវិតរបស់ពួកលោក ហើយពាក្យពេចន៍ដែលស្ត្រីមានអារក្សចូលបានចូលមកក្នុងគំនិតរបស់លោកថា ៖ «អ្នកទាំងនេះជាអ្នកបម្រើនៃព្រះដ៏ខ្ពស់បំផុត ដែលប្រាប់យើងពីផ្លូវសង្គ្រោះ»។

គាត់បានសួរដល់សាវ័កអំពីផ្លូវនៃជីវិតដោយបន្ទាបខ្លួនយ៉ាងទន់ទាប។ ពួកសាវ័កបានឆ្លើយតបទៅវិញថា «ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រិស្តទៅនោះនឹងបានសង្គ្រោះហើយ ព្រមទាំងពួកគ្រួសារលោកផង»។ ហើយ «គេក៏ផ្សាយព្រះបន្ទូលនៃព្រះអម្ចាស់ដល់គាត់ និងពួកគ្រួគាត់ទាំងអស់ដែរ»។ បន្ទាប់មក ឆ្មាំគុកក៏បានលាងរបួសឲ្យពួកសាវ័ក ហើយបានបម្រើលោក

ក្រោយមកទៀត ពួកសាវ័កបានធ្វើពិធីបុណ្យជ្រមុជទឹកឲ្យគាត់ ព្រមទាំងក្រុមគ្រួសាររបស់គាត់ទាំងអស់ផង។ ឥទ្ធិពលដ៏បរិសុទ្ធដែលបានសាយភាយឡើងដោយខ្លួនឯងនៅក្នុងចំណោមអ្នកជាប់គុកជាមួយគ្នា និងដល់គំនិតរបស់មនុស្សទាំងឡាយដែលបានស្តាប់សេចក្តីពិតដែលបាននិយាយដោយពួកសាវ័ក។ ពួកគេបានដឹងថាព្រះដែលបុរសទាំងនេះបម្រើបានរំដោះពួកគេដ៏អស្ចារ្យឲ្យរួចពីចំណង ។

ពួកបណ្តាជននៅក្រុងភីលីព មានការរន្ធត់ជាខ្លាំងដោយការរញ្ជួយដី លុះព្រឹកឡើងនាយតម្រួតពន្ធនាគារបានជម្រាបតុលាការអំពីរឿងរ៉ាវដែលបានកើតឡើងកាលពីយប់មិញ ពួកគេមានការភ្ញាក់ផ្អើលជាខ្លាំង ហើយបានចាត់នាយតម្រួតឲ្យដោះលែងពួកសាវ័ក។ ប៉ុន្តែ លោកប៉ុលបានមានប្រសាសន៍ថា «ពួកមេនគរបាលវាយយើងនឹងរំពាត់ នៅកណ្តាលជំនុំ ឥតមានកាត់ទោស ហើយបានដាក់គុកយើងផង ដែលយើងជាជាតិរ៉ូមដូច្នេះ ឥឡូវនេះលោកចង់គេចកែប្រែជាដេញយើងទៅដោយសម្ងាត់វិញឬ ធ្វើដូច្នេះពុំបានទេ ត្រូវឲ្យខ្លួនលោកមកនាំយើងចេញទៅវិញ» ។

ពួកសាវ័កជាសាសន៍រ៉ូម ហើយគ្មានច្បាប់ដែលត្រូវវាយសាសន៍រ៉ូម ឬឃុំខ្លួនពីបទឧក្រិដ្ឋដាក់ស្តែង ឬដោះលែងដោយមិនកាត់ទោសឲ្យបានត្រឹមត្រូវនោះឡើយ ។ លោកប៉ុលនិងស៊ីឡាសត្រូវបានដោះលែងពីគុកជាសាធារណៈ ហើយឥឡូវនេះ ពួកលោកបដិសធមិនព្រមឲ្យគេដោះលែងស្ងាត់ៗ ដោយមិនបានពន្យល់ឲ្យបានត្រឹមត្រូវពីសំណាក់តុលាការឡើយ ។

នៅពេលពាក្យលោកត្រូវបានគេពាំនាំទៅប្រាប់ដល់រដ្ឋអំណាច ពួកគេបានភ្ញាក់ផ្អើល ក្រែងពួកសាវ័កឡើងឧទ្ធរដល់ព្រះចៅអធិរាជ ហើយក៏បានទៅកាន់ពន្ធនាគារភ្លាម ពួកគេបានសុំទោសលោកប៉ុលនិងស៊ីឡាស ចំពោះអំពើអយុត្តិធម៌និងភាពឃោរឃៅដែលពួកគេបានប្រព្រឹត្តទៅលើពួកលោកដោយផ្ទាល់ ហើយបាននាំពួកលោកចេញពីគុក ដោយអង្វរករសុំឲ្យពួកលោកចេញពីទីក្រុងទៅ ។ ពួកតុលាការបានភ័យខ្លាចចំពោះឥទ្ធិពលរបស់ពួកសាវ័ក

ទៅលើពួកបណ្ដាជន ហើយពួកគេក៏បានភ័យខ្លាចចំពោះអំណាចរបស់ព្រះ ដែលបានធ្វើការជំនួសបុរសដែលគ្មានកំហុសទាំងនេះផងដែរ ។

<u>ព្រហស្បតិ៍-១ តុលា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ១២**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ខ្ញុំជឿសេចក្តីនេះជាយ៉ាងជាក់ថា ព្រះអង្គដែលទ្រង់បានចាប់តាំងធ្វើការល្អក្នុងអ្នករាល់គ្នា ទ្រង់នឹងធ្វើឲ្យកាន់តែពេញខ្នាតឡើង ទាល់តែដល់ថ្ងៃនៃព្រះយេស៊ូវគ្រីស្ទ។ ភីលីព ១:៦*

ដោយបំពេញសកម្មភាពតាមការណែនាំដែលព្រះគ្រិស្តបានប្រទានពួកសាវ័កមិនបានជំរុញវត្តមានរបស់ពួកគេទៅកាន់កន្លែងណា ដែលមនុស្សមិនមានសេចក្តីប្រាថ្នាចង់ឮពួកគេនិយាយឡើយ ។ «កាលចេញពីគុកហើយទើបនាំគ្នាទៅឯនាងលីឌា លុះបានឃើញពួកជំនុំ នោះក៏ទូន្មានដល់គេ រួចចេញដំណើរទៅ» ។

ពួកសាវ័កមិនបានចាត់ទុកកិច្ចការរបស់ពួកគេនៅក្រុងភីលីពជាឥតប្រយោជន៍ទេ ។ ពួកគេបានជួបនឹងការប្រឆាំងនិងការបៀតបៀនជាច្រើន ប៉ុន្តែ អន្តរាគមន៍នៃការការពាររបស់ព្រះជំនួសពួកគេ និងការផ្លាស់ប្តូរជំនឿរបស់ឆ្មាំគុក និងគ្រួសាររបស់គាត់ មានទំហំធំធេងជាងទណ្ឌកម្មនិងការឈឺចាប់ដែលពួកលោកបានរងទ្រាំ ។ ដំណឹងអំពីការចាប់ពួកលោកដាក់គុកយ៉ាងអយុត្តិធម៌ និងការរំដោះដោយការអស្ចារ្យត្រូវបានគេដឹងឮពាសពេញទាំងតំបន់នោះ ហើយការនេះបាននាំឲ្យមនុស្សជាច្រើនចាប់អារម្មណ៍ជាខ្លាំង ទៅនឹងកិច្ចការរបស់ពួកសាវ័ក ដែលគ្មានវិធីណាក្រៅពីនេះអាចចូលទៅបានឡើយ ។

កិច្ចការរបស់លោកប៉ុលនៅក្រុងភីលីព បានធ្វើឲ្យមានពួកជំនុំមួយកើតឡើង ដែលសមាជិកនៃពួកជំនុំនេះមានជំនឿយ៉ាងរឹងមាំ។ ចិត្តពុះកញ្ជ្រោល និងជំនឿស៊ប់ក្នុងសាសនារបស់លោក ជាពិសេស ឆន្ទៈរបស់លោកដែលសុខចិត្តរងការឈឺចាប់ដើម្បីព្រះគ្រិស្ត បានក្លាយជាឥទ្ធិពលយ៉ាងជ្រាលជ្រៅ

និងយូរអង្វែង ដល់ពួកអ្នកដែលបានផ្លាស់ប្តូរជំនឿ។ ពួកគេបានឲ្យតម្លៃយ៉ាងខ្ពស់ ដល់សេចក្តីពិតដែលពួកសាវ័កសុខចិត្តលះបង់អ្វីៗគ្រប់យ៉ាងដើម្បីការពារ ហើយបានលះបង់ខ្លួនឯងដើម្បីបុព្វហេតុនៃព្រះដ៏ប្រោសលោះរបស់ពួកគេ ។

ការដែលបញ្ជាក់ថាពួកជំនុំនេះមិនបានគេចវេះពីការបៀតបៀនត្រូវបានបង្ហាញនៅក្នុងសំបុត្ររបស់លោកប៉ុលដែលផ្ញើមកកាន់ពួកគេ។ លោកបានមានប្រសាសន៍ថា «ដ្បិតមានឱកាសបើកឲ្យអ្នករាល់គ្នាហើយ មិនមែនឲ្យគ្រាន់តែជឿដល់ព្រះគ្រិស្តតែប៉ុណ្ណោះទេ គឺឲ្យរងទុក្ខដោយព្រោះទ្រង់ដែរទាំងកើតមានសេចក្តីតតាំងដដែល ដែលឃើញខ្ញុំមាន ហើយឥឡូវនេះឮថាខ្ញុំមានទៀត» ។ ហើយដោយសារតែភាពរឹងមាំខាងសេចក្តីជំនឿរបស់ពួកគេដូច្នេះហើយ បានជាលោកមានប្រសាសន៍ថា «ខ្ញុំអរព្រះគុណដល់ព្រះនៃខ្ញុំ ដោយព្រោះគ្រប់ទាំងសេចក្តីដែលខ្ញុំនឹកចាំពីអ្នករាល់គ្នា ខ្ញុំក៏ទូលអង្វរឲ្យអ្នករាល់គ្នា ដោយអំណរនៅគ្រប់វេលាដែលខ្ញុំអធិដ្ឋានជានិច្ច ដោយព្រោះចំណែកដែលអ្នករាល់គ្នាបានជួយក្នុងដំណឹងល្អ ចាប់តាំងពីថ្ងៃមុនដំបូងដរាបដល់ឥឡូវនេះ» (ភីលីព ១:២៩, ៣០ និង ៣-៥) ។

មានការពិបាកជាខ្លាំងបានកើតឡើងរវាងកម្លាំងនៃអំពើល្អនិងការអាក្រក់នៅតាមកន្លែងសំខាន់ៗ ដែលព្រះបានត្រាស់ហៅឲ្យអ្នកនាំសាររបស់ព្រះអង្គចូលទៅធ្វើការ ។ លោកប៉ុលមានប្រសាសន៍ថា «ដ្បិតយើងរាល់គ្នាមិនមែនតយុទ្ធនឹងសាច់ឈាមទេ គឺនឹងពួកគ្រប់គ្រង ពួកមានអំណាច និងពួកម្ចាស់នៃសេចក្តីងងឹតនៅលោកិយនេះវិញ ហើយទាស់នឹងអំណាចអាក្រក់ខាងវិញ្ញាណ នៅឋានដ៏ខ្ពស់ដែរ» (អេភេសូរ ៦:១២)។ នឹងមានទំនាស់រវាងពួកជំនុំរបស់ព្រះជាមួយនឹងពួកទេវតារបស់អារក្ស រហូតដល់គ្រាចុងបំផុតកល្ប។

ព្រះតែងតែត្រាស់ហៅឲ្យពួកគ្រិស្តបរិស័ទដំបូង ជួបប្រទះនឹងអំណាចនៃសេចក្តីងងឹតមុខទល់នឹងមុខ។ សត្រូវនេះបានខំបង្វែរពួកគេចេញពីជំនឿពិតដោយការបោកបញ្ឆោតនិងការធ្វើទុក្ខបៀតបៀន។ នៅសម័យបច្ចុប្បន្ន

នេះ កាលទីបញ្ចប់នៃអ្វីៗគ្រប់យ៉ាងនៅលើផែនដីកំពុងតែចូលមកដល់យ៉ាងរហ័ស នោះសាតាំងក៏កំពុងខំប្រឹងប្រែងដាក់អន្ទាក់ពិភពលោកនេះដែរ។ វាកំពុងរៀបចំផែនការណ៍ជាច្រើន ដើម្បីកាន់កាប់គំនិត និងបង្វែរចំណាប់អារម្មណ៍មនុស្សជាច្រើន ចេញពីសេចក្តីពិតដ៏សំខាន់នៃសេចក្តីសង្គ្រោះ ។ ភ្នាក់ងាររបស់វាកំពុងរៀបចំជាបក្សផ្សេងៗ យ៉ាងមមាញឹក នៅក្នុងអស់អ្នកណាដែលប្រឆាំងទៅនឹងក្រឹត្យវិន័យរបស់ព្រះ ។ មេបោកកំពុងធ្វើការដើម្បីបង្កើតភាពច្របូកច្របល់និងការប្រឆាំងបះបោរ ហើយមនុស្សកំពុងតែមានចិត្តពុះកញ្ជ្រោលជាមួយនឹងអ្វីដែលមិនមែនជាចំណេះដឹង ។

អំពើអាក្រក់កំពុងកើនឡើងដល់កំពូល ដែលមិនធ្លាប់មានពីមុនមក ហើយអ្នកបម្រើដំណឹងល្អជាច្រើនកំពុងតែស្រែកថា «មានសេចក្តីសុខសាន្ត មានសេចក្តីរៀបរយហើយ»។ ប៉ុន្តែ អ្នកនាំសារដ៏ស្មោះត្រង់របស់ព្រះត្រូវតែបោះជំហានទៅមុខយ៉ាងស្វាហាប់ ជាមួយនឹងកិច្ចការរបស់ខ្លួន។ ទាំងប្រដាប់កាយដោយសព្វាវុធនៃឋានសួគ៌ ពួកគេបោះជំហានទៅមុខដោយគ្មានការភ័យខ្លាច និងដោយជោគជ័យ មិនដែលឈប់បំពេញកិច្ចការរបស់ពួកគេឡើយ រហូតទាល់តែមនុស្សគ្រប់គ្នានៅក្នុងទឹកដីដែលពួកគេទៅដល់បានទទួលសារនៃសេចក្តីពិតសម្រាប់សម័យនេះ ៕

## ជំពូកទី
## ២២

# ទីក្រុងថែស្សាឡូនីច

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ១៧:១-១០ ។*

សុក្រ-២ តុលា អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ១៣

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *រួចទ្រង់ក៏ស្រាយន័យសេចក្តី ដែលតម្រូវដល់ទ្រង់ ពីក្នុងគម្ពីរទាំងឡាយ ឲ្យគេស្តាប់ ចាប់តាំងពីគម្ពីរលោកម៉ូសេ និងគម្ពីរពួកហោរារៀងមក។ លូកា ២៤:២៧*

បន្ទាប់ពីចាកចេញពីទីក្រុងភីលីពមក លោកប៉ុលនិងស៊ីឡាសបានចេញដំណើរទៅកាន់ទីក្រុងថែស្សាឡូនីច។ នៅទីនេះ ពួកលោកបានទទួលកិត្តិយសឲ្យបញ្ចេញយោបល់ទៅកាន់ពួកជំនុំដ៏ធំនៅក្នុងសាលាប្រជុំរបស់សាសន៍យូដា។ លក្ខណៈរបស់ពួកលោកបានបង្ហាញភស្តុតាងពីការប្រព្រឹត្តដ៏គួរឲ្យអៀនខ្មាស ដែលពួកលោកបានទទួលកាលពីពេលថ្មីៗកន្លងមកនេះ ហើយតម្រូវឲ្យពួកលោកពន្យល់អំពីរឿងរ៉ាវដែលបានកើតឡើងនេះ។ ពួកគេបានធ្វើការនេះដោយមិនបានលើកតម្កើងខ្លួនឯងទេ ប៉ុន្តែ បានបង្ហាញអំពីព្រះដែលបានធ្វើការរំដោះពួកលោកទៅវិញ ។

ក្នុងការអធិប្បាយទៅកាន់ពួកអ្នកក្រុងថែស្សាឡូនីច លោកប៉ុលបានអំពាវនាវអំពីបទទំនាយនៅក្នុងគម្ពីរសញ្ញាចាស់ ទាក់ទងទៅនឹងព្រះមែស្ស៊ី។ នៅក្នុងការបំពេញព្រះរាជកិច្ចរបស់ព្រះអង្គនៅលើផែនដី ព្រះគ្រិស្តបានបើកគំនិតពួកសិស្សរបស់ទ្រង់អំពីបទទំនាយទាំងនេះ «រួចទ្រង់ក៏ស្រាយន័យសេចក្តីដែលតម្រូវដល់ទ្រង់ ពីក្នុងគម្ពីរទាំងឡាយ ឲ្យគេស្តាប់ចាប់តាំងពីគម្ពីរលោកម៉ូសេ និងគម្ពីរពួកហោរារៀងមក» (លូកា ២៤:២៧)។ នៅក្នុង

ការអធិប្បាយអំពីព្រះគ្រិស្ត លោកពេត្រុសបានបង្កើតភស្តុតាងចេញពីគម្ពីរសញ្ញាចាស់។ លោកស្ទេផានក៏បានធ្វើដូចគ្នានេះដែរ។ ហើយនៅក្នុងការបំពេញកិច្ចការរបស់គាត់ លោកប៉ុលបានលើកពីបទគម្ពីរ ប្រាប់ឲ្យដឹងជាមុនអំពីកំណើត ការឈឺចាប់ ការសុគត ការមានព្រះជន្មរស់ឡើងវិញ និងការយាងឡើងទៅកាន់ឋានសួគ៌របស់ព្រះគ្រិស្ត។ ដោយការលើកទឹកចិត្តពីទីបន្ទាល់របស់លោក ម៉ូសេនិងពួកហោរា លោកបានបញ្ជាក់យ៉ាងច្បាស់ពីអត្តសញ្ញាណរបស់ព្រះយេស៊ូវពីស្រុកណាសារ៉ែត ជាមួយនឹងព្រះមែស៊ី និងបានបង្ហាញថា មានព្រះសូរសៀងរបស់ព្រះគ្រិស្តដែលបានមានបន្ទូលតាមរយៈពួកអយ្យកោនិងពួកហោរា ចាប់តាំងពីសម័យលោកអ័ដាមរៀងមក។

ព្រះបានប្រទានបទទំនាយយ៉ាងច្បាស់និងជាក់លាក់ទាក់ទងនឹងលក្ខណៈនៃព្រះមួយអង្គតាមសេចក្តីសន្យា។ ទ្រង់បានប្រទានការធានាអះអាងដល់លោកអ័ដាមអំពីព្រះដ៏ប្រោសលោះ ដែលនឹងយាងមក។ ការកាត់ទោសដែលព្រះបានប្រកាសដល់សាតាំងថា «អញនឹងធ្វើឲ្យឯង ហើយនិងស្ត្រី គឺទាំងពូជឯង និងពូជនាងមានសេចក្តីខ្មាំងនឹងគ្នា ពូជនាងនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែងជើងគេ» (លោកុប្បត្តិ ៣:១៥) គឺជាសេចក្តីសន្យាដែលព្រះបានប្រទានដល់ឪពុកម្តាយដើមដំបូងរបស់យើង អំពីការប្រោសលោះដែលនឹងកើតឡើងតាមរយៈព្រះគ្រិស្ត ។

ព្រះបានសន្យាជាមួយនឹងលោកអ័ដាមថា ព្រះអង្គសង្គ្រោះនឹងប្រសូតមកនៅក្នុងពូជអំបូររបស់លោក៖ «គ្រប់ទាំងសាសន៍នៅផែនដីនឹងបានពរដោយសារពូជឯង» ។ «តែទ្រង់មិនបានមានព្រះបន្ទូលថា នឹងពូជទាំងប៉ុន្មានដូចជាមានពូជជាច្រើននោះទេ គឺចំពោះពូជតែមួយវិញ ដោយថា និងពូជលោកមួយនោះឯង គឺជាព្រះគ្រិស្ត» (លោកុប្បត្តិ ២២:១៨ និងកាឡាទី ៣:១៦)។

នៅជិតចុងបញ្ចប់នៃកិច្ចរបស់គាត់ ជាមេដឹកនាំនិង ជាគ្រូបង្រៀនដល់

សាសន៍អ៊ីស្រាអែល លោកម៉ូសេបានទស្សទាយយ៉ាងច្បាស់អំពីព្រះមែស៊ី ដែលនឹងយាងមក លោកបានមានប្រសាសន៍ប្រាប់ដល់រាស្ត្រអ៊ីស្រាអែល ដែលបានប្រជុំគ្នានោះថា៖ «ព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹងបណ្ដាលឲ្យមានហោរាមួយកើតឡើង ពីពួកបងប្អូនឯង ឲ្យដូចជាអញ ត្រូវឲ្យឯងរាល់គ្នាស្ដាប់តាមអ្នកនោះចុះ» ។ ហើយលោកម៉ូសេបានបញ្ជាក់ប្រាប់ដល់រាស្ត្រអ៊ីស្រាអែលថា ព្រះបានបង្ហាញអំពីរឿងនេះប្រាប់លោកដោយផ្ទាល់ កាលទ្រង់បានមានបន្ទូលនៅភ្នំហោរែបថា «អញនឹងបណ្ដាលឲ្យមានហោរាមួយកើតឡើងពីពួកបងប្អូនគេ សម្រាប់គេ ឲ្យដូចឯង ហើយអញនឹងដាក់ពាក្យអញទៅក្នុងមាត់ហោរានោះ អ្នកនោះនឹងប្រាប់ដល់គេតាមគ្រប់ទាំងសេចក្ដីដែលអញនឹងបង្គាប់មក» (ចោទិយកថា ១៨:១៥, ១៨) ។

ព្រះមែស៊ីត្រូវតែជាសែស្រឡាយរាជវង្ស ព្រោះនៅក្នុងបទទំនាយដែលបានរៀបរាប់ប្រាប់ដោយលោកយ៉ាកុប ព្រះជាម្ចាស់បានមានបន្ទូលថា «ដំបងរាជ្យនឹងមិនដែលឃ្លាតពីយូដា ឬអំណាចគ្រប់គ្រងពីជើងវាឡើយ ដរាបដល់ស៊ីឡូរបានមកដល់ នោះបណ្ដាជនទាំងឡាយនឹងចុះចូលចំពោះទ្រង់» (លោកុប្បត្តិ ៤៩:១០) ។

**<u>សៅរ៍-៣ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ១៤**

**ខព្រះគម្ពីរប្រចាំសប្ដាហ៍:** *ព្រះវិញ្ញាណនៃព្រះយេហូវ៉ា នឹងសណ្ឋិតនៅលើអ្នកនោះ គឺជាព្រះវិញ្ញាណនៃប្រាជ្ញានឹងយោបល់ ជាព្រះវិញ្ញាណនៃគំនិតវាងវៃ និងឫទ្ធានុភាព ជាព្រះវិញ្ញាណនៃសេចក្ដីចេះដឹង និងសេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា។ អេសាយ ១១:២*

លោកអេសាយបានទស្សទាយថា «មានលំពង់មួយនឹងដុះចេញពីគល់របស់អ៊ីសាយ ហើយមែកមួយ ដែលចេញពីឫសគាត់»។ «ចូរឱនត្រចៀកហើយមកឯអញ ចូរស្ដាប់ចុះ នោះព្រលឹងឯងនឹងបានរស់នៅ ហើយអញនឹងតាំងសេចក្ដីសញ្ញានឹងឯងរាល់គ្នា ជាសញ្ញាដ៏នៅអស់កល្បជានិច្ច គឺជាសេចក្ដី

មេត្តាករុណាស្មោះត្រង់ ដែលបានផ្តល់ដល់ដាវីឌ មើល អញបានតាំងដាវីឌ ទុកជាទីបន្ទាល់ដល់ប្រជាជាតិទាំងឡាយ គឺជាអ្នកនាំមុខហើយជាអ្នកបង្គាប់ដល់គេ មើលឯងនឹងហៅសាសន៍មួយដែលឯងមិនបានស្គាល់ ហើយសាសន៍មួយដែលមិនបានស្គាល់ឯង គេនឹងរត់មកឯឯង ដោយព្រោះព្រះយេហូវ៉ាជាព្រះនៃឯង គឺជាព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ដ្បិតទ្រង់បានលើកតម្កើងឯងហើយ» (អេសាយ ១១:១ និង ៥៥:៣-៥) ។

លោកយេរេមាក៏បានធ្វើទីបន្ទាល់អំពីព្រះដ៏ប្រោសលោះ ដែលនឹងយាងមកជាព្រះអម្ចាស់នៃរាជវង្សហ្លួងដាវីឌផងដែរ «ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា មើល នឹងមានគ្រាមកដល់ ដែលអញនឹងបង្កើតឲ្យដាវីឌមានលំពង់សុចរិតមួយ លំពង់នោះទ្រង់នឹងសោយរាជ្យទុកដូចជាស្តេច ហើយនឹងប្រព្រឹត្តដោយវាងវៃ ព្រមទាំងសម្រេចសេចក្តីយុត្តិធម៌ និងសេចក្តីសុចរិតនៅក្នុងស្រុកផង នៅគ្រារបស់ទ្រង់ ពួកយូដានឹងបានសង្គ្រោះ ហើយពួកអ៊ីស្រាអែលនឹងនៅដោយសន្តិសុខ ឯព្រះនាមដែលគេនឹងហៅទ្រង់ នោះគឺព្រះយេហូវ៉ាដ៏ជាសេចក្តីសុចរិតនៃយើងរាល់គ្នា»។ ហើយម្តងទៀត៖ «ដ្បិតព្រះយេហូវ៉ាទ្រង់ មានព្រះបន្ទូលដូច្នេះថា ដាវីឌនឹងមិនដែលអាក់ខានមានមនុស្សសម្រាប់អង្គុយលើបល្ល័ង្ករបស់ពូជពង្សនៃអ៊ីស្រាអែលឡើយ។ ហើយពួកសង្ឃនិងពួកលេវី ក៏មិនដែលអាក់ខានមានមនុស្ស នៅចំពោះអញសម្រាប់ថ្វាយតង្វាយដុត តង្វាយម្សៅ ហើយនិងយញ្ញបូជាជាប់នៅជានិច្ចដែរ» (យេរេមា ២៣:៥, ៦ និង ៣៣:១៧, ១៨)។

សូម្បីតែទីកន្លែងប្រសូតនៃព្រះមែស្ស៊ីក៏ត្រូវបានប្រាប់ឲ្យដឹងជាមុនដែរ៖ «ដូច្នេះ អ្នកនោះនឹងប្រគល់គេទៅដរាបដល់កំណត់នៃនាងដែលឈឺនឹងសម្រាលបានកើតកូនមក នោះសំណល់នៃពួកបងប្អូនរបស់អ្នកនោះ នឹងបានវិលត្រឡប់មកឯពួកកូនចៅអ៊ីស្រាអែលវិញ» (មីកា ៥:២) ។

ព្រះរាជកិច្ចដែលព្រះអង្គសង្គ្រោះនឹងត្រូវបំពេញនៅលើផែនដីនេះក៏ត្រូវបានសង្ខេបប្រាប់យ៉ាងពេញលេញដែរ «ព្រះវិញ្ញាណនៃព្រះយេហូវ៉ានឹង

សណ្ឋិតនៅលើអ្នកនោះ គឺជាព្រះវិញ្ញាណនៃប្រាជ្ញានឹងយោបល់ ជាព្រះវិញ្ញាណនៃគំនិតវាងវៃ និងឫទ្ធានុភាព ជាព្រះវិញ្ញាណនៃសេចក្តីចេះដឹង និងសេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា អ្នកនោះនឹងរីករាយ ចំពោះសេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា»។ ជាព្រះមួយអង្គដែលនឹងត្រូវចាក់ប្រេងតាំងឲ្យ«ផ្សាយដំណឹងល្អដល់មនុស្សទ័លក្រ ... ដើម្បីនឹងប្រោសមនុស្សដែលមានចិត្តសង្រេង និងប្រកាសប្រាប់ពីសេចក្តីប្រោសលោះដល់ពួកឈ្លើយ ហើយពីការដោះលែងដល់ពួកអ្នកដែលជាប់ចំណង ព្រមទាំងប្រកាសប្រាប់ពីឆ្នាំដែលព្រះយេហូវ៉ាទ្រង់សព្វព្រះហឫទ័យ និងពីថ្ងៃ ដែលព្រះនៃយើងខ្ញុំនឹងសងសឹកផង ហើយឲ្យកម្សាន្តចិត្តនៃអស់អ្នកណាដែលសោយសោកនឹងចែកឲ្យដល់ពួកអ្នក ដែលសោយសោក នៅក្រុងស៊ីយ៉ូនបានភួងលម្អជំនួសផេះ ហើយប្រេងនៃសេចក្តីអំណរជំនួសសេចក្តីសោកសៅព្រមទាំងអាវពាក់នៃសេចក្តីសរសើរ ជំនួសទុក្ខធ្ងន់ដែលគ្របសង្កត់ ដើម្បីឲ្យគេបានហៅថាជាដើមឈើនៃសេចក្តីសុចរិត គឺជាដើមដែលព្រះយេហូវ៉ាបានដាំ មានប្រយោជន៍ឲ្យទ្រង់បានថ្កើងឡើង» (អេសាយ ១១:២, ៣ និង ៦១:១-៣)។

«មើល នេះនែអ្នកបម្រើរបស់អញ ដែលអញទប់ទល់ គឺជាអ្នកជ្រើសរើសរបស់អញ ដែលជាទីរីករាយដល់ចិត្តអញ អញបានដាក់វិញ្ញាណអញឲ្យសណ្ឋិតលើទ្រង់ ហើយទ្រង់នឹង សម្តែងចេញ ឲ្យគ្រប់ទាំងសាសន៍បានឃើញសេចក្តីយុត្តិធម៌ ទ្រង់នឹងមិនស្រែក ឬបន្លឺឡើង ឬឲ្យអ្នកណាឮសំឡេងនៅក្នុងផ្លូវឡើយ  ទ្រង់នឹងមិនផ្តាច់ដើមត្រែងដែលបាក់ទេ ក៏មិនលត់ប្រឆេះដែលនៅហុយដែរ ទ្រង់នឹងសម្តែងចេញនូវសេចក្តីយុត្តិធម៌ដោយសេចក្តីពិត ទ្រង់នឹងមិនដែលអន់ថយ ឬរសាយចិត្តដរាបដល់បានតាំងសេចក្តីយុត្តិធម៌ឡើងនៅផែនដី ហើយកោះទាំងប៉ុន្មាននឹងសង្ឃឹមដល់ក្រឹត្យក្រមរបស់ទ្រង់» (អេសាយ ៤២:១-៤) ។

<u>អាទិត្យ-៤ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ១៥

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *តែឯង ឱបេថ្លេហិម-អេប្រាតាអើយ ឯងដែលតូចនៅក្នុងពួកយូដាទាំងពាន់ៗ នឹងមានម្នាក់កើតចេញពីឯងមកឲ្យអញ អ្នកនោះត្រូវឡើងជាអ្នកគ្រប់គ្រងលើអ៊ីស្រាអែល ដើមកំណើតរបស់អ្នកនោះបានចាប់តាំងពីបុរាណ គឺពីអស់កល្បរៀងមក។ មីកា ៥:១*

ជាមួយនឹងអំណាចដែលអាចផ្លាស់ប្ដូរចិត្ត លោកប៉ុលបានលើកហេតុផលពីគម្ពីរសញ្ញាចាស់មកថា «ព្រះគ្រិស្តត្រូវតែរងទុក្ខ រួចមានព្រះជន្មរស់ពីសុគតឡើងវិញ»។ តើលោកមីកាមិនបានទស្សទាយទេឬអីថា «អ្នកនោះនឹងត្រូវឡើងជាអ្នកគ្រប់គ្រងលើអ៊ីស្រាអែល» (មីកា ៥:១) ។ ហើយតើព្រះនៃសេចក្តីសន្យាមិនបានទស្សទាយពីព្រះអង្គផ្ទាល់តាមរយៈលោកអេសាយទេឬអីថា «ខ្ញុំបានប្រគល់ខ្នងទៅឲ្យពួកអ្នកដែលវាយ ហើយថ្ពាល់ខ្ញុំទៅឲ្យពួកអ្នកដែលបោចពុកចង្កា ខ្ញុំមិនបានគេចមុខពីសេចក្តីអាម៉ាស់ខ្មាស ឬពីការស្តោះទឹកមាត់ទេ» (អេសាយ ៥០:៦)។ ព្រះគ្រិស្តបានទស្សទាយអំពីការប្រព្រឹត្តដែលទ្រង់នឹងត្រូវទទួលរងពីសំណាក់មនុស្ស តាមរយៈអ្នកនិពន្ធគម្ពីរទំនុកតម្កើងថា «ចំណែកទូលបង្គំៗ ... មិនមែនជាមនុស្សទេ ជាទីត្មះតិះដៀលរបស់មនុស្ស ហើយជាទីស្អប់ខ្ពើមនៃពួកបណ្តាជន អស់អ្នកដែលឃើញទូលបង្គំក៏ឡកឡឺយឲ្យ គេបូញមាត់ ហើយគ្រវីក្បាល ដោយថា វាបានទុកចិត្តនឹងព្រះយេហូវ៉ា ថាទ្រង់នឹងប្រោសឲ្យរួច ចូរឲ្យទ្រង់ជួយសង្គ្រោះវាចុះ ដ្បិតវាបានយកទ្រង់ជាទីគាប់ចិត្តហើយ» ។ «អស់ទាំងឆ្អឹងក្នុងរាងកាយនៃទូលបង្គំរាប់បានទាំងអស់ គេគន់មើល ហើយសម្លឹងមកទូលបង្គំ គេយកសម្លៀកបំពាក់ទូលបង្គំចែកគ្នា ឯអាវវែងរបស់ទូលបង្គំ គេក៏ធ្វើឆ្នោតចាប់យក ឱព្រះយេហូវ៉ាអើយ សូមកុំគង់ឆ្ងាយពីទូលបង្គំឡើយ ឱព្រះដ៏ជាកម្លាំងនៃទូលបង្គំអើយ សូមយាងមកជួយទូលបង្គំជាប្រញាប់ផង» ។ «ទូលបង្គំបានត្រឡប់ដូចជាអ្នកដទៃចំពោះបងប្អូនទូលបង្គំ គឺដូចជាសាសន៍ក្រៅដល់ពួកអ្នកពោះមួយនឹងទូលបង្គំ ។ ដ្បិតសេចក្តីឧស្សាហ៍ដល់ដំណាក់ទ្រង់បានស៊ីបង្ហិនទូលបង្គំ ឯសេចក្តីត្មះតិះដៀលទាំងប៉ុន្មានដែលគេដៀលដល់

ទ្រង់ នោះបានធ្លាក់មកលើទូលបង្គំវិញ» ។ «សេចក្តីត្មះតិះដៀលបានញាំញី ចិត្តទូលបង្គំ ក៏មានសេចក្តីទម្ងន់សង្កត់នៅពេញក្នុងខ្លួន ហើយទូលបង្គំបាន គន់រកអ្នកណាដែលនឹងអាណិតមេត្តា តែឥតមានមួយសោះ ក៏ស្វែងរកអ្នក ណាដែលនឹងកម្សាន្តចិត្ត តែមិនឃើញមួយទេ» (ទំនុកតម្កើង ២២:៦-៨; ១៧, ១៨ និង ៦៩:៨, ៩, ២០) ។

អស្ចារ្យណាស់ លោកអេសាយទស្សទាយយ៉ាងច្បាស់ឥតប្រកែកបាន អំពីការឈឺចាប់និងការសុគតរបស់ព្រះគ្រិស្ត! ហោរាបានសួរថា «តើមានអ្នក ណាបានជឿដំណឹង ដែលយើងប្រាប់» «ហើយព្រះពាហុនៃព្រះយេហូវ៉ាបាន សម្តែងចេញឲ្យអ្នកណាឃើញ ដ្បិតទ្រង់បានចម្រើនធំឡើងនៅចំពោះព្រះអង្គ ដូចជាលំពង់ទន់ខ្ចី ហើយដូចជាឫសដែលពន្លកចេញពីដីហួតហែង ទ្រង់ឥត មានទ្រង់ទ្រាយល្អ ឬសណ្ឋានរុងរឿងទេ ហើយកាលយើងបានមើលទ្រង់ នោះក៏គ្មានភាពលម្អណា ដែលឲ្យយើងរីករាយចិត្តដែរ ទ្រង់ត្រូវគេមើលងាយ ហើយត្រូវមនុស្សបោះបង់ចោល ទ្រង់ជាមនុស្សទូទុក្ខ ហើយក៏ធ្លាប់ស្គាល់ សេចក្តីឈឺចាប់ ទ្រង់ត្រូវគេមើលងាយ ដូចជាអ្នកណាដែលមនុស្សគេចមុខ ចេញ ហើយយើងរាល់គ្នាមិនបានរាប់អានទ្រង់សោះ» ។

«ទ្រង់បានទ្រាំទ្រ រងអស់ទាំងសេចក្តីឈឺចាប់របស់យើង ហើយបាន ទទួលផ្ទុកអស់ទាំងសេចក្តីទុក្ខព្រួយរបស់យើងពិត ប៉ុន្តែ យើងរាល់គ្នាបាន រាប់ទ្រង់ទុកជាអ្នកមានទោសវិញ គឺជាអ្នកដែលព្រះបានវាយ ជាអ្នកដែល រងវេទនា តែទ្រង់ត្រូវរបួស ដោយព្រោះអំពើរំលងរបស់យើង ក៏ត្រូវវាយជាំ ដោយព្រោះអំពើទុច្ចរិតរបស់យើងទេ ឯការវាយផ្ចាលដែលនាំឲ្យយើងបាន ជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឲ្យជា ដោយសារស្នាមរំពាត់នៅអង្គទ្រង់ យើងទាំងអស់គ្នាបានទាសចេញដូចជា ចៀម គឺយើងបានបែរចេញទៅតាមផ្លូវយើងរៀងខ្លួន ហើយព្រះយេហូវ៉ាបាន ទម្លាក់អំពើទុច្ចរិតរបស់យើងទាំងអស់គ្នាទៅលើទ្រង់» ។

«ទ្រង់ត្រូវគេសង្កត់សង្កិន ហើយធ្វើទុក្ខ តែទ្រង់មិនបានហើបព្រះឱស្ឋ

សោះ គឺដូចជាកូនចៀមដែលគេដឹកទៅសម្លាប់ ហើយដូចជាចៀមដែលគនៅចំពោះពួកអ្នកកាត់រោមយ៉ាងណា ទ្រង់ក៏មិនបានហើបព្រះឱស្ឋសោះយ៉ាងនោះដែរ ទ្រង់ត្រូវដកចេញពីអំណាចការពារ ហើយពីសេចក្ដីយុត្តិធម៌ឯសម័យជំនាន់ទ្រង់ តើមានអ្នកណារំពឹងគិតឃើញថា ទ្រង់បានត្រូវកាត់ចេញពីឋានរបស់មនុស្សរស់នេះ ហើយត្រូវវាយ ដោយព្រោះអំពើរំលងរបស់ជនជាតិខ្ញុំនោះ» (អេសាយ ៥៣:១-៨) ។

<u>ច័ន្ទ-៥ តុលា </u>**អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ១៦**

**ខព្រះគម្ពីរប្រចាំថ្ងៃ**: *ទ្រង់នឹងបង្ហាញឲ្យទូលបង្គំឃើញផ្លូវជីវិតវិញ នៅចំពោះទ្រង់មានសេចក្ដីអំណរដ៏ពោរពេញ នៅព្រះហស្តស្តាំទ្រង់មានសេចក្ដីអរសប្បាយជាដរាបតទៅ។ ទំនុកតម្កើង ១៦:១១*

សូម្បីតែលក្ខណៈនៃការសុគតរបស់ទ្រង់ ក៏បានផ្ដល់ជាស្រមោលឲ្យដឹងជាមុនដែរ ។ ដូចជាពស់លង្ហិនត្រូវបានលើកឡើងនៅវាលរហោស្ថានយ៉ាងណា នោះព្រះដ៏ប្រោសលោះក៏បានលើកឡើងយ៉ាងនោះដែរ «ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ» (យ៉ូហាន ៣:១៦) ។

«នោះម្នាក់នឹងសួរថា ចុះតើរបួសអ្វីនុ៎ះនៅដៃអ្នក រួចអ្នកនោះ នឹងឆ្លើយថា គឺយ៉ាងនេះដែលខ្ញុំត្រូវរបួស នៅក្នុងផ្ទះរបស់មិត្រសំឡាញ់ខ្ញុំ» (សាការី ១៣:៦) ។

«ហើយក្នុងកាលដែលទ្រង់សុគត នោះគេក៏បញ្ចុះសពទ្រង់នៅជាមួយនឹងពួកអាក្រក់ ហើយនៅក្នុងផ្នូររបស់អ្នកមានម្នាក់ ទោះបើទ្រង់មិនដែលធ្វើអំពើទុច្ចរិតណាមួយក៏ដោយ ក៏មិនដែលមានការបញ្ឆោតនៅក្នុងព្រះឱស្ឋទ្រង់ផង។ ទោះបើយ៉ាងនោះ គង់តែព្រះយេហូវ៉ាបានសព្វព្រះហឫទ័យនឹងវាយទ្រង់ឲ្យជាំ ហើយឲ្យឈឺចាប់កាលណាព្រះជន្មទ្រង់បានត្រូវថ្វាយទុកជាយញ្ញបូជាលោះបាបហើយ នោះទ្រង់នឹងបានឃើញពូជពង្សរបស់ទ្រង់

ហើយនឹងចម្រើនព្រះជន្មទ្រង់ឲ្យយឺនយូរតទៅ ឯបំណងព្រះហឫទ័យនៃព្រះយេហូវ៉ា នោះនឹងជឿនឡើងដោយព្រះហស្តទ្រង់» (អេសាយ ៥៣:៩, ១០) ។

ប៉ុន្តែ ព្រះដែលបានសុគតដោយសារស្នាដៃរបស់មនុស្សអាក្រក់នឹងមានព្រះជន្មរស់ឡើងវិញ ជាព្រះដែលមានជ័យជម្នះលើអំពើបាបនិងសេចក្តីស្លាប់ ។ នៅក្រោមការលើកទឹកចិត្តពីសំណាក់ព្រះដែលជាអ្នកចម្រៀងដ៏ពីរោះនៃសាសន៍អ៊ីស្រាអែល បានបញ្ជាក់អំពីសិរីរុងរឿងនៃពេលព្រឹកដែលព្រះគ្រិស្តមានព្រះជន្មរស់ឡើងវិញ ។ លោកបានប្រកាសដោយអំណរថា «ហេតុនោះចិត្តទូលបង្គំអរសប្បាយ ហើយកិត្តិយសនៃទូលបង្គំបានរីករាយឡើង រូបសាច់នៃទូលបង្គំក៏នឹងនៅដោយសាន្តត្រាណដែរ ដ្បិតទ្រង់មិនទុកឲ្យព្រលឹងទូលបង្គំនៅក្នុងឋានឃុំព្រលឹងមនុស្សស្លាប់ទេ ក៏មិនព្រមឲ្យអ្នកបរិសុទ្ធរបស់ទ្រង់ឃើញសេចក្តីពុករលួយដែរ» (ទំនុកតម្កើង ១៦:៩, ១០) ។

លោកប៉ុលបានភ្ជាប់ទំនាក់ទំនងយ៉ាងជិតស្និទ្ធអំពីពិធីថ្វាយតង្វាយយញ្ញបូជា ជាមួយនឹងបទទំនាយដែលទាក់ទងទៅនឹងព្រះមួយអង្គដែល «ដូចជាកូនចៀមដែលគេដឹកទៅសម្លាប់» ព្រះមែស្ស៊ីត្រូវតែលះបង់ព្រះជន្មរបស់ទ្រង់ទុកជា «យញ្ញបូជាលោះបាប» ។ ដោយសម្លឹងមើលទៅការប្រោសលោះឲ្យធួននឹងបាបរបស់ព្រះអង្គសង្គ្រោះ នៅគ្រប់សតវត្សរ៍ ហោរាអេសាយបានបញ្ជាក់ថាកូនចៀមរបស់ព្រះ «បានច្រួចព្រលឹងចេញ រហូតដល់ស្លាប់ គេបានរាប់ទ្រង់ទុកជាអ្នកទទឹងច្បាប់ ប៉ុន្តែ ទ្រង់បានទទួលរងទោសនៃអំពើបាបរបស់មនុស្សជាច្រើន ហើយបានអង្វរជំនួសមនុស្សដែលទទឹងច្បាប់វិញ» (អេសាយ ៥៣:៧, ១០, ១២) ។

ព្រះអង្គសង្គ្រោះនៃបទទំនាយនឹងយាងមកមិនមែនជាស្តេច ដែលសោយរាជ្យបណ្តោះ អាសន្ន ឬយាងមករំដោះសាសន៍យូដាឲ្យរួចពីការសង្កត់សង្កិននៅលោកិយនេះប៉ុណ្ណោះទេ ប៉ុន្តែ ទ្រង់ប្រសូតជាមនុស្ស នៅក្នុងចំណោមមនុស្ស រស់នៅក្នុងជីវិតជាអ្នកទ័លក្រ និងការបន្ទាបខ្លួន ហើយ

ទីបំផុត ត្រូវគេមើលងាយ គេបដិសេធ និងសម្លាប់បង់ ។ ព្រះអង្គសង្គ្រោះដែលគម្ពីរសញ្ញាចាស់បានប្រាប់ឲ្យដឹងជាមុននោះ ត្រូវតែលះបង់ព្រះអង្គទ្រង់ទុកជាតង្វាយយញ្ញបូជាជំនួសមនុស្សលោកដែលបានធ្លាក់ចុះ ដើម្បីឲ្យបានសម្រេចតាមតម្រូវការនៃក្រឹត្យវិន័យដែលមនុស្សលោកបានរំលោភបំពាន ។ នៅក្នុងទ្រង់ តង្វាយយញ្ញបូជាដែលជានិមិត្តរូប បានជួបជាមួយនឹងតង្វាយយញ្ញបូជាពិតប្រាកដ ហើយការសុគតរបស់ទ្រង់នៅលើឈើឆ្កាងបានធ្វើឲ្យពិធីបុណ្យនៃសាសន៍យូដាមានសារៈសំខាន់ ។

លោកប៉ុលបានប្រាប់ដល់សាសន៍យូដានៅក្រុងថែស្សាឡូនីច អំពីចិត្តពុះកញ្ជ្រោលរបស់លោកកន្លងមក អំពីច្បាប់នៃពិធីបុណ្យ និងពីបទពិសោធន៍ដ៏អស្ចារ្យរបស់លោកនៅមាត់ទ្វារចូលទៅកាន់ទីក្រុងដាម៉ាស ។ មុនពេលលោកបានផ្លាស់ប្តូរជំនឿ លោកធ្លាប់ត្រូវបានគេ បង្ខាំងនៅក្នុងការគោរពស្រឡាញ់សាសនាមកពីឪពុកម្តាយ ជាសេចក្តីសង្ឃឹមខុស។ ជំនឿរបស់លោកមិនបានបោះយុថ្កាភ្ជាប់ទៅនឹងព្រះគ្រិស្តទេ ផ្ទុយទៅវិញ លោកបានទុកចិត្តទៅលើទម្រង់និងពិធីបុណ្យផ្សេងៗទៅវិញ។ ចិត្តរបស់លោកចំពោះក្រឹត្យវិន័យត្រូវបានកាត់ផ្តាច់ចេញពីជំនឿនៅក្នុងព្រះគ្រិស្ត ហើយគ្មានតម្លៃអ្វីឡើយ ។ នៅពេលអួតខ្លួនឯងថាលោកបរិសុទ្ធគ្មានកន្លែងបន្ទោសបាននៅក្នុងការប្រព្រឹត្តតាមក្រឹត្យវិន័យនោះ លោកបានបដិសេធព្រះដែលបានបង្កើតតម្លៃនៃក្រឹត្យវិន័យនោះ។

<u>អង្គារ-៦ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្យត្រទី១ ជំពូក ១៧

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ព្រះយេហូវ៉ាទ្រង់ជាចំណែកនៃមរដក ហើយជាចំណែកក្នុងពែងរបស់ទូលបង្គំ គឺទ្រង់ហើយ ដែលត្រួតមើលចំណែកទូលបង្គំ ។ ទំនុកតម្កើង ១៦:៥*

ប៉ុន្តែ អ្វីៗទាំងអស់នេះបានផ្លាស់ប្រែ នៅពេលលោកផ្លាស់ប្តូរជំនឿ ។ ព្រះយេស៊ូវពីស្រុកណាសារ៉ែតដែលលោកកំពុងបៀតបៀន នៅក្នុងភាពជា

មនុស្សនៃពួកបរិសុទ្ធរបស់ទ្រង់ បានបង្ហាញអង្គទ្រង់នៅជំពោះមុខលោកជាព្រះមែស្ស៊ីនៃសេចក្តីសន្យា។ លោកប៉ុលជាអ្នកបៀតបៀនបានមើលឃើញទ្រង់ជាព្រះរាជបុត្រារបស់ព្រះ ជាព្រះដែលបានយាងមកកាន់ផែនដីដើម្បីសម្រេចតាមបទទំនាយ និងជាតួអង្គដែលសម្រេចទៅតាមសំណេរនៃព្រះគម្ពីរដ៏ពិសិដ្ឋឥតមានខុសត្រង់ណាសោះ ។

លោកប៉ុលបានប្រកាសដំណឹងល្អក្នុងសាលាប្រជុំនៅទីក្រុងថែស្សាឡូនីចដោយសេចក្តីក្លាហានដ៏បរិសុទ្ធ ជំនន់នៃពន្លឺបានជះទៅលើអត្ថន័យពិតប្រាកដនៃពិធីខាងសាសនានិងពិធីបុណ្យផ្សេងៗ ទាក់ទងទៅនឹងពិធីថ្វាយតង្វាយនៅក្នុងរោងឧបោសថ ។ លោកបាននាំគំនិតអ្នកស្តាប់របស់លោកទៅហួសពីព្រះរាជកិច្ចរបស់ព្រះគ្រិស្តនៅផែនដី ដោយបានសម្រេចកិច្ចការជាអ្នកសម្របសម្រួលរបស់ទ្រង់ នៅគ្រាដែលព្រះគ្រិស្តនឹងយាងមកវិញម្តងទៀត ដោយព្រះចេស្តានិងសិរីល្អដ៏អស្ចារ្យ ហើយបង្កើតនគររបស់ទ្រង់នៅលើផែនដី ។ លោកប៉ុលគឺជាអ្នកជឿទៅលើការយាងមកវិញជាលើកទីពីររបស់ព្រះគ្រិស្ត ដូច្នេះ លោកបានបង្ហាញពីព្រឹត្តិការណ៍នេះយ៉ាងច្បាស់និងមានទម្ងន់ ដែលអ្នកបានឮរឿងនេះនឹងដក់ជាប់នៅក្នុងចិត្តមិនងាយនឹងរលុបបានឡើយ ។

លោកប៉ុលបានអធិប្បាយទៅកាន់ពួកជំនុំនៅក្រុងថែស្សាឡូនីចបីសប្បាតហ៍ដ៏មានជោគជ័យជាប់ៗគ្នា ដោយរៀបរាប់ប្រាប់ដល់ពួកគេចេញពីព្រះគម្ពីរ ទាក់ទងទៅនឹង ព្រះជន្ម ការសុគត ការមានព្រះជន្មរស់ឡើងវិញ កន្លែងដែលទ្រង់បំពេញកិច្ចការ និងអនាគតសិរីល្អរបស់ព្រះគ្រិស្តដែលជា «កូនចៀមដែលត្រូវគេសម្លាប់ តាំងពីកំណើតលោកិយមក» (វិវរណៈ ១៣:៨) ។ លោកបានលើកតម្កើងព្រះគ្រិស្តឲ្យមនុស្សអាចយល់បាន ថាកិច្ចការរបស់ទ្រង់គឺជាកូនសោសម្រាប់បើកគម្ពីរសញ្ញាចាស់ ដើម្បីចូលទៅកាន់ទ្រព្យសម្បត្តិដ៏បរិបូររបស់ពួកគេ ។

ដូច្នេះ ដំណឹងល្អត្រូវបានប្រកាសផ្សាយនៅទីក្រុងថែស្សាឡូនីច ដោយ

អំណាចដ៏អស្ចារ្យ ហើយបានទាក់ទាញចំណាប់អារម្មណ៍ក្រុមជំនុំជាច្រើននាក់។ «ពួកអ្នកនោះខ្លះក៏យល់ព្រម ហើយបានចូលខាងប៉ុល និងស៊ីឡាស ព្រមទាំងពួកសាសន៍ក្រិកសន្ធឹក ដែលតែងតែថ្វាយបង្គំព្រះ និងពួកស្រីអ្នកមុខជាក្រៃលដែរ»។

ចំណែកនៅកន្លែងដែលពួកលោកបានចូលទៅដល់កាលពីមុន ពួកសាវ័កបានជួបជាមួយនឹងការប្រឆាំងយ៉ាងខ្លាំងក្លា។ «ពួកសាសន៍យូដាដែលមិនព្រមជឿ» គេ «មានចិត្តឈ្នានីស» ។ កាលណោះពួកយូដាទាំងនេះមិនពេញចិត្តនឹងរដ្ឋអំណាចរ៉ូមទេ ព្រោះកន្លងមកថ្មីៗនេះពួកគេបានបង្កើតការបះបោរនៅទីក្រុងរ៉ូម។ ពួករដ្ឋអំណាចរ៉ូមបានឃ្លាំមើលពួកគេដោយការសង្ស័យ ហើយសេរីភាពរបស់ពួកគេក៏ត្រូវបានរឹតបន្តឹង។ ឥឡូវនេះ បានមើលឃើញឱកាសមួយក្នុងការកេងយកចំណេញពីកាលៈទេសៈ ដើម្បីបង្កើតការពេញចិត្តសម្រាប់ពួកគេ ហើយនៅពេលជាមួយគ្នានោះ ពួកគេបានស្តីបន្ទោសដល់ពួកសាវ័ក និងអ្នកដែលបានផ្លាស់ប្តូរជំនឿមកជឿសាសនាគ្រិស្ត ។

ពួកគេបានធ្វើការនោះដោយរួបរួមជាមួយនឹង «មនុស្សពាលអនាថាខ្លះមក» រួចប្រមូលបានមនុស្សយ៉ាងសន្ធឹក «ទៅបង្កើតវឹកវរក្នុងទីក្រុង» ដោយសង្ឃឹមថាអាចនឹងរកពួកសាវ័កឃើញ ពួកគេ «នាំគ្នាទៅចោមព័ទ្ធផ្ទះយ៉ាសុន» ប៉ុន្តែ រកប៉ុលនិងស៊ីឡាសមិនឃើញឡើយ «លុះរកមិនឃើញ» ហ្វូងមនុស្សដែលគ្មានសណ្តាប់ធ្នាប់នេះ «ក៏ចាប់យ៉ាសុន និងពួកជំនុំខ្លះកន្ត្រាក់ដឹកនាំទៅដាក់នៅមុខចៅហ្វាយទីក្រុង ដោយស្រែកថា ពួកដែលនាំឲ្យក្រឡាប់ផែនដីនោះ បានមកទីនេះហើយ ឯយ៉ាសុននេះ ជាអ្នកបានទទួលគេ ពួកនោះប្រព្រឹត្តសុទ្ធតែខុសនឹងបញ្ញត្តិរបស់សេសារ ដោយនិយាយថា មានស្តេចមួយទៀត ឈ្មោះយេស៊ូវ» ។

ខណៈដែលពួកគេមិនអាចរកលោកប៉ុលនិងស៊ីឡាសឃើញ ពួកតុលាការបានឲ្យលោកយ៉ាសុនបង់ប្រាក់ធានា ដើម្បីរក្សាភាពស្ងប់ស្ងាត់។ ដោយព្រួយបារម្ភក្រែងមានអំពើហិង្សាកាន់តែខ្លាំងឡើង «ពួកជំនុំក៏ឲ្យប៉ុល និង

ស៊ីឡាស ចេញទៅឯក្រុងបេរា ទាំងយប់ភ្លាម» ។

អស់អ្នកដែលបង្រៀនអំពីសេចក្តីពិតនៅសម័យសព្វថ្ងៃនេះ មិនត្រូវបាក់ទឹកចិត្តឡើយ នៅពេលជួបនឹងការទទួលយកដោយការមិនពេញចិត្ត ដែលលោកប៉ុលនិងសហការីរបស់លោកបានទទួលពីសំណាក់ពួកអ្នកដែលពួកលោកធ្វើការបម្រើនោះឡើយ។ អ្នកនាំសារនៃឈើឆ្កាងត្រូវតែប្រដាប់កាយដោយការចាំយាមនិងការអធិដ្ឋាន ហើយបោះជំហានទៅមុខ ដោយជំនឿនិងសេចក្តីក្លាហាន ព្រមទាំងបំពេញកិច្ចការនៅក្នុងព្រះនាមនៃព្រះយេស៊ូវជានិច្ច។ ពួកគេត្រូវតែលោកតម្កើងព្រះគ្រិស្តថា ជាអ្នកសម្របសម្រួលរបស់មនុស្សនៅរោងឧបោសថនៃឋានសួគ៌ ជាព្រះដែលជាមជ្ឈមណ្ឌលសម្រាប់ចែកចាយអំពីតង្វាយយញ្ញបូជានៃគម្ពីរសញ្ញាចាស់ទាំងអស់ ដែលពួកអ្នកបំពានទៅនឹងក្រឹត្យវិន័យរបស់ព្រះអាចនឹងរកឃើញនូវសេចក្តីសុខសាន្តនិងការអត់ឱនទោសនៅក្នុងតង្វាយធួននឹងបាបរបស់ទ្រង់ ។

ជំពូកទី
២៣

# ទីក្រុងបេរា និងទីក្រុងអាថែន

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ១៧:១១-៣៤ ។*

<u>ពុធ-៧ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ១៨

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *នោះទ្រង់មានព្រះបន្ទូលមកខ្ញុំថា ចូរទៅចុះ ដ្បិតខ្ញុំនឹងចាត់អ្នកឲ្យទៅឯសាសន៍ដទៃដែលនៅឆ្ងាយ។ កិច្ចការ ២២:២១*

នៅទីក្រុងបេរា លោកប៉ុលបានរកឃើញសាសន៍យូដាដែលចង់សង្កេតការណ៍ពីសេចក្តីពិតដែលលោកបានបង្រៀន។ លោកលូកាបានកត់ត្រាអំពីកំណត់ត្រានៃពួកគេយ៉ាងដូច្នេះ៖ «រីឯពួកអ្នកស្រុកនោះ មានចិត្តល្អជាងពួកអ្នកនៅថែស្សាឡូនីច គេប្រុងប្រៀបសព្វគ្រប់នឹងទទួលព្រះបន្ទូល ក៏ពិចារណាមើលគម្ពីររាល់តែថ្ងៃឲ្យបានដឹងជាសេចក្តីទាំងនោះត្រូវឬមិនត្រូវ»។

គំនិតរបស់ពួកអ្នកក្រុងបេរាមិនបានចង្អៀតចង្អល់ ដោយការប្រកាន់ពូជសាសន៍ទេ។ ពួកគេចង់សង្កេតពិនិត្យភាពពិតនៃគោលលទ្ធិដែលពួកសាវ័កបានអធិប្បាយ។ ពួកគេបានសិក្សាព្រះគម្ពីរមិនមែនដោយការចង់ដឹងចង់ឮទេ ប៉ុន្តែ ដើម្បីឲ្យពួកគេអាចដឹងថាតើព្រះគម្ពីរនោះបានសរសេរយ៉ាងដូចម្តេចអំពីព្រះមែស្ស៊ីដែលព្រះបានសន្យា ។ ពួកគេបានស្រាវជ្រាវកំណត់ត្រាក្នុងសំណេរនៃព្រះគម្ពីរនេះជារៀងរាល់ថ្ងៃ ហើយនៅពេលដែលពួកគេបានប្រៀបធៀបពីបទគម្ពីរមួយ ទៅបទគម្ពីរមួយ ពួកទេវតានៃឋានសួគ៌គង់នៅក្បែរពួកគេ បំភ្លឺគំនិតពួកគេ និងធ្វើឲ្យចិត្តគេមានចំណាប់អារម្មណ៍ ។

នៅកន្លែងណាដែលសេចក្តីពិតនៃដំណឹងល្អត្រូវបានប្រកាសផ្សាយ អ្នកដែលប្រាថ្នាចង់ប្រព្រឹត្តអំពើល្អ ត្រូវបានដឹកនាំឲ្យខំស្វែងយល់ពីព្រះគម្ពីរ

យ៉ាងយកចិត្តទុកដាក់ ។ នៅសម័យចុងក្រោយនៃប្រវត្តិសាស្ត្រផែនដីនេះ ប្រសិនបើអ្នកដែលបានសាកល្បងសេចក្តីពិតដែលត្រូវបានប្រកាស បានខំស្វែងយល់ពីព្រះគម្ពីរជារៀងរាល់ថ្ងៃ ហើយប្រៀបធៀបសារដែលពួកគេបានទទួលជាមួយនឹងព្រះបន្ទូលរបស់ព្រះ ដូចជាអ្នកក្រុងបេរានោះ ម្ល៉េះសមសព្វថ្ងៃនេះមានអ្នកស្មោះត្រង់ទៅនឹងបញ្ញត្តិនៃក្រឹត្យវិន័យរបស់ព្រះជាច្រើន បើប្រៀបធៀបទៅនឹងពេលបច្ចុប្បន្ននេះ ដែលមានតែមួយចំនួនតូចប៉ុណ្ណោះ។ ប៉ុន្តែ កាលណាសេចក្តីពិតនៃព្រះគម្ពីរដែលមិនសូវមានប្រជាប្រិយត្រូវបានប្រកាស មនុស្សជាច្រើនមិនព្រមខិតខំស្វែងយល់ដោយខ្ជាប់ខ្ជួនទេ។ ទោះបីជាមិនអាចប្រឆាំងទៅនឹងការបង្រៀនយ៉ាងច្បាស់នៃព្រះគម្ពីរក៏ដោយ ក៏ពួកគេនៅតែបង្ហាញការស្ទាក់ស្ទើរក្នុងការសិក្សាពីភ័ស្តុតាងដែលបានផ្តល់ឲ្យនោះដែរ។ អ្នកខ្លះបានសន្មតថាទោះបីជាគោលលទ្ធិទាំងនេះពិតប្រាកដយ៉ាងណាក៏ដោយ ក៏ការទទួលយកឬមិនទទួលយកពន្លឺថ្មីនេះ វាមិនជាបញ្ហាអ្វីធ្ងន់ធ្ងរដែរ ហើយពួកគេបានប្រកាន់ខ្ជាប់នូវរឿងមិនពិតដែលខ្មាំងសត្រូវប្រើប្រាស់ដើម្បីដឹកនាំមនុស្សឲ្យវង្វេងនេះយ៉ាងសប្បាយរីករាយ។ ដូច្នេះគំនិតរបស់ពួកគេត្រូវបានបិទបាំងឲ្យងងឹតដោយភាពខុសឆ្គង ហើយត្រូវបានបំបែកចេញពីឋានសួគ៌។

ព្រះនឹងជំនុំជម្រះមនុស្សគ្រប់គ្នាទៅតាមពន្លឺដែលព្រះអង្គបានប្រទានដល់ពួកគេ ។ ព្រះជាម្ចាស់បានចាត់រាជទូតរបស់ព្រះអង្គជាមួយនឹងព្រះរាជសារនៃសេចក្តីសង្គ្រោះ ហើយអ្នកដែលឮ ព្រះអង្គនឹងទទួលខុសត្រូវចំពោះរបៀបដែលពួកគេប្រព្រឹត្តទៅលើពាក្យសម្តីនៃអ្នកបម្រើរបស់ទ្រង់។ អស់អ្នកដែលស្វែងរកសេចក្តីពិតយ៉ាងស្មោះអស់ពីចិត្ត នឹងពិនិត្យអង្កេតយ៉ាងយកចិត្តទុកដាក់ នៅក្នុងពន្លឺនៃព្រះបន្ទូលរបស់ព្រះ ពីគោលលទ្ធិដែលបានបង្ហាញដល់ពួកគេ ។

ពួកអ្នកមិនជឿជាសាសន៍យូដាដែលនៅទីក្រុងថែស្សាឡូនីច ដែលមានការច្រណែននិងសម្អប់ចំពោះពួកសាវ័ក ហើយដែលមិនសប្បាយចិត្តនឹង

ការបណ្តេញពួកសាវ័កចេញពីទីក្រុងរបស់ពួកគេនោះ បានតាមពួកសាវ័កទៅ ទីក្រុងបេរា ហើយបំផុសឲ្យមានភាពរំជើបរំជួលនៅក្នុងមនុស្សស្រទាប់ក្រោម ។ ដោយព្រួយបារម្ភក្រែងមានអំពើហិង្សាកើតឡើងដល់លោកប៉ុល ប្រសិនបើលោកបន្តនៅទីនោះតទៅទៀត បងប្អូនរួមជំនឿក៏បានបញ្ជូនលោកទៅកាន់ទីក្រុងអាថែន អមដំណើរដោយអ្នកក្រុងបេរាដែលទើបនឹងបានទទួលជំនឿកាលពីពេលថ្មីៗនេះមួយចំនួន។

ដូច្នេះការធ្វើទុក្ខបៀតបៀនបានតាមពួកគ្រូបង្រៀនពីសេចក្តីពិតពីទីក្រុងមួយទៅទីក្រុងមួយ។ សត្រូវរបស់ព្រះគ្រិស្តមិនអាចទប់ទល់នឹងការរីកចម្រើនទៅមុខនៃដំណឹងល្អបានទេ ប៉ុន្តែ ពួកវាមានជោគជ័យក្នុងការធ្វើឲ្យកិច្ចការរបស់ពួកសាវ័កជួបនឹងការពិបាកយ៉ាងក្រៃលែង។ ប៉ុន្តែ នៅចំពោះការប្រឆាំងនិងទំនាស់នេះ លោកប៉ុលបានជំរុញកិច្ចការឆ្ពោះទៅមុខយ៉ាងរឹងមាំ ដោយប្តេជ្ញាចិត្តថានឹងអនុវត្តតាមព្រះរាជគោលបំណងដែលព្រះបានបើកបង្ហាញឲ្យលោកបានឃើញនៅទីក្រុងយេរូសាឡិមថា «ចូរទៅចុះ ដ្បិតខ្ញុំនឹងចាត់អ្នកឲ្យទៅឯសាសន៍ដទៃដែលនៅឆ្ងាយ» (កិច្ចការ ២២:២១) នោះឲ្យទាល់តែបានសម្រេច។

<u>ព្រហស្បតិ៍-៨ តុលា</u> **អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ១៩**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *«គួរឲ្យយើងខ្ញុំនៅក្រុងអាថែនតែម្នាក់ឯងចុះ»។ ថែស្សាឡូនីចទី១ ៣:១*

លោកប៉ុលបានប្រញាប់រួសរាន់ចេញពីទីក្រុងបេរាដែលមិនបានផ្តល់ឱកាសដល់លោក ហើយបានគិតថានឹងទៅសួរសុខទុក្ខបងប្អូននៅទីក្រុងថែស្សាឡូនីច ។

លុះបានមកដល់ទីក្រុងអាថែន លោកប៉ុលបានបញ្ជូនបងប្អូនដែលបានមកជាមួយលោកពីក្រុងបេរា ឲ្យនាំដំណឹងទៅប្រាប់លោកស៊ីឡាសនិងធីម៉ូថេឲ្យមកជួបនឹងលោកជាបន្ទាន់ ។ លោកធីម៉ូថេបានមកដល់ទីក្រុងបេរាមុន

ពេលលោកប៉ុលបានចេញដំណើរមក ហើយបាននៅបន្តកិច្ចការដែលបាន ចាប់ផ្ដើមឡើងយ៉ាងល្អនៅទីនេះជាមួយនឹងលោកស៊ីឡាស ព្រមទាំងបាន បង្រៀនដល់អ្នកជឿថ្មីអំពីគោលការណ៍នៃសេចក្ដីជំនឿផងដែរ ។

ទីក្រុងអាថែនគឺជារាជធានីនៃពួកអ្នកមិនជឿសាសនា។ នៅទីនេះ លោក ប៉ុលមិនបានជួបជាមួយនឹងមនុស្សល្ងិតល្ងង់ មនុស្សស្រទាប់ក្រោមដែល ឆាប់ជឿ ដូចកាលនៅទីក្រុងលីស្ត្រានោះទេ ប៉ុន្តែ លោកបានជួបជាមួយនឹង មនុស្សដែលមានឈ្មោះល្បីខាងចំណេះវិជ្ជានិងមានវប្បធម៌ខ្ពស់ម្តង។ រូប ចម្លាក់របស់ព្រះក្លែងក្លាយ និងរូបវីរបុរសនិងកវីនៃប្រវត្តិសាស្ត្របានទាក់ ភ្នែកនៅគ្រប់ទិសទី នៅពេលដែលជាងចម្លាក់និងវិចិត្រករល្បីៗបានបង្ហាញ ពីសិរីរុងរឿងនៃប្រទេសជាតិនិងប្រជាប្រិយភាពនៃការថ្វាយបង្គំរូបសំណាក របស់ពួកអ្នកដែលមិនជឿសាសនា។ វិញ្ញាណរបស់ប្រជារាស្ត្រ ត្រូវបានពោរ ពេញទៅដោយសម្រស់នៃភាពរុងរឿងនៃសិល្បៈ។ នៅតាមបង្កាន់ដៃនៃរាល់ ទីបរិសុទ្ធនិងព្រះវិហារ លម្អដោយរូបធំៗ ដែលមានតម្លៃរកកាត់ថ្លៃមិនបាន។ ជោគជ័យនៃស្នាដៃនិងទង្វើរបស់បុរសល្បីៗត្រូវបានរំឭកដោយ រូបចម្លាក់ ស្តូបអនុស្សាវរីយ៍ និងបន្ទះថ្ម។ ទាំងអស់នេះបានធ្វើឲ្យទីក្រុងអាថែន ក្លាយ ទៅជាទីប្រជុំនៃសិល្បៈដ៏សំបូរបែប។

លោកប៉ុលបានសម្លឹងមើលទៅឯសម្រស់នៃភាពថ្កុំថ្កើងដែលនៅជុំវិញ លោក ហើយបានឃើញទីក្រុងទាំងមូលថ្វាយបង្គំរូបព្រះ ចិត្តរបស់លោកពោរ ពេញដោយសេចក្ដីច្រណែនជំនួសព្រះ ដែលលោកបានឃើញគេប្រមាថ គ្រប់ទីកន្លែង ហើយចិត្តលោកពោរពេញទៅដោយសេចក្ដីអាណិតអាសូរ ដល់ប្រជារាស្ត្រនៅក្រុងអាថែន ដែលមិនបានដឹងអ្វីពីព្រះសោះ ទោះបីជា ពួកគេមានវប្បធម៌ល្បីល្បាញយ៉ាងណាក៏ដោយ ។

សាវ័កប៉ុលមិនត្រូវបានបោកបញ្ឆោតដោយអ្វីដែលលោកបានឃើញ នៅក្នុងតំបន់ដែលមានការចេះដឹងនេះទេ។ និស្ស័យខាងព្រលឹងវិញ្ញាណ របស់លោកមានភាពរស់រវើកជាខ្លាំង ដល់ការទាក់ទាញពីរឿងរ៉ាវ នៃឋានសួគ៌

ដែលធ្វើឲ្យអំណារនិងសិរីរុងរឿងនៃពួកអ្នកមានដែលមិនធ្លាប់បានវិនាសមិនមានតម្លៃ នៅក្នុងក្រសែភ្នែករបស់លោក ដោយសារភាពអ៊ឹកធឹកនិងភាពរុងរឿងដែលនៅព័ទ្ធជុំវិញលោក ។

កាលលោកបានឃើញភាពល្អឆើតឆាយនៃទីក្រុងអាថែន លោកបានដឹងអំពីអំណាចនៃការទាក់ទាញទឹកចិត្ត ទៅលើអ្នកស្រឡាញ់សិល្បៈនិងវិទ្យាសាស្ត្រ ហើយគំនិតរបស់លោកបានជិតដាមយ៉ាងជ្រៅ ដោយសារៈសំខាន់នៃកិច្ចការដែលនៅចំពោះមុខលោក ។

នៅក្នុងទីក្រុងដ៏ធំដែលគេមិនបានថ្វាយបង្គំព្រះនេះ លោកប៉ុលត្រូវបានសង្កត់សង្កិនដោយអារម្មណ៍ឯកោ ហើយមានចិត្តអាណិតអាសូរនិងចង់ជួយដល់អ្នករួមការងាររបស់លោកកន្លងមក ខណៈដែលទំនាក់ទំនងជាមិត្តភាពត្រូវបានផ្សាភ្ជាប់ លោកមានអារម្មណ៍ឯកោខ្លាំងមែនទែន។ នៅក្នុងសំបុត្ររបស់លោក ផ្ញើទៅកាន់ពួកជំនុំនៅទីក្រុងថែស្សាឡូនីច លោកបានបញ្ជាក់ពីអារម្មណ៍របស់លោក ជាពាក្យសម្ដីយ៉ាងដូច្នេះ៖ «គួរឲ្យយើងខ្ញុំនៅក្រុងអាថែនតែម្នាក់ឯងចុះ» (ថែស្សឡូនីចទី១ ៣:១)។ ឧបសគ្គដែលពុំអាចពុះពារបានយ៉ាងជាក់ច្បាស់នៅចំពោះមុខលោក ធ្វើឲ្យលោកហាក់ដូចជាអស់សង្ឃឹមថានឹងអាចទាក់ទាញទឹកចិត្តរបស់ពួកបណ្ឌិតជនបាន។

កាលលោកកំពុងរង់ចាំលោកស៊ីឡាសនិងធីម៉ូថេ លោកប៉ុលមិនបានខ្ជិលច្រអូសទេ។ លោក «ក៏ជជែកពន្យល់ដល់សាសន៍យូដា និងពួកអ្នកដែលថ្វាយបង្គំក្នុងសាលាប្រជុំគេ ហើយនៅទីផ្សារ ជាមួយនឹងអស់អ្នកដែលមកជួបនឹងគាត់រាល់តែថ្ងៃដែរ» ។ ប៉ុន្តែ កិច្ចការចម្បងរបស់លោកនៅទីក្រុងអាថែន គឺផ្សាយដំណឹងល្អនៃសេចក្ដីសង្គ្រោះដល់អ្នកមិនយល់ដឹងអំពីព្រះ និងព្រះរាជគោលបំណងរបស់ទ្រង់ ជំនួសពូជមនុស្សមានបាប។ មិនយូរប៉ុន្មានសាវ័កប៉ុលបានជួបនឹងអ្នកមិនជឿព្រះនៅក្នុងទម្រង់ដ៏ប៉ិនប្រសប់និងគួរឲ្យស្រើបស្រាល។

សុក្រ-៩ តុលា អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ២០

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *សូមឲ្យព្រះអម្ចាស់ចំរើនសេចក្តីស្រឡាញ់របស់អ្នករាល់គ្នា ឲ្យបានពេញពោរហូរហៀរដល់គ្នាទៅវិញទៅមក ព្រមទាំងដល់មនុស្សទាំងអស់ផង ដូចជាយើងខ្ញុំស្រឡាញ់ដល់អ្នករាល់គ្នាដែរ។*
*ថែស្សាឡូនីចទី១ ៣:១២*

មនុស្សល្បីៗនៅទីក្រុងអាថែនមិនចង់ឲ្យមានគ្រូបង្រៀនណាម្នាក់ នៅក្នុងទីក្រុងរបស់ពួកគេ ដែលបង្រៀនអំពីគោលលទ្ធិថ្មីនិងចម្លែកនោះទេ។ ពួកមនុស្សទាំងនេះខ្លះបានស្វែងរកលោកប៉ុល ហើយបានចូលទៅសន្ទនាជាមួយនឹងលោក មិនយូរប៉ុន្មាន ហ្វូងមនុស្សដែលជាអ្នកស្តាប់ បានប្រមូលគ្នាជុំវិញពួកលោក ។ មានពួកគេខ្លះបានរៀបចំចំអកឲ្យពួកសាវ័ក ថាជាអ្នកដែលទន់ទាបជាងពួកគេជាខ្លាំង ទាំងខាងសង្គមនិងទាំងខាងប្រាជ្ញា ហើយពួកអ្នកទាំងនេះបាននិយាយចំអកនៅក្នុងចំណោមពួកគេថា «តើអ្នកដែលនិយាយប៉ប៉ាច់នេះចង់ថាដូចម្តេច?» ខ្លះទៀតថា «មើលទៅដូចជាគាត់សម្តែងពីព្រះដទៃទេ ដ្បិតឮគាត់ប្រាប់គេពីព្រះយេស៊ូវ ហើយពីសេចក្តីរស់ពីស្លាប់ឡើងវិញ»។

នៅក្នុងចំណោមមនុស្សដែលបានជួបលោកប៉ុលនៅទីផ្សារនោះមាន «ពួកអេពីគួរ និងពួកស្ទអ៊ីកខ្លះ ជាអ្នកប្រាជ្ញបរមត្ថ»។ ប៉ុន្តែ មិនយូរប៉ុន្មាន ពួកគេនិងពួកអ្នកដែលបានមកទាក់ទងជាមួយនឹងលោកបានដឹងថាចំណេះដឹងរបស់សាវ័កប៉ុលមានច្រើនជាងចំណេះដឹងរបស់ពួកគេជាខ្លាំង។ អំណាចដ៏មានប្រាជ្ញារបស់សាវ័កប៉ុលតម្រូវឲ្យពួកអ្នកចេះដឹងគោរពដល់លោក ខណៈដែលភាពស្មោះត្រង់ ហេតុផលជាក់លាក់ និងអំណាចនៃការអធិប្បាយរបស់លោកបានទាក់ទាញចំណាប់អារម្មណ៍អ្នកស្តាប់ទាំងអស់ ។ អ្នកស្តាប់របស់លោកបានដឹងអំពីរឿងពិតដែលថា លោកមិនមែនជាអ្នកដែលមិនសូវមានបទពិសោធន៍ទេ ប៉ុន្តែ លោកអាចជួបជាមួយនឹងមនុស្សគ្រប់ស្រទាប់វណ្ណៈក្នុងការជជែកវែកញែកដែលគេអាចយល់បាន ដើម្បីគាំទ្រដល់គោលលទ្ធិ

ដែលលោកបានបង្រៀន។ ដូច្នេះ សាវ័ករូបនេះបានឈរយ៉ាងរឹងមាំដោយគ្មានការភ័យខ្លាចប្រឈមមុខ ជាមួយនឹងពួកអ្នកប្រឆាំង ផ្ទុះផ្ទង់សេចក្តីពិតជាមួយនឹងសេចក្តីពិត ទស្សនវិជ្ជា ជាមួយនឹងទស្សនវិជ្ជា វោហារសាស្ត្រជាមួយនឹងវោហារសាស្ត្រ ។

ពួកអ្នកប្រឆាំងដែលមិនជឿសាសនារបស់លោកបានទាក់ទាញអារម្មណ៍របស់លោកទៅឯលោកសូក្រាត ជាអ្នកដែលគេបង្គាប់ឲ្យយកទៅសម្លាប់ដោយសារលោកបានបង្កើតព្រះចម្លែកៗ ហើយពួកគេបានទូន្មានដល់លោកប៉ុលកុំឲ្យយកជីវិតរបស់លោកទៅប្រថុយរបៀបនោះឡើយ។ ប៉ុន្តែ សុន្ទរកថារបស់សាវ័កប៉ុលបានបង្វែរចំណាប់អារម្មណ៍របស់ពួកបណ្តាជន ហើយប្រាជ្ញាដ៏មានឥទ្ធិពលរបស់លោកទាមទារឲ្យមានការគោរព និងការកោតសរសើរ។ លោកមិនបានស្ញៀមស្ងាត់ដោយសារវិទ្យាសាស្ត្រ ឬការចំអកឡកឡឺយរបស់ពួកទស្សនវិទូនោះទេ ហើយលោកមានទំនុកចិត្តលើខ្លួនឯងថាលោកបានប្តេជ្ញាចិត្តសម្រេចកិច្ចការរបស់លោកនៅក្នុងចំណោមពួកគេ និងនិយាយប្រាប់អំពីរឿងរ៉ាវរបស់លោក ទោះបីជាមានគ្រោះថ្នាក់យ៉ាងណាក៏ដោយ ហើយពួកគេក៏បានតាំងចិត្តស្តាប់យ៉ាងយកចិត្តទុកដាក់ ។

ពួកគេក៏បាននាំលោកទៅកាន់ទីទួលអើរីយ៉ូស។ ទីនេះគឺជាកន្លែងដែលពិសិដ្ឋបំផុតនៅទីក្រុងអាថែន ហើយពិធីខាងសាសនានិងការជួបជុំគ្នានៅទីនេះធ្វើឲ្យកន្លែងនោះបានក្លាយទៅជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ដែលមនុស្សជាច្រើនមានការភ័យតក់ស្លុត។ គឺនៅកន្លែងនេះហើយដែលមនុស្ស បានធ្វើសកម្មភាពជាចៅក្រមចុងក្រោយបង្អស់ ទៅលើសីលធម៌សំខាន់ៗទាំងឡាយ ក៏ដូចជាសំណួរខាងរដ្ឋប្បវេណីដែរ ដែលតែងតែពិចារណាយ៉ាងយកចិត្តទុកដាក់អំពីរឿងរ៉ាវដែលទាក់ទងទៅនឹងសាសនា ។

នៅទីនេះ ជាកន្លែងដាច់ឆ្ងាយពីសូរសំឡេងនិងពីផ្លូវដែលមានហ្វូងមនុស្សមមាញឹកញាប់ដៃញាប់ជើង និងឆ្ងាយពីការពិភាក្សានៃហ្វូងមនុស្សដ៏ច្របូកច្របល់ មនុស្សអាចឮសំឡេងរបស់សាវ័កប៉ុលដោយគ្មានការរំខាន ។

ពួកអ្នកកវី សិល្បករ ទស្សនវិទូ សុទ្ធសឹងតែជាអ្នកប្រាជ្ញនៃទីក្រុងអាថែន បានប្រជុំគ្នានៅជុំវិញលោក ហើយពោលទៅកាន់លោកថា «តើលោកអាចប្រាប់ឲ្យយើងដឹងអំពីលទ្ធិថ្មីដែលលោកបង្រៀននោះបានឬទេ? ដ្បិតយើងបានឮលោកថ្លែងរឿងចំឡែកៗ យើងចង់ដឹងអត្ថន័យណាស់ ។ អ្នកក្រុងអាថែន និងជនបរទេសឯទៀតៗ ដែលរស់នៅក្នុងក្រុងនោះ មិនធ្វើអ្វីផ្សេងទៀតក្រៅពីនិយាយ ឬស្តាប់រឿងថ្មីៗនោះឡើយ» ។

នៅពេលដែលមានការទទួលខុសត្រូវយ៉ាងធំនេះ សាវ័កបាន រក្សាភាពស្ងៀមស្ងាត់និងភាពម្ចាស់ការ ។ ចិត្តរបស់លោកឆេះឆួលទៅដោយសារៈដ៏សំខាន់ ហើយសម្តីដែលបានចេញពីបបូរមាត់របស់លោកមក បានបំផ្លាស់បំប្រែអ្នកស្តាប់របស់លោកថា លោកមិនមែនជាមនុស្សដែលចេះតែនិយាយប៉ប៉ាច់ប៉ប៉ោចនោះឡើយ ។ លោកបានមានប្រសាសន៍ថា «ឱពួកអ្នកនៅក្រុងអាថែនអើយ» «ក្នុងការទាំងអស់ខ្ញុំយល់ឃើញថា អ្នករាល់គ្នាឧស្សាហ៍ខ្នះខ្នែងកាន់សាសនាណាស់ ដ្បិតកំពុងដែលខ្ញុំដើរចុះឡើងមើលប្រដាប់ប្រដាដែលអ្នករាល់គ្នាគោរពបូជា នោះខ្ញុំឃើញមានអាសនាមួយដែលមានចារិកថា ព្រះដ៏ពុំស្គាល់ ដូច្នេះ ខ្ញុំនឹងប្រាប់ដល់អ្នករាល់គ្នាពីព្រះដែលអ្នករាល់គ្នាគោរពបូជា ដោយឥតស្គាល់នោះឯង»។ ជាមួយនឹងប្រាជ្ញានិងចំណេះទូទៅរបស់ពួកគេ គេមិនបានស្គាល់ព្រះដែលបានបង្កើតលោកសន្និវាសនេះទេ។ តែក៏មានពួកគេខ្លះចង់ទទួលពន្លឺដ៏ធំដែរ។ ពួកគេបានឈោងទៅរកព្រះដ៏គ្មានព្រំដែន ។

លោកប៉ុលបានបញ្ចេញបន្ទុកនៃចិត្តរបស់លោក ដោយដៃលាតសន្ធឹងទៅកាន់ព្រះវិហារដែលមានពេញទៅដោយរូបចម្លាក់ ហើយបានបង្ហាញឲ្យឃើញនូវជំនឿខុសនៃសាសនានៅទីក្រុងអាថែន។ អ្នកស្តាប់ដែលមានប្រាជ្ញាបំផុតរបស់លោកមានការភ្ញាក់ផ្អើលជាខ្លាំង នៅពេលដែលពួកគេបានឮហេតុផលរបស់លោក។ លោកបង្ហាញដល់ពួកគេថាលោកបានស្គាល់កិច្ចការនៃសិល្បៈរបស់ពួកគេ អក្សរសាស្ត្រនិងវប្បធម៌របស់ពួកគេ។ ដោយ

ចង្អុលទៅរូបសំណាកនិងរូបព្រះរបស់ពួកគេ លោកបានប្រកាសប្រាប់ថា មនុស្សមិនអាចផ្សាភ្ជាប់ព្រះទៅនឹងទម្រង់នៃស្នាដៃរបស់មនុស្សឡើយ។ រូបចម្លាក់នេះ ទោះបីជាល្អយ៉ាងណាក៏ដោយ ក៏មិនអាចតំណាងឲ្យសិរីល្អនៃព្រះយេហូវ៉ាបានដែរ។ លោកបានរំឭកដល់ពួកគេថារូបចម្លាក់ទាំងនេះមិនមានជីវិតទេ ប៉ុន្តែ ត្រូវបានគ្រប់គ្រងដោយអំណាចរបស់មនុស្សអាចកម្រើកបាន តែនៅពេលដែលមនុស្សយកដៃទៅរំកិលប៉ុណ្ណោះ ហើយហេតុដូច្នេះ អ្នកណាដែលថ្វាយបង្គំដល់រូបនោះ អ្នកនោះឯងធំប្រសើរជាងរូបដែលខ្លួនថ្វាយបង្គំនោះ ។

<u>សៅរ៍-១០ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ២១

**ខព្រះគម្ពីរប្រចាំសប្តាហ៍:** *ប្រយោជន៍នឹងតាំងចិត្តអ្នករាល់គ្នា ឲ្យបរិសុទ្ធ ឥតសៅហ្មង នៅចំពោះព្រះដ៏ជាព្រះវរបិតារបស់យើងរាល់គ្នា ក្នុងកាលដែលព្រះយេស៊ូវ ជាព្រះអម្ចាស់នៃយើង ទ្រង់យាងមក ជាមួយនឹងអស់ទាំងអ្នកបរិសុទ្ធរបស់ទ្រង់។ ថែស្សាឡូនីចទី១ ៣:១៣*

លោកប៉ុលបាននាំគំនិតពួកអ្នកស្តាប់របស់លោកដែលថ្វាយបង្គំរូបព្រះទៅហួសពីព្រំដែននៃសាសនាក្លែងក្លាយរបស់ពួកគេ រហូតដល់ទស្សនៈពិតប្រាកដស្តីអំពីភាពជាព្រះ ដែលជា «ព្រះដែលពួកគេនៅតែមិនស្គាល់»។ ព្រះដែលលោកកំពុងតែប្រកាសប្រាប់ដល់ពួកគេនៅពេលឥឡូវនេះ គឺជាព្រះដែលមិនត្រូវការទីពឹងដល់មនុស្សទេ ដែលមិនត្រូវការអ្វីចេញពីដៃរបស់មនុស្ស ដើម្បីបន្ថែមទៅលើព្រះចេស្តានិងសិរីល្អរបស់ទ្រង់ឡើយ ។

ពួកបណ្ឌាជនបាននាំយកទៅជាមួយនូវការសរសើរដល់ភាពស្មោះត្រង់ និងការបង្ហាញយ៉ាងត្រឹមត្រូវរបស់លោកប៉ុល អំពីលក្ខណៈរបស់ព្រះអំពីព្រះចេស្តានៃការបង្កើតលោក និងភាពបិតថេរខាងទិព្វញ្ញាណនៃការគ្រប់គ្រងរបស់ទ្រង់ ។ សាវ័កប៉ុលបានប្រកាសដោយស្មោះត្រង់ និងវោហារយ៉ាងប៉ិនប្រសប់ថា «ដ្បិតព្រះដែលបង្កើតលោកិយ និងរបស់សព្វសារពើ ព្រះអង្គនោះ

ទ្រង់ជាព្រះអម្ចាស់នៃឋានសួគ៌ និងផែនដី ទ្រង់មិនគង់នៅក្នុងវិហារដែលដៃមនុស្សបានធ្វើទេ ក៏មិនបាច់មានដៃមនុស្សបម្រើទ្រង់ដូចជាទ្រង់ត្រូវការអ្វីនោះផងដែរ ដ្បិតគឺទ្រង់ដែលផ្តត់ផ្គង់ដោយព្រះអង្គទ្រង់ឲ្យគ្រប់ទាំងអស់មានជីវិត មានដង្ហើមគ្រប់ជំពូក ទ្រង់បានបង្កើតមនុស្សគ្រប់សាសន៍ពីឈាមតែមួយឲ្យបាននៅពេញលើផែនដី ព្រមទាំងសម្រេចកំណត់ពេលវេលាដែលបានតាំងជាមុន និងព្រំទីលំនៅរបស់គេគ្រប់គ្នា»។ សូម្បីតែឋានសួរក៏មិនមានទំហំគ្រប់គ្រាន់អាចឲ្យទ្រង់គង់នៅបានផង ចុះទម្រាំព្រះវិហារដែលដៃមនុស្សធ្វើនោះរឹតតែតូចខ្លាំងណាស់ទៅទៀត!

នៅសម័យដែលមានការបែងចែកវណ្ណៈ កាលដែលសិទ្ធិមនុស្សត្រូវបានគេមិនគោរព លោកប៉ុលបានមានប្រសាសន៍អំពីសេចក្តីពិតដ៏ធំនៃភាពជាបងប្អូន ដោយមានប្រសាសន៍ថា ព្រះ «ប្រទានឲ្យប្រជាជាតិនានា កើតចេញមកពីមនុស្សតែម្នាក់ ហើយឲ្យគេរស់នៅពាសពេញលើផែនដីទាំងមូល»។ មនុស្សទាំងអស់មានភាពស្មើៗគ្នានៅចំពោះព្រះនេត្ររបស់ព្រះ ហើយមនុស្សទាំងអស់បានជំពាក់ភក្តីភាពយ៉ាងខ្ពង់ខ្ពស់ចំពោះព្រះអាទិករ ។ បន្ទាប់មកសាវ័កប៉ុលបានបង្ហាញពីរបៀបដែលគោលបំណងនៃព្រះគុណ និងសេចក្តីមេត្តាករុណារបស់ទ្រង់រត់ដូចជាខ្សែមាស ឆ្លងកាត់ដំណោះស្រាយទាំងអស់របស់ទ្រង់ ជាមួយនឹងមនុស្ស។ «ព្រះអង្គបានកំណត់រដូវកាល និងកំណត់ព្រំដែនឲ្យមនុស្សរស់នៅ។ ព្រះជាម្ចាស់ធ្វើដូច្នេះ ដើម្បីឲ្យគេស្វែងរកព្រះអង្គ ហើយបើគេខ្នះខ្នែងរកព្រះអង្គមែននោះ ប្រហែលជាគេនឹងរកព្រះអង្គឃើញ។ តាមពិត ព្រះជាម្ចាស់មិនគង់នៅឆ្ងាយពីយើងម្នាក់ៗទេ» ។

ដោយចង្អុលទៅកាន់គំរូដ៏ថ្លៃថ្នូរនៃឈាមរបស់លោក អំពីរូបលោក លោកបានបង្ហាញរូបភាពនៃព្រះដ៏គ្មានព្រំដែន ជាពាក្យកាព្យ ថាជា ព្រះវរបិតាដែលពួកគេទាំងអស់គ្នាសុទ្ធតែជាកូនរបស់ទ្រង់។ លោកបានមានប្រសាសន៍ថា «ដ្បិតយើងមានជីវិត មានចលនា និងមានភាវៈជាមនុស្ស ដោយសារព្រះអង្គ» ។ អ្នកកវីលើកកំណាព្យខ្លះរបស់អ្នករាល់គ្នាតែងពោលថា៖ «យើង

ក៏ជាពូជរបស់ព្រះអង្គដែរ» ។ ហេតុនេះ ប្រសិនបើយើងពិតជាពូជរបស់ព្រះជាម្ចាស់មែន យើងមិនត្រូវគិតថា ព្រះអង្គមានសណ្ឋានដូចរូបសំណាកធ្វើពីមាស ប្រាក់ ឬថ្មដែលជាក្បាច់រចនាកើតឡើង តាមការនឹកឃើញរបស់មនុស្សនោះឡើយ ។

«ព្រះជាម្ចាស់មិនប្រកាន់ទោសមនុស្សលោក ក្នុងគ្រាដែលគេមិនទាន់ស្គាល់ព្រះអង្គនៅសម័យមុនៗនោះទេ តែឥឡូវនេះ ព្រះអង្គប្រទានដំណឹងដល់មនុស្សទាំងអស់ដែលរស់នៅគ្រប់ទីកន្លែង ឲ្យគេកែប្រែចិត្តគំនិត» ។ នៅក្នុងយុគសម័យដ៏ខ្មៅងងឹត ដែលបានកើតឡើងនៅមុនសម័យព្រះគ្រិស្តព្រះដែលជាអ្នកដឹកនាំ បានឃាងកាត់ការថ្វាយបង្គំព្រះដោយពន្លឺ ប៉ុន្តែ ឥឡូវនេះ តាមរយៈព្រះរាជបុត្រារបស់ទ្រង់ ព្រះអង្គបានប្រទានពន្លឺនៃសេចក្តីពិតមកដល់មនុស្សលោក ហើយព្រះអង្គបានរំពឹងចង់បានពីអ្នកដែលបានកែប្រែចិត្តមកឯសេចក្តីសង្គ្រោះមិនត្រឹមតែពួកអ្នកក្រីក្រនិងអ្នកទន់ទាបប៉ុណ្ណោះទេ ប៉ុន្តែ ពីក្នុងចំណោមពួកទស្សនវិទូដ៏អំនួត និងស្តេចនៃផែនដីនេះផងដែរ។ «ដ្បិតព្រះអង្គបានកំណត់ថ្ងៃមួយទុក ដើម្បីវិនិច្ឆ័យទោសមនុស្ស តាមសេចក្តីសុចរិត ដោយសារបុរសម្នាក់ដែលព្រះអង្គបានតែងតាំង។ ព្រះអង្គបានប្រោសបុរសនោះឲ្យរស់ឡើងវិញ ទុកជាភស្តុតាងសម្រាប់មនុស្សទាំងអស់»។ កាលលោកប៉ុលបានមានប្រសាសន៍អំពីការមានព្រះជន្មរស់ឡើងវិញ «ដូច្នេះអ្នកខ្លះក៏ចំអកឲ្យ អ្នកខ្លះទៀតពោលថា៖ «ចាំលើកក្រោយ យើងនឹងស្តាប់លោកមានប្រសាសន៍អំពីរឿងនេះទៀត»។

ដូច្នេះ នៅទីបញ្ចប់នៃកិច្ចការរបស់សាវ័កនៅទីក្រុងអាថែន ជាមជ្ឈមណ្ឌលនៃអ្នកចេះដឹង ពួកអ្នកក្រុងអាថែននៅតែប្រកាន់នូវការថ្វាយបង្គំរូបព្រះរបស់ពួកគេ និងបានបែរចេញពីពន្លឺនៃសាសនាដ៏ពិតដដែល ។ កាលពួកបណ្តាជនមានការពេញចិត្តទៅនឹងការសម្រេចចិត្តរបស់ពួកគេទាំងស្រុង ពួកគេមានសេចក្តីត្រូវការនូវការរំពឹងចង់បានបន្ថែមទៀតតែបន្តិចបន្តួចប៉ុណ្ណោះ។ ទោះបីជាគេមានអំនួតនឹងចំណេះដឹងនិងភាពស្អាតស្អំរបស់ខ្លួនក៏ដោយ ក៏ពួកអ្នក

ក្រុងអាថែនបានត្រឡប់ទៅជាពុករលួយ និងពេញចិត្តនឹងការថ្វាយបង្គំរូបព្រះដ៏អាថ៌កំបាំងយ៉ាងស្រពិចស្រពិល កាន់តែខ្លាំងឡើងៗដែរ ។

<u>អាទិត្យ-១១ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ២២

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ដ្បិតដំណឹងពីឈើឆ្កាង នោះជាសេចក្ដីចំកួត ដល់អស់អ្នកដែលកំពុងតែវិនាស តែជាព្រះចេស្ដានៃព្រះ ដល់យើងរាល់គ្នាដែលកំពុងតែបានសង្គ្រោះវិញ។ កូរិនថូសទី១ ១:១៨*

នៅក្នុងចំណោមមនុស្សដែលបានស្ដាប់ប្រសាសន៍របស់លោកប៉ុលមានខ្លះដែរ ដែលសេចក្ដីពិតបាននាំមកនូវការកែប្រែចិត្តដល់គំនិតរបស់ពួកគេ ប៉ុន្តែ ពួកគេមិនបានបន្ទាបខ្លួនទៅរកចំណេះដឹងពីព្រះ និងទទួលផែនការនៃសេចក្ដីសង្គ្រោះទេ។ មិនមានវោហារកោសល្យណា កម្លាំងនៃការជជែកវែកញែកណា ដែលអាចបំផ្លាស់បំប្រែបាបជនបានឡើយ មានតែព្រះចេស្ដារបស់ព្រះប៉ុណ្ណោះ ដែលអាចដាក់សេចក្ដីពិតនៅក្នុងចិត្តបាន។ អ្នកដែលបានងាកបែរចេញពីអំណាចនេះ គ្មានអ្នកណាផ្សេងទៀតអាចចូលទៅដល់បានឡើយ។ ពួកសាសន៍ក្រិកបានស្វែងរកប្រាជ្ញា ប៉ុន្តែ សារនៃឈើឆ្កាងជាការឆោតល្ងង់សម្រាប់ពួកគេ ពីព្រោះ ពួកគេបានឲ្យតម្លៃប្រាជ្ញារបស់ខ្លួនឯងខ្ពស់ជាងប្រាជ្ញាដែលមកពីឋានលើ។

ប្រហែលជាដោយសារតែអំនួតនៃចំណេះដឹងនិងប្រាជ្ញារបស់មនុស្សនេះហើយ ដែលជាមូលហេតុនាំឲ្យសារខាងដំណឹងល្អបានទទួលជោគជ័យយ៉ាងតិចតួចស្ដួចស្ដើង នៅទីក្រុងអាថែន។ មនុស្សមានប្រាជ្ញាខាងលោកិយដែលចូលមកឯព្រះគ្រិស្ដជាអ្នកមានបាបដែលត្រូវបាត់បង់យ៉ាងកម្សត់ នឹងក្លាយជាអ្នកមានប្រាជ្ញានៅក្នុងសេចក្ដីសង្គ្រោះ ប៉ុន្តែ អ្នកដែលមករកទ្រង់ក្នុងលក្ខណៈខុសប្លែកពីអ្នកខាងដើមនេះ ដោយលើកតម្កើងប្រាជ្ញារបស់ខ្លួនឯងនឹងមិនបានទទួលពន្លឺនិងចំណេះដឹងដែលមានតែព្រះមួយអង្គគត់ទើបអាចប្រទានឲ្យបាននោះទេ។

ដូច្នេះ លោកប៉ុលបានជួបជាមួយនឹងពួកអ្នកមិនជឿសាសនានៅសម័យរបស់លោក។ កិច្ចការរបស់លោកនៅទីក្រុងអាថែនមិនឥតប្រយោជន៍ទាំងស្រុងនោះទេ។ លោកឌេវនីស ជាពលរដ្ឋម្នាក់ដែលលេចមុខជាងគេ និងមនុស្សដទៃទៀតដែលបានទទួលសារនៃដំណឹងល្អ ហើយរួបរួមទាំងស្រុងជាមួយនឹងពួកអ្នកជឿ។

ព្រះវិញ្ញាណបានប្រទានពន្លឺនៅក្នុងជីវិតអ្នកក្រុងអាថែន ដែលមានភាពស្អាតស្អំនិងសិល្បៈរុងរឿង ព្រមទាំងមានចំណេះដឹងគ្រប់បែបយ៉ាង តែនៅខ្វះប្រាជ្ញាដែលអាចមើលឃើញព្រះ បានស្ដីបន្ទោសដល់ការថ្វាយបង្គំរូបព្រះ និងអំពើបាបនៃអំនួត និងមនុស្សដែលស្កប់ស្កល់នឹងជីវិតខ្លួនឯង តាមរយៈពួកអ្នកបម្រើរបស់ទ្រង់។ ពាក្យសម្ដីរបស់សាវ័ក និងការពណ៌នាពីអាកប្បកិរិយា និងការហ៊ុំព័ទ្ធរបស់លោក ដូចដែលព្រះគម្ពីរបានចារទុកមក ត្រូវបានទុកបន្តឲ្យមនុស្សប្រកាន់ខ្ជាប់នៅគ្រប់សម័យកាល ដោយធ្វើបន្ទាល់ពីទំនុកចិត្តដែលមិនរង្គើរបស់លោក សេចក្ដីក្លាហាននៅក្នុងភាពឯកោ និងភាពខ្វះខាតរបស់លោក ព្រមទាំងជោគជ័យដែលលោកទទួលបានសម្រាប់គ្រិស្តសាសនានៅក្នុងចិត្តនៃពួកអ្នកមិនជឿសាសនាគ្រប់ៗគ្នា។

ប្រសាសន៍របស់លោកប៉ុលមានពេញទៅដោយចំណេះដឹងដ៏មហាសាលសម្រាប់ពួកជំនុំ។ លោកបាននៅក្នុងស្ថានភាពដែលលោកអាចនិយាយបានថាអាចបង្កកំហឹងដល់អ្នកស្ដាប់ដ៏អំនួតរបស់លោក ហើយនាំឲ្យលោកធ្លាក់ចូលទៅក្នុងការពិបាកបានយ៉ាងងាយ។ ប្រសិនបើសុន្ទរកថារបស់លោកបានវាយប្រហារដោយផ្ទាល់ ទៅលើព្រះនិងវីរបុរសរបស់ពួកគេ នៅក្នុងទីក្រុងនោះ លោកនឹងធ្លាក់ចូលទៅក្នុងគ្រោះថ្នាក់ ដូចជាវាសនារបស់ពួកលោកសូក្រាតជាក់ជាមិនខាន។ ប៉ុន្តែ ដោយភាពឆ្លាតវាងវៃនៃសេចក្ដីស្រឡាញ់របស់ព្រះ លោកបានទាក់ទាញគំនិតរបស់ពួកគេចេញពីព្រះក្លែងក្លាយនៃពួកអ្នកមិនជឿសាសនា ដោយប្រុងប្រយ័ត្នដោយបង្ហាញដល់ពួកគេអំពីព្រះពិតជាព្រះដែលពួកគេមិនស្គាល់។

សព្វថ្ងៃនេះ បទគម្ពីរបាននាំមកនៅចំពោះវីរបុរសទាំងឡាយនៅលើពិភពលោកនេះ ដើម្បីឲ្យពួកគេជ្រើសរើសរវាងការស្ដាប់បង្គាប់តាមក្រឹត្យវិន័យរបស់ព្រះនិងភក្ដីភាពចំពោះមេនៃអំពើអាក្រក់។ ព្រះបានដាក់សេចក្ដីពិតដ៏នៅអស់កល្បនៅចំពោះមុខពួកគេ ជាសេចក្ដីពិតដែលធ្វើឲ្យពួកគេមានប្រាជ្ញាអំពីសេចក្ដីសង្គ្រោះ ប៉ុន្តែ ព្រះអង្គមិនបានបង្ខំពួកគេឲ្យទទួលសេចក្ដីពិតនោះទេ។ ប្រសិនបើពួកគេបែរចេញពីសេចក្ដីពិតនោះ ព្រះអង្គទុកពួកគេឲ្យរស់នៅដោយខ្លួនឯងឲ្យពោរពេញទៅដោយផលផ្លែនៃអំពើដែលពួកគេប្រព្រឹត្តដោយផ្ទាល់។

«ដ្បិតដំណឹងពីឈើឆ្កាង នោះជាសេចក្ដីចម្កួតដល់អស់អ្នកដែលកំពុងតែវិនាស តែជាព្រះចេស្ដានៃព្រះ ដល់យើងរាល់គ្នាដែលកំពុងតែបានសង្គ្រោះវិញ ព្រោះមានសេចក្ដីចែងទុកមកថា អញនឹងបំផ្លាញប្រាជ្ញារបស់ពួកអ្នកប្រាជ្ញ ហើយនឹងលើកចំណេះរបស់ពួកអ្នកដែលចេះ ចោលចេញ»។ «ព្រះទ្រង់បានរើសពួកល្ងង់ល្ងើនៅលោកិយនេះ ដើម្បីនឹងធ្វើឲ្យអ្នកប្រាជ្ញមានសេចក្ដីខ្មាសវិញ ទ្រង់បានរើសពួកកម្សោយនៅលោកិយនេះ ដើម្បីនឹងធ្វើឲ្យពួកខ្លាំងពូកែមានសេចក្ដីខ្មាស ហើយទ្រង់បានរើសអ្នកទាបថោកនៅលោកិយនេះ និងពួកអ្នកដែលគេមើលងាយ ព្រមទាំងរបស់ដែលគ្មានផង ដើម្បីនឹងលើកចោលរបស់ដែលមានចេញ» (កូរិនថូសទី១ ១:១៨, ១៩; ២៧, ២៨) ។ ពួកអ្នកប្រាជ្ញនិងពួកបុរសជាច្រើន ជាមនុស្សខ្ពង់ខ្ពស់បំផុតនៅលើពិភពលោក នឹងរត់ចេញពីពន្លឺនៅសម័យចុងក្រោយនេះ ពីព្រោះដោយសារប្រាជ្ញានៃលោកិយ ពួកគេមិនបានស្គាល់ព្រះឡើយ។ ប៉ុន្តែ ព្រះនៅតែបង្កើនឱកាសឲ្យអ្នកបម្រើរបស់ទ្រង់បង្ហាញពីសេចក្ដីពិតជាមួយនឹងពួកមនុស្សទាំងអស់នេះ។ ពួកគេមួយចំនួននឹងទទួលស្គាល់ភាពល្ងិតល្ងង់អំពីកិច្ចការខាងឯព្រះរបស់ពួកគេ ហើយដាក់ខ្លួនជាអ្នករៀនសូត្រដ៏បន្ទាបខ្លួននៅទៀបព្រះបាទព្រះយេស៊ូវ ជាព្រះគ្រូដ៏ធំរបស់ពួកគេ។

នៅក្នុងការខំប្រឹងប្រែងឈោងចាប់មនុស្សដែលមានឋានៈខ្ពង់ខ្ពស់ ពួក

អ្នកបម្រើរបស់ព្រះត្រូវតែមានជំនឿរឹងមាំ។ សភាពការណ៍មើលទៅហាក់ដូចជាគួរឲ្យខ្លាច ប៉ុន្តែ នៅក្នុងពេលវេលាដ៏ខ្មៅងងឹត នឹងមានពន្លឺមកពីលើ កម្លាំងរបស់អ្នកស្រឡាញ់និងអ្នកដែលធ្វើការបម្រើដល់ព្រះនឹងត្រូវបានបង្កើតជាថ្មីឡើងវិញ ពីមួយថ្ងៃទៅមួយថ្ងៃ។ ការយល់អំពីព្រះដ៏គ្មានព្រំដែននឹងត្រូវបានសាកនៅក្នុងកិច្ចការរបស់ពួកគេ ដែលនៅក្នុងការអនុវត្តន៍តាមគោលបំណងរបស់ព្រះអង្គ ពួកគេនឹងមិនដែលមានកំហុសឡើយ។ សូមឲ្យពួកអ្នកធ្វើការទាំងនេះប្រកាន់ខ្ជាប់នូវទំនុកចិត្តយ៉ាងរឹងមាំ តាំងពីដើមរហូតដល់ទីបញ្ចប់ ដោយចងចាំថាពន្លឺនៃសេចក្ដីពិតរបស់ព្រះ នឹងភ្លឺចែងចាំងទៅលើពិភពលោកដ៏ងងឹតរបស់យើងនេះ។ មិនមានការអាក់អន់ចិត្តណានៅក្នុងកិច្ចការរបស់ព្រះឡើយ។ ជំនឿរបស់អ្នកធ្វើការដែលមានការលះបង់ត្រូវតែឈរនៅលើរាល់ការសាកល្បងដែលកើតឡើងដល់ជំនឿនោះ។ ព្រះអាចនិងសព្វព្រះហឫទ័យចង់ប្រទានកម្លាំង និងប្រាជ្ញាដែលពួកគេត្រូវការជាចាំបាច់ដល់អ្នកបម្រើការរបស់ទ្រង់។ ព្រះអង្គនឹងបំពេញការរំពឹងចង់បានយ៉ាងខ្ពស់បំផុតរបស់អ្នកដែលទុកចិត្តទៅលើទ្រង់។

## ជំពូកទី
## ២៤

# ទីក្រុងកូរិនថូស

*ជំពូកនេះមានមូលដ្ឋាននៅក្នុងគម្ពីរកិច្ចការ ១៨:១-១៨ ។*

<u>ច័ន្ទ-១២ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ២៣

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នា ដោយខ្ញុំមានចិត្តលំបាក ហើយថប់ព្រួយ ព្រមទាំងស្រក់ទឹកភ្នែកជាច្រើន មិនមែនចង់ឲ្យអ្នករាល់គ្នាព្រួយដែរនោះទេ គឺចង់ឲ្យអ្នករាល់គ្នាស្គាល់សេចក្ដីស្រឡាញ់ ដែលខ្ញុំមានជាបរិបូរដល់អ្នករាល់គ្នាប៉ុណ្ណោះឯង។ កូរិនថូសទី២ ២:៤*

នៅសតវត្សរ៍ទីមួយនៃសម័យគ្រិស្តបរិស័ទ កូរិនថូសគឺជាទីក្រុងមួយដែលនាំមុខគេនៃទីក្រុងទាំងឡាយ មិនត្រឹមតែនៅក្នុងប្រទេសក្រិកប៉ុណ្ណោះទេ គឺនៅលើពិភពលោកទាំងមូល  សាសន៍ក្រិក យូដា និងរ៉ូម ជាមួយនឹងពួកអ្នកដំណើរមកពីគ្រប់ទិសទី ដើរពពាក់ពពូនតាមវិថីនានា ក្នុងគោលបំណងធ្វើជំនួញនិងស្វែងរកការសប្បាយផ្សេងៗ។ ជាមជ្ឈមណ្ឌលសេដ្ឋកិច្ចដ៏ធំតាំងនៅកន្លែងដែលមានផ្លូវចូលមកកាន់យ៉ាងងាយស្រួល ពីគ្រប់ផ្នែកទាំងអស់នៃចក្រភពរ៉ូម ទីក្រុងនេះ គឺជាកន្លែងដ៏សំខាន់ក្នុងការបង្កើតការរំឭកអំពីព្រះនិងសេចក្ដីពិតរបស់ទ្រង់។

នៅក្នុងចំណោមជនជាតិយូដាដែលបានតាំងទីលំនៅក្នុងទីក្រុងកូរិនថូស មានអ័គីឡា និងព្រីស៊ីល ដែលក្រោយមកបានក្លាយជាអ្នកល្បីឈ្មោះថាជាអ្នកធ្វើការថ្វាយព្រះគ្រិស្តដ៏ស្មោះត្រង់។ ដោយបានស្គាល់អត្តចរិតរបស់មនុស្សទាំងនេះយ៉ាងច្បាស់ លោកប៉ុល «ស្នាក់នៅ ហើយធ្វើការជាមួយនឹងគេ»។

នៅគ្រាដំបូងបំផុតនៃកិច្ចការរបស់លោកនៅតាមផ្លូវនៃការធ្វើដំណើរ

នេះ លោកប៉ុលបានមើលឃើញឧបសគ្គធំៗរារាំងដល់ការជឿនលឿននៃកិច្ចការរបស់លោកនៅគ្រប់ទិសទី។ ទីក្រុងទាំងមូលសឹងតែត្រូវបានញាំញីដោយការថ្វាយបង្គំរូបព្រះ។ ព្រះនាងកាមទេពគឺជាព្រះដែលគេនិយមចូលចិត្តជាងគេ ហើយពិធីខាងសាសនានិងពិធីបុណ្យផ្សេងៗជាច្រើនដែលនាំឲ្យប្រព្រឹត្តខុស ត្រូវបានភ្ជាប់ជាមួយនឹងការថ្វាយបង្គំព្រះនាងកាមទេពនេះ។ កូរិនថូសបានក្លាយជាទីក្រុងដែលលេចធ្លោជាងគេ សូម្បីនៅក្នុងចំណោមប្រជាជាតិនានា ដោយសារភាពគ្មានសីលធម៌របស់ពួកគេ។ ពួកគេហាក់ដូចជាមិនគិតឬខ្វល់ខ្វាយអំពីអ្វីក្រៅពីឱកាសនៃការសប្បាយនិងភាពសប្បាយរីករាយនោះឡើយ។

ក្នុងការអធិប្បាយដំណឹងល្អនៅទីក្រុងកូរិនថូស សាវ័កប៉ុលបានប្រើរបៀបផ្សេងពីកាលដែលលោកបានធ្វើនៅទីក្រុងអាថែន។ ចំណែកនៅតាមកន្លែងក្រោយៗមកទៀត លោកបានតម្រូវវិធីសាស្ត្ររបស់លោកទៅតាមអត្តចរិតរបស់អ្នកស្តាប់ លោកបានប្រើហេតុផលទល់នឹងហេតុផល វិទ្យាសាស្ត្រតទល់នឹងវិទ្យាសាស្ត្រ ទស្សនវិជ្ជាទល់នឹងទស្សនវិជ្ជា។ នៅពេលដែលលោកបានគិតពីពេលវេលាដែលលោកបានចំណាយ ហើយបានដឹងថាការបង្រៀនរបស់លោកនៅទីក្រុងអាថែនបានបង្កើតផលផ្លែតិចតួចប៉ុណ្ណោះ លោកក៏បានសម្រេចចិត្តប្រើផែនការមួយផ្សេងទៀតនៅទីក្រុងកូរិនថូស នៅក្នុងការខំប្រឹងប្រែងរបស់លោកដើម្បីទាក់ទាញចំណាប់អារម្មណ៍អ្នកដែលមិនយកចិត្តទុកដាក់និងពួកអ្នកដែលព្រងើយកន្តើយ។ លោកបានតាំងចិត្តចៀសវាងការជជែកវែកញែក និងការពិភាក្សា ហើយ «នោះខ្ញុំមិនព្រមស្តាប់រឿងអ្វីទៀតក្រៅពីព្រះយេស៊ូវគ្រិស្តទេ ហើយគឺដែលទ្រង់ត្រូវឆ្កាងផង» នៅក្នុងចំណោមអ្នកក្រុងកូរិនថូសទេ។ លោកបានអធិប្បាយប្រាប់ពួកគេ «មិនមែនដោយពាក្យឧត្តុង្គឧត្តម ដែលពូកែបញ្ចុះបញ្ចូលនោះដែរ គឺដោយការសម្តែងចេញជាព្រះវិញ្ញាណ និងព្រះចេស្តាវិញទេតើ» (កូរិនថូសទី២ ២:២, ៤) ។

ព្រះយេស៊ូវដែលលោកប៉ុលនឹងបង្ហាញដល់សាសន៍ក្រិក នៅទីក្រុងកូរិនថូសថាជាព្រះគ្រិស្តនោះ មានដើមកំណើតនៅទីក្រុងដែលសុភាសិតបានចែងថា

ជាទីក្រុងដ៏អាក្រក់ ជាសាសន៍យូដាដែលមានត្រកូលទន់ទាប ។ ទ្រង់ត្រូវសាសន៍របស់ព្រះអង្គបដិសេធ ហើយទីបំផុត គេបានយកទ្រង់ទៅឆ្កាងដូចជាឧក្រិដ្ឋជន។ សាសន៍ក្រិកជឿថាពួកគេត្រូវការមនុស្សដែលមានត្រកូលខ្ពស់ ប៉ុន្តែ ពួកគេបានគោរពការសិក្សាទស្សនវិជ្ជានិងវិទ្យាសាស្រ្តថាជាមធ្យោបាយតែមួយគត់ដើម្បីទទួលបាននូវភាពខ្ពង់ខ្ពស់និងកិត្តិយសពិតប្រាកដ។ តើលោកប៉ុលអាចដឹកនាំពួកគេឲ្យជឿថា ជំនឿទៅលើអំណាចនៃសាសន៍យូដាដែលងងឹតងងល់នឹងលើកតម្កើងនិងធ្វើឲ្យអំណាចរបស់មនុស្សមានតម្លៃបានដែរឬទេ?

ចំពោះគំនិតរបស់មនុស្សជាច្រើនដែលរស់នៅសម័យបច្ចុប្បន្ននេះ ឈើឆ្កាងនៅកាល់វ៉ារីព័ទ្ធជុំវិញដោយអនុស្សាវរីយ៍ដ៏ពិសិដ្ឋជាច្រើន។ សហាគមដ៏បរិសុទ្ធជាច្រើនបានភ្ជាប់ទំនាក់ទំនងជាមួយនឹងកន្លែងកើតហេតុនៃការជាប់ឆ្កាង។ ប៉ុន្តែ នៅសម័យលោកប៉ុល ឈើឆ្កាងត្រូវបានគេចាត់ទុកថាជាការស្អប់ខ្ពើមនិងអំពើអាក្រក់ ។ ការលើកតម្កើងព្រះដែលជួយសង្គ្រោះមនុស្សលោកដែលបានសុគតនៅលើឈើឆ្កាងនោះបង្កើតឲ្យមានការចំអក និងការប្រឆាំងយ៉ាងពិតប្រាកដ ។

**<u>អង្គារ-១៣ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ២៤**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ដ្បិតខ្ញុំគ្មានសេចក្តីខ្មាស ចំពោះដំណឹងល្អនៃព្រះគ្រីស្ទទេ ពីព្រោះជាព្រះចេស្តានៃព្រះ សំរាប់នឹងជួយសង្គ្រោះដល់អស់អ្នកណាដែលជឿ គឺដល់ទាំងសាសន៍យូដាជាដើម និងសាសន៍ក្រេកផង។ រ៉ូម ១:១៦*

លោកប៉ុលបានជ្រាបច្បាស់ថាទាំងសាសន៍ក្រិកនិងសាសន៍យូដានៅក្នុងទីក្រុងកូរិនថូសនឹងចាត់ទុកសាររបស់លោកនេះទៅជាយ៉ាងណា។ លោកបានទទួលស្គាល់ថា «យើងខ្ញុំប្រកាសប្រាប់ពីព្រះគ្រិស្ត ដែលទ្រង់ត្រូវឆ្កាងវិញ ជាហេតុនាំឲ្យរវាតចិត្តដល់សាសន៍យូដា និងជាសេចក្តីល្ងង់ល្ងើដល់សាសន៍ក្រិក» (កូរិនថូសទី១ ១:២៣)។ នៅក្នុងចំណោមពួកអ្នកដែល

ស្តាប់លោកជាសាសន៍យូដា មានមនុស្សជាច្រើនបានខឹងសម្បាដោយសារដែលលោកបម្រុងនឹងប្រកាសនេះ។ នៅក្នុងការប៉ាន់ប្រមាណរបស់សាសន៍ក្រិក សម្តីរបស់លោកគឺជាពាក្យមិនសមហេតុផលយ៉ាងលីលា។ ពួកគេបានចាត់ទុកលោកប៉ុលជាមនុស្សដែលមានគំនិតទន់ខ្សោយ ដោយលោកប៉ុនប៉ងបង្ហាញថាឈើឆ្កាងមានទំនាក់ទំនងទៅនឹងការលើកតម្កើងដល់មនុស្សជាតិ ឬសេចក្តីសង្គ្រោះរបស់មនុស្សលោកនោះ។

ប៉ុន្តែ សម្រាប់លោកប៉ុល ឈើឆ្កាងគឺជាវត្ថុដែលគួរឲ្យចាប់អារម្មណ៍យ៉ាងខ្ពង់ខ្ពស់។ ចាប់តាំងពីព្រះបានចាប់លោកនៅក្នុងកិច្ចការធ្វើទុក្ខបៀតបៀនប្រឆាំងនឹងអ្នកដើរតាមព្រះយេស៊ូវពីស្រុកណាសារ៉ែតដែលជាប់ឆ្កាងមក លោកមិនដែលឈប់លើកតម្កើងឈើឆ្កាងទេ។ នៅពេលនោះ ព្រះបានបើកបង្ហាញឲ្យលោកបានឃើញនូវសេចក្តីស្រឡាញ់ដ៏គ្មានព្រំដែនរបស់ព្រះ ដែលបានបង្ហាញឲ្យឃើញនៅក្នុងការសុគតរបស់ព្រះគ្រិស្ត និងការបំផ្លាស់បំប្រែដ៏អស្ចារ្យ ដែលបាននាំមកដល់ជីវិតរបស់លោក និងបាននាំមកនូវផែនការទាំងអស់របស់លោកឲ្យស្របទៅនឹងឋានសួគ៌។ ចាប់តាំងពីពេលនោះមក លោកគឺជាមនុស្សថ្មីនៅក្នុងព្រះគ្រិស្ត។ លោកបានដឹងដោយបទពិសោធន៍ផ្ទាល់ខ្លួនថា នៅពេលដែលមនុស្សមានបាបបានឃើញសេចក្តីស្រឡាញ់នៃព្រះវរបិតា នៅក្នុងការលះបង់ព្រះរាជបុត្រារបស់ទ្រង់ ហើយបានទោរទន់ទៅរកឥទ្ធិពលនៃព្រះ ការផ្លាស់ប្តូរចិត្តបានកើតឡើង ហើយចាប់តាំងពីពេលនោះមកព្រះគ្រិស្តគឺជាគ្រប់ទាំងអស់ ។

នៅពេលនៃការផ្លាស់ប្តូរជំនឿរបស់គាត់ ព្រះបានលើកទឹកចិត្តដល់លោកប៉ុលឲ្យមានចិត្តចង់ជួយដល់មនុស្សឲ្យមើលឃើញព្រះយេស៊ូវ ថាជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់ ដែលមានព្រះចេស្តាអាចផ្លាស់ប្តូរចិត្ត និងអាចជួយសង្គ្រោះ។ ចាប់តាំងពីពេលនោះមក ជីវិតរបស់លោកត្រូវបានលះបង់ទាំងស្រុងសម្រាប់ការខិតខំពណ៌នាអំពីសេចក្តីស្រឡាញ់ និងព្រះចេស្តានៃព្រះអង្គដែលត្រូវបានគេឆ្កាង។ ចិត្តលោកមានការអាណិតអាសូរដ៏ធំចំពោះមនុស្សគ្រប់ស្រទាប់វណ្ណៈ។ លោកបានមានប្រសាសន៍ថា «ខ្ញុំមាន

សេចក្តីជំពាក់ទាំងសាសន៍ក្រិក និងសាសន៍ដទៃ ទាំងអ្នកប្រាជ្ញ និងអ្នកខ្លៅផង» (រ៉ូម ១:១៤) ។ សេចក្តីស្រឡាញ់ចំពោះព្រះនៃសិរីល្អ ជាព្រះដែលត្រូវគេធ្វើទុក្ខបៀតបៀនឥតឈប់ឈរ នៅក្នុងភាពជាមនុស្សបរិសុទ្ធរបស់ទ្រង់ គឺជាគោលការណ៍ដ៏មុតស្រួចក្នុងអាកប្បកិរិយានិងអំណាចនៃមូលហេតុរបស់លោក ប្រសិនបើភាពភ្លៀវភ្លានៅក្នុងផ្លូវនៃភារកិច្ចរបស់លោកបានទ្រោមចុះ ការក្រឡេកមើលទៅឈើឆ្កាងមួយភ្លែត ហើយសេចក្តីស្រឡាញ់ដ៏អស្ចារ្យដែលបានបង្ហាញនៅទីនោះ ក៏ល្មមឲ្យលោកយកជ័យជម្នះលើតោកំណាចនៅក្នុងគំនិតរបស់លោក ហើយបោះជំហានទៅមុខតាមផ្លូវនៃការលះបង់ខ្លួនឯង។

មើល សាវ័កប៉ុលកំពុងអធិប្បាយនៅក្នុងសាលាប្រជុំនៅទីក្រុងកូរិនថូស រៀបរាប់ពីសំណេររបស់លោកម៉ូសេ និងពួកហោរា ហើយបាននាំអ្នកស្តាប់របស់លោកចុះទៅរហូតដល់ការយាងមករបស់ព្រះមែស៊ី។ ដោយបានស្តាប់ការរៀបរាប់យ៉ាងជាក់ច្បាស់អំពីកិច្ចការរបស់ព្រះដ៏ប្រោសលោះជាសម្តេចសង្ឃរបស់មនុស្សលោក ជាព្រះមួយអង្គដែលបានលះបង់ព្រះជន្មរបស់ទ្រង់ដើម្បីជាតង្វាយឲ្យធួននឹងបាបរបស់មនុស្ស មួយដងជាសម្រេច ហើយបន្ទាប់មកបានបំពេញកិច្ចការរបស់ទ្រង់នៅក្នុងទីបរិសុទ្ធនៃឋានសួគ៌។ ពួកអ្នកស្តាប់របស់លោកប៉ុលបានយល់ថាព្រះមែស៊ីដែលពួកគេបានរង់ចាំទ្រង់នោះ បានយាងមករួចទៅហើយ និងថាការសុគតរបស់ទ្រង់គឺជាការសម្រេចពិតប្រាកដនៃតង្វាយយញ្ញបូជាទាំងឡាយ ហើយព្រះរាជកិច្ចរបស់ទ្រង់នៅក្នុងរោងឧបោសថនៅឋានសួគ៌គឺជាសេចក្តីពិតនៃស្រមោលស្តីពីកិច្ចការរបស់ពួកសង្ឃនៃសាសន៍យូដាកន្លងមក ។

លោកប៉ុល «ក៏ធ្វើបន្ទាល់អស់ពីចិត្តដល់សាសន៍យូដាថា ព្រះយេស៊ូវជាព្រះគ្រិស្តពិត» ។ ចេញពីគម្ពីរសញ្ញាចាស់ លោកបានបង្ហាញថា យោងតាមបទទំនាយ និងការរំពឹងរង់ចាំជាសាកលរបស់សាសន៍យូដា ព្រះមែស៊ីគឺជាសែស្រឡាយរបស់លោកអ័ប្រាហាំ និងស្តេចដាវីឌ បន្ទាប់មក លោកបានរៀបរាប់ពីពូជអំបូររបស់លោកតាអ័ប្រាហាំ រហូតដល់រាជវង្សស្តេចដែល

សរសេរគម្ពីរទំនុកតម្កើង។ លោកបានអានទីបន្ទាល់របស់ពួកហោរា ទាក់ទងនឹងលក្ខណៈនិងកិច្ចការរបស់ព្រះមែស្ស៊ីដែលព្រះបានសន្យា និងការទទួលយកនិងការប្រព្រឹត្តមកលើទ្រង់នៅលើផែនដី បន្ទាប់មក លោកបានបង្ហាញថាទាំងអស់នេះត្រូវបានសម្រេចនៅក្នុងព្រះជន្ម ព្រះរាជកិច្ច និងការសុគតរបស់ព្រះយេស៊ូវពីស្រុកណាសារ៉ែតរួចរាល់ហើយ ។

**<u>ពុធ-១៤ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ២៥**

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ឯខ្ញុំ បើសិនជាខ្ញុំត្រូវលើកពីដីឡើង នោះខ្ញុំនឹងទាញមនុស្សទាំងអស់មកឯខ្ញុំ។ យ៉ូហាន ១២:៣២*

លោកប៉ុលបានបង្ហាញថា ព្រះគ្រិស្តបានយាងមកដើម្បីនឹងផ្តល់សេចក្តីសង្គ្រោះជាមុនដំបូងបង្អស់ ដល់សាសន៍ដែលកំពុងរង់ចាំការយាងមករបស់ព្រះមែស្ស៊ី ជាការបំពេញឲ្យបានបរិបូរ និងជាសិរីល្អដល់ជីវិតនៃសាសន៍របស់ពួកគេ។ ប៉ុន្តែ សាសន៍នោះបានបដិសេធទ្រង់ ជាព្រះដែលបានប្រទានជីវិតដល់ពួកគេ ហើយបានជ្រើសយកអ្នកដឹកនាំមួយផ្សេង ដែលរាជរបស់អ្នកនោះនឹងត្រូវបញ្ចប់ដោយសេចក្តីស្លាប់។ លោកបានខិតខំធ្វើឲ្យអ្នកស្តាប់របស់លោកនឹកឃើញថាមានតែការកែប្រែចិត្តមួយមុខប៉ុណ្ណោះ ដែលអាចជួយសង្គ្រោះសាសន៍យូដាឲ្យរួចពីសេចក្តីវិនាសដែលកំពុងគំរាមកំហែង។ លោកបានបង្ហាញដល់ភាពល្ងិតល្ងង់របស់ពួកគេទាក់ទងនឹងអត្ថន័យនៃព្រះគម្ពីរ ដែលពួកមេដឹកនាំរបស់ពួកគេបានអួតអាងថាពួកគេបានយល់យ៉ាងច្បាស់នោះ ។ លោកបានស្តីបន្ទោសដល់ភាពជាលោកិយរបស់ពួកគេ ការស្រឡាញ់ តួនាទី មុខតំណែង និងភាពសំញែង និងភាពអាត្មានិយមជ្រុលហួសហេតុរបស់ពួកគេ ។

លោកប៉ុលបានរៀបរាប់អំពីរឿងរ៉ាវនៃការផ្លាស់ប្តូរជំនឿដ៏អស្ចារ្យរបស់លោក និងពីទំនុកចិត្តរបស់លោកទៅលើគម្ពីរសញ្ញាចាស់ ដែលបានសម្រេចយ៉ាងត្រឹមត្រូវនៅក្នុងព្រះយេស៊ូវពីស្រុកណាសារ៉ែត។ លោកបានមានប្រសាសន៍ដោយភាពស្មោះត្រង់ដ៏អស្ចារ្យ ហើយពួកអ្នកស្តាប់របស់លោក

អាចមើលឃើញថា លោកបានស្រឡាញ់ដល់ព្រះអង្គសង្គ្រោះដែលគេបានឆ្កាងនិងបានមានព្រះជន្មរស់ឡើងវិញ យ៉ាងអស់ពីចិត្ត។ លោកបានបង្ហាញថាចិត្តរបស់លោកមានមូលដ្ឋាននៅក្នុងព្រះគ្រិស្ត ដែលជីវិតរបស់លោកទាំងមូលត្រូវបានចងភ្ជាប់ជាមួយនឹងព្រះអម្ចាស់។ សម្ដីរបស់លោកធ្វើឲ្យមានចំណាប់អារម្មណ៍យ៉ាងខ្លាំង ដែលមានតែអ្នកដែលប្រឆាំងនឹងសាសនារបស់គ្រិស្តបរិស័ទដ៏ជូរចត់ប៉ុណ្ណោះ ដែលអាចឈរមិនកម្រើកដោយសារពាក្យសម្ដីទាំងនោះ ។

ប៉ុន្តែ សាសន៍យូដានៅទីក្រុងកូរិនថូសបានបិទភ្នែក មើលមិនឃើញភ័ស្តុតាងយ៉ាងច្បាស់ដែលសាវ័កប៉ុលបានបង្ហាញនោះទេ ហើយបានបដិសេធមិនស្តាប់ការអំពាវនាវរបស់លោកឡើយ។ វិញ្ញាណដដែល ដែលបានដឹកនាំពួកគេឲ្យបដិសេធព្រះគ្រិស្តនោះ បានបំពេញចិត្តពួកគេនូវកំហឹងនិងសេចក្តីក្រេវក្រោធទាស់នឹងអ្នកបម្រើរបស់ទ្រង់ ហើយប្រសិនបើព្រះមិនបានការពារលោកជាពិសេស សម្រាប់បន្តផ្សាយសារនៃដំណឹងល្អដល់សាន៍ដទៃទេ ម្ល៉េះសមពួកគេបានបញ្ចប់ជីវិតរបស់លោកបាត់ទៅហើយ ។

«តែដោយព្រោះគេតាំងខ្លួនទាស់ទទឹង ហើយក៏ជេរប្រមាថផង បានជាប៉ុលរលាស់អាវខ្លួន និយាយថា ចូរឲ្យឈាមអ្នករាល់គ្នាធ្លាក់លើក្បាលអ្នករាល់គ្នាវិញចុះ ឯខ្ញុំៗ បរិសុទ្ធទេ អំណឹះទៅមុខ ខ្ញុំនឹងទៅឯសាសន៍ដទៃហើយ គាត់ក៏ចេញពីទីនោះចូលទៅក្នុងផ្ទះម្នាក់ ឈ្មោះយូស្ទុស ជាអ្នកថ្វាយបង្គំព្រះ ដែលមានផ្ទះនៅជាប់នឹងសាលាប្រជុំ»។

លោកស៊ីឡាសនិងធីម៉ូថេ «បានមកពីទីក្រុងម៉ាសេដូន» ដើម្បីមកជួយដល់លោកប៉ុល ហើយពួកលោកបានធ្វើការបម្រើដល់សាសន៍ដទៃទាំងអស់គ្នា។ លោកប៉ុលនិងគូកនរបស់លោកបានអធិប្បាយអំពីព្រះគ្រិស្តជាព្រះអង្គសង្គ្រោះដល់មនុស្សដែលមានបាប ប្រាប់ដល់សាសន៍ដទៃព្រមទាំងសាសន៍យូដាផងដែរ។ ដោយចៀសវាងការគិតគូររកហេតុផលដែលស្មុគស្មាញពិបាកយល់ ពួកអ្នកនាំសារនៃឈើឆ្កាងបាននិយាយអំពីលក្ខណៈរបស់ព្រះអាទិករនៃពិភពលោក ព្រះដែលជាកំពូលអ្នកដឹកនាំនៃចក្រវាល។ ចិត្តរបស់

ពួកគេបញ្ចេញពន្លឺសន្ធោសន្ធៅពីសេចក្តីស្រឡាញ់របស់ព្រះ និងព្រះរាជបុត្រា នៃទ្រង់ ពួកគេបានអំពាវនាវដល់សាសន៍នានាដែលមិនជឿព្រះ ឲ្យមើលឃើញ ការលះបង់ដ៏ធំគ្មានព្រំដែន ដែលព្រះបានធ្វើជំនួសមនុស្សលោក។ ពួកលោក បានដឹងថា ប្រសិនបើអ្នកដែលបានបិតនៅក្នុងភាពងងឹតនៃសាសន៍ដទៃជា យូរមកហើយអាចមើលឃើញពន្លឺដែលចែងចាំងចេញពីឈើឆ្កាងនៅកាល់ វ៉ារី នោះពួកគេនឹងត្រូវបានទាញទៅឯព្រះដ៏ប្រោសលោះជាក់ជាមិនខាន ។ ព្រះអង្គសង្គ្រោះបានមានបន្ទូលថា «ឯខ្ញុំ បើសិនជាខ្ញុំត្រូវលើកពីដីឡើង នោះខ្ញុំនឹងទាញមនុស្សទាំងអស់មកឯខ្ញុំ» (យ៉ូហាន ១២:៣២) ។

អ្នកបម្រើដំណឹងល្អនៅទីក្រុងកូរិនថូសបានដឹងពីគ្រោះថ្នាក់យ៉ាង ធ្ងន់ធ្ងរ ដែលកំពុងគំរាមកំហែងដល់ចិត្តរបស់មនុស្សដែលពួកគេកំពុងធ្វើការ បម្រើ ហើយដោយបានដឹងពីទំនួលខុសត្រូវដែលបានធ្លាក់មកលើពួកគេ ដោយពួកគេបង្ហាញសេចក្តីពិតដែលមាននៅក្នុងព្រះយេស៊ូវ។ សាររបស់ ពួកគេច្បាស់ៗ ចំៗ និងពិតប្រាកដ ជាសារនៃរសជាតិដែលនាំឲ្យបានជីវិត ឬសេចក្តីស្លាប់ដល់មនុស្សជាច្រើន ។ ហើយពួកគេមិនត្រឹមតែបង្ហាញដំណឹង ល្អតាមរយៈពាក្យសម្តីប៉ុណ្ណោះទេ ប៉ុន្តែ ដោយជីវិតរស់នៅប្រចាំថ្ងៃរបស់ពួក គេថែមទៀតផង ។ ពួកទេវតាបានរួមសហការជាមួយនឹងពួកគេ ហើយ ព្រះគុណនិងព្រះចេស្តារបស់ព្រះត្រូវបានបង្ហាញនៅក្នុងការផ្លាស់ប្តូរជំនឿ របស់មនុស្សជាច្រើន។ «ឯគ្រីសប៉ុស ជាមេសាលាប្រជុំ គាត់ជឿដល់ ព្រះអម្ចាស់ ព្រមទាំងពួកគ្រួ (សារ) គាត់ទាំងអស់ដែរក៏មានពួកក្រុង កូរិនថូសបានស្តាប់ ហើយជឿជាច្រើន ទាំងទទួលបុណ្យជ្រមុជទឹកផង» ។

ឥឡូវនេះ សម្ពប់ដែលពួកយូដាតែងតែមានមកលើពួកសាវ័កបានពុះ ពោរកាន់តែខ្លាំងឡើង។ ការផ្លាស់ប្តូរជំនឿនិងការទទួលបុណ្យជ្រមុជទឹក របស់លោកគ្រីសប៉ុស បានជះឥទ្ធិពលទៅលើកំហឹងដែលកំពុងតែឆេះឆួល គឺមិនបានបំផ្លាស់បំប្រែពួកអ្នកប្រឆាំងក្បាលរឹងទាំងនោះទេ។ ពួកគេមិន អាចនាំមកនូវការជជែកវែកញែកដើម្បីបញ្ជាក់ឲ្យឃើញថាការអធិប្បាយ របស់លោកប៉ុលខុសនោះទេ ហើយដោយមិនមានភស្តុតាងគ្រប់គ្រាន់ដូច្នេះ

ពួកគេក៏បានប្រើប្រាស់ការបោកបញ្ឆោតនិងការវាយប្រហារដោយការមួលបង្កាច់។ ពួកគេបានប្រមាថដល់ដំណឹងល្អ និងដល់ព្រះនាមរបស់ព្រះយេស៊ូវ។ នៅក្នុងកំហឹងដ៏ជូរចត់របស់ពួកគេ ពួកគេបានប្រើសុទ្ធតែពាក្យពេចន៍ដ៏សែនល្វីងជូរចត់ ឧបាយកលដ៏មហាថោកទាប ។ ពួកគេមិនអាចប្រកែកមិនទទួលស្គាល់ថាព្រះគ្រិស្តបានធ្វើការអស្ចារ្យទេ ប៉ុន្តែ ពួកគេបានអះអាងថាព្រះអង្គបានធ្វើការនោះដោយសារអំណាចរបស់អារក្សទេ ហើយពួកគេក៏បានអះអាងដោយក្លាហានផងដែរថាការអស្ចារ្យដែលលោកប៉ុលបានធ្វើនោះក៏បានសម្រេចដោយសារតែភ្នាក់ងារដដែល (អារក្ស) នោះដែរ ។

<u>ព្រហស្បតិ៍-១៥ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ២៦

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ហើយយើងក៏និយាយពីសេចក្តីទាំងនោះឯង មិនមែនដោយពាក្យសំដី ដែលប្រាជ្ញាមនុស្សបានបង្រៀនទេ គឺដោយពាក្យសំដីដែលព្រះវិញ្ញាណបង្រៀនវិញ ព្រមទាំងផ្ទឹមពន្យល់សេចក្តីខាងវិញ្ញាណដោយសារសេចក្តីខាងវិញ្ញាណផង។ កូរិនថូសទី១ ២:១៣*

ទោះបីជាលោកប៉ុលមានជោគជ័យយ៉ាងធំធេងនៅទីក្រុងកូរិនថូសក៏ដោយ ក៏ពួកមនុស្សដែលបានឃើញនិងបានឮនៅក្នុងទីក្រុងដ៏អាក្រក់នេះសឹងតែធុញទ្រាន់នឹងលោកដែរ ភាពគ្មានគុណធម៌ដែលលោកបានឃើញក្នុងចំណោមសាសន៍យូដា ព្រមទាំងការមើលងាយនិងការប្រមាថដែលលោកបានទទួលពីពួកគេ បានបណ្តាលឲ្យលោកមានសេចក្តីវេទនាយ៉ាងធំ។ លោកមានមន្ទិលសង្ស័យអំពីប្រាជ្ញានៃការខំប្រឹងប្រែងស្ថាបនាពួកជំនុំចេញពីសម្ភារៈដែលលោកបានរកឃើញនៅទីនោះ ។

កាលលោកបម្រុងនឹងចាកចេញពីទីក្រុងនោះ ដើម្បីបំពេញកិច្ចការនៅកន្លែងផ្សេងទៀតតាមសេចក្តីសន្យា និងស្វែងយល់យ៉ាងស្មោះអស់ពីចិត្តនូវភារកិច្ចរបស់លោក ព្រះជាម្ចាស់បានលេចមកឲ្យលោកឃើញនៅក្នុងការជាក់ស្តែងមួយ ហើយបានមានបន្ទូលថា «កុំខ្លាចអ្វី ចូរសម្តែងទៅ កុំនៅស្ងៀមឡើយ ដ្បិតខ្ញុំនៅជាមួយនឹងអ្នកហើយ គ្មានអ្នកណានឹងប្រទូស្តដល់អ្នកបាន

ទេ ខ្ញុំក៏មានមនុស្សជាច្រើននៅក្នុងទីក្រុងនេះដែរ» ។ លោកប៉ុលបានយល់ថាព្រះបន្ទូលនេះគឺជាការត្រាស់បង្គាប់ឲ្យលោកបន្តនៅក្នុងទីក្រុងកូរិនថូស និងជាការធានារ៉ាប់រងថាព្រះជាម្ចាស់នឹងធ្វើឲ្យគ្រាប់ពូជដែលលោកបានសាបព្រោះបានរីកចម្រើនឡើង ។ លោកបានបន្តធ្វើការនៅទីនោះដោយមានកម្លាំងនិងសេចក្តីក្លាហានជាមួយនឹងទឹកចិត្តពុះកញ្ជ្រោលនិងការតស៊ូស្វិតស្វាញ ។

ការខំប្រឹងប្រែងរបស់ពួកសាវ័កមិនត្រូវបានបង្ខាំងទុកឲ្យនៅត្រឹមតែការនិយាយជាសាធារណៈប៉ុណ្ណោះទេ មានមនុស្សជាច្រើនដែល មិនបានឮដោយសារវិធីនេះ ។ លោកបានចំណាយពេលធ្វើការពីផ្ទះមួយទៅផ្ទះមួយ ធ្វើដូច្នេះ ធ្វើឲ្យលោកអាចប្រស្រ័យទាក់ទងបានយ៉ាងជិតស្និទ្ធជាមួយនឹងរង្វង់ក្រុមគ្រួសារ ។ លោកបានទៅសួរសុខទុក្ខអ្នកមានជំងឺនិងអ្នកមានទុក្ខព្រួយ កម្សាន្តចិត្តអ្នកមានវិបត្តិ និងលើកអ្នកដែលត្រូវគេជិះជាន់ឡើង។ ហើយនៅគ្រប់ទាំងពាក្យសម្តីដែលលោកបាននិយាយ និងសកម្មភាពដែលលោកបានធ្វើ លោកបានបង្ហាញពីព្រះនាមរបស់ព្រះយេស៊ូវ។ ដូច្នេះ លោកបានធ្វើការ «ជាមួយនឹងអ្នករាល់គ្នា ទាំងមានសេចក្តីកម្សោយភិតភ័យ ហើយញាប់ញ័រជាច្រើនដែរ» (កូរិនថូសទី១ ២:៣)។ លោកបារម្ភក្រែងពួកគេយកចិត្តទុកដាក់លើការបង្រៀនរបស់មនុស្ស ខ្លាំងជាងការបង្រៀនរបស់ព្រះ។

បន្ទាប់មក លោកប៉ុលបានមានប្រសាសន៍ថា «ប៉ុន្តែ នៅក្នុងចំណោមមនុស្សគ្រប់លក្ខណ៍ នោះយើងខ្ញុំក៏និយាយតាមប្រាជ្ញាដែរតែមិនមែនតាមប្រាជ្ញារបស់លោកិយនេះ ឬរបស់ពួកចៅហ្វាយនៅលោកិយនេះ ដែលត្រូវសាបសូន្យនោះទេ គឺនិយាយតាមតែប្រាជ្ញានៃព្រះវិញ ជាសេចក្តីអាថ៌កំបាំងដ៏លាក់ទុក ដែលព្រះបានគិតគូរ តាំងពីមុនអស់ទាំងកល្បសម្រាប់ជាសិរីល្អដល់យើងរាល់គ្នា គ្មានចៅហ្វាយណា ក្នុងលោកិយនេះបានស្គាល់សេចក្តីអាថ៌កំបាំងនោះឡើយ បើបានស្គាល់ នោះគេមិនបានឆ្កាងព្រះអម្ចាស់ដ៏មានសិរីទេដូចមានសេចក្តីចែងទុកមកថា សេចក្តីដែលភ្នែកមិនដែលឃើញ ត្រចៀកមិនដែលឮ ហើយចិត្តនឹកមិនដែលដល់ គឺសេចក្តីនោះឯងដែលព្រះ

បានរៀបចំទុក សម្រាប់ពួកអ្នកដែលស្រឡាញ់ទ្រង់»  ព្រះទ្រង់បានសម្តែង ឲ្យយើងរាល់គ្នាឃើញសេចក្តីទាំងនោះ ដោយសារព្រះវិញ្ញាណទ្រង់ ដ្បិត ព្រះវិញ្ញាណនៃទ្រង់ស្ទង់មើលគ្រប់ទាំងអស់ ព្រមទាំងសេចក្តីជ្រាលជ្រៅនៃ ព្រះដែរ ដ្បិតបើមិនមែនជាវិញ្ញាណ ដែលនៅក្នុងខ្លួនមនុស្សទេ នោះតើមាន អ្វីនឹងស្គាល់សណ្ឋានមនុស្សនោះបាន ហើយបើមិនមែនជាព្រះវិញ្ញាណ នៃព្រះ នោះក៏គ្មានអ្នកណាស្គាល់សណ្ឋានព្រះបានដែរ ។

«ឯយើងរាល់គ្នា យើងមិនបានទទួលវិញ្ញាណរបស់លោកិយទេ គឺទទួល វិញ្ញាណដែលមកពីព្រះវិញ ដើម្បីឲ្យបានស្គាល់អស់ទាំងព្រះគុណ ដែល ព្រះបានផ្តល់មកយើង ហើយយើងក៏និយាយពីសេចក្តីទាំងនោះឯង មិនមែនដោយពាក្យសម្តី ដែលប្រាជ្ញាមនុស្សបានបង្រៀនទេ គឺដោយ ពាក្យសម្តី ដែលព្រះវិញ្ញាណបង្រៀនវិញ ព្រមទាំងផ្ទឹមពន្យល់សេចក្តីខាង វិញ្ញាណដោយសារសេចក្តីខាងឯវិញ្ញាណផង» (កូរិនថូសទី១ ២:៦-១៣)។

លោកប៉ុលបានដឹងថា សមត្ថភាពរបស់លោកមិនមែនមាននៅក្នុងជីវិត របស់លោកទេ ប៉ុន្តែ នៅក្នុងព្រះវត្តមាននៃព្រះវិញ្ញាណបរិសុទ្ធវិញ ដែល ឥទ្ធពលដ៏ប្រកបដោយព្រះគុណរបស់ទ្រង់បានបំពេញចិត្តលោក ដោយនាំ គំនិតមនុស្សគ្រប់គ្នាឲ្យចុះចូលជាមួយនឹងព្រះគ្រិស្ត។ លោកបានមាន ប្រសាសន៍ពីខ្លួនលោកថា «យើងខ្ញុំផ្ទុកសេចក្តីសុគតនៃព្រះអម្ចាស់យេស៊ូវ នៅក្នុងរូបកាយយើងខ្ញុំជានិច្ច ដើម្បីឲ្យព្រះជន្មនៃទ្រង់បានសម្តែងមកក្នុង រូបកាយយើងខ្ញុំដែរ» (កូរិនថូសទី២ ៤:១០)។ ព្រះគ្រិស្តគឺជាគំនិតដ៏សំខាន់ នៅក្នុងកាបង្រៀនរបស់ពួកសាវ័ក។ លោកបានមានប្រសាសន៍ថា «ប៉ុន្តែ ខ្ញុំរស់នៅ មិនមែនជាខ្ញុំទៀត គឺជាព្រះគ្រិស្តទ្រង់រស់ក្នុងខ្ញុំវិញ» (កាឡាទី ២:២០)។ លោកបានលាក់ភាពអាត្មានិយមទុក ហើយបានបង្ហាញនិងលើក តម្កើងព្រះគ្រិស្តវិញ។

<u>ព្រហស្បតិ៍-១៦ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ របាក្សត្រទី១ ជំពូក ២៧

**ខព្រះគម្ពីរប្រចាំថ្ងៃ:** *ខ្ញុំបានជាប់ឆ្កាងជាមួយនឹងព្រះគ្រីស្ទ ប៉ុន្តែខ្ញុំរស់នៅ មិន*

*មែនជាខ្ញុំទៀត គឺជាព្រះគ្រីស្ទទ្រង់រស់ក្នុងខ្ញុំវិញ ហើយដែលខ្ញុំរស់ក្នុងសាច់ឈាមឥឡូវនេះ នោះគឺរស់ដោយសេចក្តីជំនឿ ជឿដល់ព្រះរាជបុត្រានៃព្រះដែលទ្រង់ស្រឡាញ់ខ្ញុំ ក៏បានប្រគល់ព្រះអង្គទ្រង់ជំនួសខ្ញុំហើយ។*
*កាឡាទី ២:២០*

លោកប៉ុលគឺជាអ្នកនិយាយដែលប្រកបដោយវោហារសាស្ត្រ។ នៅមុនការផ្លាស់ប្តូរជំនឿរបស់គាត់ លោកតែងតែស្វះស្វែងទាក់ទាញចំណាប់អារម្មណ៍អ្នកស្តាប់របស់លោកដោយការបណ្តែតអារម្មណ៍ទៅតាមវោហារស័ព្ទ។ ប៉ុន្តែ ឥឡូវនេះ លោកបានទុករបៀបនោះចោលមួយអន្លើ ។ ជំនួសឲ្យការបណ្តែតបណ្តោយទៅតាមការពណ៌នាបែបកំណាព្យនិងការបកស្រាយតាមបែបមនោសញ្ចេតនា ដែលបំពេញដល់វិញ្ញាណនិងចម្អែតក្តីស្រមៃ ប៉ុន្តែមិនបានប៉ះពាល់ដល់បទពិសោធន៍ប្រចាំថ្ងៃសោះនោះ លោកប៉ុលបានប្រើភាសាសាមញ្ញ ដើម្បីធ្វើឲ្យអ្នកស្តាប់របស់លោកបានយល់ពីសេចក្តីពិត ដែលមានសារៈសំខាន់ស្មើនឹងអាយុជីវិត។ ការបកស្រាយពីសេចក្តីពិត បែបមនោសញ្ចេតនា អាចបណ្តាលឲ្យមានអារម្មណ៍អណ្តែតអណ្តូង ប៉ុន្តែ សេចក្តីពិតទាំងឡាយដែលត្រូវបានបកស្រាយតាមរបៀបនេះមិនបានផ្តល់ចំណីអាហារជាចាំបាច់ដើម្បីពង្រឹងកម្លាំងនិងការពារពួកអ្នកជឿសម្រាប់សមរភូមិនៃជីវិតទេ។ សេចក្តីត្រូវការជាបន្ទាន់ ការពិបាកៗនៅពេលបច្ចុប្បន្ន ចិត្តខ្វេចខ្វាំទាំងអស់នេះត្រូវតែដោះស្រាយដោយការបង្រៀនត្រឹមត្រូវ និងសាមញ្ញ នៅក្នុងគោលការណ៍គ្រឹះនៃគ្រិស្តសាសនា។

ការខំប្រឹងប្រែងរបស់លោកប៉ុលនៅទីក្រុងកូរិនថូស មិនដែលខកខានមិនបានបង្កើតផលផ្លែទេ។ មនុស្សជាច្រើនបានងាកបែរចេញពីការថ្វាយបង្គំរូបព្រះ មកថ្វាយបង្គំដល់ព្រះដ៏មានព្រះជន្មរស់ ហើយពួកជំនុំដ៏ធំត្រូវបានបង្កើតឡើងនៅក្រោមផ្ទាំងបដារបស់ព្រះគ្រិស្ត។ អ្នកខ្លះត្រូវបានជួយសង្គ្រោះឲ្យរួចពីការបោះបង់យ៉ាងធ្ងន់ធ្ងរបំផុតនៃសាសន៍ដទៃ ហើយបានក្លាយជាស្នាដៃនៃសេចក្តីមេត្តាករុណារបស់ព្រះ និងជាភាពសក្តិសិទ្ធិនៃព្រះលោហិតរបស់ព្រះគ្រិស្តក្នុងការលាងសម្អាតបាប ។

ជោគជ័យដែលចេះតែកើនឡើង ដែលលោកប៉ុលមានក្នុងការបង្ហាញពីព្រះគ្រិស្តបានបំផុសសាសន៍យូដាដែលមិនជឿឲ្យតាំងចិត្តប្រឆាំងកាន់តែខ្លាំងឡើង ។ ពួកគេបានលើកគ្នា «ព្រួតទាស់នឹងប៉ុល គេចាប់នាំគាត់ទៅ ឯទីជំនុំក្ដី» គឺទៅឯលោកកាលីយ៉ូ ដែលធ្វើជាអ្នកតំណាងសាសន៍រ៉ូម នៅស្រុកអាខៃ។ ពួកគេបានរំពឹងថារដ្ឋអំណាចនឹងចូលដៃខាងពួកគេដូចកាលពីលើកមុនៗ ហើយពួកគេបានស្រែកទាស់នឹងសាវ័កប៉ុលដោយសំឡេងខ្លាំងៗថា "អ្នកនេះជាអ្នកបញ្ចុះបញ្ចូលមនុស្ស ឲ្យថ្វាយបង្គំព្រះខុសច្បាប់" ។

សាសនាយូដាត្រូវបានការពារដោយអំណាចទីក្រុងរ៉ូម ហើយពួកអ្នកដែលចោទប្រកាន់ដល់លោកប៉ុលបានគិតថា ប្រសិនបើពួកគេអាចធ្វើឲ្យលោកប៉ុលជាប់ចោទពីបទបំពាននឹងច្បាប់សាសនានោះ ពួកចៅក្រមមុខជាប្រគល់លោកប៉ុលមកក្នុងកណ្ដាប់ដៃពួកគេ ឲ្យជំនុំជម្រះនិងកាត់ទោសជាក់ជាមិនខាន ។ ពួកគេបានសង្ឃឹមថាប្រសិនបើយ៉ាងដូច្នោះមែន ពួកគេនឹងឡោមព័ទ្ធសម្លាប់លោកចោល។ ប៉ុន្តែ លោកកាលីយ៉ូគឺជាមនុស្សដែលមានកេរ្ដិ៍ឈ្មោះ លោកបានបដិសេធមិនព្រមធ្វើជាមនុស្សដែលគេបោកបានដោយងាយៗ ដោយសារការច្រណែននិងល្បិចទុច្ចរិតរបស់សាសន៍យូដានោះទេ។ ដោយការស្អប់ខ្ពើមចំពោះអំពើឆ្គួតលីលានិងសេចក្ដីសុចរិត ផ្ទាល់ខ្លួន របស់ពួកគេ លោកមិនបានចាប់អារម្មណ៍ទៅនឹងការចោទប្រកាន់នោះទេ។ កាលលោកប៉ុលរៀបនឹងនិយាយការពារខ្លួន លោកកាលីយ៉ូបានប្រាប់ថាមិនចាំបាច់ទេ។ រួចលោកបែរទៅនិយាយជាមួយដើមចោទដែលពោរពេញដោយកំហឹងថា៖ «នែ ពួកសាសន៍ យូដាអើយ បើសិនណាជាមានការទុច្ចរិតណា ឬទោសកំណាចអ្វីដទៃ នោះតាមទំនងខ្ញុំត្រូវតែទទួលស្ដាប់អ្នករាល់គ្នា ប៉ុន្តែ បើសិនជាកើតក្ដីពីដំណើរពាក្យសម្ដី ឬពីនាមឈ្មោះ ឬពីក្រឹត្យវិន័យរបស់អ្នករាល់គ្នាវិញ នោះស្រេចនឹងអ្នករាល់គ្នាចុះ ខ្ញុំមិនចូលចិត្តនឹងជំនុំជម្រះចំពោះការយ៉ាងនោះទេ លោកក៏បណ្ដេញគេចេញពីសាលាជំនុំជម្រះទៅ» ។

ទាំងសាសន៍យូដានិងសាសន៍ក្រិកបានរង់ចាំការសម្រេចចិត្តរបស់

លោកកាលីយ៉ូជាអ្នកដែលមិនបានចាប់អារម្មណ៍ទៅនឹងសាធារណៈជនសោះ យ៉ាងអន្ទះសា ហើយលោកក៏បានបំបែកអង្គសាវនាការជាបន្ទាន់ ដែលធ្វើឲ្យសាសន៍យូដាកប់យោបល់ ទ័លគំនិតនិងខឹងសម្បាជាខ្លាំង។ ការសម្រេចចិត្តរបស់អ្នកតំណាងខេត្តរ៉ូមនេះបានបើកភ្នែកមើលហ្វូងមនុស្ស ដែលស្រែកឡូឡាដែលបានចូលរួមគាំទ្រដល់ពួកយូដា។ នេះជាលើកទីមួយ នៅក្នុងការបំពេញភារកិច្ចរបស់លោកប៉ុល នៅអឺរ៉ុប ដែលហ្វូងមនុស្សដ៏ពោរពេញដោយកំហឹងបានចូលរួមជាមួយលោក នៅក្រោមក្រសែភ្នែកនៃអ្នកតំណាងខេត្តរ៉ូម ដោយគ្មានការរំខានពីសំណាក់លោកអភិបាលខេត្ត ពួកគេបានចោមរោមចោទប្រកាន់ដល់ពួកសាវ័ក។ «នោះគេក៏ចាប់សូស្ថេន ជាមេសាលា ប្រជុំ មកវាយផ្ចាលនៅមុខសាលាជំនុំតែលោកកាលីយ៉ូមិនរវល់សោះ»។ ដូច្នេះ គ្រិស្តសាសនាក៏ទទួលបានសញ្ញានៃជ័យជម្នះ ។

«ឯប៉ុល គាត់នៅទីនោះជាយូរថ្ងៃទៀត» ។ ប្រសិនបើសាវ័កប៉ុលបានចាកចេញពីទីក្រុងកូរិនថូស នៅពេលនោះ ពួកអ្នកផ្លាស់ប្តូរជំនឿនៃព្រះយេស៊ូវប្រាកដជាជួបប្រទះនឹងស្ថានភាពដ៏មានគ្រោះថ្នាក់ជាក់ជាមិនខាន។ ពួកសាសន៍យូដាបានខំប្រឹងប្រែងបន្តកេងយកចំណេញជានិច្ច ទោះបីជាត្រូវបំផ្លាញគ្រិស្តសាសនាក៏ដោយ ។